LIBRARY

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ - ប៊ុក -
ក្រុមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសត្ថា - ស្សរ - ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	អត្ថបញ្ជីរឿង	ទំព័រ
លោក ភ័យ-ប៊ុក ក្រមការ	ឱវាទមហាឥន្ទ្រិ(តមក).....	៤៨១
— —	ប្រវត្តិសាស្ត្រខ្មែរស៊ីវិល្ហៃខ្មែរសម័យបុរាណ(តមក)	៤៨៨
ក្រុមដំនុំវប្បធម៌	សព្ទានុក្រមខ្មែរ ញ៉ាក-ថែម រួបរួម (តមក)	៤៩៣
លោកសាង-សាវិត លេខាធិការ	រឿងព្រៃគភូមា (តមក).....	៥០០
អ្នកនាងកញ្ញាវិបុលភាដីសេតា ធូ-ភន	រឿងសាមកុក (តមក).....	៥០៧
— ទេពពិទូរ ឈឹម-ក្រសែម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	៥១៤
ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ	សាវតារវត្តចាយធន ខេត្តឃុំ ឆ្លង-អ៊ូច តែង	៥១៩
លោក ផេង-ស្រីវ សាស្ត្រាចារ្យ	បក្សីទិព្វ រឿងព្រៃនប្រទេសរូម៉ានី	៥២៧
ផ្នែកសាសនា		
លោក ភ័យ - ប៊ុក ក្រមការ	ពន្ធអាស៊ីទ្វីប (តមក)	៥៣៥
ព្រះទេពមុនី យូរ-ប៊ុណ្ណា	ពលកថា	៥៣៦
កំណាត់ទឹងប្រវត្តិការណ៍		
ព្រះទេពសត្ថា ស្សរ - ហាយ	ពិធីបុណ្យស្រែង់ទឹក សម្តេចព្រះមហាសុមេធាធិបតី ជួម - ណាត (ត-ចប់)	៥៤៥
ក្រសួងធម្មការ	បញ្ជីឈ្មោះតាមបៅអធិការដែលតាំងថ្មី (តមក)	៥៥៨

ឆ្នាំទី ២២ — លេខ ៧ ខែកក្កដា ឆ្នាំ ១៩៥១ — ដំឡើងវេ ឆ្នាំ ១៤៥ រៀល

M.814

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Ray-Buc Kramakar (I.B.)	Paroles de GANDHI (suite).....	481
— id —	Histoire: Ancienne civilisation khmère de M. George COEDES (traduction) (suite)	488
Commission Culturelle	Mots traduits par la commission Culturelle et recueillis par M. Nhok-Thèm (suite).....	493
M. Sarg-Savath, Ministère des Finances	Contes birmans (suite).....	500
Neak Okna Vibularaja-séna Nou-Kân	Histoire de SAMKOK (suite).....	507
Neak Okna Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite).....	514
Commission des Mœurs et Coutumes	Notice historique sur la pagode de Banoi (Angkanh-Takéo) par Mékhum Duong-Ouch	519
M. Pheng-Chrieu, Professeur au Collège des jeunes filles	Contes roumains: L'oiseau de paradis.	527

Partie religieuse:

M. Ray-Buc Kramakar	Lumière de l'Asie (suite)	533
Préah Debamuni You-Ponn	Balakatha	536

Notes et chroniques

Brah Debasattha So-Hay	Cérémonie d'aspersion d'eau lustrale de Samdach Préah Moha Sumedhathi-padi Chuon-Nath, Chef de Secte Mohanikay	545
Ministère des Cultes	Nomination des nouveaux Chau-Adhikar (suite)	558

លោក រ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រៃរៀបរៀង

(តមក)

---

៣៦ – មធ្យោបាយដ៏បរិសុទ្ធដើម្បីទំនីរកយុត្តិធម៌ ចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្ត គេមិនត្រូវស្រាវជ្រាវរកបុព្វហេតុនៃរឿងព័រនេះទេ អ្នកដែលបានប្រព្រឹត្តធ្វើឃាតកម្ម ទោះបីជាជាតិសិក្ខ (sikhs) ឬប៉ាថាំង (Pathans) ឬឥណ្ឌូ ជាអ្នកស្នេហាជាតិ ទណ្ឌកម្មដែលធ្វើចំពោះអ្នកទាំងនោះ មិនមែនធ្វើឲ្យបុគ្គលដែលទទួលមរណភាពទៅហើយ មានជីវិតរស់ឡើងវិញបានឡើយ ។ ខ្ញុំចង់សូមអ្នកដែលរងនូវសេចក្តីសោកចំពោះបុគ្គលដែលអនិច្ចកម្មទៅនោះ ឲ្យមានចិត្តសន្តោសត្រាប្រណីដល់អ្នកដែលបានធ្វើមនុស្សឃាត, ធ្វើបែបនេះមិនមែនយល់ថា អ្នកដែលទទួលនូវសេចក្តីសោកជាបុគ្គលទុព្វលភាព (ខ្ញុំដឹងថាអ្នកទាំងនោះមានមធ្យោបាយជាច្រើនស្ថាន ដើម្បីនឹងធ្វើទណ្ឌកម្មដល់អ្នកប្រព្រឹត្តល្មើស) តែដោយហេតុថា ពួលភាពអ្នករងសេចក្តីសោកនោះគ្មានខ្ពស់ព្រំដែនទេ ។ អ្នកណាមួយដឹងខ្លួនដោយខ្លួនឯងថា ខ្លួនមានពួលភាព អ្នកនោះតែងមានចិត្តខន្តីអត់ឧនូវទោសនោះបាន ។

ខ្ញុំជាអ្នកស្នេហាជាតិព្រោះខ្ញុំជាជាតិមនុស្ស ហើយខ្ញុំមានសភាព
នឹងចរិយាបស់មនុស្ស ខ្ញុំមិនបានធ្វើទុក្ខលំបាក ដល់ប្រទេសអង់គ្លេ
ឬប្រទេសអល្លឺម៉ាញ ដោយខ្ញុំបានបំរើប្រទេសឯណោះទេ, លទ្ធិច្រ-
តត្តិនិយមគ្មានសន្ធិតជាប់នៅក្នុងសន្ដានខ្ញុំ តាមយោបល់បស់ខ្ញុំចំពោះ
ជីវភាពលោក, សីលធម៌នៃអ្នកស្នេហាជាតិ (Patriote) - មិនខុសគ្នាពី
សីលធម៌នៃពួកបេតឺ្តយ្យបុគ្គល (patriarche) ។

មនុស្សធម៌ - តម្លៃនៃសភាពស្នេហាជាតិ
(១៦-៣ - ១៩២១)

ក ៣៧ – កុំឲ្យប្រើកំភ្លើងយើងហួសប្រមាណក្នុងការណ៍ដែលគិតពី
បញ្ហាប្រជាជាតិ ព្រមទាំងមធ្យោបាយក្នុងបញ្ហានេះ បុគ្គលអាចជដែល
បរិភោគនូវទុស្សចេ្រនប្រការតែម្តង មុខជាអន្តរាយដល់ជីវិតមិនខាន ។

ប្រភាពនៃសភាពក្រែស
(៣០ - ៣ - ១៩២១)

៣៨ – ប្រជាជាតិត្រូវមានទង់ជ័យជាដួងវិញ្ញាណរបស់ជាតិ, មនុស្ស
ជាច្រើនសែននាក់ចានបូជាជីវិតព្រោះតែទង់ជ័យនេះ; ទង់ជ័យតាំងផ្តើម
ឡើងដោយលទ្ធិតាហិរសាសនាមួយយ៉ាង ដែលយើងមិនត្រូវបំភ្លាញ
ឲ្យសាបសូន្យ, រូបគំនូរសាមគ្គីសាក់ (Union Jack) បើគេបានបង្ហាញឲ្យ
យើញជាក់ស្តែងចំពោះមុខ អាចនាំឲ្យជាតិអង់គ្លេសមានមនោសញ្ចេតនាដ៏
ខ្លាំងក្លាមិនអាចនឹងកំណត់នូវពលភាពបាន, រូបគំនូរ ស្តារូអង់ដ្រូប

(Stars and Stripes) ដែលជាតិអាមេរិកាំងបានយកទៅរចនាជាក់លើទង់ជ័យ ប្រៃថា: "លោកទាំងមូល", តាកន់ឆន្ទដ៏ព្រះចន្ទខាងរនោចនាំឲ្យជាតិអឺស្លាមមានចិត្តក្លាហានពន់ពេក, ពួកជាតិឥណ្ឌូមហាម៉ាត់ក្រៃចឹង ស្ទើហូ ទឹងជាតិឯទៀត ដែលបានយកប្រទេសឥណ្ឌាជាមាតុភូមិយើងត្រូវការឲ្យមានទង់ជ័យមួយជាប្រធានរបស់ជាតិ ដែលយើងត្រូវការបម្រុងខ្លួនរស់ឬស្លាប់ព្រោះទង់ជ័យនេះ ។

ទង់ជ័យប្រជាជាតិ
(១៣-៦-១៩២១)

៣៩– បើទុកជាចេះប្រើវិធីយ៉ាងណាក៏ដោយ វឌ្ឍនធម៌នៃប្រជាជាតិមិនមែនមកពីមនុស្សម្នាក់ឯទេ ឬមកពីក្រុមណាមួយៗទេ ។

. . . គេស្គាល់ដើមឈើដោយឃើញផ្លែវា ។

ខេយចុះអ័ព្ទ
(២០-៤-១៩២១)

៤០– ប្រទេសណាមិនអាចទៅជាប្រជាជាតិមួយបាន បើនៅប្រទេសនោះមានតែពួកវិបត្តិយុត្តិបុគ្គល ។

ការសិក្សាអង់គ្លេស
(២៧-៦-២១)

៤១ – សាតាបែកសាមគ្គីជាទោសនាំទៅកាន់សេចក្តីវិនាសជាប្រាកដ ។

សាមគ្គីភាពរវាងជាតិឥណ្ឌៀនិងមហាម៉ាត
(១១-៥-១៩២១)

៤៤— រង៉ែសេចក្តីទុក្ខហើយទុកចិត្តខ្លួនឯង នេះជាគុណសម្បត្តិ
ពិសេសរបស់អាត្មាន ។ ជាតិឥណ្ឌកុំច្រែមាវ
(១៨-៥-៦១)

៤៥— ការពិសោធន៍ បានបង្ហាញឲ្យឃើញថា ការសិក្សា
អក្សរសាស្ត្រ មិនអាចធ្វើឲ្យចំរើនខួរសីលធម៌ សូម្បីបន្តិចបន្តួចក៏គ្មាន
ហើយការអប់រំខួរអក្សរសាស្ត្រ មិនមានហេតុផាត់ខន់ក្នុងការអប់រំខួរ
ចរិយា ។

. . . រដ្ឋាភិបាលដែលនឹងតាំងក្រឹត្យានុភាពបាន ដោយការ
អាស្រ័យប្រជាពលស្តេរួបរួមយល់ព្រមប្រតិបត្តិតាម ។

. . . ពួកយុវនន៍ជាទីសង្ឃឹមរបស់ប្រជាជាតិ ។

. . . ត្រូវតែលះបង់ពាក្យដែលមិនប្រកបដោយសច្ចៈ ទើបជាអ្នក
ទទួលពាក្យសត្យបាន ។

. . . សាសនាកន់លោកសំដែងថា នៅក្នុងខ្លួនយើងមានកំឡាំងពីរ
ហើយសេចក្តីប្រឹងប្រែងរបស់មនុស្ស គឺសម្រេចថាព្រមទទួល ឬ មិន
ព្រមទទួល ខ្ញុំពាក្យប្រៈដៅតាំងទោះ ជាទិន្នន័យកាល ។

. . . ការណ៍ដែលមិនព្រមសមាគមជាមួយនឹងពួកការ ជាវិធីមួយ
ដែលប្រជាជាតិត្រូវប្រើ ដើម្បីឲ្យរដ្ឋាភិបាលដឹងខ្លួនជាមុនថា ប្រជាជាតិ
មិនព្រមសុខចិត្តនៅក្រោមអធិបតេយ្យទៀយ ។ សភាពជារដ្ឋនៃពួកការ
(ខ ៦-១៧៦១)

៤៤ - វត្ថុអ្វីដែលរង្គាត់ចាលស្វែងរកកន្លែងបរិយោសានគាល ដោយប្រែកំឡាំងអាវុធ, វត្ថុនោះត្រូវស្វែងរកដោយប្រែកំឡាំងមេត្តាចិត្ត ។

ឧណាៈកម្មាធិការកម្មកាពន្ធនាគារ
(ខ. ត. ១៩៦០)

៤៥ - ខ្ញុំបានបង្ហាញឲ្យឃើញថា គេអាចស្អប់ខ្ពើមអំពើទុច្ចរិតដែលបងប្អូនណាមួយប្រព្រឹត្ត តែគេមិនអាចនឹងស្អប់ខ្ពើមបុគ្គល ដែលប្រព្រឹត្តទុច្ចរិតនោះឡើយ ។

. . . ខ្ញុំបានរកឃើញថា មនុស្សមានគុណធម៌ខ្ពង់ខ្ពស់ ប្រសើរជាងវិធីដែលខ្លួនបានរៀបចំអង្គការ ។

. . . អ្នកឯងនឹងយល់ជាខាសានៃវិធីការដែលធ្វើ ។

ចំពោះជាតិអង់គ្លេសនៅប្រទេសឥណ្ឌា
(១៣ - ធ ១៩២១)

៤៦ - យើងមានវត្ថុពីរបែបដែលជាប្រធានកន្លែងចិត្តគ្រប់រូប គឺសេចក្តីស្នេហាចំពោះមាតុភូមិ និងសេចក្តីព្យាយាមដោយមិនគិតនឿយហត់ដើម្បីនឹងឲ្យបានស្វ័យភាព ។

អបលឧសត្ថ
(១៦ - ធ. ១៩២១)

៤៧ - ត្រូវតែនារីមានសិទ្ធិបោះឆ្នោត, គួរតែរក្សាសមភាពចំពោះសិទ្ធិនារីនឹងបុរស ។

. . . ច្បាប់លទ្ធិអិស្លាមប្រកាសប្រគល់ឲ្យនារីមានសិទ្ធិស្មើគ្នានឹងបុរស ។

... ត្រូវតែនាំកុំយល់ថាខ្ញុំគ្រាន់តែជាវត្ថុសម្រាប់ឲ្យបុរសត្រេក
ត្រអាលតំណាងខ្លួនប៉ុណ្ណោះ ។

សិទ្ធិនៃនារី
(១៩-៣-១៧២១)

៤៨- បើតាមយោបល់ខ្ញុំថា ក្រៅពីសម្ពន្ធកិច្ចនៃការសិក្សាចំពោះ
វដ្ឋកិច្ចលុច្ចតែចេញ នៅមានវិធីសិក្សាក្នុងសម័យបច្ចុប្បន្នជា
សកាពលាមកមួយ ដោយវិចារណញ្ញាណ ៣ យ៉ាង គឺ:

១- វិធីសិក្សានេះ ពឹងផ្អែកលើវប្បធម៌ របស់បរជាតិជា
គោល ដោយការលុបចោលស្ទើរតែទាំងអស់នូវវប្បធម៌នៃជាតិរបស់ខ្លួន ។

២- វិធីសិក្សានេះ លះបង់ចោលនូវវប្បធម៌ខាងផ្លូវចិត្ត
ហើយនឹងវប្បធម៌ខាងហត្ថកម្ម ច្រើនអប់រំចំពោះវប្បធម៌ខាងផ្លូវជាជ្ញា ។

៣- មិនត្រូវយល់ថា ការសិក្សាច្រកដូនោះព្រោះអប់រំប្រើភាសា
ជនបរទេសទេ ។

បើខ្ញុំធ្វើគ្រូ ខ្ញុំនឹងបំភ្លាញនូវសៀវភៅតម្រាក្សុន្ទាតគម្ពីរដែលក្មេងរៀន
សូត្រសព្វថ្ងៃនេះចេញ ហើយខ្ញុំចាត់វិធីអក្ខរកាវតែងសៀវភៅបែបថ្មី គឺ:
សរសេរអំពីរឿងដ៏គោរពនៃត្រកូល ឬត្រួសារ នឹងការចាក់ចងក្នុងត្រួសារ
នេះ. ដើម្បីនឹងបង្ហាញឲ្យក្មេងរៀន ត្រមាំងអប់រំចិត្តគំនិតអង្គាស្រ័យ
ទៅតាមមជ្ឈដ្ឋានដែលខ្លួនទៅ ។

... ពួកយុវនៃត្រូវទទួលការសិក្សាណាដែលមានការអប់រំហត្ថកម្ម ជាប្រធាន ។

... មិនមានវត្ថុអ្វីដែលនាំឲ្យខូចសីលធម៌ប្រជាជាតិដូចការប្រមាទនូវការហត្ថកម្មឡើយ ។

... ចំណេះចេញពីបណ្ឌិតសភា តែមិនបានយកមកអប់រំខាងវិធីប្រតិបត្តិ ប្រៀបដូចសាកសពដែលគេអប់ដោយគ្រឿងក្រអូប គួរជាទីទស្សនីយភាពពន់ពេក តែមិនអាចរចនាអ្នកដែលមើលឲ្យមានគំនិតថ្លៃថ្នូមានចិត្តប្រែឡើងទៅកាន់អរិយធម៌ឯាន, លទ្ធិរបស់ខ្ញុំ ហាមខ្ញុំ កុំឲ្យបន្ទោកប្អូមើលងាយវប្បធម៌អ្នកដទៃ តែបង្ខំខ្ញុំឲ្យប្រតិបត្តិតាមវប្បធម៌ដែលខ្ញុំបានអប់រំមក ឲ្យធ្វើវប្បធម៌នោះជាកល្យាណមិត្ត មានជួងវិញ្ញាណតែមួយឯកឯង, បើខ្ញុំមិនប្រព្រឹត្តតាមសភាពនេះទេ គេនឹងទុកខ្ញុំជានាយពេជ្ឈឃាតនៃពួកពាល់ដ្ឋស៊ីវិល ។

ការសិក្សាប្រជាជាតិ
(១-៩-១៩៤១)

(មាន៣)

កុំបាប់នេះបាប់នោះមិនឆ្ពោះត្រង់ណា,
បើធ្វើអ្វីគប្បីធ្វើឲ្យហើយទើបមានសួស្តី

ប្រវត្តិសាស្ត្រនៃស៊ីវិលីយ៉ាសុខមុកណា

លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(តទៅ)

ក្រសួងក្រមពាដការសំខាន់ៗ ចែនប្រគល់ឲ្យពួកវណ្ណព្រាហ្មណ៍, តំណែងទាំងប៉ុន្មាន គឺក្រមសង្ឃការពីសេសផ្ទាល់ព្រះអង្គ (Chapelain du Roi) ១ ព្រាហ្មណ៍ដែលសូត្រធម៌ថ្វាយព្រះពាដសព្វសាធុការពរដល់ព្រះវិញ្ញាណមហាក្សត្រដែលប្រតិស្ឋានរូបជាព្រះមួយ (Officiant du Dieu Roi) ១ សាស្ត្រាចារ្យព្រះពាដភាយាទ (Précepteur) ១ ត្រូវទុកឲ្យពួកវណ្ណក្សត្រកូលដ៏ខ្ពង់ខ្ពស់តទៅ ។ មុខងារទាំងនេះ ត្រូវផ្ទេរទៅតាមក្រសែទាងស្ត្រី, ប្អូនទៅខាងបងស្រី ឬបុត្រនៃបងស្រីខ្លួនមុខងារទាំងនេះ តអំពីបងប្រុសឬងឬឪពុកមា ។ ត្រកូលព្រាហ្មណ៍អាចធ្វើសមរសជានជាមួយនឹងត្រកូលក្សត្រ, សមរសបែបនេះមានចែន ព្រោះវណ្ណៈក្សត្រនឹងវណ្ណៈព្រាហ្មណ៍ទាំងពីរនេះជាវណ្ណៈខ្ពង់ខ្ពស់ជាងគេបង្អស់ហើយមានឋានៈត្រៀវដោយវែកវែក ដែលគេខុកជាក្រម ១ ហៅថា ក្រមបណ្ឌិត ចំពោះស៊ីវិលីយ៉ាហិណ្ឌូទាំងមូល; តែកិច្ចការរៀបចំរបៀបវណ្ណៈនេះចំពោះបណ្តាជាតិ ទៅជាសភាពអនាធិបតេយ្យដែលមានលក្ខណៈផ្សេងពីប្រជាពស្តង់ខ្មែរ ។ យើងបានឃើញជាញឹកញាយនូវឈ្មោះទាងក្សត្រក្រុមព្រះពាដវង្សានុវង្ស និងក្រុមព្រះសង្ឃ ។

តាមសិលាចារឹកបង្ហាញឲ្យឃើញថា មានពួកត្រកូលពួកមន្ត្រីជាច្រើន ។ យើងអាចយល់ថាកន្លះពេលនោះព្រះពជរដ្ឋាភិបាល បានរៀបចំមាំមួនខ្លួនវដ្ដមន្ត្រី, មេទ័ព, ទីប្រឹក្សា, អធិការ, ចៅហ្វាយខេត្ត, - ស្រុក - ភូមិ, ប្រជាពលស្ត្រ, នាយឃ្លាំងផ្សេង ។, នាយបាត់ការខាងពួកគូលីធ្វើការថ្ម, នឹងមន្ត្រីឯទៀតជាច្រើនដែលមានហានន្តរស័ក្តិមិនសូវច្បាស់លាស់ ហើយព្រមទាំងជាប្អូនថ្នាក់ដែលមានលក្ខណៈមិនច្បាស់ ។ បើដោយស្មាន, ប្រហែលត្រូវគ្នានឹងព្រះពជវង្សានុវង្សប្អូនយ៉ាងនៃប្រទេសកម្ពុជាចំនើប គឺ: ព្រះមហាក្សត្រិយ៍ ១ ព្រះពជមាយាទ ១ ព្រះពជមាយាទបន្ទាប់តមក ១ នឹងព្រះអគ្គមហេសី ១ ។

មន្ត្រីទាំងអស់នោះត្រូវនៅក្រោមព្រះបញ្ជាព្រះមហាក្សត្រិយ៍ដោយធ្វើសច្ចប្រណិធាន ដូចមាននៅប្រទេសកម្ពុជានឹងសារ ដែលមានពិធីធ្វើសច្ចប្រណិធាន ជាព្រះពជពិធីមួយធំសព្វថ្ងៃ ។ សិលាចារឹកដែលបានឆ្លាក់នៅជ្រុងនៃព្រះបរមពជវាំងអង្គរធំ មានគោលទំអំពីរឿងពិធីធ្វើសច្ចប្រណិធាន ដែលលោកអធិការក្រុមព្រះបរមពជវាំងទាំងប្អូនថ្នាក់បានថ្លែងពី ព. ស. ១០១១ ដូចមានខសំខាន់ៗខាងក្រោម:

"យើងមិនបានសរសើរព្រះពជកិត្តិយសព្រះមហាក្សត្រិយ៍ណាក្រៅពីព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូងរបស់យើង, យើងមិនទទឹងទាស់នឹងព្រះពជបំណងហើយយើងមិនបានចូលដៃនឹងពួកបច្ចាមិត្តរបស់ព្រះ

អង្គ, យើងមិនបានប្រព្រឹត្តខ្ញុំអំពើដែលនាំឲ្យវិនាសដល់ព្រះអង្គ យើងខ្ញុំព្យាយាមប្រព្រឹត្តខ្ញុំអំពើដែលមានផលនៃអកិរិយាខ្ជិនខ្ជឹលតបវិញចំពោះព្រះករុណា; បើមានសង្គ្រាម យើងខ្ញុំព្យាយាមចូលតស៊ូដោយពលភាពរបស់ចិត្ត ព្រមទាំងមិនគិតដល់ជីវិតសោះឡើយ; ដោយអកិរិយាខ្ជិនខ្ជឹលចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង, យើងខ្ញុំមិនរត់ចេញឲ្យឆ្ងាយពីទីសមរភូមិ, បើមិនមានចម្បាំងទេ, យើងខ្ញុំស៊ូស្លាប់ដោយសារធ្វើយាតកម្មខ្លួនឯងឬដោយមរណភាព; យើងខ្ញុំសូមឲ្យបានឆ្កាន់ឬកិត្តិយសចំពោះបុគ្គលដែលមានចិត្តត្រង់ទឹងចៅហ្វាយនាយ; យើងខ្ញុំធ្វើការថ្វាយព្រះមហាក្សត្រិយ៍ទាល់តែខ្លួនមរណភាព បើសិនណាជាត្រូវស្លាប់កង់ពេលដែលធ្វើការនោះ យើងខ្ញុំបំពេញកណ្តាលកិច្ចចំពោះព្រះមហាក្សត្រិយ៍ឥតមានរួញរាសោះឡើយ; បើមានកិច្ចការអ្វីដែលព្រះករុណាចាត់យើងខ្ញុំឲ្យធ្វើដោយមានព្រឹត្តិការ ដែលព្រះអង្គបានជ្រាបជាមុន, យើងត្រូវខំប្រឹងប្រែងរកឬធ្វើនោះដោយពិស្តារ ។ បើបណ្តាយើងខ្ញុំទាំងអស់គ្នា មានអ្នកណាមិនព្រមធ្វើតាមសច្ចប្រណិធាននោះ យើងសូមឲ្យព្រះមហាក្សត្រិយ៍ដែលសោយរាជ្យសម្បត្តិតទៅអនាគតធ្វើព្រះរាជទណ្ឌកម្មដល់អ្នកនោះ បើមានអ្នកណាក្បត់ព្រះអង្គមិនព្រមធ្វើតាមពាក្យសច្ចាប្រណិធាន សូមឲ្យអ្នកនោះទៅរងទុក្ខលំបាកវេទនាទៅមហានគរភាំងសាមសិបពាន់ ឲ្យបានយូរអង្វែងស្មើនឹងសេចក្តីស្ថិតនៅនៃព្រះអាទិត្យទឹងព្រះចន្ទ; បើបានប្រតិបត្តិតាមពាក្យសច្ចា

ប្រណិធាន សូមឲ្យព្រះមហាក្សត្រិយ៍មានព្រះពជគម្រាស់ថា ដូចនិយ-
ដ្ឋានគ្រប់ទីកន្លែងក្នុងប្រទេស ត្រូវចាត់ឲ្យវង្សត្រកូលយើងមើលថែរាំ
កិត្តិយសនៃបុគ្គលដែលចិត្តត្រង់ ចំពោះព្រះមហាក្សត្រ យើងសូមឲ្យបាន
សម្រេចចាប់ដើមអំពីលោកនេះ រហូតដល់បរលោក ។

ក្នុងសម័យបច្ចុប្បន្ន, ពិធីធ្វើសច្ចាប្រណិធាននៅកំពេញត្រូវបរិភោគ
ទឹកមួយពែង ដែលគេដងពីពាងមួយគ្រាំដោយគ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌ
កងពេលនោះត្រូវផ្តងចិត្តអធិដ្ឋានតាមទំនៀមថា: បើមិនប្រព្រឹត្តទៅតាម
ពាក្យពោលហើយ សូមឲ្យគ្រឿងសស្ត្រាវុធច្រហារ; ដោយយល់
ឃើញថាពលភាពនៃគ្រឿងសស្ត្រាវុធជាបច្ចួលទៅកងហាយវត្ត ។ ក្នុង
សម័យអង្គរ ការធ្វើសច្ចាប្រណិធានជាកិច្ចពិតប្រាកដ គេយកលោហិត
ជាប្រធានរូបមន្តចំពោះសច្ចាប្រណិធានគឺ "នេះជាសេចក្តីអធិដ្ឋាន
ដែលយើងបានពោលក្នុងទុកាស ដែលយើងបានចាក់ដៃឲ្យចេញឈាម
ហើយដែលយើងបូជាជីវិត ចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង",
ខ្មាប់នោះមានធ្លើរឿងរៀបមកដល់សព្វថ្ងៃ ។ នៅប្រទេសកម្ពុជា
ចំពោះពួកចោរលួច, ប្លន់, ការធ្វើសច្ចាប្រណិធាន គឺត្រូវធ្វើសម្ពន្ធភ័ក្តិ
ដោយបរិភោគស្រាមួយពែង ដែលគេបានសម្រក់លោហិតពីសរសៃកដៃ
គឺជាទំនៀមខ្មាប់ដូចគ្នា ដែលគេបានចារឹកពាក្យសច្ចាប្រណិធានទាំង
ព្រះបរមរាជវាំង ។

រូបមន្តនៃពាក្យសច្ចាប្រណិធានមានខាងក្រោមបញ្ជីពយឈ្មោះមន្ត្រី ដែលត្រូវប្រកាសពាក្យនេះចំពោះឈ្មោះនីមួយ ។ មានចុះឈ្មោះកូមិភាគ ។ ជាកន្លងសតវត្សទី ១១ គេមានឃើញបញ្ជីពយនាមកូមិភាគនៅប្រទេសកម្ពុជា ដែលមកដល់ចុងសតវត្ស ១៣, កន្លងពេលដែលមហាឧបរាជ្យបានចាត់គណៈប្រតិភូមក មានដល់ ៩០ ខេត្ត ។ គណៈប្រតិភូនេះ បានកត់ត្រាអំពីរបៀបរដ្ឋាភិបាលកន្លងពេលនោះ ដែលគេហៅថា អភិជនសិទ្ធិជាអនាធិបតេយ្យ (Olifarchie aristocratique) ពួកគណៈប្រតិភូនោះ បានឲ្យដំណឹងថា " ដួនកាលគេជ្រើសតាំងព្រះអង្គម្ចាស់ឲ្យទទួលមុខការងារផ្សេងៗ, ចំពោះមន្ត្រីធំ - តូច បើចង់បានការអ្វីត្រូវយកកូនស្រីទៅថ្វាយព្រះមហាក្សត្រិយ៍ " ។ រូបមន្តបែបនេះគេបានយកមកអនុវត្តន៍នៅប្រទេសកម្ពុជា នឹងប្រទេសសៀមជាដើមសតវត្សនេះ ។ តាមដំណឹងចំនេះថាបានកត់ត្រាពីគ្រឿងឥស្សរិយយស នៃនាហ្លួនសព្វមុខមន្ត្រី គឺអង្រឹងមានឈើសែង មាសប្លុកថ្កាក់, សប្បធនមានដៃលនដោយមាស ប្លុកថ្កាក់ តាមឋានន្តរស័ក្តិប្លុមុខងារ ។

(មានត)

មិនអាចរកសេចក្តីសុខឃើញទេ
បើគ្មានវិជ្ជា ចូរមើលសត្វបំរើ!

សព្ទចាក់ផ្តែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

ហ្គ្លង់ឌិពន្ធមន្ត្រី ញ៉ក-បែម រួបរួម

(ភាគ)

Centralisation = មជ្ឈការ

Décentralisation = វិមជ្ឈការ

Le secrétaire archiviste = លេខាធិការការគាន់ឯកសារ

Le Chef du Service des Recettes = នាយក្រុមប្រាក់ចំណូល

Le Chef du Service des Dépenses = នាយក្រុមប្រាក់ចំណាយ

Le Chef du Service des Budgets = នាយក្រុមថវិកា

Confidentiel = អាថ៌កំបាំង

Pour copie conforme = ចំឡងត្រឹមត្រូវហើយ

Pour ampliation = សម្រាប់ចំឡងវិចក

Vu pour attache = បានឃើញដើម្បីខ្ទួលជាំង

En communication = ដើម្បីជាតំណឹងដល់

Marge = រឹមដើម (ខំព័ររសៀវភៅ)

Parité de solde = (ថ្នាក់) ប្រៀវត្ស៍ស្មើគ្នា

Diplôme d'études primaires = សញ្ញាប័ត្របឋមសិក្សា

Brevet Elémentaire = ប្រកាសនីយប័ត្រជាន់ដំបូង

Baccalauréat = មធ្យមសិក្សាប័ត្រ

Licence = បរិញ្ញាប័ត្រ

Agrégation = មហាបរិញ្ញាប័ត្រ

Doctorat = ថ្នាក់បណ្ឌិត្យ

Valider = ជានគារ

Affiliation = ការចូលរួម

Catégorie = ថ្នាក់, ប្រភេទ

Brigadier = អ្នកត្រួតត

Chef de poste = នាយតំបន់

Poste de contrôle = តំបន់ត្រួតត្រា

Chef de contrôle = នាយត្រួតត្រា

Chef de section = នាយផ្នែក

Contrôleur = អ្នកត្រួតត្រា

Receveur = បដិគ្គាហក, អ្នកទទួល

(Le 15 — 3 — 49

Nimbus = ដុលជរ

Cumulus = កំទឹក

Stratus = អន្តលិក្ខ, អន្តរិក្ស (ដើងភ្នាយ)

Cirrus = ពពកស្រែកានាគ

(Le 18 — 3 — 49)

Thermomètre = ខ្ញុំមាត្រ

Degré = កម្រិត

Fiche = សលាកប័ដ

Sens Unique = ឯកទិស

Température = សីតុណ្ហភាព

Travail = ការងារ

(Le 22 — 3 — 49)

Compromis = ការសម្រប

Fête = មហោស្រព, បុណ្យ

Cérémonie = ពិធី

Adjudication = ការដេញថ្លៃ

Appel d'offres = ការដេញថ្លៃ

Fête nationale = បុណ្យជាតិ

Fête royale = ព្រះរាជពិធី

Attributs (de l'indépendance) = វិសេសសម្គាល់ (នៃឯកភាព)

Délégué = ប្រតិភូ

Délégation = គណៈប្រតិភូ,ការបែងអំណាចឲ្យ

Minute = សំណៅ, នាទី

Original = សំណៅដើម, ច្បាប់ដើម

Copie = សេចក្តីចំឡង·

Eventuel = ដែលជា យថាហេតុ, ស្រេចលើ យថាហេតុ

Eventualité = · យថាហេតុ

(Le 20 — 5 — 49)

garantie = ការសំអាង, ការធានា

Réserve = ឋបនីយ៍ (ឋ:—ប៉:—ណី)

Preuve = តឹកតាង, ព័ស្តុតាង, ឯកសារ

Métropôle = Mère-Patrie = មាតុប្រទេស

(Le 24 5 — 49)

Condition = លក្ខខ័ណ្ឌ

Spectacle = ទស្សនីយភាព

Disposition = បទបញ្ញត្តិ

Œuvre de bienfaisance = ការកុសល

Garactère = លក្ខណៈ, ចរិត, ទិស្សុយ

Athlétisme = អត្តពលកម្ម

Culture physique = កាយសិក្សា

Nature = ធម្មជាតិ, ប្រភេទ

Bienfaisance = ការកុសល

Paysage = ទេសភាព

Admirable = បសំសនីយ៍, គួរស្ងើច, គួរកោត

Sport athlétique = គីឡាអត្តពលិក

Athlète = អ្នកអត្តពលកម្ម

(Le 31 — 5 — 49)

Préambule = លំនាំដើម, បុព្វកថា

Introduction = បុព្វយោគ, ពាក្យនាំ

Préface = អារម្ភកថា, ពាក្យប្រារព្ធ

Avant — propos កថាមុខ

Prologue = អារម្ភបទ

Epilogue = អវសានបទ

Livre de lecture = សៀវភៅហាត់អាន

(3 — 6 — 49

Dactylographie = អក្ខរលេខ

Dactylographe = អ្នកអក្ខរលេខ

Candidat libre = បេក្ខជនឯស្ងាន

Communiqué = សេចក្តីថ្លែងការណ៍

– សេចក្តីប្រកាស

Proclamation = ការប្រកាស

(7 – 7 – 49)

Scepticisme = លទ្ធិមជ្ឈនិយម

Sceptique = អ្នកមជ្ឈនិយម

Optimisme = លទ្ធិសុទិដ្ឋិនិយម

Optimiste = អ្នកសុទិដ្ឋិនិយម

Pessimisme = លទ្ធិទុទិដ្ឋិនិយម

Pessimiste = អ្នកទុទិដ្ឋិនិយម

Sténographie = ជវរលេខ

Fermier = មេភាស៊ី

Affermage = ការចងភាស៊ី

Martyr = ទុក្ករបុគ្គល

Auréole = វង់រស្មី

Priorité = អាទិភាព

Gloire = កិត្តិគុណ

Saint = សន្ត:, សន្តបុគ្គល

Sainte = សន្តិ (ប៉ារិសុទ្ធ)

Aspect = ទិដ្ឋភាព

Composition = សមាសភាព

(10 — 6 — 49)

Lier = ព័ន្ធ ព័ន្ធ, បង

Interview = សម្ភាសន៍ (ការសួរនាំឲ្យឆ្លើយ)

O malheur ! = ទុក្ខម្ន៉េះ !

Misère ! = ពិបាកអ្វីម្ល៉ះ !

Douleur ! ទុក្ខអីខ្លាំងម្ល៉ះ !

Nous allons mourir ! ស្លាប់ឥឡូវហើយយើង

Quelle souffrance ! វេទនាអីម្ល៉ះ !

(21 — 6 — 49)

Ressortissant = អាណិកជន (ជនដែលនៅក្រោ
អំណាចច្បាប់)

Révolution = បរិវត្តន៍

Titre d'Identité = អត្តសញ្ញាណប័ណ្ណ

Carte d'Identité = ប័ណ្ណសំគាល់ខ្លួន

(24 — 6 — 49)

Parole = ពាក្យសំដី, វចនាគាស

(មានត)

រឿងព្រៃឥតូមា

លោក សាង-សារ៉ាត លេខានុការក្រសួងកោរញ្ជោវត្តិ

ប្រែតាមសាច្ចាកំឡមកជាខ្មែរ

(តមក)

ព្រះនាងសង់ជាកុមារី លុះនិយាយរឿងនេះចប់ហើយ កំនៅស្ងៀមមួយស្របក់ ។ ក្នុងពេលនោះ វត្តមាងអស់ហាក់ដូចជាប្រមូលចូលក្នុងវិញ្ញាណរបស់ព្រះនាង ។ ទើបសួរទៅព្រាហ្មណ៍ទាំងបួន ម្នាក់ម្តងៗ ថា "បណ្តាមនុស្សទាំងប៉ុន្មានដែលខ្ញុំបានពោលក្នុងរឿងនេះ តើអ្នកមានចិត្តសរសើដែលមនុស្សប្រុសណា ?" ។

ព្រាហ្មណ៍ដែលចាស់ជាងគេធ្វើយឡើងថា "ខ្ញុំសរសើព្រះកុណាជាងគេ ព្រោះព្រះអង្គទ្រង់មានកិរិយាប្រកបតាមច្បាប់ទាំង ១០ ដែលស្តេចគ្រប់អង្គតែងប្រតិត្តិ ខ្ញុំសរសើ ដោយសារទ្រង់នៅវ័យក្មេងក្លាហានមានឫទ្ធិអំណាច ហើយទ្រង់ចេះបង្ក្រាបតណ្ហាព្រះអង្គ មិនឲ្យស្នេហាចំពោះរូបនារីដែលបានសន្យានឹងព្រះអង្គ" ។

ព្រាហ្មណ៍ទី ២ និយាយថា "ខ្ញុំសរសើរទេវតាដែលរក្សាដើមពោធិ៍នោះ ព្រោះលោកបានឲ្យដំណឹងមាសដល់នាង, មួយទៀត លោកជាទេវតាពៃ លោកចេះសង្កត់ចិត្តហានក្លាយោរយៅរបស់លោក ក្នុងកាលដ៏ប្រសើរនោះ គឺលោកឯកចិត្តបានមិនស្រឡាញ់នាង មិនដូច

មនុស្សយើងធម្មតា, ឯការណ៍ធ្វើចិត្តយ៉ាងនេះ ជាការមួយពិបាកណាស់" ។

ព្រាហ្មណ៍ទី ៣ និយាយថា "ខ្ញុំសរសើរប្តីរបស់នាងជាងគេ ព្រោះបុរសនេះ មានចិត្តបរិបូណ៌ដោយកិរិយាប្រពៃណាស់ គឺចិត្តដូចដើងភាន មាសមួយដែលគេជាក់ទឹកពេញប្រៀប ហើយនៅបាតដើងភានមាសនោះមានពេជ្រមួយគ្រាប់ផង, បុរសនេះនៅក្មេងហើយក្លាហាន ប៉ុន្តែគេចេះបង្ក្រាត់ចិត្តគេមិនឲ្យកាន់ផ្លូវសំរើប រួចកាលដែលកិរិយាសុំចេញទៅ កាលនោះគឺជាថ្ងៃដែលត្រូវផ្សំដំណេកផង បុរសនោះជាប់ចិត្តឲ្យច្បាប់នាងទៅដោយឥតរួញរាឡើយ, បុរសនោះឯងពិតជាមនុស្សមានជីវិតមួយយ៉ាងប្រសើរ ហើយមានចិត្តមួយយ៉ាងខ្ពង់ខ្ពស់បំផុត" ។

ក្រោយមក ដល់វេនព្រាហ្មណ៍កម្ងោះនិយាយ ។ ព្រះនាងខត្តិយានីបានប្រទងស្មារតីចាំស្តាប់ ។ ព្រាហ្មណ៍កម្ងោះក៏និយាយថា "បណ្តាមនុស្សក្នុងរឿងនេះទាំងប៉ុន្មាន ខ្ញុំមានចិត្តសរសើរមេចោរជាងគេ ព្រោះធម្មតាមេចោរ តែងតែប្រថុយស្លាប់ដើម្បីយកទ្រព្យគេ, ប៉ុន្តែក្នុងពេលនោះ មេចោរបែរជាឲ្យមាសពេជ្រ កងក ដើងភានមាសនឹងសំលៀកបំពាក់ទាំងប៉ុន្មានរបូតចេញពីកណ្តាប់ដៃខ្លួនវិញ, នេះជាព័ស្តុតាងមួយយ៉ាងស័ក្តិសិទ្ធិ ដែលបង្ហាញឲ្យឃើញថា មេចោរនេះមានគំនិតនឹងចិត្តសទ្ធាប្រសើរណាស់ ខ្ញុំសរសើរតែមេចោរនេះទេ" ។

រួចនៅសៀមទាំងអស់គ្នា ។ ស្រីស្នំរបស់ព្រះនាងខត្តិយានីដែលនៅជិតព្រះនាង និយាយខ្សឹបៗថា "ព្រះនាងឃើញថ្លៃតម្លៃទេ? ព្រាហ្មណ៍

ទាំងមនាក់សរសើរទៀត ព្រោះតែហេតុណា ទើបបុរសជាស្វាមី ដូចយើងបាន
ឆ្ងែគិតខុសដែរ; ឯព្រាហ្មណ៍កម្មោះបែរជាសរសើរមេចោរតែម្នាក់ឯង?" ។
ព្រះនាងឆ្លើយថា «ពាក្យឆ្លើយរបស់ព្រាហ្មណ៍កម្មោះនេះស្រេចនឹងគំនិត
របស់គាត់ពិតមែន, ខ្ញុំយើញច្បាស់ថា គាត់នេះហើយដែលលួចមាស
របស់មិត្តសំឡាញ់គាត់ទាំងអស់គ្នា, ប៉ុន្តែមិនអ្វីទេ . បន្តិចទៀតយើងគង់
តែបានយើញព័ស្តុតាងពិតប្រាកដមិនខាន, ចូរបងទៅកន្លែងបន្ទប់របស់ខ្ញុំ
យកសំលៀកបំពាក់របស់ខ្ញុំ ស្លៀកពាក់រួចតុបតែងខ្លួនយ៉ាងណាឲ្យបាន
ដូចខ្ញុំ, ធ្វើយ៉ាងនេះរួចហើយ បងទៅកព្រាហ្មណ៍កម្មោះក្នុងសួនច្បារ
កាលណាព្រាហ្មណ៍កម្មោះនេះនៅតែឯង បងត្រូវនិយាយដូចតទៅនេះថា
"បង!ពាក្យដែលព្រាហ្មណ៍ទាំង ៣ នាក់បាននិយាយជាពាក្យចចាមអាមទេ
ឯពាក្យរបស់បងវិញ ជាពាក្យអ្នកមានប្រាជ្ញាពិត ខ្ញុំសរសើរបងជាខ្លាំង
សុំឲ្យបងស្តាប់ខ្ញុំ ដ្បិតបងនៅលីវ ខ្ញុំស្រឡាញ់បងណាស់ សុំឲ្យបង
យល់ព្រមរៀបការនឹងខ្ញុំ" លុះកាលណាព្រាហ្មណ៍កម្មោះបងទទួលតាម
បងហើយ បងនិយាយបន្ថែមទៀតថា "បងយល់តាមប្អូនហើយ ប៉ុន្តែ
យើងត្រូវធ្វើយ៉ាងណា ដើម្បីចិញ្ចឹមជីវិតជាមួយគ្នា, ឥឡូវបងបាត់ទ្រព្យ
ធនធានអស់ទៅហើយ ឯចំណែកខាងខ្ញុំជាប្អូនមានតែមាសពេជ្របន្តិច
បន្តួចទេ ហេតុដូច្នេះ យើងត្រូវតែយ្លាតគ្នាមួយគ្រាសិន ចាំទំពាំតែខ្ញុំបាន
ស្រុះស្រួលនឹងឥតុកបស់ខ្ញុំ រួចយើងនឹងបានទៅជាអ្នកមានពុំខាន; ប៉ុន្តែ
ពីនេះទៅ នោះយើងមុខជារកអាហារចិញ្ចឹមជីវិតដោយលំបាកពុំខាន;"

ដល់និយាយយ៉ាងនេះរួចហើយ គ្រូបង៏មកជ្រាបខ្ញុំវិញភ្លាម តែព្រាហ្មណ៍កម្ញើនិយាយយ៉ាងណាខ្លះ ។

ឯស្រីស្នំកំខ្ចីតផ្ដង់ធ្វើតាមពាក្យព្រះនាងខត្តិយានី ដោយឥតរំលងកន្លែងណាឡើយ ។ នាងបានទៅរកព្រាហ្មណ៍កម្ញើរហើយនិយាយគ្រប់ប្រការដោយប្រើសំឡេងយ៉ាងខ្ចីកូន តាមពាក្យបង្គាប់របស់ព្រះនាង ។ ព្រាហ្មណ៍កម្ញើមានចិត្តត្រេកអរពន់ពេក ហើយនិយាយឡើងថា "ចូរអ្នកកុំព្រួយបារម្ភអ្វីឲ្យសោះ មាសបង៏គ្មានបាត់ទេ បង៏បានបញ្ជោតថាបាត់ ដើម្បីឲ្យព្រាហ្មណ៍ចាំងបីចែកមាសឲ្យបង៏ថែមទៀត ប៉ុន្តែបង៏មានទ្រព្យគ្រប់គ្រាន់ល្មមចិញ្ចឹមជីវិតយើង៏បានតាមត្រូវការ ទោះបីយើង៏ទៅនៅស្រុកណាឆ្ងាយក៏ដោយ យើង៏ក៏មិនស្ងាប់ដែរ" ។

នាងធ្វើល្បិចបញ្ជោតថា នាងទៅរៀបចំខ្លួន ដើម្បីនឹងរត់ទៅ តែដោយពិតនាងមករកព្រះនាងខត្តិយានី ហើយនិយាយអំពីការពិភាក្សាដែលនាងបានធ្វើជាមួយព្រាហ្មណ៍កម្ញើ ។

ព្រះនាងខត្តិយានីចូលទៅជិតឪពុករបស់ព្រះនាងភ្លាមដោយឥតបង្អង់យូរឡើយ ហើយដំណរថា "លោកឪពុក! រឿងនេះខ្ញុំបានរៀបចំស្រេចអស់ហើយ, ឯមាសដែលបាត់នោះ គឺនៅក្នុងកណ្ដាប់ដៃព្រាហ្មណ៍កម្ញើ" ។ នាងនិយាយបន្តទៀតថា "បើសិនណាខ្ញុំបានមាសគ្រប់ចំនួនដែលបាត់នោះ កូនវេងពីរម៉ឺនក្នុង ខ្ញុំនឹងយកមាស ១០០ ដំឡឹងដែល

ជាតំនោះមកដូនពុំខាន" ។ បិតាក៏ធ្វើតាមបំណងកូនយ៉ាងរួសរាន់ ។ ព្រះនាងយកមាសនោះ ទៅប្រគល់ឲ្យស្រីចំបើដែលមានចិត្តស្មោះត្រង់នឹងព្រះនាងជាតន់ពេកនោះ ហើយបានផ្តែផ្តាំថា "ចូរបងយកមាសនេះទៅបង្ហាញព្រាហ្មណ៍កម្ងោះនោះចុះ" ។

ឯស្រីចំបើ ក៏ទៅរកព្រាហ្មណ៍កម្ងោះដែលនៅចាំនាងក្នុងសួនច្បារដល់ហើយនិយាយថា "បងមានមាសចំនួនប៉ុន្មាន? ចំណែកខាងខ្ញុំជាប្អូនមានមាសបន្តិចបន្តួចទេ គឺមានតែ ១០០ ដំឡឹងប៉ុណ្ណោះឯង ប៉ុន្តែបើយកទៅបញ្ចូលជាមួយរបស់បងផង យើងមុខជារស់នៅបានដោយសុខសប្បាយជាមួយគ្នាមិនខាន" ។ ព្រាហ្មណ៍កម្ងោះលុះបានគិតយូរបន្តិចក៏ឲ្យថង់មាសរបស់ខ្លួនមកនាង ។ កន្លង ២ ឬ ៣ នាទីក្រោយមក ថង់មាសនោះក៏បានដល់ដៃព្រះនាងទក្ខិយានី ។ ព្រះនាងក៏មានចិត្តត្រេកអរជាខ្លាំងហើយនិយាយថា "អ្នកបង យើងបានការហើយ កុំឲ្យបង្អង់យូរឲ្យសោះ ចូរបងទៅហៅព្រាហ្មណ៍ទាំង ៣ នាក់មក ហើយឲ្យព្រាហ្មណ៍ទាំង ៣ នោះយកមាសរបស់ខ្លួនមកផង ក្នុងព្រះនាមនៃព្រះករុណាជាអម្ចាស់ដីវែតលើត្បូង" ។ ឯព្រាហ្មណ៍ម្នាក់ៗ ក៏ប្រញាប់ប្រញាល់យកមាសមកប្រគល់ឲ្យនាងទក្ខិយានី ។

លោកកុង្សីយ៍បានអញ្ជើញទៅទូលព្រះករុណា ព្រោះលោកឃើញមាសវិញហើយ ។ ប៉ុន្តែលោកទូលព្រះករុណាដោយពិតត្រង់ថា

មាសនេះមិនមែនខ្ញុំនលោកអេយ៉ាញទេ ដែលអេយ៉ាញនេះ គឺបុត្រ
របស់លោកដែលបាន់ដឹកនាំស្រាវជ្រាវរកវិធីដ៏លំបាកនេះ ។ ព្រះកុ-
ណាខ្ញុំហៅព្រះនាងខត្តិយានី នឹងព្រាហ្មណ៍ទាំងបួនមក ។ ព្រះនាង
ខត្តិយានីក្រាបទូលថា "សូមខ្ញុំព្រះមេត្តាប្រោសកុងរឿងនេះមានល្បិច
អាក្រក់ នឹងការលួចមួយយ៉ាងធំដែលព្រាហ្មណ៍ម្នាក់បានធ្វើ ព្រាហ្មណ៍
ទាំងបួននាក់នេះ សុទ្ធតែជាអ្នកប្រកបដោយសន្តិចរិយានឹងវិជ្ជាសាស្ត្រ
ប៉ុន្តែមានព្រាហ្មណ៍ម្នាក់ ពុំមានដាក់ខ្ញុំនចេញឲ្យផុតពីចំណងនៅឡើយ;
នុះក្បាលមនុស្សតែងតែឆ្ងល់គ្នាពីមួយទៅមួយ មិនថាអ្នកប្រាជ្ញអ្នក
ខ្លៅទេ, ឯនុះក្បាលនេះ អាចទៅជាទុំកម្ពរនៃបំណង កំហឹង នឹងតណ្ហា
បាន អាស្រ័យហេតុនេះហើយបានជាកុងសៀវភៅធម៌របស់ព្រះពុទ្ធ
មានន័យយថា ដំបូងត្រចៀកពុំ រួចត្រចៀកបណ្តាល់ឲ្យក្តៃកចង់ឃើញ,
ឯបំណងរបស់ចក្ខុ ប្រាថ្នាដល់ចិត្ត រួចជីវិតយើងវិលប្រែប្រួលពីល្អទៅ
អាក្រក់ ហើយជីវិតនេះចង់ជាប់នឹងតំរេកកុងកពលោកយើងនេះ; ក្រោយ
មកជីវិតនេះធេងធោងចាត់ស្អាតល្អ ឯមនុស្សដែលមានជីវិតបែបនេះ
អាចធ្វើអំពើអាក្រក់បានគ្រប់យ៉ាងដោយគ្មានអ្វីចប់ នឹងគ្មានវិប្បដិសារៈ;
មួយទៀតមនុស្សបែបនេះ មុខជាជ្វាក់ខ្ញុំនកុងនរកឯទុក្ខវេទនា ពីទុក្ខ
មួយទៅទុក្ខមួយជាអចិន្ត្រៃយ្យពុំមានឡើយ" ។

លុះនិយាយចប់ហើយ នាងនុខ្ញុំនកុងទីចំពោះព្រះភក្ត្រស្តេច
ហើយដាក់មាសចាំង ៤ ថង់ នៅក្រោមព្រះបាទព្រះអង្គ ។ ស្តេចទ្រង់

បង្គាប់ឲ្យព្រាហ្មណ៍ម្នាក់ ។ យកបង្អែនទៅវិញ ។ លុះដល់វេនព្រាហ្មណ៍ កន្លះ ព្រះពជាមានព្រះបន្ទូលថា "ម្តេចក៏អ្នកថាវេរបង្អែនអ្នកជាត់ ឥឡូវនេះ យើញវិញហើយ" ។ អ្នកដែលខុសខ្លួនក៏ដាក់មុខចុះដោយការសញ្ជប់ សញ្ជឹងពន់ពេក ។ នាងវត្តិយានីបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, ព្រាហ្មណ៍ទាំង ៤ នាក់នឹងត្រឡប់ទៅកាន់ព្រះវិហារ ដើម្បីទៅធ្វើសមណធម៌ជាថ្មីវិញ ឯព្រាហ្មណ៍ដែលខុសខ្លួននេះ នឹងកែប្រែគំនិតហើយកាន់ផ្លូវសន្តិចរិយាវិញហើយ ហេតុដូច្នេះ សុំព្រះអង្គទ្រង់ព្រះពជានុញ្ញាតទោសឲ្យផងចុះ" ។

ក្នុងពេលនេះ នាងទេពធីតាដែលរក្សាស្មៅតច្ចីត្រចៀកខ្មៅនឹង ថា "ជយោ" លាន់ឮរំពងឡើង ។

ព្រះកុណា មានព្រះហឫទ័យសរសើរប្រាជ្ញារបស់នាងជាពន់ពេក ហើយទ្រង់លើកនាងជាអគ្គមហេសី ក្នុងព្រះពជអាណាចក្រ ដោយទ្រង់គិតឃើញថា គ្មានអ្នកណាមួយ ចេះអាចកាត់រឿងស្មុកស្មាញបែបនេះបានទេ ។

អស់លោកសុភា ! ត្រូវលោកមានសេចក្តីពង្រឹងនឹងប្រាជ្ញា ក្នុងការដំនុំដំរះដែលគេប្តឹងលោកឲ្យដូចរឿងនេះ ។ ត្រូវលោកយកតម្រាប់ធ្វើតាមនាងវត្តិយានី ធ្វើជាម្ចាស់ វាវែ ដែលបានបង្ហាញយើងនេះ ។

(មានត)

ភាគទី ៦

អ្នកឧកញ៉ាវិបុលរាជសេនា ង្វៃ-កង ប្រែរៀបរៀង

(ត្រមក)

កងស៊ុនចាន នឹង អ្នងសៀវកំប្រង់ប្រៀបរៀបសេនាតូហានទៅវិញទៅមក យ៉ាងម៉ាំមួន តាំងបន្ទាយរាយទ័ពជាប់ដៃនគ្នាខាងត្រើយស្ទឹងម្ខាងម្ខាក់ ត្រឹមតែតាំងទ័ពជាប់នៅទីនោះប្រហែលមួយខែទ្បាយ ។

វេលានោះ មានមនុស្សម្នាក់នាំយកដំណឹងនោះទៅប្រាប់លីយូនៅក្រុងតៀងហាន់តាមដំណើរដែលអ្នងសៀវ នឹង កងស៊ុនចានតតាំងច្បាំងគ្នានោះគ្រប់ប្រការ ។ លីយូក៏នាំសេចក្តីនោះទៅដំកបតាំងតុះ។ ពីគ្រានឹងលីយូថា ដែលអ្នងសៀវនឹងកងស៊ុនចានមានថ្វីដៃ ធ្វើពិជ័យសង្គ្រាមនឹងគ្នាដូច្នេះ យើងនឹងគិតប្រការដូចម្តេច? ។ លីយូថា អ្នងសៀវនឹងកងស៊ុនចាននោះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែណាស់ បានតតាំងច្បាំងគ្នានៅតំបន់ស្ទឹងកួនហួយរួចហើយ បើខាងណាមានជ័យដំនះ ខាងនោះក៏នឹងកំរើកឡើង យូរទៅគង់នឹងនាំឲ្យរំខានដល់ខ្លួនលោក បើដូច្នេះសូមឲ្យលោកតែងសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេ ទៅហាមឃាត់ខាងសងខាងឲ្យជាមេត្រីនឹងគ្នាទៅវិញ យូរទៅអ្នងសៀវនឹងកងស៊ុនចាននឹងនៅក្នុងបង្គាប់បញ្ជាលោក ។ តាំងតុះយើញត្រូវ ក៏តែងជាព្រះតម្រាស់ព្រះ

លៅហៀនតេជា ២ ច្បាប់តាមតាក្យលើយថានោះ ហើយឲ្យតៀវគីនឹងម៉ាយិត នាំទៅឲ្យអូនសៀវនឹងកង់ស៊ុនថាន ។

ឯអូនសៀវកាលដឹងដំណឹងហើយ ក៏ចេញទៅទទួលព្រះតម្រាស់តាមទំនៀមទម្លាប់ រួចនាំគ្នាត្រឡប់ចូលទៅក្នុងបន្ទាយ លុះមើលដឹងសេចក្តីហើយ ក៏ព្រមទទួលប្រតិបត្តិតាមព្រះរាជតម្រាស់គ្រប់ប្រការ ។ រួចតៀវគីនឹងម៉ាយិតនាំគ្នាគាន់ព្រះតម្រាស់ ១ ច្បាប់ទៀត ឆ្ងន់ទៅឲ្យកង់ស៊ុនថានក្នុងបន្ទាយ ។ កង់ស៊ុនថានកាលដឹងសេចក្តី ក៏ទទួលប្រតិបត្តិតាមព្រះរាជតម្រាស់នោះ ហើយចាត់បំរើទៅចរចាជ្រាប់អូនសៀវ។ ទទួលព្រមលួមតាមគ្នា, ព្រះរាជបំរើទាំង ២ នាំសេចក្តីត្រឡប់ចូលទៅក្រុងតៀងហាន់, ខាងអូនសៀវលើកពលត្រឡប់ទៅក្រុងគីជីវិញ ។

ចំណែកកង់ស៊ុនថាន បានរៀបចំសេនាគាហានហើយនាំទៅពីគួនអ៊ូតៀវហ៊ុយ ដូឡុង លើកទ័ពត្រឡប់ទៅវិត, លុះដល់ស្រុកផេងឆ្នូនគួនទៅពីគួនអ៊ូតៀវហ៊ុយលាចូលទៅទៅនិយាយរាជការដូចដើម ។ ដូឡុងបាននិយាយនឹងទៅពីថា កាលពីដើមមក ខ្ញុំឃើញអូនសៀវជាមនុស្សអាក្រក់បានជាត្រឡប់មកទៅនឹងកង់ស៊ុនថាន ឥឡូវនេះខ្ញុំបានឃើញថាកង់ស៊ុនថានជាមនុស្សគ្មានដំរេះប្រាជ្ញាសោះ កំមានសេចក្តីព្រួយលំបាកក្នុងចិត្តពន់ពេក ដល់ខ្ញុំបានបានឃើញលោកមានសតិបញ្ញាក្លៀវក្លាគិតថានឹងចង់ចូលសមាគមជាមួយផង ប៉ុន្តែថាស់នៅឆ្ងាយជាច់ស្រយាលពីគ្នា

ពេក ខ្ញុំបាទមិនដឹងជានឹងគិតវេរបបណា ។ ខ្លៅពីតបដោយយកចិត្តដួលឡើងថា អ្នកនឹងយើងស្គាល់ចិត្តគ្នាកន្លែងនេះ ក៏ត្រូវនៅរាប់អានជាស្និទ្ធស្នាលនឹងគ្នាតទៅ តែឥឡូវនេះត្រូវអ្នកទៅនៅជាមួយនឹងកងស៊ុនចាន សិនចុះ បើដំរីតយើងនៅមានទៅខាងឯមុខទៀត អ្នកក៏គង់បានជួបប្រសប់ធ្វើការជាមួយមិនខានទេ អ្នកចូរចាំពាក្យនេះទុកកុំភ្លេច ។ ខ្លៅពីនាញដៃដួលឡើងចូលទៅជិតហើយ ក៏មានសេចក្តីសៅសោក ។ ដួលឡើងក៏យំអាល័យខ្លៅពី ហើយខ្លៅពីលាដួលឡើងចូលទៅកន្លែងស្រុកផងងួនគួន, កងស៊ុនចាននាំដួលឡើងលើកគ្រហានទៅស្រុកចាំកប៉ង ។

ឯអ្នងសុតទៅហ្វាយស្រុកឡាំយ៉ុង លុះដឹងដំណឹងថា អ្នងសៀវជាបងបានស្រុកគីជាវដូច្នោះ ក៏ធ្វើសំបុត្រ ១ ចាប់ឲ្យនាំទៅដាក់សុំសេះអ្នងសៀវមួយពាន់, តែអ្នងសៀវមិនព្រមឲ្យដូចប្រាថ្នា, អ្នងសុតខឹងណាស់មានសេចក្តីព្យាបាទអ្នងសៀវជាបង អ្នងសុតធ្វើសំបុត្រទៅសុំស្បៀងអាហារពីខ្លៅពៀវទៅហ្វាយស្រុកគេងជាវិញ ខាងខ្លៅពៀវក៏មិនព្រមឲ្យស្បៀងអាហារទៅអ្នងសុត ។ ក៏ខឹងចង់ព្យាបាទនឹងខ្លៅពៀវទៀត ។ អ្នងសុតធ្វើសំបុត្រទៅដល់ស៊ុនកៀនទៅហ្វាយស្រុកកាំងតាំងថា ខ្លៅពៀវលើកគ្រហានចេញស្តាត់ច្បាំងដណ្តើម យកគ្រាសម្រាប់ពាក្យពីលោភៈនោះក៏ព្រោះអ្នងសៀវបងខ្ញុំឲ្យដំណឹង ឥឡូវនេះអ្នងសៀវនឹងខ្លៅពៀវមួយគំនិតគ្នានឹងលើកទ័ពមកវាយយកស្រុកកាំងតាំងដណ្តើមយកគ្រាឲ្យបាន រឿង

នេះបើលោកនឹងតាំងចិត្តសម្លុតស្រីមិនគួរទេ ចូរប្រញាប់លើកតាហានទៅជួយស្រុកកេងជីវិតវិញ ខ្ញុំនឹងជួយសងសឹកលោក ហើយយើងលើកទ័ពប្រសព្វគ្នាទៅវាយស្រុកគង់ជីវិតវិញដែលអ្នកស្រីវានៅនោះ។ ឯស៊ុនកៀនបានឧទ្ទូលសំបុត្រដឹងសេចក្តីហើយក៏ពេញចិត្តណាស់ ទើបប្រឹក្សានឹងសេនាតាហានថា អ្នកឯណានឹងយល់ឃើញដូចម្តេច? ធៀវ៉ៅធ្វើយតបថា ដែលអ្នកសុតឲ្យសំបុត្រមកនេះ យើងនឹងជឿស្តាប់តុំពាន់បានព្រោះអ្នកសុតនោះជាមនុស្សគេក្រក់មែនញុះញង់ឲ្យអ្នកជវៃទាស់នៃងគ្នាម្យ៉ាងទៀតអ្នកសុតត្រូវជាប្អូនអ្នកស្រីវាផង ដែលថានឹងលើកទ័ពទៅច្បាំងនឹងបងវានោះដូចមិនពិត ។ ស៊ុនកៀនធ្វើយតបថា "ដែលធៀវ៉ៅថានោះក៏ត្រូវហើយ តែថាខ្លាវានោះជាមនុស្សគ្រងនឹងយើង បើប្រសិនជាអ្នកសុតមិនមានសំបុត្រមកដល់យើង ។ មិនមែនទៅស្រីមដែរ គង់តែលើកទ័ពទៅច្បាំង ការទាំងនេះមិនមែនដឹងឃើញដោយសារគេជួយប៉ុណ្ណោះទេ," ថាហើយក៏បង្គាប់អ៊ុយកាយឲ្យទៅកេណ្ឌប្រមូលតាហាននឹងរៀបយោធាជំនិះទាំងផ្លូវដែលរៀបចំវាយគ្រឿងសស្ត្រាវុធ មានទូកតូចធំផ្ទុងាក់សេះនឹងស្បៀងអាហារបរិបូណ៌ ចាំដល់ពេលបូស្សុទ្ធនឹងលើកព្យុហ៍យាត្រា ។ ឯពួកកងត្រៃវែលស្លាត គាលបានដឹងដំណឹងច្បាស់ ក៏នាំសេចក្តីទោះទៅដំកបដល់ខ្លាវា ។ ក៏ប្រជុំទីប្រឹក្សាថា ស៊ុនកៀននឹងលើកទ័ពតឹតមកនោះ តើអ្នកទាំងអស់គ្នាយល់ឃើញ

ដូចម្តេច? ។ គេឆ្លើយថា ដែលស៊ុនកៀនឧទ្ធឹងលើកទ័ពទៅកោះ
ឃើញថាឧទ្ធឹងតស៊ូនឹងយើងខ្លាំងទ័ពគេកម៏មិនបានទេ ព្រោះបញ្ជូនស្បៀង
លំបាក សូមឲ្យលោកគេណ្ហាហានបេះហង៏ច ចៅហ្វាយខ្ញែគាំង
ហែ ដែលឡើងខ្ញែគយើងគាំងដាទ័ពមុខ ខ្លួនលោកលើកជាភាហាន
ទ័ពហ្លួង ។ ឡៅពៀរឃើញគ្រូវកំឲ្យទៅគេណ្ហាហានហង៏ច លើកទៅ
តាំងនៅមាត់ព្រៃកហួនសៀ ហើយចាត់ចែងភាហានក្នុងស្រុកគេងដ៏វ
គេណ្ហាទុកតាមពាក្យគេងលៀងថា ។

ឯស៊ុនកៀនមានភរិយា ២ នាក់ជាបង់ប្អូនបង្កើតនឹងគ្នា បង់ឈ្មោះ
នាងង៉ីហ៊ីយិន ប្អូនឈ្មោះនាងង៉ីយ៉ាហ៊ីយិន ។ នាងបង់មានបុត្រប្រុស ៤
នាក់ ឈ្មោះស៊ុនសេក ១ ស៊ុនកួន ១ ស៊ុនសៀង ១ ស៊ុនខង ១ ។ នាង
ប្អូនមានបុត្រប្រុសឈ្មោះស៊ុនឡង ១ បុត្រស្រីឈ្មោះស៊ុនយិន ១ បុត្រប្រុស
ចំញឹមម្នាក់ទៀតឈ្មោះកង់ឡេ ។ ស៊ុនកៀនមានប្អូនប្រុសម្នាក់ឈ្មោះ
ស៊ុនចេង, កាលថ្ងៃមានបុក្ស្ស ស៊ុនកៀនឧទ្ធឹងចុះទៅនោះ ស៊ុនចេងជា
ប្អូនកំនាំបុត្រស៊ុនកៀនតាំង ៧ នាក់ តាមចុះទៅឃាត់ស៊ុនកៀនថា គ្រា
នេះព្រះចៅហៀនតេចាន់សោយរាជសម្បត្តិ រាជការអាណាចក្រកំណាកម្ម-
សិទ្ធិដាច់ខាតលើតាំងតុ: ។ ធ្វើការខុច្បាតអាក្រក់ អាណាខ្ញែគាំងតួងក៏
តើតចលាចលលែងចំណុះចុះចូលគ្នា អាណាប្រជានុពស្ត្រកំចាន់សេចក្តី
ក្តៅក្រហាយខ្លាំងផែនដី ឥឡូវដែនស្រុកតាំងតាំងខើបនឹងពាបាបជា

សុខសាន្តគ្រាណាហើយ ដែលអ្នកជាបងនឹងលើកទ័ពទៅច្បាំងនឹងខ្មៅ-
ពៀរទៅហ្ន៎យវែគ្រកេងដ៏វ សូមឲ្យគ្រិះរិះរំពឹងមើលសិន ។ ស៊ុនកៀនតប
ថា កាលតាមុនមកខ្ជិនយើងម្ចាក់ឯង ម្តេចក៏ចេះតាំងខ្ជិនឡើងបាន ឥឡូវ
យើងបានសេនាគាហានមកជាកម្លាំងដៃដើងច្រើនប៉ុណ្ណេះហើយ យើង
នឹងលុះបងនៅស្ងៀមមិនទៅធ្វើការសង្គ្រាមកន្ទេញពៀរដែលជាគូសត្រូវឲ្យ
បានទេ ក៏ហាក់ដូចជាយើងមិនមែនកូនប្រុសជាជាតិគាហានមានថ្លៃដៃ ។

ស៊ុនសេកធ្វើយដំរាបស៊ុនកៀនជាបិតាថា បើបិតាមិនព្រមឈប់,
នឹងលើកទ័ពទៅឲ្យបាននោះខ្ញុំបាទក៏សូមទៅជាមួយផង ។ ស៊ុនកៀនមាន
សេចក្តីស្រឡាញ់ស៊ុនសេកជាខ្លាំងបំផុត តែនឹងឃាត់មិនកើត ក៏ទុកឲ្យ
ទៅជាមួយ ហើយលើកគាហានចុះទូកចំបាំងឆ្លងឈូងសមុទ្រទៅដល់
តាមស្រុកហ្ន៎ងសៀប្រទល់នឹងស្រុកគាំងហែ ។

ចំណែកហងចខៅហ្ន៎យស្រុកគាំងហែដឹងតាមសំបុត្របង្គាប់អំពីខ្មៅ
ពៀរឲ្យមក ក៏តាំងតែកេណ្ឌគាហានប្រមូលជាកងទ័ព ហើយលើកទៅ
បុំងការនៅមាត់កំពង់ស្រុកហ្ន៎ងសៀ លុះឃើញស៊ុនកៀនលើកគាហាន
ចឹកមកប្រពាក់ប្រពួនដល់មាត់កំពង់ ក៏តាំងតែឲ្យគាហានបាញ់ធ្នូចុះចុះ
ទៅសំដៅទូកទាំងនោះ ។ ស៊ុនកៀនឃើញដូច្នោះក៏បំបាំងខ្លួន ថយទូក
បញ្ជោត បណ្តែតឲ្យបាញ់ដល់ ៣ ថ្ងៃ ៣ យប់ គាហានកងទ័ពទូកក៏
មិនមានសេចក្តីអន្តរាយ ។ ហងចក៏ឲ្យបាញ់បន្ថែមទាល់តែអស់ព្រួញ ។

ឯស៊ុនកៀនបានដឹងថា ព្រួញធ្នូសូប់ស្លាត់ហើយ ក៏ឲ្យទាហានដកយកព្រួញដែលជាប់នៅទឹងខ្នងទាំងអស់បានចំនួនព្រួញប្រហែលដប់ជុំមុន ។

ពេលនោះ មានឱ្យលប់បក់ត្រឡប់ខ្លួនត្រឡប់ក្រោយ ស៊ុនកៀនឲ្យចៃវខ្លួនចំបាំងចូលទៅចត ហើយឲ្យបាញ់ធ្នូឡើង ។ ទាហានហង៍ចអស់ព្រួញហើយ ឃើញទឹងតទល់ពុំឈ្នះ ក៏លើកទ័ពថយចូលស្រុកហួនសៀ. ចៀវផៅទឹងអ៊ុយកាយ ឃើញដូច្នោះ ក៏លើកទាហានបំបែកជា ២ កង៍ដេញប្រកាប់ជាប់ចូលទៅដល់ទ្វារស្រុកហួនសៀ, ស៊ុនកៀនទឹងហាន់តុង៍ក៏លើកទាហានទ័ពដំនួយប្រពាក់ប្រពួនចូលទៅទៀត លុះឃើញហង៍ចថយទ័ពចូលទ្វារស្រុក ក៏បរទាហានសម្រុកតាមទៅក្នុង៍ស្រុកនោះបាន, ហង៍ចទប់ទល់ពុំឈ្នះ ក៏ត្រឡប់រត់ទំលាយចេញទៅនៅស្រុកតេង៍សៀ ។ ស៊ុនកៀនបានការកំឲ្យអ៊ុយកាយលើកពលត្រឡប់ទៅថែរក្សាខ្លួចម្ប៉ាង ឯខ្លួនលើកទាហានតាមហាង៍ចទៅទៀត, ហង៍ចឃើញស៊ុនកៀនខ្លាំងលើកតាមទល់ទឹង៍កំពែង៍ស្រុកដូច្នោះ ក៏លើកទាហានចេញមកច្បាំងតទល់នៅក្រៅកំពែង៍ ។ (មានត)

កំពុងខឹងគ្នាដឹងអ្វី ដល់សេបក្តីក្រោធសូប
ត្រឡប់ជារឿងសារី (ស្នាយក្រោយ) ។

ភាគទី ២

សម័យឧត្តរៈ

អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(ត្រឡប់)

ព្រះនាងនេះជាបង្កើតសែព្រះពុទ្ធលោហិតតមកអំពីព្រះបាទហស៊ីវ័ន្តទី ១ នឹងព្រះបាទគ្តសាណវ័ន្តទី ២. ខ្ញុំមានព្រះពុទ្ធនុសេ២អង្គ ព្រះនាមទេវយាទត្សវ័ន្ត ១ ហស៊ីវ័ន្ត ១ ដែលបានទទួលពុទ្ធសម្បត្តិតទៅទាំងពីរអង្គ។

ក្នុងរជ្ជកាលនេះ មានព្រាហ្មណ៍ប្រាជ្ញឈ្មោះ **សទាសិវ:**, ជារាជ**កំសៀងស្រីជំយេន្ទ្របណ្ឌិត** ជាពុទ្ធបុរោហិតរបស់ព្រះអង្គ។ ប្រវត្តិសង្ខេបរបស់ព្រាហ្មណ៍នេះ [1] សទាសិវ: នៅស្រុកកុតក្នុងបូព៌ាទិសមានៈសេចក្តីចេះដឹងទាំងផ្លូវគតិលោក ទាំងផ្លូវគតិធម៌ ប្រកបដោយគុណឈ្មោះជាអ្នកប្រាជ្ញធំ។ ក្នុងសម័យមួយ សទាសិវ: បានចេញទៅបួស តែមិនដឹងជាបួសបានប៉ុន្មានវស្សា. ព្រះបាទសុរ្យវ័ន្តខ្ញុំទិមន្តឲ្យសឹកមក ហើយព្រះពុទ្ធទានពុទ្ធកុមារី ១ អង្គ ត្រូវជាកនិដ្ឋភគិនីរបស់ព្រះអគ្គមហេសីនៃព្រះអង្គឲ្យជាភរិយា ទាំងខ្ញុំតាំងជាពុទ្ធបុរោហិតក្នុងពុទ្ធសំណាក់ មាន

---

[1] មានព្រះអនុជ ២ អង្គ ព្រះនាម សទាសិវ: ១ ជយេន្ទ្រវ័ន្ត ១ ។

ជារជា **កំស្តេងស្រីជយេន្ទ្របណ្ឌិត** មានមុខការជាទីប្រឹក្សាការ
វែនដ៏ ការព្រះសាសនា ទឹងការធ្វើពិធីផ្សេងៗ (ថ្វាយ) ចាំងទ្រង់តាំងជា
ខ្ញុំញកមាំង គឺជាមេជាងធំរបស់ពាជការ ។ ព្រះមហាក្សត្រទ្រង់
ប្រស័យកិច្ចការផ្សេងៗ ទឹងស្រីជយេន្ទ្របណ្ឌិតនេះជាយ៉ាងច្រើន ។

ការផ្នែកអាណាចក្រ – ព្រះបាទសូរ្យវរ្ម័នទ្រង់បានតម្រាបអរិភាព
សត្រូវចាំងកង្វែប្រទេសចាំងក្រៅប្រទេស ចាប់តាំងពីព្រះអង្គទ្រង់នៅជា
តំណែងមហាឧបពាជដូចបានពណ៌នាមកហើយ, ដល់មានពេលព្រះអង្គ
បានគ្រងពិភពកម្ពុជាហើយ ក៏នៅតែមានការណ៍បះបោរក្នុងប្រទេសតមក
ទៀត, ព្រះអង្គគោងព្យាយាមកម្រាបរហូតដល់ឆ្នាំ ព. ស. ១៥៥៣
ទើបបានសាន្តត្រាណរៀបរយ ។

ព្រះពាជអាណាចក្រកង្វែរជួសម័យនេះ ប្រាកដជាបានរីកធំធូលាយ
ជាងរជ្ជកាលមុននេះជាច្រើន គឺប៉ែកទិសនិរតី លាតសន្ធឹងទៅដល់កោះ
ម៉ាលកា រាប់ថា ឆ្ងាយមិនមែនតិច ។ ខាងប៉ែកទិសពាយ័ព្យ បានន្ទគរ
លំកូនរបស់មន បញ្ចូលមកក្នុងព្រះពាជអាណាចក្រកម្ពុជា ១ ភាគទៀត ។
ការគ្រប់គ្រងក្នុងរជ្ជកាលនេះ បានប្រព្រឹត្តទៅតាមប្រពៃណីដើម គឺភាគ
មជ្ឈមរដ្ឋនៅក្នុងអំណាចព្រះអង្គគ្រប់គ្រងផ្ទាល់, ភាគបច្ចន្តរដ្ឋទាំងប៉ុន្មាន
គង់ឲ្យមានមហាឧបពាជគ្រប់គ្រង ទំនងដូចជាប្រទេសរាជតមក ?

វេដ្ឋម៉ាលីយ ទ្រង់តែងតាំងព្រះពាជវង្ស ១ អង្គឲ្យនៅគ្រប់គ្រង តែ
ព្រះពាជវង្សនោះព្រះនាមឬបម្តេច មិនច្បាស់ជ ។

វេដ្ឋគ្លាវតី ទ្រង់ឱ្យព្រះចក្រវត្តិគង់នៅជាមហាឧបពាជតមក ។ លុះ
ដល់ឆ្នាំ ព. ស. ១៩៥៨ ព្រះចក្រវត្តិទំវង្គត ទ្រង់តែងតាំងព្រះពាជវង្ស
ព្រះនាម ព្រះបន្ទូរជោតិ ឲ្យគ្រប់គ្រងតមក ។ ព្រះបន្ទូរជោតិមាន
ព្រះអគ្គទេវី ព្រះនាម បដិមាសុតាដួងបន្ទូរ មានព្រះនរេស ១ អង្គ
ព្រះនាម ព្រះនារាយណ៍ ។

នគរលំកូនជាមណ្ឌលធំ ១ គឺមានផ្ទៃទឹមណ្ឌលតាយ័ត្យរបស់ថៃក្នុង
បច្ចុប្បន្ននេះជាខែត្រដែន មានព្រំប្រទល់ជាប់នឹងប្រទេសកូមា ហើយ
ដែលខើបបានមកខ្មែរក្នុងគ្រាលច្នេះ ទ្រង់តែងតាំងព្រះនាង បាមទេវី
ជាព្រះធីតានៃព្រះបន្ទូរជោតិទៅលវបុរៈ ឲ្យគ្រប់គ្រងតាមសេចក្តីសុំរបស់
ប្រជារស្ត្រកង់ដែនគរលំកូន ។ ការគ្រប់គ្រងរបស់ព្រះនាងបាមទេវី
ប្រព្រឹត្តទៅយ៉ាងធូរៗ មិនដូចការគ្រប់គ្រងរបស់មហាឧបពាជដទៃ ។

ប៉ុន្តែព្រះនាងបាមទេវីទៅគ្រប់គ្រងនគរលំកូន មានសេចក្តីពិស្តារ
ទៅក្នុងបាមទេវីវង្ស[1] សូមស្រង់សេចក្តីដោយសង្ខេបមកថ្លែងក្នុងទីនេះ
ដូចតទៅនេះ ។

---

១ បាមទេវីវង្ស គឺជាពង្សាវតាររបស់ព្រះនាងបាមទេវី ដែលព្រះថេរ ១ អង្គបានតែងឡើង
ជាភាសាមគធៈ តែយើងមានសេចក្តីស្តាយដោយបាត់ដុតត្រង់ដែលថា រឿងនេះជាពង្សាវតារប្រទេស
កម្ពុជា តែត្រូវប្រាប់ជាគ្មានន័យយល់ក្នុងព្រះពុទ្ធពង្សាវតារក្រុងកម្ពុជ សោះ ។

ព្រះនាងចាមទេវីមានព្រះរូបប្រកបដោយបញ្ញាពិធកល្យាណី ។ កុងកាលមុនសោយរាជ្យនេះ ព្រះនាងមានព្រះពរជស្វាមីហើយ ព្រះរាជស្វាមីនោះជាព្រះរាជវង្សវែរ តែទ្រង់មានព្រះហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនាខ្លាំងណាស់ ឥតលា ព្រះនាងទៅទ្រង់ព្រះផ្នួស ។ ឯព្រះនាងក៏ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់ដែរ ឥតបើកអនុញ្ញាតឲ្យព្រះស្វាមីទៅទ្រង់ព្រះផ្នួស ។ លុះព្រះស្វាមីទៅទ្រង់ព្រះផ្នួស ព្រះនាងទ្រង់គតិបាន ៣ ខែហើយ។ ក្រោយដែលព្រះស្វាមីទ្រង់ព្រះផ្នួសហើយ ព្រះនាងក៏ត្រូវតែឡើងគាំទ្រជាមហាឧបាសិកានៅគ្រងនគរលំពូន ។ កាលព្រះនាងយាងទៅ ឥតនិមន្តព្រះពុទ្ធរូបសំខាន់ដែលព្រះនាងធ្លាប់គោរពបូជា ព្រមទាំងនិមន្តព្រះថេរៈដែលធ្លាតក្នុងព្រះវិតបិដកយកទៅផង ។ ព្រះនាងនៅគ្រងនគរលំពូនមិនយូរប៉ុន្មាន ក៏ប្រសូតព្រះរាជបុត្រ គេបានថ្វាយព្រះនាម មហន្តយស ១ អនន្តយស ១ ។ ព្រះនាងគ្រប់គ្រងរដ្ឋប្រកបដោយគន្ធឯធម៌ អ្នកនគរលំពូនមានសេចក្តីគោរពស្វាមិភក្តិចំពោះព្រះនាងជាយ៉ាងក្រៃពេក ។ ទ្រង់បានរៀបចំសាងនគរលំពូនឲ្យត្រូវតាមប្រពៃផង ហើយដាស់ឈ្មោះជាថ្មី ហៅថា ឆគរហរិបុញ្ជ័យ (គំនរមាសច្បាក់) តែតាមសំឡេងសាមញ្ញហៅថា ហរិភុញ្ជ័យ ។ ព្រះនាងបានសាងវត្តស្ថានក្នុងព្រះពុទ្ធសាសនាជាច្រើន មានព្រះពុទ្ធរូបធំៗ ព្រះអារាម នឹងព្រះជាតុចេតិយដ៏ធំ ។ វត្តស្ថានអំបាលនេះ នៅ

មានជាតិស្តុតាងដកបដិសេធបច្ចុប្បន្ននេះ ។ ព្រះពាជវង្សវេស្ស ព្រះនាងមាន ព្រះពាជនុសេ ព្រះពាជនត្តោជាដើម ប្តូនគ្រប់គ្រងនគរបានបុញ្ញ័យតរៀង មក ជាច្រើនព្រះអង្គប្តូរច្រើនសតវត្ស ដូចមានប្រាកដក្នុងចាមទេវីវង្ស នោះស្រាប់ ។

ចំណែកវដ្ដដលៀង ឬហៅ សួគាលោក ដែលមានពាជធានីនៅ កំពេងពេជ្រ ឬហៅថា គោសម្ពី នោះគង់មានព្រះមហាឧបពាជគ្រប់គ្រង ដូចអំពីដើម តែព្រះមហាឧបពាជក្នុងវេលានោះព្រះនាមដូចម្តេច មិន ប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ។

ឯវដ្ដគោត្របុរៈ ដែលមានពាជធានីតាំងនៅកំម៉ាយឬនគរកុំនោះ បានបញ្ចូលមកក្នុងមជ្ឈមវដ្ដពីយូរណាស់មកហើយ វេលានេះគង់គ្មាន ព្រះមហាឧបពាជគ្រប់គ្រង តែគង់មានអ្នកពាជការជាន់ខ្ពស់ដែលហៅតាម ភាសាបុរាណ សឹងប្រាកដនៅសិលាចារឹកថា គាយក ឬ បតិ (សឹង ត្រូវនឹងឋានៈក្នុងបច្ចុប្បន្នថា ចៅហ្វាយវៃត) នៅនៅតាន់តាប់ពាជការ ។

ចំណែកបច្ចន្តវដ្ដប៉ែកខាងកើត គង់មានមហាឧបពាជគ្រប់គ្រងតាម ប្រពៃណីដើម តែព្រះមហាឧបពាជក្នុងសម័យនោះព្រះនាមដូចម្តេច មិន ប្រាកដ ។

សាវតារវត្តចាន យ៉ៃ

នៅឃុំអង្គាញ់ ស្រុកកៀកឃ្លាស ខេត្តតាកែវ

លោកមេឃុំ ង្ហួង – អ៊ូច

ជាអាចារ្យវត្តនេះ រៀបរៀង

(រក្សាទុកលេខ ១)

វត្តចានយ

ថ្ងៃពុធ ១ កើត ខែចែត្រ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ ត្រូវ
នឹងថ្ងៃ ៣១ មិនា ១៩៤៨ ។

ខ្ញុំបាទឈ្មោះ ង្ហួង - អ៊ូច អាយុ ៥៦ ឆ្នាំជាតិខ្មែរ. ទីលំនៅភូមិកៀ
ឃុំអង្គាញ់ ស្រុកកៀកឃ្លាស ខេត្តតាកែវ ធ្វើអាចារ្យសំរាប់វត្តចានយ
ឃុំ ស្រុក ខេត្តដដែល ។ ខ្ញុំសូមតែងពង្សាវតារ វត្តចានយ ជាវត្ត
ដែលខ្ញុំបាននៅសិក្សារៀនអក្សរ តាំងពីកុមារហូតដល់បព្វជ្ជា ជាសាម-
ណេរ ជាភិក្ខុ តាមរឿងហេតុដែលខ្ញុំបានឃើញផ្ទាល់ខ្លួនខ្លះ ឮចាស់ៗ
និយាយតៗមកខ្លះ ដូចមានអធិប្បាយខាងក្រោម:

កាលខ្ញុំអាយុ ១២ ឆ្នាំ មាតាបិតារបស់ខ្ញុំបានយកទៅឲ្យនៅរៀន
អក្សរនៅទីវត្តចានយនេះ; កុងសម័យលោកគ្រូចៅអធិការនាម ភ្ញ័ - តង់
ធ្វើជាចៅអធិការ (ទី ៤) នោះមានអាចារ្យវត្តម្នាក់ឈ្មោះ ព្រាប - ម៉ី អាយុ
៨០ ឆ្នាំហ្នឹង ផ្ទះនៅជិតវត្ត គាត់ទស្សាហ៍មកវត្តញយៗ បានឱ្យយ

ប្រាប់ខ្ញុំថា វត្តនេះអាចតាំងកំណើតមុនសាងដំបូងឡើងតាំលោកតា រឿង ១ ប្លុស ជាសង្ឃនិមន្តមកអំពីស្រុកសៀម លោកជាអ្នកចេះស្មូបារតហោះ លោកមកនៅខ្ពស់ព្រៃតូច សង់កេង ១ នៅស្មូបារត ហើយបានសង់កេងអ្នកតា ២ ឈ្មោះតាសុខ ១ តាស៊ុវ ១ ។ លោកគ្រូនោះថែរក្សាខ្មុកជាគោលចារឹក ដើម្បីនឹងរៀបពីការស្មូបារត នឹង តាំងពីដើមន្តអាគមឲ្យបានពូកែធុតធាប់ បានជាមានដាប់ឈ្មោះអ្នកតាសុខ ១ អ្នកតាស៊ុវ ១ រហូតដល់មកសព្វថ្ងៃនេះ ។ លុះនៅយូរៗទៅ អ្នកស្រុកភូមិបានយកដែលមានផ្ទះតូចៗ ចំនួន ៥-៦ ប៉ុណ្ណោះ បានយើញលោកគ្រូនោះចេះស្មូបារតហោះព្រមតាំង ចេះមន្តអាគមស្រោចទឹកធ្វើខ្សែ មានថ្នាំកែះពគផ្សេងៗ ពូកែធុតធាប់ដូចបំណង ក៏នាំគ្នាទៅមកប់អានយកកូនចៅទៅខ្មុកឲ្យនៅរៀនសូត្រ ហើយជួយធ្វើកុដិសាលា កេង១ចោសថ ជាប់រហូតដល់មកសព្វថ្ងៃនេះ គេហៅថា វត្តបានយ ។ ។ តែទីវត្តនេះចំនងជាភូមិលាអំពីដើមជ្រៃនៅជិតខាងវត្តនេះ មានឈ្មោះភូមិគោកលាវ, ណងវែ, ណងតាសំ, ណងហួង, ណងសាង, ណងចក, ណងចិន, ចាំស្រែ, ចាំសិង, ចាំណយ ក្រាយយូរទៅហៅ ចានយ បើតាមពាក្យលាវ ចាំណយ ប្រែថា "ព្រៃតូច" ត្រូវតាមចំនងវត្តនេះពីខាងដើម មានខ្ពស់ព្រៃតូច ១ សមមកម្យដូចពាក្យអាចារ្យ ត្រាប-ម៉ី ប្រាប់ខ្ញុំមែន ។ វត្តនេះគសាងចំនួន ១៩០ ឆ្នាំទ្វាយមកហើយ កាលពីជ្រុស្តេចព្រះបាទអង្គ ឌួង ប្រហែលជា

គ្រិស្តសករាជ ១៨៥០ ។ តាំងពីកសាងវត្តនេះដរាបដល់មកសព្វថ្ងៃនេះ ៥ រាជ្យស្តេចមកហើយ, ដែលខ្ញុំបានដឹងថាក្នុងរាជ្យព្រះបាទអង្គឌួងនោះ ព្រោះខ្ញុំគិតពីត្រឹមមន្ត្រីថាស់ម្នាក់ឈ្មោះ មៅ ងារការជា ពិភ័ក្តិសង្ឃរាម ធ្វើជានាយកចាំគ្រានៅទីសង្ខម្មនឹងព្រះវត្តមេតគ្រុងក្នុងភ្នំពេញ គាត់ប៉ាន ធ្វើពុជការក្នុងរាជ្យព្រះបាទនរោត្តម កាលដែលលើកទីគ្រុងពីខ្ពង់ខ្ពស់មកភ្នំពេញវិញ, គិតពីត្រឹមនោះមកចៅអធិការវត្តបានយ៉ាងនេះចំនួន ៩ រូបមក ហើយ ដូចមានរាយនាមខាងក្រោម :

១ -	ចៅអធិការ	រឿង
២ -	"	សេក
៣ -	"	អ៊ុក
៤ -	"	រ័ត្ន - គង់
៥ -	"	ដែក - គិម
៦ -	"	ស្រី - សុីម
៧ -	"	សុខ - គល់
៨ -	"	ឆ៉ាយ - ម៉ាង
៩ -	"	ស - អ៊ិន

ពង្សាវតារវត្តបានយ សង្ខេបតែប៉ុណ្ណោះ ។

អធិប្បាយអំពីនាទីដែលសាងវត្ត

បើតាមក្បួនវៃតូម៉ូ ត្រូវរើសរកដីខ្ពស់ខាងត្បូងនឹងខ្ពស់ខាងលិច

ទើបហៅថា កូមិមានសីរី ។ បើកូមិខ្ពស់ដុំវិញតាបកណ្តាល ហៅ
កូមិសំបុកមាន់ នៅពុំសូវស្មុគស្មាញទេ ។ បើកូមិខ្ពស់កណ្តាលតាបដុំវិញ
ហៅកូមិមេលិមទន់ដំយ នៅស្មុគស្មាញ តែពុំសូវចូលចិត្តសម្បត្តិ ។

បើទំកសាងវត្តជាថ្មី តាមទំនៀមលាបដបូងឲ្យកេដីបាន ១ បុស
គឺដី ៨ យកមករៀបបញ្ចាន់កូមិគ្រប់ទិស ហើយទើបបរដំមែកប្រជុំគ្នានៅ
ផ្ទៃតកូមិ, ហើយមានរៀបរណ្តាប់ខ្នើន ៥ ធួប ៥ លាជង្កាស្មាបារី ៥ ។
ដូចគ្នា, រៀបជា ៨ សំពាប់គ្រប់ទិស ឯបាយសី ៨ ថ្នាក់ ១ ដើមជាក់ត្រង់
ផ្ទៃតកូមិ, ហើយអាចារ្យសូត្របូជា មានតែចែង ៥ ជួនទៅគ្រប់ទិស ហើយ
អាចារ្យសូត្រមន្តប់ស្តីតី សរព្រះនាកយណ៍មហាសម្បុរ ទើបអាចារ្យ
ចោះគោលធំ ១ កណ្តាលផ្ទៃតកូមិ, មើលតាមនាមវត្ត បើវត្តមាននាមដូច
ម្តេច ដូចជាវត្តបានយនេះជាដើម ត្រូវយកអក្សរខាងចុង ព្រោះមនុស្ស
ប្រុសយកដើមអក្សរ, មនុស្សស្រី ស្រុក កូមិ នគរ យកចុងអក្សរវិញ,
ឧបមាដូចមនុស្សប្រុសឈ្មោះ នយ ត្រូវយកអក្សរ ន ខាងដើម; ចុះដូចជា
ស្រី ឬវត្ត កូមិត្រូវយកអក្សរខាងចុងគឺអក្សរ យ ហើយមើលថាវត្តនេះ
ត្រូវនាមអក្សរ យ, អក្សរ យ ត្រូវនាមអ្វី ជានាមដំរី ។, មូលនៅទិសណា
ថានៅទិសអគ្នេយ៍, ឲ្យរាប់តាំងទិសអគ្នេយ៍ជាដើមថា មូល, ឧស្សាហ៍,
មន្ត្រី, តាឡកណ្តី, បរិវារ, គាយុ, តេជះ, សីរី ។ ត្រូវដាក់ផ្លូវត្រង់ បរិវារ
ឬតេជះសីរី ជានាំងអស់ រៀងតែតាឡកណ្តី, ឯតាឡកណ្តីសំពាប់សង

បង្គន់, មូល សង់សាលាដំនុំ, តេជៈ សង់ហោរ៉ែត, មន្ត្រី សង់ក្នុងដៅ ចៅអធិការ, សិរី សង់ព្រះវិហារ ។

ឯព្រះវិហារបានជាប្រែមុខទៅឯកើតនោះ ព្រោះធ្វើតាមបវរណៈព្រះពុទ្ធដែលបានត្រាស់ដំបូង គេឃើញតែឆ្ពោះព្រះភក្ត្រទៅទិសឯកើត, ហើយទិសឯកើតនេះ ជាលំនៅដើមរបស់ព្រះអាទិត្យ តែងគោចរពីទិសឯកើតទៅឯលិចតាំងពីដើមរៀងមកជាដរាប ។ ព្រះវិហារបានជាមានរូបនាគជាសត្វតិរច្ឆាននៅចាំងលើនោះ គឺធ្វើតាមរឿងកាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទើបបានត្រាស់ថ្មីៗទៅគង់នៅមុដលិន្ទសែះ ភ្លៀងបង្អុរចុះ ៧ យប់ ៧ ថ្ងៃលិចផែនដី ទើបស្តេចនាគទៅធ្វាយរង្វេលធ្វើជាបល្ល័ង្កលើកពពារខ្បែងចាំងភ្លៀងកុំឲ្យទទឹកព្រះអង្គ បានជាជាប់ទំនៀមទំលាប់ពីនោះមក ។ សេចក្តីនេះតាមមតិរបស់ខ្ញុំយល់ឃើញតាមគម្ពីរបឋមសម្ពោធិ ។

ឯពិធីដែលកសាងព្រះវិហារដំបូង មេជាងបង្គាប់ឲ្យរៀបរណ្តាប់ព្រះពិស្ណុការមានក្បាលជ្រូក ១ គូ, ឋវង្គម ៨, ចំអាម ៨, ស្វាធម៌ ៨, ផ្តិលទឹក ៨, សំពត់ផ្ទាត់ ៨, ច្រាក់ ៨ រៀល, ស្រវ ១ កន្ទាំង, ជម ៤, អង្ករ ១ ថាម, ខ្ញែន ១ ដើម, សំពត់ស ៥ ហ័ត្ត, ខ្ញែន ៥, ធូប ៥, លាជផ្កាស្វាចារ ៥ ។ ដូចគ្នា. ប្រមូលចាស់ព្រឹទ្ធាចារ្យមកដុំហើយអុជខ្ញែនធូបសំបូងសង់ប៉ែនថា "ឧតេជតេជៈ ថ្ងៃនេះថ្ងៃជាតេលាស្អ ព្រះភូមិព្រះការព្រះធរណីម្ចាស់ទឹកម្ចាស់ដីព្រះពិស្ណុការ ព្រះចារមីសូរ ដ្បិតយើងខ្ញុំទាំងអស់គ្នាកសាងព្រះវិហារថ្មី សូមព្រះពិស្ណុការព្រះចារមីសូរដួយការខ្នងរងមុខ ឲ្យជាង

ធ្វើការនេះកុំឲ្យបែកដៃបែកជើង ទូលបង្គំនឹងសុខចំរើនគ្រប់ប្រការ" លុះប្តីនិងប្រពន្ធគ្រប់ ៣ ដងហើយសេដ្ឋីក្រោកឡើង ក៏យល់ច្បាស់ដូចជាវាដុតក្រដាសគ្រប់ហើយ ទើបអាចារ្យគាត់ទូលទៅអង្គុយកណ្តាល សូត្រអញ្ជើញព្រះពិស្តារថា អុំ ធម្មំ សង្ឃំ ឯវំ ច យោ សោ ពិស្តារកោ នោ ឯវំ បុព្វបការណំ សព្វត្ថាញ្ជេ ំ ប្ញដាមិ ។ ៣ ដង ។ ហើយសូត្រអញ្ជើញព្រះពិស្តារ សូត្រថ្វាយបាយព្រះពិស្តារ ។ ឯធម៌ទាំងអស់នេះ ខ្ញុំមិនបានយកមកអធិប្បាយក្នុងទីនេះទេ ព្រោះសេចក្តីនេះវែងពេកនាំឲ្យខាតពេលវេលា ។ ឯប្រជាប់ពុំការ ទំនងធម៌សូត្រអញ្ជើញព្រះពិស្តារ ដូចបានរៀបរាប់មកខាងអស់នេះ ខ្ញុំបានដឹងអំពីសំណាក់លោកគ្រូព្រះសិរីវង្ស វត្តពោធិភមា នាមឡុង មេគណស្រុកកោះធំ ខែត្តកណ្តាល លោកបានតត់ជារបៀបឲ្យខ្ញុំធ្វើអាចារ្យទុកសំរាប់តទៅ ។

តិឆបញ្ចុះសីមា

អំពីនេះ ទំនងអធិប្បាយអំពីរឿងបុណ្យបញ្ចុះសីមាសំរាប់ព្រះសង្ឃធ្វើសង្ឃកម្មផ្សេង ។ តាមដែលខ្ញុំបានឃើញផ្ទាល់ខ្លួន ។ ទំនៀមទម្លាប់ដែលធ្លាប់ឃើញអាចារ្យជាន់ចាស់ប្រាប់ផ្តែ ។ មកគឺដំបូងគេទៅរកទិញថ្ម ឫសសីមាទំនងស្មើកសីមាដែលជាដីរបស់ស្រែច ចំនួន ៩ ដុំ មានទំហំមិនធំមិនតូច ទម្ងន់ប្រហែល ២ ហាប ហើយដង្ហែនាំទៅទុកក្នុងទីព្រះវិហារ ទើបប្រជុំគ្នាជា ៩ ក្រុមដើម្បីចាប់ឆ្នោតរើសរកអាចារ្យ ៩ នាក់ ជាអ្នកអង់អាច

ឈ្មោសក់ងវៃ ធ្វើឆ្នោត ៩ ក្នុងសេចក្តីឆ្នោតដាក់ថា ទិសបូព៌, អគ្នេយ៍, ទក្សិណ, និរតី, បស្ចិម, ពាយ័ព្យ, ឧត្តរ, ឦសាន, ឥន្ទកីល ។ ប៉ើ អាចារ្យណាចាប់ត្រូវទិសណា អាចារ្យនោះត្រូវរៀបគាំងពិធីទិសនោះ; ប៉ើ អាចារ្យណាចាប់ត្រូវឥន្ទកីលត្រូវលើកអាចារ្យនោះជាធំ ជាចាងហ្វាងត្រួត គ្រាការខុសត្រូវក្នុងបុណ្យគាំងអស់ ។ លុះចាប់ឆ្នោតរួចស្រេចហើយ អាចារ្យគាំង ៩ នាក់ដំនុំគ្នាពីទេយ្យទានអ្វីខ្លះសម្រាប់ប្រគេនដល់លោក សង្ឃមួយអង្គ។ ។ លុះដំនុំមូលមាត់គ្នាហើយអាចារ្យធំសម្រេចសេចក្តីថា បើលោកអាចារ្យណាគិតប្រដាប់ចាន់ប៉ុន្មាន ត្រូវនិមន្តលោកប៉ុណ្ណោះអង្គ តាមប្រដាប់ចុះ, ហើយដីករណ្តៅគ្រប់ទិសតាមទិសដែលខ្លួនត្រូវឆ្នោត, រួចយកអំបោះចងស្រោកឫសសីមាសិកឈើឲ្យបន្តោកនៅមាត់រណ្តៅហើយ រៀបគ្រឿងសក្ការៈបូជាតាំងនៅបៀតមាត់រណ្តៅតាមទិសរៀងខ្លួន ។ លុះដល់ពេលល្ងាច ប្រជុំនមស្សការនិមន្តលោកចំរើនត្រៃបិដកគ្រប់ទិ.ប ហើយអាចារ្យធំមើលឫក្សពារវេលា តាមពេលសុរិយៈ ដូចចាន់រៀបរាប់ ជាសង្ខេបខាងក្រោមដូច្នេះ : សូរិយៈ, សុក្រៈ, ពុធៈ, ចន្ទោ, សោរោ, គារុ, កុម្ភៈ ។ តាំងលេខ ៣ ដូរួចដាក់តេលថា : ព្រឹកឥន្ទ្រីតូច, ឥន្ទ្រីធំ, ខៀបត្រង់, រសៀលតូច, រសៀលធំ, ឥន្ទ្រីកុំ, គោប្លួលក្រោល ។ ល្ងាច ហើយឫក្សចាន់ប៉ុន្មានត្រូវគ្រាខុក ហើយយក ៣ គុន ៧ ហា, ចាន់ម៉ត្រ តេលណា ទើបអាចារ្យធំច្រាប់ថាថ្ងៃនេះ តេលមាំងប៉ុណ្ណោះត្រូវចាំស្តាប់

សូតេងឯកអន្ទង ដល់អន្ទងបង្ហើយឲ្យកាត់ឫសសីមាទំលាក់ឲ្យស្រុះព្រមគ្នា កុំឲ្យចាញ់មួយ ។ , ហើយអាចារ្យធំប្រាប់ថាបើលោកគ្រូធំជាចៅអធិការ ត្រូវធ្នាំកំណើតឬត្រូវឡាក់ហ្មិយឆ្នងលើថ្ងៃខន្ធកំណើត ដល់ពេលកាត់ ឫសសីមា និមន្តថយចេញឲ្យផុតសូតេងស្តារដើម្បីកុំឲ្យចាញ់មេវត្ត តាម ទំនៀមទំលាប់រៀង ។ មក ។ រឿងនេះខ្ញុំបានឃើញចាស់ទឹងក្នែក កាលបញ្ជុះសីមាវត្តព្រៃធ្លាំ ឃុំព្រៃផ្តៅ ស្រុកព្រៃតឃ្មាស ខែត្តតាកែវ លោកគ្រូចៅអធិការវត្តនោះ នាម ជា; ដល់ពេលទឹងកាត់ឫសសីមាស្រាប់ តែលោកគ្រូនោះកៀសខ្លួនគេចបាត់ដោយខ្លាចចាញ់ លុះដល់ព្រឹកឡើង ល្ងាមពេលធាន់ព្រឹកក៏មិនឃើញលៃចូលមកវត្តវិញ លុះបាត់ដល់ថ្ងៃពេក ទើបកូនសិស្សយកចង្ហាន់ទៅប្រគេន ដើរតាមរកទំពាំឃើញក្នងព្រៃស្ទើរតែ ហួសពេលធាន់ លុះដល់ឆ្នងបុណ្យរួចទើបហ៊ានទិមន្តចូលមកវត្តវិញ ។

ខ្លាចយ៉ាងនេះជ្រុលពេក, កាលបុណ្យសីមានោះ ខ្ញុំបានធ្វើជាអាចារ្យ សមន្តកែធំជាងគេ តែនៅតាន់តាមទំនៀមទំលាប់ ។ រឿងនេះមាន លោកគ្រូព្រះបពុមសីលាចារ្យមេគណស្រុកព្រៃតឃ្មាស នាម សួស ១ លោកគ្រូសីរីវង្សវត្តគោធិកមា នាម ឡង ១, លោកគ្រូចាន់ លាង វត្តសំប៉ាន់ស្រុកកោះធំ ១ ទាំង ៣ អង្គនេះបានទិមន្តទៅបុណ្យ ធ្វើជា អធិបតី បានជ្រាបច្បាស់ច្បាកដងង ។

រឿងព្រៃងប្រៃទេសរ៉ូម៉ានី

លោក ផេង - ជ្រៃ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ

ប្រែជាភាសាបារាំង

ក្នុងកាលដ៏កន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គមានឈ្មោះមិនប្រាកដ ខ្ញុំទស្សពិធរាជធម៌ ខ្ញុំមានព្រះរាជបុត្រាបីព្រះអង្គ ។ ដរៃអំពីកុសលកម្មដែលខ្ញុំតែងប្រទានចំពោះអាណាប្រជានុរាស្ត្រក្នុងព្រះនគរព្រះរាជាខ្ញុំកសាងព្រះវិហារមួយ ដែលល្បីឈ្មោះរន្ធឹសុះសាយដល់ទីឆ្ងាយ ។ ព្រះរាជាខ្ញុំធ្វើលំអព្រះវិហារនោះដោយមាសដោយត្បូងពេជ្រ ដោយវត្ថុអ្វីដែលជាឯកក្នុងព្រះបុរីនិយមថាប្រសើរថ្លៃថ្លាបំផុត ។ សសរនៃព្រះវិហារទាំងខាងក្នុងទាំងខាងក្រៅ សុទ្ធសឹងជាវិការៈនៃថ្មតែស្រោបមាស ។ គ្រឿងចម្លាក់យ៉ាងប្រសើរ ប្រដាប់ខ្ចប់ឆ្អឹងដ៏រលើបចឆ្អឹងជាច្រើនដែលសម្រាប់អុជជាអចិន្ត្រៃយ៍ជាវិការៈនៃធូបក់សុទ្ធ, គម្ពីរធម៌ដ៏ប្រពៃពុកជាក់យ៉ាងរៀបរយ,វត្ថុទាំងនេះពុកជាសម្បត្តិនៃព្រះវិហារ ។ ព្រះរាជាតែងមានព្រះហឫទ័យរីករាយយ៉ាងក្រៃលែង ព្រោះខ្ញុំតែងឃើញព្រះវិហារល្អអស្ចារ្យនេះ, ប៉ុន្តែខ្ញុំត្រួយព្រះហឫទ័យមួយយ៉ាង ដោយការមិនអាចនឹងបង្កើយនូវព្រះវិហារនោះ ព្រោះតំបូលស្ងួចខាងលើកាលណាធ្លាក់ហើយចេះតែបាក់ធ្លាក់ចុះមកវិញជានិច្ច ។

ថ្ងៃមួយ ព្រះពាជាខ្ញុំត្រេតម្រិះថា "អញប្រហែលមិនអាចនឹងបង្ហើយព្រះវិហារនេះទេដឹង? ខ្ញុំឮសម្បត្តិរបស់អញទាំងអស់ចំណាយទៅក្នុងព្រះវិហារ, ឥឡូវព្រះវិហារនៅតែធ្វើមិនហើយ" ។

រួចព្រះអង្គបង្គាប់ឲ្យគេប៉ាតង់យោសនាក្នុងព្រះនគរថា "បើជាងណាចេះ អាចបង្ហើយកំពូលព្រះវិហារនោះបាន ព្រះអង្គនឹងប្រទានរង្វាន់យ៉ាងស្កុកស្កម្ភ ហើយនឹងបញ្ចូលជាងនោះក្នុងក្រសែនៃព្រះរាជ្យផង" ។ ក្នុងថ្ងៃជាមួយ ខ្ញុំបង្គាប់ឲ្យប្រជាពលស្តុកស្តូកតមិត្រប់ត្រួ ហើយឲ្យធ្វើបុណ្យផង ដើម្បីបន់ព្រះជាម្ចាស់ឲ្យជួយបញ្ជូនជាងយ៉ាងឆើតមក តាមសេចក្តីត្រួយនឹងសេចក្តីអង្វរបស់ខ្ញុំ ។

លុះកន្លងមក ក្នុងយប់ទី ៣ ព្រះពាជាខ្ញុំសុបិនថា: បើប្រសិនជាអ្នកណាមួយអាចទៅយកបក្សីខ្ញីឯត្រើយសមុទ្រម្ខាងបាន ហើយយកសត្វនុ៎ះទៅឲ្យនៅត្រង់កំពូលព្រះវិហារ១ នឹងឈប់រលំ ។ លុះខ្ញុំតើនពីដំណេក ព្រះពាជាបានថ្វាយសុបិននិមិត្តនោះប្រាប់ព្រះពាជបុត្រទាំងបីព្រះអង្គ ដើម្បីពិសោធមើល តើព្រះពាជបុត្រអង្គណានឹងជួយយកអាសាព្រះអង្គ ហើយនឹងចេញទៅស្វែងរកបក្សីខ្ញីមុនគេបង្អស់? ។

ព្រះមហាក្សត្រ មានព្រះពាជឱង្ការថា: "ម្នាលបាទាំងឡាយ, បិតាយល់ឃ្លាសុបិនថាអ្នកទាំងបីមានបំណងនឹងបំពេញនូវកណ្តាលក្នុងចំពោះព្រះជាម្ចាស់ ប៉ុន្តែអ្នកទាំងបីមិនត្រូវចេញទៅស្វែងរកតែម្តងស្របគ្នាឡើយ;

គឺត្រៃកូនច្បងចេញទៅរកមុន បើកិច្ចនោះមិនសម្រេច ជាការកូនទី ២ ចេញទៅម្តង យើងធ្វើបន្ទាប់ៗ គ្នាដូច្នេះតទៅ លុះត្រាតែព្រះជាម្ចាស់មេត្តាជួយយើង” ។

ព្រះពោធិសត្តបានទទួលព្រះពុទ្ធដីការនៃព្រះបិតា ឥតមានយល់ទាស់ហើយ ព្រះពោធិសត្តច្បង ជាបឋម ចាប់រៀបប្រដាប់ប្រដាំនៃដំណើរ ។ ព្រះអង្គម្ចាស់បង កំធ្វើដំណើរចេញទៅ ហើយឈប់សម្រាកព្រះកាយក្នុងព្រៃមួយនៅក្បែរមាត់ស្រែមួយដ៏ស្អាតត្រជាក់ ខាងក្រោយដែលឃ្លាន ដើរត្រេច ទឹង ធ្វេងកាត់ដែនសីមាមាតុភូមិជាយូរអង្វែងវែង ។ លុះដែលព្រះអង្គម្ចាស់អង្គនេះកំពុងតែបង្គាត់ភ្លើងដើម្បីចំអិនព្រះក្រយាស្ងោយ ទ្រង់ឃាត់ឃើញក្រញ្ជោងតូចមួយមិនដឹងលេចចេញពីទីណាមកមួយរំពេច រាអង្វរសុំកុំឲ្យទ្រង់លែងឆ្កែទៅឲ្យដេញវា ហើយសុំឲ្យទ្រង់មេត្តាបានទំប៉ុងមួយដុំ ស្រាមួយតែវ៉ា ទាំងសុំឲ្យគាណិតនៅជ្រកកំដៅខ្លួនក្បែរភ្លើងផង ។ ព្រះពោធិសត្តមានទទួលធ្វើតាមសេចក្តីអង្វរ បែរជាលែងឆ្កែឲ្យទៅដេញក្រញ្ជោងនោះវិញ ។ ខណៈនោះ សត្វក្រញ្ជោងធ្វើសញ្ញាមួយស្រាប់តែព្រះពោធិសត្តមានក្តាយខ្លួនទៅជាដុំថ្មភ្លាម ។

ព្រះពោធិសត្តដឹងថាព្រះពោធិសត្តច្បងពុំយើញត្រឡប់មកវិញ ទ្រង់បណ្តាយឲ្យព្រះពោធិសត្តទីពីរ ធ្វើដំណើរចេញទៅម្តង ។ ព្រះពោធិសត្តទី២នេះ លុះស្តេចទៅដល់កន្លែងដែលត្រង់ដង្ហក់ក្តាយខ្លួនជាថ្ម

កាលណា ខ្ញុំទទួលបង្គាប់គ្រានេះដូចព្រះរៀមដែរ ដោយហេតុចង់បានស្បែកកញ្ជើង ហើយមិនព្រមទទួលយកសេចក្តីអង្វរបស់ក់ ។

ព្រះពាជាខ្ញុំព្រួយព្រះពាដប្លែកណាស់ ព្រោះខ្ញុំឃើញកាលវេលាចេះតែកន្ទុំទៅ ហើយមិនឃើញកូនណាមួយបានបក្សីទិព្វត្រឡប់មកវិញ ។

ថ្ងៃមួយ ព្រះពាដបុត្រៈក៏ក្រាបបង្គំទូលព្រះពាដបិតាថា: "បពិត្រព្រះអង្គដ៏ខ្ញុំឧត្តមយស ! ព្រះរៀមទាំងពីរព្រះអង្គ ស្តេចយាងចេញទៅស្វែងរកបក្សីទិព្វកន្ទុំមកអស់កាលជាយូរឆ្នាំហើយ តែឥឡូវពុំឃើញស្តេចយាងត្រឡប់មកវិញសោះ មិនដឹងជាព្រះដង្កាបានសេចក្តីសុខទុក្ខយ៉ាងណា; បើដូច្នេះ សូមព្រះអង្គខ្ញុំព្រះមេត្តាប្រោស ប្រទានច្បាក់ដល់ខ្ញុំព្រះបង្គំៗ នឹងយកទៅទិញប្រជាប់ប្រជា នឹងធ្វើដំណើរចេញទៅស្វែងរកម្ចាស់ដើម្បីជួនព្រៃឆ្ងាយនាលមើល បើខ្ញុំព្រះបង្គំចេញទៅស្វែងហើយរកបាន នោះព្រះអង្គសមនឹងមានព្រះហឫទ័យរីករាយដោយហេតុតែបំណងរបស់ព្រះអង្គបានសម្រេច; បើព្រះអង្គមិនព្រមអនុញ្ញាតទេ, ខ្ញុំព្រះបង្គំនឹងមានក្តៅឈ្នោះមិនប្រសើរឡើយ" ។

ព្រះពាជាមានបន្ទូលតបមកវិញថា: "ម្នាលបា ! ព្រះរៀមរបស់អ្នកមិនទាន់ឃើញត្រឡប់មកវិញ ប្រហែលអ្នកទាំងពីរនោះដល់នូវសេចក្តីវិនាសវៀងខ្លួន ដោយការចំប្រឹងរកបក្សីទិព្វដ៏អស្ចារ្យ, ឯងឃើញឬទេ?

គេទៅអស់អំឡុងយូរណាស់ហើយ ។ មិនឃើញអ្នកណាមួយត្រឡប់មកវិញសោះ! ឥឡូវបិតាចាស់ហើយ, បើបាឯងចេញទៅទៀត តើនរណានឹងនៅជួយចាត់ចែងការពារក្នុងព្រៃនេះ! បើប្រសិនបិតាទៅផ្តួតទៅតើអ្នកណានឹងគ្រងរាជ្យស្នងបិតា, ម្ចាស់ក្លូនសម្លាញ់បិតា! ណ្លើយចូរនៅក្នុងព្រៃនេះហើយ កុំចេញទៅអី" ។

ព្រះរាជបុត្រទៅទូលស្នងវិញថា: "បពិត្រព្រះរាជបិតាដ៏ជាកំពូលកត! ព្រះអង្គតែងទ្រង់ជ្រាបមកហើយថា: ទូលព្រះបង្គំមិនដែលធ្វើអ្វីជាបទដំទាស់ឲ្យឃ្លាតចាកព្រះរាជទ្រព្យរេ ចុះហេតុអ្វីថ្ងៃនេះ ទូលព្រះបង្គំទទូចសុំ គឺថាទូលព្រះបង្គំមានបំណងនឹងបំពេញកិច្ចព្រះអង្គ ដោយអានុភាពនៃទូលព្រះបង្គំ តាមព្រះរាជបំណងដែលចេះតែធ្វើជូនព្រលឹងព្រះអង្គមិនឲ្យនៅសុខសម្រាន្ត ហើយដែលតាំងពីប៉ុន្មានឆ្នាំមកហើយ ទ្រង់បានចំណាយអស់ទ្រព្យជាច្រើន ឥតប្រយោជន៍ ។

ដោយសេចក្តីអង្វរនឹងការទទូចសុំខ្ញុំឯពេក ព្រះរាជាក៏ទ្រង់យល់ព្រមបើកឲ្យទៅ ។ ព្រះអនុជាយកសេះយ៉ាងចំណានទឹងត្បូងមួយទៅផងធ្វើជាគូកន យកស្បែងយ៉ាងបរិបូណ៌ ហើយទ្រង់ធ្វើដំណើរចេញទៅ ។

លុះកាលកន្លងទៅមិនយូរប៉ុន្មាន ព្រះរាជបុត្រច្បងតាំងពីក៏យាងត្រឡប់មកវិញ បាននាំបក្សីទិព្វមក ព្រមទាំងស្ត្រីម្នាក់មកផង ដែលគេ

ខ្ញុំតទៀតនៅធ្វើជាអ្នកបាំងរាំ ព្រះឥសិទាន ។ ប្រជាពលស្ត្រីគ្រប់គ្នាតែងស្ងើចសរសើរខ្លួនលំអដ៏ប្លែកប្លំភ្ញាចពណ៌ប្លែកៗគាន់មួយទៅក្នុងពេលហ្នឹង ហើយក៏ចាំងផ្លេកៗ ដូចជាអគ្គិនីមុខចាំងត្រង់ខ្ញុំ ; ចំណែកកំពូលព្រះវិហារក៏លែងចាក់ឆ្នាត់ចុះមកគ្រាម សត្វបក្សីទិព្វ ធ្វើសំបុកនៅលើកំពូលវិហារនោះ ។ ប៉ុន្តែមិនយូរប៉ុន្មាន គេសំគាល់ឃើញថា សត្វបក្សីនោះហាក់ដូចជាសត្វគ ឥតមានដែលឮសំឡេងរាសោះ ឃើញល្អតែពេលស្ងាប តែងសំឡេងតិរេះគ្មានឮ ។ អ្នកណាដែលបានឃើញបក្សីនោះតែងតែព្រួយឆ្ងល់អំពីការនេះ, សូម្បីព្រះរាជាឯង ទោះបីមានព្រះហឫទ័យតែងយកដោយឧត្តមលំពូលនៃព្រះវិហារបានសង់ហើយស្រេចក៏នៅព្រួយព្រះហឫទ័យតែងមិនបានព្រះសណ្តាប់ខ្ញុំសំឡេងរបស់បក្សីទិព្វ ។

អ្នកស្រុក អ្នកនគរាំងឆ្ងាយ សព្វាយតែងយកដោយការតែងបានបក្សីទិព្វ ទាំងឃើញព្រះវិហារកេសៈងហើយ ក៏ក្តេចគិតដល់ព្រះអាណុជ៧ ។ ចំណែកតែព្រាហ្មណ៍ ខ្ញុំមិនក្តេចព្រះពាជ្ញបុត្រៃរបស់ព្រះអង្គសោះ ខ្ញុំមានព្រះហឫទ័យព្រួយតែមួយព្រះអង្គឯងឯណ៎ាងស្ងាត់ ព្រោះចាត់តុំឃើញព្រះរាជបុត្រៃណាឯទៀតមកសោះ ដើម្បីនឹងបានចែកសេចក្តីតែកយគ្នា ។

(មានត)

La Lumière de l'Asie

លោកស៊ីរ - អេតវ៉ាំងអារណ្ណលដ៏ តែង

លោកវ៉ាយ - ប៊ីត គ្រមការ ប្រែរៀបរៀង

(១៥ក)

ព្រះពោធិសត្វទ្រង់ស្តេចមកដល់ទីក្រុងជាមួយនឹងពួកមេសចាល់អ្នកគង្វាលពពែ (bergers) នៅពេលសាយណ្ហសម័យដែលព្រះសូរ្យាកំពុងចាំងរស្មីជាអវសាន ធ្វើឲ្យទឹកស្ទឹងសោណៈ (Sona) មានសម្បុរគ្រហម់ផ្នែដូចជាសុវណ្ណពណ៌ ហើយធ្វើឲ្យប្រថពីមានស្រមោលងងឹតដោយសាសពេញវិថី, មាត់ក្លោងទ្វារព្រះពជ្រាំងមានឥហានក្បាព្រះអង្គយាមល្បាតនៅទីនោះ។ តែឥហានទាំងនោះដល់ឃើញព្រះពោធិសត្វបីកូនចៀមដូច្នោះ ក៏ថយចេញដោយគោរព, ពួកប្រជាជនដែលនៅផ្សារចូលរៀបចំយានដំនិះជាដួរហែនៅតាមពាណិជ្ជដ្ឋាន, ពួកអ្នកលក់នឹងអ្នកទិញឈប់តវ៉ាទំនិញ ហើយក្រឡេកមើលព្រះកិត្តិព្រះពោធិសត្វដែលមានតេជានុភាពគួរគោរព, ពួកអយការ "ជាងដែក" (forgeron) ដែលកាន់ញញួរនៅដៃលើតឡើងទៅជាស្រឡាំងកាំងឈប់ឥឡូវដែក, អ្នកត្បាញសំពត់លះបង់ចោលសរសៃអំបោះ, អ្នកចារ (សរសេរ) សាស្ត្រាបោះបង់ចោលក្រដាស, អ្នកជួរបុំយវត្តុយកតម្លៃឈប់តំតណាខាង

ចំណែកឯឫទ្ធាភិសង្ខារនៃព្រះសារីៈ បរិភោគស្រូវដែលគ្មានអ្នកណាមើលថែទាំ, ឯបាន់ដែលដាក់ទឹកដោះគោរលំតាប់ហូរទឹកដោះគោចេញអស់, ឯអ្នកលក់ទឹកដោះគោបានរត់ទៅមើលព្រះពោធិសត្វកំពុងតែចតាមផ្លូវគ្នា ដែលមានព្រះចរិយាស្ងៀមស្ងាត់ស្ងៀមស្ងំ ហើយមានព្រះដំណើរគួរឲ្យគោរពគួរឲ្យកោតក្រែង ។ មានពួកស្ត្រីប្រជុំគ្នាទៅមាត់ទ្វារសួរគ្នាថា "អ្នកនេះជាអ្វី? ដែលមកធ្វើពលីកម្មដោយមានចិត្តគួរជាទីទស្សនាម្ល៉េះ ពន់ពេក ហើយកាលត្រែចទៅទីណា មានមនោតតិផ្សាយដុំវិញ ន្លូវសេចក្តីសុខសប្បាយស្រួលម្ល៉េះ, តើអ្នកនេះចូលកន្លែងអ្វី? ហេតុម្តេចបានក្តៅក្រហាយដ៏អ្វីម្ល៉េះ? ឬហៃលជាពួកសក្រៈ[1] ឬជាទេវតា[2]?" ។ នាងខ្លះតបថា "នេះជាសេខបុគ្គលដែលទៅជាមួយនឹងពួកឥសីលើភ្នំ" ។ ចំណែកព្រះពោធិសត្វទ្រង់យាងផុតទីនោះដោយមានព្រះទ័យចុះស្ងប់ទៅក្នុងសមាធិ ហើយព្រះអង្គទ្រង់ពិចារណាកន្លែងព្រះទ័យថា "នុចៀមរបស់អាត្មាអញ បន្តិចទៀតគ្មាននាយមេស-ចាលថែរក្សាទេ, ចៀមទាំងនោះធ្វើដំណើរទៅកន្លែងវាលាយប៉ន្មានគ្មានមគ្គទេសក៍ទេ ហើយនឹងវង្វែកយំវង្កែង ។ ដើរចូលទៅដិតគាំបិតនៃស្តេច

---

១ សក្រៈ បើតាមភាសាមគធៈថា សក្កៈ ឬសក្យ. "ព្រះឥន្ទ្រឬអមនុស្ស" ។

២ ទេវតា: ស្តេចនៃទេវតា ។

មច្ចុរាជ ដូចជាមនុស្សនឹងសត្វតិរច្ឆានដែលឈរឥតនិយាយស្តីនៅទីនេះ ដែលជាបងប្អូនញាតិនឹងគ្នាដូចនោះ" ។

ខណៈនោះ មានមនុស្សម្នាក់ចូលទៅក្រាបបង្គំសួរព្រះមហាក្សត្រិយ៍ថា "មានលោកសង្ឃធុតង្គមួយអង្គនិមន្តមកដល់ទីនេះ ជានាំហ្វូងគ្រឿងដែលព្រះអង្គមានព្រះទុក្ខារ ដើម្បីនឹងយកមកធ្វើពលិកម្ម" ។

ព្រះមហាក្សត្រិយ៍ទ្រង់គង់នៅកន្លែងដែលធ្វើមហាយ័ញ្ញ, ពួកព្រាហ្មណ៍ស្វែកតាក់អាវវែងពណិសឈរអមព្រះអង្គ សូត្រធម៌"មន្ត្រា" (man-tras) ហើយដុតភ្លើងឲ្យឆេះនូវបូជនិយដ្ឋាន, កណ្តាលកន្លែងនោះអណ្តាតភ្លើងឆាបឆេះចេញពីឈើក្រអូបឬសរស់ដូចគេហួច ហើយឥតពន់ពេនបត់បែនដូចជាគេលិទ្ធដង្វាយបូជាមានទ្វាញ់ គ្រឿងអលង្ការផ្សេងៗនឹងព្រះទុទកៈសូមា" (๑) ដែលព្រះឥន្ទ្រាធិរាជសព្វព្រះទ័យបំផុត ។ នៅជុំវិញបូជនិយដ្ឋាន, មានទឹកស្ទឹងមានសភាពក្រាស់ៗ មានពណ៌ក្រហមឆ្អៅ មានពពុះផុះខ្ចោល ។ ហូរចូលទៅក្នុងដីខ្សាច់ ហើយមានជានិច្ច; ទឹកនោះគឺជាឈាមសត្វដែលគេយកមកពិឃាតធ្វើពលិកម្មនោះឯង ។

(មានត)

---

๑ សូមា (Soma) រុក្ខជាតិនៅក្នុងក្រុម (Asclépiades) ជារុក្ខជាតិមានរោមដុះចេញពីគ្រាប់ ហើយមានទឹកដែលហើយកមកលាយគ្រាប់ថ្នើ ខឹងទឹកដោះគោខាប់ថ្នា យកទៅចំរាញ់ធ្វើជាថ្នែងមួយបែប ថ្នែងនោះគេអុជមានសភាពធ្វើឲ្យស្រឡាំងចិត្ត គឺជាថ្នែងសម្រាប់ប្លូជាព្រះឬទេវតាព្រហ្ម ។

ព្រះវត្តមុនី យ៉ូរ - ប៉ុណ្ណា

ក្រមជំនុំព្រះគ្រូបឋមនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការបំពោះព្រះគតវន្តមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ និងស្រង់យកពាលធម៌ដែលព្រះសម្ពុទ្ធជាបរមគ្រូយើងសំដែងទុកក្នុងសុត្តន្តបិដក មកអធិប្បាយជាផ្លូវធម៌ខ្លះ ផ្លូវលោកខ្លះ តាមសមគួរដូចតទៅនេះ ៖

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងលោកនេះ សុទ្ធតែមានកិច្ចការគួរប្រែកបឬគួរប្រែតិបត្តិ ដែលជាផ្លូវធម៌ផ្លូវសាសនា ឬក៏ផ្លូវលោក ។ ឯកិច្ចការដែលគួរប្រែកបគួរប្រែតិបត្តិនោះ មានច្រើនស្ថានគឺតូចខ្លះ ធំខ្លះ ថោកខាបខ្លះ ទត្តមខ្លះ លំបាកខ្លះ ងាយខ្លះ ។ អ្នកប្រែកបកិច្ចការគ្រប់ចំពូកនោះ ត្រូវការស័យកំឡាំងជាប្រមុខ, បើមិនមានកំឡាំងហើយពុំអាចនឹងប្រែកបកិច្ចការនោះ ។ ជានឡើយ ។ កំឡាំងនេះជាធម្មជាតិសំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ

បុគ្គលគួរខំនុកបំរុងរក្សាកំឡាំងកាយឲ្យរឹងប៉ឹង សម្រាប់ប្រកបកិច្ចការតាមនាទីរបស់ខ្លួន ។ កំឡាំងកាយជាធម្មជាតិសំខាន់ក៏ពិត ប៉ុន្តែបើមិនហ៊ានកំឡាំងចិត្តដួយអម្បង កិច្ចការនោះៗ ក៏មិនបានសម្រេចប្រយោជន៍ដ៏ធំធ្ងាយប៉ុន្មាន ព្រោះកំឡាំងកាយនឹងកំឡាំងចិត្តគាំងពីរនេះអាស្រ័យគ្នាខ្លះណាមួយពុំបាន បើមានត្រប់លក្ខណៈគាំងពីរស្មើនក្នុងបុគ្គលណាហើយ បុគ្គលនោះទើបមានសមត្ថភាពអាចបំពេញប្រយោជន៍សព្វគ្រប់បាន ។

មួយទៀត ចិត្តនេះបើមិនបានទទួលការអប់រំសេចក្តីល្អទុកទេ ក៏មិនមានគោលអ្វីដ៏សំខាន់ជាគ្រឿងខំនុកបំរុងកាយ ឬ ឥស្សរភាពបានឡើយ ។ បុគ្គលដែលនឹងឡើងទៅកាន់ឋានខ្ពស់បាន ក៏ព្រោះអាស្រ័យការអប់រំចិត្តគំនិតឲ្យប្រព្រឹត្តទៅក្នុងផ្លូវល្អ ប្រកបដោយប្រាជ្ញាដឹងច្បាស់ថែសេរកផ្លូវគួរនឹងផ្លូវមិនគួរ ឲ្យសមតាមគាលៈទេសៈ; បើបណ្តែតបណ្តោយទៅតាមទំនើងចិត្តហើយ មុខជាសេចក្តីអាក្រក់ធំៗពាំទំលាក់ទៅកាន់ទីថោកទាបពុំខាន ។

បុគ្គលដែលមានចិត្តអប់រំល្អហើយ រមែងនាំសេចក្តីល្អមកដល់ខ្លួនគឺល្អជាងសេចក្តីល្អដែលមាតាបិតាញាតិមិត្រចង់ប្អូនផ្តត់ផ្តង់ឲ្យទៅទៀត ។ ប៉ុន្តែចិត្តប្រាសចាកសេចក្តីអប់រំហើយក៏រមែងនាំឲ្យកើតសេចក្តីវិនាសផ្សេងៗ ។

មួយវិញទៀត ការដែលនឹងអប់រំចិត្តឲ្យមានកំឡាំងក្លាហានគួរដល់ការងារនោះ ត្រូវអាស្រ័យសេចក្តីអប់រំតាមធម៌, ព្រោះធម៌ជាគ្រឿងចង្អុល

ច្រាប់ផ្លូវឲ្យដឹងច្បាស់ ទុសត្រូវ ល្អអាក្រក់ បុណ្យបាប គុណទោស ។ ព្រោះហេតុនោះ ជនអ្នកស្រឡាញ់សេចក្តីល្អ គួរអប់រំកំលាំងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមធម៌ ๑ ពួក ដែលជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធសាសនា ហៅថា ពលធម៌ មានទៅក្នុងពួកពោធិបក្ខិយធម៌ (ធម៌កើតមានក្នុងចំណែកនៃការត្រាស់ដឹង) ទុកជាគ្រឿងអប់រំចិត្តឲ្យមានសមត្ថភាពក្នុងការប្រតិបត្តិ ។ ពលធម៌នោះ មាន ៥ យ៉ាងគឺ: សទ្ធាពល: ๑ វីរិយពល: ๑ សតិពល: ๑ សមាធិពល: ๑ បញ្ញាពល: ๑ ។

๑ **សទ្ធាពល:** ប្រែថា "កំលាំងគឺសទ្ធា" ។ ការប្រតិបត្តិធម៌ជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធសាសនា ឬប្រកបកិច្ចការអ្វីមួយជាប្រយោជន៍ក្នុងបច្ចុប្បន្ននេះ, ខាងដើមត្រូវមានសទ្ធាជាមូល ។ ពាក្យថាសទ្ធានេះ ជាសំដីដែលមហាជនធ្លាប់ពូថ្នឹកត្រៀកមកហើយ, តែបើទុកជាដូច្នោះ ក៏នៅតែមានពួកជនខ្លះ ពុំទាន់ចូលចិត្តច្បាស់លាស់នៅឡើយ ហេតុនេះ សូមអធិប្បាយពាក្យថា សទ្ធា នេះតទៅ ។ ដូចម្តេចហៅថា សទ្ធា? សទ្ធា ប្រែថា "ធម្មជាតិមិនរំកើបញាប់ញ័រកេងសភាពដែលមិនគួរដឿ" ដូចដឿឆោឡៃគេច្រាប់ពន្យល់ថា សេចក្តីសុខទុក្ខចំរើនវិនាសបានមកពីហេតុខាងក្រៅ មានការបន់ស្រន់បួងសួងខ្លាអាស័ក្សអ្នកតាជាដើម ឬដឿឆោឡៃសេចក្តីល្ងង់ ឬក៏កាន់ច្រឡំព្រោះមិនមានច្បាប់ត្រិះរិះឲ្យឃើញហេតុផលជាមុនសិន ហើយកាន់តាមប្រព្រឹត្ត

តាមទៅ, ដ្បើយ៉ាងនេះមិនហៅថាសទ្ធាកុងទីនេះទេ ព្រោះដ្បើដោយ
កាន់ច្រឡំ ។ ជនអ្នកមានសទ្ធា មុននឹងធ្វើអ្វីនឹងប្រព្រឹត្តអ្វី គួរពិចារ-
ណាឲ្យឃើញហេតុផលជាក់លាក់សិនហើយសឹមដ្បើ កុំដ្បើតាលំតែស្ដាប
ស្ដាកខកគំនិតតាញមកវិញមិនបាន ។ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង
ថា សទ្ធានឹងបញ្ញាជាគូគ្នា បើមានតែសទ្ធាមិនមានបញ្ញា នឹងប្រកាន់ដ្បើ
ទៅលើខុសពុំបានសម្រេចប្រយោជន៍ ។ សទ្ធាកុងដូចជាពូជ, បញ្ញា
កុងដូចជាផែនដី, កាលបើគេយកពូជទៅសាបព្រោះបណ្ដុះដាំលើដែនដី
ឬក្រែសថ្មដែលជាធម្មជាតិឥតមានដីជាតិ ពូជនោះក៏ពុំអាចនឹងដុះមាន
ពន្លកដើមដង់បានឡើយ ព្រោះបណ្ដុះដាំទៅលើធម្មជាតិដែលឥតមាន
ដីជាតិ ។ លុះណាតែយកពូជនោះទៅបណ្ដុះដាំលើផែនដីមានដីជាតិល្អ
ទើបពូជនោះនឹងមានពន្លកដុះលូតលាស់ទៅបាន យ៉ាងណាមិញ;
សទ្ធាក៏ដូច្នោះដែរ លុះណាតែប្រកបដោយបញ្ញាផង ទើបសទ្ធានោះនឹង
មានកំឡាំងមិនងាកបែររេទៅរកផ្លូវខុសបាន ។

មួយទៀត សទ្ធាកុងដូចជាទ្រព្យដ៏ប្រសើរ, មានពុទ្ធភាសិតថា
សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ "សទ្ធាជាទ្រព្យដ៏ប្រសើរបស់បុរស
កុងលោកនេះ" ។

ទ្រព្យទាំងអស់កុងលោកមានមាសប្រាក់ជាដើម សុទ្ធតែជារបស់
តែងមានសេចក្ដីវិនាសអន្តរាយទៅដោយហេតុផ្សេង ។ មានចោរលួចក្ដី

នេះជាដើម ជាទ្រព្យដ៏ខ្ពស់ក្នុងអំណាចបង្គាប់បញ្ជារបស់ខ្លួនឡើយ មានតែនាំខ្លួនឲ្យដល់នូវសេចក្តីវិនាសតែប៉ុណ្ណោះ ។

ចំណែកទ្រព្យគឺសទ្ធានេះ ជាធម្មជាតដ៏ប្រសើរបំផុត ជារបស់មានទ្វីម មិនពុកផុយរសាយទៅដោយហេតុផ្សេងៗ ទោះចោរកើតចិត្តលួចយកតាំងបានជាទ្រព្យដ៏ពេញចិត្ត គាប់ចិត្ត របស់អ្នកប្រាជ្ញ ជាទ្រព្យសម្រាប់ទិញយកអស្សទ្ធិយធម៌ គឺសេចក្តីមិនជឿនោះចេញចាកសន្តាន ។

សទ្ធានេះមាន ៤ យ៉ាងគឺ

១ – ជឿកម្ម (កម្មស្សកតា)

២ – ជឿផលរបស់កម្ម (វិបាកស្សទ្ធា)

៣ – ជឿថាសត្វមានកម្មជារបស់ខ្លួន (កម្មស្សកតាសទ្ធា)

៤ – ជឿប្រាជ្ញាត្រាស់ដឹងព្រះតថាគត (តថាគតពោធិស្សទ្ធា) ។

ក្នុងទីនេះនឹងលើកយកតែសទ្ធាពីរយ៉ាងខាងចុងមកអធិប្បាយ ។

ជឿប៉ាសត្វមានកម្មជារបស់ខ្លួន នោះគឺ ជឿថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ សេចក្តីនេះគប្បីយើញនូវអំពើរបស់ខ្លួននឹងអ្នកដទៃ ដែលមានអំណោយផលឲ្យយើញប្រាកដ ដូចជនអ្នកមានសទ្ធាឲ្យទានវត្ថុអ្វីៗដល់គេ ប៉ុន្តែមិនបានវត្ថុអ្វីជាទីគាប់ចិត្តមកវិញទេ ក៏គង់បានពរសំឡាសាធុការអំពីបង់គ្នាបាកក្នុងបច្ចុប្បន្ននេះមកវិញដែរ; នេះជា

ចំណែកខាងស្តាំ ដែលហៅថាកុសលកម្ម ។ បើខាងអាក្រែកវិញ ដូចយ៉ាងមនុស្សប្រព្រឹត្តឆ្គើចោរកម្ម ហានលួចប្លន់ឆក់ដណ្តើមយកទ្រព្យគេឯដើម ពេលការចាប់យកមកវាយតប់ធាក់ជាក់គុកជាក់ច្រវាក់ ធ្វើតាមទោសដែលខ្លួនប្រព្រឹត្តនេះ, ជាអំពើអាក្រែកដែលហៅថា អកុសលកម្ម ។ កម្មទាំងពីរយ៉ាងនេះ ជួនកាលឲ្យផលក្នុងបច្ចុប្បន្ននេះភ្លាមៗក៏មាន ជួនកាលឲ្យផលទៅបរលោកក៏មាន; ប៉ុន្តែកម្មទាំងពីរយ៉ាងនេះឲ្យផលមិនស្មើគ្នាទេ ដូចព្រះពុទ្ធភាសិតថា:

គ ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតិំ

"ធម៌ពីរយ៉ាងគឺបុណ្យនឹងបាប មានផលមិនស្មើគ្នាទេ បាបរមែងនាំសត្វឲ្យទៅកើតក្នុងនរក បុណ្យរមែងនាំសត្វឲ្យទៅកើតក្នុងសុគតិភព ។

មួយទៀត មានបុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើអំពើល្អក៏អាក្រែកក៏ភ័យ, ប៉ុន្តែអំពើនោះមិនទាន់ឲ្យផល ដោយមានហេតុដទៃមកសូរបំផ្ចាំងផ្ចាំងផ្លាមិនចេញមុខឲ្យឃើញច្បាស់ជ, ក៏ឃើញថាសេចក្តីល្អអាក្រែកមិនឲ្យផល; ម្ចាស់រហ័យក៏លែងធ្វើលែងធ្វើលែងប្រព្រឹត្តតាមទៀតវិញក៏មាន; ប៉ុន្តែតាមសេចក្តីពិត មិនមែនដូច្នោះទេ ឃុំរង់បង់តែអំពើនោះឲ្យផលពុំខាន; សមដូចព្រះពុទ្ធភាសិតថា:

ปาปោបំ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ បាបានិ បស្សតិ

"បុគ្គលអកផ្ដើនូវអំពើអាក្រក់ ឃើញតែសេចក្ដីចំរើន កំណត់ត្រឹមពេលដែលបាបមិនទាន់ឲ្យផល, លុះដល់ពេលណាបាបឲ្យផល គេទើបជួបប្រទះនូវបាបទាំងឡាយក្នុងពេលនោះ" ។

ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតិ ភទ្រំ អថ ភទ្រានិ បស្សតិ

"បុគ្គលអកផ្ដើនូវសេចក្ដីល្អ ជួបប្រទះតែសេចក្ដីអាក្រក់ កំណត់ត្រឹមពេលដែលសេចក្ដីល្អមិនទាន់ឲ្យផល, លុះដល់ពេលណាសេចក្ដីល្អឲ្យផល គេទើបជួបប្រទះនូវសេចក្ដីសុខក្នុងពេលនោះ" ។

ពុទ្ធភាសិតនេះ បំភ្លឺឲ្យឃើញថា អំពើល្អក្ដីអាក្រក់ក្ដី ដែលបុគ្គលផ្ដើហើយ ជួនកាលឲ្យផលភ្លាមៗ ជួនកាលក៏ពុំទាន់ឲ្យផល ដោយមានហេតុជាច្រើនមកសម្លុះបិទខ្ទប់មិនចេញមុខឲ្យឃើញច្បាស់ ; ប៉ុន្តែមុខជានឹងមានឱកាសណាមួយនឹងឲ្យផលពុំខាន ។

មានពុទ្ធភាសិតមួយបែបទៀតថា សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនិ កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ

"សត្វសត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទ្រព្យសំបាច់ ប្តជាមត៌ក មានកម្មជាកំណើត មានកម្មជាសេវាពន្ធ្យ មានកម្មជាទីពឹងអាស្រ័យ នោះសត្វទាំងនោះធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី ត្រូវជាអ្នកទទួលខុសត្រូវនៃកម្មនោះ" ។

ព្រោះហេតុនោះ ជនអ្នកមានសទ្ធាគួរមានសេចក្តីជឿថា សេចក្តីល្អអាក្រក់បានមកពីហេតុ គឺអំពើដែលខ្លួនធ្វើ ធ្វើយ៉ាងណាត្រូវទទួលអំណាយផលយ៉ាងនោះ មិនខុសពីដំណើរអំពើដើម; យ៉ាងនេះហៅថា "ជឿថាសត្វមានកម្មជារបស់ខ្លួន" ។

ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគតនោះ គឺ: សទ្ធាដែលជឿនូវការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធថា ព្រះពុទ្ធជាម្ចាស់បានត្រាស់ឡើងក្នុងលោកនេះ ទ្រង់មានប្រាជ្ញាជាអស្ចារ្យជាងមនុស្សសាមញ្ញ រកបុគ្គលណាស្មើគ្មាន, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ព្រះអង្គត្រាស់ដឹងនូវពោធិញ្ញធម៌ចំពោះព្រះអង្គ. ព្រះអង្គបរិបូណ៌ដោយវិជ្ជាទំងចរណៈ, ព្រះអង្គមានដំណើរល្អ, ព្រះអង្គជ្រាបច្បាស់នូវលោក, ព្រះអង្គប្រសើរដោយគុណមានសីលជាដើម, ព្រះអង្គជានាយសារថីទូន្មានទូន្មនបុរសដែលគួរទូន្មាន, ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ, ព្រះអង្គត្រាស់ដឹងនូវអរិយសច្ច ៤ ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង, ព្រះអង្គមិនត្រឡប់កើតក្នុងភពថ្មីទៀត, ធម៌ឯណាដែលមានប្រាកដឡើងហើយ ធម៌នោះមិនកំចាត់នឹងញាណរបស់ព្រះអង្គឡើយ, ធម៌មានត្រឹម

ណា ប្រាជ្ញាញាណតំហេ[illegible] ព្រះអង្គមិនខ្វះប្រាជ្ញាត្រាស់ដឹងខ្លួនមិនពាំងពួនឡើយ ។ ដូចបានបញ្ជាក់ក្នុងគាថាគន្ថមុខពន្ធកនិកាយបដិសម្ភិទាមគ្គថា : យាវតកំ ញេយ្យំ តាវតកំ ញាណំ, យាវតកំ ញាណំ តាវតកំ ញេយ្យំ, ញេយ្យបរិយន្តិកំ ញាណំ, ញាណបរិយន្តិកំ ញេយ្យំ "ធម៌ដែលព្រះសព្វញ្ញុពុទ្ធគប្បីជ្រាបត្រឹមណា ប្រាជ្ញាញាណក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមណា ធម៌ដែលព្រះអង្គគប្បីជ្រាបក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមទីបំផុតនៃធម៌ដែលព្រះអង្គគប្បីជ្រាប ធម៌ដែលព្រះអង្គគប្បីជ្រាបមានត្រឹមទីបំផុតនៃប្រាជ្ញាញាណ គឺជាធម៌ទីធំប្រាជ្ញាញាណមិនលើសមិនខ្វះគ្នា" ។

ការត្រាស់ដឹងរបស់ព្រះសព្វញ្ញុពុទ្ធនេះ ជាអស្ចារ្យប្លែកជាងមនុស្សសាមញ្ញ, កាលបើត្រាស់ដឹងធម៌ណាហើយ ធម៌នោះជាធម៌ពិតធម៌មែនហើយព្រះអង្គមិនលាក់ទុកដំដែតឯព្រះអង្គឯង ទ្រង់សំដែងពន្យល់ដល់សព្វសត្វឲ្យប្រតិបត្តិតាម យល់តាមដូចព្រះអង្គដែរ ។

ព្រោះហេតុនោះ យើងទាំងពុទ្ធសាសនិកជន គួរជឿចំពោះការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធដូចបានសម្តែងមកខាងលើនេះ ហើយគាន់តាមប្រតិបត្តិតាមពាក្យប្រៀនប្រដៅដែលទ្រង់សំដែងទុកមក ដើម្បីនឹងកសាងកំឡាំងកាយកំឡាំងចិត្តឲ្យ[illegible]ឯកម្ចាត់; ដើម្បីនឹងនេះហៅថា "ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត" ។

តំណាងបុណ្យស្រង់ទឹកកា

សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត

សង្ឃនាយក គណៈមហានិកាយ

នៃ

ព្រះទេពសុត្តា សូរ - ហាយ

ក្រុមដុំទុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(ត - ចប់)

សុទ្ធរកថា

ព្រះពោធិវង្ស ហួត - តាត

ចាងហ្វាងសាលាជាលីជាន់ខ្ពស់

សូមថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិត,

សូមចំរើនពរលោកកុម្មៃស្ស្រីដើឡារេពុយញឹក,

សូមទូលសម្តេច,

សូមចំរើនពរ ព្រះតេជព្រះគុណ ទូរអស់លោក-អ្នកពុទ្ធបរិស័ទ្ធ សប្បុរសទាំងឡាយ!

តាមនាមនៃព្រះសង្ឃគ្រប់តំណែងទំនងគ្រប់ឋានៈ, អាត្មាភាពសូមថ្លែងអំណរដ៏លើសលប់ចំពោះព្រះពរដ៏ឧឡារៈរបស់ព្រះករុណាជាម្ចាស់

ដ៏តែ ដែលទ្រង់ស្តេចមកគង់ ទីភ្នាក់ងារធិបតី ព្រមទាំងលោកកុម្ភីសៀរនីធ ព្រះតេជព្រះគុណទាំងឡាយ ដែលបានអញ្ជើញមកកាន់ពិធីបុណ្យ ស្រង់ទឹកសម្តេចព្រះមហាសុមេធាធិបតីនេះ ។

អាត្មាភាពសូមព្រះរាជទានឧកាសខ្ញុំដើម្បីប្រវត្តិរបស់សម្តេចព្រះមហាសុមេធាធិបតីថ្វាយជាសេចក្តីសង្ខេបដូចតទៅនេះ ៖

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយអង្គនេះ កើតឆ្នាំវកធស័ក ព. ស. ២៤២៦, គ. ស. ១៨៨៣ ។

កាលនៅជាសាមណេរអាយុ ១៦ ឆ្នាំ បានចេញពីវត្តពោធិព្រឹក្ស (ហៅវត្តពោលល្វាំ) ឃុំលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាជាតិភូមិរបស់លោក មកនៅវត្តខ្ណោលោម បានរៀនសូត្រព្រះបរិយត្តិធម៌ដោយឫទ្ធិយ៉ាងមុឺងមាត់ អំពីសំណាក់ធម្មាចារ្យជាច្រើនរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងសម័យនោះ ។

លុះបានជន្មាយុ ២១ ឆ្នាំ សម្តេចបានទៅសូមឧបសម្បទាជាតិកុកាវៈឯវត្តពោធិព្រឹក្ស ហើយបានត្រឡប់មកកាន់វត្តខ្ណោលោមវិញ ។ សម្តេចតែងមានហឫទ័យសប្បាយតែនឹងការរៀនសូត្រ មិនត្រឹមតែភាសាខ្មែរឡើយ សម្តេចរៀនដែរ ព្រមទាំងភាសាបាលី, ឡាតាំង, សៀម, លាវ, កូមា, លង្កា (សិង្ហឡ) ហើយរៀនភាសាសៀមនឹងលាវយ៉ាងស្ទាត់ ព្រមទាំងរៀនភាសាបារាំងល្មមសរសេរបានចរចាបានខ្លះ ។

កាលពីក្នុង ព.ស. ២៤៥៦ (គ.ស. ១៩១៣) សម្តេចបានចូលប្រឡងដេញប្រយោគក្នុងព្រះទេវោសថវត្តនាគម (វិហារព្រះកែវមរកតក្រុងភ្នំពេញ) បាន ៤ ប្រយោគ ដែលជាប្រយោគផុតថ្នាក់ក្នុងសម័យនោះ ។ នៅ គ.ស. ១៩១៥ សម្តេចបានប្រឡងជាប់បានទទួលនាមជាសាស្ត្រាចារ្យ នៅសាលាចាលីជាន់ខ្ពស់, បានធ្វើជាក្រុមដំទុំតែងវចនានុក្រមខ្មែរបានបង្ហើយការនោះវិត ១ អង្គលោកដកបដល់ចប់ ។ ការនេះជាស្នាព្រះហស្តមួយយ៉ាងឯក ។ សម្តេចបានរៀបរៀងសៀវភៅកថ្នាយន្តបត្តមួក: វេយ្យាករណ៍ចាលី, សៀវភៅគីហិបតិបត្តិ, សាមណេរវិនិយ, តិក្ខប្បាតិមោក្ខសង្ខេបនិងសៀវភៅពាយរង៉ខ្លះទៀតជាច្រើន ។

កាលពីក្នុង ព.ស. ២៤៦៥ - ២៤៦៦ (គ.ស. ១៩២២ - ១៩២៣) ភជការបានចាត់សម្តេចឲ្យទៅនៅក្រុងហាណូយ ជាមួយនឹងអាគ្នាភាព បានរៀនភាសាសំស្ក្រឹត, អក្សរខេមរនាគរី, អក្សរថ្មបុរាណនិងពង្សាវតារព្រះពុទ្ធសាសនាក្នុងនានាប្រទេស ក្នុងសំណាក់អ្នកប្រាជ្ញប្រាំងជាច្រើនរូប មានលោកល្វីហ្វីណូត់ដែលជាចាងហ្វាងសាលាប្រាំងសៃសនៅបុងប្ងាប្រទេសក្នុងពេលនោះជាដើម ។

សម្តេចបានទិមន្តទៅកាន់ប្រទេសលាវ ២ ដង, ទៅកាន់ប្រទេសកូស៊ីងស៊ីន ម្តង ជាតំណាងពុទ្ធសាសនបណ្ឌិត្យនឹងសាលាចាលីជាន់ខ្ពស់ក្នុងការជួយបំពេញកិច្ចសម្រាប់ព្រះពុទ្ធសាសនានឹងការសិក្សា ។

សម្តេចបានឡើងជាចាងហ្វាំងវរគណៈសាលាបារាំងតាំងពី គ. ស. ១៨៣០, បានឡើងជាចាងហ្វាំងសាលាបារាំងតាំងពី គ. ស. ១៨៤២, បានទទួលឡើងជាបេសាអធិការវត្តខណ្ឌលោមនេះពី គ.ស. ១៨៤៣, បានទទួលនាទីជាអធិបតីបេសកាកូន គ. ស. ១៨៤៥ បានធ្វើជាអនុប្រធានគណៈកម្មការប្បទានមិកូន គ. ស. ១៨៤៧ ។ មិនត្រឹមតែកិច្ចការដែលជានាទីរបស់សម្តេចប៉ុណ្ណោះឡើយ ទោះបីអស់លោកមន្ត្រីធំ-តូចកូនក្រសួង កូនក្រុមនានា ដែលត្រូវការសោតសូរប្តឹងសុំឲ្យជួយស្រាវជ្រាវរកពាក្យពេចន៍ដែលត្រូវ ដែលតំចាំងជាដើម សម្តេចក៏តែងមានធុញ្ញទាន់ឲ្យដែរ សម្តេចបានទទួលការធ្វើជាក្រុមដំនុំខាងអក្សរសាស្ត្រនឹងជាមេប្រយោគបង្ហូរកូនក្រសួងសិក្សាធិការជាច្រើនឆ្នាំ ។

ព្រះគុណជាម្ចាស់ដ៏វិតថិនភាជការចាក់ចាងបានប្រគេនគ្រឿងឥស្សរិយយសតាមសម័យនិយមដែលសាកលលោកកាន់ គ្រឿងឥស្សរិយយសនោះដូចតទៅនេះ ៖

សម្តេចបានទទួលមេដាយមុខងារពណ៌ប្រៃទេសកម្ពុជានៅ គ. ស. ១៩១៧ មេដាយអស្សបុរុស្ស ប្រៃទេសកម្ពុជា ខ្ទង់មេដាយអស្សបុរុស្សដំរីៈ១ លានត្រែស នៃក្រុងលួងព្រះបាទ (ប្រៃទេសលាវ) នៅ គ. ស. ១៩៣២ មេដាយសេនានៃបណ្ឌិតសភាប្រៃទេសបារាំង (Officier de l'Académie) នៅ គ. ស. ១៩៣៧ មេដាយអស្សបុរុស្ស (Chevalier) ដ៏ឱឡារិកសុរុង

ដូណ្ណើរនៃប្រទេសថ្មីកំនើនៅ គ. ស. ១៩២៣, មេដាយសេនានៃប្រទេសតម្កល់នៅគ. ស. ១៩៤៤, មេដាយសេនា (Officier) ដ៏ឡាឡេស្ស៊ុងដូណ្ណើរនៃប្រទេសថ្មីកំនើនៅ គ ស. ១៩៤៨ ។

ឯបំណែកខាងសមណស័ក្តិសម្រាប់គ្រួសង្ឃ ក៏សម្តេចឃុនទូលឃុនឡើងជាលំដាប់គឺ:

សម្តេចឃុនទូលធ្លើជាឃុនឡាត់សាក្យបុត្តិយ៍ (ឃុនឡាត់របស់ព្រះសាក្យវង្ស នុត) នៅ គ. ស. ១៩១០ ឃុនឡើងជាព្រះគ្រូសង្ឃសត្តា (ទីឃានានុក្រមសម្រាប់ឯករបស់សម្តេចព្រះមហាសង្ឃរាជ) ក្នុង គ. ស. ១៩១២ ឃុនឡើងសមណស័ក្តិជាព្រះសាសនាសោភ័ណ (ពីពាគណៈកិត្តិយស) ក្នុង គ. ស. ១៩៣១ ឃុនឡើងសមណស័ក្តិជាព្រះពុទ្ធឃោសាចារ្យ (ពាគណៈថ្នាក់ទី ២ ក្នុងសម័យបច្ចុប្បន្ន) ក្នុង គ.ស. ១៩៤០, ឃុនឡើងសមណស័ក្តិជាព្រះរតនធិរ័ត្ន (ពាគណៈថ្នាក់ទី ១) ក្នុង គ. ស. ១៩៤៤, ហើយឃុនឡើងសមណស័ក្តិជាន់ខ្ពស់បំផុតជាព្រះមហាសុមេធាធិបតី សង្ឃនាយកគ្រប់គ្រងសង្ឃមណ្ឌលខាងគណៈមហានិកាយកម្ពុជវង្សនៅ គ. ស. ១៩៤៨ រហូតមកដល់ថ្ងៃអង្គារ ២ កើតខែពិសាខឆ្នាំខាលទោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ១៨ ខែមេសា ១៩៥០ នេះ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ប្រោសព្រះរាជទានសមណស័ក្តិឲ្យឃុនឡើងទីជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ។

ឥឡូវព្រះភិក្ខុសង្ឃនិងពុទ្ធបរិសទ្យទាំងឡាយ មានអំណរដ៏លើសលប់បំពោរសមណៈសក្តិឆ្កួតឆ្កាក់ សម្រាប់ព្រះសង្ឃនាយក ដែលព្រះករុណាជាអម្ចាស់ដ៏វិត ទើបនិងប្រោសព្រះពជ្ជទាននេះ ដោយយល់ឃើញថា សម្តេចព្រះសង្ឃនាយកអង្គនេះ ជាព្រះថេរអ្នកអង់អាចបរិបូណ៌ដោយសមត្ថភាព និងវីរិយភាព អាចគ្រប់គ្រងសង្ឃមណ្ឌលឲ្យមានការល្អូតលាស់ចំរើនក្នុងព្រះពុទ្ធសាសនាតទៅ ទើបបានព្រមព្រៀងរួបរួមកំឡាំងធ្វើពិធីបុណ្យស្រង់ទឹកជាយសាកវិឌ្ឍនមង្គលប្រគេនសម្តេច ដោយព្រះករុណាជាអម្ចាស់ដ៏វិតខ្ពង់ប្រោសព្រះពជ្ជទាន ព្រះពជ្ជានុញ្ញាតផង ។

បុណ្យកុសលនេះ មានព្រះករុណាជាអម្ចាស់ដ៏វិតជាប្រមុខ, អាត្មាភាពជាតំណាងពុទ្ធបរិសទ្យទាំងអស់ ដែលបានព្រមព្រៀងចាត់ការបុណ្យនេះ សូមធ្វើសត្យាធិដ្ឋានយកកុសលនេះមកប្រតិស្ថាន សូមឲ្យសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក បានប្រកបដោយសុភមង្គលសុខចំរើនជាយូរយឺន! ដើម្បីគ្រប់គ្រងសង្ឃមណ្ឌលក្នុងកម្ពុជរដ្ឋ នូវអស់ពុទ្ធបរិសទ្យ ឧបាសកឧបាសិកា ឲ្យបានលូតលាស់ចំរើនក្នុងព្រះពុទ្ធសាសនាអស់កាលជាអង្វែងតទៅ ! ។

ទីបំផុតនេះ, អាត្មាភាពសូមឧទ្ទិសផលដែលកើតឡើងអំពីការបុណ្យនេះថ្វាយចំពោះព្រះករុណាជាម្ចាស់ដ៏វិត សូមខ្ពង់បំតនៅក្នុងសិរីពជ-សម្បត្តិអស់កាលជាអង្វែង ! សូមខ្ពង់ប្រកបដោយព្រះជន្មាយុយឺនយូរ ព្រមទាំងប្រកបដោយសិរីសុវត្ថិមង្គលគ្រប់ប្រការរៀងតទៅ ! ។

ជូនចំពោះលោកកុម្មៃសៀរដើម្បីរេពុយពួក, ថ្វាយទ្រង់, ជូនអស់លោក, អ្នកទាំងឡាយ សូមឲ្យបានស្ថិតនៅក្នុងសុខ-ចំរើនអស់កាលជាអង្វែងតទៅ! ។

សុន្ទរកថា

របស់សម្តេច ព្រះមហាសុមេធាធិបតី ជួន - ណាត

សង្ឃនាយក គណៈមហានិកាយ

ថ្វាយព្រះពរ ព្រះករុណាជាម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

កាលពីថ្ងៃទី ៤ មីនា គ.ស. ១៩៤៨ ព្រះករុណាជាម្ចាស់ជីវិតបានទ្រង់ព្រះមេត្តាទ្រោសព្រះពរជ័យ សមណស័ក្តិជាព្រះមហាសុមេធាធិបតីសង្ឃនាយកដល់អាត្មាភាព ។ កន្លងមកមិនយូរប៉ុន្មាន ទើបនឹងបានចំនួន ២ ឆ្នាំប៉ុណ្ណោះ ព្រះករុណាជាម្ចាស់ជីវិត ទ្រង់សព្វព្រះហឫទ័យនឹងបំពេញព្រះរាជករណីយកិច្ច តាមលំអាននៃរដ្ឋប្បវេណី ព័ហ្មពណាកាលរៀងមក ទ្រង់បានឡាយព្រះរាជក្រឹត្យចុះថ្ងៃទី ១៨ មេសា ១៩៥០ ទ្រោសព្រះពរជ័យសមណស័ក្តិថ្នាក់ខ្ពស់នេះដល់អាត្មាភាព ឲ្យបានឡើងទីជា "សម្តេច" មិនតែប៉ុណ្ណោះ លុះដល់មកថ្ងៃនេះ ដែលសន្មតថាជាឧបលក្ខិតសម័យសុភមង្គលដ៏ឧត្តម, ព្រះករុណាជាម្ចាស់ជីវិតទ្រង់លះព្រះរាជកិច្ចឈ្មៀតស្តេចមកឆ្លៀតព្រះអង្គជាព្រះពរជាធិបតី, ទ្រង់

ព្រះមេត្តាប្រោសព្រះពរជាទីឥតរាល់ឧត្តាគាតទៀត, ដោយមានលោក
កុម្មិស្សៃដើរឆ្ងាយតួយពីកន្លែងដ៏ប្រទេសចាំវ័ន ព្រមទាំងអស់លោកដ្ឋ-
មន្ត្រី នឹងអស់លោកប៉ូលិសក្សត្រ ព្រះពរអាណាចក្រជាដើម ចូលមកថ្វាយ
អំបរមគោរពព្រះអង្គជាធំ, តាមរបៀបដូរការ; អាត្មាភាពសូមទទួលព្រះ
ពរដ៏ប្រសើរ ដែលព្រះករុណាជាម្ចាស់ជីវិត ទ្រង់ព្រះមេត្តាព្រះរាជទាន,
ដោយអាត្មាភាពមានមនោសញ្ចេតនាត្រេកអរជាអនេក ចំពោះព្រះគុណ
ដ៏ឧត្តុង្គឧត្តមនេះ ។ ព្រះរាជករណីយកិច្ចនេះ អាចជ្រួតជ្រាបដិតជាប់នៅក្នុង
ដួងចិត្តនៃអាត្មាភាព នឹងពួកពុទ្ធបរិសទ្យក្នុងព្រះរាជអាណាចក្រកម្ពុជា
បីដូចជាស្នាមនៃព្រះវិលញ្ជរគឺត្រាស្រម៉ាប់ផែនដីដែលប្រថាប់ដិតជាប់
លើថ្មក្រាសដ៏ត្រាស់មិនរលុបរលាយ ជាទីឲ្យគនឹកឃើញឥតមានភ្លេចៗ
អាត្មាភាពនឹងទទួលការៈបំពេញករណីយកិច្ច ដែលជានាទីសម្រាប់ព្រះ
សង្ឃនាយក បំរើព្រះពុទ្ធសាសនាដោយសភាពជាពុទ្ធទាស: ឬជាពុទ្ធ-
លេខាធិការ ដោយមានព្រះករុណាជាម្ចាស់ជីវិតជាអគ្គសាសនូបត្ថម្ភក:
ជាទីពឹងពំនាក់ដ៏ឧត្តុង្គឧត្តមរបស់ប្រជានិករ ជាពុទ្ធមាមកជនកង្កមដរដ្ឋទាំង
មូល ។ ការទទួលការៈបំពេញករណីយកិច្ច ដោយយកចិត្តទុកដាក់ពុំហ៊ាន
ប្រហែសធ្វេសនោះ ជាកិច្ចតបស្នងព្រះបរមគុណនៃព្រះករុណាជាម្ចាស់
ជីវិត ដែលអាត្មាភាពត្រូវបំពេញ, ត្រូវប្រតិបត្តិ តាមសមគួរដល់ថាមពល
នឹងសមត្ថភាព នឹងគោរតើយព្រងើយពុំបាន នឹងខានក៏ពុំកើត ដោយ

អាត្មាភាពមានសេចក្តីគោរព ចំពោះព្រះពុទ្ធសាសនានឹងព្រះគុណជាម្ចាស់ដ៏វិតជាព្រះប្រិយមហាក្សត្រិយ៍ ទោះបីកង់វេលានេះ អាត្មាភាពមានវ័យចំណាស់គួរតែសម្រាកហើយ ក៏នឹងខានគ្រោព ខានបំពេញការណ៍យកិច្ចនេះពុំបាន ។

នៅទីបំផុតនេះ អាត្មាភាពសូមលើកយកគុណព្រះរតនត្រ័យនឹងគុណធម៌ដ៏ទុត្តមមកជាអានុភាព ជាទីតាំងថាជាវត្ថុស័ក្តិសិទ្ធិ, សូមព្រះគុណជាម្ចាស់ជីវិត នឹងសម្តេចព្រះបរមកជបិតា, សម្តេចព្រះវររាជជននី-នាថ ទ្រង់ជ្រាបប្រកបដោយសិរីសុខក្នុងរាជសម្បត្តិវិឌ្ឍនមង្គល, សូមមានព្រះជន្មវស្សាយឺនយូរអង្វែង !

លោកកុម្មវិស្សរដ៏ឧត្តរពុទ្ធញ្ញឹក, អស់លោកវជ្ជមន្ត្រី, អស់លោកទាំងឡាយដែលបានអញ្ជើញមកក្នុងមហាសន្និបាតអមព្រះអង្គនេះ, ទ្រង់នឹងសម្តេចទាំង ២ ព្រះអង្គនឹងព្រះតិក្ខុសង្ឃសាមណេរទាំងអស់ សូមតាំងនៅក្នុងវឌ្ឍនធម៌នឹងសីលធម៌គ្រប់ប្រការសព្វទិវាកត្រីរៀងទៅ !

សូមព្រះរាជអាណាចក្រកម្ពុជា ប្រាសចាកន្ទរាសន្តិភាពយ៉ាងរួសរាន់ខាន់សម័យ កុំបីហ្មត់ក្លាយទៅជាប្រតារៈដដែរឡើយ ! ។

សុទ្ធរកថា

របស់ព្រះទេពសង្គា ស្ងួ-ហោយ ក្រុមជំទុំព្រះត្រៃបិដក

ថ្លែងតំណាងតាមព្រះសង្ឃរាជគណៈ មេត្តណ អនុត្តណ និងចៅអធិការ

សម្តេច !

ពេលនេះជាឱកាសល្អ ដែលគួរឆ្លៀតសំដែងសេចក្តីសោមនស្ស ចំពោះសម្តេចដោយសង្ខេប ។

ខ្ញុំព្រះករុណា នៅក្នុងនាមនៃព្រះសង្ឃ សូមថ្លែងសេចក្តីដែលថា, សេចក្តីគ្រែកអរ ចំពោះកិត្តិយសនៃសម្តេច ជាតំណាងនៃព្រះថេរៈជាអជ្ឈាគណៈ ទីឋានានុក្រម ព្រមទាំងព្រះសង្ឃក្នុងកម្ពុជរដ្ឋទាំងមូល ដូចសេចក្តីរៀបរាប់តទៅនេះ ៖

*ខ្ញុំព្រះករុណា ពាល់រូបមានសេចក្តីដែលថា គ្រែកអរជាទីបំផុត ចំពោះសម្តេចដែលបានឡើងឋានៈដ៏ខ្ពង់ខ្ពស់ ដូចបំណងរបស់ខ្ញុំព្រះករុណាទាំងឡាយ ដែលបានទឹកដមចំពោះជាយូរឆ្នាំមកហើយ ; ទាំងលោកចៅអធិការ គ្រូសូត្រ ជាច្រើនវត្តច្រើនរូប តែងមានសំឡេងលាន់មាត់សរសើរដោយតេញចិត្ត ស្រេចទាំងទឹកសង្ឃឹមមកជាយូរហើយ ចំពោះសម្តេច តាំងពីកាលសម្តេចនៅក្នុងឋានៈជាព្រះគ្រូសង្ឃសង្គានៅឡើយ ទឹកថា « ក្នុងចំណោមបព្វជិតជាអ្នកប្រាជ្ញច្រើនអង្គ, ព្រះថេរៈអង្គនេះ មានគុណសម្បត្តិសមគួរតាំងប្រសើរ ជាមេគំនិតនៃពុទ្ធបរិស័ទ្យក្នុងផ្លូ

ព្រះពុទ្ធសាសនាដោយពិត, ព្រះថេរអង្គនេះដែលបានមកចាប់កំណើត
ក្នុងប្រទេសកម្ពុជា, ហើយបានទទួលកេរមត៌កជាតិ, មានឫទ្ធិ
មានប្រាជ្ញាវាងវៃ, បានធ្វើការព្រះពុទ្ធសាសនាឲ្យរុងរឿងដោយតតាំង
ហាត់ខ្លឹយ, បំរើព្រះពុទ្ធសាសនាដោយពេញបរិបូណ៌, ឈ្មោះនៅ
ក្នុងការសានឹងអក្សរសាស្ត្រជាច្រើនមុខ តាំងសំដែងធម៌ទេសនាក៏មាន
របៀបខាន់សម័យពីពេះក្បោះក្បាយជាខ្លីបំផុត; អំណើះតទៅគួរបាន
ឡើងសមណស័ក្តិយ៉ាងខ្ពស់ទើបសមគួរ ។

ខ្ញុំព្រះករុណាតាំងឡាយចេះតែនឹកត្រិះរិះថា "កាលណាទៅហ្ន៎!
ទើបព្រះថេរអង្គនេះបានទទួលសមណស័ក្តិនីកជាតណា:" ។

លំដាប់តមក សម្តេចក៏ចេះតែបានឡើងសមណស័ក្តិតគ្រឿនជា
ជរាបតមានទបស័ក្តណាមួយមកដំបាស់ទេ ។ សម្តេចបានឡើងហាន:
ជាព្រះសង្ឃនាយកកន្លងមកចំនួន ២ ឆ្នាំ, ដល់មកថ្ងៃអង្គារ ២ កើតវៃ
ពិសាខឆ្នាំខាលនេះ ស្រាប់តែព្រះករុណាជាម្ចាស់ដីវិតទ្រង់ព្រះមេត្តា
ប្រោស ស្តេចមកប្រទានព្រះរាជកិត្យដោយផ្ទាល់ព្រះហស្ត ក្នុងវិហារ
វត្តទុណ្ណាលោម ប្រោសប្រទានហាន:ជាសម្តេចព្រះមហាសុមេធាធិបតី
តេញទី ដូចសេចក្តីនឹកប៉ុនប៉ងនៃខ្ញុំព្រះករុណាតាំងឡាយពិតមែន ។

ខ្ញុំព្រះករុណាកល់រូបតាំងក្រងក្តុំតេញតាំងស្រែកគ្រៃ ដែលជុះ
មកដោយឈូងរវៀបចំរោងតាំងតុ ចូរយព្រះតេនត្រៃយក្នុងទុកាសពីរ

បុណ្យស្រង់ទឹក ចំពោះព្រះដន្ដសម្ដេចខេះជាកិត្ដិនាមនៃសេចក្ដីជ្រះថ្លាសាទរបស់យើងខ្ញុំព្រះករុណាជាស្ដេច ត្រមាំងចុងនិមន្ដព្រះសង្ឃ ៦៩អង្គ ចំពោះព្រះបរិត្ដដើម្បីប្រគេនទុសល ប្រគេនតាមចំពោះសម្ដេច សូមជយមង្គលស៊ីរីសុស្ដីចូរមានដល់សម្ដេច ដោយហេតុថា ខ្ញុំព្រះករុណាទាំងឡាយ ដែលចុះទទួលតាមសិក្សារៀនសូត្រយល់ច្បាប់ធម៌នៃយកក្នុងព្រះពុទ្ធសាសនាច្បាស់លាស់ពោះចុះ កំដោយសារគុណធម៌នៃសម្ដេច ។

ខ្ញុំព្រះករុណាភ្លក់រូបសូមបង្ហាញសេចក្ដីត្រេកអរ នឹងសេចក្ដីសរសើរយ៉ាងសង្ខេបដោយតតិលាក់លៀម ។ សម្ដេចទុកជាសង្ឃបិតានៃព្រះសង្ឃទាំងអស់, ជាប្រិយមហាចេរៀនៃពុទ្ធបរិសទ្យ ទាំងបព្វជិតទាំងគ្រហស្ថ, ព្រោះថា សម្ដេចដែលចុះទទួលកំណើតកងប្រទេសកម្ពុជានេះ មានភ័ព្វដ៏ប្រសើរ, មានជំរិតប្រកបដោយប្រយោជន៍ទាំងផ្លូវលោកទាំងផ្លូវធម៌ ។ សម្ដេចរាប់ថាជាបុត្រមួយក្នុងពួកបុត្រនៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ដែលមានប្រវត្ដិដ៏ល្អ ដោយសម្ដេចចុះរៀបចំធម៌វិន័យលើកសង្ឃាយនាព្រះពុទ្ធសាសនា ឲ្យមានរបៀបត្រឹមត្រូវដូចចុះឃើញជាភ័ស្ដុតាងមកហើយ ។ ខ្ញុំព្រះករុណាទាំងឡាយនឹកឃើញមជ្ឈឹមជាមុនទៀតថា "ព្រះពុទ្ធសាសនានឹងចំរើនរុងរឿងថ្កុំថ្កើងតទៅអនាគតពុំខាន" ។

បណ្ដាពុទ្ធបរិសទ្យទាំងអស់ សម្ដេចទុកជាអគ្គសាសនិកបុរសមួយរូបដែលគួរគោរព, គួរយកតម្រាប់តាម, ជាទីពិគ្រោះប្រឹក្សាក្នុងផ្លូវអក្សរ

សាស្ត្រ នឹងប្រាប់ព្រះពុទ្ធសាសនាដោយពិត ។ ក្នុងពេលនេះ មានពុទ្ធបរិសទ្យជាច្រើនគុះគរមកដួបជុំក្នុងវត្តនេះ ដើម្បីធ្វើបុណ្យទក្ខិណានុប្បទាន ចំពោះសម្តេច ដែលទើបនឹងបានទទួលសមណសក្តិ ជូចបំណងនៃពុទ្ធបរិសទ្យ ។ ការធ្វើបុណ្យគុសលនេះ ជាតវណីយកិច្ចនៃពុទ្ធបរិសទ្យទាំងឯបព្វជិតទាំងគ្រហស្ថ ។

ក្នុងទីបំផុតនេះ, ខ្ញុំព្រះករុណាជាតំណាងនាមនៃព្រះសង្ឃទាំងអស់ សូមសម្បង់សង្រឹងព្រះរតនត្រ័យ, សូមប្រគេនពរចំពោះសម្តេច ដូចសេចក្តីតទៅនេះ ៖

១ - សូមសម្តេចមានព្រះជន្មាយុយឺនយូរអង្វែង !

២ - សូមសម្តេចមានសម្បុរវិរ័ណ្ណចំរើនក្នុងកាយជាប្រក្រតី !

៣ - សូមសម្តេចប្រកបដោយសេចក្តីសុខគ្រប់ប្រការ !

៤ - សូមសម្តេចមានកំឡាំងកាយវាំងឫទ្ធិកុំបីមានភេគាពាធ !

៥ - សូមសម្តេចមានបដិភាណ គឺប្រាជ្ញាឆ្លាតវៃ ជានិច្ចកាល ចាប់ដើមតាំងអំពីថ្ងៃនេះតរៀងទៅ ! ។

អ្នករៀបរៀងពីធីបុណ្យស្រង់ទឹក

ព្រះខេតសត្ថា សូរ - ហាយ

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៤៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - តុក នាមនាយា ធម្មជោត កើតឆ្នាំ វក អាយុ ៣០ វស្សា ៩ ជាចៅអធិការៈ វត្តពោធិ៍ខ្ទឹម ឃុំស្វាយតោ ស្រុកវាំជ្រុល ខែត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៤៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង - សួង នាមនាយា ធម្មលិស្សត្ថេរ កើតឆ្នាំ មមែ អាយុ ៣១ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ខ្ទឹម ឃុំ - ស្រុក - ខែត្តដដែល ។

សញ្ញាប័ត្រលេខ ៦៤៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - ឃិន នាមនាយា លិស្សត្ថេរ កើតឆ្នាំឆ្លូវ អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខែត្តដដែល ។

សញ្ញាប័ត្រលេខ ៦៤៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សយ - លុយ នាមនាយា វិរិយប្បញ្ញោ កើតឆ្នាំ ... អាយុ ... វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តសំណា ឃុំតំពង ស្រុកដំគ្រែង ខែត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៤៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កេង - ហោង នាមនាយា ធម្មស្សត្ថា កើតឆ្នាំ ជូត អាយុ ៣៨ វស្សា ១៧ ជាចៅអធិការវត្តដំគ្រែង ឃុំ - ស្រុក - ខែត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥៨ ចុះថ្ងៃពុធ ១ កើតខែចេត្រឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ គាំងលោកប៉ាង - ភ្ញើម នាមធាយ៉ា ពុទ្ធត្តេរ កើតឆ្នាំខាលអាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំវត្តដីក្រែង ឃុំកំពង់ ស្រុកដីក្រែង ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦៥៩ ចុះគាលបរិច្ឆេទដដែល គាំងលោកគ្រូ គល់ - ម៉ង នាមធាយ៉ា ព្រហ្មកេសរ កើតឆ្នាំរកា អាយុ ៤៩ វស្សា ៦ វា គ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦៦០ ចុះគាលបរិច្ឆេទដដែល គាំងលោកគ្រូ ភ័ - សួន នាមធាយ៉ា ព្រហ្មសរ កើតឆ្នាំ ខាល អាយុ ៤៨ វស្សា ៦ ខែ ជាចៅអធិការវត្ត ល្បើត ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៦១ ចុះថ្ងៃអង្គារ ៣ កើតខែអាសាធ ឆ្នាំឆ្លងស័ក ព. ស. ២៤៩២ គាំងលោកគ្រូ ស - កេ នាមធាយ៉ា ពុទ្ធត្តេរ កើតឆ្នាំជូតអាយុ ៤៦ វស្សា ៥ ជាគ្រូសូត្រស្តាំវត្តល្បើត ឃុំកំពង់ ស្រុកដីក្រែង ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦៦២ ចុះគាលបរិច្ឆេទដដែល គាំងលោកគ្រូ ខ្លួន - សាម នាមធាយ៉ា ឥន្ទសីរៈ កើតឆ្នាំ ខាល អាយុ ៣៦ វស្សា ១៣ ជាគ្រូសូត្រស្តាំវត្តកណ្តាល ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៦៣ ចុះគាលបរិច្ឆេទដដែល គាំងលោកគ្រូ យ៉ង់ ម៉ី នាមធាយ៉ា ឥន្ទនាគ កើតឆ្នាំមមី អាយុ ៤៤ វស្សា ១៩ ជាគ្រូសូត្រស្តាំ

វត្តបុព្វវិសារាម ឃុំតំបន់ត្រើ ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស់ - សុខ នាមនាយោ គន្ធសុវណ្ណ កើតឆ្នាំ ច អាយុ ៤១ វស្សា ១៩ ជាគ្រូសូត្រឆ្នេងវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សាន - យ៉ាន នាមនាយោ នន្ទសិរី កើតឆ្នាំ ឆ្លូវ អាយុ ២៥ វស្សា ៥ ជាចៅអធិការ វត្តស្វាយលើ ឃុំស្វាយលើ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ នួ - សេង នាមនាយោ បញ្ញាជោត កើតឆ្នាំ ឆ្លូវ អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ វង - នុត នាមនាយោ ព្រហ្មសរ កើតឆ្នាំវក អាយុ ៣០ វស្សា ៩ ជាចៅអធិការវត្តគោកដូក ឃុំវត្តសៀម ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម - ឯម នាមនាយោ សុវណ្ណសិរី កើតឆ្នាំឆ្លូវអាយុ ២៥ វស្សា ៤ ជាគ្រូសូត្រស្តាំ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ - ទិត នាមនាយោ ធម្មជោត កើតឆ្នាំ មមី អាយុ ៣២ វស្សា ១១ ជាចៅអធិការ វត្តក្បាលដំរី ឃុំលែង ស្រុក ខេត្តដដែល ។ (ម្ភៃឆ)

កែពាក្យខុសក្នុងកម្ពុជសុរិយា

លេខ ១ ឆ្នាំ ១៩៥០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ បន្ទាត់
លុះត្រាតែអំណាចនោះ	លុះត្រាតែអំណាចនោះ	
ជាស្នាដៃនៃវិចារណញ្ញាណ	ជាស្នាដៃនៃវិចារណញ្ញាណ	
ដែលផ្ដួចឆ្នើមពីសំឡេង	ប៉ុន្តែអំណាចនោះលេចធ្លង់	
	ន្ទូវិចារណញ្ញាណ ដែល	
	ផ្ដួចឆ្នើមពីសំឡេង	៤០១ ១៣
Moutar noire	Moutarde noire	៤៩៣ ១៣

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ឌាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភ័យ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ឌាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា សួរ - ហាយ
ក្រុមដំនុំព្រះធ្លៃចំណិក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ហ្វូងទំពន្ធមន្ត្រី ញ៉ុក ថែម	ព្រះរាជក្រិត្យ ក្រមទសកវិយោ	៥៦១
លោក ផេង-ត្រីវ៉ែ សាស្ត្រាចារ្យ	បក្សីទិព្យ រឿងព្រៃឥន្ទ្រទេសរ៉ូម៉ាំង	៥៧៣
គណៈកម្មការវប្បធម៌	ស័ព្ទបារាំងប្រែជាខ្មែរ ញ៉ុក - ថែម រួបរួម (តមក)	៥៩១
លោកសាង - សារ៉ាត លេខាធិការ	រឿងព្រៃឥន្ទ្រភូមិ (តមក)	៥៩៥
អ្នកឧកញ៉ាវិបុលរាជសេនា ឆួ - កន	រឿងសាមកុក (តមក)	៥៩៣
— ទេពពិទូរ ឈឹម - ក្រសែម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	៦០១
គណៈកម្មការទំនៀមទម្លាប់ខ្មែរ	សាវតារវត្តបាទយ មេឃុំ ឆួង-អ៊ូច តែង (ត-ចប់)	៦០៥
លោកប៊ុន-ថាន់អតីតតំណាងអាស្ត្រ	គតិបណ្ឌិត	៦០១

ផ្នែកសាសនា		
លោក ភ័យ-ប៊ុក ក្រមការ	ពន្ធអាសុីទ្វីប (តមក)	៦០៩
ព្រះទេពមុនី យួរ-ប៊ុណ្ណ	ពលកថា (ត-ចប់)	៦២២
ឃុនបណ្ណានុរក្ស ប៊ូ - ប៊ុំ	អម្ពដាគត	៦២៩

កំណាត់ទំនឹងប្រវត្តិការណ៍		
ព្រះគ្រូសិរីសោភ័ណ កឹម-ភួ	ពិធីដួងដំណើរសម្តេចសង្ឃនាយក ដែលនិមន្ត	
	ទៅលង្កាទ្វីប	៦៣៣
ក្រសួងធម្មការ	បញ្ជីឈ្មោះនាមចៅអធិការដែលតាំងថ្មី (តមក)	៦៣៩

Revue religieuse et littéraire éditée par l'Institut Bouddhique

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		pa
Luong Nibandhamantri Nhok-Thèm	Edit royal : Kramadasabhariyâ.....	56
M. Pheng-Chrieu, Professeur au Collège des jeunes filles	L'oiseau du paradis (Conte roumain)	57
Commission Culturelle	Mots traduits par la commission Culturelle et recueillis par M. Nhok-Thèm (suite).....	58
M. Sang-Savath, Secrétaire Ministère des Finances	Contes birmans (suite).....	58
Neak Okrha Vibularaja-séna Nou-Kân	Histoire de SAMKOK (suite).....	59
Neak Okrha Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite).....	60
Commission des Mœurs et Coutumes	Notice historique de la pagode de Banoi (Angkanh-Takéo) par le Mékhum Duong-Ouch (suite et fin).....	60
M. Bun-Than ancien député	L'opinion d'un Sage.....	61

Partie religieuse :

M. Ray-Buc Kramakar (L.B.)	Lumière de l'Asie (suite)	61
Préah Debamuni Yon-Tonn	Balakathâ (suite et fin)	62
Khun Pannanurak Bou-Po	Amba jâtaka	62

Notes et chroniques

Brah Krou Sirisobhana Kem-To	Départ de Samdech Brah Moha Sumédhadhipati, Chef de secte pour Colombo (Ceylan).....	63
Ministère des Cultes	Nomination des nouveaux Chau-Adhikar (suite)	63

ព្រះរាជក្រិត្យ
ក្រមទសកវិយោ

ក្នុងរាជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា (ចៅពញាសូរ) ព. ស. ១៦៩៣

ហ្លួងធិពន្ធមន្ត្រី ញ៉ាក-ថៃម រួបរួម

ពាក្យផ្តើម

ព្រះរាជក្រិត្យ ក្រមទសកវិយានេះ កើតឡើងក្នុងរាជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា (ចៅពញាសូរ) ក្នុងឆ្នាំជាមួយនឹងក្រមពលទេព នឹងក្រមដទៃៗទៀតជាច្រើន ខុសគ្នាតែថ្ងៃ-ខែ គឺក្រមទសកវិយានេះ គេបានរៀបរៀងឬរួបរួមចម្ងន់ នៅថ្ងៃអាទិត្យខែបុស្សឆ្នាំមមែ ។ ឯក្រមពលទេព គេបានរៀបរៀងឬស្រង់ចម្ងន់ នៅថ្ងៃចន្ទ ៣ កើតខែកត្តិកឆ្នាំមមែ ក្នុងកម្ងន់មហាសកពជ ១៦១៥ ដូចគ្នា ។ ឯសេចក្តីសារសំខ្លះក្រៅអំពីនេះ យើងបានពោលរួចមកហើយក្នុងក្រមពលទេពឯណោះ ។

ពាក្យថា "ក្រមទសកវិយា" ប្រែថា "ច្បាប់សម្រាប់កវិយា ១០ ដំពូក" បានដល់កវិយាដូចម្តេចខ្លះ ច្បាប់ដើមមិនបានពោលទុកដោយច្បាស់លាស់ឡើយ មានន័យតែពីច្បាប់លក់ពិន័យប្រុស-ស្រីប្តីប្រពន្ធ-សហាយស្មន់អន្ធការ-អាពាហ៍ពិពាហ៍ ដូចជាលក់ពិន័យប្តីប្រពន្ធដែលបានគ្នាហើយលះលែងគ្នាវិញ-លក់ពិន័យប្រុសស្រីដែលសហាយគ្នាហើយលះលែងគ្នាវិញ-លក់ពិន័យខ្ញុំនាំដំរត់កូនក្រមុំគេ-លក់ពិន័យអ្នក

ជង្គង់នាំដំរៀតម្ខែពួនគេ - លក់ពិន័យក្រមុំកម្លោះសហាយគ្នា - លក់ពិន័យ
អាពុកម្តាយខាងប្រុសនឹងកូនប្រុស អំពីដំណើរកូនក្រមុំគេរត់មកទៅជា
មួយនឹងកូនប្រុសរបស់ខ្លួន - លក់ពិន័យអ្នកជាទៅសហាយនឹងខ្ញុំគេ -
លក់ពិន័យអ្នកជាក់ស្តែងកូនក្រមុំគេ - លក់ពិន័យកូនប្រុសដែលទៅ
សហាយនឹងកូនក្រមុំគេ ចានហើយលះលែងចោល - លក់ពិន័យខ្ញុំគេ
នឹងខ្ញុំគេចានគ្នាហើយលះលែងគ្នា ។ល។ ដូច្នេះជាដើម មិនមានរៀប
រាប់ចេញឈ្មោះទេសកិរិយាសោះឡើយ ។ តាមទំនងនេះ នាំឲ្យយើង
យល់ថា តាមច្បាប់ជាន់ដើមនោះ មិនមានធ្វើទោសជាក់គុកយ៉ាំង
មានកំណត់ ខែ - ឆ្នាំ ទឹង បង្ខំឲ្យធ្វើការដូចសព្វថ្ងៃនេះទេ, វៀរលែងតែ
មានទោសជាទ្រព្យ ដូចជាសម្លាប់គេដោយអាយាជព្យាបាទជាដើម
ទើបត្រូវសម្លាប់តែម្តង ។ ក្រៅអំពីនេះច្រើនតែធ្វើទោសជាក់ខ្នោះច្រក
ឃ្នាងនឹងកាយផ្តាលបណ្តេញអោក្រៅស ឬលក់ពិន័យតិចច្រើនតាមទោសា-
នុទោស ដូចគោលមកហើយ ។

ឯសំដីពាក្យពេចន៍ ក្នុងក្រមទេសកិរិយានេះ មានពាក្យក្រៅ ជា
ច្រើនអន្លើ ។ ការចម្លងចេញមកនេះ គង់មានភ្លាំងភ្លាត់មិនខានទេ
ដ្បិតច្បាប់សាស្ត្រាស្ទឹកតែនោះ មានវិបត្តិតួអក្សរនឹងសេចក្តីជាច្រើនអន្លើ
ដោយការចារចម្លងរ៉ើរុះមកជាច្រើនតំណ ។ មួយវិញទៀត បើពុំជា
យើងបានធ្វើនយល់ក្នុណា: ដើម្បីតម្យល់ពាក្យនឹងសេចក្តីក្រៅ ពុំជា

ច្រើនអន្ទឹ កំគង់តែមិនសព្វគ្រប់ទេ បើនៅមានសេចក្តីភ្ញាំងភ្ញាត់ខ្លះ យើងសូមអភ័យទោសអំពីលោក អ្នកមើលក្រមនេះក្នុងឧកាសនេះផង ។

នៅទីបំផុត បើទុកជាក្រមទេសកវិយានេះ មិនមានប្រយោជន៍ជាសាធារណៈដល់អ្នកមើលខ្លួនឯង ក្នុងដំនាន់ឥឡូវនេះ ព្រោះជាច្បាប់កន្លងកាលសម័យមកយូរហើយ ទឹងប្រកាន់យកជាច្បាប់សម្រាប់ប្រើការក្នុងសម័យនេះពុំបានឡើយ កំគង់តែមានប្រយោជន៍បានខ្លះ ដល់ក្បួនច្បាប់អក្សរសាស្ត្រ ទឹងជាប្រយោជន៍បានខ្លះ ដល់អស់លោកអ្នកដែលចង់ចេះចង់ដឹងក្បួនច្បាប់ចាស់ ។ ទឹងរបៀបពាក្យពេចន៍សំដីវោហារជាន់ដើម ។ ដ្បិតការចម្លងចេញចោះពុម្ពនេះ យើងបានរក្សាទុកនូវពាក្យពេចន៍សំនួនវោហារតាមច្បាប់ដើមទាំងអស់ មិនបានកែប្រែសម្រួលទៅតាមកាលសម័យឡើយ ។

មួយវិញទៀត ព្រះរាជក្រឹត្យ ក្រមទេសកវិយានេះ នៅខាងចុងបញ្ចប់ដាក់ថា “នេះច្បាប់ទេសកវិយា អ្នកឧកញ៉ាពិភ័ក្តិសេនីចារចប់នៅថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះនក្សត្រឯកស័ក ” ។ ដូច្នេះ មានដាក់បញ្ជាក់តែថ្ងៃ – ខែ – ឆ្នាំ ដែលបានចារចម្លងចប់ គ្មានដាក់សករាជបញ្ជាក់ឲ្យដឹងទេ ប៉ុន្តែមានដាក់លេខ ២០ លើពាក្យថា “ឯកស័ក ” សឲ្យដឹងថា នៅក្នុងកម្ពុជរដ្ឋកាលណាមួយ ដែលមានស្តេចគ្រងរាជ្យក្នុងទៅបានគំរប់ទី ២០ វស្សា ។ តាមទំនងនេះ ប្រហែលជានៅក្នុងកម្ពុជ

រដ្ឋកាល ព្រះហ្វាខសាម្តេចព្រះនរោត្តមព្រហ្មបរិរក្ស (ព្រះករុណា សុវណ្ណគោដ្ឋ) ព្រោះប្រការ ១) ព្រះរហាក្សត្រអង្គនេះ ទ្រង់ភជ-សម្បត្តិជាយូរអង្វែងដល់ ៥០ឆ្នាំ, ២) ទ្រង់ឡើងគ្រងភជសម្បត្តិក្នុង ឆ្នាំវក ទោស័ក ពុទ្ធសករាជ ២៤០៣ បើគិតតាំងពីឆ្នាំនេះ រហូតដល់គំរប់ ឆ្នាំទី ២០ កន្លងភជសម្បត្តិឃើញថាត្រូវនឹងឆ្នាំថោះឯកស័ក ពុទ្ធសករាជ ២៤២៤ ហើយ, ៣) ចំណាស់របស់ស្តេចតែនោះប្រហែលមានអាយុដល់ ៦០ - ៧០ ឆ្នាំហើយ (បើគិតតាំងពីឆ្នាំទី ២០ កន្លងរដ្ឋកាលនោះ រហូត មកដល់ឆ្នាំនេះ ព. ស. ២៤៨៧ ជារយៈវេលាដល់ ៦៤ ឆ្នាំ ឃើញថា សមនឹងចំណាស់របស់ស្តេចតែ) ។ ហេតុដូច្នេះ ទើបគួរយល់ថាព្រះពជ-កិត្យ ក្រមទេសកិរិយានេះ ប្រាកដជាអ្នកទុកញ៉ាំពិតប្រាកដ ដូចមានចារ ចម្លងចប់នៅកន្លងថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះឯកស័ក ២០ ពុទ្ធសករាជ ២៤២៤ កន្លងរដ្ឋកាលនោះឯង ។

ពុទ្ធសាសនបណ្ឌិត្យថ្ងៃ ១១ សេបតេមប្រ៊ី ១៩៤៤

ហ្សង់និតន្ទមន្ត្រី ញ៉ាក - ចែម

ព្រះរាជក្រិត្យ

ក្រែមទសរាំយា

ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះនរាយណ៍ស្តា (ព. ស. ១៦៧៣)

សុភមស្តុសួស្តី សុភមង្គលពហុលចេស្តាជយាតិរេក ១៦១៤ ស័ក
មេនក្សត្រ[1] បុស្សមាសា អាទិត្យពារនាមន្តិ ២ ព្រះបាទសម្តេចនរោត
ព្រះបរមបពិត្រ អ្នកជាអម្ចាស់ស្តេចគង់ឦជព្រះរាជមន្ទីរបុរីបវរមៀលយ
ស្តេចមានព្រះរាជឫទ្ធានុភាព បើកព្រះបន្ទូលមធុរព្រះតម្រាស់គ្រាស់លើក្បួន
ទុកញ៉ាសុភាធិបតី បវរក្សត្រពិភក្តិក្រឡាប្រាក្រមស្តម្ភពាហុ ឲ្យធ្វើជាមាត្រា
ប្បាប់ប្រញ៉ាប្តី ចិញ្ចឹមក្រឡាសមរដកខុនលែងឲ្យចេញមកដល់ព្រះវង្ស
នូវរាជវង្សវ្រុងធ្នារ នូវរាជគ្រូបុរោហិត នូវអស់នាហ្មឺនមុខមន្ត្រី ភរិបណ្ឌិត
ព្រឹទ្ធាចារ្យ នូវអស់ចៅហ្វាយស្រុក នៅលំនៅខេត្តខ័ណ្ឌផង តាំងភូង
ឲ្យបានដឹងក្នុងព្រះមាត្រាច្បាប់នេះ កុំឲ្យរំដួលចិត្តភស្តែកើតកោលាហល
កង្វល់ក្តៅក្រហាយក្នុងផ្ទៃក្រាមឡើយ ឲ្យបានក្សេមក្សាន្តអស់ចិត្តអាណា
ប្រជានុកស្តួផង នាកំឡុងផ្ទៃក្រាមនេះ ។ ទើបព្រះបាទអ្នកជាអម្ចាស់
គ្រាស់បើកព្រះអំណាចឲ្យទុកញ៉ាសូភាធិបតី ជាមាត់ផ្ទៃក្រាម ឲ្យស្រដី

---

១ ត្រង់ពាក្យថា "១៦១៤ ស័ក មេនក្សត្រ" គឺមហាសកពាជ ១៦១៤ ឆ្នាំមមែនក្សត្រ

២ ពាក្យថា "បុស្សមាសា អាទិត្យពារនាមន្តិ" គឺថៃបុស្សក្នុងអាទិត្យ នាដើត ។

មុខពាដការសារតើដំនុំសេចក្តីយកទ្វាត់អបករណ៍ (១) ចូលជាដង្វាយថ្វាយ
ព្រះបាទអ្នកជាម្ចាស់ច្បាស់ដោយទូវព្រះមាត្រាកេះនេះ (២)

មាត្រា ១ គេះយោបីពាដវង្សវ្រែងធ្នារ ទុកញ៉ា, ពញា, ព្រះដី, ចៅ
ហ្វាំន, មានឆារ, ឥតឆារ, ទូវអាណាប្រជានុកស្តេចាសការកួយតារ
ខ្មែរ ចិន ចាម ជ្វា ចាកំង យួន ស្វៀង មន តួន ចារគូបុកេហិត ពល
អ្នកឆារ អ្នកជា ខ្ញុំគេ មហាតចាទត្រា ពលព្រះកញ្ចះព្រះសង្ឃបំពេស
ចោសចាសឲ្យចានដឹងក្នុងព្រះរាជកិត្យច្បាប់នេះ កុំឲ្យអាណាប្រជា
នុកស្តេផង កន្ទងរំលងនឹងព្រះរាជកិត្យនេះឡើយ ។

មាត្រា ១ សោត ទូវអ្នកផងឲ្យទៅដណ្តឹងកូនក្រមុំគេយកជាប្រពន្ធ
មានក្រាបសំពះមេចាជាសូវេចការហើយ បើប្រលែងលែងគ្នាវិញនោះ
ឲ្យចៅពញាជាខុនក្នាក់ឆារខុនលែង ហូតយកទ្វាត់តម្លឹង ៦ ក័ចាន តម្លឹង
៣ ក័ចាន និមួយតួ ទូវដើងគោះស្លឹង ១ និមួយតួហោង ។

មាត្រា ១ សោត បើប្រពន្ធស៊ីស្វាងឹកកំណត់ហើយ បើប្រលែង
លែងគ្នាវិញ ឲ្យយកទ្វាត់តម្លឹង ៣ ក័ចាន ចាទ ១០ ក័ចាននិមួយតួ
ទូវដើងគោះស្លឹង ១០ និមួយតួហោង ។

• ពាក្យថា "អបករណ៍" តាមរូបស័ព្ទប្រែថា ដំណើរប្រាសចាកអំពើ គឺការធ្វើមិនល្អ, អំពើពុំប្រសើរ, ការធ្វើខុស ។ តែក្នុងទីនេះ ពាក្យថា "យកទ្វាត់អបករណ៍" សំដៅការយកពន្ធ ជាក់ព្រះឃ្លាំងព្រះរាជទ្រព្យ ចំពោះបុរសស្ត្រីដែលធ្វើខុសនឹងព្រះរាជប្រពន្ធរបស់ព្រះមហាក្សត្រ ដូចមានសេចក្តីសារស័ព្ទក្នុងផ្នែរបៀងនេះក្រមនេះស្រាប ។ ២. មាត្រាកេះនេះ គឺមាត្រាអ្វីច្នេះ ឬមាត្រាអ្វីមកទៅនេះ ។

មាត្រា ១ សោត បើប្រពន្ធប្អូនស្មើថង់រងហើយ ប្រវែងវែងគ្នាវិញ ឲ្យខុនភ្នាក់ងារហូតយកខ្វាត់ប្អូន ១០ កំប៉ុន ប្អូន ៦ កំប៉ុន ដើងកោះស្មើង ១០ និមួយគួរហោង ។

មាត្រា ១ សោត បើប្រពន្ធស្មើម្ខាងវែង បើ (ប្រវែងវែង) វែងគ្នាវិញ ឲ្យខុនភ្នាក់ងារហូតយកខ្វាត់ប្អូន ៦ កំប៉ុន ប្អូន ៣ កំប៉ុន ដើងកោះស្មើង ១០ និមួយខ្នងហោង ។

មាត្រា ១ សោត បើអ្នកផងជាអន្តករ[1] ផងគ្នា ប្អូនសំពះខ្មោចមេប្អូហើយប្រវែងវែងគ្នាវិញ ឲ្យហូតយកខ្វាត់ប្អូន ៦ ដើងកោះស្មើង ១០ និមួយគួរហោង ។

មាត្រា ១ សោត នូវអ្នកផងជាស្មន់អន្តកនេងគ្នាហើយវែងគ្នាវិញ ឲ្យហូតយកខ្វាត់ប្អូន ៣ ដើងកោះស្មើង ១០ និមួយគួរហោង ។ លាងខ្មាសប្អូន ៦ កំប៉ុន ប្អូន ៣ កំប៉ុនហោង ។

មាត្រា ១ សោត កោះបើអ្នកផងនាំម្រែត់ (ដំរែត់, ពង្រែត់) ខ្ញុំគេកោះប្រុសក្តី ស្រីក្តី កោះនាំម្រែត់ទៅលក់ក្តី នាំម្រែត់ទៅយកជាប្រពន្ធក្តី ឲ្យពិន័យអាប្រុសនាំម្រែត់ខ្ញុំគេជាប្រាក់តម្លឹង ៣០ មេស្រីខ្ញុំគេតម្លឹង ១២ ដើងកោះប្អូន ៥ ដើងកោះអាប្រុសនាំម្រែត់ស្មើង ១០ ហោង ។

---

១ អន្តករ មកពី អន្ត: "ដងដំត, ខ្ចាក់" + ករ: "ធ្វើ" > អន្តករ: "ធ្វើឲ្យដងដំត, ធ្វើឲ្យខ្ចាក់" ជាទស្សេចក្តីថា លួចលាក់ធ្វើកិច្ចខោះក្នុងទីកំបាំងភ្នែកអ្នកផង ត្រូវខំតស៊ូដងលួចថ្ងៃនេះ ហៅថា សហាយ ត្រើនខំយាយថា សហាយស្មន់អន្តករ ។

មាត្រា ១ សោត បើវ៉ៃគេនាំម្រែតំអ្នកណាក្តី កូនក្រមុំគេក្តី បើចាប់បាន ឲ្យទៅជ្រាបអម្ចាស់ ហើយឲ្យតិន័យអាប្រុសចោរខ្លួរមេស្រីចោរនោះដាច់ស្លរិលនិមួយៗតួ ឲ្យជ្រាណីទឹកដោះមេស្រី (ម្ហាយ) តម្លឹង ៥ ឲ្យទៅពញ្ញាជាខ្ទុនក្នាក់ជារហូតយកភ្ងាត់ព្រះឃ្លាំងពុះគ្រឹង[1] និមួយៗតួហោង ។

មាត្រា ១ សោត បើអ្នកឯណានាំម្រែតំប្រពន្ធគេ (ដែល) បានរៀបការសំពះភ្ងេច ជាច់សត្វដើង ២ ដើង ៤ ក្តី[2] ឲ្យតិន័យប្រុសតម្លឹង ១២ ស្រីតម្លឹង ៥ ឲ្យហូតយកភ្ងាត់បាទ ១០ និមួយខ្ទួន ភ្ងាត់ព្រះឃ្លាំងតម្លឹង ៦ ដើងកោះស្លឹង ១០ និមួយខ្ទួនហោង ។

មាត្រា ១ សោត បើប្រពន្ធបានគ្រាបក្បាលសំពះមេបាម្ហាយអាពុកក្តី គោះបីបានគ្រាបថ្វាយបង្គំព្រះបាទអ្នកជាអម្ចាស់ក្តី គោះសំពះ ១០ ហូរាន់ក្តី ៨ ហូរាន់ក្តី ៦ ហូរាន់ក្តី បើឈ្លោះគ្នាហើយ បានប្តឹងទៅក្រមឲ្យដំនុំផ្តេចចេញហើយ ឲ្យខ្ទុនក្នាក់ជារហូតយកភ្ងាត់តម្លឹង ៦ ខ្លួរដើងកោះស្លឹង ១០ និមួយតួ ។ ឯរបស់សម្បាច់តាំងប៉ុន្មាន។ ឲ្យទៅពញ្ញាជាខ្ទុនក្នាក់ជាខ្លួរព្រះសុគាដំនុំចែក ហើយឲ្យហូតយកថ្លៃរបស់តាំងនេះ តាមដម្លៃរបស់ប៉ុន្មាន។ (ចំនួន) ១០ ឲ្យយក ១ . . . . . ។

---

១ ពុះគ្រឹង គឺពះយកតែពាក់កណ្តាលហូតយកភ្ងាត់ជាក់ព្រះឃ្លាំង ។ ២ គឺសើចការរៀបការសំពះភ្ងេចមេបាខោះ ពេលខទិញឬសម្លាប់សត្វដើង ២ ដូចមានខ្ទាជាដើម ខំងសត្វដើង ៤ មានខ្ទ្រីកគោជាដើម ។

. . . . . បើគោសសេចក្តីឯណា ។ ដល់ជាត្រូវបែអស់របស់ខ្ញុំ
បើចៅក្រមដំនុំផ្តាច់ឯងក្តី ចែករបស់ខ្ញុំឯងក្តី នោះជាបំពុំងបាត់មុខដារ
អ្នកទុកញ៉ាសុកាធិបតី ឯខ្លាត់ដំនុំអ្នកឲ្យលំនៅនោះ ឲ្យក្រយាពិន័យកាត
១០ ឯអាចារមេចារនោះ ត្រូវឲ្យក្រយាពិន័យដាច់សុរិលហោង (១) ។
ឲ្យថ្កុំណីទឹកដោះគម្ងឹង ៥ និមួយគួ ហើយឲ្យទៅចៅពញាជាខ្ញុំក្នាក់
ដារយកភ្នាត់ព្រះឃ្លាំងពុះគ្រឹង និមួយគួហោង ។

មាត្រា ១ គោះបើអ្នកផងទៅស្នងអន្ធការនឹងកូនក្រមុំគេ ហើយម្តាយ
អាពុកមាក្តើបងប្អូនឯប្រុស ឲ្យទៅដណ្តឹងម្តាយអាពុកឯស្រីនោះគេពុំ
ព្រមឲ្យជាប្រពន្ធកូនឯងនោះឡើយ ។ គោះចិត្តស្រីនឹងប្រុសនោះវា
ស្រឡាញ់គ្នាវាហើយ ស្រីវាវត់ទៅនឹងប្រុសទៅ (នៅ) នឹងអាពុក
(ម្តាយ) ប្រុសនោះ ព្រះកែត្យដីកាថាឲ្យអាប្រុសនៅម្តាយអាពុកអាប្រុស
ជាអន្ធការនឹងកូនក្រមុំគេ នឹងកូននឹងប្រពន្ធគេ គោះបើចាប់បានក្តី ចាប់
ពុំបានក្តី វាវត់រួចក្តី នោះឲ្យប្តឹងចៅក្រមឲ្យទៅចាប់ធ្វើក្តីឲ្យក្តត់ពាក្យ
បើអាចារមេចារវាធ្វើយថាលួចមែន ចោរមែន គួរដំនុំរកមេតន្ទាប់គ្រប
តន្ទាប់ ឃើញហើយឲ្យកាត់ក្រយាពិន័យ អាចារនូវមេចារដាច់សុរិល
ឯមេអណ្តើកមេនាំការប្រពន្ធគេ កូនក្រមុំគេនោះ (ឲ្យពិន័យជាច្រាក់)

---

១ – មាត្រានេះស្តាប់ចាប់យកសេចក្តីគុំទាន់ច្បាស់ ប្រហែលជាមានបាត់សេចក្តីជា
ច្រើនឃ្លា ច្រើនអង្គ ។

តម្លឹង ១៩ ហើយឲ្យចៅតាញាដាខុនក្នាក់ដារហូតយកទ្វាត់ព្រះយ្ងាំងពុះ
គ្រឹង ឯប្រតន្ទះបើប្តីស្រឡាញ់ខឹងយកជាប្រតន្ទវិញបានហោង ឲ្យបង់
តែទ្វាត់តម្លឹង ៦ ប៉ាត ២ ខ្លះដើងកោះស្លឹង ១០ និមួយៗតួឲ្យខុនក្នាក់ដារ
ហោង ។

មាត្រា ១ (សោត) កោះកម្ងោះនឹងក្រមុំជាអន្តរកនើងគ្នាហើយនាំ
ម្រែត់ទៅពឹងពាក់សំណាក់ទៅឯកញ្ញា" ព្រះពញ្ញា ហ្នឹង ខ្លួវមេស្រុក ខ្លួវ
សាច់ញាតិបងប្អូនដីចៅព្រៀង (លាន) នោះ ព្រះកែត្យដីកាឲ្យពិន័យ
កុំឲ្យបង្គាប់ការឡើយ មានតែប្រាក់ខាន់ស្លាតិចច្រើនប៉ុន្មាន ក្តី បើ
ប្រាប់ចៅពញ្ញា ជាខុនក្នាក់ដារ ឲ្យហូតយកទ្វាត់តម្លឹង ៣ និមួយតួ ដើង
កោះស្លឹង ១០ និមួយតួ ។ ប៉ែតុំបានប្រាប់ក្នាក់ដារស្រុក ខ្លួវចៅពញ្ញាជា
ខុនក្នាក់ដារ ទុកជាម្តាយអាពុកមេស្រីនោះបំបាំងទ្វាត់ព្រះយ្ងាំងឯកញ្ញា
សុភាធិបតី ឲ្យពិន័យជាប្រាក់ដើង ៣ តម្លឹង ១៧ [1] កុំឲ្យប្រាណីឡើយ ។
ឯប្រាក់ខាន់ស្លានោះឲ្យហូតយកពុះគ្រឹង តាមដោយតិចច្រើននោះឯង ឯ
អាចោរខ្លួវមេចោរនោះ ទុកជានាំម្រែត់កូនក្រមុំគេហោង ដ្បិតពុំបានដួន
កូនក្រមុំគេឲ្យពិន័យជាគ្រឹតុណាហោង ។ បើប្រាប់ខុនក្នាក់ដារឲ្យហូត
យកទ្វាត់តម្លឹង ៣ ដើងកោះស្លឹង ១០ និមួយខ្លួន ឯអាពុកម្តាយអាប្រុស

---

១ ពាក្យថា ជីង ឬ តម្លឹង ជាអាត្រាថ្លាក់ប្អូរណា បើគិតតាមអាត្រាប្រាក់សៀម ក្នុង ១ ជញ្ជីង
មានដំឡៃ ៨០ ជាង, ៣ ជញ្ជីង ត្រូវជា ២៤០ ជាង ។ ឯតម្លឹងមានដំឡៃ ៤ ជាង ១៧ តម្លឹង
ត្រូវជា ៦៤ ជាង ។ ហេតុនេះ ជីង ៣ តម្លឹង ឬ ត្រូវជា ៣០៤ ជាង ។

ដែលឲ្យលំនៅមេស្រីនូវអាប្រុស ដែលពុំបានយកទៅដូនម្តាយអាពុក
ស្រីនោះឡើយ ឲ្យពិន័យម្តាយអាពុកពុំបានដូនកូនក្រមុំគេ ជាប្រាក់តម្លឹង
១៥ និមួយតួ នូវដើងកោះស្លឹង ១០ និមួយតួហោង ។ បើអាពុកម្តាយ
អាប្រុសបានដូនកូនក្រមុំគេហើយ ឥតគោរសឡើយ ឲ្យចៅពញាជាខុន
ភ្នាក់ងារហូតយកតែខ្លាត់បាទ ៦ ដើងកោះស្លឹង ១០ និមួយតួហោរ ។
បើលែងគ្នា ហូតយកខ្លាត់តម្លឹង ៣ និមួយខ្លួន ដើងកោះស្លឹង ១១ និមួយ
តួហោង ។ បើចិត្តប្រុសស្រឡាញ់ (ស្រី) នោះឲ្យដណ្តឹងម្តាយអាពុក
ឯស្រីនោះដើង ១ ដើង ២ ដើង ៣ បើម្តាយអាពុកពុំឲ្យកូននោះជាប្រពន្ធ
ប្រុសនោះឡើយ បើចិត្តប្រុសនោះវាអាល័យស្រីនោះវាទៅតាមគ្នាវា
នោះបើពុំរាប់កូនឡើយឲ្យភាត់ខាន់ស្លាជាប្រាក់ដើង ៣ ស្លាសំពះ ៣ រួច
ហើយឲ្យចៅពញាជាខុនភ្នាក់ងារ យកខ្លាត់ព្រះឃ្លាំងពុះគ្រឹងហោង ។
តែបានប្រាប់ភ្នាក់ងារស្រុក នូវភ្នាក់ងារជាខុនភ្នាក់ងារឲ្យបានដឹងផង បើពុំ
បានប្រាប់ ទុកជាបំបាំងខ្លាត់ព្រះឃ្លាំងព្រះរាជទ្រព្យ ឲ្យពិន័យអាពុក
ម្តាយទាំងសងខាង ជាប្រាក់ដើង ៣ តម្លឹង ១៧ និមួយតួហោង ។

មាត្រា ១ សោត មេស្រីនោះវាត់ទៅនៅនឹងប្រុស នឹងម្តាយអា-
ពុកប្រុសនោះ ដល់ថ្ងៃ ១ ថ្ងៃ ២ ថ្ងៃ ៣ ម្តាយអាពុកប្រុសនោះពុំបានយក
កូនស្រីគេទៅដូនម្តាយអាពុកឯស្រីនោះឡើយ ពុំរៀបការសំពះគេឡើយ
(បើ) ប្រាកដដូច្នោះ ឲ្យពិន័យអាពុកទាំងតួប្រុសជាចំសុរិលហោង ។

ហើយឲ្យចៅតញ្ជាជាខុនក្នាក់ដារយក (ខ្លាត់) ព្រះយាំងពុះគ្រឹង ឯអាតុក ម្តាយមេស្រីនោះខុកជាបំប្លុំង ព្រះរាជទ្រព្យឲ្យតិនយ៉ាជាប្រាក់ដឹង ៣ តម្លឹង ១៧ ឲ្យប្រណីទឹកដោះតម្លឹង ១៩ ហោង ។

មាត្រា ១ សោត ខាងអ្នកជងចៅស្នងអន្ធកវនឹងខ្ញុំគេ ពុំបានកូនក្តី បើបានកូន ១ ក្តី បានកូន ២ ក្តី អាប្រុសនោះលែងវិញ ឲ្យតិនយ៉ាជាប្រាក់ខុកជាអាប្រុសនោះ លួចកូនគ្រែមុំគេ តម្លឹង ៤៥ ឯកូននោះឲ្យបើកយកតែកំភ្លាំងតម្លឹង ៥ និមួយខ្ទួន លាងភ្នាសបាទ ៦ ឲ្យយកខ្លាត់ព្រះយ៉ាំងអំពីអាប្រុសនោះ តម្លឹង ៦ ប៉ាទ ១ ដើងគោះបាទ ១ និមួយតួហោង ។ បើខ្ញុំគេចៅកាចនឹងអ្នកជាវិញ ពុំមានកូនក្តី មានកូនប៉ុន្មាន ។ ក្តី លែងគ្នាវិញនោះ ឲ្យចៅតញ្ជាជាខុនក្នាក់ដារយកខ្លាត់ . . . អំពីអាប្រុសខ្ញុំគេនោះ ហោង មេស្រីអ្នកជាតម្លឹង ៣ ដើងគោះស្លឹង ១០ ខ្ញុំគេបាទ ៥ និមួយតួហោង លាងភ្នាសបាទ ៦ ។

មាត្រា ១ (សោត) នោះខ្ញុំគេបង្កាត់បន្សាចោរ[1] ជ្រាបតុំពុំបានប្រាប់ក្នាក់ដារស្រុក ខ្លួវចៅតញ្ជាខុនក្នាក់ដារនោះ (ត្រូវ) តិនយ៉ាជាប្រាក់ដឹង ៣ តម្លឹង ១៧ ឲ្យហូតខ្លាត់ព្រះយ៉ាំងពុះគ្រឹងហោង ។

---

១ ប្រហែលជាសំដៅសេចក្តីថា លាក់បំពួនបង្ខំចិត្តបង្ខាំងចោរទេដឹង ។

បកប្រែ ។

រឿងព្រៃងប្រទេសរូអាំង

លោក ផេង - ឆ្លីវ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ
បែបបកភាសាចាំង

(តមក)

នៅវេលាព្រឹកមួយ មេឃស្រឡះគ្មានពពកបិទបាំង ព្រះអាទិត្យ, នាងក្រមុំជាអ្នកបោសព្រះពុទ្ធរូបានចូលមកបង្គំគាល់ព្រះពុទ្ធ ហើយក្រាបទូលថា: បពិត្រព្រះសម្មតិទេពមហាពុទ្ធ ! ប្រជាពុទ្ធស្តាំងអស់មានសេចក្តីសប្បាយក្រៃពេក ព្រោះបក្សីច្រៀងនិយាយហើយ; គ្មានតែអ្នកគង្វាលច្រៀមម្នាក់ដើរចូលមកក្នុងព្រះវិហារ សាប់តែបក្សីតាំងបំពាងរងារពេញទំហឹង ស្ទើរតែបែកបំពង់ក; គឺជាលើកទីពីរហើយ សូមព្រះករុណាថ្លៃវិសេសទ្រង់ផ្តាប គាលណាអ្នកគង្វាលច្រៀមចូលមកព្រះវិហារ, ហើយវាឈប់ងារក្នុងវេលាដែលអ្នកគង្វាលនោះចេញទៅវិញ ។

ព្រះពុទ្ធមានព្រះបន្ទូលថា: ចូរឲ្យគេនាំអ្នកគង្វាលច្រៀមមកក្រយើងយ៉ាងប្រញាប់ ។

នាងនោះក្រាបបង្គំទូលស្នងថា: បពិត្រព្រះសម្មតិទេព ! អ្នកគង្វាលច្រៀមនោះ ជាអ្នកបរទេស មនុស្សក្នុងទីនេះគ្មាននរណាស្គាល់ខ្លះ, ខ្ញុំ

ម្ចាស់ភ្នែគេ ឯ ឃាយថា ព្រះពជបុត្រាបស់ព្រះអង្គចាត់ឲ្យក្រុមល្បាតស៊ើប រកដើម្បីចាប់អ្នកនោះ ។

ព្រះពជាមានព្រះតម្រាស់ថា: ត្រូវមើហឆងឆងស្បៀម កុំនិយាយ បង្ខិចកូនបេស់អញ; ហេតុយ៉ាងដូចម្តេច ចានជាមើហឆងឆងហានចោទ ប្រកាន់កូនប្រុសទាំងពីរបេស់អញ? ។

ប៉ុន្តែព្រះពជាចានចាត់ការយ៉ាងស្ងាត់ឲ្យក្រុមនគបាល ឃ្លាំចាំ មើលអ្នកគង្វាលចៀម កាលណាក្រុមនគបាលចានឃើញវាចូលមក កងព្រះវិហារ ត្រូវចាប់យកមកថ្វាយព្រះអង្គ ។ រឿងនេះតើប្រព្រឹត្តទៅ ដូចម្តេចខ្លៃត? គឺនៅថ្ងៃបុណ្យទី ១ ព្រះពជាកំយាងទៅកាន់ព្រះវិហារដែរ ដើម្បីឲងព្រះសណ្តាប់ទ្រូវសំនៀងនៃបក្សីដោយព្រះកាណិឲងផង ដើម្បី ទតអ្នកគង្វាលចៀមដ៏អស្ចារ្យដោយព្រះនេត្របេស់ព្រះអង្គផង ។ ជា គ្រោះល្អ បើកុំតែព្រះពជាយាងទៅ ការតយុទ្ធរវាងក្រុមមនុស្សស្រេចម្ងាត់ របេស់ព្រះអង្គនឹងក្រុមមនុស្សរបេស់ព្រះពជបុត្រ ក្នុងការដេញ្ជើមចាប់ទ្រូវ អ្នកគង្វាលចៀមតែរឿងខ្លួន មិនដឹងជាយ៉ាងដូចម្តេចទៅទេ ។ ព្រះពជា បង្គាប់ឲ្យគេនាំអ្នកគង្វាលចៀមទៅក្នុងកំង ហើយថ្កាប់កុំឲ្យនរណាធ្វើទុក្ខ បុកម្នេញអ្វីឡើយ ព្រោះព្រះពជាហាក់ដូចជាមានព្រះហឫទ័យទន់ទោរ ទៅរកអ្នកគង្វាលចៀមនោះដែលនៅក្មេងនៅឡើយ ហើយមានទំនងជា អ្នកសុភាពនឹងមានអាការៈជាអ្នកស្លាហានផង ។

លុះចេញផុតពីព្រះវិហារហើយ ព្រះពុទ្ធជាម្ចាស់ក៏បង្កើនព្រះហឫទ័យពន់ពេក ក៏ស្តេចតម្រង់ទៅព្រះបរមកដកំនែតម្ពង ។

ព្រះពុទ្ធជាម្ចាស់ត្រាស់សួរអ្នកគង្វាលចៀមថា: ម្នាលកុមារ! ចូរឯងនិយាយរឿងប្រាប់យើងមើល: តើឯងមកពីណា? ឯងមានឪពុកម្តាយឬទេ? ហេតុដូចម្តេចបានជាឯងមកកើតទីនេះ? ។

– បពិត្រព្រះមហាពុទ្ធដ៏ចំរើនទូរមហានុភាព! រឿងរបស់ខ្ញុំព្រះបង្គំវែងណាស់. ខ្ញុំព្រះបង្គំមានតាំងឪពុកម្តាយតាំងបងប្អូន; បើព្រះអង្គសព្វព្រះពុទ្ធហឫទ័យឲ្យខ្ញុំព្រះបង្គំរ៉ាយរ៉ាប់ អំពីខ្ញុំព្រះបង្គំមកពីណានឹងហេតុដូចម្តេចបានជាមកកើតទីនេះ នោះត្រូវមានពេលវែងទើបនិយាយថ្វាយបាន; បើដូច្នេះ ខ្ញុំព្រះបង្គំនឹងត្រឡប់មកថ្ងៃរឿងនេះថ្វាយ នៅវេលាព្រឹកស្អែកពីព្រលឹម ព្រោះឥឡូវនេះហួសពេលហើយ ។

– ម្នាលកុមារ! ចូរចាំណែ! ស្អែកនៅពេលថ្ងៃរះ យើងរង់ចាំឯង ។

ស្អែកព្រលឹមឡើង អ្នកគង្វាលចៀមមកតាមព្រះពុទ្ធបណ្តាំ ហើយមិនយូរប៉ុន្មាន គេក៏នាំទៅថ្វាយព្រះពុទ្ធជា ។

ព្រះពុទ្ធជាមានព្រះបន្ទូលសួរថា: ម្នាលកុមារ! ចូរឯងនិយាយមើល: តើហេតុដូចម្តេច ក៏បក្សីទាំងឡាយកើតកាលដែលឯងចូលមកកើតព្រះវិហារ ហើយឈប់រង់កើតវេលាដែលឯងចេញទៅវិញ? ។

– បពិត្រព្រះមហាក្សត្រដ៏ឧត្តមអំណាច! ព្រះអង្គទ្រង់ជ្រាបរឿងនេះ ព្រមទាំងរឿងដទៃទាំងឡាយដោយដាក់ច្បាស់ លុះតែទ្រង់បណ្តាយឲ្យ ខ្ញុំព្រះបង្គំនិយាយប្រាប់នូវរឿងសព្វគ្រប់ កុំបីព្រះអង្គបង្អាក់ឡើយ ។

ខ្ញុំព្រះបង្គំ នៅពុកក៏មាន បងប្រុសក៏មាន, ខ្ញុំព្រះបង្គំបានចេញពីផ្ទះលោកនៅពុក មានបំណងនឹងស្វែងរកនូវឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលលោកនៅពុកត្រូវការពន់ពេក តែលោកមិនអាចនឹងធ្វើឲ្យសម្រេចបានតាមសេចក្តីបំណង; លុះត្រាចនៅបានពីរ – បីថ្ងៃ ខ្ញុំព្រះបង្គំបានដល់មាត់ព្រៃមួយដ៏ស្អាតត្រជាក់ដែលមានផ្លូវបែកជាច្រើន, ខ្ញុំព្រះបង្គំកំណត់ខុកក្នុងចិត្តថានឹងសម្រាកអាយមួយភ្លែតក្នុងទីនោះ ហើយក៏តាំងបង្អាត់ក្តៅងយកស្បៀងចេញមក ប្រុងប្រៀបនឹងបរិភោគ ស្រាប់តែលេចកញ្ជ្រោងកញ្ជាស់ពីណាមួយ មកមួយរំពេច ទៅកៀរខ្ញុំព្រះបង្គំ ។ មិនដឹងជាវាមកពីទិសណា ខ្ញុំព្រះបង្គំក៏មិនបានឃើញ, បើតាមស្មានប្រហែលជាវាចេញពីកន្លែងដ៏ម្ភក ។

កញ្ជ្រោងនិយាយនឹងខ្ញុំព្រះបង្គំថា: ខ្ញុំសូមរាង្វរចិត្តអ្នក, អ្នកមេត្តាឲ្យខ្ញុំអាងក្តៅងផង ខ្ញុំឆ្ងាញ់ត្រូន ចូរអ្នកមើល ធ្មេញរបស់ខ្ញុំណ្តុំគ្នាកិក ។, មា៉ងទៀតសូមៈមត្តាករុណាឲ្យនំបុ័ងមួយដុំនឹងស្រាមួយកែវដល់ខ្ញុំផង ដើម្បីនឹងបង្អន់អារសៃកឃ្លាន ដែលកចាក់ដៅតខ្លួនខ្ញុំ, ហើយបើចង់ឲ្យ

ខ្ញុំអាចអាស្រ័យជាសុខនឹងអាងក្តៅនឹងឥតភ័យ សូមអ្នកចង្អុលផ្លែទុកឲ្យជាប់ខ្លាចក្រែងវាទាំងពីរ ។

ទូលព្រះបង្គំក្រាបថា: មិនអីទេ ចូរឯងមកអាងក្តៅនឹងចុះ, នេះនែ៎សម្បុរអាហារអញ ដបស្រាអញ ចូរឯងអាស្រ័យនឹងអាងតាមគាប់ចិត្តចុះ ។

រួចទូលព្រះបង្គំចង្អុលផ្លែជាប់ ហើយយើងទាំងពីរនាក់ គឺទូលព្រះបង្គំនឹងកន្ត្រៃឆ្នាងដដែកគ្នាលេងពីនេះពីនោះ, និយាយទៅ និយាយមកទូលព្រះបង្គំថ្វែងច្បាប់វា ខ្លួវការណ៍ដែលទូលព្រះបង្គំត្រូវស្វែងរក ដោយសួរវាក្រែងលោវាដឹង តើទូលព្រះបង្គំនឹងត្រូវធ្វើដូចម្តេច បែបណា ដើម្បីញុំាងកិច្ចនុ៎ះឲ្យបានសម្រេចដូចក្តីប៉ុ្មាថ្នា ។

កន្ត្រៃឆ្នាងឆ្លើយច្បាប់ថា: រឿងនេះ សូមលោកកុំព្រួយឲ្យសោះ, ស្អែកឡើង ពេលសងៀតតឹត យើងនឹងចេញឆ្ងើដំណើរទាំងពីរនាក់ ហើយខ្ញុំអាចជានាអះអាង បើការណ៍ហ្នឹងមិនសម្រេច ខ្ញុំឲ្យអ្នកចងកខ្ញុំព្យួរឡើង ។

យើងនៅអាងក្តៅទាំងពីរនាក់ យើងបបួលគ្នាបរិភោគអាហារជាកល្យាណមិត្ត រួចកន្ត្រៃឆ្នាងឲ្យពរដល់ទូលព្រះបង្គំថា: ភក្តីសុវត្ថិ! ហើយវាក៏អន្លង់ជានមួយរំពេចហ្មត់ទៅ ដូចជាខ្មោចលង់, ទូលព្រះបង្គំចុះតែតប់ប្រមល់ក្នុងចិត្ត មិនដឹងឆ្លើដូចម្តេចនឹងឲ្យដឹងថាវាមកតំវិសណា រួចវាចេញទៅវិញតាមកន្លែងណា, កំពុងតែគិតចុះគិតឡើង ស្រាប់តែទូលព្រះបង្គំឮទូលព្រះពជ្ឈានដំណេកលក់ទៅ ។

លុះត្រៃកុឡើង គេក្លែងមកដល់ ទូលព្រះបង្គំកំពុងតែសំឡឹងមើលដុំថ្មខ្លះដែលមានពន្លឺដូចជាមនុស្សត្រីខ្លះ ដូចជារូបសេះពីរ ដូចជារូបខ្លែពីរ, កាលគេក្លែងមកដល់ហើយ ទូលព្រះបង្គំក៏រៀបប្រដាប់ប្រដាធនឹងធ្វើដំណើរចេញទៅ ។

សត្វគេក្លែងលោតដំត្រឡប់ប៉ីដង ស្រាប់តែក្លាយខ្លួនជាមនុស្សម្នាក់សើចញញឹមទៅពីមុខទូលព្រះបង្គំ, គាត់និយាយបណ្តើរ ដើរបណ្តើរច្រាបទូលព្រះបង្គំថា : កន្លែងដែលទូលព្រះបង្គំអាស្រ័យដំណេកយប់មិញ គឺជាដីរបស់គាត់។ មានប្រពន្ធកូន ប៉ុន្តែគាត់ត្រូវសិល្បៈរបស់គេ។ ជាក់ទណ្ឌកម្មឲ្យគាត់នៅស្បែកគេក្លែងលុះត្រាតែមានទណ្ឌិតណាចិត្តល្អបានមកប្រទះ ហើយគាណិតឲ្យអាំងភ្លើង ឲ្យទំបុងស៊ី ឲ្យស្រាងឹត ទើបឲ្យរបូតចេញពីស្បែកគេក្លែង; ឥឡូវគាត់បានរួចពីគ្រោះថ្នាក់ រាប់ឆ្នាំអាត្រក់ហើយ ហេតុនេះ គាត់ទឹងតាមដូនទូលព្រះបង្គំទៅសព្វទិសទីកន្លែង ហើយទឹងមិនលះបង់ទូលព្រះបង្គំឡើយ មុនដែលទូលព្រះបង្គំមិនគាន់សម្រេចកិច្ចការសឹងកន្លងវត្តដែលត្រូវការ ។

ទូលព្រះបង្គំដឹងដូច្នោះហើយ មានសេចក្តីរីករាយក្រៃពេក ហើយយើងនាំគ្នាដើរទៅ លេចកាលចូលព្រៃ លេចព្រៃចូលភ្លាម ក៏បានដល់មាត់ព្រៃមួយ រួចនាំគ្នាដេកក្នុងទីនោះ ។ សំឡាញ់របស់ទូលព្រះ

បង្ហិចប្រាប់ថា: ម៉ែថ្លៃស្អាត យើងត្រូវចូលកន្លែងដែនយក្ស គឺជាប្រទេសដែល
មានវត្ថុដែលខ្ញុំត្រូវការរក ។

ស្អាតឡើង យើងចូលកន្លែងនគរយក្ស ដើរដោយសេចក្តីប្រយ័ត្ន
លុះវេលាល្ងាច យើងបានដល់ទីប្រាសាទរបស់វា ។ គេមិនអាចពណ៌-
នាទ្រព្យសំអាងដែលមាននៅក្នុងទីនោះឡើយ គឺសួនច្បារ ប្រកបដោយផ្កាគ្រប់
ពណ៌និងដើមឈើគ្រប់បែប, ដំបូលប្រាសាទក្តីចាំងដូចជាកញ្ចក់ត្រូវថ្ម,
កំពែងមានតាក់តែងដោយរូបផ្សេង ។ ដោយផ្កាចម្លាក់ក៏មាន ដោយក្បាច់
ដើងកោសទឹបមាសខាងក្នុង មានទឹកប្រាក់ហូរឡើងទៅលើដូចកាំជ្រួច ។
ដ្ឋនជាមានកត្តូវដែរពេលនោះ. ពួកយក្សមិននៅ យើងឃើញស្រីក្រមុំម្នាក់
យ៉ាងស្អាតចេញមកទទួលយើងនៅមាត់ទ្វារចូល ។

នាងក្រមុំនោះប្រាប់យើងថា: វេលាដែលយក្សមិននៅ អ្នកមិន
ត្រូវចូលមកកន្លែងនេះទេ សេចក្តីទុក្ខធំមានដល់អ្នកជាមិនខាន ។

ហើយនាងសែនត្រេកអរ ដោយបានជួបមនុស្សដូចគ្នា មកពីត្រើយ
សមុទ្រខាងនាយ ព្រោះនាងនុ៎ះ គឺយក្សតក់យកមក ។

លុះយើងបានប្រាប់រឿងបំណងដល់នាងៗក៏ប្រាប់ថា: វត្ថុដែលយើង
ត្រូវស្វែង មិនមែននៅកន្លែងនេះទេ គឺមាននៅកន្លែងនគរយក្សមួយដទៃ
ទៀត ដែលជាញាតិនឹងយក្សនេះ ។

នាងក្រមុំច្បាប់ទៅនាង: ចូរអ្នកអញ្ជើញទៅចុះ ប្រហែលទឹងបានសម្រេច ប៉ើប្រសិនបើព្រះដាំម្ចាស់ដួយផង, ហើយលុះអ្នកត្រឡប់មកវិញ ចូរនាំខ្ញុំទៅផងក៏បាន ។

រួចនាងក្រមុំទ្រឹង្ខុំម្ចាស់ស្បថដាក់ក្បាលអាពុកខ្លួលព្រះបង្គំជាប្រជានថាមិនត្រូវលះចោលនាងក្នុងនគរយក្ស តែត្រូវតែជួយនាំនាងត្រឡប់មកកាន់ផែនដីយើងវិញ; រួចយើងនាំគ្នាចេញទៅ, បើតាមពិត នាងក្រមុំពេញចិត្តទឹងខ្លួលព្រះបង្គំណាស់ ។

លុះទៅដល់ យើងឈប់សំពាកមួយយប់នៅនាងមុខនគរយក្ស, រៀលស្អែក ពេលថ្ងៃរះយើងចូលក្នុងនគរយក្ស ។ ថ្លៃត្រង់យើងបានដល់កំងវេសក់ ដែលមានសតាពស្ដអស្ចារ្យលើសកំងមុនទៅទៀត ។ យើងចុះពីសេះ ហើយសំឡាញ់វេសខ្លួលព្រះបង្គំ ត្រូវត្រឡប់មកវិញតាមដំបូន្មានទៃនាងក្រមុំ, ចំណែកខ្លួលព្រះបង្គំចេះតែដើរតម្រង់ទៅកាន់គ្រែលសេះរបស់យក្ស ។

មានសេះយ៉ាងច្រើន ដេកសម្រាកទៅទីនោះ ។ សេះមួយដាកមើលខ្លួលព្រះបង្គំ ។ ស្ទាបត្អែកក់ ទាញស្ទឹតត្រចៀកក់ ដេញក់ឲ្យគ្រែកឈរឡើង បង្ខាំបង្ខ្រៀវ រួចលោតផែលទំលើខ្លួង ហើយខ្លួលព្រះបង្គំដឹះបរបំផាយទៅបណ្ដាច់យកគ្រួងសត្វបក្សីទិព្វ ដែលព្យួរនៅត្រង់សំយាបច្រាសាទ ។

(មានត)

Phénomène = ហេតុភូត, ការប្រែភេទ

Dieu = អាទិទេព

Hypothèse = សម្មតិកម្ម, ការស្មាន

Destin = ជោគវាសនា

(1er – 7 – 49)

Empereur = អធិរាជ

Impératrice = អធិរាជិនី

Dialecte = គ្រាមភាសា

Langue diplômatique = ភាសាទូត

Diplômate = អ្នកការទូត

Amlassadeur = ឯកអគ្គរាជទូត

Consul Général = កុងស៊ុលធំ

Diplômatie = ការទូត

Légation = ស្ថានអគ្គរាជទូត

Vice-Consul = កុងស៊ុលរង

Consulat = ស្ថានកុងស៊ុល

(5 – 7 – 49)

Jury d'examen = គណៈមេប្រយោគ

(8 – 7 49)

Armement សព្វាវុធ

Equipement = យោធបរិក្ខារ

Division blindée = កងពលគ្រែះ

Aile volante = ស្លាបហោះ

Matériel roulant = សម្ភារយាន

Mobilisation = ការកេណ្ឌ

Officier d'Etat-Major = នាយទាហានសេនាធិការ

Munitions = គ្រាប់រំសេវ

Revue des troupes = ពិធីត្រួតពល

Inspection des troupes = ការពិនិត្យកងពល

(16 – 7 – 49)

Office de riz = មន្ទីរស្រូវ

Institut Océanographique = វិជ្ជាស្ថានមហាសាគរលេខ

Champion = អ្នកដើរឯក

Complémentaire = បំពេញ

Supplémentaire = បន្ថែម

(26 — 7 — 49)

Initialler = ចុះអក្សរអាទិសង្កេត

Parapher = ចុះហត្ថលេខាសង្ខេប

Lettre d'initiative = អក្សរអាទិសង្កេត

Initiative = ដើមគំនិត

Rédaction = ការតែងសេចក្តី

Rédacteur = អ្នកតែងសេចក្តី

Sujet (de rédaction) = រឿង (នៃការតែងសេចក្តី)

Opération (du problème = ការធ្វើលេខ (ចំណាទ)

Système métrique = របៀបមាត្រម៉ែត្រ

Cœfficient = មេគុណ

Notre éliminatoire = ពិន្ទុត្រូវទម្លាក់

Solution (problème) = ការដោះ (ចំណាទ)

(29 — 7 — 49)

Avertissement (peine disciplinaire)= ការដាស់តឿន, ការព្រមាន

Déterminer = កំណត់, សម្រេច, បញ្ជាក់

Définition = អត្ថន័យ

(2 – 8 — 49)

Poste et télécommunication = ប្រៃសនីយ៍ទំនិញនិងទូរគមនាគមន៍

Confort = ផាសុកភាព

Inconfort = អផាសុកភាព (អផ្សុក)

Confortable = ផាសុក

Utile = មានប្រយោជន៍

Utilité = ប្រយោជន៍

Nécessaire = ចាំបាច់

Nécessité = ការចាំបាច់, ការខានពុំបាន

Indispensable = ដែលខានពុំបាន

Effet = ផល

En effet = យ៉ាងហ្នឹងហើយ, ដូច្នោះមែន, ព្រោះហេតុនោះ

Réalité = របស់ពិត, ការពិត

Réaliste = អ្នកប្រកាន់ជំនឿយកការពិត

Réel = ពិត, ប្រាកដ

(មានត)

លោក សាង - សារ៉ាត លេខាធិការក្រសួងវប្បធម៌

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(ត្រួត)

៦ – ស្រែចំការមិនត្រង់ដីឆ្ងល់

"ការក្សត់ចិត្តប្តី ជាមន្ទិលស្រី ក្នុងលោកទាំងពីរ លោកនេះរង់ទុក្ខ អាប់មុខហ្នឹងក្តៅ លោកមុខតុក្កដែ ក្នុងអវិចិ" ។

ក្នុងសាសនាព្រះពុទ្ធ ថេមិយ័ទ: «Thermayda» ទី ១៦, ព្រះពុទ្ធអង្គនេះ ដូចអ្នកផងជ្រាប់ស្រាប់ហើយ ព្រះអង្គមានព្រះជន្មចំនួន ៩០.០០០ ព្រះវស្សា ។ កាលនោះ នៅស្រុកសីឡង់ (Ceylan) មានបុរសម្នាក់ជាកូនមហាសេដ្ឋី កាលវ័យចំរើនធំឡើង ក៏ចាប់ចិត្តស្រឡាញ់រូបនារីម្នាក់ ដែលត្រូវជាកូនមហាសេដ្ឋីមួយទៀត នៅក្នុងភូមិនោះដែរ ។ ឯមាតាបិតាទាំងសងខាងជ្មាន់ស្រុះស្រួលគ្នា ហើយរៀបមង្គលការបុត្រាបុត្រីទាំងពីរជ្មាណយ៉ាងអឹកធឹក ។

លុះដល់រៀបការរួច បុរសជាស្វាមីត្រឡប់ជាមិនសប្បាយចិត្តដូចជ្មាថ្មីសោះ ទើបនិយាយនឹងភរិយាថា "នែអូនសំឡាញ់! ឪពុកម្តាយរបស់បងនឹងឪពុកម្តាយរបស់អូន ជាអ្នកមានធនធានសំបើមណាស់

ប៉ុន្តែយើងទាំងពីរនេះ គ្មានរបស់អ្វីដែលជារបស់យើងទេ ; ហេតុដូច្នេះ បងគិតសូមលោអូនម្ដុយគ្រាសិន ទីធ្លាំងកប៉ាល់ទៅស្រុកក្ដុកនឹងស្រុកពេជ្រ ដើម្បីរកធនធានតាមកំឡាំងរបស់បង" ។

នាងជាកញ្ញាលុះឮដូច្នោះ ក៏ព្រួយចិត្តជាភ្លាំង និយាយទៅកាន់ស្វាមីវិញថា "ទុតូដ៏វិសេសបួន! មានតែពួកអ្នកក្រែដែលរស់នៅម្នាក់ឯងវេទនាជានិច្ច គ្មានជាប់ចំណងអ្វីទៅនាលោកនេះទេ ទើបគេទៅតាមមហាសមុទ្រធ្វើការត្បាល់ទឹកគ្រាំថ្នាក់ផ្សេង ។ ដើម្បីស្វែងរកធនធាន ; ឯរូបអ្នកបងវិញឆ្ងាយអំពីប៉ាន: នោះជាអនេក តោងអ្នកបងគិតថា: "បើប្អូនអត់អំពីបងទៅ ប្អូនគ្មានបង្អែកឯណាទៀតទេ, ដូច្នេះសូមបងគិតទៀតថា: ប្អូនស្រឡាញ់បងណាស់, ឪពុកម្ដាយរបស់យើងជាអ្នកមានទ្រព្យសម្បត្តិច្រើន, លោកក៏គង់ចែកទ្រព្យសម្បត្តិរបស់លោកមកឲ្យយើងខ្ញុះដែរ ទោះបីលោកៈវរសក្ដី លោកមិនឆ្នេចកែកទេ ព្រោះលោកស្រឡាញ់យើងណាស់" ។

– ពិតមែនហើយអូន, ប៉ុន្តែយើងត្រូវតែមានទ្រព្យណាមិនមែនជាទ្រព្យកើតឡើងអំពីសេចក្ដីជ្រះថ្លាសទ្ធារបស់លោក, យើងត្រូវតែមានទ្រព្យណាដែលកើតឡើងអំពីកិច្ចការរបស់យើងផ្ទៃ, បើសិនណាបងស្លាប់តណ្ហាលផ្លូវ ឈ្មោះថា បងស្លាប់ដោយកិត្តិយស រួចគេនឹងគោរពដល់បងមិនខាន; មនុស្សណាដែលមិនចេះរកចិញ្ចឹមជីវិតខ្លួនឯង មនុស្ស

នោះជាសត្វធុនអន់ជាបំផុត, ដូនកាលគេមើលងាយផង; មួយទៀត យើងមិនត្រូវរស់នៅដោយគ្មានតែស៊ីផឹកដេកដោយឥតកម្រើកមាមដៃ ទាំង ១០ នោះទេ, អ្នកប្រាជ្ញបានចារក្នុងសៀវភៅធម៌ថា "ជនណាមិនខ្ជាប់ដើរតាមសមុទ្រលោកគឺគតគឺគែងដើម្បីស្វែងរកទ្រព្យសម្បត្តិ ជននោះទើបសមជាមនុស្សគួរឲ្យគេរាប់គ្នាសរសើរបាន ពោះបើមិនបានទ្រព្យនោះដូចបំណងក៏ដោយ; ហេតុដូច្នេះ កុំឲ្យអូនគិតដដែលៗឲ្យសោះព្រោះបងប្រាកដជាទៅហើយ" ។

លុះកាលណាបុរសបានឧបថ្នាក់ថ្នមភរិយាដោយស្នេហាយ៉ាងស្ងប់ស្ងាលហើយ ក៏ចេញដំណើរទៅ ដូចពាក្យដែលបានពោលមែន ។

ដល់យូរបន្តិចមក នាងភរិយានៅម្នាក់ឯងកើតទុក្ខក្រៃលែងជាខ្លាំង; ប៉ុន្តែធម្មតាស្រីដែលគ្រាស់ដោយតណ្ហាតែងមិនស្កប់ចិត្តប្តីរបស់ខ្លួនទេ ។ ឯនាងនេះក៏ជាស្រីតណ្ហាគ្រាស់ផង មានវ័យនៅក្មេងផង នាងធាប់ក្តៅចិត្ត នាងបានទៅមកធ្វើអនាចារជាមួយបុរសអកបំរើរបស់ឪពុកម្តាយនាងម្នាក់ ឈ្មោះប៉ាយតា (Payta) ។ ប៉ាយតានេះមានវ័យនៅក្មេង មានរូបល្អអាយុប្រមាណស្មើនឹងអាយុនាង ។

ថ្ងៃមួយ ប្រុសសង្ឃរនោង ប្រាប់ថា "អូន! យើងរស់នៅជាមួយគ្នាបានសុខសប្បាយណាស់; ប៉ុន្តែបើសិនណាប្តីដើមរបស់អូនមកវិញ តើយើងគិតយ៉ាងណា? យើងគិតបែកគ្នាឬអ្វី? ។ នាងតប

គិតកង់ចិត្តជាយូរបន្តិច ដើម្បីរំលែកស្រាយបញ្ហានេះ ដែលមើលទៅហាក់គ្មានផ្លូវសោះ រួចនាងនឹងប្រាប់ខ្លឹងនិយាយថា: "ឧបាសិកា! ប្អូនឮតើយ៉ាងហើយ យប់នេះបងនៅឯប៉ុន្មានខ្មោច ហើយបងយកបូបខ្មោចស្រីម្នាក់ដែលគេទើបតែបញ្ចុះយកមកឲ្យខ្ញុំ, យើងយកខ្មោចនេះទៅដាក់លើដំបូលផ្ទះ ហើយយើងដុតផ្ទះរបស់យើងទៅ; លុះកាលណាឪពុកម្តាយរបស់ខ្ញុំ យើញរូបខ្មោចដែលនេះពេលភ្លើងនោះ លោកនឹងនឹកស្មានថា: ខ្ញុំស្លាប់តែងអគ្គិភ័យនេះ ដូច្នេះមិនខាន, រួចយើងនាំគ្នាទៅនៅកន្លែងមួយទៀត ដែលគ្មានអ្នកណាមកជំទាស់រំលោភក្តីស្នេហារបស់យើង" ។

ប៉ាយតាយល់យើញតែងង៉ក៏ធ្វើតាមបង្គាប់របស់នាង ។ តង់រៀលដែលភ្លើងកំពុងឆេះខ្លាំង ប៉ាយតាទៅជាមួយស្រីសង្ឃរាតាមផ្លូវបត់បែនលុះតែតែងរំលងកូមមួយដែលនៅឆ្ងាយជាច្រើយាលពីស្រុកកំណើតនាង ។ រីឯឪពុកម្តាយរបស់នាង ឃានមឹកស្មានថា: កូនស្រីរបស់ខ្លួនស្លាប់តង់ភ្លើងកំយំសោកថ្មោកថ្មាណា ហើយឃានឆ្លៀបុណ្យបញ្ចុនឲ្យនាងយ៉ាងបរិបូណ៌ យកខ្មោចនោះទៅដុតនឹងឈើក្រមុំជាច្រើនក្បាយឃ្មោះតង់យ៉ាងគគ្រឹកគគ្រែង ។

សុភាសិតថា "សេចក្តីស្នេហានាំឲ្យមនុស្សទៅជាភ្លាក់មិនចេះគិតវែងឆ្ងាយ" ។ ហេតុនោះ ឃានជាប៉ាយតានឹងនាងស្រឡាញ់គ្នាណាស់ គ្មានភ្លាចអ្វី គ្មានខ្លាចអ្នកណាបន្តោស គ្មានទឹកតិតភ័យអ្វីឡើយ ។

កន្លងពេលដែលរត់ទៅនោះ ជនទាំងពីរនាក់មានសេចក្តីត្រេកអរប្រហែលគ្នាបានយកអ្វីជាប់ដាមួយទៅផងដែរ មានតែមាសពេជ្រប៉ុណ្ណោះ, ដែលយូរបន្តិចទៅ គំរាយកាយអស់គ្មានសល់អ្វីសោះ ។

«សេចក្តីពិត គាល់ណាសេចក្តីស្រែកឃ្លានគាបត្រពះ សេចក្តីស្នេហាយ៉ាងខ្លាំងត្រូវប់ជាអន់ថយវិញ ។ នេះជាពាក្យចាស់ពុំជានិយាយ ។ ហេតុតែជនទាំងពីរនាក់ភ្ជាក់ក្នុងស្មារតីសុភាសិតនេះហើយ បានជាកន្លងមួយ ស្វាមីភរិយា ឧបត្រសោបគ្នារួចហើយ, ស្រីសង្ឃរនិយាយថា: "បង ! ប្អូនយើញថាបងស្រឡាញ់ប្អូនខ្លាំងណាស់ ឯប្អូនក៏ស្រឡាញ់បងណាស់ដែរ, ប៉ុន្តែឥឡូវនេះ យើងត្រូលំបាក់ខ្លាំង, ហេតុដូច្នេះ យើងមុខជានឹងស្លាប់ដោយអត់ឃ្លានតណ្ហាលតណ្ហារបស់យើងពុំខាន ; ប្អូនសុំចិត្តបងចុះ, យើងត្រូវនាំគ្នាទៅផ្ទះរបស់ឪពុកម្តាយប្អូនវិញ, គាត់ចំណាំបងមិនបានទេ ប្រហែលគាត់ភ្លេចមុខបងហើយ ដោយគាត់មិនបានចាប់ភ្នែកនឹកនាដល់រូបបង ; ចំណែកខាងប្អូនវិញគាត់មុខជាស្គាល់ថា រូបប្អូននេះគ្រាន់តែដូចរូបកូនរបស់គាត់, ប្អូនហ៊ានថា មុខជាគាត់ឲ្យលុយកាក់ច្រើនគាសមកប្អូននឹងបងសម្រាប់ទិញម្ហូបអាហារនឹងសំលៀកបំពាក់ផ្សេង ។ បើនិយាយសារុះទៅ គឺថាគាត់មុខជាឲ្យរបស់ដែលយើងត្រូវការទាំងប៉ុន្មានមិនខាន ។

ប៉ាយតាដែលមានបំណងស្រេចគ្មានទីតណាដែរ ក៏ត្រមធ្វើតាមនាង ។ លុះអាលណាបរិភោគអាហារស្រេស់ស្រួបពេលព្រឹកបន្តិចបន្តួចរួចហើយ ប្តីប្រពន្ធទាំងពីរនាក់នាំគ្នាត្រឡប់មកផ្ទះរបស់ខ្លួនវិញ ; ដល់ពេលល្ងាច ក៏ចុះមកដល់មាត់ទ្វារសួនច្បារដែលលាតសន្ធឹងពីមុខគេហដ្ឋាន ហើយបាននាំគ្នាអង្គុយសំពាកនៅត្រោមម្លប់ដើមឈើមួយធំដែលមានផ្កាកែតពោរពាស ហើយដែលបក់ក្លិនក្រអូបឈ្ងុយឈ្ងប់ដូចផ្កាក្រូច ។

ក្នុងពេលនោះ ភ្លុកខ្ញុំអ្នកបំរើដែលធ្លាប់តែចុះពីលើផ្ទះតាមធម្មតាដើម្បីយកទឹកទៅដ្រួចសែនភ្ញោចនាងដែលស្ងាប់ក្នុងអគ្គីនោះ បានឃើញស្វាមីកវិយាទាំងគូទៅអង្គុយលើស្មៅ ក៏ឈប់ឈរសំឡឹងមើល ហើយនិយាយគ្នាថា : " យីអើបើសិនណាជានាងនេះគ្មានប្តី គេទៀងតែថាទៅហ្វាយស្រីរបស់យើងតុំខាន " ។ រួចអ្នកបំរើទាំងនោះយកដើងគានមាសត្រឡប់ទៅវិញ ដោយគតគ្មានសែនត្រេកអ្វីទេ ហើយនិយាយព័យព័ប់ប្រាប់អ្នកស្រីដែលជាម្តាយរបស់នាងគ្រប់ប្រការ ។

ឯអ្នកស្រីនេះក៏ចុះអំពីឆ្នុះយ៉ាងប្រញាប់ ដើរទៅកន្លងសួនច្បារតម្រង់ទៅគល់ឈើធំ ដែលអ្នកដំណើរទាំងពីរអង្គុយនៅ ក៏បានឃើញកូនស្រីរបស់គាត់ ។ គាត់ស្រែកដឹកដៃកូនទៅសួរមមួយភន្លែង ឈរមើលតាំងស្មាតែ ប៉ុន្តែឥតហ៊ានិយាយទៅកនាងទេ ។ ក្រោយមក ដោយសារចិត្ត

ខ្លួនខ្លាញ់ភ្ញាំងពេក គាត់សង្ឃឹមចិត្តគាត់ថាន ហើយទៅអង្គុយជិតនាង សាកសួរនាងដោយមានសំឡេងយ៉ាងខន់ថា: តើនាងកូនចៅអ្នកណា? ។ កូនស្រីឆ្លើយថា: "ជំពប់ប្រសាសន៍អ្នកមីង! យើងតាំងពីរនេះជាអ្នកដំណើរ, យើងមកឈប់សម្រាកក្នុងទីនេះក្រោមម្លប់ឈើដែលមានផ្លែក្រអូបនេះបន្តិច, តឡូវយើងធ្វើដំណើរតទៅទៀតហើយ" ។ — ទេនាង! កុំទៅ, នាងនៅទីនេះហើយ, ខ្ញុំជានាចិញ្ចឹមនាងដូចកូនខ្ញុំបង្កើត; ព្រោះមុខរបស់នាងនាំឲ្យខ្ញុំនឹកដល់កូនស្រីសំឡាញ់របស់ខ្ញុំ ដែលអនិច្ចកម្មកន្លក្នុងកន្លែងចាត់ទៅនោះ ហើយដែលខ្ញុំនៅតែនឹកគ្មានភ្លេចឡើយ, នាងនោះបុះ ខ្ញុំសុំចិត្តនាងឲ្យអាណិតមីង ។

ដូចយើងដឹងស្រាប់ហើយ, ដែលនាងនេះធ្វើឲ្យម្ដាយអង្វរខ្លួនយ៉ាងនេះ គឺធ្វើតែក្បាច់ទេ ចំណែកចិត្តឥតប្រែកសោះ ហេតុដូច្នេះហើយទើបនាងសុខចិត្តព្រមនៅតាមអង្វរ ។ ឯអ្នកស្រីជាមាតាមានចិត្តត្រេកអរជាពន់ពេកណាស់ ហើយនាំថ្លុំប្រពន្ធតាំងពីប្រាណចូលទៅក្នុងផ្ទះមួយសន្ធឹកអំពីឈើម៉ៃសាក់លាបពណ៌យ៉ាងស្អាតនាយ មានដំបូលច្រែនជាន់នៅក្នុងសួនច្បារនោះ ។

អស់កាលចំនួនជាច្រើនថ្ងៃរំលងមក ជនតាំងពីរនាក់គ្មានរឿងហេតុអ្វីទេ សឹងនៅជាសុខសប្បាយដោយសម្បូណ៌គ្រឿងបរិភោគទុំបរិភោគឆៅគ្រប់ប្រការ ។ ឯអ្នកស្រីមិនចេះអស់ចិត្តនឹងមើលមុខនាងនោះសោះ ព្រោះ

គាល់ឃើញនាងជារៀងរាល់ថ្ងៃ ក៏ចង់ឃើញដល់កូនស្រីសំឡាញ់របស់គាត់ ។ ប៉ុន្តែថ្ងៃមួយនោះ មានអ្នកនាំសំបុត្រមកជូនប្រាប់ថា ប្តីដើមរបស់នាងត្រឡប់មកពីការដើរផ្សងត្រីនៅភ្លាមហើយ ចាន់ចាំងនាំធនធានជាច្រើនមកជូន ។ កន្លងពេលយប់នោះ បុរសផ្សងត្រីក៏មកដល់មែន ហើយសាកសួរគេអំពីសុខទុក្ខកូនភរិយាខ្លួនមុនគេបង្អស់ ។ គេក៏ប្រាប់យ៉ាងច្បាស់ពីអំពីអគ្គិភ័យ ទឹងអំពីមរណភាពយ៉ាងរហ័សរួស រៀបរាប់ពីការដែលជួបប្រទះក្នុងអណ្តាតភ្លើង ឃើញតែរូបដែលត្រូវឆេះផ្សែងពេលមើលមិនស្គាល់ ព្រមទាំងប្រាប់ពីធីបុណ្យយ៉ាងអឺកធឹកដែលគេបានធ្វើទៅដូរខ្មោចនាង ។

បុរសផ្សងត្រីធំទប់ទឹកភ្នែកដែលហៀបនឹងហូរចេញមក ក្នុងចិត្តខ្មោចជ្រាបអនេក ទើបដើរគ្នាទៅកាន់ផ្ទះម្តាយដែលបានសង់ហើយថែមមួយបន្ទប់ដល់ខ្លួននោះ ។ កន្លងពេលនោះ ខ្លួនអ្នកបានអង្គុយនៅលើកន្ទេលតាំងមួយមានស្រីស្អាតជុំវិញ ស្រាប់តែក្រឡេកភ្នែកទៅឃើញភរិយាខ្លួនឈរមើលអ្នកតាំងពីមុខ ។ ដំបូងអ្នកតាំងទៅស្ទើរមើលភ្នែកធំដូចមនុស្សគ្មានវិញ្ញាណ រួចអ្នកនិយាយយ៉ាងខ្សឹកខ្សួលថា : "តើហេតុអ្វីក៏ដូច្នេះ? ឥឡូវមើលទេឬ? ឬមួយគេកុហកអញ? អ្នកលក់គ្នាថាប្រពន្ធអញស្លាប់ តែម្តេចឡើយក៏អញឃើញនាងទាំងសាច់ទាំងឆ្អឹងយ៉ាងនេះ?" ។

(មានត)

កណ្តាំទី ៦

អ្នកទុកញ្ជើរិបុលរាជសេនា ន្ធូ - កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ចំងបេះទុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

សម័យនោះ ស៊ុនកៀនធំស៊ុនសិកជាកូនបានតែងខ្លួនដិះសេះស្រួតទៅឈរនៅមុខតាហាន, ហង៍ចបរសេះចេញមកប្រកួលមុខហើយវៃស្រែកដេរស៊ុនកៀនថា " អាឯងនេះ ជាពួកអាចារស្រែកកាំងតាំងយ៉ាងកំណាច ហេតុម្តេចអាចរុកពានទន្លានចូលមកដល់ដែនព្រះចៅហាន់គោចោ អាឯងមិនខ្លាចស្លាប់ទេឬ?" ហើយប្រើតៀវហៅឲ្យចូលទៅតយុទ្ធ ។ ស៊ុនកៀនប្រើហាន់តុងចេញច្បាំងនឹងតៀវហៅបាន ៣០ ស្នៀត, គាន់សេងក៏បរសេះចេញមកជួយតៀវហៅទៀត, ស៊ុនសិកឃើញដូច្នោះ ក៏យឺតធ្វើបាញ់ត្រូវមុខគាន់សេងធ្លាក់ពីលើសេះស្លាប់, តៀវហៅឃើញគាន់

សេងស្ងាប់ដូច្នោះ សុតស្ងាំងកាំងស្ងាតគ្មាំងឡឹងឡង់, ហាន់តុងក៏លើក ជាវគាប់តឿរហៀងខ្លាក់តីលើសេះស្ងាប់ទៅទៀត, ឆៀងក៏បំផាយសេះ ត្រង់ទៅប្រជងនឹងចាប់ហាន ។ តែយណាស់ ស៊ុះដកមួកចោលពីក្បាល ហើយលោតចុះពីលើសេះរត់ទៅបង្ខំខ្លួនជាមួយនឹងហាន, ស៊ុនកៀន ដេញបរគាហានចូលទៅចាក់គាប់សម្លាប់ពលហាន ។ គេទៅដល់តំបន់ ហាន់ស៊ុយ, ហាន ចគេចរត់រួចទៅ, ស៊ុនកៀនប្រើគាហានទៅច្បាប់ អ៊ុយកាយឲ្យនាំខ្លួនចម្បាំងឡើងទៅខ្លួលឯកំពង់ហាន់កាំង ។

ចំណែកហាន ចូចទាតសេនាគាហានជាច្រើន ទំស្រួតរួតរត់កាត់ទៅ ដល់ស្រុកគេងជីវ យកសេចក្តីចូលទៅដំរាបព្រៀវ ។ ឮនដឹងតំយ ណាស់ ទើបប្រឹក្សានឹងគេងលៀង ។ ឆ្លើយដំរាបថា ដែលហាន ចមែក មកនោះ គាហានស៊ុនកៀនមុខជានឹងមានចិត្តកំរើប បើយើងនឹងលើកទ័ព ទៅច្បាំងឥឡូវនេះ កំហាក់បីដូចជាលត់ក្តៅងត្រៃមួល បើដូច្នេះយើង ត្រូវតែឲ្យរក្សាបន្ទាយនឹងខ្លាស្រុកទីចម្បាំង ឲ្យ មាំមួនសិន ហើយត្រូវ ឲ្យមានសំបុត្រទៅសុំកងទ័ពពីរួនសៀវលើកមកជួយ ទើបឃើញថា ស៊ុនកៀននឹងមិនប្រកួសាំយប្លាន ។ ឈ្មួម៉ាឆ្លើយថា ដែលគេងលៀងថា នោះមិនត្រូវសោះ ព្រោះទ័ពស៊ុនកៀនលើកមកដល់ដ៏ងកំពែងហើយ ត្រូវតែបម្រុងរក្សាស្រុកឲ្យមាំមួនក្តងគ្រានេះ ដែលនឹងធ្វើសំបុត្រទៅសុំ កងទ័ពអួនសៀវមកជួយនោះ មុខជាមិនទាន់ការ ឥឡូវនេះខ្ញុំបានសុំយក

អាសាលើកតាហានចេញទៅវាយតតាំងស៊ុនកៀនជាមុន ។ ឡៅតឿះ
បានស្តាប់ហើយក៏យល់ព្រម ហើយប្រគល់តាហានឲ្យឈួម៉ូចំនួនមួយម៉ឺន
លើកចេញទៅដល់កុំហ៊ីសាន់ ក៏ចោះតង់តតាំងនៅទីនោះ ។ ឯស៊ុន
កៀនមិនបានដឹងជាឈួម៉ូលើកទ័ពមកតាំងនៅទីនោះទេ ក៏លើកតាហាន
ស្រុតរូតទៅដល់កុំហ៊ីសាន់ពីម្ខាង, ឈួម៉ូដឹងច្បាស់ក៏ខ្សែជីសេះគាន
លំពែងចេញមកឈរមុខតាហាន, ស៊ុនកៀនឃើញឈួម៉ូក៏និយាយទំនឹង
ពួកតាហានថា នរណានឹងអាចយកអាសាទៅចាប់យកឈួម៉ូ បានឯ
ឡៅតឿវិញឲ្យយើងបាន? ។

ឆៀផា ឡើយទទួលយកអាសា ស្រែចហើយខ្សែជីសេះកំពួនចេញ
ទៅតយុទ្ធនឹងឈួម៉ូបាន ១០ ស្នៀត, ឈួម៉ូដឹងកំឡាំងនឹងតវៃឆៀផា
ពុំបាន ក៏ញាក់សេះគេចថយក្រោយ, ស៊ុនកៀនលើកតាហានដេញ
បណ្តាយហើយចាក់តាប់សម្ងាប់ពលឈួម៉ូស្លាប់ជាច្រើន; ឯឈួម៉ូក៏រត់
ចូលទៅក្នុងស្រុក ហើយនាំពតមាននោះទៅដំរាបឡៅតឿ, គេងលៀង
និយាយនឹងឡៅតឿថា ព្រោះលោកមិនស្តាប់ពាក្យខ្ញុំទើបថ្មោះការយ៉ាងឯ
នេះ ឈួម៉ូដែលអួតខ្លួនយកអាសាទៅធ្វើការ ហើយបែកទ័ពចូលមកវិញ
ឲ្យចាតពលជាច្រើនដូច្នេះ គ្រាតែកាត់ក្បាលឈួម៉ូដោតផ្ចាលទើបគួរ ។
ឡៅតឿវិញបានឮដូច្នោះ (ក៏ខឹកក្តៅក្រហាយណាស់) តែដោយមាន
សេចក្តីស្រឡាញ់នាងឈួហ៊ូយ៉ិនដែលជាភរិយា ក៏មានចិត្តអាណិតមេត្តា
ឈួម៉ូមិនបានយកទោស ។

ចំណែកស៊ុនកៀន ឮនេះក៏ភ្ញាក់ផ្អើលខ្លាចខាងតួនឡោមព័ទ្ធជុំវិញស្រុកគេងដីវ, ថ្ងៃ ១ បណ្តាលកើតព្យុះយ៉ាងធំអស្ចារ្យចោកបក់លំដងខ្លាំងជ័យមេទ័ពរបស់ស៊ុនកៀនចាក់ដាច់ណា ២ ចំណែក ។ ហានតុងឃើញដូច្នោះក៏ដាកបស៊ុនកៀនថា ពេលនេះមានបង្កើតអកេខអស្ចារ្យណាស់ នេះជាប្រផ្នូលកងទ័ពរបស់យើង ទើបចាក់ដងខ្លាំងជ័យដែលយើងកំពុងឡោមព័ទ្ធស្រុកគេងដីវទុកដូច្នេះ ខ្លាចតែកងមានសេចក្តីភ័យអន្តរាយដល់លោក សុំឲ្យលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញទៅ, ចាំពេលក្រោយសុំគិតការជាថ្មីទៀត ។ ស៊ុនកៀនតបថា "យើងលើកទ័ពមកធ្វើសង្គ្រាមលើកនេះ ឃើញមានជ័យជំនះជាច្រើនលើក ឥឡូវនេះជិតនឹងបានស្រុកគេងដីវព្រឹកស្អែកនេះហើយ អ្នកមកសង្ស័យខ្លាចតែព្រោះខ្យល់បក់ចាក់ដងខ្លាំងជ័យប៉ុណ្ណោះមិនគួរទេ" ថាហើយក៏លើកទាហានបំពានចូលទៅដោយច្បាស់ថានឹងចំណាយកំពែងស្រុកគេងដីវឲ្យបានក្នុងពេលយប់នោះ ។ លុះដល់ពេលយប់ គេងលឿងឃើញផ្កាយ ១ ដួងធ្លាក់ពីលើអាកាស បានពិនិត្យមើលក្នុងតម្រាឃើញច្បាស់ ទើបដំកបទៀវថា ខ្ញុំឃើញផ្កាយ ១ ដួងសៅហ្មងធ្លាក់ចុះមកយ៉ាងអស្ចារ្យ បានមើលក្នុងតម្រាឃើញថាមានគ្រោះធ្ងន់លើស៊ុនកៀន បើដូច្នេះសូមឲ្យលោកធ្វើសំបុត្រទៅសុំកងទ័ពអ្នួនសៀវ ឲ្យលើកមកជួយទ័ពស៊ុនកៀនខ្ចប់ពីខាងក្រោយ ។ ទៀវធ្វើយថា ដែលនឹងឲ្យទៅសុំកងទ័ពអ្នួនសៀវនោះ យើងបាន

យល់ព្រមផងហើយ តែថាពេលនេះកងខ័ពស៊ុនកៀនឡើមត័ខ្លួនជុំវិញ
ស្រុកតាំងអស់ គ្មានចន្លោះនឹងចេញទៅបានដោយងាយ ចើយ៉ាងនេះ
ទើងមាននរណាយកអាសាតុះខំលាយកាន់សំបុត្រទៅបាន ។ លីកុងជា
ភាហានឡើតៀរធ្វើយទទួលយកអាសា, កេងលឿងធ្វើយថៃមថា "ចើ
អ្នកហានទទួលយកអាសានោះខ្ញុំអរណាស់ តែអ្នកត្រូវធ្វើតាមពាក្យខ្ញុំ។
ទើងកេណ្ឌភាហានជ្រើ ៩០០ ឲ្យទៅជាមួយ ចើអ្នកខំលាយចេញទៅបាន
ចូរចែងភាហាន ២០០ ជាប្រញាប់ គឺភាហាន ១០០ ឲ្យទៅបង្កប់នៅចុង
ភ្នំហ៊ីសាន់ ភាហាន ១០០ ទៀត ឲ្យឡើងទៅបង្កប់នៅលើកំពូលភ្នំ រើស
យកដុំថ្មធំ។ បម្រុងទុកឲ្យច្រើន ហើយប្រាប់ថាចើឃើញកងខ័ពស៊ុន-
កៀនតាមច្បាំងឲ្យអ្នកទើងភាហាន ៣០០ តទល់ហើយថយរត់ទៅ គ្រា
តែដល់ដើងភ្នំហ៊ីសាន់, ចើភាហាន ២ កងដែលបង្កប់ចាំនៅទីនោះ បាន
ប្រាញ់ជ្រើចេលដុំថ្មគ្រាណា អ្នកត្រូវអុជផ្ទាំងជាសញ្ញា ៣ ដង ឃើងបានឮ
សំឡេងផ្ទាំងហើយ ទើងលើកភាហានចេញទៅវាយខ្ទប់ពីខាងក្រោយ,
ចើសត្រូវមិនបានតាមអ្នកទៅទេ ឲ្យអ្នកខំស្រុតរួតនាំសំបុត្រទៅឲ្យអ្ន-
សៀវជាប្រញាប់ឲ្យបាន ក្នុងពេលយប់នោះវែងឆ្ងាយណាស់ អ្នកចូរលើក
ភាហានស្រុតចេញទៅចុះ ។ លីកុងបានស្តាប់ក៏ទទួលពាក្យកេងលឿង
បង្គាប់នោះគ្រប់ប្រការ ហើយលាឡើតៀរលើកភាហានជ្រើ ៩០០ ចើកទ្វារ
ទិសឯកើតចេញទៅ,. លីកុងក៏តាំងតែច្បាំងតាប់ទំលុះយដោយកំភ្លាំង

ខ្លួនទឹងគាហានចេញទៅប្លន់ ហើយចាត់គាហាន ២០០ បង្គប់ទុកនៅទីក្នុងប៉ុស្តាន់ដា ២ កង តាមភាក្យកេងលឿនបង្គាប់ ។

ខណៈនោះ ស៊ុនកៀនឃើញគាហានក្នុងស្រុកហែកចំលាយចេញទៅបាន ក៏ឡើងសេះកាន់ដាវនាំគាហាន ៣០ នាក់ដែលជិតស្និទ្ធ សុទ្ធតែជិះសេះលើកតាមទៅ, ឯសេះស៊ុនកៀនលឿនស្រួតទៅបានន់សេះលើកុងហើយស្រែកថា រ៉ាយអាឯងចេញពីក្នុងស្រុកនេះទឹងវេះរត់ទៅណា ។ លីកុងឮហើយក៏ញាក់សេះត្រឡប់មកតទល់ច្បាំងនឹងស៊ុនកៀនបាន ៥ ស្នែត ហើយត្រឡប់សេះបរគេចទៅមុខ តម្រង់ត្រង់គាហានបង្គប់នោះ, ស៊ុនកៀនក៏បរសេះតាមទៅដល់ច្រកភ្នំ, កាលមិនឃើញលីកុងក៏ញាក់សេះត្រឡប់មកក្រោយ រកគាហានបេស់ខ្លួនតាំង ៣០ នាក់វិញ ស្រាប់តែភ្លាំងឡើងឃ្លោះគន់ខ្លួនស្ករលើកំពូលភ្នំ ដុំថ្មធំៗក៏ធ្លាក់ចុះមកព្រាងត្រាត គាហានដែលបង្គប់នៅជើងភ្នំក៏ជ្រាញធ្លាចម្រុះមកខ្មៅត, ស៊ុនកៀនទឹងសេះនោះ ត្រូវត្រួញទឹងដុំថ្មបែកហូរឈាមជោកប្លាក់ពេញអស់តាំងខ្លួន សេះទឹងមនុស្សក៏អស់ដីវិតក្រៀមនៅទីច្រកភ្នំនោះ; កាលស៊ុនកៀនស្លាប់ អាយុបាន ៣០ ឆ្នាំគត់ ។

លីកុងលុះឃើញដូច្នោះ ក៏ចាត់គាហានទៅសូកសម្លាប់គាហានសេះស៊ុនកៀនស្លាប់តាំង ៣០ នាក់ ហើយឲ្យអុជផ្ទាំងផ្ទាសញ្ញា ៣ ដង កេងលឿនបានឮច្បាស់ចាត់ឲ្យកេងអួន ហង់ច ឈួម៉ុ, លើកគាហានចេញ

ទៅជា ៣ ផ្លូវ តាហានស៊ុនកៀនមិនដាន់ដឹងខ្លួនក៏បែកប្រភាក់ប្រពួនរបួសស្លាប់ជាច្រើន ។

ឯអ៊ុយកាយ ដែលនៅថែរក្សាខ្លួនចម្បាំងនោះ ដល់ឃានឮសំឡេងហោកញ្ជែរតឹកកង ក៏លើកតាហានឡើងគោកនឹងទៅជួយ ស្រាប់តែប្រទះនឹងកងទ័ពហង៍ច ចៅហ្វាយស្រុកកាំងហែលើកទៅទល់ពីមុខ ក៏តយុទ្ធគ្នាអស់ ៦ ស្នៀត អ៊ុយកាយចាប់ហង៍ចបាន ។

ខាងឆៀផៅ ស៊ុនសិកលើកទ័ពទៅតាមស៊ុនកៀន ស្រាប់តែជួបប្រទះនឹងលីកុង ឆៀផៅច្បាំងនឹងលីកុងបាន ៥ ភ្លែង, ឆៀផៅចាក់លីកុងនឹងខ្លួនធ្លាក់ពីលើសេះស្លាប់ ។ ក្នុងពេលយប់នោះ តាហានឡៅពៀវនឹងតាហានស៊ុនកៀនច្បាំងប្រកាប់គ្នាស្លាប់ជាច្រើន, ឯតាហានដែលលីកុងនាំទៅនោះ ក៏យកសពស៊ុនកៀននាំទៅជូនឡៅពៀវ, ដល់ពេលព្រឹកឡើងតាហានឡៅពៀវក៏នាំគ្នាចូលទៅក្នុងស្រុក ។

ឯស៊ុនសឹកនឹងឆៀផៅ ដល់មិនបានជួបប្រទះនឹងស៊ុនកៀន ហើយក៏នាំសេនាតាហានដែលចាក់បែកទាំងប៉ុន្មាននោះទៅតាំងទីនៅដំបន់ហាន់ស៊ុយ ។ ពេលនោះ មានតាហានម្នាក់នាំតតិមានទៅជ្រាបស៊ុនសឹកថា: ស៊ុនកៀនជាបិតាអ្នកនោះត្រូវព្រួញស្លាប់នៅទីច្រកភ្នំហ៊ីសាន់តាយបម៉ិញទៅហើយ សពនោះពួកតាហានស្រុកគេងដីនាំចូលទៅជូនឡៅពៀវហើយ ។

ស៊ុនសឹកដឹងដំណឹងឮស្រាប់ កំចោកច្រាស់ខ្លួនផ្តួលយំសោក
ស្រែណោះបិតាដាអនេក លុះស្ងប់សេចក្តីសោកសៅហើយ ក្រោក
ឡើងនិយាយនឹងពួកភាហានតាំងពួងថា ឥឡូវសពបិតារបស់យើងនៅ
ក្នុងស្រុកគេងដីវឯណោះ បើយើងនឹងលះបង់មិនចាំងយកស្រុកនេះ
ឲ្យបាន ហាក់ដូចជាគ្មានសេចក្តីកតញ្ញូចំពោះបិតា ។ អ៊ុយកាយតប
ថា ខ្ញុំចាប់ខ្លួនហង៍ចចៅហ្វាយស្រុកកាំងវៃបានយកមកទុកក្នុងកង់ឥត
បើដូច្នេះ ចាំប្រើបំរើចូលទៅឲ្យដំណឹងឡៅពៀវសិន បើគេព្រមបញ្ជូន
សពបិតាអ្នកមកឲ្យយើង សុំយើងបញ្ជូនខ្លួនហង៍ចទៅឲ្យគេវិញ ឯការ
ដែលធ្វើសង្គ្រាមនឹងគ្នានោះ ត្រូវបង្អង់ទុកឲ្យជាមេត្រីនឹងគ្នាតទៅ បើបាន
ការដូច្នេះ ត្រូវលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ ។

ហួនកាយនិយាយឡើងថា ខ្ញុំនឹងឡៅពៀវស្គាល់គ្នាតាំងពីតូចមក
ខ្ញុំនឹងសុំយកអាសាទៅនិយាយនឹងឡៅពៀវព្រមតាមពាក្យអ៊ុយកាយថា
នោះ, ស៊ុនសឹកបានស្តាប់ហើយមានសេចក្តីត្រេកអរជាពន្លឹក ហើយ
បាត់ឲ្យហួនកាយចេញទៅនិយាយការនោះ, កាលហួនកាយទៅដល់ឡៅ
ពៀវហើយនិយាយថា ឥឡូវនេះស៊ុនសឹកមិនបានធ្វើសង្គ្រាមនឹងលោកត
ទៅទៀតទេ ទឹងសុំយកតែសពស៊ុនកៀនជាបិតាទៅវិញ បើខាងលោក
យល់ព្រមឲ្យហើយ ទឹងបញ្ជូនខ្លួនហង៍ចដែលចាប់បាននោះមកលោក
ហើយស៊ុនសឹកនឹងលើកទ័ពត្រឡប់ទៅស្រុកវែតម្តង ។ (មានត)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - គ្រសេម រៀបរៀង

(ពមក)

ព្រះបាទអនុរុទ្ធគិតវិវាយក្រុងលវបុរៈ

ព្រះបាទអនុរុទ្ធមិនមែនជាក្សត្រដោយព្រះជាតិទេ តែដោយហេតុមានស្នាដៃខ្ពាំងពូកែ ក៏បានជាព្រះរាជាគ្រប់គ្រងប្រជាជន ជាតិមន ទទឹងជាតិភូមារួមគ្នា តាំងព្រះរាជធានីនៅភុកាម (បុណ្ណកាម) កន្លងកាល ព. ស. ១៥៥៣ ដល់ ១៥៩៥ ។ ព្រះបាទអនុរុទ្ធនេះជាអ្នកដែរថ្វាយកន្លងព្រះពុទ្ធសាសនាយ៉ាងខ្ពាំងក្លា, តាំងពីពេលព្រះអង្គបានឡើងគ្រងរាជ្យ ហើយ ក៏មានប្រថ្នាយ៉ាងខ្លាំងក្នុងការផ្សាយអំណាចនឹងផ្សាយព្រះពុទ្ធសាសនា ទំនងដូចព្រះបាទធម្មាសោកពាជនៅប្រទេសឥណ្ឌា ។ តអំពីនោះ ទ្រង់លើកទ័ពទៅវាយពួកអនុប្រទេសបែកខាងលើ បានជាច្រើនប្រទេសមកជាចំណុះ ។ ទ្រង់កាលវាយបានអនុប្រទេសជាច្រើន គ្មានអ្នកណាទប់ទល់បានដូច្នេះហើយ ក៏រឹតតែមានព្រះរាជហឫទ័យក្លាហានខ្លាំងឡើង ទើបគិតលើកទ័ពមកវាយបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជាទៀត ។

កាលនៅថ្ងៃ ១៣ រោចខែមិគសិរ ឆ្នាំរោះ ៣. ស. ១៤៩៨ ព្រះបាទអនុរុទ្ធសោយរាជ្យបាន ៦ ឆ្នាំ ក៏លើកទ័ពធំចូលកម្ចាជែនរដ្ឋឆ្លាកវតី ដោយបំណងនឹងកម្ចាក្រុងលវបុរៈ ហើយទឹងក្រុងហរិបុញ្ជ័យ ។ ព្រះចន្ទ្រជោតិអ្នកគ្រងនគរលវបុរៈទ្រង់ជ្រាប ទ្រង់ចាន់ចាំមើលកំឡាំងសឹកក៏ទ្រង់ជ្រាបច្បាស់ថា បើចំរោះតែកំឡាំងទ័ពក្រុងលវបុរៈនោះ ពុំអាចនឹងទប់ទល់កំឡាំងទ័ពបច្ចាមិត្តបានទេ ឯរលែងតែមានកងទ័ពខាងព្រះមហានគរមកជួយផង, បើទ័ពខាងព្រះមហានគរ (គឺទ័ពព្រះបាទសូរ្យវង្ស) មកជួយខាន់នោះទ័ពបច្ចាមិត្តគ្មានផ្លូវនឹងឈ្នះទេ តែនេះទ័ពបច្ចាមិត្តចូលមកទៀបដល់ក្រុងហើយ ទំរាំតែឲ្យដំណឹងទៅដល់ព្រះមហានគរ នឹងទំរាំតែកងទ័ពខាងមហានគរលើកមកដល់ ក្រុងលវបុរៈគង់ខ្លួចទៅមុន, ហេតុនេះ ទើបគ្រាស់ឲ្យប្រជុំគណៈសេនាបតី ។ កាលទ្រង់ថ្លែងព្រះរាជឧបាយល់សព្វគ្រប់ហើយ គណៈសេនាបតីក៏យល់ព្រមតាមព្រះរាជតំរិះ, លំដាប់នោះ ទ្រង់ឲ្យតែងព្រះរាជសារ ១ ច្បាប់ ឲ្យសេនាបតីធំនាំទៅថ្វាយព្រះបាទអនុរុទ្ធ ។ ខំនង់សេចក្តីកងព្រះរាជសារនោះថា "សូមឲ្យស្តេចធុលីព្រះបាទរង់ ៧ ថ្ងៃសិន, ក្រុងលវបុរៈនឹងតស៊ូ ប្តូនឹងញ៉ាំមចាញ់ដោយសុភាព, ព្រះអង្គអាចនឹងទ្រង់ជ្រាបបានក្នុងរវាង ៧ ថ្ងៃខាងមុខនេះ" ។

ដើម្បីចៀសវាង កុំឲ្យមានសឹកសង្គ្រាមក្នុងប្រទេស ព្រះចន្ទ្រដោតតំ
តាស់ឲ្យភ្ជាក់ងារផ្សេង ๆ រៀបក្បួនសម្រាប់ហែព្រះនាង កែវប្រពាឡ
ជាព្រះជដ្ឋគតិនីនៃព្រះអគ្គទេវី ទ្រង់ហែព្រះពុទ្ធសារៀវថ្ងាយព្រះបាទ
អន្ទុះទ្ធ សុំចង់សម្ពន្ធមេត្រី ។

លុះដល់ថ្ងៃគំរប់ ๗ ក្បួនហែក៏ចេញអំពីក្រុងលវបុរៈឆ្ពោះទៅកាន់
ទីដំរំទ័ពនៃព្រះបាទអន្ទុះទ្ធ ដោយមានអគ្គសេនាបតី ๑ នាក់ជាអ្នកតំណាង
ព្រះពុទ្ធសារៀវផង ។ ព្រះបាទអន្ទុះទ្ធបានទទួលព្រះពុទ្ធសារសូមចង់សម្ពន្ធ-
មេត្រី ទ្រង់ទទួលព្រះរូបព្រះនោមព្រះនាងកែវប្រពាឡដែលទុកជាចំណង
សម្ពន្ធភាព ក៏ទ្រង់មានសេចក្តីបដិព័ទ្ធជាយ៉ាងក្រៃពេក ទើបទ្រង់ទទួល
ព្រះនាងទុកហើយគ្រាស់ឲ្យតែងពុទ្ធសារតប ស្រេចហើយទ្រង់ឲ្យសេនា-
បតីរបស់ព្រះអង្គ នាំព្រះពុទ្ធសារព្រមទាំងពុទ្ធបណ្ណាការ គឺដំរី ๑๐๐
សេះ ๑๐๐ ទៅថ្វាយព្រះចន្ទ្រដោត ហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ
គ្រាស់ឲ្យធ្វើពិធីអភិសេកព្រះនាងកែវប្រពាឡជាឯកអគ្គមហេសី[1] ។
អំពីនោះមក ប្រទេសភូមានឹងប្រទេសកម្ពុជាក៏បានជាមិត្តនឹងគ្នា ភូមា
លើកលែងមកវុកពុនប្រទេសកម្ពុជាទៀត ។

---

๑ ព្រះនាងកែវប្រពាឡ តទកមានព្រះរាជនាម ๑ អង្គព្រះនាគនារេស្សរ ។

ក្រោយនេះ ព្រះចន្ទ្រោតិ ចានយកសេចក្តីក្រាបបង្គំទូលព្រះចាន
សូរ្យវរ្ម័នទី ១ តាមហេតុការណ៍ដែលមានមកហើយនោះ ដើម្បីឲ្យ
ជាបសព្វគ្រប់ប្រការ ។ ព្រះចានសូរ្យវរ្ម័នឲ្យសព្វព្រះពជហឫទ័យ
ក្នុងកិច្ចការដែលព្រះចន្ទ្រោតិចានបំពេញមកហើយជាយ៉ាងក្រៃពេក
ត្រាស់សរសើរព្រះយោបល់នេះយ៉ាងៗរបស់ព្រះចន្ទ្រោតិថា "ប្រសើរ
ណាស់ ដែលចេះសេកប្រចេះសង្គ្រាមដែលមកដល់ចំពោះមុខហើយឲ្យ
ថយទៅចានដោយមន្តតាមខេត" ហើយត្រាស់ថា "ត្រូវរៀបចំក្រុង
លវបុរៈឲ្យមាំមួន ដើម្បីទប់ទល់សឹកសត្រូវចានទៅក្នុងអនាគត" ។

មកក្នុងឆ្នាំ ព.ស. ១៥៧៤ (គ.ស ១០៣០) ព្រះចានសូរ្យវរ្ម័ន
បរមរាជាធិរាជ ទ្រង់ចានតែងរាជទូត ឲ្យនាំព្រះរាជសារទូរវាជបណ្ណាការ
ទៅសុំចងសម្ពន្ធមេត្រីភាព នឹងស្តេចក្រុងចិន ។ ខាងស្តេចចិនក៏ព្រម
ទទួលចងសម្ពន្ធភាពតាមដូរការ ហើយទ្រង់ចានតែងរាជទូតឲ្យនាំរាជសារ
ទូរវាជបណ្ណាការតបមកវិញ ។ ប្រទេសកម្ពុជារុងរឿងយ៉ាងចង
សម្ពន្ធមេត្រីភាពនឹងប្រទេសចិនរាប់ជាគ្រាទី ៦ ក្នុងរជ្ជកាលនេះ ។

ចំណែកខាងតណ្ឌ ក្នុងរជ្ជកាលនេះ ក៏មានការចាក់ទង្គិចគ្នាទៅ
វិញទៅមក ដូចក្នុងរជ្ជកាលព្រះចានជយវរ្ម័នទី ៥ តែមិនច្បាស់ជាចាន
ចងសម្ពន្ធមេត្រីភាព តាមដូរការដែរ ឬយ៉ាងណា ។

(មានត)

នៅឃុំអង្គាញ់ ស្រុកត្រែកបប្អាស ខេត្តតាកែវ

លោកមេឃុំ ឡង – អ៊ួប

ជាអាចារ្យវត្តនេះ រៀបរៀង

(រឿងលេខ ១)

(៤ ចប់)

អធិប្បាយអំពីឱឡែងបុណ្យ

ចំនៀមចំលាប់ដែលឆ្វងបុណ្យនេះ ខ្ញុំបានឃើញសាស្ត្រា ១ ឈ្មោះ "សាស្ត្រាចំឡងបុណ្យ" ។ ក្នុងសេចក្តីសាស្ត្រានោះ មានដំណាលថា: កាល: ដូចបានភ្ជាប់រៀងមក កាលណោះ មានជន ២ នាក់ (ប្តីនឹងប្រពន្ធ) មានឈ្មោះមិនច្បាស់ នៅស្រុកឥន្ទបត្តបុរីមហានគរ បានធ្វើបុណ្យ ១២ ឆ្នាំហើយមិនទាន់បានឆ្វង, ថ្ងៃ ១ បុរសជាប្តីគិតនឹងប្រពន្ធថា "អានេះយ! បុណ្យដែលយើងធ្វើនេះ ១២ ឆ្នាំហើយ តែមិនទាន់រៀបគ្រយ៉ាងឆ្វងបុណ្យដល់ម្តងសោះ ហេតុនេះយើងនឹងគិតធ្វើទំនិញដើម្បីឆ្វងបុណ្យយើងនេះឲ្យហើយ ដ្បិតសង្ខារយើងនេះមិនទៀង ស្អាប់ថ្ងៃនេះក៏មិនដឹង ស្អែកក៏មិនដឹង ខានស្អែកក៏មិនដឹង" ។ ប្រពន្ធឮហើយក៏ត្រេកអរ បានដាំបាយវេចឲ្យប្តីដើម្បីទៅកសេះបេះបន្លែ ។ ប្តីនោះចេញទៅដោយសេចក្តីរីករាយសប្បាយ ច្រៀងហួចត្រចាស់អង្គុចបណ្តើរទៅតាមផ្លូវ លុះដល់ចូលព្រៃ

ឆ្ងាយបន្តិចទៅ ឃើញដើមឈើ ១ ធំមានមែកត្រសាយសាខា បុរសនោះក៏ចូលទៅដេកក្រោមដើមឈើនោះលក់ទៅ ។

ក្នុងសាស្ត្រានោះ មានន័យយថា: កាលនោះព្រះឥន្ទ្រជ្រើសស្តេចចតុលោកបាល ឲ្យចុះមកមើលភពមនុស្សលោកនេះ បើឃ្លោះណាធ្វើអំពើបាប ឲ្យកត់ទឹងបញ្ជីស្បែកឆ្កែ បើឃ្លោះណាធ្វើបុណ្យ ឲ្យកត់ទឹងដម្បាមាស ។ លុះស្តេចចតុលោកបាល បានដើរត្រួតត្រាត់ប្រទេះដួចទឹងបុរសដែលកំពុងដេកលក់មិនដឹងខ្លួនក្រោមដើមឈើធំនោះក៏សួរថា "បុរសឯងមកពីណា" ។ ព្រលឹងបុរសនោះបាននិយាយទឹងស្តេចចតុលោកបាលដូចយើងសព្វថ្ងៃហៅថាយល់សប្តិថា "ខ្ញុំមកពីទេសបេះបង្ខៀទៅធ្វើបុណ្យធ្ងន់ ដ្បិតធ្វើបុណ្យមក ១២ ឆ្នាំហើយមិនទាន់បានធ្ងន់" ។ ស្តេចចតុលោកបាលស្តាប់ហើយត្រេកអរ បានស្រូបព្រលឹងបុរសនោះទៅឋានតាវតឹង្ស នាំទៅក្រាបទូលព្រះឥន្ទ្រតាមដំណើរ ។ លុះព្រះឥន្ទ្របានឃើញបុរសនោះហើយ ក៏សួរទៅបុរសនោះ ។ ឆ្លើយទូលព្រះឥន្ទ្រតាមដំណើរដែលខ្លួនបានធ្វើបុណ្យ ។ លុះព្រះឥន្ទ្របានស្តាប់បុរសនោះហើយ ក៏ត្រេកអរបាននិយាយប្រាប់បុរសនោះថែមទៀតថា "មហាបុរសអើយ អ្នកដែលបានធ្វើបុណ្យហើយបានធ្ងន់នោះប្រសើរណាស់, អ្នកដែលធ្វើបុណ្យហើយមិនធ្ងន់ បុណ្យនោះនាំទៅឯណាមិនរួចទេ; អញនឹងនិយាយឲ្យបុរសឯងស្តាប់: កាលណោះមានបុរស ១ នាក់ ដាំដើមដ្រៃ

ហើយមិនបានធ្វើ ស្ងាប់ទៅ។កើតជាត់ដសីហ៍ទៅស៊ីស្មៅតែគ្រាមម្ខាង ដៃខោះ ចេញទៅរកស៊ីឯណាទៀតពុំរួច ។ មានបុរស ១ ទៀត ដីកអណ្តូងដីកស្រះឲ្យគេផឹកទឹក ហើយមិនបានធ្វើបុណ្យទ្រង់ ស្ងាប់ទៅ។ កើតជាមនុស្សទៀត ដីកអណ្តូងមិនចេញទឹក .។ បុរស ១ ទៀត ចេញទៅរៀនសិល្បសាស្ត្រអំពីអាចារ្យ ចេះស្រេចកាលណាមិនបានធ្វើពិធីការបូជាដល់អាចារ្យនោះ លុះស្ងាប់ទៅ។ កើតជាមនុស្សទៀតរៀនរៀនសិល្បសាស្ត្រអ្វី។ក៏មិនចេះមិនចាំ។ ហើយក៏មិនពូកែធុតធាប់ ។ មានព្រាហ្មណ៍ ១ ទៀត មានកូនច្រើនណាស់ តែមិនបានគោរសត់បង្កក់ឆ្អបធ្វើធ្នេញលេញលឺ។ចូលមួយបន្ទុកការឲ្យកូន ស្ងាប់ទៅ។ កើតជាព្រាហ្មណ៍ទៀត គ្មានកូន ១ សោះ ទៅរកសុំកូនគេ។មិនឲ្យថែមទៀត ហេតុតែមិនបានធ្វើកិច្ចឲ្យកូន ,, ។

លុះព្រលឹងបុរសនោះ បានស្តាប់ព្រះឥន្ទចប់សព្វគ្រប់ហើយ ក៏លាព្រះឥន្ទត្រឡប់មកវិញ ចូលមកក្នុងរូបដែលដេកលក់នោះក៏ភ្ញាក់ឡើង ។ បុរសនោះគិតថា "អញដេកលក់អម្បាញ់មិញនេះយល់សប្តិឃើញល្អណាស់ ព្រលឹងអញបានទៅឋានសួគ៌ ស្តាប់ធម៌របស់ព្រះឥន្ទអំពីរឿងទ្រង់បុណ្យនេះប្រសើរណាស់" ។ លុះរសនោះគិតដូច្នោះហើយ ក៏រកទីសេះបង់ខ្នែត្រឡប់មកផ្ទះវិញ និយាយប្រាប់ប្រពន្ធនឹងអ្នកជិតខាងតាម

ដំណើរដែលខ្លួនយល់សប្តិនោះ ។ ឥឡូវទំនៀមទំលាប់ថាធ្វើបុណ្យ
ក៏មានជាប់ពីនោះរៀង ។ មក ។

ឯរបៀបធ្វើបុណ្យ ដែលខ្ញុំបានឃើញអ្នកដែលធ្វើបុណ្យតាមទំនៀម
ទំលាប់អ្នកស្រុកដែលធ្វើត ។ គ្នាមកនោះ : មានរៀបចំ ៤ ផ្លែឈើ ៤
សិង ៤ ខៀន ៤ ដើម ផ្តិលទឹក ៤ មានប្រែងមេ៧ដាក់ពែង ១ គូ, លុះ
លោកសូត្រសត្តបករណាភិធម្ម · ទីឆ្នាំមមិតភោកចប់ហើយ អាចារ្យអុជ
ខៀន ៤ ដើម និមន្តលោកសូត្រតហូរទៅធ្វើបុណ្យ, លុះចប់ធម៌តហូ
ទៅហើយ អាចារ្យប្រគេនដើងស្រាបពែង ២ ទៅលោក ។ ទទួលយកមក
អនុស្ថានធ្វើ ហើយប្រគល់មកឲ្យអាចារ្យវិញ ទើបអាចារ្យលើកពែង
តាំងពីរឡើងបញ្ចេញវាចីកេទថា " តានាបុណ្យបរិ - ឬណាដល់ស្មោះសរ
ជាមហាបុញ្ញា នៃអ្នកដើមការ សទ្ធាសេដ្ឋា អ្នកនោះវិសោ វិសុទ្ធិប្រែម-
ប្រិយ ។ មានចិត្តស្ម័គ្រស្មោះ ប៉ុនប៉ងចំពោះ គ្រប់អង្គម្ចាស់ថ្ងៃ ជា
ទីពឹងពាក់ ពុំនាក់អាស្រ័យ ព្រះស្រីរត្នត្រ័យ សព្វថ្ងៃនេះណា ។
អ្នកដើមការគិត តែងនឹងព្រួយចិត្ត អាណិតអាត្មា រលង់វិលក សង្វេគ
អនិច្ច ខ្ចាចក្រែងសង្ខារ មិនថេរថិតនៅ ។ ដូចដើមរាំង ដុះខៀវមាត់
ច្រាំង ទឹកហូរជ្រោលជ្រៅ រមើការបេះ រលេះច្រាំងទៅ រាំងនោះនៅ
ពុំបានឡើយណា ។ រលើងរលំ សាត់ទៅតាំងតុម្ព ក្រឡាប់ផ្តាប់ផ្សំ ភាល់
រួបប្រុសស្រី សព្វថ្ងៃនេះណា ក្នុងធម៌លោកថា ឧបមាដូចហោង ។

ហេតុនេះគួរគិត គួរតែតាំងចិត្ត កុំឲ្យមានហ្មង ធ្វើបុណ្យឲ្យទាន ជាស្ពាន
ចំឡង នាំបូរួចឆ្ងង ពីអកុសល ។ អង្គុយដញ្ជឹង ដេកហើយរំពឹង គន់
គិតឲ្យយល់ សក់ល្អដ្បិតច្រែង ទឹករវែងដ្បិតខ្យល់ កម្មអកុសល ពាល់រូប
ឥតល្អៃ ។ លោកថាកំណើត កក់ផងតែងកើត ពីទឹកឯងឯង បើទឹងលាង
កក់ ឲ្យជ្រះឲ្យថៃ ឲ្យជ្រះមានតែ ទឹកខើបលាងជ្រះ ។ រីអកុសល
អំពើអំពល់ ពៀរពុំស្រឡះ វាមានតែចិត្ត គំនិតម្នាម្នុះ មិនតាមធម៌ព្រះ
បន្ទូលទេសនា ។ ថាបើទឹងផ្តាច់ ចាបពៀរសម្រេច លាលាងវៀរ
មានប៉ុន្តែចិត្ត គំនិតសទ្ធា ចែកចាយទ្រព្យា ធ្វើបុណ្យឲ្យទាន ។
គោះមានគោះខ្វាត់ គោះនឿយគោះហត់ គោះអត់គោះឃ្លាន គោះចាយ ១
វែក សំឡ ១ ចាន ធ្វើបុណ្យឲ្យទាន ទាន់ខ្លួនរស់នៅ ។ មានទ្រព្យតិចតួច
មានកាលចោរលួច ភ្លើងឆេះអស់ទៅ កាលខ្លួនទៅរស់ របស់គង់នៅ
ជាប់ខ្លួនស្លាប់ទៅ អសារសូន្យសោះ ។ កូនចៅនៅក្រោយ គេធ្វើ
បុណ្យឲ្យ គេទឹកតែឈ្មោះ ការខ្ទេចជាច់ជាយ ធ្នាំងចាយទំលុះ កាំបិត
បន្ទោះ បញ្ចុះកំពង់ ។ គ្រឿងច្រាក់គ្រឿងមាស គ្រឿងស្ពាន់តុថាស
ដែលខ្លួនបំរុង គេថាទ្រព្យគេ មិនយកទៅបូង គេទុកបំរុង ចេញចាយ
ចែកគ្នា ។ ហេតុដូច្នោះនៃ ពាល់រូបប្រុសស្រី គួរគិតអនិច្ចា ស្លាប់ទៅ
ជាខ្មោច អសោចវិនា មិនមានអ្នកឯណា កំដរទៅផង ។ មានតែ
សីលទាន នោះខើបនឹងបាន នាំបូរួចហោង ជាខ្លួកជាភ្លោះ ចែកចែវឆ្លង

ដំណើរដែលខ្លួនយល់សប្តិនោះ ។ ភាគឬទំនៀមទំលាប់ថាធ្វើបុណ្យ
ក៏មានជាប់តាំនោះរៀង ។ មក ។

ឯរបៀបធ្វើបុណ្យ ដែលខ្ញុំបានឃើញអ្នកដែលធ្វើបុណ្យតាមទំនៀម
ទំលាប់អ្នកស្រុកដែលធ្វើត ។ គ្នាមកនោះ : មានរៀបនំ ៤ ផ្លែឈើ ៤
សិង ៤ ទៀន ៤ ដើម ដួលទឹក ៤ មានប្រែងមេ្យាដាក់ពែង ១ គូ, លុះ
លោកសូត្រសត្តបករណាកិច្ច · ទើងធម៌តភេកចប់ហើយ អាចារ្យអុជ
ទៀន ៤ ដើម និមន្តលោកសូត្រតហូរទៅធ្វើបុណ្យ, លុះចប់ធម៌តហូ
ទៅហើយ អាចារ្យប្រគេនដើងស្រោចពែង ២ ទៅលោក ។ ទទួលយកមក
អធិស្ឋានធ្វើ ហើយប្រគល់មកឲ្យអាចារ្យវិញ ទើបអាចារ្យលើកពែង
តាំងពីរឡើងបញ្ចេញវាចាកេតថា " តានាបុណ្យបរិ - បូណាជលំស្មោះសរ
ជាមហាបុញ្ញា នៃអ្នកដើមការ សទ្ធាសោដ្ឋា អ្នកនោះវិសោ វិសុទ្ធចិម-
ចិយ ។ មានចិត្តស្ម័គ្រស្មោះ ប៉ុនប៉ងចំពោះ គ្រប់អង្គម្ចាស់ថ្ងៃ ជា
ទីពឹងពាក់ តុំនាក់អាស្រ័យ ព្រះស្រីរត្នត្រ័យ សព្វថ្ងៃនេះណា ។
អ្នកដើមការគិត តែងនឹងព្រួយចិត្ត អាណិតអាត្មា រលំរលែក សង្វែគ
អនិច្ច ខ្លាចក្រែងសង្ខារ មិនថេរថិតនៅ ។ ដូចដើមរតាំង ដុះទៀបមាត់
ច្រាំង ទឹកហូរជ្រោលជ្រោ រលើករបេះ រលេះច្រាំងទៅ រតាំងនោះនៅ
តុំបានឡើយណា ។ រលើងរលំ សាត់ទៅតាំងតុម្ព ក្រឡាប់ផ្កាប់ផ្ងា ភាល់
រូបប្រុសស្រី សព្វថ្ងៃនេះណា តថធម៌លោកថា ឧបមាដ្ឋោះហោង ។

ហេតុនេះគួរគិត គួរតែតាំងចិត្ត កុំឲ្យមានហ្មង ធ្វើបុណ្យឲ្យទាន ជាស្ពានចំឡង នាំរូបរួចខ្លួន ពីអកុសល ។ អង្គុយជញ្ជឹង ដេកហើយរំពឹង គន់គិតឲ្យឃើញ សក់ល្អដ្បិតប្រែង ទឹករឹងដ្បិតខ្សាយ កម្មអកុសល កាលរូបឥតល្អ ។ លោកថាកំណើត កក់ផងតែងកើត ពីទឹកឯងឯង បើនឹងលាងកក់ ឲ្យជ្រះឲ្យថៃ ឲ្យជ្រះមានតែ ទឹកទើបលាងជ្រះ ។ រីអកុសលអំពើអំពល់ ទៀរពុំស្រឡះ វាមានតែចិត្ត គំនិតម្នាម្នុះ មិនតាមធម៌ព្រះបន្ទូលទេសនា ។ ថាបើនឹងផ្តាច់ ចាបពៀរសម្រេច លាលាងវោមានប៉ុន្តែចិត្ត គំនិតសទ្ធា ចែកចាយទ្រព្យា ធ្វើបុណ្យឲ្យទាន ។ ទោះមានទោះខ្សត់ ទោះទ្បើយទោះហត់ ទោះអត់ទោះឃ្លាន ទោះចាយ ១ វែក សំឡ ១ ចាន ធ្វើបុណ្យឲ្យទាន ទានខ្លួនរស់នៅ ។ មានទ្រព្យតិចតួច មានតាលចោរលួច ក្តើងឆេះអស់ទៅ តាលខ្លួនទៅរស់ របស់គង់នៅជាប់ខ្លួនស្លាប់ទៅ អសារសូន្យសោះ ។ កូនចៅនៅក្រោយ គេធ្វើបុណ្យឲ្យ គេនឹកតែឈ្មោះ តន្ទេលដាច់ដាយ ឆ្នាំងចាយទំលុះ តាំបិតបន្ទោះ បញ្ចុះតំពង់ ។ ត្រឿងច្រាក់ត្រឿងមាស ត្រឿងស្ពាន់តុថាស ដែលខ្លួនបំរុង គេថាទ្រព្យគេ មិនយកទៅប្តូង គេទុកបំរុង ចេញចាយចែកគ្នា ។ ហេតុដូច្នោះនៃ ពាល់រូបប្រុសស្រី គួរគិតអនិច្ចា ស្លាប់ទៅជាខ្មោច អសោចវែទនា មិនមានអ្នកឯណា តំដរទៅផង ។ មានតែសីលទាន នោះទើបនឹងបាន នាំរូបរួចហោង ជាខ្លួកជាគ្តារ ច្រកចែវឆ្លង

នាំរួចរំលង ក់លវង្គសង្ឃ ។ ហេតុនោះគួរគិត ឲ្យមានសុចរិត គ្រប់
អង្គអាត្មា ដើមនឹងទ្រង់ព្រះ តាំងក្នុងវេនា ទៅដល់ភពមហា - និព្វានខោះ
ហោង" ។

រួចអាចារ្យថា អនុមោទនា . លោកអើយ ! ។
អ្នកបុណ្យទទួលថា សាធុ . ។ ៣ ដង ។

ពង្សាវតារវត្តប្វាយ ទីធ៌ពិធីតសាធវត្ត, ពិធីបញ្ចុះសីមា, ពិធី
ឆ្លងបុណ្យ ចប់ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

សូមជូនចូលមកដល់ក្រមធំនំទំនៀមទំលាប់ខ្មែរ នៅក្រសួងពុទ្ធសាស-
នបណ្ឌិត្យ មើលោកពិនិត្យទៅឃើញថាត្រូវដាប់លេខថ្នាក់ណា, ខ្ញុំបាទ
សូមទទួលរង្វាន់ជាថ្នាក់តាមថ្នាក់នោះ ក្រែងតុំថ្នាកដសូមស៊ីញ្ជេះឈ្មោះ
ជូនទុកខាងក្រោមនេះ ។

ថ្ងៃ ៨ ខែមេសា ឆ្នាំ ១៩៤៩

អាចារ្យ ង្វង - អ៊ូ

ចេះប្រសើរជាងមិនចេះ
ទំនៀមណាដែលថាមិនគួរកាន់
ទំនៀមនោះគេគ្រាន់តែសិក្សា
ឲ្យចេះចាំដួចថ្នាំវិសជា
គង់ពេលណាឲ្យដែលដល់តុខ្លាន ។

លោកប៊ុន - ហាត់ អតីតតំណាងរាស្ត្រ

រៀបរៀង

យើងសូមបង្ហាញកាយ សំដែងសេចក្តីគោរព រាប់កន្លងដល់ព្រះគុណ របស់រត្នបុរសទាំងឡាយក្នុងសាគលលោកនេះ ដែលជាអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ, អ្នកប្រាជ្ញទាំងនោះ បានតាំងលោកឲ្យមានសេចក្តីសុវត្ថិភាព ទំនឹង រឭនធម្មតាគ្រប់ដំណាក់គ្រប់ថែបគ្រប់យ៉ាង ទុកមកឲ្យយើងរាល់គ្នាគ្រប់ជាតិគ្រប់ភាសា បានឃើញបានស្គាល់ នូវស្នាដៃស្នាមគំនិតរបស់លោក រហូតមកដល់សព្វថ្ងៃនេះ ។

ឯវិទ្យាសាស្ត្ររបស់អ្នកប្រាជ្ញទាំងឡាយនោះ ហួសវិស័យយើងរាល់គ្នា ដែលជាអ្នកមិនធ្លាប់គិតមិនធ្លាប់ទឹក ឃើញថារបស់ទាំងឡាយនោះមិនគួរនឹងកើតឡើងបាន តែជាកើតឡើងបាន ដោយអាស្រ័យថ្វីគំនិតរបស់លោកអ្នកប្រាជ្ញទាំងឡាយនោះ ដូចយ៉ាងលោកនិយាយថា នូវគ្រឿងចក្រផ្សេងៗ មានរថយន្តរថភ្លើងនឹងគ្រឿងអាកាសយាន មាននាវាបើកបរលឿនលើទឹកមុជជ្រៃកទឹកជ្រៃកដី (ដូចមច្ច) នឹងគ្រឿងប្រដាប់ខាងវិទ្យុទូរស័ព្ទទូរលេខផ្សេងៗ ជាដើមក្តី ផ្លូវឯណាដែលធ្លាប់ធ្វើដំណើរតែពាក់ខែកំតាចបន្តុយឲ្យតែជារាប់ថ្ងៃ, ផ្លូវឯណាដែលធ្លាប់ធ្វើដំណើរពាក់ថ្ងៃក៏ក្លាយតែជាពាក់ម៉ោងតែវិញបាន ។ ល ។ ។

ឯចំណែកខាងវិស្ញុតេរ្យសាស្ត្រនោះសោតទៀត ក៏កាន់តែចំរើនកើនឡើងៗចេញជាលំដាប់រាល់ឆ្នាំ លោកខំគិតប្រឌិតប្រែងជួយខ្ចែងដល់ជីវិតមនុស្សលោក ឲ្យមានជីវិតរស់នៅបានវែង មានការរុះរាត់បិទបាំងតិចតួចនឹងគ្រឿងពិនិត្យពុំសោយឈឺកសម្លាប់ដោយហេតុផលឲ្យដឹងជាក់លាក់ ដើម្បីនឹងប្រកបតុសថទៅតាមជម្ងឺរោគ, លោកខំកសាងក្បួនតម្រាទឹងវិធីបង្ការរោគ បំបាត់រោគដែលកើតមានឡើងហើយ ឲ្យអន់ថយខ្សោយចុះ កុំបីឲ្យកើតមាន ហើយប្រឹងស្រាវជ្រាវរកនូវតុធាតុផ្សេងៗយកមកផ្សំប្រកបជាតុសថ ដើម្បីនឹងជួយជីវិតមនុស្សឲ្យបានមានអាយុវែងតទៅ (ល) ។

រឿងនេះ យើងមិនចាប់ពោលឲ្យវែងតទៅទៀតទេ ព្រោះអស់លោក-អ្នកតាំងឮស្រាយ សឹងបានជ្រាបស្រាប់ហើយនូវអារម្មមិនឹងវឌ្ឍនធម៌នឹងសេចក្តីលំបាកក្នុងការស្រាវជ្រាវរកបស់អ្នកចាស់, ការស្រាវជ្រាវរកនូវអារម្មធម៌ នឹង វឌ្ឍនធម៌ជាគ្រឿងវិទ្យាសាស្ត្រដែលកើតមានក្នុងលោកដល់សព្វថ្ងៃនេះ នោះមិនមែនជាការងាយទេ ពុំមែនរកឃើញដោយធាប់រហ័សទៅតាមចំណុះយើងនឹកនោះទេ, តោងអាស្រ័យសេចក្តីព្យាយាមយ៉ាងខ្ជាប់ខ្ជួនក្លា តោងប្រើពេលវេលាពប់តាន់ឆ្នាំ ធ្វើឲ្យស្ទាប់មនុស្សក្នុងការល្បងលមើលនូវវិទ្យាសាស្ត្រផ្សេងៗ ស្ទាប់អស់ជាច្រើននាក់ ។ វិទ្យាសាស្ត្រមួយៗដែលសម្រេចឡើងនោះ តោងប្រើអស់អ្នកចាស់ជា

ច្រើនតំណាអាយុទើបសម្រេចឡើងបាន ។ ការខំគិតខំលៃខំសូធ្វើសូធ្វេកន្លួវត្តជាតុនឹងវត្តធម្មជាតិ ដើម្បីនឹងយកមកផ្សំប្រែកបន្លួវិទ្យាសាស្ត្រផ្សេងៗនោះ លោកក៏ខំគិតស៊ូអត់អាហារនឹងដំណេកក៏សឹងមាន, ឯការឆ្លាញ់នឹងតារសប្បាយរបស់លោក លោកយកការកេរយើញនេះ ជាគ្រឿងឆ្លាញ់គ្រឿងសប្បាយរបស់លោក ។ ហេតុនាំនេះឯងវាដល់បណ្តាលឲ្យយើងមានបីតិគិតនឹកដល់ព្រះគុណរបស់លោក ដែលលោកមានព្រះគុណលើសាកលលោកទាំងមូលនេះ; ដោយលោកខំប្រឹងប្រែងយកជីវិតរបស់លោក មកប្រើក្នុងការស្វះស្វែងស្រាវជ្រាវរកន្លួវិទ្យាសាស្ត្រផ្សេងៗ ប្រយោជន៍ទុកជាគ្រឹះមគ្គសម្រាប់សាកលលោក ដើម្បីនឹងឲ្យយើងពាល់គ្នាបានខ្លួលក្រែបដញ្ជក់យកន្លួវស្នាមគំនិតរបស់លោក ជាគ្រឿងរីករាយសប្បាយដល់ពលលោកទាំងមូល ។

ហេតុនេះ យើងសូមបង្អោនកាយរបស់យើងចូលកាន់មរណសញ្ញាចំពោះដួងវិញ្ញាណក្ខន្ធរបស់លោកអ្នកច្បាស់ទាំងឡាយនោះ ដែលបានលាចាកអំពីលោកនេះទៅ ទុកសល់នៅតែស្នាមគំនិតជាគ្រឹះមគ្គទាំងឡាយឲ្យដល់ពលលោក យើងទាំងអស់គ្នានេះ សូមឲ្យលោកបានទៅសោយសេចក្តីសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

យើងមានសេចក្តីតក់ស្លុតរន្ធត់ញាប់ញ័រក្នុងហទយ: (បេះដូង) ដោយមានសេចក្តីនឹកស្តាយស្រណោះ ដល់ស្នាមគំនិតនៃវិទ្យាសាស្ត្រ

របស់ក្តុបុរសទាំងឡាយនោះ ដែលលោកចំរើនកុសលបាន តើត
ឡើងដោយកម្លាំងយើងបានប្រែប្រាប់ដូនមកខាងលើនេះ គឺយើងបាន
ខ្ជួលដំណឹងខ្លះតាមវិស្សជ្ជនាសាតិមានខ្លះ ថាមានអ្នកស្ថាជ្ញខាងប្រដិត
ខ្លួរគ្រឿងយុទ្ធសាស្ត្រផ្សេង ។ ចុះដំរើនកើនឡើងខ្លួរកម្លាំងអាទុកាត គឺ
គ្រឿងប្រហារប្រលយ័លោក មានគ្រាប់ដែកបរមាណូនឹងអ័ត្រហ្ស៊ែន
ជាដើមនោះ; នាំឲ្យយើងមានសេចក្តីតូចចិត្តនឹកស្តាយដល់អាវុធមិនឹង
វិឡ្ឍនធម៌ទាំងឡាយនោះ ដែលប្រសូតចេញមកអំពីខួរក្បាលរបស់អ្នក
ស្ថាជ្ញទាំងឡាយដោយកម្លាំងនេះ, លោកចំព្យាយាមបីជាដរក្បា
ចំញឹមមកមានអាយុអស់រយៈវេលាប៉ន្មានឆ្នាំ ទំពាំតែបានធំធាត់ឡើង
បានប៉ុនសព្វថ្ងៃនេះ ។

ឯពលលោកទាំងមូល កំពុងមានសេចក្តីស្ងើចសរសើរដល់អាវុធមិ
នឹងវិឡ្ឍនធម៌ទាំងឡាយនោះពុំទេរអស់ពុំចេះហើយ មានសេចក្តីរីករាយ
ត្រេកត្រអាលចំរើបជាញឹកខ្លួរសេចក្តីរុងរឿងគ្រប់បែបគ្រប់យ៉ាង ក៏ស្រាប់
តែមកបានឮដំណឹងអកុសលម្លឹយ៉ាងដូច្នេះ; នេះនាំឲ្យពលលោកទាំង
មូលមានសេចក្តីត្រួយចិត្តម្តង ទឹកស្តាយស្រណោះដល់វិទ្យាសាស្ត្រទាំង-
ឡាយ ដែលកំពុងតែចំរើនឡើងសព្វថ្ងៃនេះពុតជាមុន មានអ្នកខ្លះលាន់
មាត់ចេញពាក្យថា ឲ ! តុបាកតុមារីក្នុងសាកលលោកទាំងឡាយអើយ !
បើគ្រឿងយុទ្ធសាស្ត្របែបនេះ ចំរើនខ្លួរអាទុកាតខ្លាំងក្លាយ៉ាងម្ល៉ះ

តើអនាគតរបស់អ្នកនឹងទៅជាយ៉ាងណាទៅ? ទុព្វែរបរមកជាំជនឹងហោ គេហឆ្ងាន់ប្តូរតុបុកណាស្រេច។ ដែលជាវិនុងរឿងក្នុងលោកនេះទាំងឡាយ អើយ! តើអនាគតរបស់នៃគ្រឿងលំអលោកទាំងឡាយនេះ នឹងទៅជាយ៉ាងណាទៅ? ទុក្ខួនតម្រាដែលជាឃ្លាំងសម្រាប់ផ្ទុកគោនៃភាវធម៌ នឹងវឌ្ឍនធម៌ទាំងឡាយអើយ ដែលរត្នបុរសទាំងឡាយនោះខំតតំសារសេរខុកមកច្រើនជួរភាយុមនុស្សយ៉ាងដូច្នេះ! តើអនាគតរបស់ក្ខួនតម្រាទាំងនោះនឹងទៅជាយ៉ាងណាទៅអេះ?

កាលណាបើបានឮដំណឹងអំពីអានុភាពនៃគ្រឿងយុទ្ធសាស្ត្រនោះឡើងហើយ នាំឲ្យយើងមានសេចក្តីនឹកព្រួយស្តាយស្រណោះ ដល់ភាវធម៌នឹងវឌ្ឍនធម៌នោះខុកជាមុនឥតឧបមា ។

ទំនួញ'សាកស្តាយ

បទពហ្មរត

ខ្ញុំឮដំណឹងឡើង ភ្ញាក់សើងម្តើងញ័រអង្គា
ព្រួយដល់វង្គនានា ដែលកំពុងតែរុងរឿង ។
បរិបូណ៌ដោយវឌ្ឍនៈ ទាំងភាវធម៌តើតឡើង
សព្វថៃថ្ងៃកំពុងច្នៃង ដោយស្នាដៃនៃអ្នកជ្រាជ្ញ ។
ត់ឡូវមកមានហេតុ ក្នុងខ្ណៈខែត្រចិត្តកំណាច
ផ្តងរំខ្វែឲ្យម្ខាងខ្លាច គាចនឹងគាចចង់ល្បងគ្នា ។

ដរណ្តើមយកឈ្នះចាញ់ មានតែអញក្នង់លោកា
អួតអាងញាក់ជាក់គ្នា ឲ្យវេទនាដល់ពលលោក ។
សង្គ្រាមលើកទីពីរ មនុស្សវែកវីស្ទាប់គរគោក
ព្រោះតែដណ្តើមជោគ ជ័យដំនះតែរឿងខ្លួន ។
ហ៊ានហោចដល់កោគទ្យ មនុស្សក្រែងរាប់រាប់ចំនួន
លានលានតែរឿងខ្លួន គិតចំនួនគួរស្តាយណាស់ ។
អាសូរក្មេងកំព្រា គួរវេទនាដោយព្រាត់ប្រាស
ឪពុកម្តាយវិនាស ខ្វះព្រាត់ប្រាសកូនប្រពន្ធ ។
បង្ហូរតែទឹកភ្នែក ខ្វះយំស្រែកដើរកេគន់
ស្វែងរកកូនប្រពន្ធ ថែមទុក្ខធ្ងន់ធ្ងរអត់ប្រាយ ។
សង្គ្រាមផុតកាលណា តាំងនាំគ្នាអង្គុយស្តាយ
ជីវិតទ្យទាំងឡាយ ដែលវិនាសកងសង្គ្រាម ។
អំណាចនៃលោភៈ កើតទោសៈមោហៈតាម
ប្រកិតបិទប្រាំងស្នាម ប្រាជ្ញាត្រូវយល់ថាខុស ។
ខ្ញុំសូមទុនកាយា ដល់ទៅតាដួយសន្ធោស
ឲ្យលោកផុតពីគ្រោះ ទង្វើសង្គ្រាមបរមាណូ ។

ឬមួយម៉ែត្រហ៊ែន ផ្ទុះឡើងដែនដីនេះខ្លាំង
សូមជួយឲ្យសុខយូរ រាប់ពាន់ឆ្នាំទៅមុខហោង ។
ខ្ញុំសូមទុកចិត្តា លើអង្គការជាតិជាម្ចាស់
សូមឲ្យជួយលោកផង កុំឲ្យមានសង្គ្រាមអើយ !!! ។

ខ្ញុំសូមលើកយកន្ទូរសេចក្តីសុខ ទឹងអារូធម៌ ព្រមទាំងវឌ្ឍនធម៌ក្នុងលោកទាំងមូលនេះ ផ្ញើទៅលើអង្គការសហប្រជាជាតិ គឺលោកនេះហើយដែលជាគ្រឿងក្រោមួយយ៉ាងសំខាន់ សម្រាប់ហ៊ុំព័ទ្ធការពារន្ទូវក្តីងសង្គ្រាមលោកទៅអនាគត កុំបីឲ្យមានឆេះពាល់ដាលទៅលើសេចក្តីសុខ ក្នុងលោកទាំងមូលនេះដែលជាទីជ្រកកោនដល់មនុស្សលោក ដែលកំពុងត្រូវការចង់ដឹងចង់ស្គាល់ចង់ឃើញដោយរីករាយ ។

ខ្ញុំសូមសង្ឃឹមទុកចិត្តលើអង្គការនេះហើយ ដែលមានសមាជិក ជាងកន្លះរយប្រទេសដែលនៅប្រចាំក្នុងអង្គការនេះ ទុកដូចជាតួអង្គទេវតាប្រចាំក្នុងវដ្តមួយ ។ គឺលោកនេះហើយដែលជាអ្នកទទួលខុសត្រូវចំពោះលោកទាំងមូល, ហើយសូមទុកលោកជាទេវតាប្រចាំទិស សម្រាប់ការពារន្ទូវសេចក្តីវិនាសគ្រប់បែបគ្រប់យ៉ាង ហើយជាអ្នកស្វែងរកន្ទូវសេចក្តីសុខ មកឲ្យសាកលលោកទាំងមូលនេះផង ដូចជាក្នុងកាលថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៤០នេះ មានប្រជាជាតិតូចៗប្រហែលជា ៥០ ជាតិ បានទាំគ្នាអត់អាហារប្រឆាំងនឹងគ្រាប់បែកបរមាណូ នឹងអ៊ីដ្រូហ្សែន ។

មានសារគមហាត្ថុះត្ថុប្បវែលជា ៥០ នាក់ កើតសេចក្តីដែរថ្វាចំពោះសោកសលោក ហើយ ។ ខ្ញុំនាំដែរចេញក៏ចាប់ថា មានតែលទ្ធិអហិង្សា (ការមិនបៀតបៀមអ្នកដទៃ) មួយនេះទេ ដែលអាចនឹងនាំយកសេចក្តីសុខមកជាក់ក្នុងលោកនេះបាន ។ ពួកនេះបានរួមចិត្តគាំអត់អាហារអស់រយៈវេលាមួយសប្តាហ៍ គឺចាប់តាំងពីថ្ងៃទី ២ ដល់ថ្ងៃទី ៨ ខែមេសា ឆ្នាំ ១៩៥០ នេះ ប្រយោជន៍ដើម្បីនឹងប្រទាំងដល់ជាតិណាដែលបំរុងនឹងធ្វើសង្គ្រាមទៅអនាគត ហើយប្រទាំងទឹងគ្រាប់បែកអ័ត្រូហ្សែននឹងអាតូមិចនោះផង ។

ប៊ុន - ចាន់ អតីតតំណាងរាស្ត្រ

ស្នេហ៍ជាតំពិតមិនស្លាយជីវិត

ស្នេហ៍ជាតំពិតត្រូវពិនិត្យដោយធម៌បី
មួយគឺក្តីលៃញ្ញាយាមប្រកបកិច្ច
ពីរគាន់ទៀងរៀងរាល់ថ្ងៃទោះច្រើនតិច
បីបើកិច្ចមិនសម្រេចស្ងឹមរណ៍អង្គ ។
តែកុងធម៌ដ៏ប្រសើរ ៣ នេះ
បើនឹងរិះរកវែកគុណដែលឲ្យផ្តល់
ធម៌ទី ៣ ធំជួចដល់ភាពខ្ពស់ខ្ពង់
ធម៌ ២ ឥស្សរគង់វង់តើតមានបាន ។

La Lumières de l'Asie

លោកស៊ីរ - អេឌវ៉ាំងអារណ្យលង់ តែង

លោកព័ឃ - ប៊ុក ត្រមការ បែបរៀបរៀង

(ពន្ធក)

មានពពែញីមួយមានសម្បុរធ្លុត ។ មានស្នែងវែង ដេកសន្ធឹងនៅដីមានក្បាលគេចង់ក្លាប់ទឹងស្មៅមុត្សា[1] (Moudja); -មានព្រាហ្មណ៍ម្នាក់យកកាំបិតផ្តាច់ទឹងកសត្វនោះហើយសូត្រធម៌ខ្សឹប ។ ថា "ឧត្រែះដែលមានឥទ្ធានុភាព! នេះហើយជាយ័ជ្ញាស[2] (yadjaras) ដែលព្រះបាទពិម្ពិសារ (Bimbisara) យកមកបូជា; អ្នកចូរត្រែកអរ ដោយការឃើញលោហិតហូរចុះ, អ្នកចូរមានចិត្តរីករាយសប្បាយ ដោយការឃើញសាច់មានខ្លាញ់ដែលគេមកចំអិនទឹងភ្លើងចុះ, ចូរបអកុសលដែលព្រះមហាក្សត្រធ្លាន់ធ្លើសូមឲ្យធ្លាក់ទៅលើពពែញីនេះ ហើយសូមឲ្យភ្លើងឆេះរំលាយសត្វនេះទៅចុះ, ខ្ញុំទឹងសម្លាប់សត្វនេះក្នុងកាលឥឡូវនេះ" ។

តែព្រះពោធិសត្វទ្រង់មានព្រះបន្ទូលថា: "ឧត្រែះសម្មតិទេព, កុំឲ្យគេពិឃាតវាធ្លើអី" ដល់មានព្រះបន្ទូលដូចនេះរួច ព្រះអង្គបានស្រាយ

---

១ មុត្សាជាការសាវណ្ឋ គឺជាឈ្មោះបម្រាំងហើស្មៅមួយប្រែបានដែរ ឯមានជុំវិញទៅប្រទេសតំណៀរហើយសម្រាំងយកមកធ្វើញវែញជាខ្សែ ។ ២ យ័ជ្ញាស ប្រែហែល យជ្ញ (Yajna) ទេ ព្រោះក្នុងពាក្យ ខ្លះគេយកសត្វទៅធ្វើពលិកម្ម ។

ចំណង់ដែលចង់ក្លាប់ខ្មោះខ្លួន ។ ក្នុងសាលរោះ គ្មានអ្នកណាហាមឃាត់ព្រះអង្គឡើយ ព្រោះព្រះអង្គមានព្រះញាណជាអស្ចារ្យ គួរឲ្យជនទាំងពួងគោរពកោតក្រែង ។

ព្រះពោធិសត្វបានសូមទៅសព្រះមហាក្សត្រ ហើយមានព្រះបន្ទូលថា: "ជីវិតរបស់ជនគ្រប់រូបគេអាចយកចេញបានតែមិនមានអ្នកណាអាចឲ្យបាន; ជីវិតគឺពួកសត្វទាំងអស់ក្នុងសាកលលោកតែងស្រឡាញ់ហើយមានចិត្តតស៊ូចំពោះសត្រូវព្រោះតែជីវិតនេះ; ជីវិតជាវត្ថុប្រកបដោយអច្ឆរិយវត្ថុ ថ្លៃហើយជាទីគោរពចិត្តចំពោះជនទាំងពួងគ្រប់រូប រហូតដល់សាមញ្ញសត្វ; មែនហើយ ជីវិតគឺជាអំណោយដ៏ថ្លៃថ្លាចំពោះសត្វលោកដែលមានចិត្តមេត្តា ព្រោះចិត្តមេត្តានេះ ធ្វើឲ្យសត្វលោកស្លូតត្រង់ចំពោះសត្វណាដែលទុព្វលភាព ហើយធ្វើឲ្យវិសេសវិសាលចំពោះសត្វណាដែលមានកំឡាំងជាងគេ" ។ ព្រះពោធិសត្វទ្រង់ជាអ្នកតំណាងពួកសត្វដែលមានមាត់មិនចេះស្ដីនិយាយ ព្រះអង្គមានព្រះបន្ទូលជូនសត្វទាំងនេះ ដោយព្រះប្រៀយវាចាដ៏ទន់ផ្អែមល្ហែម ដើម្បីនឹងតវ៉ាចំពោះព្រះកត្តិព្រះមហាក្សត្រ; ព្រះអង្គទ្រង់បង្ហាញឲ្យឃើញថា: "មនុស្សដែលសូមឲ្យព្រះសន្ដោសត្រាប្រណីគោសខោះ ជាអំសាវតកាល ព្រោះមនុស្សនោះជាព្រះរបស់សត្វតិរច្ឆានទៅហើយ, តែវត្ថុដែលមានជីវិតក្នុងលោកតែងមានក្រសែភាក់ទង់គ្នាដោយញាតិសាច់ឈាមហិត ហើយ

សត្វដែលយើងពិឃាតទាំងនោះគឺជាសត្វដែលបានឲ្យទឹកដោះគោ, ឬ
ទុណ្ណាម័យដល់យើង ហើយក៏បានទុកចិត្តប្រគល់ដីវិតឲ្យយើងដែលមាន
ចំណង់ទឹងសម្លាប់" ដូច្នេះហើយ ព្រះអង្គមានព្រះបន្ទូលអំពីសៀវភៅ
ធម៌ផ្សេងៗ ដែលបានសំដែងដោយជាក់ច្បាស់ថា: "ក្រោយដែលសត្វ
អនិច្ចកម្មៅ មិនថាយើងឬគេទេ ខ្លះត្រូវទៅចាប់កំណើតជាបក្សា, សត្វ
តិរច្ឆាន, ខ្លះជាមនុស្សជាតិគឺធ្លាក្លើងដែលធ្លើដំណើរតាមអាកាស ប្រែ
សភាពទៅជាក្លើងបរិសុទ្ធស្អាតទៅវិញ ព្រោះហេតុដូចនេះ ពលិកម្មនេះ
ជាកម្មមួយថ្នាក់ទៀត បើយាត់ហាមមិនឲ្យព្រលឹងទៅចាប់កំណើតតាមផ្លូវ
វាសនាសត្វ។ ខ្លួន ។ មិនមានអ្នកណាយកលោហិតមកធ្វើឲ្យប្រាជ្ញាមាន
សភាពបរិសុទ្ធស្អាតទេ; បើព្រះ,ទេវតានឹងព្រះព្រហ្មនោះចិត្តល្អ, លោ
ហិតទាំងនេះមិនមែនធ្វើឲ្យលោកទាំងនោះមានហសនចិត្តទេ បើព្រះទាំង
នោះមានសន្តានចិត្តកាច, លោហិតនេះមិនធ្វើឲ្យប្រែចិត្តគំនិតបានទេ ។
គេមិនអាចយកជាបកម្ម ១ ចំរៀកសក់ដែបត្រូវទទួលផលចំពោះខ្លួន មក
ជាក់លើក្បាលសត្វដែលឥតប្រព្រឹត្តខុសបានឡើយ ព្រោះបុគ្គលម្នាក់ៗ
ត្រូវទទួលដំពាក់ចំពោះខ្លួនតាមច្បាប់លេខគណិតនៃលោកធាតុ ដែល
ពោលថា: "អ្នកធ្វើល្អនឹងបានល្អ, អ្នកធ្វើអាក្រក់នឹងបានអាក្រក់ តាម
ការប្រព្រឹត្តដោយកាយ-វាចា ឬចិត្ត: ច្បាប់ដែលមានសភាពពិត មិន
ចេះយោគយល់ដោយអគតិ មិនចេះប្រែប្រួល ហើយថ្លែងថា "អនា-
គតហេតុជាផលនៃអតីតហេតុ" ។ (មានត)

ព្រះទេវមុនី យ្ញរ - ប៉ុណ្ណា

ក្រុមដំបូងព្រះត្រៃបិដក ទៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(ត - ចប់)

ជនអ្នកមានសទ្ធា រមែងបានអានិសង្ស ៥ យ៉ាងគឺ :-

១ - បឋមំ អនុកម្បន្តិ សប្បុរសតាំងឡាយតែងអនុគ្រោះដល់អ្នកមានសទ្ធាមុនគេ ។

២ - បឋមំ ឧបសង្កមន្តិ សប្បុរសតាំងឡាយតែងចូលទៅរកអ្នកមានសទ្ធាមុនគេ ។

៣ - បឋមំ បដិគ្គណ្ហន្តិ សប្បុរសតាំងឡាយតែងទទួលយកទេយ្យវត្ថុរបស់ជនអ្នកមានសទ្ធាមុនគេ ។

៤ - បឋមំ ធម្មំ ទេសេន្តិ សប្បុរសតាំងឡាយរមែងសំដែងធម៌ដល់ជនអ្នកមានសទ្ធាមុនគេ ។

៥ - សុគតិ សគ្គំ លោកំ ឧបបជ្ជតិ ជនអ្នកមានសទ្ធានោះលុះធ្វើមរណកាលហើយ រមែងទៅកើតកន្លែងសុគតិភពគឺស្ថានសួគ៌ ។

តោលមកប៉ុណ្ណោះ ហៅថា សទ្ធាពលៈ ។

៣) **វីរិយពល:** ប្រែថា "កំឡាំងគឺសេចក្តីព្យាយាម" ។ សេចក្តីព្យាយាមនេះជាគុណជាតិម្យ៉ាង ដែលយឹតយោងចិត្តឲ្យមានកំឡាំងក្នុងការប្រព្រឹត្តធម៌ ឬប្រកបការងារគ្រប់យ៉ាង, បើទុកជាមានដំនឿយ៉ាងណាក៏ដោយ តែបើខ្វះសេចក្តីព្យាយាមហើយ ការផឿនោះ ក៏មិនមានកំឡាំងប៉ុន្មាន ។

សេចក្តីព្យាយាមនេះ បើគោលដោយសង្ខេបមានពីរយ៉ាងគឺ:

១- **បហាន:** ព្យាយាមលះសេចក្តីអាក្រក់កុំឲ្យកើតឡើងក្នុងសន្តាន ។

២- **ភាវនា** . ព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងក្នុងសន្តាន ។

សេចក្តីព្យាយាមនេះ កាលបើបុគ្គលបានធ្វើហើយ ប៉ុន្តែមិនបេះរក្សាសេចក្តីល្អទុក, សេចក្តីល្អនោះ ក៏នឹងវិនាសទៅវិញ, ព្រោះសេចក្តីល្អមិនមែនជារបស់គួរធ្វើម្តងម្កាលឡើយ គួរធ្វើជានិច្ច ទើបឈ្មោះថាមានសេចក្តីល្អប្រចាំនៅក្នុងសន្តាន ឬក៏ព្យាយាមរក្សាសេចក្តីល្អដែលបានធ្វើម្តងនោះហើយមិនធ្វើតទៅទៀត សេចក្តីល្អនោះក៏ខ្សោយកំឡាំងយឺតយូរទៅវិញ, កាលបើសេចក្តីព្យាយាមមានកំឡាំងមាំមួនហើយ ក៏រមែងជាឧបករណ៍ប្រឆាំងហ្មត់ទៅរកសេចក្តីចំរើន, សូម្បីការងារប្តូរផ្លាស់ប្រែតិបត្តិនោះ នោះ

ត្រលំបាកយ៉ាងណាក៏ដោយ គង់បានសម្រេចដូចបំណង ។ សូមភាញ
ចេតោវណ៌មកបន្ថិចឲ្យឃើញកំឡាំងនៃសេចក្តីព្យាយាម ; ដូចមហា-
សមុទ្រដែលមើលគោះមើលត្រើយម៉ិនឃើញ ផុតវិស័យមនុស្សសាមញ្ញ
នឹងគិតលែលកកេប្រយោជន៍ឲ្យកើតដល់ខ្លួនមិនបាន, តែគង់មានមនុស្ស
អ្នកមានគំនិតច្បាស់ អាចគិតឃើញ គេធ្វើនាវាធំតូចប្រកបដោយ
ក្តោង ឬត្រឹងចក្រត្រឹងយន្ត ហើយផ្លុកទំនិញត្រប់យ៉ាង បើកកាត់
ទ្វីបទៅមកលក់ដូរត្រប់ប្រទេសក្នុងលោក យកមាសប្រាក់ភ័ស្តុភារមក
ជាប្រយោជន៍ខ្លួន ឬយកមកកសាងប្រទេសរបស់គេ ឲ្យទៅជាអារ្យ
ប្រទេសបាន ។

មួយទៀត ដូចយ៉ាងមនុស្សជាន់ខ្ពស់ក្តី ស្តាននសួគិក្តី ស្តានព្រហ្មក្តី
ព្រះនិញ្វានក្តី សុទ្ធតែជាកន្លែងជាន់ខ្ពស់ គេក្រែបានចួបប្រទះ ក្រែបានទៅ
កើតណាស់ ; តែបើទុកជាដូច្នោះ ក៏គង់មានបុគ្គលអ្នកព្យាយាមខំប្រឹងធ្វើ
ប្រឹងប្រែត្តតែតែបានទៅកើតទៅនៅកប់មិនអស់, មើលចុះដូចយ៉ាង
ព្រះមហាកស្សបត្ថេរមន្ត្រីសេដ្ឋីគហបតីតូចធំ នឹងពួកទេវតា ពួកព្រហ្ម ឬ
ព្រះអរហន្តចាំងឡាយមានព្រះពុទ្ធជាដើម ដែលនឹងបានសម្រេចដល់ឋាន
តាមលំដាប់ខាងនោះ ក៏ព្រោះសេចក្តីព្យាយាមអប់រំកំឡាំងចិត្តឲ្យប្រព្រឹត្ត
ទៅក្នុងកុសលធម៌តាមជាន់តាមថ្នាក់ដែលគួរធ្វើគួរប្រព្រឹត្តបាន; យ៉ាងនេះ
ហៅថា វីរិយពលៈ ។

៣) សតិពល: ប្រែថា "កំឡាំងគឺសតិ" ។ សតិនេះ ជាគួគ្នានឹងសម្បជញ្ញ:, សតិនឹងសម្បជញ្ញ:ជាធម៌មានឧបការៈច្រើន ។ សតិប្រែថា "សេចក្តីរលឹក" ។ សម្បជញ្ញ: ប្រែថា "សេចក្តីដឹងខ្លួន" ។ គុណធម៌ទាំងពីរនេះ ប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងគ្នាតែអាការ:; សតិជាក្នាក់ជារខាងឯនឹកឃើញក្នុងវេលាដែលធ្វើហើយ និយាយហើយ គិតហើយ, សូម្បីយូរ ។ ក៏នឹកឃើញបានទាំងអស់ ។ សម្បជញ្ញ: ជាក្នាក់ជារខាងឯដឹងខ្លួនក្នុងវេលាដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត ។ ចិត្តរបស់យើង កាលបើមិនមានសតិសម្បជញ្ញ:គ្រប់គ្រងហើយ តែងតែស្ទុះស្ទាត់ទៅតាមអន្ទះអន្ទែងទៅរកវិសភាគារម្មណ៍ផ្សេងៗ តាមតែប្រទះ មិនរើសថាគួរនឹងមិនគួរឡើយ ។ ដូចជារថទឹមដោយសេះដែលមិនមាននាយសារថីបរ សេះចេះតែអូសរថទៅតាមទំនើងចិត្តរបស់វា ស្ទុះទៅផ្លូសផ្លាសប៉ះនេះប៉ះនោះហែ ។ ទៅតាមផ្លូវ ធ្វើឲ្យកើតសេចក្តីអន្តរាយផ្សេងៗយ៉ាងណាមិញ; ឯសេចក្តីប្រព្រឹត្តរបស់មនុស្សក៏ដូចគ្នា គឺថាមនុស្សម្នាក់ៗបើមិនមានសតិសម្បជញ្ញ:ហើយ រមែងប្រព្រឹត្តកាយវាចាទុស្សៗភ្លាត់ៗ ធ្វើឲ្យកើតសេចក្តីអន្តរាយផ្សេងៗ ដល់ខ្លួននឹងអ្នកដទៃពុំខាន ។ ចំណែកមនុស្សដែលមានសតិសម្បជញ្ញ:វិញ រមែងប្រព្រឹត្តកាយវាចាតាមគន្លងដែលល្អៗ ជាហេតុនាំឲ្យបានសេចក្តីសុខចំរើនដល់ខ្លួននឹងអ្នកដទៃ: ដោយនេះ ហៅថា សតិពល: ។

๔) សមាធិពល: ប្រែថា "កំឡាំងគឺសមាធិ" ។ សមាធិ ប្រែថា "សកាពនឹងដ៏ន, ខ្ជាប់ខ្ជួន, មាំមួន" ។ សមាធិនេះ ជាធម៌ សម្រាប់ពត់ចិត្តតម្រង់ចិត្តឲ្យតាំងនៅដោយល្អក្នុងអារម្មណ៍តែមួយ ព្រោះ ចិត្តនេះតែងត្រេកត្រអាលទៅក្នុងអារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើម ។ ចិត្តនេះទៅមិនស្ងៀមទេ, ដូចជាសត្វស្វា ធម្មតាសត្វស្វាជាសត្វរឹសណាស់ នៅមិននឹងមិនស្ងៀម ចាប់នេះចាប់នោះតាមតែប្រឌុះ, កាលបើគេចង់ដៃជាប់ហើយ ក៏យកជើងទៅលូកចាប់ទៀត, កាលបើជាប់ជើងយកមាត់ទៅខាំទៀត, កាលបើជាប់មាត់ ទំផ្លួសបម្រះនទៀលខ្ជួនឲ្យទៅប៉ះនឹងវត្ថុនោះទៀត ធ្វើដូចម្តេចឲ្យតែបានទៅប៉ះពាល់ ទោះបីវត្ថុនោះក្តៅត្រជាក់រឹងទន់ ល្អិតគ្រោតគ្រាត ក៏មិនធុញធ្លាន់ យ៉ាងណាមិញ; ចិត្តរបស់មនុស្សក៏ដូចគ្នាដែរ, កាលបើមិនមានសមាធិចិត្តនៅត្រង់ត្រង់ហើយ ក៏រមែងធ្វេធ្វាស្ទុះស្ទាទៅតាមត្រកៀសោបយកអារម្មណ៍ផ្សេងៗ តាមតែប្រឌុះ ធ្វើឲ្យកកស្អែក ដល់ជាតិដែលធ្លាប់បានអប់រំទុកមក ។ ព្រោះហេតុនោះ បុគ្គលគួរដំកល់ចិត្តឲ្យនឹងឲ្យស៊ប់ទៅក្នុងសមាធិធម៌ ទើបជាចិត្តស្ងប់ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌តាំងពួយមានវិវេកធម៌ជាដើម ហើយក៏បានដល់បឋមជ្ឈាន, ទុតិយជ្ឈាន, តតិយជ្ឈាន តាមុំលាំងដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខមិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយចិត្តក៏ធ្វើធុតចាកកតតាំង ៣ បានដល់ព្រះនិព្វាន ឥតមានការតើតសាប់តទៅ: យ៉ាងនេះហៅថា សមាធិពល: ។

៥ បញ្ញាពលៈ ប្រែថា "កំឡាំងគឺបញ្ញា" ។ បញ្ញានេះជាធម្ម-ជាតិដែលមានប្រចាំនៅក្នុងសន្តានតាំងពីកំណើត ទោះបីតិចច្រើនតាមឧបនិស្ស័យដែលបានអប់រំខុសមក ។ បញ្ញានេះជាគុណជាតិមិនញាប់ញ័រ កន្ត្រើយ អាចជួយឧបត្ថម្ភនូវសហជាតធម៌តាំងពួនឲ្យមានកំឡាំង ហើយញ៉ាំងបុគ្គលឲ្យស្ថិតនៅក្នុងសេចក្តីសុខគឺព្រះនិព្វាន ។ បញ្ញានេះមានការជួយដោះខ្ញុកដោះកុនដែលកើតឡើងក្នុងបច្ចុប្បន្ននេះភ្លាម ។ បានបញ្ញានេះមានការដឹងច្បែកជាងសញ្ញានឹងវិញ្ញាណ ។ សញ្ញាគ្រាន់តែដឹងនូវអារម្មណ៍មានពណ៌ខៀវលឿងជាដើម, មិនអាចចាក់ធ្លុះនូវតែលក្ខណ៍បានឡើយ ឬក៏ដឹងនូវតែមានតម្លៃល្អអាក្រក់បានឡើយ ។ វិញ្ញាណដឹងច្បាស់នូវអារម្មណ៍មានពណ៌ខៀវលឿងជាដើមផង ចាក់ធ្លុះនូវតែលក្ខណ៍ផង, តែមិនអាចឲ្យសំរេចមគ្គផលបានឡើយ ។ ឯបញ្ញាអាចដឹងច្បាស់នូវអារម្មណ៍គ្រប់យ៉ាង តាំងចាក់ធ្លុះនូវតែលក្ខណ៍ នឹងអាចជ្រាបដែងឲ្យបានសម្រេចមគ្គផលគឺព្រះនិព្វានផង ។

ឯផ្លូវប្រតិបត្តិរបស់បញ្ញា ដែលព្រះពុទ្ធជាអ្នកត្រាស់សំដែងដោយច្រើននោះ បានខាងបញ្ញាដែលដឹងច្បាស់កងលក្ខណៈ ៣ យ៉ាង គឺ អនិច្ចតា = សភាពជារបស់មិនទៀង ១, ទុក្ខតា = សភាពជាទុក្ខ ១, អនត្តតា = សភាពមិនមែនជារបស់ខ្លួន ១ ។ តាំងបីនេះជាផ្លូវប្រតិបត្តិនៃបញ្ញា អាចយល់ច្បាស់នូវការកើតឡើងនឹងវិនាសទៅវិញ ហើយអាច

ចាត់ធ្វើនូវសុះសំណាយនូវគំនរនៃលោភៈ ទោសៈ មោហៈ ឲ្យអស់ទៅ ដាច់
បញ្ញាបរិសុទ្ធផុតចាកកិលេស ហើយធ្វើវដ្តទុក្ខឲ្យអស់ទៅដោយប្រពៃ ។
បញ្ញាចែកចេញជា ២ យ៉ាងគឺ លោកិយប្បញ្ញា ១ លោកុត្តរប្បញ្ញា ១ ។
បញ្ញាឈ្មោះកវន្ធវៃ ស្គាល់ហេតុ-ផល ចេះរក្សាខ្លួនឲ្យបានសុខស្រួល
តាំងបច្ចុប្បន្ន ហៅថា លោកិយប្បញ្ញា ។ បញ្ញាដែលធ្វើផុតលោកទាំងបី
ហៅថា លោកុត្តរប្បញ្ញា ។

បញ្ញានេះទុកដូចជាការុងមុតថ្លា អាចកាប់ឆ្កាវនូវព្រៃទុច្ចរិតគឺ
កិលេសដែលធ្វើចិត្តសត្វឲ្យសៅហ្មង , ឬ ដូចជាប្រទីបសម្រាប់បំភ្លឺក្នុងទី
ងងឹត ។

ហេតុឲ្យកើតបញ្ញាមាន ៣ យ៉ាងគឺ :

១ – សុតាមយប្បញ្ញា បញ្ញាកើតអំពីការស្តាប់ ។

២ – ចិន្តាមយប្បញ្ញា បញ្ញាកើតអំពីការគិត ។

៣ ភាវនាមយប្បញ្ញា បញ្ញាកើតអំពីការចំរើនភាវនា ឬការ
ធ្វើឲ្យច្បាស់ ។ តាំង ៣ នេះជាឧបាយធ្វើឲ្យកើតបញ្ញា ។

បុគ្គលអ្នកស្រឡាញ់សេចក្តីសុខ ចំរើន គួរអប់រំបញ្ញាឲ្យកើតឲ្យ
មានឡើងក្នុងសន្តាន ដើម្បីនឹងបំពេញប្រយោជន៍របស់ខ្លួនឲ្យបានគ្រប់
គ្រាន់ តាំងបច្ចុប្បន្ន តាំងបរលោក; គោលមកដោយសង្ខេបប៉ុណ្ណេះ
ហៅថាបញ្ញាពលៈ ។ ចប់តាលកថា

ឃុនបណ្ណាគុរ៌ក្ស ប៊ូ-ប៊ូ ទៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

រឿងនេះ ព្រះបរមសាស្តាទ្រង់ទេសនាក្នុងវត្តជេតពន ជ្រាបនឹងព្រាហ្មណ៍អ្នកប្រតិត្តល្អម្នាក់ របស់តែកូលគហបតីនៅនគរសាវត្ថី ។ ព្រាហ្មណ៍នោះ មានចិត្តសទ្ធាជ្រះថ្លាក្នុងសច្ចធម៌ បានចូលមកទុបសម្ប័ទជាតិក្តី ជាអ្នកព្យាយាមធ្វើសមណកិច្ចគ្រប់ប្រការ ជ្រាបថាកញ្ញាគហានិន្នាក្នុងការប្រតិបត្តិអាចារ្យទាំងឡាយ ដោយទំយកចិត្តទុកជាក់ក្នុងការចាត់ចែងអាហារនឹងការដេរឹតប្រើជ្រាបទឹកធាន់ ទុស្សាហ៍ជ្រាបសំអាតកុដិសាលាកន្លែងស្រង់ទឹកនឹងទីផ្សេងៗ, ខ្វល់ខ្វាយក្នុងការប្រតិបត្តិធម៌វិន័យជាតួចាំងតួង លោកចូលចិត្តជ្រាបសំអាតភេងទុជ្រាបថ កុដិលានសីមា ទឹងផ្លូវដើរទៅកាន់ភេងទុជ្រាបថ ចាំងឲ្យទឹកដល់មនុស្សអ្នកស្រេកធឹកផងខ្លះ ។ ព្រោះសេចក្តីល្អដ៏ធំក្រៃលែងរបស់លោកនេះឯង បានជាពួកមហាជនប្រគេនចង្ហាន់ដល់លោកក្នុង ១ ថ្ងៃច្រើនរយថាសជានិច្ច, លាភសក្ការៈដ៏ថ្លៃថ្លានឹកត្តិគុណក៏កើតឡើងដល់វត្តអារាម, សេចក្តីរុងរឿងចាំងឡាយក៏កើតមានឡើងដោយសារកិក្ខុ ១ រូបនេះឯង ។

ថ្ងៃមួយ កុងធម្មសភា កិក្ខុទាំងឡាយអង្គុយជំនុំគ្នាពណ៌នាគុណសេចក្តីល្អរបស់តិក្ខុនោះ ដែលជាអ្នកបានមកនូវលាភសក្ការៈនឹង

កិត្តិគុណ, ត្រមាំងភ្នាំងដ៏វិតរបស់មនុស្សជាច្រើនឲ្យរស់នៅដោយសេចក្តីសប្បាយរីករាយ ។ សម្តេចព្រះបរមសាស្តាស្តេចចូលមកកាន់ធម្មសភាហើយទ្រង់ត្រាស់សួរ, កាលកិកុខាំងនោះ ចាន់ក្រាបទូលរឿងដែលចាន់សន្ទនាគ្នាហើយ, ព្រះអង្គក៏មានព្រះពុទ្ធដីកាថា ៖

ម្នាលកិកុខាំងឡាយ ! កិកុនេះចាន់ជាអកសង្ឃាតនុហាតកាន់ការប្រតិបត្តិកាន់នាទីរបស់ខ្លួនដោយពេញលេញ, មិនមែនតែកាន់កាលឥឡូវនេះទេ សូម្បីកាន់អតីតកាល ឫសី ៥០០ រូបចំញាំមដ៏វិតរស់នៅចាន ដោយសារតែផ្លែឈើផ្សេង ៗ ដែលកើតអំពីគុណតំសេចក្តីល្អរបស់កិកុនេះដែរ ។

កាលត្រាស់ដូច្នះហើយ ក៏ទ្រង់ទេសនារឿងកាន់អតីតកាលតទៅថា ៖

ត្រាមួយ កាលព្រះចាន់ត្រហ្មទត្តសោយរាជ្យកាន់ក្រុងពារាណសី, ព្រះពោធិសត្វសោយព្រះជាតិជាព្រាហ្មណ៍ នៅខាងផ្លូវទក្ខិណទិស លុះចំរើនវ័យធំឡើង ទ្រង់លះលោកិយវិស័យចេញបព្វជ្ជា ចាន់ជាប្រធានរបស់ពួកឫសី ៥០០ រូប សំណាក់ក្រសែយនៅត្រង់ដើងភ្នំ ។ ត្រានោះ ទឹកកាន់ជ្រោះភ្នំហិមាល័យប្រទេសវែងសូតអស់ ទឹកកាន់ស្ទឹងត្រពាំង បឹងបួរ អូរត្រពាំងតូចក៏វែងហូតរហស់ដែរ សត្វត្រពាំងឡាយក៏កើតសេចក្តីក្តៅក្រហាយដោយសារស្រេកទឹក ។ តាបសចាន់យើញសត្វពាំងនោះមានទុក្ខវេទនាដោយសេចក្តីស្រេកទឹកដូច្នោះ ឫសី ១ អង្គកាន់ចំនួននោះចាន់កាប់រំលំឈើ ១ ដើម ហើយចោះលុងធ្វើជាស្មកវែង រួចទៅដងទឹកដែល

លោកអាចស្វែងរកបាន យកមកដាក់កង្វក់ក្នុងបម្រុងឲ្យហូរដល់សត្វ
ទាំងនោះផឹក ។ ពួកសត្វនាំគ្នាមកផឹកទឹកនោះទាំងហូរៗចេះតែផឹកគ្មានឈប់
ឈរ តាល់តែតាបសអស់ទុក្ខាសនឹងចេញទៅស្វែងរកបន្លែផ្លែឈើយកមក
ផាន់ខ្លួនឯង ។ លោកមិនអើពើនឹងសេចក្តីស្រែកឃ្វានរបស់លោក។ គិត
តែពីខំដងទឹកយកមកចាក់កង្វក់ក្នុកឲ្យហូរដល់សត្វផឹក ឲ្យវាបាត់ស្រេក ។

ពួកសត្វទាំងនោះបានដំនុំគិតគ្នាថា "យើងនឹងតបស្នងសងគុណ
តាបសនេះ ព្រោះថាការដែលលោកបំពេញកិច្ចតាមសេចក្តីត្រូវការរបស់
យើងពាល់គ្នានោះ តាល់តែលោកគ្មានទុក្ខាសចេញទៅរកបន្លែផ្លែឈើយក
មកផាន់ខ្លួនឯង លោកមានសេចក្តីស្រែកឃ្វានជាខ្លាំង យើងពាល់គ្នាគួរតែ
ព្រមព្រៀងគ្នាចុះខសន្យាថា អ្នកណាមកផឹកទឹកកង្វក់នេះ អ្នកនោះត្រូវ
យកផ្លែឈើបៃបណាមួយមកប្រគេនឫសីនេះ" ។

ពួកសត្វទាំងអស់ក៏ព្រមព្រៀងគ្នាធ្វើតាមខសន្យានោះ សត្វគ្រប់
រូបដែលមកផឹកទឹក បានន្លាយកផ្លែស្វាយនឹងផ្លែឈើនានាមកប្រគេនឫសី
តាល់តែផ្លែឈើទាំងនោះសម្បូណ៌ពោរពាស បើផ្គុតរះទះបាន ២. ៥០០
រះទះ, ពួកឫសីទាំង ៥០០ រូបបានឆ្អែតគ្រប់គ្នា ហើយទៅសេសសល់ជា
ច្រើនទៀត ។

ដោយហេតុមានផ្លែឈើសម្បូណ៌ហូរហៀរដូច្នោះ ព្រះពោធិសត្វ
ប្រកាសថា "គុណគឺសេចក្តីល្អរបស់បុគ្គលតែម្នាក់ប៉ុណ្ណោះ អាចបណ្តាល

ឲ្យតើតមានពាហារសប្រមាប់តួតគណៈបរិភោគឆ្អែតគ្រប់គ្នាបាន, តាមពិត
យើងតាំងឡាយគួរតែតាំងសេចក្តីព្យាយាមឲ្យខ្ជាប់ខ្ជួន ក្នុងការបំពេញ
សេចក្តីល្អនេះ" ។ កាលព្រះគោតមសាស្តាត្រាស់ដូច្នេះរួចហើយ ក៏
បញ្ចេញគាថាថា ដូច

អ្នកតាំងឡាយចូរខំប្រឹងព្រៃឈើ ស្មៅស្មៅ ប្រយោជន៍សាធារណា
កុំឲ្យទម្រន់ហួសមាត្រា កុំយកសុខាតែខ្លួនមួយ ។
មនុស្សម្នាក់ធ្វើគុណគាប់ប្រៃ អាចជួយអ្នកដទៃឲ្យផុតព្រួយ
:បើអាត្រកត់តែម្នាក់នាំរត្មួយ ដល់ពួកជាមួយរាប់រយពាន់ ។

ពាក្យនេះជាឧទាន របស់ព្រះមហាសត្វ ទូន្មានដល់ពួកឫសីតាំងឡាយ ។
កាលព្រះបរមសាស្តាទេសនាចប់ហើយ ទ្រង់សំដែងអតីតជាតិថា កិក្ខុ
នេះ គឺឫសីអ្នកមានគុណធ្លើអំពើល្អក្នុងគ្រានោះ, ឯតថាគតគឺឫសីជា
ប្រធាននៃឫសីតាំងឡាយ ។

អម្ពជាតក ចប់

វីរិយេន ទុក្ខមច្ចេតិ
គេកន្ទដ៏ផុតទុក្ខដោយព្យាយាម

ពិធីដួងដំណើរសម្តេចសង្ឃនាយក

ដែលនិមន្តទៅលង្ការទ្វីប

ដោយ

ព្រះគ្រូសិរីសោភ័ណ កិម – ពួ

ក្រុមដំទុំព្រះវិនៃបិដកនៅពុទ្ធសាសនបណ្ឌិត្យរៀបរៀង

ពិធីដួងដំណើរសម្តេចព្រះមហាសុមេធាធិបតី ដួង-ណាត សង្ឃនាយក គណៈមហានិកាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាគណៈប្រតិភូកម្ពុជរដ្ឋ និមន្តទៅធ្វើសន្និសិទនៅលង្កាទ្វីប ពីកន្លែងខែឧសភា ឆ្នាំ ១៩៥០ ដូចមានសេចក្តីភាយការតទៅនេះ ៖

វិធីប្រសិទ្ធពរប្រគេនសម្តេប

កាលពីថ្ងៃទី ១៩ ឧសភា ១៩៥០ វេលាម៉ោង ១៩ ពួកពុទ្ធបរិសទ្យគាំងបពួជិតគាំងគ្រហស្ថជាច្រើន មានព្រះតេជព្រះគុណព្រះពោធិវង្សជាប្រធាន បានទិមន្តនិងអញ្ជើញមកប្រជុំគ្នា ក្នុងវិហារវត្តឧណ្ណាលោម រៀបគាំងគ្រឿងសក្ការបូជានឹងប្រទីបជ្វាលា ដើរជាសក្ខីព្រោងព្រាតថ្វាយព្រះរត្នត្រ័យ គួរឲ្យជាទីពិតពិលរមិលមើលជាយ៉ាង

ក្រៃលែង ។ ក្នុងពិធីនោះ ព្រះសង្ឃដែលមានឋានន្តរស័ក្តិធំជាងគេ នឹងឋានានុក្រមជាច្រើនអង្គ ឋានមន្តមកគង់លើអាសនៈដ៏វិចិត្រដែលគេតាក់តែងយ៉ាងស្អាតឋាតដើម្បីចំរើនព្រះបរិត្ត រួចហើយនិមន្តសម្តេចព្រះមហាសុមេធាធិបតី មកគង់លើអាសនៈពិសេសមួយដែលគេរៀបចំទុកប្រគេនជាមុន និមន្តព្រះគ្រូសង្ឃសត្ត ប៊ុណ្ណ-សុម្ភាជ អញ្ជើញទុកជាសក ២ រូបទៀតគឺ ថៅកែ បេ-យាន នឹងលោកតាន់-ជូហេង ដែលជាអ្នកតាមអមជូនដំណើរសម្តេចរហូតទៅលង្កាទ្វីបដែរនោះ មកគង់នឹងអង្គុយលើអាសនៈជាលំដាប់ដោយឡែកចំពោះមុខព្រះសង្ឃ ។ លុះព្រះសង្ឃចំរើនព្រះបរិត្តប្រសិទ្ធីពរចប់ហើយ ព្រះតេជព្រះគុណព្រះញាណវង្ស ពៅ-នេត ជាតំណាងព្រះសង្ឃក្នុងពេលនោះ ឋានបញ្ចេញវាចាបួងសួងប្រសិទ្ធីពរជោគជ័យសិរីមង្គលគ្រប់ប្រការ ប្រគេនចំពោះសម្តេច នឹងព្រះគ្រូ ប៊ុណ្ណ-សុម្ភាជ នឹងថៅកែ បេ-យាន, លោក តាន់-ជូហេង ។

លំដាប់នោះ សម្តេចព្រះមហាសុមេធាធិបតីលើកព្រះហស្តប្រណម្យទទួលពរដោយសោមនស្សជាគំរប់ភាព ។

ចំណែកខាងក្រុមឧបាសកឧបាសិកា មានព្រះតេជព្រះគុណអគ្គឥតរដ្ឋមន្ត្រី ស៊ុំ-ហាំង ជាដើម ដែលអង្គុយតឿបត្រានៅទីនោះដែរ ឋានបញ្ចេញវាចាប្រគេនពរសិរីសួស្តីឧត្តមាធុភាពចំពោះសម្តេចតែរៀងខ្លួន ។ ។

ពិធីជួនដំណើរសម្តេចសង្ឃនាយក ទៅទ្បើងយន្តហោះទៅពោធិ៍បិតតុង

ថ្ងៃទី ២០ ខែសីហា ១៩៥០ វេលាព្រឹកម៉ោង ៨ ឃើញមានរថយន្តធំតូចឈប់ដេរជាសន្តែបគ្នានៅតាមវិថីអូហ៊ីយេរពីខាងលិចវត្តនឹងតាមវិថីអែមក្រែងពីខាងជើងវត្ត នឹងតាមវិថីព្រះពជ្រាំងពីខាងមុខវត្តនឹងផ្លូវមួយខាងកើតវត្តខ្មែរលោម ។ រថយន្តនីមួយ ។ ឃើញច្រើនតែពួកព្រះសង្ឃទីជារាជគណៈធំ ។ មានសម្តេចព្រះធម្មលិខិតទីខេត្តមប្រីក្សានឹងព្រះតេជព្រះគុណព្រះពោធិវង្សជាដើម ព្រះសង្ឃទីជាហ៊ានុក្រមនឹងព្រះសង្ឃជាសិស្សសាលាចុលីជាន់ខ្ពស់ សាលាចុលីរងដែលនៅវត្តខ្មែរលោមខ្លះ ដែលចេញមកពីវត្តផ្សេង ។ ក្នុងទីក្រុងខ្លះ ព្រមទាំងពួកគ្រហស្ថមកត្រៀមរង់ចាំជួនដំណើរសម្តេចតែសព្វ ។ ខ្លួន ។

ដំណើរនេះ គួរឲ្យស្ងើចណាស់, ពួកព្រះសង្ឃក្តី ពួកគ្រហស្ថក្តី ដែលជិះរថយន្តមកត្រៀមចាំជួនដំណើរទាំងប៉ុន្មាននោះ ឥតមានលោកណា ឬ អ្នកណាដើរយោសនាបបួលដឹកនាំឲ្យធ្វើដូច្នេះឡើយ ស្រាប់តែបណ្តាលទឹកចិត្តទាំងព្រះសង្ឃទាំងគ្រហស្ថឲ្យមានសាមគ្គីរួមដំណើរស្រេបជាមួយគ្នាតែម្តង ។ លុះដល់ម៉ោង ៨ ទឹង ២០ នាទី មានរថយន្តចំនួនជា ៥០ ទាំងធំទាំងតូច បើករត់ចេញបន្តជង្វែគ្នាពីខាងមុខនៃរថយន្តសម្តេចព្រះមហាសុមេធាធិបតី តាមថ្នល់តីរវិថី (កេស៊ីសុវត្ថិ) លឿន

តម្រង់ទៅទិសខាងជើង, មានរថយន្តមួយក្រុមទៀតចំនួន ៣០ ដែរ បើកចេញដង្ហែបន្តគ្នាពីខាងក្រោយ នៃរថយន្តសម្តេចព្រះមហាសុមេធាធិបតី លុះដល់ទៅវិថីអង់ដួង, ក៏បត់តម្រង់ទៅទិសខាងលិចសំដៅទៅពោធិ៍ចិនតុង, ស្ទាប់តែឃើញមានរថយន្តតូចៗ គឺជារថយន្តនៃពួកបព្វជិតខ្លះ ពួកគ្រហស្ថខ្លះ បើកបរចូលទៅដង្ហែរអមជូនដំណើរ ពីខាងមុខនឹងពីខាងក្រោយនៃរថយន្តសម្តេចព្រះមហាសុមេធាធិបតីថែមទៀត ។

កងពេលនោះ រថយន្តដែលបើកបន្តគ្នាតាមថ្នល់ មានចំនួនកាន់តែច្រើនឡើងចំនួន ១០០ រថយន្ត ក្រឡេកមើលទៅរថយន្តខាងមុខនឹងរថយន្តខាងក្រោយ ឃើញគ្មាយរលឹមពីគ្នា ប្រហែលជា ១ គីឡូម៉ែត្រ ។ ចំណែកខាងពួកមហាជនប្រុសស្រី ដែលដើរទៅមកតាមចិញ្ចើមថ្នល់ គាំងសងខាង ក៏បញ្ឈប់ដំណើរនៅគ្មាឈរមើលស្ទក្ខឹងកាំងគ្រប់គ្នា ។

ក្បួនរថយន្តដែលដង្ហែនោះ លុះដល់ទៅពោធិ៍ចិនតុងហើយ ក៏បត់ចូលទៅចតឈប់នៅត្រង់លានវាលមួយ, ទីលាននោះឯងក៏បង្អែតគាន់តាប់ទៅដោយរថយន្តធំតូច, ពួកព្រះសង្ឃគាំងអស់ចុះពីរថយន្តរៀងខ្លួនទៅនោះចំនួន ១.០០០ អង្គ ហើយគេនិមន្តឲ្យទៅឈរធ្វើចាំជូនដំណើរនៅត្រង់លានវាលស្មៅមួយចំពីខាងមុខយន្តហោះឈប់, ឯពួកគ្រហស្ថចំនួនជា ២០០ រូប ក៏នាំគ្នាទៅឈប់រង់ចាំជូនដំណើរនៅត្រង់លានវាលមួយ ដោយឡែកអំពីពួកព្រះសង្ឃ ។

លុះដល់ម៉ោង ៩ ព្រះករុណាជាម្ចាស់ដ៏វិតលើត្បូង, សម្តេចព្រះបរមកជបិតា នឹងសម្តេចព្រះរាជជននីនាថ ព្រមទាំងគណៈរដ្ឋមន្ត្រីទ្រង់យាង នឹងអញ្ជើញទៅដល់ចំណតយន្តហោះនៅពោធិចិនតុងដែរ ដើម្បីដួនដំណើរជាព្រះកិត្តិយសចំពោះសម្តេចព្រះមហាសុមេធាធិបតី ។

លុះដល់ម៉ោង ៩ នឹង ២០ នាទី មុននឹងឡើងយន្តហោះ សម្តេចព្រះមហាសុមេធាធិបតី, ព្រះគ្រូសង្ឃសត្តា ប៊ុណ្ណ សុម្ពាជ, ថៅវ៉ែ យេ-យាន នឹងលោក តាន់-ជូហង់ និមន្តនឹងអញ្ជើញទៅចំពោះមុខព្រះសង្ឃចំនួន ១.០០០ អង្គនោះ ហើយសម្តេចមានព្រះពុទ្ធដីកាថា : ខ្ញុំករុណាអាត្មាភាពសុំលាហើយ! សូមឲ្យព្រះសង្ឃគ្រប់អង្គនឹងទ្រង់អស់លោកនៅជាសុខសប្បាយចុះ! ។ ពួកព្រះសង្ឃនឹងឧបាសកឧបាសិកាទទួលពរអំពីសម្តេចវិញថា សាធុត្រមគ្គា ។

ខណៈនោះ សម្តេចព្រះមហាសុមេធាធិបតី កំពុងវែបព្រះកំភ្លឹកនិមន្តសំដៅទៅឡើងយន្តហោះ ឯពួកព្រះសង្ឃក៏ចាប់សូត្រ ជយន្តោ . . . ប្រសិទ្ធីពរប្រគេនសម្តេចព្រះមហាសុមេធាធិបតី ។ ក្នុងខណៈនោះមានឥស្សរជនជាន់ខ្ពស់ គឺព្រះករុណាជាម្ចាស់ដ៏វិតលើត្បូង, សម្តេចព្រះបរមរាជបិតា, សម្តេចព្រះបរមកជជននីនាថ, សម្តេចព្រះធម្មលិខិតទីឧត្តមប្រឹក្សា. នឹងព្រះតេជព្រះគុណព្រះពោធិវង្សជាដើម ទ្រង់ស្តេចយាងនិមន្តដួនដំណើរទៅដល់ឡើងយន្តហោះ ។

លុះដល់ម៉ោង ៩ ទីង ៣០ នាទី គ្រឿងចក្រយន្តហោះ ក៏ដើរលឿនឡាន់ឮសូរគ្រហឹងអឺងអាប់ ហើយក៏ស្ទុះលឿនស្ទៅទៅទិសទក្សិណ, កាលហោះអណ្តែតផុតពីផែនដីឡើងហើយ ក៏បែរមុខសំដៅទៅក្រុងវៃពនគរ ។ ពួកព្រះសង្ឃទីងពួកគ្រហស្ថ ឈរសំឡឹងមើលយន្តហោះ ដែលសម្តេចព្រះមហាសុមេធាធិបតីគង់នោះ ជាបដល់ផុតគន្លងចក្ខុលែងមើលឃើញ ទើបនាំគ្នាឡើងជិះរថយន្តវិលត្រឡប់មកកាន់លំនៅវឿង ខ្ជូនវិញហោង ។

ព្រះគ្រូសិរីសោភ័ណ

តាម - ភ្លូ

សុភាសិត

ចំណេះវិជ្ជា ទីង សេចក្តីប្រព្រឹត្តិ ទាំង ២ នេះ
រមែងប្រាឯមនុស្សឲ្យឡើងទៅកាន់ស័ក្តិយស
ជាន់ខ្ពស់បាន ដូចជាភ្នំដ៏ធំខ្ពស់ ។

របស់ក្រសួងធម្មការ

(ពេញ)

សញ្ញាប័ត្រលេខ ៦៧០ ចុះថ្ងៃអង្គារ ៣ កើតខែអាសាធឆ្នាំឆ្លូវឯក-សក័ ព. ស. ២៤៩២ តាំងលោកគ្រូ ថោង - ខិត នាមធាយា វិនយត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨, ជាគ្រូសូត្រស្ដាំវត្តក្បាលដំរី ឃុំស្លែក ស្រុកដីក្រែង ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ - ពេជ្រ នាមធាយា ញាណត្ថេរ កើតឆ្នាំឆ្លូវអាយុ ២៥ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ នង - ទេព នាមធាយា ព្រហ្មសិរី កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៥ ជាចៅអធិការវត្តព្រហូត ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថន - ធួក នាមធាយា ធម្មជោត កើតឆ្នាំរកា អាយុ ២៩ វស្សា ៦ ជាគ្រូសូត្រស្ដាំ វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ - យ៉ង់ នាមធាយា ធម្មកេសរ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២១ ជាចៅអធិការវត្តគ្នាតកាង ឃុំព្រះធាតុស្រុកកំពង់ត្រែបែក ខែត្រកែវវែង ។

សញ្ញាប័ត្រលេខ ៦៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តំ - តាំ នាមធាយ៉ា សិរីវណ្ណា កើតឆ្នាំមមែ អាយុ ៣១ វស្សា ៦ ជា គ្រូសូត្រធ្លេង វត្តឃុំកំពង់ក្ងុក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លាក់ - ប៊ីរ នាមធាយ៉ា ធម្មកេសរ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៧ ជាចៅអធិការវត្តត្រពាំងគ្រួស ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រ លេខ ៦៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ីក - អុក នាមធាយ៉ា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការវត្តក្តីកណ្តាល ឃុំកែវត្រែ ស្រុកស្វាយចាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស - ឥន្ទ នាមធាយ៉ា ពុទ្ធបញ្ញោ កើតឆ្នាំជូត អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ១៣៨ ចុះថ្ងៃសុក្រ ៦ កើតខែអាសាឍឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៨២ តាំងលោកគ្រូ មាឃ - ស៊ីម នាមធាយ៉ា សុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៣៦ វស្សា ១១ ជាចៅអធិការវត្តដំរីស ឃុំចៀប ស្រុកទឹកផុះ ខេត្តកំពង់ឆ្នាំង ។

(មានត)

ពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងជាថ្មីដល់ពុទ្ធបរិស័ទ
ជ្រាបថា ។ ដោយហេតុបោះពុម្ពព្រះត្រៃបិដកខ្សែឆ្នាំងនោះដូចយើងបាន
រៀបរាប់បោះជាសៀវភៅចែកផ្សាយ កាលពីថ្ងៃទី ៤ ខែកក្កដា ១៩៩០
គឺ ១) ចាប់បោះសារឡើងវិញតាំងពីសៀវភៅលេខ ១-២ រហូតទៅដល់
សៀវភៅលេខ ៣៩; ២) បោះបន្តពីសៀវភៅលេខ ៣៦-៣៧ រហូតដល់ចប់ ។

ឥឡូវនេះ ការបោះពុម្ពនោះ មានដំណើរការទៅមុខរួចស្រេច
ណាស់ហើយ ជាពិសេសពុទ្ធបរិស័ទខ្មែរកំពុងមានទៅចុះឈ្មោះជាវ
ជាបន្តបន្ទាប់គ្នាជារៀងរាល់ថ្ងៃ មានចំនួនច្រើនណាស់ដែរហើយ ដែលមិន
ទាន់អស់ ។

ហេតុនេះ ប្រសិនជាយើងទិញស្មានត្រឹមតែនៅមានអស់លោក-អ្នក
ដែលបានជាវហើយមិនទាន់ចុះឈ្មោះជាវនោះ សូមមេត្តាទៅចុះឈ្មោះ
ជាវ នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យជោយរួសរាន់ ពេលក្នុងពេលនេះ
នេះ ដើម្បីយើងអាចនឹងកំណត់ចំនួនសៀវភៅបោះពុម្ពជាមុន ហើយលៃ
លកមាណឲ្យបានត្រឹមត្រូវតាមចំនួនឈ្មោះដែលចុះជាវ កុំឲ្យមានខ្វះខាត
ដល់អស់លោក-អ្នកឯណាដែលប្រាថ្នាចង់ជាវសៀវភៅនោះ ព្រោះ
យើងនឹងកំណត់ចំនួនសៀវភៅនោះឲ្យច្រើនខុសប្លែកពីមុនមិនកើត ។

ពុទ្ធសាសនបណ្ឌិត្យ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀម អក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ៖ លោក ភ័ក្ត្រ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា៖ ព្រះទេពសត្ថា ស្រួ - ហាយ
ក្រុមដំទុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម	ព្រះរាជក្រឹត្យ ក្រមទេសការិយា (តមក)	៦៤១
លោក ផេង-ដ្រើ សាស្ត្រាចារ្យ	បក្សីទិព្យ រឿងព្រៃងប្រៃទេសអ៊ីម៉ាឌ (ត-ចប់) ..	៦៤៨
លោក ម៉ិញ - ឥន្ទ្រី	ស័ព្ទបាភាំងប្រែជាខ្មែរ (តមក)	៦៥៧
លោកសាង - សាភ័ត លេខាធិការ	រឿងព្រៃងភូមា (តមក).....	៦៦១
អ្នកឧកញ៉ាវិបុលរាជសេនា ភូ - កន	រឿងសាមកុក (តមក)	៦៦៧
— ទេពពិទូរ ឈឹម - ក្រសេម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).....	៦៧៧
អ្នកអង្គម្ចាស់ស្បថ្រ្តី ន. សុភានារី	សារៈគ្មានវត្តមដ្ឋានសិ	៦៩៥
លោកផែង-ដ្រើ	ប្រវត្តិរបស់អេសុប	៦៩០

ផ្នែកសាសនា		
អ្នកឧកញ៉ាទេពពិទូរ ឈឹមក្រសេម	ប្រវត្តិព្រះកែវមរកត	៦៩៦
ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម	ប្រវត្តិព្រះអនុរុទ្ធស្ថេរ	៧១២
សាមណេរ គក - គីឡេង	រឿងនាងបជាបាវ	៧១៧
លោក អ៊ុម - តយ សាស្ត្រាចារ្យ	ប្រវត្តិព្រាហ្មណ៍ចាស់.....	៧១២

កំណត់ទិដ្ឋប្រវត្តិការណ៍		
ក្រសួងធម្មការ	បញ្ជីឈ្មោះតាមបៅអធិការដែលតាំងថ្មី (តមក)...	៧១៩

ឆ្នាំទី ២២ — លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៤១ — ជំរៀងជាវ ១ ឆ្នាំ ១៤៥ រៀល -។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

page

Luong Nibandhamaatri Nhok-Thèm
M. Pheng-Chrieu, Professeur au Collège des jeunes filles — Edit royal : Kramadasabhariyâ (suite). 641

M. Menh-Nakry — l'Oiseau du Paradis (Conte roumain) (suite et fin) 648

M. Sang-Savath, Secrétaire au Ministère des Finances — Recueil des mots traduits par la commission Culturelle (suite) 657

Neak Oknha Vibularaja-séna Nou-Kân — Contes birmans (suite) 661

Neak Oknha Debabidura Chhim-Krasem — Histoire de SAMKOK (suite) 667

Contesse Norodom Sukhanari, secrétaire de la Commission des Mœurs et Coutumes — Histoire du Royaume du Cambodge (suite) 677

M. Pheng Chrieu, professeur au Collège des Jeunes Filles — Notice historique de Vat Attharasa 685

Partie religieuse :

Neak oknha Debabidura Chhim-Krasem — Biographie d'Esope 690

Luong Nibandhamantri Nhok-Them — Historique du Bouddha d'émeraude 696

Samanera Kok-Kileng — Biographie d'Anuruddhatthera 702

Oum-Koy professeur à l'Ecole supérieure de Pali — Histoire de Neang Patâcâra (poème) 707

Notes et Chroniques

Ministère des Cultes — Biographie du vieux Brahmana 712

Nomination des nouveaux Chau-

ECOLE FRANÇAISE
(BIBLIOTHÈQUE)
D'EXTRÊME ORIENT

ព្រះភទ្រកែត្ស

ក្រមទសភរិយា

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរាយណ៍ (ចៅពញាសូរ) គ. ស. ១៦៩៣

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តទៅ)

មាត្រា ១ សោត នោះអ្នកឯងទុកស្នេហ៍ [1] កូនក្រមុំឲ្យឆ្លួតកូនគេ បន្ទៃ [2] ក្តីយំស្រែកក្តី ឆ្លួតកូនក្រមុំគេក្តី នោះឲ្យពិន័យអានោះ ជាប្រាក់តម្លឹង ៣ ឲ្យហូតខ្លាត់ព្រះឃ្លាំងពុះគ្រឹង ។ បើពុំបានឆ្លួត-បន្ទៃ-យំស្រែកទេរ៉ើយ ឲ្យពិន័យតម្លឹង ១៥ ជាទ ២ ឲ្យហូតខ្លាត់ព្រះឃ្លាំងពុះគ្រឹង ដើងកោះខ្លាត់ដំនុំបានទៅចៅហ្វាយស្រុក ពុះគ្រឹងបានមកចៅពញា ជាខុនក្នាក់ជារ ឯខ្លាត់ខុនក្នាក់ជារឲ្យយកតម្លឹង ៣ ហោង ។

មាត្រា ១ សោត នោះបើអ្នកឯងទៅស្នង់អន្ទងនឹងកូនក្រមុំគេ បើពុំបានកូនក្តី បង្កើតបានកូន ១ ក្តី កូន ២ ក្តី កូន ៣ ក្តី រាលែងគ្នាវិញ នឹងចំតួរាងឯងក្តី មានអ្នកដទៃបង់ប្លន់បញ្ឆោះបង្អាប់ឲ្យលែងក្តី ទុកអានោះ (មេនោះ) ជារាយកអំណាចពាដ៏សក្តិព្រះបាទអ្នកជាអម្ចាស់ឲ្យប្រាណីយកក្រយាពិន័យ តម្លឹង ១៥ ដើងកោះស្លឹង ១០ ។ បើអាពុកម្តាយឯស្រីនូវ

---

១ ទុកស្នេហ៍ - គឺជាក់ស្នេហ៍ ។ ២ បន្ទៃ. គឺពោលពាក្យរើរាយ ។

ម្តាយអាពុកឯប្រុសនោះ ពុំស្រដីពុំប្រាប់ទុនញ្ជាក់ផារ ទុកញ៉ាសុករធិបតី នូវក្នាក់ផារស្រែកឲ្យបានដឹងដន់ឡើយ ឲ្យចាប់អាចោរនោះមកធ្វើគ្តី រកយើញជាមាជាម្តាយម៉ងជាបងជាប្អូន . . . បើមានខ្ញុំ មានគ្រប់ មានគោរខេះនូវសោរតើរបស់នោះឲ្យបែងបែកបានម្ចាស់របស់ភាគ ២ បានទុនក្នាក់ផារភាគ ១ ឯអាចោរមេចោរនោះ ឲ្យពិន័យតាមអំណាចព្រះហាទអ្នកជាអម្ចាស់នោះហោង[1] ។

មាត្រា ១ សោត ទោះបីអ្នកឯណានាំម្រត់កូនក្រមុំគេទៅហើយ ឯម្តាយអាពុកឯស្រីនោះឃើញដឹងហើយ ពុំស្រដីពុំប្រាប់កូនក្រមុំឯងឡើយ ឲ្យកូនក្រមុំឯងមានប្តីឯទៀតវិញ ឲ្យចាប់អាពុកម្តាយនោះ ជាបំពាំងព្រះរាជទ្រព្យ ឲ្យពិន័យម្តាយអាពុកស្រីនោះ ជាប្រាក់ដីន ៣ តម្លឹង ១៧ កុំសន្ទុះឡើយ ។ ឯអាប្រុសដែលកាន់ម្រត់នោះ ឲ្យពិន័យ

---

១ តាមដំណើរសេចក្តីនៃមាត្រានេះគឺងស្តាប់គឺងយល់បន្តិច ព្រោះគេបានរៀបរៀងសេចក្តីខុសទំនងគ្នាធ្វើឲ្យគឺងរបៀបសេចក្តីសម័យនេះ ។ បើតាមមតិរបស់អ្នករួបរួមព្រះរាជក្រឹត្យនេះមានសេចក្តីយល់ដូច្នេះ: អ្នកណាមួយទៅសហាយស្មន់គឺងកូនក្រមុំគេ មានកូនក្តី គ្មានកូនក្តី ហើយសុខចិត្តលែងគ្នាតែរៀងខ្លួនក្តី មានអ្នកជិតខែ ឬបងប្អូនបញ្ចេះឲ្យលែងគ្នាក្តី នោះត្រូវពិន័យចំពោះប្តីភរិយាដាច់ ១៤ តម្លឹង ធើងកោះ ១០ ស្លឹង ។ បើអាពុកម្តាយខាងប្រុសក្តី ខាងស្រីក្តីមិនបានប្តឹងឲ្យភ្លាក់ងារបានដឹងទេ នោះត្រូវចាប់អាប្រុសមកសួរបញ្ជាក់ បើរកទៅឃើញជាមានបងប្អូនបញ្ចេះមែន ត្រូវឲ្យអ្នកយកទ្រព្យសម្បត្តិរបស់អ្នកញុះញង់ចំបែកចំបាក់ប្តីប្រពន្ធគេនោះ ហើយបែងជា ៣ ភាគ គឺ ២ ភាគបានម្ចាស់ទ្រព្យ ១ ភាគបានទៅទុនក្នាក់ផារ ។ ឯអាមិប្តីប្រពន្ធនោះឲ្យពិន័យតាមអំណាចព្រះមហាក្សត្រ ។

តម្លឹង ១៥ ដង្រិតវាជាចោរលួច នាំម្រែត់កូនក្រមុំគេបង្ខាំចង់ខ្ញុសហើយបិទ
ចាំងឲ្យទៅនៅទឹងម្ដាយអាពុកវិញ ។ ក្ដីម្រែត់យកជាប្រពន្ធហើយ ពុំ
ច្បាប់ពុំស្រដីដោយច្បាប់ឡើយ . សឹងបានជាខ្វាត់ព្រះឃ្លាំងតម្លឹង ៦
បានខ្វាត់មកខុនភ្នាក់ងារតម្លឹង ៣ ហោង ។

មាត្រា ១ សោត ទោះខ្ញុំគេនឹងខ្ញុំគេវាជាអន្ធកវង្គ្រាជ ចានកូន
ប៉ុន្មានៗក្ដី ពុំចានកូនក្ដី បើវាលែងគ្នាវិញនោះ ឲ្យខុនភ្នាក់ងារយក
ខ្វាត់ចាន ៦ នូវដើងកោះចាន ៥ និមួយតួ ។ បើម្ចាស់ពុំចានច្បាប់
ភ្នាក់ងារស្រុក នូវខុនភ្នាក់ងារនោះ ទុកជាបំចាំងព្រះរាជទ្រព្យ ឲ្យ
ពិន័យតាមច្បាប់ហោង ។

មាត្រា ១ សោត ទោះអ្នកផងទៅស្នងអន្ធកវង្គ្រាជ ខ្ញុំគេមានកូន ១ ក្ដី
កូន ២ ក្ដី កូន ៣ ក្ដី បើលែងគ្នាវិញនោះ ឲ្យខុនភ្នាក់ងារ ហូតយក
ខ្វាត់ចាន ៦ មេស្រីខ្ញុំគេចាន ៣ ដើងកោះចាន ៥ និមួយតួ ។ បើប្រុស
ជាអន្ធកវង្គ្រាជ (ស្រី) ដែលខ្ញុំលែងនោះ ពុំចានច្បាប់ភ្នាក់ងារស្រុក នូវ
ខុនភ្នាក់ងារនោះ ទុកជាបំចាំងព្រះរាជទ្រព្យ ព្រះចាន អ្នកជាអម្ចាស់
ហោង ។ បើមានកូនប៉ុន្មានៗ ឲ្យចែកផ្នែកមេផ្នែកចា តាមច្បាប់
ហោង ។

មាត្រា ១ នូវអ្នកផងឯណា ពញា, ព្រះ, ហ្មឺន, ដី, ខេវឯណា
ផងចាំងពួង យកគ្នាជាប្ដីជាប្រពន្ធហើយអារពុំមានកូនឡើយ ស្លាប់ព័ក្ស័រ

នោះត្រូវមុខងារខុសញ៉ាំសុភាធិបតីយកទ្រព្យអាករជាដង្វាយព្រះចុងអ្នកជាអម្ចាស់ នោះមានទ្រព្យរបស់តិចជ្រើនប៉ុន្មាន ។ ក្តី មានកូនធម៌ មាម្តាយម៉ង់ បងប្អូនកូយ ចៅក្តី នោះត្រូវគិតរដីការឲ្យយកអស់ទ្រព្យរបស់ទាំងនោះមកកាត់ថ្លៃហើយបែងជាភាគ ៥ ភាគ ៣ បានជាដង្វាយ ភាគ ២ បានអ្នកវស់នៅហោង ។

មាត្រា ១ (សោត) នោះកូនធម៌ចាប់កូនក្រមុំគេទាំងអំណាចទាំងថ្លៃ (ក្តី) ឯពន្ធ្រលប់ក្តី ឲ្យពិន័យអាប្រុសនោះជាប្រាក់ជីង ១ តម្លឹង ៥ ដើងគោះបាទ ៥ ល្អាឃ្លោងបាទ ១ នោះឲ្យចៅពញាជាខុនក្នាក់ងារហូតយកខ្លាត់ព្រះយ៉ាងពុះគ្រឹង ខ្លាត់ខុនក្នាក់ងារតម្លឹង ៣ ហោង ។

មាត្រា ១ (សោត) នោះអ្នកជនាំការកូនក្រមុំគេក្តី ជាមេអណ្តើកប្រពន្ធគេក្តី ជាមេអណ្តើកខ្ញុំគេក្តី បើគេទៅ (ឃើញ) ប្រាកដឲ្យពិន័យមេនាំការជាប្រាក់តម្លឹង ១៥ ក័បាន តម្លឹង ៦ ក័បានដើងគោះស្មឹង ១០ និមួយគ្នា ។ លាងខ្លាសកូនក្រមុំគេ ខ្លួវអ្នកជាខ្លួវខ្ញុំគេជាប្រាក់បាទ ៦ ហោង ។

មាត្រា ១ (សោត) នោះបើអ្នកជនឲ្យទៅដណ្តឹងកូនក្រមុំគេនឹងយកជាប្រពន្ធកូនប្រុសឯង នោះបើកូនប្រុសនោះក្តី កូនស្រីនោះក្តី បើទៅពុំគង់នឹងសណ្តាប់ម្តាយអាពុកពុកជាក់ឡើយ ក៏ប្រែខ្វៃទៅយកប្រពន្ធឯទៀតដទៃក្តី ប្រពន្ធបើក៏ចេញទៅជាអន្ធករនឹងប្រុសឯទៀតក្តី នោះឲ្យ

ចៅពញាជាខុនក្នាក់ងារ ហូតយកខ្នាត់តម្លឹង ៦ ជាខ ១ ជាខ្នាត់ព្រះឃ្លាំង នូវដើងកោះស្លឹង ១០ និមួយតួ ខ្នាត់ខុនក្នាក់ងារតម្លឹង ៣ ហោង ។

មាត្រា ១ (សោត) ខោះបើចាប់កូនក្រមុំគេក្តី ម្រត់ទាំងអំណាចទាំងថ្លៃ (ក្តី) ឯពន់ព្រលប់ក្តី ឲ្យពិន័យជាប្រាក់តម្លឹង ៣០ និមួយតួ ហោង ។ បើស្រីនឹងប្រុសនោះរាត្បើយថាជាសង្សារនឹងគ្នារាហើយរាត្បើយប្រាប់ចៅចៅក្រមថាជាសង្សារពាមែន ។ បើម្តាយអាពុកពុំរាប់ឡើយឲ្យពិន័យស្រីនឹងប្រុសជាប្រាក់តម្លឹង ៣០ និមួយតួ ឲ្យប្រាណីទឹកដោះមេស្រីតម្លឹង ៥ ហោង ឲ្យយកខ្នាត់ព្រះឃ្លាំងពុះគ្រឹងថ្នាត់ថ្នាយហោង ។

មាត្រា ១ (សោត) ខោះប៉ិអ្នកផងចៅសម្ងាប់កូនក្រមុំគេក្តី ប្រពន្ធគេក្តី (យកទ្រព្យរបស់) នោះប្តី (ឬអាពុក) សម្ងាប់វិញបានហោង ។ បើរាត្បើយមកឯកូនក្រមុំជាសង្សារនឹងគ្នារាវ បើកូនក្រមុំនោះថាពុំបានជាសង្សារនឹងប្រុសនោះ បើប្រាកដនោះ ព្រះក្រឹត្យដីកាថាទុកជាចោរដែលចាប់បានមក គ្រាពាក្យដោយតួទីមែ ហើយយកពាក្យចោរដើមក្តី មើលមុនហើយ ទើបឲ្យយកពាក្យចុងក្តីមើលក្រោយ ទើបឲ្យចៅក្រមដំនុំពិចារណាបើចោរដើមក្តីឈ្នះ ទុកចោរចុងក្តីជាប្រាក់យរបស់ទ្រព្យឲ្យគេ ឲ្យពិន័យ ១ ជា ៣ ។ បើចោរចុងក្តីឈ្នះ ទុកជាចោរដើមក្តីប្រលោមរបស់គេ ប្រលោមរៃហ្លួង ឲ្យពិន័យ ១ ជា ២ ហោង ។ បើសេចក្តីរើនងឹងគ្នា បើមានបន្ទាល់ឲ្យដណ្តើងបន្ទាល់ បើផ្តួបបន្ទាល់ឲ្យ

ប្រកាន់ចាប់ផ្នោត (បើ) ចោរដើមក្តី ឈ្នះបីដង ឲ្យពិន័យចោរចុងក្តី ១ ជា ៣ ។ បើចោរចុងក្តីឃុនគូឈ្នះដែរ . . . ស្រីដទៃហើយវាយកអន្តករ នោះជាប្តីប្រពន្ធ ឲ្យសងតែព្យាបស្ថដែលផឹកស៊ីនោះឯង ១ ជា ៣ ហោង ។ ឲ្យខុនក្នាក់ជារយកខ្វាត់តម្លឹង ៣ ដើងកោះស្លឹង ១០ និមួយគួរហោង ។

មាត្រា ១ (សោត) បើអ្នកឯណាយកគ្នាជាប្តីប្រពន្ធហើយប្តីស្លាប់មុនហើយពុំបានលើកភ្នោចឡើយ ហើយទៅមានអន្តកក្តី បើមានគេទៅដណ្តឹងយកជាប្រពន្ធហើយក្តី ឯព្រះច្បាប់ទុកជាកន្ទុងខ្ចប់(១) ។ បើខុនក្នាក់ជារដឹងហើយ ឲ្យកាត់ក្រយាពិន័យជាប្រាក់ដឹង ៣ ពាន់ប្រសពាន់ស្រែនូវដើងកោះស្លឹង ១០ និមួយគួរ ហូតយកខ្វាត់ព្រះឃ្លាំងពុះគ្រឹងខ្វាត់ខុនក្នាក់ជារតម្លឹង ៦ ហោង ។

មាត្រា ១ (សោត) នរអ្នកផងជាក្តីនឹងគ្នា គោះបីជាខ្ញុំបំពេសជាជំពូក គោះថាគេចង្អាវប្រាក់ក្តី គោះថាគេដំពាក់សារពើអ្វីៗ ក្តី បើចៅមានខ្លួនដែលថាគេដំពាក់ប្រាកដ នោះថាពុំបានខ្លី ពុំបានចង្អាវ ពុំបានជាខ្ញុំបំពេស ពុំបានជាជំពូកឡើយ ឲ្យចៅដែលថាគេដំពាក់ គោះចុងក្តីឈ្នះចៅដើមក្តី ខូត ១ ឲ្យកាត់ថ្លៃបេស់នូវថ្លៃគួរចៅដើមក្តីដែលដំពាក់ នូវចៅចុងក្តីនោះមកបែងភាគ ៣ ភាគ ២ ឲ្យចោលចេញ ឲ្យយកភាគ ១ មកពិន័យចៅដើមក្តី គឺឲ្យទ្វេគុណទ្បើង ។ ១ សោត ចៅចុងក្តីបានខូត

---

១ តំកន្ទុងសពប្តី ព្រោះខ្លួនមិនទាន់យកភ្នោចប្តីទៅកប់ ឬឃុបជាតាមទំនៀម ។

ឈ្នះឯកទូតហើយ ចៅដើមក្តីបានគ្រឹទូតក្តីបានទូតឈ្នះឯកទូត គ្រឹទូតទោទូតហើយចៅដើមក្តី យកទោទូតនូវគ្រឹទូត ទុកជាស្មើគ្នា ឲ្យយកទូតទុកជាចុងក្តីឈ្នះចៅដើមក្តី ទូត ១ ឲ្យយកថ្លៃរបស់ ថ្លៃតួចៅដើមក្តីដែលជំពាក់នៅគេមកពិន័យចៅដើមក្តី ១ ជា ២ ។ បើចៅដើមក្តីបានទូតឈ្នះឯកទូតក្តី ហើយចៅចុងក្តីបានគ្រឹទូតក្តី បើចៅដើមក្តីបានទូតឈ្នះឯកទូតនូវគ្រឹទូតហើយ ចៅចុងក្តីបានទោទូតនូវគ្រឹទូតនោះទុកជាស្មើគ្នា ឲ្យយកឯកទូតចៅដើមក្តីឈ្នះចៅចុងក្តី ទូត ១ ឲ្យយកថ្លៃតួដែលជំពាក់នៅចៅចុងក្តី មក (បែង) ជាភាគ ៣ ភាគ ២. ឲ្យចោលចេញ ឲ្យយកភាគ ១ មកពិន័យចៅចុងក្តីជា ៤ ហោង[1] ។

បើចៅដើមក្តីបានទូតឈ្នះឯកទូត ចៅចុងក្តីបានទោទូតនូវគ្រឹទូត នោះឲ្យយកទោទូតឯកទូតនោះទុកជាស្មើគ្នា ឲ្យយកគ្រឹទូតទុកជាចៅទីពៃវែប ពាក្យប្រកាំងគ្នា នោះចៅដែលកំណត់គេថាជំពាក់នោះមកចាប់ឆ្នោតលាន ខ្វួនឆឹងចំណាំខ្មោច បើដែលកំណត់ចំណាំគេថាជំពាក់នោះ បានទូតចាញ់ពាំង ៣ ដង នោះឲ្យចៅជំពាក់បំណុលគេបេស់ទ្រព្យគេសងគេពេញហោង ។ បើដែលកំណត់ចំណាំគេថាជំពាក់បានទូតឈ្នះ ៣ ដង នោះឲ្យបង្អាត់ទូវដើងគោះឲ្យចៅត្រមហើយរួចចេញហោង ។ (មានត)

---

១ មាត្រាខោះមិនសមភប់ចញ្ចូលក្នុងក្រមទេសភរិយាទេ ព្រោះនិយាយតែអំពីការបង្គាប់ប្រាប់កាល នឹងការដំណាក់សារពើរបស់ទ្រព្យផ្សេងៗ ។

រឿងព្រៃងប្រៃទេសរូម៉ាំង

លោក ផេង - ជ្រៃ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ

ប្រែចាកភាសាចាវ៉ាំង

(ត-ចប់)

ព្រះពជាស្រែកឡើងថា : ឧ ! ឯងទេ ដែលអាចរកបានបក្សីទិព្វ ? ឯងហ្នឹងទេតើ ជាកូនទៅរបស់អញ ដែលអ្នកនគរស្មានថាជាស្លាប់ចាត់បង់ទៅហើយ ?

— បពិត្រព្រះវរពជបិតា គឺខ្ញុំព្រះបង្គំហ្នឹងហើយ !

ហើយទុនបុម្ពិតទូវព្រះហស្តនៃព្រះពជា រួចអង្វរសុំឲ្យហៅនាងក្រមុំដែលជាស្ត្រីចោសព្រះពជលាននោះចូលមក ។

កាលណានាងនោះមកដល់នៅចំពីមុខ ក៏ច្បាប់ថា : ហ្នឹងហើយគឺគួនាងស្រីក្រមុំដែលខ្ញុំព្រះបង្គំទើបនឹងនិយាយថ្វាយអម្បាញ់មិញ ។

ព្រះពជាត្រាស់សួរថា : ច្បាកដមែនឬ ? ចុះហេតុដូចម្តេចក៏នាងនេះបែជាស្រីចោសព្រះពជលានទៅវិញ ? ។

— ការណ៍ហ្នឹងជាការៈនៃនាងជាអ្នកថ្លែងរឿងថ្វាយ ព្រោះខ្ញុំព្រះបង្គំឥតបានដឹងឡើយ ។

រួចក៏បន្តរឿងខ្លួនក៏ទៅទៀតថា : ខ្ញុំព្រះបង្គំ លុះឆក់បានទុនដ៏សត្វហើយ ក៏បរសេះរបស់យកទុំបាយតែ ។ ប៉ុន្តែខណៈនោះ ពួកសេះឯទៀត

នាំគ្នាស្រែកកញ្ជ្រៀវ: ភ្លៀងស្រែកខ្ទាំងពេក ធ្វើឲ្យខ្ញុំព្រះបង្កំ ព្រឺក្បាលសំពោង តែខ្ញុំព្រះបង្កំឥតមានភ័ន្តភាំងស្មារតីអ្វីឡើយ ។ ឯពួកយក្សបានឮសំរែកសេះ ក៏នាំគ្នាដេញតាម: ភ្លាដេញប្រកិតៗ រហូតដល់ព្រំដែនសីមា គឺជាទីដែលសំឡាញ់នៃខ្ញុំព្រះបង្កំនៅរង់ចាំ, កន្លងពេលនោះបើគ្មានសំឡាញ់ខ្ញុំព្រះបង្កំឈប់ចាំនៅកន្លែងនោះទេ ខ្ញុំព្រះអង្គំទៀងតែធ្លាក់ក្នុងកណ្តាប់ដៃយក្សជាមិនខាន ។ ប៉ុន្តែវេលានោះ សំឡាញ់ខ្ញុំព្រះបង្កំលាតដៃចង្អុលទៅរកយក្សហើយស្រែកយ៉ាងខ្លាំងថា: "ឈប់!" ហើយពួកយក្សហាក់ដូចជាស្ងួន មិនអាចនឹងឈានដើរ សូម្បីតែមួយជំហានក៏មិនបាន ។ សំឡាញ់ខ្ញុំព្រះបង្កំសុះមកចាប់ទុបហើយត្រេកអរវិកវល់ ដោយឃើញសត្វបក្សីទាំង ។ កន្លងវេលានោះ យក្សបានសន្យាថានឹងឲ្យព្រះបន្ទូនឹងព្រះអាទិត្យក្តុំមាសនឹងកូនប្រាក់ ដល់ខ្ញុំព្រះបង្កំ សូមឲ្យតែខ្ញុំព្រះបង្កំបង្វិលបក្សីទាំងនឹងសេះឲ្យទៅវាំញ ។ លុះតមកដឹងច្បាស់ថា ឧបាយកលរបស់ខ្លួនមិនអាចធ្វើឲ្យខ្ញុំព្រះបង្កំកម្រើកបានទើបវានិយាយអង្វរថា: យ៉ាងម្តេចម្តា សូមអាណិតឲ្យតែសេះទៅវិញ ។ ខ្ញុំព្រះបង្កំឆ្លើយតបទៅវិញថា "ត្រង់សេះកុំឲ្យត្រួយ" ហើយខ្ញុំព្រះបង្កំក៏បង្វិលសេះឲ្យទៅវាំញ ។ រួចខ្ញុំព្រះបង្កំចេញមកជាមួយនឹងសំឡាញ់ព្រមទាំងបក្សីទាំងដែលពួកយក្សសំឡឹងសំឡក់ដោយក្តៅផ្សៃក។ ។

មកដល់ភ្នំយក្សទីមួយ នាងនារីឈរចាំយើងនៅមាត់ទ្វារ ។ នាងមាណវីគ្រាន់តែគ្រវីពាត់ច្បាប់។ បីដង ព្រះសាខយក្សក៏ញញួលូនគ្នា

នៅប៉ុន្តែពុត្រា ហើយនាងកាន់យកមកជាមួយ ។ ខ្ញុំព្រះបង្គំឆក់នាង ជាក់ឲ្យទំពីខាងក្រោយខ្នង ហើយបំផាយសេះតមកទៀត ។ លុះយក្ស ដឹងការណ៍ភ្លាមកាលណា វាន៎ាំគ្នាលើកកងពលដេញតាម ហាមាត់ ស្រែកសន្ធាប់ស្ទើរតែនឹងធ្វើឲ្យតក់ស្លុតស្ទុះទៅណាពុំបាន ។ ប៉ុន្តែយើងមិន ជាត់ស្មារតី ពេញដោយក្តីក្លាហាន ខ្ញុំព្រះបង្គំវាយសេះបំចោលជា មួយនឹងសំឡាញ់លឿនដូចជាខ្យល់ ។ ចំណែកពួកយក្សហោះដេញតាម រហ័សដូចចិត្តនឹក . . . ។ សំឡាញ់នៃខ្ញុំព្រះបង្គំដឹងខ្លួនថាយើងមើល ទៅស្ទុះពីដៃយក្សមិនរួចទេ ក៏ឈប់ហើយលើកដៃចង្អុលចំពោះយក្ស ធ្វើឲ្យវាក្លាយខ្លួនទៅជាដុំថ្មគាំងអស់ ។ រួចយើងធ្វើដំណើរតមកទៀត មិនយូរប៉ុន្មាន ក៏បានមកដល់មាត់ព្រៃកន្លែងចាស់ ដែលជាទីលំនៅនៃ សត្វកញ្ជែង ។ ខាងក្រោយ ដែលបានសម្រាកកាយយ៉ាងស្រួលនឹង អរគុណចំពោះព្រះជាម្ចាស់ដែលជួយបំពេញបំណងនៃយើង ខ្ញុំព្រះ បង្គំក៏សួរសំឡាញ់ អំពីរឿងនៃដុំថ្មគាំងឡាយដែលខ្ញុំព្រះបង្គំបាន សំគាល់ខុកក្នុងពេលមុន ។

សំឡាញ់ខ្ញុំព្រះបង្គំឆ្លើយថា: រឿងនេះ បើខ្ញុំជ្រាបដល់អ្នក។ នឹងមាន សេចក្តីស្តាយក្រោយ បើខ្ញុំមិននិយាយជ្រាប ក៏អ្នកស្តាយក្រោយដែរ ។

– សូមសំឡាញ់និយាយជ្រាបចុះ ។

សំឡាញ់ខ្ញុំព្រះបង្គំជ្រាបថា: ដុំថ្មនេះគឺជាបងទាំងពីររបស់អ្នក

ដែលមានចិត្តឫស្យាមិនស្តាប់នូវសេចក្តីអង្វរនៃខ្ញុំ ហើយថែមទាំងត្រលែងឆ្កែឲ្យមកខាំខ្ញុំទៀត ធ្វើខ្ញុំឲ្យជាប់នៅក្នុងវាសនាអាក្រក់ពាក់ស្បែកគង្វែងរឹងរឹតតែយូរទៅទៀត ហេតុដូច្នេះ ទើបខ្ញុំធ្វើឲ្យក្លាយទៅជាឋ្មាំងអស់ ។

ទូលព្រះបង្គំអង្វរថា: បំណាច់យើងស្រឡាញ់គ្នា ខ្ញុំសុំឲ្យអ្នកជាប់បងរបស់ខ្ញុំឲ្យបានរស់ឡើងវិញផង ។

សំឡាញ់ទូលព្រះបង្គំឆ្លើយថា: សេចក្តីស្នេហានៃអ្នកជាវត្ថុមានដំឡៃរបស់ខ្ញុំ ណ្តើយសូមបំណាងនៃអ្នកសម្រេចចុះ ប៉ុន្តែមកនឹងមានវិប្បដិសារីអំពីកិច្ចនេះជាមិនខាន ។

ប្រហែលមួយនាទី ទូលព្រះបង្គំមិនដឹងថាគាត់ធ្វើសញ្ញានឹងដៃដូចម្តេចស្រាប់តែរូបឋ្មាំងប៉ុន្មានហាក់ដូចជាត្រឹមៗ ត្រៃតៗ ឡើង រួចព្រះរៀមនៃទូលព្រះបង្គំ ក៏ត្រឡប់មានជីវិតឡើងវិញ ឈរនៅរហាំពីមុខទូលព្រះបង្គំ។

យើងទាំងបីនាក់នាំគ្នាលាសំឡាញ់នៃទូលព្រះបង្គំ ហើយត្រឡប់មកព្រះនគរវិញ ។ ប៉ុន្តែព្រះរៀមទាំងពីរហាក់ដូចជាមិនសព្វព្រះរាជហឫទ័យនឹងដំណើរបស់ទូលព្រះបង្គំសោះ ។

កាលពេលដែលដើរបានឆ្ងាយបន្តិចទៅ ព្រះរៀមទាំងពីរមានវាចាថា: ម្ចាស់ប្អូន! យើងអស់កំឡាំងណាស់ ដ្បិតថ្ងៃក្តៅពេក ហើយនៅក្បែរនេះមានត្រពាំងទឹកមួយ បើដូច្នេះ យើងនឹងចុះផឹកទឹកសិន ។

ខ្ញុំព្រះបង្គំមានសេចក្តីខុសចិត្ត ក៏ព្រមតាមព្រះរៀមទៅ ។ លុះព្រះរៀមសោយរួចស្រេចហើយ ត្រូវវិនខ្ញុំព្រះបង្គំទទួលព្រះពរជាទានម្តង, កំពុងតែលុតជង្គង់ទន្ទេរដើម្បីឲ្យមាត់ទៅដល់ទឹក ខ្ញុំព្រះបង្គំដឹងថាមានការឈឺចាប់យ៉ាងអស្ចារ្យមកប៉ះទង្គិចដើងមួយរំពេច ។ ខ្ញុំព្រះបង្គំចង់ងាកមកវិញហេតុនៃការឈឺចាប់នោះដែរតែគ្រាកណ្តាលពុំរួច គឺព្រះរៀមចាំងពីរបាន កាប់ដើងចាំងពីរបស់ខ្ញុំព្រះបង្គំត្រង់កន្ទាក់អាចម៍ហើយនាំគ្នាធ្វើដំណើរហួសទៅ មិនអើពើនឹងពាក្យអង្វរ ហើយនឹងការថ្វាយនៃខ្ញុំព្រះបង្គំ ។

ខ្ញុំព្រះបង្គំស្ថិតនៅបីយប់បីថ្ងៃក្បែរត្រពាំងទឹក ។ កាលណាមានសត្វសាហាវមកវិលវៀនខ្ញុំព្រះបង្គំ សេះរបស់ខ្ញុំព្រះបង្គំចាំអាវខ្ញុំព្រះបង្គំលើកឡើងពាត់ទៅទីឆ្ងាយ ហើយបាយខ្ញុំសត្វសាហាវណាដែលចង់ចូលមកកេងាន់ខ្ញុំម្ចាស់ ។

ថ្ងៃទីមួយកន្លងមក ខ្ញុំព្រះបង្គំបានប្រទះនឹងមនុស្សខ្វាក់ម្នាក់ដើរតាមតើមដោយលំបាកដែរ ។

ខ្ញុំព្រះបង្គំសួរថា : នរណាដើរ? ។

គេឆ្លើយថា : ខ្ញុំជាមនុស្សកែលវិការខ្វាក់ភ្នែកលំបាកណាស់, រួចគាត់ប៉ាយរឿងរបស់គាត់ តាមដំណើរដែលបងរបស់គាត់បានខ្វះភ្នែកគាត់ចោល ។ ខ្ញុំព្រះបង្គំរៀបរាប់រឿងរបស់ខ្ញុំម្ចាស់ប្រាប់ទៅគាត់វិញអំពីព្រះរៀមកាប់ដើងខ្ញុំព្រះបង្គំហើយនាំគ្នាត់ចោល ។

- គាត់និយាយថា : បើដូច្នេះ ចូរយើងចងចាប់គ្នាធ្វើជាមិត្ត ខ្ញុំធ្វើជាដើង សំឡាញ់ធ្វើជាក្អែក ខ្ញុំជាអ្នកដើរ សំឡាញ់ជាអ្នកមើល ហើយនៅត្រៃដិតខាងនេះ ខ្ញុំដឹងកន្លែងជាលំនៅនៃខ្យាដំរីមួយដែលឈាមរបស់វាអាចយកមកធ្វើជាថ្នាំសំរាប់តែជម្ងឺគ្រប់ដំណក្បាន ។

លុះចុះសម្រុងគ្នាហើយ យើងក៏ធ្វើដំណើរចេញទៅ ដើម្បីស្វែងរកខ្យាដំរី ។ ទីបំផុត យើងបានរកឃើញទីលំនៅរបស់វា ហើយទទួលពេលនោះ ខ្យាដំរីចេញទៅរកស៊ីបាត់ ។ សំឡាញ់កង្វាក់ដាក់ទូលព្រះបង្គំឲ្យពួននៅក្បែរគៀនទ្វារ ហើយចាប់ទូលព្រះបង្គំឲ្យកាប់ភ្លាមកាលណាវាត្រឡប់ចូលមកវិញ ។ ខ្លួនគាត់ទៅពួននៅខាងក្រោយឡាំងខ្លះ ។ ខ្យាដំរីមិនយូរប៉ុន្មាន ក៏ត្រឡប់ចូលមកវិញ ហើយក្រោធក្តៅក្រហាយ ដោយធុំក្លិនមនុស្សលោក ។ អាការនៃខ្យាដំរីធ្វើឲ្យខ្ញុំម្ចាស់ខ្លាចក្រៃពេក ។ គាន់តែវាមកដល់ទន្ទឹមទូលព្រះបង្គំ។ ត្រលែងមួយជាវយ៉ាងអស្ចារ្យ ខ្លួនវាជាប់ជាបីកំណាត់ ។

ទូលព្រះបង្គំយកឈាមក្តៅៗមកលាបអាយវ: ហើយយកដើងមកផ្គុំគ្នា ដើងទាំងពីរក៏ចាប់គ្នាឡើងវិញរលាយសាច់មួយ ហាក់ដូចជាមិនដែលមានរបួសអ្វីសោះ ។ ទូលព្រះបង្គំយកឈាមនោះទៅលាបក្អែកឲ្យសំឡាញ់ទូលព្រះបង្គំផង រួចគាត់ត្រឡប់មានចក្ខុប្រសាទឡើងវិញ ។ លុះសំរេចកិច្ចរៀងខ្លួនហើយ ខាងក្រោយដែលអរគុណចំពោះព្រះជាម្ចាស់ យើងក៏លាគ្នាធ្វើដំណើរចេញទៅរៀងខ្លួន តាមយថាកម្ម ។

ទូលព្រះបង្គំមិនមានបំណងនឹងចូលមកកាន់ទីព្រះរាជវាំងតែម្តងទេ ក៏ក្លែងខ្លួនជាអ្នកគង្វាលចៀម ដោយគិតថា ស្រែចនៅព្រះជាម្ចាស់ចុះ ជាអ្នកសម្រែចទូរអំពើអកុសលនៃមនុស្សកំចាបចាំងឡាយ ។ ការសង្ឃឹមរបស់ទូលព្រះបង្គំក៏មិនអស់រសាត់តការេ ព្រោះអានុភាពនៃព្រះអង្គធំណាស់ ហើយការវិនិច្ឆ័យរបស់លោកខ្ញុំតសោតក៏ខ្ញុំនត្រង់ ។

ព្រះចៅភជាធិបជ មានព្រះបន្ទូលទៅកាន់នាងស្រែកម៉ុថា : ម្តងនេះត្រូវនាងនិយាយឲ្យយើងស្តាប់មើល តើយ៉ាងដូចម្តេច នាងក៏ចាំនមកធ្វើជាទាសីសម្រាប់បោសព្រះរាជវាន? ។

នាងមាណវីក្រាបបង្គំទូលថា : លុះបានកាប់ដើងព្រះអណ្តូងរួចស្រេចហើយកាលណា ព្រះរៀមតាំងពីរ ម្នាក់នាំទូលព្រះបង្គំ ម្នាក់ទៀតកាន់បក្សីចិញ្ចូចេញចោលព្រះកនិដ្ឋាមក ។ ចំណែកខ្ញុំម្ចាស់ចិត្តនៅតែប្រតិព័ទ្ធក្នុងព្រះរាជបុត្រនៅនៃព្រះអង្គជានិច្ច ព្រោះទូលព្រះបង្គំជាសាក្សីនៃសេចក្តីក្លាហានរបស់ព្រះអណ្តូង ។ បណ្តាព្រះរៀមតាំងពីរ មានព្រះរៀមមួយព្រះអង្គបង្ខំឲ្យទូលព្រះបង្គំយកលោកធ្វើជាព្រះស្វាមី ក្នុងពេលដែលលោកយាងមកដល់ព្រះរាជវាំង ។ ទូលព្រះបង្គំចេះតែរឹងទទឹងចំពោះសេចក្តីបំណងក្នុងការកំហែងចាប់ចង់នៃព្រះរៀមអង្គនោះ ហើយមិនព្រមចេញទៅទីដទៃ ស៊ូអត់ទ្រាំនៅធ្វើជាទាសីឆ្នាំសត្វក្មាន នឹងជាស្រីបោសព្រះរាជវាន ព្រោះនឹកឃើញថា ព្រះជាម្ចាស់មិនដែលលះបង់

ចោលមនុស្សស្រុចវិតឡើយ ។ ឥឡូវនេះខ្ញុំព្រះបង្គំសូមអរព្រះគុណ
នៃព្រះជាម្ចាស់ដែលបានសំដែងឲ្យឃើញជាក់ច្បាស់ដល់ភ្នែកខ្ញុំព្រះបង្គំ
ថា អំពើកុសលមិនដែលស្លាប់ ។

ព្រះចៅមានព្រះតម្រាស់សួរថា : តើនាងបានអ្វីជាបន្ទាល់
ដើម្បីធ្វើឲ្យដឹងថា នាងគឺជាកដជាតួនាងនារីដែលកូនយើងបាននាំយក
មកពីនគរយក្សា? ។

នាងមាណវីយកផ្ទៃពុត្រាបង្ហាញ ហើយទូលថា: ផ្ទៃពុត្រា
នេះ អាចបញ្ជាក់ឲ្យដឹងច្បាស់បានថាខ្ញុំព្រះបង្គំ គឺជាអ្នកណា ! ព្រះ
រាជបុត្រនៃព្រះករុណាថ្ងៃវិសេសមិនបានជ្រាបរឿងនេះទេ ព្រោះខ្ញុំព្រះ
បង្គំមិនដែលយកផ្ទៃនេះមកបង្ហាញឲ្យឃើញម្តងឡើយ ។

នាងមាណវីចេញទៅកណ្តាលវាល យកវាំងតវ៉ែតវាយបំដង
ពីខាងលើផ្ទៃពុត្រា ស្រាប់តែប្រាសាទយ៉ាងល្អអស្ចារ្យផុះឡើង ។
ប្រាសាទបែបនេះ ក្នុងព្រះរាជបុរីអាយ ឥតមានប្រាសាទឯណាយកមក
ប្រៀបផ្ទឹមបានឡើយ ។ ព្រះករុណាថ្ងៃវិសេសក៏ទ្រង់សរសើរប្រាសាទ
នេះវែរ ។ ហើយព្រះរាជាគិតបំរុងនឹងធ្វើបុណ្យមួយជាទ្រព្យវិត ដើម្បី
សំដែងសេចក្តីត្រេកអរ ចំពោះការវិលត្រឡប់មកដល់ព្រះនគរវិញនៃ
ព្រះរាជបុត្រវែរ; ប៉ុន្តែព្រះរាជបុត្រអង្គនេះ ទូលស្នងថា: បពិត្រព្រះ
វររាជបិតា! មុននឹងអរគុណចំពោះព្រះជាម្ចាស់ ខ្ញុំព្រះបង្គំមានបំណងចង់

ឲ្យព្រះជាម្ចាស់វិនិច្ឆ័យយើងបីនាក់ ។ ព្រះពាក៌មិនហ៊ានយល់ទាស់ ។ គេនាំព្រះពជបុត្រច្បងទាំងពីរមកហើយ ព្រះរៀមលុតជង្គង់សូមទោសចំពោះព្រះអណុជ។ និយាយថា បើព្រះជាម្ចាស់អត់ទោសឲ្យព្រះរៀមទូលព្រះបង្គំក៏ត្រូវអត់ទោសដែរ ។ ហេតុដូច្នេះត្រូវតែយើងធ្វើតាមបំណងនៃព្រះអង្គ ។

នៅមុខព្រះវិហារ គេដាក់ដើមឈើបីកំណាត់ ហើយលុងឲ្យមានប្រហោងកណ្តាល ចម្ងាយប្រវែងគ្នាពីមួយទៅមួយ ព្រះពជបុត្រមួយអង្គ។ ត្រូវចូលក្នុងប្រហោងឈើនោះ ហើយកាន់ដុំថ្មយ៉ាងធំមួយម្នាក់រួចបោះទៅលើអាកាស ។ ដុំថ្មព្រះពជបុត្រច្បងទាំងពីរដែលបោះទៅលើ ក៏ត្រឡប់ធ្លាក់មកលើក្បាលយ៉ាងខ្លាំង ខ្លាំងពេកទាល់តែធ្វើឲ្យស្លេចសុគតមួយរំពេច ។ ចំណែកដុំថ្មរបស់ព្រះពជបុត្រពៅត្រឡប់ធ្លាក់មកខាងមុខ ។ កាលវេលាដែលគេធ្វើកិច្ចល្បងនេះ មហាជនមកមើលច្រើនជាអនេក ។ ខាងក្រោយដែលព្រះចៅពាជាធិពជបានអភិសេកផ្សាំផ្តុំព្រះពជបុត្រពៅជាមួយនឹងនាងមាណវីធ្នាំព្រះពជលាន ព្រះពជបុត្រអង្គនេះ ក៏ទ្រង់ស្លេចសោយពជ្យស្នងព្រះអង្គឡើង ។

ចប់រឿងបក្សីទី ៧ ។

ស័ព្ទចាក់ផ្សែងខ្មែរ

របស់គណៈកម្មការវប្បធម៌

ពេក មុញ - ជ៉ាគ្រី រួបរួម

(តមក)

Réalisation — ការធ្វើឲ្យបានពិត, ប្រាកដ

Vérité = — សច្ចៈ, សត្យ

Réalisme = — ប្រាកដនិយម

(១៩ - ៨ - ៤៩)

Débouché = — វិវរដ្ឋាន, ច្រកចំហ

Désidérata = — ឥច្ឆិតា

Essentiel = — សារវន្ត, (សារវន្តី)

Possibilité = — ការអាចធ្វើបាន

Dilemme = — ខ្វេគ្រាះ (ការកាន់យកពីរដង)

Alternative = — ខ្វេបថ, ការឆ្ងាស់គ្នា

Anarchie = — អនាធិបតេយ្យ

Volontaire = — អ្នកស្ម័គ្រ, ដែលស្ម័គ្រ, ដែលប្រកបដោយចេតនា

Volonté = — ឆន្ទៈ, សេចក្តីស្ម័គ្រ

Bonne volonté = ឆន្ទៈល្អ

(៦៦ - ៨ - ៤៩)

Fédération nationale des coopératives de con ommation = ប្រជុំក្រុមសហការណ៍នៃគ្រឿងឧបភោគ បរិភោគ ។

Point faible = ចំណុចខ្សោយ

Le fond et la forme (d'un texte) = អត្ថសន្ធឹងទម្រង់ (នៃអត្ថបទ)

Grâce à = ដោយសារតែ...

A cause de = ព្រោះហេតុតែ... ពាល់តែ...

(៣០ - ៨ - ៤៩)

Sagesse = គតិបណ្ឌិត

Sage = បណ្ឌិត

Ecole Normale d'Institutrices à Montpellier = សាលាគរុវិជ្ជាកុមារី នៅម៉ុងប៉ែលីយេរ៍

Centre Régional d'Education Physique de Dinard (Rennes) = ទីប្រជុំកូមិភាគនៃការសិក្សារូបនិយម នៅឌីណាដ៍ - (រែន្នស៍)

Académie Internationale de Coupe à Paris = បណ្ឌិតសភាអង្គបរទេសខាងការកាត់ដេរ នៅប៉ារីស ។

Syndicat = សហជីព

Milieu parlementaire = មជ្ឈដ្ឋានសភា

(๒ - ๙ - ๔๙)

Orthodoxie = សម្មាមតិ (មតិ)

Impression (de voyage) = ការចាប់អារម្មណ៍ (នៃដំណើរ)

Improviser = មិនបានគិតទុកជាមុន

A l'improviste = ដោយមិនបានដឹងខ្លួនមុន

Impromptu = ដែលមិនបានគិតទុកជាមុន

Aventure = ការដើរផ្សងព្រេង

Aventurier = អ្នកដើរផ្សងព្រេង អ្នកដើរទេស

(๖ - ๙ - ๔๙)

Aristocrate = អភិជន

Aristocratie = អភិជនាធិបតេយ្យ

Noble = អភិជន

Noblesse = អភិជនភាព, ថ្នាក់អភិជន, គណៈ: អភិជន, អភិចរិយា

Bourgeoisie = ថ្នាក់ឬគណៈគហបតី

Spécialiste = អ្នកឯកទេស

Argument = ហេតុផល, ហេតុការណ៍

Argumentation = ការអាងហេតុផល

Raison = វិចារណញ្ញាណ, គ្រឹមត្រូវ, ខ្នង

Bourgeois = ហេតុគហបតី

Commandement = កងបញ្ជាការ, អំណាចបង្គាប់បញ្ជា, ការបង្គាប់បញ្ជា

Raisonnable = សមហេតុសមផល

Raisonnement = ការពិចារណារកហេតុផល (๑๓ – ๙ – ๘๙)

Motif = ហេតុ

Prétexte = លេស, អន្តរាគាស

Pouvoir = អំណាច

Puissance = អានុភាព

Force = កម្លាំង

Energie = ថាមពល, ពលិន្ទ្រិយ៍

Prétexter = ធ្វើតយកលេស, ធ្វើតយកអន្តរាគាស

Puissance magique = មន្តានុភាព, ឥទ្ធានុភាព, ឫទ្ធានុភាព (មាឧត)

រឿងព្រៃឆកូមា

លោក សាង - សារ៉ាត លេខានុការក្រសួងកិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តទៅ)

បុរសផ្សង់ព្រៃឆខ្លាំងគំនិតពេក ឥតបានសាកសួរគេទេ ក៏ដើរចុះពីផ្ទះរត់តម្រង់ទៅប្តឹងលោកសុភានៅក្នុងភូមិ សុំឲ្យលោកជួយឲ្យបានប្រពន្ធមកខ្លួនវិញ ។ ឯអ្នកស្រីជាម្តាយក្មេកបុរសនេះត្រមាំងជនានុជនច្រើនរូបទៀតត្រូវគេហៅទៅធ្វើជាសាក្សី ។ – ទេ! រឿងនេះគ្មានអាំឲ្យយើងឆ្ងឹងឆ្ងល់អ្វីសោះ ព្រោះករិយារបស់អ្នកស្មាប់ឆង់ជីវិតក្នុងកណ្តាលអណ្តាតភ្លើងទៅហើយតើ, បើមិនមែនដូច្នោះទេ ម្តាយប្រពន្ធអ្នកមិនមែនមកប្តឹងបញ្ជាក់ពីថ្ងៃមុនឡើយ នាងនេះគ្រាន់តែមានរូបកាយប្រហែលករិយារបស់អ្នកតើ ឯម្តាយក្មេករបស់អ្នកបានត្រៀតមើលមុខនាងនេះមកយូរថ្ងៃដើម្បីកុំឲ្យមានទុក្ខព្រួយពេកប៉ុណ្ណោះទេ ។ ប៉ុន្តែទោះបីបុរសនោះខំជជែកយ៉ាងណាក៏ដោយ លោកសុភាក៏មិនព្រមស្តាប់សោះ ។ ក្រោយមកលោកចៅហ្វាយខេត្តក៏បានកាត់សេចក្តីដូចលោកសុភានេះទៀត ។

លុះធ្វើសង្គ្រាមដែលអស់សង្ឃឹមនេះហើយ, បុរសផ្សង់ព្រៃឆបានទៅទូលដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ព្រះករុណាម្ចាស់ជីវិតទ្រង់ខំស្តាប់ពាក្យបណ្តឹងយ៉ាងម៉ត់ចត់; ប៉ុន្តែទ្រង់មិនសូវប្រសប់ខាងផ្លូវ

ច្បាប់ ហើយដោយទ្រង់មានព្រះហឫទ័យចង្អៀតចង្អល់ជាពន់ពេក ។
កន្លងពេលនោះ ទេវតាដែលរក្សាសូត្តច្ចត្រជាន់ខ្ពស់បំផុតនឹងព្រះកាណាព្រះអង្គ
ថា: "សូមទ្រង់ព្រះមេត្តាប្រោស ! រឿងនេះធំណាស់ ហើយពិបាកផង;
ជនណាដែលល្ងង់ខ្លៅជននោះមិនត្រូវមកច្រលំកន្លងរឿងនេះទេ; ឯលោក
នាយកអគ្គិជនរបស់ព្រះអង្គជាចៅក្រមមួយយ៉ាងប៉ុនប្រសប់, លោកនេះ
អាចនឹងវាក្យការណ៍ពិតឃើញច្បាស់" ។

ព្រះពជាក៏ទ្រង់មានព្រះបន្ទូលហៅលោកដ៏ចំណាប់នេះ មកជិត
ព្រះអង្គ ហើយទ្រង់បង្គាប់ឲ្យរូបនេះបំភ្លឺរឿងនុ៎ះឡើង ។

មិនមែនជាការស្ងួលទេ ដែលគេប្រគល់រឿងនេះឲ្យលោកវង្ស
ដ៏វិសេសនេះ, លោកជាអ្នកប្រាជ្ញមែនពិត ប៉ុន្តែលោកមិនដឹងធ្វើយ៉ាងណា
ឬគិតយ៉ាងណាសោះ ។ ឯបុត្រីរបស់លោកឈ្មោះនាងធូដាម្ន៉ាសារី
ម៉ង់សាមី (Thoudamna sari menzamie) បានសង្កេតឃើញកង្វល់របស់
លោកដោយឥតយូរឡើយ ហើយសួរកហេតុនេះភ្លាម ។ ឪពុកដែល
ទុកចិត្តតែលើរូបកូនស្រី ១ នេះ គ្មានតែនិយាយត្រង់កន្លែងពិបាក ដែល
ព្រះករុណាទ្រង់ត្រាស់បង្គាប់ឲ្យលោកសម្រេច ។ នាងធ្វើយថា: "សូម
លោកឪពុកកុំព្រួយឲ្យសោះខ្ញុំជានាំងអស់ ខ្ញុំគ្មានតែសូមលោកឪពុក
ឲ្យសង់ខ្នមមួយផ្សែងក្នុងសួនច្បាររបស់យើង ហើយឲ្យជនទាំងអស់ដែល
មានរឿងមកកេខ្ញុំ, ជនម្នាក់ៗ ឈរនៅជ្រុងមួយៗ, ឯខ្ញុំនៅកណ្តាល

ជាមួយនឹងស្មៀនរបស់ខ្ញុំម្ចាក់, រួចខ្ញុំសាកសួរជនទាំងនោះម្ចាក់ម្ចង ។, ខ្ញុំហ៊ានសន្យាថាខ្ញុំរកសេចក្តីពិតឲ្យឃើញពុំខាន" ។

លុះកាលណាធ្វើបានសព្វគ្រប់ដូចបំណងនាងហើយ នាងហៅប្តីដើមមកហើយពោលពាក្យដូចមានតទៅនេះ "នុអ្នកដ៏ថ្លៃថ្លា ! គេនិយាយអ្នកអត័ព្វប្រពន្ធស្ងាប់ក្នុងអគ្គិភ័យ ដែលឆេះផ្ទះរបស់អ្នក កាលដែលអ្នកចេញផុតទៅធ្វើដំណើរតាមសមុទ្រ ដោយក្លាហានដើម្បីទៅរកជនជាន, ឥឡូវនេះ អ្នកបានត្រឡប់មកវិញពេញចិត្តដោយការរកជនជាននោះបានដូចបំណងរបស់អ្នក, ឯឪពុកម្តាយរបស់អ្នកទៀតក៏សុទ្ធតែអ្នកមានទ្រព្យសម្បត្តិសម្បើមណាស់ដែរ; ចំណែកខាងមតិពិតត្រង់របស់ខ្ញុំយល់ថាមនុស្សឈ្លាសវាងវៃនឹងពុំថ្លើងដូចអ្នកនេះ មិនសមឡើយមកប្តឹងផ្តល់ជណ្តើមប្រពន្ធដូច្នេះទេ, ឯរូបស្រីបានប្រកាសថា គេជាប្រពន្ធពិតរបស់គូសត្រូវរបស់អ្នក, ឯគូសត្រូវនេះ គេក៏ប្រកាសដូច្នេះដែរ; មួយទៀតតាំងពីស្តេចផែនដីរហូតដល់តំខេចសុកាក្នុងប្រទេស គេថាអ្នកពុំសូវតាំងអស់, ឥឡូវនេះ សូមអ្នកនិយាយប្រាប់ខ្ញុំឲ្យពិតត្រង់មើល តើនាងនោះប្រាកដជាប្រពន្ធរបស់អ្នកមែនឬទេ ? ហើយតើហេតុយ៉ាងណាបានជាគេស្អប់អ្នក ? គួរណាស់តែអ្នកធ្វើតាមពាក្យខ្ញុំដែលជំពប់អ្នកដូចមានតទៅនេះ: ប៉ុន្តែខ្ញុំមិនដឹងជាអ្នកសុខចិត្តធ្វើតាមខ្ញុំឬយ៉ាងណាទេ ឯចំណែកខាងខ្ញុំ។ សឹងតែមិនហ៊ានហាមាត់និយាយផង" ។ លុះនិយាយដូច្នេះហើយនាងអៀនខ្មាសយកដៃបិទមុខដ៏ល្អឆើតឆាយរបស់នាង ។ ក្នុងពេលនោះ

បុរសអង្វរឲ្យនាងនិយាយតទៅទៀត ។ នាងដើមមុខឡើងជាប់ចិត្តមិនខ្មាសអៀន ហើយនិយាយថា: "ឯដំបូន្មានរបស់ខ្ញុំមានដូចតទៅនេះ: រូបអ្នកជាអ្នកមានទ្រព្យសម្បត្តិ រូបខ្ញុំជាកូនរបស់លោកនាយកវេដ្ឋមន្ត្រីនៃព្រះមហាក្សត្រ; បើសិនណាយើងស្រឡាញ់គ្នា ហើយព្រមព្រៀងរៀបការនឹងគ្នា យើងមុខជាគ្មានទុក្ខភ័យអ្វីទេលុះអស់ជីវិតរៀងខ្លួន, អ្នកមានបុក្ខ្លាគួរឲ្យខ្ញុំសរសើរណាស់ តើអ្នកយល់ព្រមតាមខ្ញុំទេ? ហើយចូរអ្នកធ្វើយឲ្យត្រង់ដូចចិត្តខ្ញុំដែលបានបង្ហាញអ្នកអម្បាញ់មិញនេះ" ។ បុរសធ្វើយបែបព្រួយបន្តិចថា: "ឯពាក្យធ្វើយរបស់ខ្ញុំវាយទេ, នាង! ខ្ញុំចាប់ចិត្តចាប់គំនិតនឹងពាក្យរបស់អ្នកនាងជាពន់ពេក, ប៉ុន្តែតើឲ្យខ្ញុំលះបង់ចោលកន្លែងណា · ដែលឪពុកម្តាយរបស់ខ្ញុំបានជាក់ទុកឲ្យម្តេចបាន? ខ្ញុំបានសន្មតកន្លងចិត្តថា នាងនេះជាគូដំណើរបស់ខ្ញុំ ពីព្រោះយើងស្គាល់គ្នាតាំងពីតូចមក, នាងស្រាតតែលេងយ៉ាងសប្បាយក្នុងផ្ទះរបស់យើង, មនុស្សប្រុសមិនត្រូវជាប់ចិត្តធ្វើអំពើកំណាចបំបាត់កិច្ចព្រមព្រៀង ដែលបានធ្វើយ៉ាងនេះឡើយទេ" ។ នាងលុះកាលណាបានឮសំដីដ៏ប្រពៃនេះហើយ នាងញញឹមទៅរកបុរសរួចបើកទ្វារឲ្យចេញទៅ, នាងបានគិតយើញរួចជាស្រេច ។

ក្រោយមក នាងបានហៅប៉ាយតាទៅឯបន្ទប់នាង, នាងនឹកថាប៉ាយតានេះជាមនុស្សអាក្រក់ ប៉ុន្តែនាងខំលាក់ពុត ហើយសួរដោយខ្ជិលខ្ជា

បន្តិចថា: "បុរសក្មេងៗ ទាំងពីរនាក់នេះឈ្លោះគ្នាព្រោះស្ត្រីម្នាក់ប៉ាងនេះមិនត្រូវទេ, ឯខ្ញុំជាស្រីគ្មានប្តី បើអ្នកសុខចិត្ត ខ្ញុំព្រមយកអ្នក, ខ្ញុំជាកូនរបស់លោកនាយករដ្ឋមន្ត្រីមានទ្រព្យសម្បត្តិសម្បើមណាស់, ខ្ញុំមានមាសពេជ្រក្នុងលោកនេះគ្មានអ្នកណាស្មើ, បើយើងបានគ្នាមុខជាសប្បាយដោយទ្រព្យនឹងយសស័ក្តិរបស់យើងមិនខាន" ។

ប៉ាយតា ឥតបានសង្កេតថា នាងនិយាយអំពីតណ្ហាសោះ ឃើញថានាងនិយាយតែអំពីទ្រព្យ ហើយក៏ធ្វើយភ្លាមថាសុខចិត្ត ។ នាងទំលាក់ពុតរបស់នាង ហើយធ្វើយថា: "បើអ្នកយល់តាមគ្រោងការនេះ យើងត្រូវនាំគ្នារត់ទៅនៅឯទីណាមួយឆ្ងាយពីទីនេះ, លុះតែធ្វើយ៉ាងនេះទើបខ្ញុំជឿថាអ្នកស្រឡាញ់ខ្ញុំ" ។ ប៉ាយតាឥតប្រកែកអ្វីមួយម៉ាត់សោះ ធ្វើមុខស្មើដូចធម្មតា ។ ឯនាងក្តៅក្រហាយលើកដៃគ្រវាសចង្ក្រានឲ្យប៉ាយតាចេញទៅ ។ ប៉ាយតានៅតែគ្មានចាប់ក្តីកន្ទឹងអាការរបស់នាង ហើយថយខ្លួនយ៉ាងស្រួលបួលទៅ ក្អែកវិតមើលនាងទៀត ។ ឯនាងគ្មានមើលវិញទេ ។

ក្រោយមកទៀត នាងហៅនាងកវិយាមក ហើយនិយាយថា "អ្នកបង! ប្តីរបស់អ្នកបងសព្វថ្ងៃក្រខ្សត់ខ្លាយ, គាត់គ្មានអ្វីសោះ ហើយគាត់មានគំនិតហាក់ដូចជាអន់ថយជាងបុរសកូនអ្នកមានជាពន់ពេក, ឯរូបគេនេះពេញលេញប្រសើរណាស់, គេមានទ្រព្យសម្បត្តិក៏ច្រើន

គេអាចនាំអ្នកបង់ឲ្យបានសប្បាយ, បើអ្នកបង់រួមរស់នឹងគេ អ្នកបង់មុខជា
លែងស្គាល់សេចក្តីត្រេកអរទៀតហើយ រៀងរហូតដល់ស្លាប់ទៅវិញ, ខ្ញុំ
សូមឲ្យអ្នកបង់ប្រាប់ខ្ញុំ តើហេតុដូចម្តេចបានជាអ្នកបង់មិនព្រមយកគេ? ។

នាងកវិយាឆ្លើយថា "ជំទាវប្រសាសន៍អ្នកនាង! អ្នកនាងក៏ស្រី
ខ្ញុំក៏ជាស្រីដែរ អាស្រ័យហេតុនេះ អ្នកនាងមុខជាយល់តាមខ្ញុំមិនខាន,
មនុស្សស្រីគឺជាផ្លែឈើមួយដែលជាប់នឹងមែក, ឯប្តីគុកដូចជាដើមឈើ
ដែលទ្រមែកនោះ, អ្នកនាងជ្រាបស្រាប់ហើយ តើធម្មជាតិផ្លែឈើណា។
ខ្លះ គឺដំបូងនៅលើដើមឈើមានតែត្រួយមួយទេ, ត្រួយនេះបង្កើតជា
សន្ទឹកមួយប្តីរប៉ុណ្ណោះ. សន្ទឹកនេះក្លាយបានទៅជាមែក, នៅលើមែក
នោះផ្ទាស់រួចបានទៅជាផ្លែ. ឯផ្លែបានជាផ្លែ, រួចផ្លែនេះទុំជ្រុះពីលើដើម
ឈើ, ជួនកាលគេរើសផ្លែនេះយកទៅបរិភោគ ជួនកាលទៀតផ្លែនេះ
នៅរលួយលើធរណី, ហេតុដូច្នោះ ខ្ញុំសូមសួរអ្នកនាង តើផ្លែដែលជ្រុះ
ពីលើដើមឈើ អាចភ្ជាប់ទៅតន្ទែងដែលជ្រុះនោះវិញបានឬទេ? ឯកូន
ដែលកើតចេញពីផ្លែមាតាមក អាចចូលនៅក្នុងផ្លែនោះវិញបានឬទេ?" ។

នេះហើយជាការៈរបស់ស្រីដែលជ្រលួនខុស ។ ឯការក្សត់ចិត្ត
របស់ស្រីនេះ នាំឲ្យក្លេចសេចក្តីស្នេហា នឹងសេចក្តីគោរពចំពោះប្តី
ស្វាមី ។ ហេតុដូច្នេះ បើគ្មានរបស់អ្វីមួយប្លែកអស្ចារ្យទេ ស្រីនេះ
គ្មានសង្ឃឹមឡើយ ទោះប៉ស្តីបន្ទោសខ្លួនឯងយ៉ាងណាក៏ដោយ ។

(មានត)

កណ្ឌទី ៦

អ្នកឧកញ៉ាវិបុលរាជសេនា ឆ្លៀត ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខ្ញុំពៀវធ្វើយថា សពស៊ុនកៀនដែលពួកគាហានាំមកឲ្យយើងនោះ យើងបានតុបតែងទុកតាមប្រវេណីដោយសមគួរ, ដែលស៊ុនសឹកឲ្យអ្នកមកនិយាយនេះយើងមិនថាអ្វីទេ តែថាតទៅមុខ កុំឲ្យស៊ុនសឹកគិតបំពានចូលមកធ្វើអន្តរាយដល់យើងទៀត ។

គេងលៀងធ្វើយជំរាបខ្ញុំពៀវថា ដែលលោកនឹងព្រមឲ្យសពស៊ុនកៀនទៅគេនោះ ខ្ញុំមិនខានយល់ព្រមជាមួយផងទេ ព្រោះស៊ុនកៀនបំពានមកធ្វើការខាំងនេះដោយចិត្តអាក្រក់ណាស់ ទើបដល់ខ្លួនសេចក្តីវិនាសដ៏វិតយ៉ាងនេះ ឯស៊ុនសឹកជាកូននៅក្មេងណាស់, សេនាគាហាន

ស៊ុនសឹកមានសេចក្តីកោតញញើតយើងជាច្រើន បើលោកស្តាប់ខ្ញុំៗនឹងគិតធ្វើតាហានស្រុកកាំងតាំងដែលសល់នៅនោះ កុំឲ្យវិលទៅរួចដល់ម្ចាស់ឡើយ សូមឲ្យលោកចាប់ហួនកាយនេះសម្លាប់ចេញទៅ រួចសឹមលើកទ័ពទៅវាយកងទ័ពវាំងនោះដោះគ្រាយ ស្រុកកាំងតាំងនោះគង់នឹងធ្លាក់មកជាកម្មសិទ្ធិរបស់លោក បើលោកមិនស្តាប់ខ្ញុំ ហើយប្រគល់សពស៊ុនកៀនទៅឲ្យគេ ថ្ងៃក្រោយលោកគង់មានសេចក្តីអន្តរាយជាប្រាកដ ។

ឡៅពៀវតបថា "ហង់ចនឹងយើងជាមនុស្សស្រឡាញ់ពាក់អានគុណចិត្តគ្នាមកពីដើម កាលបើយើងធ្វើដូច្នោះហាក់ដូចជាក្លែងសម្លាប់ហង់ចឲ្យស្លាប់ សេចក្តីដែលយើងប្តេជ្ញាទុកពីដើមក៏ខូចអាសោទៅវិញ" រួចហើយប្រាប់ហួនកាយឲ្យស្រួតត្រឡប់ទៅវិញ ហើយថា "ព្រឹកស្អែកឲ្យនាំខ្លួនហង់ចមកប្រគល់ឲ្យយើងត្រឹមទ្វារស្រុក យើងនឹងជូនសពស៊ុនកៀនទៅឲ្យ" ។ ហួនកាយក៏នាំសេចក្តីនោះត្រឡប់ទៅដំណាបស៊ុនសឹក។ មានសេចក្តីត្រេកអរជាខ្លាំងផុត, ដល់វេលាព្រឹកឡើង ចាត់តាហានឲ្យនាំខ្លួនហង់ចទៅជូនឡៅពៀវដល់ទ្វារស្រុក ហើយទទួលយកសពស៊ុនកៀនជាស្រេចក្នុងដៃ លើកតាហានត្រឡប់ទៅស្រុកកាំងតាំងវិញ ។

កាលនាំសពឡើងទៅដល់លើទីគ្រែហាស្នានហើយ ក៏ឲ្យតាត់តែងគ្រឿងដង្ហែដ៏រុងរឿង នាំទៅបញ្ចុះទៅដំបន់ខយ៉ុកគុ ។ សម័យនោះស៊ុនសឹកបានឡើងឋានៈជាធំក្នុងស្រុកកាំងតាំង, បណ្តាអ្នកស្រុក

តាំងអស់នៅត្រកាមបង្គាប់បញ្ជាស៊ុនសឹក. ឯការយោស៊ុនសឹកនោះជាមនុស្សមានសតិប្បញ្ញា បើឃើញអ្នកឯណាដែលធ្វើវាឆ្ងាសខ្ពាំងតូចតែតែងមានសេចក្តីគោរពកោតក្រែង ហើយចង់ចិត្តយកមកជាប័ក្សពួកធ្វើពាណិជ្ជការជាមួយ មនុស្សក៏ចុះចូលកុះករមកជាច្រើន ។

កណ្ឌ ទី ៣

ចាប់តាំងព័ត៌តាំងតុ:កំរើបចិត្តតាំង២ខួបជា សង់អ៊ូ (ធម្មបិតា) រួចគិតពាលៈចាយ:ទំនងសម្ងាប់តៀរអ៊ុន, តមកអង់អ៊ុនលួងលោម៤ងតៀរសៀតជាកូនចៅក្តីម ឲ្យទៅធ្វើជាភរិយាលីចោ:ទំនងតាំងតុ: ដើម្បីសួរអ្នកទាំង ២ នេះថាស់ខែងខ្វែងគំនិតគ្នា, រហូតដល់តាំងតុ: ប្រឹក្សាទំនងលីសុកអំពីទំនុកដែលក្មេងច្រៀង ។

តាំងតុ:នៅស្រុកតៀវហាន់ជាទីក្រែង លុះបានឮថា ស៊ុនកៀនជាចៅហ្វាយស្រុកតាំងតាំងស្ងាប់ហើយ មានសេចក្តីសោមនស្សត្រេះត្រេកខើបប្រជុំទីប្រឹក្សាហើយថ្លែងសេចក្តីថា ដែលស៊ុនកៀនស្លាប់នោះ យើងបានធូរស្រួលក្នុងចិត្តច្រើន ទុបមាដូចជាគេដកបន្ទាលចេញពីដើមទ្រូងនៃយើងបាន, ចុះក្នុងសម័យនេះ នរណាបានដឹងជាស៊ុនកៀនអាយុប៉ុន្មានហើយ? ។ លីយូធ្វើយថា ស៊ុនកៀននោះទើបនឹងបានអាយុ ៣០ ឆ្នាំគត់ ។ តាំងតុ:បានឮដូច្នោះក៏ឃើញថា ស៊ុនកៀននោះនៅក្មេងនៅឡើយ មិនមានសង្ស័យថាដូចម្តេច ។ ក្នុងខណៈនោះ តាំងតុ:ក៏តែតែមានចិត្តកំរើបឡើង នឹងធ្វើការអ្វីក៏រំលោភបំពាន.ទៅតាមអំពើចិត្តលែសពីដើម តាំងតុ:ក៏ងើលើកខ្លួនឲ្យមនុស្សទាំងពួងហៅថា "សង់អ៊ូ" ប្រែថា

"ព្រះធម្មបិតានៃព្រះចៅហៀនតេ" បើនឹងចេញដំណើរទៅទីឯណា ក៏ឲ្យមានក្បួនហែយ៉ាងព្រះមហាក្សត្រស្តេចយាង ហើយលើកតំកើងតាំងហាងជាប្អូនឲ្យធ្វើនាយទាហានកងត្រៃ បណ្តាសែតាំងទាំងប៉ុន្មានក៏ហៅទៅតាំងជានាហ្មឺនតូចធំទាំងអស់, តាំងតុ: ឲ្យកេណ្ឌពលស្តុ ២៥'ម៉ឺមទៅកសាងកំផែង ១ ចម្ងាយពីទីក្រុងតៀវហាន ២៥០០ សិន (១០០ ក.ម.) ធ្វើកំពែងខ្ពស់ប្រហែលនឹងកំពែងស្រុកក្រុង ខាងក្នុងក៏ឲ្យសង់ដំណាក់តូចធំដុំបរិវេណខាងមុខនឹងខាងក្រោយ មានទីឃ្លាំងនឹងដង្កែកជាក់ស្តែវអង្ករស្បៀងអាហារសម្រាប់សេនាទាហានបរិភោគបាន ២០ ឆ្នាំ ឯមាសប្រាក់ពន្ធជារនឹងសួយសារភាគទាំងប៉ុន្មាន ក៏ឲ្យបញ្ជូនទៅជាក់ឃ្លាំងក្នុងក្រុងថ្មីទាំងអស់ ហើយឲ្យចាត់ស៊ីវិបុលអ្នកបំរុងទុកប្រមាណ ៨០០ នាក់, ឯតាំងតុ:ជូនកាល ២០ ថ្ងៃ ទើបឡើងទៅគាល់ព្រះចៅហៀនតេម្តង បណ្តានាហ្មឺនតូចធំកងក្នុងស្រុកក្រុងទាំងប៉ុន្មាន ក៏ត្រូវទៅចាំទទួលឬជូនដំណើរចេញទៅវិញដល់មាត់ទ្វារក្រុង ឯកន្លែងដែលចូលទៅគាល់នោះមានទីប្រថាប់ជាច្រើនដំបន់, ក្នុងស្រុកតៀវហាន់នោះ ក៏មានទីកន្លែង ១ សម្រាប់សំណាក់ទៅតាមត្រូវការ ។ មាន ១ ថ្ងៃនោះតាំងតុ: ចេញអំពីទីគាល់បណ្តានាហ្មឺនទាំងពួង ក៏ជូនដំណើរទៅដល់មាត់ទ្វារក្រុង, តាំងតុ:ទើបបង្គាប់ឲ្យនាហ្មឺនទាំងនោះទៅពិសាសៀងឯទីប្រថាប់ ។

កងខណៈនោះ ចៅហ្វាយស្រុកមណ្ឌលខាងដើង បញ្ជូនមនុស្សប្រុសចាស់ប្រហែល ៥០០ នាក់មកដល់តាំងតុ:។ បង្គាប់ទាហានឲ្យយកមនុស្ស

អស់នោះទៅកាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ត្រចៀកខ្លះ កាត់អណ្តាតខ្លះ ឲ្យស្មោរដាក់ក្នុងខ្លះដែរខ្លះ ។ មនុស្សពាំងនោះ ក៏មានសេចក្តីសោយទុក្ខវេទនា នរណាដែលមិនទាន់ដាច់ខ្យល់ស្លាប់ក៏បំរះនៀលដោយឈឺចាប់ស្រែកខ្ទរហោយំរងំអឺងកង ។ នាហ្វូនពាំងពួង ដែលកំពុងបរិភោគអាហារបានត្រឡេកទៅឃើញ មានសេចក្តីអាណិតអាសូរពន់ប្រមាណណាស់ ខ្លះក៏ភ័យស្លុតរបូតចេញពីធ្លាក់ពីដៃ ខ្លះក៏រត់ឆ្ងងស្មារតីធ្លាក់តែរស្រាពីដៃកំពប់ស្រាអស់ ព្រោះឃើញសេចក្តីទុក្ខវេទនាយ៉ាងដាក់ស្តែងមុខគួរឲ្យកើតធម្មសង្វេគពន់ពេក ។ ឯតាំងតុ:នោះជាមនុស្សចិត្តអាក្រក់គ្មានមេត្តាករុណាសោះ លើកពែងស្រាផឹកភ្លាង, ម៉ើលភ្លាង, ស៊ើចភ្លាង, មនុស្សពាំង ៥០០ នោះ ក៏ស្លាប់ពាំងអស់គ្នា ។ នាហ្វូនពាំងអស់បរិភោគអាហារហើយ ក៏លាចុះទៅជាប្រញាប់ ។

ក្រោយនោះ តាំងតុ:បង្គាប់លីហ៊ោថា យើងនឹងឲ្យអញ្ជើញនាហ្វូនពាំងអស់មកលៀងអាហារម្តងទៀត បើតាលណាដួបជុំគ្នាហើយចូរកូនឯងទៅនឿបដិតត្រចៀកបិតាចុះ បិតានឹងឲ្យចាប់តៀវអ៊ីនទៅសម្លាប់ចេញ ហើយកាត់ក្បាលយកមក ។ លុះដល់ថ្ងៃកំណត់ដែលនាហ្វូនពាំងពួងមកស៊ីលៀងអាហារព្រមគ្នាហើយ តាំងតុ:ក៏អង្គុយផឹកស្រាតាមធម្មតា ។ ឯលីហ៊ោធ្វើជាចូលទៅនឿបដាក់ត្រចៀកតាំងតុ:។ ធ្វើជាសើចហើយថា គិតយ៉ាងនេះឬ! ចូលចាប់ខ្លួនវាទៅឲ្យនាប់ ។ លីហ៊ោក៏សួរទៅចាប់ខ្លួន

តៀវអ៊ុនអួសកន្លែងកៅ ។ នាហ្នឹងតាំងពួងដែលកំពុងបរិភោគនៅនោះ មិនដឹងសេចក្តីអ្វីសោះតាំងអស់គ្នា ក៏ស្រឡាំងកាំងមួយស្របក់ ស្រាប់តែឃើញលីចោ"យួរក្បាលតៀវអ៊ុន ជាក់កងគ្រចាស់ ចូលមកឲ្យតាំងតុ: មើល នាហ្នឹងតាំងពួងក៏តែតក់ត្រឹកឈាស់ ។ តាំងតុ: ឃើញដូច្នោះហើយ សើចថា អ្នកតាំងអស់គ្នាកុំភ័យចុះម្តេចអ្ី, ដែលកើតហេតុតាំងនេះ ព្រោះតៀវអ៊ុនឲ្យសំបុត្រស្វាត់ៅដល់អ្នងសុត ឲ្យមកធ្វើសេចក្តីអន្តរាយដល់យើងមានគេជឿងរឿងនោះ គេធ្វើសំបុត្រមកឲ្យយើង ចានដាលីចោ"ឱ្យប្រុប ប្រាប់យើង។ ទើបឲ្យចាប់ៅសម្លាប់ចេញដូច្នេះ បើអ្នកឯណាមិនចានរួមគំនិតជាមួយនឹងតៀវអ៊ុននោះទេក៏កុំគប្បីជាទុក្ខ ត្រូវបរិភោគលេងឲ្យសប្បាយៅចុះ ។ ខណៈកាលនាហ្នឹងតាំងនោះបរិភោគហើយក៏លាៅ ។

ខណៈនោះ មានមន្ត្រីម្នាក់ឈ្មោះអង្គុន កាលត្រឡប់ៅដល់ផ្ទះ ហើយគិតរំពឹងថា រឿងដែលតាំងតុ: ឲ្យហៅៅស៊ីលៀងហើយចាប់តៀវអ៊ុនសម្លាប់ចេញនោះប៉ងដឹងសឆ្កែតឲ្យឃើញពិតៅថា តៀវអ៊ុននោះគ្មានគិតគំនិតអាក្រក់ ឲ្យសំបុត្រៅអ្នងសុតមកធ្វើសេចក្តីអន្តរាយដល់តាំងតុ: សោះទេ តែដែលតាំងតុ: មានសេចក្តីព្យាបាទសម្លាប់គ្នាតាំងម្ល៉ះ ក៏គឺធ្វើយកអំណាចមិនឲ្យនាហ្នឹងតាំងពួងគិតអាក្រក់នឹងវាតៅ, ដែលវាធ្វើដូច្នេះក៏មិនមានអ្នកឯណានឹងគិតរំលាងបំផ្លាញវាចេញសោះ ។ អង្គុនមានសេចក្តីរំខានមិនចានស៊ីដេកដាស់ខ្ញុ លុះដល់ពេលយប់ស្ងាត់ ក៏ភាន់ឈើ

ច្រត់ទៅឈរផ្អែកនៅដើមឈើ ១ កន្លែងសួនផ្កា ហើយក្រឡេកមើលទៅ
លើអាកាស ឃើញផ្កាយរក្សាស្រុកអាប់រស្មីមិនមានពន្លឺ ទើបគិតថា
សព្វថ្ងៃនេះ ព្រះមហាក្សត្រនឹងអាណាប្រជានុរាស្ត្រថ្កានសេចក្តីក្តៅ
ក្រហាយក្រៃពេកតាំងតុ: ។ អង្គអ៊ុនគិតហើយក៏ដកដង្ហើមធំ ហើយយំ
ខ្សឹកខ្សួល ។ ក្នុងខណៈនោះ ស្រាប់តែឮសំឡេងស្រីម្នាក់ទៅដកដង្ហើមធំ
អំពីខាងមុខអង្គអ៊ុន។ ក្រឡេកទៅឃើញ ក៏ឈ្វេងមើលមុខស្គាល់ជាស
ជានាងតៀវសៀនដែលអង្គអ៊ុនលោះយកមកពីគូច ឃើញរូបភាពល្អបះ
ច្រៀងពីពេកក៏សន្មតទុកជាកូនចិញ្ចឹម នាងនោះកំពុងអាយុបាន ១៦
ឆ្នាំ ។ រំលោះនោះអង្គអ៊ុនសួរថា តើលុយប៉ាវនេះហើយម្តេចមិនទៅដេក
ចុះមកក្រអ៊ូកន្លែងសួនផ្កានេះ? ហើយដកដង្ហើមធំឬកើតទុក្ខពីព្រោះមិន
ឃើញសហាយមកជួបឬអ្វី? ។ នាងតៀវសៀនបានឮដូច្នោះក៏ភ័យស្លុត
ខ្លួលស្លុតដង្កង់ហើយដំរាបអង្គអ៊ុនថា ខ្ញុំនឹងបានមានសហាយស្នំហើយ
មកនៅចាំដូច្នោះក៏ទេ ខ្ញុនខ្ញុំជាទាសីលោក។ ក៏បានបីបាច់ចិញ្ចឹមរក្សាទុក
ជាកូនតាំងពីតូចមក ព្រះគេជព្រះគុណរកទីបំផុតគ្មាន សព្វថ្ងៃខ្ញុនខ្ញុំក៏
គិតនៅជានិច្ចថា បើលោកមានសេចក្តីទុក្ខព្រួយប្រការដូចម្តេច ខ្ញុំនឹង
ត្រូវជួយធុរៈនោះទៅតាមសតិប្បញ្ញា ដើម្បីនឹងបានតបស្នងសងគុណ
លោក ប្រសិនបើដីវិតខ្ញុំនឹងរលត់ផុតទៅ សាច់ឈាមសរសៃនឹងរលួយ
ស្មារផ្ទះធង់ធួលី ឬឆ្អឹងនឹងខ្ទេចខ្ទីជាធូលី ខ្ញុំក៏មិនបានសៅកស្តាយដល់

ដ៏តែសោះឡើយ. តាំងពីតូចមកម៉ែញដែលតាំងតុ:អស្ចើញលោកទៅពិសាសៀង ហើយលោកត្រឡប់មកដល់ផ្ទះវិញនោះ ខ្ញុំឃើញទឹកមុខលោកសៅហ្មងខ្លែតជាងសព្វដង ខ្ញុំក៏ស្មានថាលោកប្រហែលមានទុក្ខព្រួយអំពីការអ្វីជាមិនខាន់ណាស ទើបបានជាខ្លែតអស្ចារ្យដូច្នេះ លុះខ្ញុំឃើញលោកអស្ចើញមកដល់នេះខ្ញុំក៏លបចុះមកសង្កេតមើលឲ្យដឹងការ ដើម្បីនឹងជួយរំនិតជាផ្លូវតបស្នងសងព្រះគុណគ្រាតែអស់ជីវិត ។

អង្គអ៊ុនបានឮដូច្នោះតិចតួចថា "គ្រានេះបើផែនដីនឹងបានសុខក្សេមក្សាន្តឡើងវិញ ក៏ដោយសារនាងតៀវសៀនជាប្រាកដ" ទើបនាំនាងតៀវសៀនឡើងទៅលើលំនៅក្នុងល្អួងស្ងាត់ ហើយឲ្យនាងអង្គុយលើកៅអីប្លែកតែងឆ្ងាយចុះគំនាបខាងៗ នាងតៀវសៀនឃើញដូច្នោះក៏ភ័យណាស់ ស្ទុះចុះអំពីលើកៅអីមកគំនាបអង្គអ៊ុនវិញ ហើយចូលទៅក្រាបទូលបង្គាយាត់ថា លោកឪពុកម៉ែនត្រូវគំនាបខ្ញុំជាកូនទេ ។ អង្គអ៊ុនតបថា "ឪពុកបានឮកូនថាអំបាញ់ម៉ែញនោះ ឪពុកមានសេចក្តីត្រេកអរណាស់ ដែលបានជាឪនគំនាបកូនៗ ប្អូរមានមេត្តាករុណាដល់ព្រះមហាក្សត្រនឹងអាណាប្រជាទុកស្តេចនឹងព្រះពន្ធអាណាខែត្រចុះ" ថាតែប៉ុណ្ណោះហើយក៏យំអោកអួលៗ នាងតៀវសៀនបានឃើញបិតាខ្លួយយំក៏លើកដៃប្រណម្យជំរាបថា ខ្ញុំបានចេញវាចាខ្លាំងយកជីវិតតបស្នងសងគុណលោកឪពុកហើយ ហេតុអ្វីមិនមានប្រសាសន៍ប្រាប់រឿងហេតុដែលកើតទុក្ខនោះឲ្យ

ខ្ញុំដឹង, ដែលលោកឪពុកមកប្រឹងអង្វរយំដូច្នេះនឹងអស់ទុក្ខហើយឬ? ។
អង្គអ៊ុនឆ្លើយថា សព្វថ្ងៃនេះផែនដីក្តៅរំជួលគ្រប់ដើមស្មៅនៅឈើព្រៃ
ទាំងអស់ កូនក៏ល្មមដឹងព្រណាស់ហើយ ព្រះចៅហៀនតេនោះ ឧបមា
ដូចពងមាន់ដែលគេចាល់ទុកលើឋ, ឯនាហ្នឹនមុខមន្ត្រីនឹងអាណាប្រជា-
ទុកស្តេកង់ព្រះនគរ ឧបមាដូចជាគំនរសម្រាមដែលនៅជិតក្លើងមិនចាន់ដឹង
ថាសេចក្តីស្ងាប់នឹងមកដល់វេលាណា, តាំងតុ:ធ្វើការអាក្រក់កំរើកឡើង
ប្រឹងនឹងយកពាជសម្បត្តិ នឹងរកអ្នកឯណាគិតរំលងរាចេញគ្មាន ឯតាំងតុ:
នោះវាមានកូនចិញ្ចឹម ១ ឈ្មោះលីហ៊ោ ឯលីហ៊ោនោះ កំមានថ្ងៃដឹងខ្លាំង
ពូកែណាស់ តែថាសន្តានចិត្តអកតាំង ២ នេះ វាមែងវង្វេងស្រឡាញ់ទៅ
កង់រូបស្ត្រីភាពដែលស្អាតល្អ បើកូននឹងជួយទ្រទ្រង់ផែនដី ឪពុកនឹង
គិតឧបាយកលលើកកូនឲ្យទៅធ្វើជាកសិយាលីហ៊ោ ហើយទើបទៅប្រាប់
តាំងតុ:ឲ្យមកទទួលកូនយកទៅធ្វើជាកសិយាខ្មែត បើកូនបាន់ទៅនៅនឹង
តាំងតុ:វេលាណា ចូរលបធ្វើកលមាយាផ្សេងៗ ឲ្យលីហ៊ោមានចិត្តស្និទ្ធ
ស្រឡាញ់កូនជាប្រាកដ ហើយកូនលបប្រាប់តាំងតុ:ដោយកលមាយា
តាមដំរេះប្រាជ្ញារបស់កូនស្រាប់ យូរទៅឃើញថាតាំងតុ:នឹងលីហ៊ោមាន
សេចក្តីបែកចិត្តគ្នាតែប្រទូសរ៉ាយគ្នា លីហ៊ោគង់នឹងសម្លាប់តាំងតុ:ចេញ,
កាលអាសត្រូវវាជសម្បត្តិវិនាសហើយ អាណាខ្មែតាំងអស់ក្នុងព្រះនគរ
នឹងបានសេចក្តីសុខតទៅ ឯខ្លួនកូនដែលបានយកអាសាផែនដីនោះ នឹង

មានគេវ័ណ្ណោះពីកេះវាលែតអស់អាយុផែនដី ។ តុកគិតដូច្នេះតើកូនធំឯ
យល់ត្រមង្វើតាមដែរឬទេបង្គប់ ? ។

នាងតៀវសៀនឆ្លើយតបថា ខ្ញុំបានចេញវាចាថានឹងតបស្នងសង
គុណលោកតុកហើយ កុំថាឡើយតែត្រឹមរូបកាយខ្ញុំទៅធ្វើប៉ុណ្ណោះ
ទោះបីនឹងប្រើឲ្យទោស្ងាប់ក៏ខ្ញុំមិនស្តាយដីតែសង្ឃារ វេលានេះបើបិតានឹង
គិតកុហកយ៉ាងណា . ក៏ត្រូវតំណែលកឲ្យបានស្រេចធាប់។ ទៅចុះ បើខ្ញុំ
បានទៅទៅនឹងតាំងតុ:ហើយ ខ្ញុំនឹងធ្វើតលមាយាឲ្យលីចោ៉ាសម្លាប់តាំងតុ:
ឲ្យបាន ។ អង់អ៊ុនតបថា ! បើកូនបានយកអាសាផែនដីដំនួសទុកហើយ
តារ៉ូវ។ ដែលកូនគំនោះត្រូវបំពេញឲ្យជិតកុំឲ្យនរណាជឿពាក្យមួយ
ជា ២ ឡើយ កូនអើយរឿងនេះបើបែកធ្លាយចេញទៅកាលណា អាយុ
កូនឯងបិតាមុខជានឹងវិនាសរន្ធត់ឃើញទៅថ្ងៃមុខជាច្រាកជ ។ នាងតៀវ
សៀនបានស្តាប់ច្បាស់ក៏ឆ្លើយថា សេចក្តីនេះបើខ្ញុំមិនបិទបាំងតាំងធ្វើឲ្យ
បែកខ្ចាយហើយ ខ្ញុំសូមឲ្យត្រូវប្រហារដោយអាវុធផ្សេងៗចុះ ។ អង់អ៊ុន
បានឮពាក្យនាងធំពាក្យដូច្នោះហើយ ក៏មានសេចក្តីសោមនស្សត្រេកអរ
ពន់ពេក ។ លុះដល់ព្រឹកឡើង អង់អ៊ុនក៏ចាត់ចែងរើយកគ្រឿងពេជ
ន៍ឯងមាសច្បាក់មកទុក ហើយហៅជាងមកធ្វើជាមួកសម្រាប់បុត្រព្រះ
មហាក្សត្រែទ្រង់ពាក់ លុះធ្វើស្រេចហើយ ក៏ប្រើមនុស្សទំនុកទុកចិត្តឲ្យ
លបយកទៅឲ្យលីចោ៉ា។ ឃើញមួកដ៏វិសេសដូច្នោះទទួលយកហើយដោយ
សេចក្តីពេញចិត្ត លុះដល់ថ្ងៃក្រោយលបមកជូបនឹងអង់អ៊ុនទៅផ្ទះ ។(មានត)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - គ្រសេម រៀបរៀង

(តមក)

ការកសាង: ព្រះបាទសូរ្យវរ្ម័ន ទី ១ ទ្រង់បានសាងវត្តស្ថាន សម្រាប់ព្រះសាសនា និងសម្រាប់ពដការផែនដីជាយ៉ាងច្រើន, ប៉ុន្តែ តាមដែលស្រាវជ្រាវក្នុងវេលានេះ គឺ: ទ្រង់សាងវត្ត ១ នៅក្នុងកំពែងក្រុងយសោធរបុរៈ ឲ្យឈ្មោះថា "សោគតាស្រម" (អាស្រមព្រះសុគត) គឺវត្តដែលគេហៅក្នុងកាលឥឡូវនេះថា "ទេពប្រណម្យ" សឹងមានព្រះពុទ្ធរូបព្រះដ៏វិ ១ អង្គ, សន្ធឹកសីមាថ្មជាច្រើន និងសុំលាបាកែ ១ ផែនទៀត នៅក្នុងបរិវេណវត្តនេះជាតំស្តុតាង ។ តាំងទ្រង់ចជិសង្ឃរណ៍ប្រាសាទទេវស្ថានទៅលើកំពូលភ្នំបាខែង ដែលបានសាងឡើងតាំងពីក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ទី ១ គឺទ្រង់បានជួសជុលក្នុងផ្នែកខ្លះ ដែលបាក់បែកខ្ទេចខ្ទាម និង ទ្រង់កសាងថែមឡើងទៀតខ្លះ និង ទ្រង់រៀបចំធ្វើផ្លូវសម្រាប់ឡើងទៅកំពូលភ្នំនេះ ឲ្យបានស្រួលជាងមុន ព្រោះ

ភ្នំនេះជា **គារវិស្ថាន** ឬជា **ប្ញជនីយស្ថាន** របស់ព្រះមហាក្សត្រិយ៍ទាំងឡាយបណ្តាដែលគង់នៅក្រុងយសោធរបុរៈនេះ ។ រួចពីនេះស្តេចឡានៅសាងប្រាសាទរវាស្ថាននៅភ្នំដីសូរ ក្នុងខែត្រចាប៉ី សម្រាប់សាធារណជនគោរពប្តូរ, ប្រាសាទទៅស្ថាននេះគង់រួបពង់នៅដល់សព្វថ្ងៃនេះ ។

ក្រៅអំពីនេះ ព្រះអង្គឡានៅសាងនៅតាមបច្ចន្តរដ្ឋជាច្រើនអង្គទៀត, ចំពោះក្រុងយសបុរៈនោះប្រាកដថា ជាទីសព្វព្រះពុទ្ធហ្ឫទ័យច្រើនតែណ៎ះស្តេចយាងគោសម្រាក ព្រះកាយនៅទីនោះជាញឹកញយ ទ្រង់ឡានចាប់ពាត់ការរៀបចំតាំងពីក្រោយពេលដែលព្រះឡានអន្តរុទ្ធគតលើកមកហយ គឺទ្រង់ពង្រីកទីក្រុងឲ្យធំទូលាយចេញទៅ ទ្រង់សាងព្រះពុទ្ធរូបកំពង់កំពែង-ប៉មយ៉ាងមាំមួន សម្រាប់ការពារសឹកមកពីក្រៅ ទ្រង់សាងថ្កល់-ស្ថានជាច្រើនអង្គទៀត ។ នឹងទ្រង់សាងវត្តស្ថានក្នុងសាសនាទៀតជាយ៉ាងច្រើន ព្រះពុទ្ធរូប គឺព្រះស្ពូបចេតិយ វត្ត វិហារ, ព្រះទេវរូប ព្រះប្រាង្គសិលាកំពូលប៉ី ខ្ទីង សិលាចារឹក ។ បុពណវត្តស្ថានអំបាលនេះទៅគង់មានរួបពង់ជាច្រើនដល់សព្វថ្ងៃនេះជាច្រើន ។ ព្រះប្រាង្គនោះធំជាងព្រះប្រាង្គដែលសាងទុកទៅតំបន់ដទៃទាំងអស់, នេះជាអនុស្សាវរីយក្នុងសម័យដែលខ្មែរជាធំក្នុងដែនខ្មែរគោកវត្តី ។

លំដាប់តពីនេះ ឃុនស្តេចទៅសាងក្រុងកំពែងពេជ្រខៅកងរដ្ឋ
ដសៀង ហើយប្រហែលផ្ទាស់ឈ្មោះក្រុងនេះហៅថា **ឧគរកោសម្ពិ**
កងពេលនេះផង ព្រោះទីនោះមានសណ្ឋានគូមិភាគប្រហែលគ្នានឹង
នគរកោសម្ពី កងមជ្ឈិមប្រទេស ។ តែសព្វថ្ងៃនេះ គេច្រើនហៅ
កំពែងពេជ្រតាមដើម ។

ចំណែកឯព្រះកំស្តេងអញ្ជើសដយេន្ទូបណ្ឌិត ក៏ឃានតសាងវត្ត-
ស្ថានកងសាសនា នឹងរបស់ជាសាធារណប្រយោជន៍មានដីតស្រះ ដីត
អណ្តូង ផ្លូទំនប់ទឹក ។ល។ ជាច្រើនណាស់ដូចមានប្រាកដខៅ
សិលាចារិក កងស្តុកកូម្ពុជស្រាប់ ។

ព្រះឃុនសូរ្យវរ្ម័ន ទី ១ ស្តេចនៅកងរាជសម្បត្តិឃាន ៣៨ ឆ្នាំ ក៏
សោយទិវង្គតរាជឬណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា **បរមនិរ្វាណបទ**
(បរមនិព្វានបទ) ដោយហេតុទ្រង់និយមកងព្រះពុទ្ធសាសនាជាសំខាន់
កងព្រះរាជហ្ឫទ័យ ។

ទ្រង់មានព្រះកិត្តិយសជា រាជាធិរាជ ១ អង្គកងប្រវត្តិសាស្ត្រ ។

ព្រះឋានន្ទនយាទិត្យវរ្ម័ន ទី ២

ព.ស. ១៥៩៣ - ១៦០៨, គ.ស. ១០៥១ - ១០៦៦

ព្រះឧទយាទិត្យវរ្ម័ន ជាព្រះរាជឧរសរបស់ព្រះឃុនសូរ្យវរ្ម័ន ទី ១
នឹងព្រះនាង វីរលក្ស្មី អគ្គមហេសី, ទ្រង់ប្រសូតកងសករាជប៉ុន្មានមិន

ច្បាកដ ខ្ញុំបានសំភ្សាវន្តាគ្រប់យ៉ាង មានដើមថា សិទ្ធន្ត, វ្យាករណ៍, ធម៌សាស្ត្រ ទឹងសាស្ត្រឯទៀត។ ក្នុងសំណាក់ព្រះរាជគ្រូ ស្រីដយេន្ទ្រ បណ្ឌិត ។ កាលព្រះរាជដនតមាថសោយទំវង្គតហើយ ខ្ញុំបានទទួលគ្រងរាជសម្បត្តិស្នងព្រះអង្គតមក, គេថ្វាយព្រះបរមនាមថា ព្រះបាទ ចន្ទយាទិត្យវរ្ម័ន រាប់ជាទី ៦ ។ ខ្ញុំមានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនច្បាកដ តែខ្ញុំគ្នាមព្រះរាជនុសព្រះពាជធីតាទេ ។

ការផែនដី: ការគ្រប់គ្រងផែនដីក្នុងវង្សកាលមេះមិនច្បាកដថាចូចចាតផែនដីកន្លងភាគណាមួយទេ តែះគ្រាយដែលខ្ញុំសោយរាជ្យបាន ១ ឆ្នាំ គឺក្នុងឆ្នាំ ៣ ស ១៤៨ មានរាជសត្រូវឈ្មោះ អាណាវិន្ទ្រាជ រួបរួមសេនាចាហានបង្កហេតុបះបោរឡើង ក្នុងព្រះរាជអាណាចក្រដើម្បីរាជបល្ង័ង្ក, ព្រះបាទចន្ទយាទិត្យវរ្ម័នខ្ញុំជ្រាប ក៏គ្រាស់ឲ្យសេនាបតី ១ នាក់ ឆ្ការជា ព្រះសង្ក្រាម (គឺជាសេនាបតីក្រសួងសឹក) ឲ្យលើកទ័ពចេញទៅកម្ចាប, កងទ័ពទាំងពីរខាងបានតស៊ូគ្នាតេញទំហឹង តែកងទ័ពបំផុតអាណាវិន្ទ្រាជបរាជ័យ ហើយរត់ទៅជ្រកទៅក្នុងចម្ប៉ា (ចាម្ប៉ា) ប៉ាត់ទៅ ។

លុះកន្ទងមកដល់ឆ្នាំ ព. ស. ១៦០៩ (ម. ស. ៨៨៨) មានមន្ត្រី ១ នាក់ជាចាហានរបស់ព្រះអង្គ ឈ្មោះកាមភាវៈ ជាទីប្រឹក្សាឆ្ងាណរបស់ព្រះអង្គ ប្រាន់ក្រាបទូលញុះញង់ឲ្យខ្ញុំដកសេនាបតី ១ នាក់

អ្នកមានអាយុខ្ពស់ ចេញពីតំណែងពជការ ដោយបំណងនឹងចូលកាន់តំណែងនោះដោយខ្លួនឯង ។ ព្រះបាទទ្រង់យាងទៅព្រះវត្តនិ ពុំព្រមតាម ។ តាមការ: ទោមនស្សផ្ទង់កំយ៉ខ្លួនឯង ក្រែងព្រះមហាក្សត្រិយ៍រកឿនកំនាំពួកគាហានដែលទៅតង់បង្កាប់របស់ខ្លួនចេញទៅខែត្រក្រៅ ហើយបញ្ជូនបញ្ជូលពស្ត្រចង្កដាទំពាំបន់ចោរឡើង ព្រះមហាក្សត្រិយ៍ទ្រង់ជ្រាប ក៏គ្រាស់ចាត់មេទ័ព ១ នាក់ឲ្យលើកទ័ពចេញទៅតម្រាប តែមេទ័ពនោះតស៊ូពុំបាន កំបរាជ័យក្រឡែជីវតបង់ ។ តាលព្រះមហាក្សត្រិយ៍ទ្រង់ជ្រាបពត៌មានសឹកដូច្នេះហើយ ក៏ទ្រង់ព្រះរាជបញ្ជាក្សត្រិយ៍សឹក (១) (សេនាប្រមុខ) ១ នាក់ ដែលធ្លាប់មានច្បាំងដែ ឲ្យនាំទ័ពចេញទៅតម្រាប ។ រំលាដែលក្សត្រិយ៍សឹកនេះទៅដល់តស៊ូគ្នានោះ មានមេកង ១ នាក់ខាងខ្មាំង ឃុនចាក់ត្រូវក្សត្រិយ៍សឹកធ្លុះបង្កា, ព្រះក្សត្រិយ៍សឹកនោះទោះបីត្រូវប្លុសម្ល៉ះហើយក៏ដោយ ក៏មិនរំភើបឃុនប្រឹងតស៊ូតទៅទៀតយ៉ាងអង់អាច គឺលោកប្រើឆ្កែដំយរបស់លោកឃាញចេញទៅយ៉ាងញឹក ក្ងូនសរឃុនរត់ទៅត្រូវត្រង់ក្បាលការ: ១ អន្ទើ ទឹងត្រង់ក ១ អន្ទើទៀត; ការការ: ទ្រាំរបួសពុំបាន ក៏ដួលគ្រែងតាំងគ្រឿនអាវុធដែលកាន់នៅដៃ មិនយូរប៉ុន្មានក៏អស់ឮលំអស្សាស: បស្សាស: ទៅតាមយថាកម្ម ។

---

១ ក្សត្រិយ៍សឹកនេះ ប្រហែលជាព្រះសង្គ្រាម ដែលជាសេនាបត៌ាហរ ។

កាលស្រែចកំចូកម្រាបស៊ីកសត្រះហើយ លោកក្សត្រិយ៍សឹកក៏រៀបចំ
ខែត្រនោះ (មិនដឹងឆ្នាំសំណាខែត្រណា) ឲ្យរៀបរយដូចដើមហើយ
ទើបបានលើកទ័ពត្រឡប់ចូលក្រុង ។ កាលមកដល់ក្រុង ក៏មាន
ចុប្បត្តិហេតុ ១ ជាថ្មីទៀតមកប៉ះរាល់ គឺមានបងប្អូនពីរនាក់ ឈ្មោះស្វាត
ស្វាគត់? ១ ឈ្មោះ សិទ្ធិករ ១ ឃុនលើកគ្នាមកចាំប្រទូសរ៉ាយ លោក
ក្សត្រិយ៍សឹកបានបញ្ជាឲ្យគាហានចោមព័ទ្ធចាប់បច្ចាមិត្រទាំងពីរ តែវា
រៀកចំណោមចេញរួចទៅ ឃុនទាំងសម្លាប់គាហានរបស់លោកអស់ជា
ច្រើនឆ្ងាយ ។ លោកក្សត្រិយ៍សឹកជាបក់ចេញដេញចាំងដោយខ្លួនឯង
ចាប់បានតួទាំងពីរប្រហារដំរីតបង[1] ហើយលោកនាំទ័ពចូលក្រុង ។
អំពីនោះប្រទេសក៏បានសាន្តត្រាណជាប្រក្រតី ។

ការសាសនា : ព្រះចៅ ... យាទិត្យវ័ន្ទ ទ្រង់កាន់ទាំងសាសនា
ព្រាហ្មណ៍ទាំងព្រះពុទ្ធសាសនា តែទ្រង់និយមខាងសាសនាព្រាហ្មណ៍
ដែលជាសាសនាសម្រាប់ផ្លូវរឹងសម័យនោះធ្ងន់ជាង ទ្រង់ចាត់តំស្តេងអញ
ស្រីជាយន្តិចណ្ឌិត ជាពូជបុរោហិតចាស់តាំងពីរជ្ជកាលព្រះរាជបិតាមក
ហើយជាព្រះរាជគ្រូរបស់ព្រះអង្គជាន់នោះ ជាទីប្រឹក្សាការផែនដី ទឹង
ផ្ទៃពិធីផ្សេងៗ ថ្វាយតាមទំនៀម ទ្រង់គោរពព្រះមហាក្សត្រីនេះខ្លាំង
ណាស់ ... ទ្រង់ព្រះមេត្តាតាំងឲ្យឡើងយសសក្តិជា "ព្រះកម្រែតេង

---

១ បើងក្បាត់នេះគេឃើញក្រាបដំនៅសំណាកដែលបច្រែតស្ថានទុកនៅវត្តព្រះដែក
ក្នុងកំពែងព្រះមហានគរ ។

អញ ស្រីជយេន្ទ្រវរ្ម័ន" មានយសសក្តិធំជាងភជបុរោហិតក្នុងរជ្ជកាលមុនទាំងអស់ ការស្តីនិយាយតោងប្រែភជសព្ទជួចជាស្តេច ។ ភជបុរោហិតនេះហើយដែលបានសាងសិលាចារឹកនៅស្តុកកូម្ម និយាយរៀបរាប់រឿងភ័ស្តុតាងតាមដោយព្រះភជពង្សាវតារ តាំងពីរជ្ជកាលព្រះបាទជយវរ្ម័នទី ២ រៀងមកដល់ផុតរជ្ជកាលព្រះបាទយោគិស្វរ្ម័នទី ២ នេះ ហើយលោកស្ងាប់ក្នុងរាជរជ្ជកាលនេះ ។

ក្នុងរជ្ជកាលនេះមានសេនាបតីធំ ១ នាក់ ឈ្មោះ "ព្រះសេនាបតីសង្គ្រាម" ជាអ្នកមានចូរដៃក្នុងការសង្គ្រាមធ្លាប់មានជ័យជំនះមកហើយ ជាអ្នកកាន់ព្រះពុទ្ធសាសនា បានសាងវត្តដែលតាក្យសាម័ញ្ញហៅ "ព្រះធោត" នៅក្នុងកំពែងក្រុងស្រីយសោធរបុរៈ នៅជាខាងលិចប្រាសាទយសោធរតារី (ប្រាយ័ន) មានឪតា ១ នាក់ ឈ្មោះ នាង ។ បាជាអ្នកកាន់ព្រះពុទ្ធសាសនាបែបយ៉ាងបិតា ។

ការព្រះពុទ្ធសាសនាដែលប្រាកដក្នុងប្រវត្តិសាស្ត្រ ហើយដែលយើងត្រូវទុកជាសំខាន់បំផុតមួងទៀត គឺក្នុងរជ្ជកាលនេះ ក្រោយដែលព្រះអង្គសោយរាជ្យបាន ៣ ឆ្នាំ ក៏ទទួលបានគម្ពីរព្រះត្រៃបិដក និងព្រះពុទ្ធរូបព្រះកែវមរកត(១) ដែលខ្មាត់ខ្មាន់ចូលមកក្នុងព្រះរាជអាណាចក្រ (ក្នុងឆ្នាំ ព.ស. ១៥៨៦) ។

---

១ ប្រវត្តិព្រះកែវមរកតមានសេចក្តីឥតស្ថិរនៅក្នុងរតនពិម្ពវង្ស ។

រឿង ព្រះវិន័យ ទីន ព្រះវិន័យមកតដែលភ្ជាប់មកប្រទេសកម្ពុជានេះ ប្រាកដក្នុង ព្រះពុទ្ធវចនៈ ព្រះបាទអនុរុទ្ធ ក្សត្រិយ៍ភូមា សោយរាជសម្បត្តិនៅក្រុងភុកាម (បុណ្ណាការ) ក្នុងរវាង ព. ស. ១៥៩៣ ដល់ ១៥៩៩ ព្រះអង្គជាអ្នកដែរថ្វាយក្នុង ព្រះពុទ្ធសាសនា មានព្រះរាជក្រមថ្វាយ ដ៏ខ្ពស់ក្នុងការទំនុកបម្រុង ព្រះពុទ្ធសាសនា ។ ក្នុងមួយនោះ ព្រះអង្គបានផ្ញើអ្នកប្រាជ្ញចាំងអ្នកដែលដំនាញការសរសេរចារ ក្នុងសំណៅ ធំ ២ ហើយបើកសំណៅទៅលង្កា ដើម្បីចម្លងគម្ពីរព្រះវិន័យបិដក ។ កាលចម្លងចប់ហើយ ក៏បានសូមយកព្រះវិន័យមកត អំពីព្រះបាទលង្កិស្សរាជ (ព្រះរាជាក្រុងលង្កា) មកឯង ដែរដ៏ឲ្យផ្ញើគម្ពីរព្រះវិន័យបិដកនឹងព្រះវិន័យមកតក្នុងសំណៅ ១ ហើយឲ្យរាជបរិពារខ្លះដែរក្នុងសំណៅនោះ, ចំណែកព្រះអង្គគង់ក្នុងសំណៅ ១ ទៀតជាមួយរាជបរិពារខ្លះ បើកត្រឡប់ព្រះនគរវិញ លុះបើកផុតកោះម៉ាលការមកហើយ ក៏បត់បែរមកទិសខាងជើងសំដៅមកប្រទេសភូមា តែជួនវេលានោះ មានខ្យល់ព្យុះខ្លាំង បោកផាត់សំណៅដែលផ្ញើព្រះវិន័យបិដកនឹងព្រះវិន័យមកត រសាត់ជ្រុលចូលមកដល់ប្រទេសកម្ពុជា គឺចូលមកត្រង់ជាយខែត្របន្ទាយមាសខាងត្បូង (ត្រង់ហាទៀង) អ្នករាជការខែត្រនេះចាប់បាន ក៏នាំទៅថ្វាយព្រះករុណាព្រះបាទយ៉ាទិត្យវង្ស ដែរដ៏មានព្រះរាជហឫទ័យសោមនស្សខ្លាំងណាស់ ។

នៅលើកំពូលភ្នំព្រះពាជទ្រព្យ ស្រុកទុង្គ ខេត្តកណ្តាល

អ្នកអង្គម្ចាស់ក្សត្រី នរោត្តម-សុខានារី

ធ្វើការនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

(រង្វាន់លេខ ២)

ប្រទេសកម្ពុជាយើងចាំងមូល គេតែងធ្វើព្រះវិហារបែរមុខឆ្ពោះទៅទិសខាងកើតចាំងអស់ ពុំដែលមាននរណាមួយធ្វើវត្តធ្វើព្រះវិហារបែរមុខទៅទិសដទៃឯទៀតឡើយ ។ សេចក្តីនិយមប្រកាន់តាមទំនៀមទម្លាប់អំពីបូរាណមកនេះ ព្រោះគេយល់ឃើញថា ព្រះពុទ្ធអង្គកាលនៅវេលាដែលទ្រង់ចាត្រាស់សម្មាសម្ពោធិញ្ញាណ ទ្រង់គង់បែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងកើត ។

ប៉ុន្តែអ្នកចាំងឡាយចាំនសង្កេតឃើញទេ? នៅក្នុងប្រទេសខ្មែរយើងចាំងមូល មានតែព្រះវិហារមួយទេដែលគេធ្វើបែរមុខឆ្ពោះទៅទិសខាងជើង ដែលអ្នកស្រុកយើងពុំធ្លាប់និយមធ្វើយ៉ាងនេះសោះ ។ ព្រះវិហារនោះ ឈ្មោះថា "អដ្ឋារស" សាងនៅលើកំពូលភ្នំព្រះពាជទ្រព្យ ក្នុងស្រុកទុង្គ ខេត្តកណ្តាល ។ សេចក្តីចំឡែកប្លែកអស្ចារ្យនេះហើយ ដែលនាំឲ្យខ្ញុំកើតអំណល់រវល់នៅពុំសុខដើរស៊ើបសួរអ្នកដែល

ខ្ញុំស្គាល់តាំងប៉ុន្មាន ដែលធ្លាប់ស្គាល់ថាជាអ្នកចេះដឹងខាងទំនៀមទម្លាប់ របស់ខ្មែរយើងអំពីបុពណ ហើយមិនយូរប៉ុន្មាន ខ្ញុំក៏បានដឹងដូចបំណង ។

អ្នកត្រឹង្គាខាវ្យដែលប្រាប់និទានរឿងនេះ ច្បាប់ខ្ញុំ គឺជាព្រះពជវង្ស-នុវង្សមួយព្រះអង្គ ទ្រង់ជាកណាស់ទៅហើយ កាលពីដើមទ្រង់គង់នៅភ្នំពេញដែរ តែក្នុងរវាងប៉ុន្មានឆ្នាំនេះ ទ្រង់ស្តេចទៅគង់នៅឧដុង្ក ។ កាលពីដើមទ្រង់ធ្លាប់ស្គាល់តែសេចក្តីរុងរឿង សេពគប់តែនឹងចំណោមធំ គាល់ចំពើព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ យ៉ាងជិតដិតញឹកញាប់ ហើយធ្លាប់ស្តេចទៅមកពាក់អានឹងមន្ត្រីធំៗ រដ្ឋមន្ត្រីឯទៀតជាច្រើន ។ ហេតុដែលខ្ញុំមិនចេញព្រះនាមនេះ ដោយទ្រង់តុំយល់ព្រមផង ។ ទ្រង់សព្វព្រះទ័យតែសេចក្តីស្ងប់ស្ងាត់តុំឲ្យមានអ្នកណាទៅរំភួនរំភើនដល់ទ្រង់ឡើយ ។ សេចក្តីដែលមានតទៅនេះ គឺជាព្រះបន្ទូលរបស់ទ្រង់ :

កាលទៅក្នុងសតវត្សរ៍ ១៣ គឺទៅក្នុងសម័យអង្គរ ព្រះចៅប្រទេសចិនទ្រង់ចាត់ទេសកជនជាច្រើនក្រុមឲ្យដើរមើល ស៊ើបសួរក្នុងប្រទេសនានា តើបណ្តាជនមានអារ្យធម៌ប្រៀបណាខ្លះ ។ បើអារ្យធម៌ប្រទេសណាប្លែកឆ្ងើងរុងរឿងនោះ ត្រូវលួចកត់យកមកប្រគិបត្តិផ្សាយក្នុងប្រទេសចិន, បុប្រទេសចិនទទឹងសុំចងសម្ពន្ធមិត្តនឹងប្រទេសនោះ ។

បើប្រទេសណាហើយប្រកបដោយនូវអារម្មណ៍ដ៏ខ្ពស់អាប់ ប្រទេសចំនួនទឹក
គិតរំខុកបំរុងឬមួយយកឆ្នើជាប្រទេសចំណុះ ។

កាលនោះ ក្រុមទេវតាជនចិន ឃ្លានចូលមកមើលស៊ើបសួរក្នុង
ប្រទេសខ្មែរយើងសព្វគ្រប់ហើយ ក៏ត្រឡប់ទៅទូលព្រះចៅក្រុងចិនវិញថា
"ប្រទេសខ្មែរជាប្រទេសប្លុំច្រើងរុងរឿងមានឥទ្ធានុភាព តែឥឡូវនេះបុះ
អាប់ខ្ពស់ជាងកាលពីមុនបន្តិចហើយ, អ្នកស្រុកនៅដើរដើងទេ, បរិភោគ
អាហារនឹងដៃ, ក្បាលទេ, ពុំសូវឃើញមានប្រើប្រាស់អ្វីឲ្យឃ្លានងាយ
ស្រួលទេ, ប៉ុន្តែមិនយូរប៉ុន្មានទេ ប្រទេសខ្មែរមុខជានឹងជួបប្រសព្វ
នឹងសេចក្តីវិបត្តិធ្ងន់ធ្ងរវិញលើសរដើមជាអស្ចារ្យ" ។ ព្រោះថាពួកទេវតា-
ជនទាំងនោះឃ្លានមកឃើញទីមួយកន្លែង ដែលតាមក្បួនចិនសែថា ទីកន្លែង
នោះអាចនឹងឲ្យផលល្អផ្សេងៗ ដល់ប្រទេស ។ ទីកន្លែងនុ៎ះ គឺក្នុងព្រះ
រាជវាំងយើងសព្វថ្ងៃ ដែលនៅក្នុងស្រុកខ្មែរដូច្នឹង ។ ពួកទេវតាជនឃ្លាន
មើលឃើញកុំនេះមានពន្លឺដូចជាសត្វមករ គឺតួខ្លួនសត្វមកនៅត្រង់ចេតិយ
ត្រៃត្រឹង្ស, ក្បាលនឹងពុកមាត់មកនៅត្រង់ចេតិយទន្ទឹម, រីឯកន្ទុយមក
នៅត្រង់ព្រះពុទ្ធរូបចូលនិព្វាន ។ មិនត្រឹមតែប៉ុណ្ណោះទេ នៅលើកំពូលក្តោ
ថែមទាំងមានរូងមួយធំជ្រៅស្រឡងចុះទៅក្រោមផង ។ ពួកចិនយល់
ឃើញថា មិនយូរប៉ុន្មានសត្វមកនឹងកំរើកចេញមកតាមរូងនេះ ហើយ
តាមក្បួនចិនសែថា បើប្រទេសឯណា ឬ ទីឯណាមានសត្វមកឆ្លុះឡើង

ប្រទេសខោះរីខោះ ខ្ញុំមានវិធីអំណាចថ្កុំថ្កើងរុងរឿងអស្ចារ្យ ពុំមាន ប្រទេសឯណាអាចនឹងតស៊ូប្រកាន់ខ្ជាប់ ។ ដូច្នេះ ដើម្បីជាសេចក្តីសុខ ដល់ប្រទេសចិនទៅអនាគត មន្ត្រីចិនគាំងឡាយខ្ញុំលស្តេចចិនសូមឲ្យ លើកទ័ពមកកាយយកប្រទេសខ្មែរធ្វើជាចំណុះឲ្យហើយ ។ ស្តេចចិនត្រេង ត្រាំតំរិះថា ធ្វើយ៉ាងនេះយើញដូចជារំលោភលើប្រទេសខ្មែរពេកណាស់, ម្យ៉ាងទៀតប្រទេសខ្មែរនៅខ្ទាំងពូកែចំបើងនៅឡើយ ប្រទេសចិនពុំអាច ទ្រាំកាយយកបានដោយងាយទេ បើទោះបីប្រទេសខ្មែរគង់តែច្បាំងចាញ់ ប្រទេសចិនក៏ពិតមែនហើយ ប៉ុន្តែប្រទេសចិនមុខជាលំបាកវេទនាខ្លួន អស់ពលយោធា មានទុក្ខវេទនាដល់បណ្តាជនមិនខានឡើយ ។ ដូច្នេះ, ស្តេចក្រែងចិនត្រេងត្រាំតំរិះរកកលឧបាយផ្សេងៗទៅវិញ ។

ដំបូងឡើង, ដើម្បីទប់ឃាត់កុំឲ្យប្រទេសខ្មែរបានលួតលាស់តទៅ ទៀត, ពួកចិនគិតសន្ធប់រូងក្នុងឲ្យដិត កុំឲ្យសត្វមករចេញមកបាន ។ លើយកដុំថ្មសន្ធប់រូងនោះ ខ្លាចក្រែងថ្មក្រោយមកខ្មែរយល់គំនិតនឹងគាស់ ចេញវិញបាន ។ លើដូច្នេះ ពួកចិនស៊ើបទៅឃើញថាប្រទេសខ្មែរកាន់ព្រះ ពុទ្ធសាសនាមុតមាំណាស់ នៅវិហារណាដែលមានព្រះពុទ្ធរូប, មានព្រះ វិហារ ខ្មែរពុំហ៊ានទៅរំលាងរំលើងទីនោះទេ ។ ដោយហេតុនេះហើយ បានជាស្តេចក្រែងចិន ឲ្យមន្ត្រីចិនមកសុំធ្វើព្រះវិហារនៅលើកំពូលភ្នំនេះ ។

ដំបូង, ពួកចិនចាប់កសាងព្រះពុទ្ធរូបមុនគេ រួចតមក ទើបបានធ្វើ ព្រះវិហារនឹងសីមាតាមទម្លាប់នៅមុខអ្នកស្រុក ត្រមាំងតាមក្បួនហោរ-

សាស្ត្រចិនផង ហេតុនេះហើយបានជា ព្រះវិហារនោះបែរមុខឆ្ពោះទៅទិសខាងជើង គឺឆ្ពោះទៅរកប្រទេសចិន ។ នាមព្រះវិហារ យើងពុំដឹងជាភ្លូកចិនឲ្យឈ្មោះដូចម្តេចទេ តែជនជាតិខ្មែរ ដោយឃើញព្រះពុទ្ធរូបធំអស្ចារ្យមានកំពស់ ១៨ ហត្ថ ក៏នាំគ្នាហៅថា "ព្រះវិហារ'អង្គារស" ។ តមកស្តេចក្រុងចិនឲ្យមន្ត្រីចិននាំប្រស្នា ៣ ខមកថ្វាយព្រះរាជាប្រទេសខ្មែរដោះស្រាយ បើដោះស្រាយប្រស្នាពុំ ៣ នេះពុំបាន នោះប្រទេសខ្មែរត្រូវទៅចំណុះប្រទេសចិន ត្រូវយកសួយសារអាករទៅថ្វាយស្តេចក្រុងចិនរាល់ឆ្នាំ ។ ឯប្រស្នារបស់ស្តេចក្រុងចិនទាំង ៣ នោះ ដូចមានតទៅនេះ

ដំបូង, មន្ត្រីចិនម្នាក់ដែលជាអ្នកនាំប្រស្នាពីស្តេចក្រុងចិន មកថ្វាយស្តេចខ្មែរឲ្យដោះស្រាយនោះ គ្រោតឈរឡើងចំពោះព្រះកន្ត្រៃព្រះរាជាខ្លួនអស់មន្ត្រីខ្មែរទាំងឡាយ ហើយធ្វើអាការដូចតទៅនេះ ។

ប្រស្នាទី ១ មន្ត្រីចិនចំកោងខ្នង លាដៃទាំងពីរ ធ្វើរបៀបដូចនុបរបស់អ្វីយ៉ាងធំ ។

ប្រស្នាទី ២ មន្ត្រីចិនក្តាប់ដៃម្ខាង លើកឡើងកំពស់មុខ ។

ប្រស្នាទី ៣ មន្ត្រីចិនបោះដៃម្ខាងត្រង់ទៅមុខ ហើយលាមដៃទាំង ៥ ក្រញ៉ាង ។

ហើយថ្វាយកាលកំណត់ស្តេចខ្មែរថា ៧ ថ្ងៃទឹងត្រឡប់មកគាល់សុំព្រះពុទ្ធានុសេចក្តីដោះស្រាយ ។ (មានត)

ប្រវត្តិរបស់អេសុប

លោក ផេង-ជ្រៃ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារីភ្នំពេញ

ប្រែរៀបរៀង

អេសុបជាកវីជាតិក្រិក កើតនៅដែនហ្វ្រីស៊ី (phrygie) ក្នុងភូមិមួយឈ្មោះអាមូរីយុម (Amorium) ប្រហែលជាពីរយៈឆ្នាំ ក្រោយការកើតឡើងនៃនគរោម (Rome) បើគិតទៅត្រូវជា ១៤៦ ឆ្នាំ ក្រោយព្រះពុទ្ធយើងបានត្រាស់ ហើយត្រូវជា ៥៥៤ ឆ្នាំមុនគំរើតនៃព្រះគ្រិស្ត ។

អេសុប គេមិនដឹងជាលោកត្រេកអរឬតូចចិត្តនឹងឋានៈរបស់លោកឬដូចម្តេច? ព្រោះគំនិតនឹងប្រាជ្ញារបស់លោកមានបរិបូណ៌ ប៉ុន្តែកាយរបស់លោកវិកលវិការ មុខអាក្រក់ ស្ទើរតែមិនមែនជាមុខមនុស្សដូចគេឯងសោះ ហើយលោកថែមទាំងដំឡង់ផង ។ បើយ៉ាងដូច្នេះ ក្រៅតែពីទៅនៅស៊ីឈ្លួសអ្នកដទៃ លោកមិនដឹងនឹងរកអ្វីចិញ្ចឹមខ្លួនបានឡើយ, ទោះបីយ៉ាងដូច្នេះក៏ដោយ ចំណែកចិត្តរបស់លោកតាំងនៅមាំជាចិត្តស្មើជាចិត្តគ្មានជាប់ចំពាក់នឹងវត្ថុអ្វីៗ ទាំងពួងក្នុងលោក ។

ចៅហ្វាយនាយរបស់លោក ដើមដំបូង បញ្ជូនលោកឲ្យទៅក្លាដើឯចំការ, ដែលគេឲ្យទៅដូច្នេះ ប្រហែលជាគេគិតថាលោកមិនប្រសប់ខាងការផ្ទះ ឬមួយគេឲ្យចេញឲ្យតែបាត់ពីមុខគេ ដ្បិតរូបលោកអាក្រក់ពេក ។ ពេលមួយចៅហ្វាយរបស់លោកនៅឯចំការ, មានអ្នកស្រែម្នាក់យកផ្លែក្រឡុបមក

ដូន ១ លោកកុដ្ដមីត៍ឃើញផ្លែឈើល្អពេញចិត្ត ក៏ប្រាប់ឲ្យបាវម្នាក់ឈ្មោះ អាគាថូពុះ (Agathopus) យកទៅខុតដាក់ឲ្យស្រួល លុះកាលណាលោកឆ្អែតទឹកហើយ ឲ្យយកមកជូនលោកបរិភោគ ។ ខេសកាលអ៊ី ពេលនោះនាំឲ្យអេសុបមានការណ៍ចូលទៅកន្លែង ។ បានលេសបន្តិចប៉ុណ្ណឹង អាគាថូពុះ បបួលគ្នាវាស៊ីផ្លែក្រឡុបអស់ ហើយទំលាក់ទោសទៅលើអេសុប ព្រោះស្មានថាលោកអេសុបត្រូវពុំឃើញ ព្រោះលោកនិយាយជាប់ៗ ហើយដូចជាគ្មើគ្មៃផង ។ មនុស្សសម័យពីដើមធ្វើទោសខ្ញុំកំដរអត្រកំណាស់ ហើយក្នុងរឿងនេះ អេសុបប្រាកដជាត្រូវមានជាប់ពាក់ព័ន្ធយ៉ាងធ្ងន់ ។

អេសុបលុតជង្គង់សំពះចៅហ្វាយនាយ ហើយទំនិយាយធ្វើដៃជាសញ្ញាឲ្យយល់ថា លោកសូមពរឲ្យគេព្យរទោសមួយស្របក់សិន ។ លោកកុដ្ដមីត៍ស្តាប់បានយល់ត្រមតាម, អេសុបរត់ទៅរកទឹកក្តៅអ៊ុនៗ យកមកផឹក នៅចំពោះមុខចៅហ្វាយនាយ ហើយយកម្រាមដៃលូកក្នុងបំពង់កឲ្យក្អួត គេឃើញសុទ្ធតែទឹកជាដែលចេញមកវិញ, គ្មានឃើញផ្លែក្រឡុបសោះ ។ រួចហើយ អេសុបធ្វើសញ្ញាឲ្យម្ចាស់របស់លោកបង្គាប់អាប៉ុន្មានអ្នកឲ្យធ្វើដូចលោក ។ អ្នកវាល់គ្នាសង្ស័យហើយគិតថា ចំណេះហ្នឹងមិនមែនជាចំណេះដោះខ្លួនរួចទេ ។ ពួកអាប៉ុន្មាននាក់ដូចជាគ្មានភ័យសោះ ក៏នាំគ្នាផឹកទឹកក្តៅហើយធ្វើដូចអេសុប ស្រាប់តែខ្លួតមកសុទ្ធតែផ្លែក្រឡុបនៅស្រស់ញ៉ាញ៉ឹម ។ ពួកអាគាថូពុះត្រូវមានទោសជាទ្វេគុណ ដែ ទី ១

ដោយលួចស៊ីផ្លែក្រឡុក, ទី ២ ដោយចិត្តឥតគ្រប់ផ្ទៃរោសដាក់លើគេ, ចំណែកអេសុបរួចរោស ។

ព្រឹកឡើងលោកកុដុម្ពីក៍ត្រឡប់ទៅផ្ទះវិញ, អេសុបនៅធ្វើការតាមធម្មតា ។ មានអ្នកដំណើរ ៣-៤ នាក់វង្វេងផ្លូវ ហើយមកអង្វរឲ្យអេសុបអាណិតបង្ហាញផ្លូវដែលទៅកាន់ទីក្រុងធំ ។ អេសុបឃើញដូច្នោះក៏ឲ្យអ្នកដំណើរនោះសម្រាក់នៅក្រោមម្លប់ឈើសិន ទៅរកទឹកយកមកឲ្យផឹកដើម្បីឲ្យបាត់ស្រេក, លុះកិច្ចនេះរួចហើយ ទើបលោកនាំអ្នកវង្វេងផ្លូវទៅដាក់នៅផ្លូវធំជាស្រេចបានលោកត្រឡប់មកវិញ ។ អ្នកដំណើរមុនទីឆ្ងៀសចេញទៅ លើកដៃទៅលើតាំងសច្ចាថា "សូមខ្ញុំពាំងឡាយនៅទីនេះកុំមើលបំណាំ ទុកសេចក្តីល្អនៃឈ្មោះនេះឲ្យនៅឥតផុត" ។

អេសុបគ្រាន់តែចេញផុតពីអ្នកដំណើរបានបន្តិច ក៏ចូលទៅដេកក្រោមម្លប់ឈើមួយដើម ព្រោះថ្ងៃក្តៅខ្លាំង ហើយអស់កំឡាំងផង ។ កំពុងដេកលក់ លោកយល់សុបិន៍ឃើញដូចមានបុរសម្នាក់ មកលាអណ្តាតរបស់លោកឲ្យនិយាយរួចដូចមនុស្សផងទាំងពួង លោកកំពុងតែសប្បាយចិត្ត លុះភ្ញាក់ឡើងហើយនឹកអង្វរចិត្តថា "យី ឥឡូវសំដីរបស់អញ គ្មានជាប់ខេតើ! អញហៅវានាស់ក៏ច្បាស់ នង្គ័លក៏ច្បាស់តាមចិត្តចង់" ។ ការណ៍អស្ចារ្យនេះ នាំឲ្យអេសុបផ្ទាស់នាយទៅហ្វាយថ្មីទៀត ព្រោះមេតំរូវនៅធ្វើចំការខ្វាចខ្លួនក្រែងរឿងដែលវាបានធ្វើបាបគេនោះ នឹងដឹង

ដល់ចៅហ្វាយនាយ ដ្បិតវាជាអ្នកត្រួតលើកូនឈ្នួល មើលការណ៍ខុសត្រូវ ហើយជាអ្នកសន្សំទោសផង ។ ពីថ្ងៃមុនវាបានធ្វើបាបកូនឈ្នួលម្នាក់មិនត្រូវតាមច្បាប់ កំហុសនេះវាស្មានថា អេសុបពុំនៅស្ងៀម មុខជាយកទៅប្តឹងលោកកុដ្ឋម៉ក់ជាមិនខាន ។ ដើម្បីនឹងបំបាត់រឿងខុសត្រូវនេះ ហើយនឹងការសងសឹកខ្លួនវា វាដំរាបលោកកុដ្ឋម៉ក់ថា "ឥឡូវនេះមានហេតុផ្សែកកើតឡើងក្នុងផ្ទះលោក គឺថាអេសុបចេះស្តី ចេះនិយាយហើយៗមុខជានិយាយដើមពីលោកជាមិនខាន" ។ លោកកុដ្ឋម៉ក់ ឮដូច្នោះហើយ ដឿនិយាយថា: "ចូរឯងប្តឹងថា: បើវាចង់ទៅណាក៏ទៅចុះ យើងលែងទុកវាឲ្យនៅហើយ" ។ មេនាយតំរួតត្រឡប់មកវិញ ប្រទះឈ្នួញម្នាក់ស្រែកទិញសត្វលាដើម្បីផ្ទុកអីវ៉ាន់ ។ វាធ្វើយថា "ខ្ញុំគ្មានទេសត្វលា បើអ្នកចង់ទិញមនុស្ស ទើបខ្ញុំមាន" ។ ថាដូច្នោះហើយ វាទាំអេសុបយកមកឲ្យមើល ។ ឈ្នួញស្តីថា "អ្នកកុំលេងចំអកឲ្យខ្ញុំដូច្នេះ មនុស្សដូចជាការង្គ អ្នកហានយកមកលក់ឲ្យខ្ញុំ" ។ រួចហើយឈ្នួញក៏ដើរចេញទៅនិយាយផងសើចផង អំពីរូបរាងអេសុប ។ អេសុបស្រែកហៅឈ្នួញមកវិញ ហើយថ្លែងថា "សូមលោកទិញខ្ញុំយកទៅចុះ មិនឥតប្រយោជន៍ទេ បើលោកមានកូនចៅវាយំច្រើនឬវាកាច មុខខ្ញុំគ្មានបានយកទៅតឡុយបន្ទោបវាឲ្យនៅស្ងៀម" ។ ពាក្យដែលអេសុបនិយាយហាក់ដូចជាត្រូវចំណុចចិត្តរបស់ឈ្នួញ។ ក៏ព្រមទិញលោកយក ថ្លៃជាថ្លាក់បីអូបុល (obole)

គិតជាថ្លៃក់យើងប្រហែល ៣ សេន ហើយនិយាយសើចថា "អញទិញមនុស្សនេះដូចជាចោះថ្លៃក់ខោលទេ" ។

ឯឈ្មួញនេះមិនដូញត្រឹមតែរបស់ទេ ដូញទាំងមនុស្សផង កាលណាទៅដល់ក្រុង ១ ឈ្មោះ អេហ្វូស (Ephèse) គាត់នឹងលក់របស់ព្រមទាំងមនុស្សចេញខ្លះ ។ លោកវៀបធ្វើដំណើរទៅ គេឲ្យមនុស្សទាំងឡាយយកវត្ថុផ្សេងៗ វៀនខ្លួនតាមកំឡាំង ។ អេសុបអង្វរមនុស្សទាំងនោះឲ្យអាណិតលោកផង កុំឲ្យលោកយករបស់ធ្ងន់ៗ ពេក ជ្រួតខ្លួនរបស់លោកវិលវិការៈ ។ មនុស្សទាំងឡាយធ្វើយថា "តាមតែឯងចុះ ចង់យកក៏បាន ដើរខ្លួនទេក៏បាន គ្មាននរណាច្រណែនឡើយ" ។ អេសុបបានចិត្តចង់យកដូចគេដែរៈ មនុស្សទាំងអស់ថាៈ "បើដូច្នោះ ចូរឯងរើសមើលចុះ របស់ណាស្រាល យកអាហ្នឹងចុះ" ។ លោករើសយកកញ្ជើអាហារដែលធ្ងន់ជាងគេ, ពួកមនុស្សឯទៀតគិតគ្នាថា "អានេះចំជាឆ្កើ" ហើយក៏នាំគ្នាដើរចេញទៅ ។ ដល់ពេលចុងយ គេបរិភោគអាហារវៀងខ្លួន មិនយូរប៉ុន្មានបានតែពីរពេលចុងអស់រលីងពីកញ្ជើ លោកដើរតែខ្លួនទេ ទើបអ្នកទាំងអស់គ្នាក្ងក់ខ្លួននាំគ្នាសរសើរប្រាជ្ញារបស់អេសុប ។

ចំណែកឈ្មួញ លក់អ៊ីវ៉ាន់នឹងមនុស្សទាំងអស់ ទុកតែគ្នា ៣ នាក់គឺៈ អ្នកចេះខាងវេយ្យាករណ៍ ១, អ្នកចំរៀង ១, អេសុប ១, សម្រាយទៅលក់ឯក្រុងសាមូស (Samos) ។ មុននឹងនាំទៅលក់ គេឲ្យបុរសពីរនាក់

ស្មៀតពាក់ឃ្លាំងល្អ, ចំណែកអេសុបគេឲ្យស្មៀតចាវ ហើយឲ្យឈរនៅ
កណ្តាលបុរសពីរនាក់ ដើម្បីឲ្យអ្នកទាំងពីរនឹងរកតែល្អឡើង គេនឹង
លក់ឯកតម្លៃច្រើន ។ មានអ្នកប្រាជ្ញខាងទស្សនវិជ្ជាម្នាក់ឈ្មោះសង្ហុះ
(Xanthus) មកតម្លៃបុរសចេះវេយ្យាករណ៍នឹងអ្នកចំរៀង ហើយសួរថា:
"ឯងចេះអ្វីខ្លះ?" ។ បុរសទាំងពីរនាក់ឆ្លើយថា "យើងចេះធ្វើសព្វទាំង
អស់" ។ អេសុបឮដូច្នោះអស់សំណើចតែម្នាក់ឯង ។ មុខលោកតែសើច
ឡើងកាលណា បើមនុស្សគ្រាប់ខ្វាចខ្មោច ឃើញហើយចង់រត់មិនហ៊ាន
មើល ព្រោះវាអាក្រក់ក្រៃពេក ។ សង្ហុះសួរទិញ, ឈ្មួញកាត់ថ្លៃពេក ។
ឈ្មួញនិយាយថា "បើអ្នកទិញបុរសណាមួយ ខ្ញុំនឹងថែមអេសុបឲ្យទេ
ដូចជាខ្នាប់" ។ សង្ហុះមិនហ៊ានថ្លៃ ។ តែដើម្បីកុំឲ្យទៅវិញទេ ពួក
កូនសិស្សប្រាប់គ្រូវាឲ្យសួរទិញនូវអាកំនេចមនុស្ស ដែលសើចអម្បាញ់
មិញយកទៅលេង ។ អានេះគ្រាន់ជាទឹកអង្រុតរបស់យើងដោយសារ
មុខរបស់វា ។ គ្រូរបស់វាយល់ព្រមក៏សួរថា "ឯងចេះធ្វើអ្វីខ្លះ?" ។
អេសុបឆ្លើយថា "ខ្ញុំគ្មានចេះអ្វីទេ ព្រោះគេពីរនាក់នេះចេះធ្វើអស់លើង
ទៅហើយតើខ្ញុំបានអ្វីនឹងធ្វើ!" ។ សង្ហុះត្រេកចិត្តហើយទិញលោកយក
តម្លៃជាប្រាក់ ៥០ អូបុល ។

(មានត)

ប្រវត្តិព្រះកែវមរកត

អ្នកឧកញ៉ា ទេពតិន្ទ្រ ក្រិសេម គន្ធបណ្ឌិត

រៀបរៀង

សេចក្តីដើម

រឿងប្រវត្តិព្រះកែវមរកត នោះបើយ៉ាងណាក៏ដោយ ខ្ញុំបានស្តាប់សេចក្តីគេនិយាយដំណាល ឧទ្ទិសបានមើលរឿងក៏វែលគេតែងខ្លះ តាំងជាភាសាខ្មែរតាំងជាភាសាសៀម ស្ទើរតែគ្មានសល់រឿងណាមួយ ។ តែក្នុងរឿងតាំងអំបាលនោះ មានរឿងខ្លះ ដែលខ្ញុំមិនសូវជាគិតចិត្តជឿតាម ព្រោះមានពាក្យនៅក្នុងខ្លួន គួយ៉ាងដូចរឿងដែលដំណាលថា កាលខែតសៀមលើកមកឡោមព័ទ្ធបម្ភាយលង្វែកប្រមាណក្នុងឆ្នាំ ព. ស. ២១៣៦ ដើម្បីបូនយកព្រះកែវមរកត ខ្មែរបានយកព្រះកែវមរកត ទៅលាក់ទុកនៅគុម្ពឫស្សី ដើម្បីកុំឲ្យសៀមចូលយកបាន ។ ល ។ នោះជារឿងមិនពិត ព្រោះព្រះកែវមរកតមិនដែលមកស្ថិតនៅបម្ភាយលង្វែកទេ ។ ដូច្នេះជាហេតុឲ្យខ្ញុំខាក់ចិត្ត ទើបស្រាវជ្រាវរកសេចក្តីពិតរបស់រឿងនេះតមក តែមិនមានឧកាសនឹងបំពេញកិច្ចនេះ ដោយពេញលេញ ។

លុះមកដល់សម័យ ១ ដែលខ្ញុំទទួលការៈស្រាវជ្រាវនឹងរៀបរៀងរឿងព្រះពុទ្ធពចនៈ ក៏បានស្រាវជ្រាវតាំងរឿងព្រះកែវមរកតជាមួយគ្នាផង ព្រោះរឿងនេះ ទាក់ទាមដោយរឿងប្រវត្តិសាស្ត្រដែរ ។ ការរៀបរៀង

ប្រវត្តិព្រះកែវមរកតគ្រានេះ សុំឲ្យជ្រាបថា ដោយអាស្រ័យតាមគោលប្រវត្តិសាស្ត្រដែលខ្ញុំស្រាវជ្រាវក្នុងបច្ចុប្បន្ន ទំនងតាមរឿងប្រវត្តិព្រះកែវមរកត ដែលគេតែងជាភាសាសៀមចុះពុម្ពកន្លងមក ។

រឿងនេះ ទោះបីជាដូចម្តេចក៏ដោយ ខ្ញុំមានសេចក្តីសង្ឃឹមថា គង់ប្លែកគួរលក្ខណៈតែមត្រូវគ្រាន់បើ តែនៅមានសេចក្តីបារម្ភថា ប្រហែលជានៅមានភ្លាត់ខុសឆ្គងខ្លះមិនខាន ទើបសូមឧកាសបវារណាទុកជាមុនថា បើអស់លោកអ្នកណាបានមើលហើយឃើញខុសឆ្គងត្រង់កន្លែងណា សូមមេត្តាជួយផ្តល់ប្តូរជួយតម្រង់ឲ្យបានផង ។

ព្រះកែវមរកត

រយៈទី ១

កំណើតព្រះកែវមរកតនៅតំណែ

ក្នុងរវាង ព.ស. ៩០០ - ១.០០០

ព្រះកែវមរកត (ក្នុងវេលានេះនៅក្រុងចាងកក) កើតឡើងប្រមាណជាក្នុង ព.ស. ៩០០. ដំបូងឡើង ព្រះនាគសេនត្ថេរដ៏ជាព្រះអរហន្តនៅអសោការាម ក្រុងចាតលិបុត្រ ប្រទេសមគធៈ មានចិត្តខ្នះខ្នែងសាងព្រះពុទ្ធបដិមាករ ជាតំណាងអង្គព្រះសម្មាសម្ពុទ្ធដែលបរិនិព្វានទៅហើយ ។

សេចក្តីនោះ ឮបានដល់ព្រះឥន្ទ្រ៑ក៏ចូលដ្រះថ្វាយកាសាវនេះដែរ ទើបត្រាស់ប្រើវិស្សកម្មទេវបុត្រឲ្យទៅសុំកែវមរកតអំពីបម្មុខយក្សដែលនៅក្បែកែវឆ្ងែ្ងៗនៅភ្នំវិបុល ។ តែបម្មុខយក្សពុំព្រមឲ្យដោយអាងថាខ្លួនសម្រាប់ថ្វាយស្តេចចក្រពត្តិ ដែលនឹងកើតក្នុងលោកនេះទៅក្នុងអនាគត ។ វិស្សកម្មត្រឡប់ទៅទូលព្រះឥន្ទ្រ៑វិញតាមដំណើរ ។ ព្រះឥន្ទ្រ៑ព្រមដោយវិស្សកម្ម ក៏ស្តេចទៅកប់បម្មុខយក្ស ទ្រង់ថ្លែងអំពីប្រយោជន៍ដែលសាងព្រះពុទ្ធរូបសព្វគ្រប់ហើយ ក៏ត្រាស់សុំយកកែវមរកត ។ បម្មុខយក្សក៏ព្រមថ្វាយកែវមរកតមួយដុំធំ ។ ព្រះឥន្ទ្រ៑ឲ្យវិស្សកម្មនាំយកកែវនោះទៅប្រគេនព្រះនាគសេន ឲ្យសាងព្រះពុទ្ធរូបពាំងត្រាស់ឲ្យវិស្សកម្មទៅជួយសាងផង ។ ដោយហេតុវិស្សកម្មធ្លាប់បានឃើញព្រះពុទ្ធអង្គក្នុងកាលគង់ព្រះជន្មនៅ អាចនឹងសាងព្រះពុទ្ធរូបឲ្យមានលក្ខណៈប្រហែលនឹងព្រះអង្គដោយច្រើន ។ កាលសាងស្រេចហើយ ព្រះនាគសេនបានបញ្ចុះព្រះបរមធាតុ ๗ អង្គ នៅក្នុងព្រះកែវមរកតនោះ គឺនៅព្រះសិរ ๑ អង្គ, នៅព្រះនលាដ ๑ អង្គ, នៅព្រះឧក ๑ អង្គ, ព្រះអង្សា (ស្មា) ស្តាំ ๑ អង្គ, ព្រះអង្សាឆ្វេង ๑ អង្គ, ព្រះជង្ឃ (ជង្គង់) ស្តាំ ๑ អង្គ, ព្រះជង្ឃឆ្វេង ๑ អង្គ, ។

ឯតព្រះកែវមរកតនោះ តាមដែលគេកាស់កុងកាលឥឡូវនេះ ដូច្នេះ

កំពស់ព្រះអង្គ ๑ ហត្ថ ๗ ឆ្នាប់

ព្រះកែន ๒๓ ឆ្នាប់ ។

ក្រោយដែលសាងហើយ គេបានសាងមណ្ឌបប្រតិស្ថានព្រះកែវមរកត នោះនៅក្នុងបាតលិបុត្រ ហើយមានការធ្វើពិធីសម្ពោធដ៏ធំឆ្ងាយ ។ ល្បីរីក មានមហាជនអំពីគ្រប់ទិសមកមើលច្រើនមហិមា ដោយគេសំគាល់ថាជា វត្ថុវិសេសអស្ចារ្យ ជាទស្សនានុត្តរិយវត្ថុ ទើបទុំធំកើតមានឡើង ។

ដោយហេតុព្រះកែវមរកតជាវត្ថុវិសេសអស្ចារ្យនោះ ព្រះនាគសេន ទើបទូន្មានព្យាករណ៍ទុកថា "ព្រះកែវមរកតអង្គនេះ ទៅកន្លងអនាគត ទំនឹងស្ថិតនៅបានតែក្នុងប្រទេស ដែលកាន់ព្រះពុទ្ធសាសនា ហើយជា ប្រទេសថ្កើងរុងរឿង" ។

រឿង ទី ២

ព្រះកែវមរកតចេញចាកឥណ្ឌៅទៅស្ថិតនៅលង្កាទ្វីប

ពី ព. ស. ១.០០០ - ១.៦០០

សេចក្តីព្យាករណ៍របស់ព្រះនាគសេននោះមិនបានយឺងយូតឡើយ ដោយហេតុក្រោយនោះ ប្រទេសមគធៈកើតបះបោរចលាចលតាប់សម្ងាប់ គ្នាដើម្បីដណ្តើមរាជបល្ល័ង្ក, កន្លងពេលនោះ ការព្រះសាសនាក៏រឿរោយ ថយចុះយ៉ាងច្រើន ។ កន្លងទីបំផុត មកកន្លងរដ្ឋកាលព្រះបាទសិរីកិត្តិរាជ កន្លងរាង ព. ស. ១.០០០ ជាសម័យដែលបណ្តាលកើតក្តៅក្រហាយ ខ្លាំងឡើង ទើបមានពុទ្ធបរិស័ទ ១ ពួកបានទិមន្តព្រះកែវមរកតចុះកាន់ សំពៅបើកមកតាមទន្លេគង្គាចេញទៅដល់តាមទន្លេបង្គ្លឹល ហើយបើក

សំរេចនៅទៅគោះលង្កា ដោយបំណងបណ្តោះយកព្រះតែវមកតទៅ
ប្រតិស្ថានទុកទៅពីខោះ ឲ្យរួតអំពីកណ្តាប់ដៃពួកមិច្ឆាទិដ្ឋិបំផ្លាញ ។
ព្រោះកន្លងពេលខោះ ព្រះពុទ្ធសាសនានៅគោះលង្កាកំពុងចំរើនជាន់នានា
ប្រទេសចាំងអស់ ។

កាលព្រះតែវមកតអណ្តែតត្រសែតទៅដល់គោះលង្កាហើយ ពួក
ពុទ្ធមាមកៈនៅលង្កា មានព្រះមហាសង្ឃបរិនាយក នឹងព្រះមហាក្សត្រិយ៍
ជាអាទិ៍ ក៏ត្រេកអរខ្លួលខ្ជិមខ្ពស់ទៅប្រតិស្ថានទុកនៅវត្តមេឃគីរីមហាវិហារ
ដែលជាវត្តសំខាន់ក្នុងក្រុងនោះ ។ អំពីនោះព្រះពុទ្ធសាសនានៅលង្កា
ក៏សន្សឹមចំរើនរុងរឿងមកអស់កាលដ៏យូរ ។

តែសម័យតមក ប្រទេសលង្កាត្រូវខ្លួលគ្រោះថ្នាក់ជាច្រើនលើក
ដោយត្រូវខ្មាំងដែលនៅក្នុងដែនឥណ្ឌាលើកទ័ពធ្ងន់ទៅវាយបៀកខ្លួចខ្លី
រហូតដល់ទៅបានឡើងគ្រងរាជបល្ល័ង្កជាច្រើនដង ។ ព្រះពុទ្ធសាសនា
ក្នុងគ្រានោះភ្ញាក់រៀវរោយជាច្រើន ដោយស្មាដៃពួកមិច្ឆាទិដ្ឋិនេះបៀត
បៀន ។ តែគ្រោយមក ក្សត្រិយ៍លង្កាបានរើខ្ជិនពីកំណាប់ដៃខ្មាំង
ឡើងវិញក៏ផ្តើមខំនុកបម្រុងព្រះពុទ្ធសាសនាឲ្យរុងរឿងយ៉ាងដើម, ដូចជា
កន្លងសម័យពុទ្ធសតវត្សរ៍ទី ១៦ កន្លងរដ្ឋកាលក្សត្រិយ៍ព្រះនាមហៅតាមក្នុង
សង្ខ្លីតវ៉ាស្យថា "លង្កិស្សរាជ" ទ្រង់បានចាត់ចែងខំនុកបំរុងព្រះពុទ្ធ-
សាសនាជាថ្មីទៀត តែក៏មិនបានជាចំរើនប៉ុន្មាន ។ ចំណែកឯគម្ពីរព្រះ

ព្រៃតែបដកនៅមានគ្រប់បរិបូណ៌ តាំងបែបភាសាថាលីតាំងបែបភាសាលង្កា ។

ព្រះកែវមរកតទៅស្ថិតនៅកោះលង្កា ដោយអាការយ៉ាងនេះ ។

រឿង ទី ៣

ព្រះកែវមរកត ចេញចាកលង្កាមកប្រតិស្ឋាន នៅក្រុងស្រីយសោធរបុរៈប្រទេសកម្ពុជា ពីរវាង ព. ស. ១ ៥៦០ - ១ ៦៤៣

ហេតុដែលព្រះកែវមរកតមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជា ប្រាកដតាមប្រវត្តិសាស្ត្រថា: ក្នុងរវាង ព ស. ១ ៥៥៣ ដល់ ១.៥៨៥ ប្រទេសកម្ពុជាមានព្រះមហាក្សត្រិយ៍ ១ អង្គ ព្រះនាមអនុរុទ្ធឬអនុរុទ្ធ មានព្រះកិត្តិយសជាមហាពជ ទ្រង់ជាអ្នកជឿថ្វាក្នុងព្រះពុទ្ធសាសនាយ៉ាងខ្លាំង ឬានផ្តើមទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងប្រទេសឲ្យចំរើនឡើង ។ តែក្នុងវេលានោះ ព្រះត្រៃបិដកក្នុងប្រទេសកម្ពុជាមានមិនគ្រប់បរិបូណ៌, ទ្រង់ជ្រាបថា នៅលង្កាមានចប់បរិបូណ៌ ទើបស្តេចឲ្យតាក់តែងសំពៅពីរ ហើយស្តេចចុះសំពៅទៅលង្កាទូបជាមួយនឹងអ្នកប្រាជ្ញជាច្រើន មានតាំងគ្រហស្ថតាំងបព្វជិត ដើម្បីចំឡងព្រះត្រៃបិដក ។

ប្លែងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

ព្រះអនុរុទ្ធត្ថេរនេះ ជាឧរសរបស់ព្រះអមិតោទនសក្យរាជ ដែលជាព្រះអនុជព្រះបាទសុទ្ធោទនសក្យរាជ គ្រងក្រុងកបិលពស្តុ ប្រសូតចេញពីព្រះមាតារួមជាមួយគ្នា ៣ អង្គ គឺ: ព្រះដេដ្ឋាព្រះនាមមហានាមសក្យ ១ ព្រះកនិដ្ឋភគិនី (ប្អូនស្រី) ព្រះនាមភេទាភិនី ១ ជា ៣ អង្គនឹងព្រះអនុរុទ្ធកុមារ បើកបរៀងតាមព្រះវង្សត្រកូលជាព្រះអនុជព្រះបរមសាស្តា ។ ព្រះអនុរុទ្ធកុមារនេះជាក្សត្រសុទ្ធមាលជាតិ មានប្រាសាទ ៣ សម្រាប់នៅក្នុងរដូវទាំង ៣ បរិបូណ៌ដោយស្រីស្នំស្រីភ្លាបរិវារទាំងពួង សូម្បីសព្វថៃពាក្យថាមិនមានឬគ្មាន ក៏មិនដែលឮមិនដែលស្តាប់ឡើយ ។ សម័យ ១ ព្រះបរមសាស្តា ស្តេចប្រថាប់នៅអនុបិយនិគមរបស់ពួកមល្លក្សត្រ, ក្នុងវេលានោះ ពួកសក្យកុមារដែលមានកេរ្តិ៍ឈ្មោះមានមនុស្សស្គាល់ច្រើន នាំគ្នាចេញទៅបួសតាមសម្តេចព្រះបរមសាស្តា ។ ថ្ងៃ ១ ព្រះមហានាមដែលជាព្រះដេដ្ឋាប្រារព្ធដល់រឿងនេះហើយ ទើបទៅពិគ្រោះប្រឹក្សានឹងព្រះអនុរុទ្ធជាប្អូនថា "ម្នាលអនុរុទ្ធ! កុលត្រកូលរបស់យើងមិនមានអ្នកណាមួយ ចេញទៅបួសតាមព្រះបរមសាស្តាឡើយ បើដូច្នោះ មានតែប្អូនប្តូនបងចេញទៅបួសតាមព្រះអង្គទើបសមគួរ" ។ ព្រះអនុរុទ្ធ

ឆ្លើយទៀតថា "ប្អូនជាមនុស្សឆ្លាប់តែនៅកន្លែងសេចក្តីសុខ ប្អូនមិនត្រមៅបួសទេ អញ្ជើញស្តេចបងទៅបួសចុះ" ។ ព្រះមហានាមពោលទៀតថា "បើដូច្នេះ ត្រូវប្អូនរៀនសូត្រឲ្យចេះដឹងការងាររបស់អ្នកនៅគ្រប់គ្រងផ្ទះសិនបងនឹងបង្រៀនឲ្យចេះដឹង" លុះពោលដូច្នេះ ទើបបង្រៀនអនុរុទ្ធអំពីការងាររបស់អ្នកនៅគ្រប់គ្រងផ្ទះ លើកយកការធ្វើស្រែជាដើមទៀតអធិប្បាយពន្យល់សព្វគ្រប់ ។ កាលព្រះអនុរុទ្ធបានស្តាប់ហើយក៏យើញថា "ការងារនេះមិនមានទីបំផុត ទីបំផុតរបស់ការងារមិនមាន" ទើបកើតចិត្តនឿយណាយក្នុងការងារ រួចពោលទៅនឹងស្តេចបងថា "បើដូច្នោះបងនៅគ្រប់គ្រងផ្ទះចុះ ប្អូននឹងចេញទៅបួសវិញ" ។ កាលព្រះអនុរុទ្ធពោលដូច្នេះហើយ ទើបចូលទៅគាល់ព្រះមាតាទូលថា "ព្រះមេម្ចាស់! ខ្ញុំម្ចាស់ចង់ទៅបួស សូមព្រះមេម្ចាស់អនុញ្ញាតឲ្យខ្ញុំម្ចាស់ទៅបួសចុះ" ។ ឯព្រះមាតាគ្រាស់ហាមមិនត្រមឲ្យចេញទៅបួស, ព្រះអនុរុទ្ធក៏ចេះតែទទូចទូលអង្វរសូមអនុញ្ញាតជាច្រើនគ្រា ។ ព្រះមាតាឃើញដូច្នោះទើបគិតរកឧបាយមិនឲ្យព្រះអនុរុទ្ធចេញបួស ដោយរលឹកនឹកឃើញដល់ព្រះបាទកញ្ចុយៈជាសំឡាញ់របស់ព្រះអនុរុទ្ធ ថាមុខជាទ្រង់មិនត្រមៅបួសជាប្រាកដ ទើបមានព្រះបន្ទូលថា "បើព្រះបាទកញ្ចុយៈទ្រង់ព្រះផ្នួស ចូរកូនបួសចុះ" ។ កាលព្រះអនុរុទ្ធបានស្តាប់ព្រះមាតាដូច្នេះហើយ ទើបចូលទៅគាល់ព្រះបាទកញ្ចុយៈ ទូលតាមវេហារដែលឆ្លាប់ស្ទង់ស្ទាលថា

"សំឡាញ់អ៊ីយ ! តម្បូវបព្វជ្ជារបស់យើងជាប់ទាក់ទងនឹងបព្វជ្ជារបស់សំឡាញ់" ។ ដំបូងព្រះឋេរកថ្លែយ: ទ្រង់បដិសេធន៍មិនព្រមទ្រង់ព្រះផ្នួស តែទ្រាំទ្រឮពាក្យអង្វរមិនបានក៏ជាប់ព្រះហឫទ័យព្រមទទួលបួសផង ។ ទើបព្រះអនុរុទ្ធទៅបបួលសក្យរាជដទៃទៀត ៣ អង្គ គឺ អានន្ទ ១ ភគុ ១ កិម្ពិល ១ កោលិយវង្ស គឺទៅទត្ត ១ ត្រូវជា ៧ នាក់ នឹងឧបាលីដែលជាខ្ញាន់ព្រះកេស ព្រមចិត្តគ្នាចេញអំពីស្រុកទៅគាល់ព្រះបរមសាស្តាឯអនុបិយនិគម ហើយគ្រាបទូលសុំឧបសម្ប៉ទ ក្នុងព្រះពុទ្ធសាសនា ។ កាលព្រះអនុរុទ្ធបានឧបសម្ប៉ទហើយ បានរៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្តត្ថេរ ហើយបានចូលទៅចំរើនសមណធម៌នៅព្រៃបាចិនវង្សមិគទាយវន បានត្រិះរិះដល់ព្រះមហាបុរិសវិតក្ក: ៧ ប្រការថា:

๑ — ធម៌នេះជាធម៌របស់អ្នកប្រាថ្នាតិច មិនមែនរបស់អ្នកប្រាថ្នាធំឡើយ ។

๒ — ធម៌នេះជាធម៌របស់អ្នកសន្តោសត្រេកអរដោយរបស់ដែលមានមៅ មិនមែនរបស់អ្នកមិនសន្តោសឡើយ ។

๓ — ធម៌នេះជាធម៌របស់អ្នកស្ងាត់ មិនមែនរបស់អ្នកត្រេកអរដោយពួកគណៈឡើយ ។

๔ — ធម៌នេះជាធម៌របស់អ្នកប្រារព្ធសេចក្តីព្យាយាម មិនមែនរបស់អ្នកខ្ជិលច្រអូសឡើយ ។

๕ — ធម៌នេះជាធម៌របស់អ្នកមានសតិខ្ជាប់ខ្ជួន មិនមែនរបស់អ្នកមានសតិវង្វេងឡើយ ។

๖ — ធម៌នេះជាធម៌របស់អ្នកមានចិត្តខ្ជាប់ខ្ជួន មិនមែនរបស់អ្នកមានចិត្តមិនខ្ជាប់ខ្ជួនឡើយ ។

๗ — ធម៌នេះជាធម៌របស់អ្នកមានប្រាជ្ញា មិនមែនរបស់អ្នកឥតប្រាជ្ញាឡើយ ។

កាលព្រះអនុរុទ្ធត្ថេរកំពុងតែរិះរិះយ៉ាងនេះ, ព្រះបរមសាស្តាទ្រង់ជ្រាបស្តេចយាងទៅដល់ហើយ ទ្រង់អនុមោទនាថា "ត្រូវហើយៗ អនុរុទ្ធ! អ្នកបានត្រិះរិះដល់ធម៌ដែលមហាបុរសបានត្រិះរិះប្រពៃហើយ ម៉ើដូច្នេះ ចូរអ្នកត្រិះរិះដល់ធម៌ដែលមហាបុរសបានត្រិះរិះជាគំរប ๘ នេះថា:

๘ — ធម៌នេះជាធម៌របស់អ្នកត្រេកអរក្នុងធម៌ដែលមិនយឺតយូរ មិនមែនជារបស់អ្នកត្រេកអរក្នុងធម៌ដែលយឺតយូរឡើយ" ។

លុះព្រះអង្គទ្រង់ប្រទានព្រះអនុរុទ្ធដោយប្រការដូច្នេះហើយ ទើបស្តេចយាងត្រឡប់ទៅទីប្រថាប់វិញ ។ ឯព្រះអនុរុទ្ធបានខំប្រតេញព្យាយាមកំចាត់សម្រេចព្រះអរហត្តផល. តាំងអំពីនោះមក លោកតែងសំឡឹងមើលសត្វលោកដោយទិព្វចក្ខុជានិច្ច ។ មានសេចក្តីដំណាលថា ត្រែវពីពេលឆាន់ចង្ហាន់ចេញ កាលវេលាដែលសេសសល់អំពីនេះ លោកតែងពិចារណាមើលឥតព្លាតសត្វទាំងពួងដោយទិព្វចក្ខុញាណ ហេតុនេះ

ហើយបានជាព្រះដ៏មានព្រះភាគត្រាស់សរសើរលោកថា ប្រសើរលើសលែងជាងគ្រប់ទាំងឆ្នាំង ដែលមានវិជ្ជាចរណៈ ។ ព្រះអនុរុទ្ធត្ថេរលោកបានបំពេញកិច្ចក្នុងព្រះពុទ្ធសាសនា តាមសមគួរនឹងកាលវេលាហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វាន ក្រោយព្រះបរិនិព្វានរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ។

ចប់ ប្រវត្តិរបស់ព្រះអនុរុទ្ធត្ថេរ តែប៉ុណ្ណោះ ។

សុភាសិត

ប្រាំបួនទាល់ ដប់ទាល់ កុំទាល់គំនិត
ប្រាំបួនគិត ដប់គិត កុំគិតមេឃដី
ប្រាំបួនធ្វើ ដប់ធ្វើ កុំធ្វើការអប្រិយ
ប្រាំបួនស្តី ដប់ស្តី កុំស្តីអសុរោះ ។

សាមណេរ គក - គីឡែង វត្តឧណ្ណាលោម ភ្នំពេញ

ប្រែរៀបរៀង ជាភាសាភាគ ៧

ឃុនសុវត្ថិវេធី យូរ អ៊ុន ពិនិត្យកែ

ខ្ញុំសូមតែងរឿងបជាចារ ជាគាថាវេហារដោយបរិយាយ
ទុកសម្រាប់ពួកពុទ្ធនិកាយ មើលស្តាប់ឲ្យក្លាយឃ្លាតនីរណា ។
និទានថាមានកូនសេដ្ឋី ជាស្រីរូបល្អសាច់ស្រស់ថ្លា
អាយុដប់ប្រាំមួយវស្សា បិតាមានទ្រព្យសែសិបកោដិ ។
នៅភូមិនគរសាវត្ថី មានឈ្មោះពុលីគួរឲ្យកោត
ដែលគ្រប់ប្រមប្រិយល្បីនាមគេត្រេក រូបសោភល្អផុតស្រីនានា ។
មាតាឲ្យនៅលើប្រាសាទ ប្រាំពីរជាន់ស្អាតសមសោភា
មានស្រីបំរើប្រើសើរជា ឥតទុក្ខវេទនាពេលណាឡើយ ។
គ្រាមួយមានប្រុសពូជសេដ្ឋី ចូលស្តីបិតាក៏ព្រមហើយ
បុរាណការធាប់មិនព្រងើយ កម្មអើយទាញនាងឲ្យឃ្លាតឃ្លា ។
នាំនាងឲ្យស្រឡាញ់ខ្ញុំឯង វង្វេងក្លេចគិតការល្អជា
យកខ្ញុំធ្វើប្តីមិនរួញរា មាតាបិតាឥតដឹងសោះ ។
ថ្ងៃក្រោយធីតាគិតភ័យខ្លាំង ស្ងួតស្ងុតស្ងន់ស្លាំងញាំញីពន់ពោះ
ហើយនាងនិយាយគិតពិគ្រោះ នឹងប្តីនាងនោះដូចេះថា ។

បងអើយយើងនៅនេះមិនបាន　　ត្រែងគេដឹងជានបែកការណា
ប្រសិនបើដឹងដល់បិតា　　គាត់ផ្តាច់ដីក៏យើងមិនខាន ។
តែយើងបង្អង់ខ្លីនឹងបានទុក្ខ　　ដ្បិតម្តាយឪពុកគាំងពីប្រាណា
គេមកដណ្តឹងខ្ញុំស្មោះស្មាន　　គាត់បានឲ្យខ្ញុំទៅគេហើយ ។
គេនឹងនាំគ្រឿងតំស្អុបណ្ណា　　មកជូនបិតាមិនយូរឡើយ
ខ្ញុំព្រួយភ្ញាំងណាស់ទុក្ខតស៊ូឡើយ　　ដូច្នេះបងអើយយើងត្រូវវាត់ ។
កាលនោះស្រុះបិត្តគាំងពីនោក់　　វេចគ្រឿងស្លៀកពាក់អាវសំពត់
យប់ជ្រៅភ័យជ្រលនាំគ្នាវាត់　　គួរគិតកំសត់ដល់ធីតា ។
ភ្ជាប់សុខបានទុក្ខមកដល់ប្រាណ　　ដើរទៅដោយជានហានព្រឹកព្រា
លេចពីលចូលព្រៃទ្រូវប្លោ　　មុខគួរអនិច្ចាពន់ពេកព្រៃ ។
ទៅដល់ស្រុកមួយឆ្ងាយលន្លោច　　ត្រមោចតតញាតិពឹងប្រស័យ
នាំគ្នាធ្វើទុំមៅក្បែរព្រៃ　　យកអ្នកជនៃធ្វើញាតា ។
រកស៊ីតាប់ទសធ្វើស្រែស្រូវ　　លំបាកពេកក្រៃតទុបមា
ពីនោក់ស្វាមីនឹងកវិយា　　កំសត់វេទនាប្រៀបពុំបាន ។
មុខគួរអាសូរក្មេងស្រីដ្ឋី　　ជាស្រីភ្ជាប់សុខតតំខាន
ពេលនោះពិបាកដល់អង្គប្រាណ　　ទំនេរពុំបានកន្លះពេលណា ។
ធ្វើការនឿយហត់ជាប្រក្រតី　　បំរើស្វាមីនៃអាត្មា
កើតទុក្ខកង់ចិត្តគំនុំខ្លាចផ្សា　　ស្រក់ទឹកនេត្រាត់តមានស្បើយ ។

លុះនាងមានគភ៌ក្នុងផ្ទៃពោះ គឺហេតុកម្មគ្រោះមកដល់ហើយ
ត្រួយច្បាណាណែនទ្រូងឥតមានស្បើយ កើតទុក្ខពេញហើយក្នុងខ្លួន ។
ទើបនាងបបួលប្រុសជាប្តី សូមឲ្យស្វាមីមានមេត្តា
អាណិតដូនប្អូនទៅមាតា ប្រសូតបុត្រាណាប្រុសថ្លៃ ។
បើប្អូនប្រសូតកូនមិនឆ្លាត គ្មានញាតិណាជំនួយទុក្ខភ័យ
ដូច្នេះសូមអ្នកបងថ្លៃមេត្តា លកលៃដូនប្អូនទៅនាប់ក៉ា ។
ទើបប្រុសជាប្តីនិយាយច្បាប់ ប្អូនអើយចាំស្តាប់បងចរចា
ថាបើបងដូនទៅកាលណា មាតាបិតានឹងសម្លាប់ ។
ទើបនាងពន្យល់ដូច្នេះថា សូមបងមេត្តាកុំសារសំពូ
ធម្មតាបិតាមិនសម្លាប់ ធ្វើឲ្យកូនស្លាប់នោះគ្មានឡើយ ។
បើទឹងខ្លាំងណាស់កន្ទុះវៃ ឲ្យតែបាត់យូរនឹកឥតស្បើយ
ចិត្តខន់នឹងកូនមិនលែងឡើយ បងអើយដូនប្អូនទៅនាបណា ។
ប្អូនមានទម្ងន់ធ្ងន់កន្ទុយខ្លួន ទុក្ខធំធំផ្ទុកកាយា
គ្មានញាតិណាមួយជួយរក្សា មេត្តាដូនខ្ញុំទៅកុំខាន ។
ចំណែកស្វាមីស្តីប្រែកែក ដដែកមិនហ៊ានដូនស្មោះស្មាន
ព្រោះខ្លាចអន្តរាយស្លាប់ដល់ច្បាណា ឬក្រែងមិនបានសមច្បាថ្លា ។
ថ្លៃក្រោយប្រុសជាស្វាមី គ្រាចំខ្ចីគាប់ៗសក្តិព្រឹក្សា
ចំណែកនាងបងាចាក ត្រួយក្នុងចិត្តាពុំមានស្បើយ ។

នាងផ្តាំអ្នកស្រែកឯតទាន់ចុះ
ថាបើប្តីខ្ញុំមកដល់ហើយ
ប្រាប់គាត់ថាខ្ញុំលែងទៅស្រែក
ផ្តាំស្រែចនាងបងាចាក
មុខគួរឲ្យខ្លាចកន្លែងត្រគុំ
នាងព្រួយចំប្រឹងគាត់ចិត្តទៅ
និយាយពីទាងប្រុសជាប្តី
ដល់ខ្លួនគេប្រាប់យ៉ាងជាក់ស្តែង
បុរសជាប្តីស្តីខ្សឹកខ្សួល
ស្រែកឮញាត់តាមនាងទាន់ហើយ

ហេតុអ្វីក៏ស្រីស្រស់ចំណាប់
ឲ្យរៀមកិតក័យក័ន្តចិន្តា
ខេសកាលពេលនោះនាងឈឺពោះ
ប្រសូតកូនក្នុងស្រែស្ងាត់សុងសូន្យ
ប្រសូតរួចហើយខើបស្ងាម៏
ប្អូនអើយបំណងនាងប្រាថ្នា
តម្លៃប្រសូតរួចស្រេចហើយ
លួមយើងទៅខ្លួមស្លូនបរិសុទ្ធ

ទុ! លោកយាយតាបងប្អូនអើយ
អ្នកកុំកន្តើយសូមមេត្តា ។
ដ្បិតខ្ញុំវិតក្កក្នុងខ្លោចផ្សា
យាត្រាដើរកាត់តាមព្រៃជ្រៃ ។
សូរសៀងសត្វយំព្រុសន្ធៅ
ដើរកន្លងព្រៃជ្រៃតែម្នាក់ឯង ។
រាលខ្ចីចាកព្រៃជាប់សង្កែង
កវីយាអ្នកឯងទៅស្រែកហើយ ។
អាក់អួលក្នុងទ្រូងមិនមានស្បើយ
និយាយធូរធ្លើយដូច្នេះថា ។
នាងមកមិនប្រាប់ដល់រៀមក៏
សោកាហាមាត់តែតាមប្អូន ។
គឺមោះខ្លាល់ចាប់បង្ខិលកូន
សូរសៀងសំឡូនយំខ្លោចផ្សា ។
លួងលោមស្រដីដូច្នេះថា
ទៅស្រុកមាតាប្រសូតបុត្រ ។
ចាន់ស្បើយពីទុក្ខធំបំផុត
ថែរក្សាបុត្រទៅតាមក្រម ។

ស្រីត្រមល្មមចិត្តនាំគ្នាទៅ　　កាន់ទូមលំនៅទំប្រឹងគ្រាំ
ពិបាកទុក្ខត្រួយព្រោះកម្មនាំ　　ដៀមជាំក្នុងចិត្តឥតឧបមា ។
នៅយូរថ្ងៃទៅមានគតិខ្មៅគ　　ចង្អៀតណែនណាន់ដោយទុក្ខា
ត្រួយប្រាណទឹកភ្នែកដោកកក្រា　　ភ្លេចផ្សាភ្លក់ភ្លាយភាលថ្ងៃថ្ងៃ ។
លោមឲ្យកស្តាជូនទៅស្រុក　　នៃម្តាយតុំពុកមានគុណវៃ
ចំណែកកស្តាមានប្អូនម៉ែ　　នឹកព័យមិនហ៊ានជូនទៅសោះ ។
ទើបនាងពកូនលបរត់ទៅ　　ប៉ុន្តែចិត្តនៅនឹកអាឡោះ
ទូញសោកភប់រៀបញ៉ែរពេងពោះ　　គួរឲ្យស្រណោះឥតឧបមា ។
ស្រែកទូញថាតុអ្នកស្វាមី　　ហេតុអ្វីអ្នកកាត់ក្តីមេត្តា
មិនត្រមជូនប្អូនទៅម៉ាតា　　ឲ្យកើតទុក្ខាត្រួយដល់ម្តុំង ។
ចិត្តអ្នកប្រហែលមិនអាណិត　　អាសូរដល់ចិត្តប្អូនទំប្រឹង
គ្រាសូនឹងអ្នកពិបាកម្តុំង　　ប្អូនកមិនដឹងចិត្តប្អូនទេ ។
កម្មប្អូននាំឲ្យស្រឡាញ់ជាក់　　កម្មអកនាំស្តុគចិត្តស្និទ្ធស្នេហ៍
ស៊ូស្លាប់ស៊ូរស់ពីព្រោះតែ　　ចិត្តស្មោះប្រែប្រួលចិត្តា ។
កូនអើយខ្ញុំនម្តាយម្តង៍នេះហើយ　　ឥតមានគោរត្រួយគ្រាទុក្ខា
គឺកម្មកូនឯងនឹងមាគា　　គ្មានអ្នកឯណាខ្មីពីងប្រាណ ។
នាងដើរគាំងយប់ងងឹតសូន្យ　　តែម្តាយនឹងកូនក្នុងស្មៅ សាន
លុះដល់អធ្រាត្រទើបនាងបាន　　ដល់ហាងវៃព្រៃផ្សៅទៅខ្ញាចផ្សា ។

ប្រវត្តិព្រាហ្មណាចារ្យ

លោក អ៊ុម គយ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់

រៀបរៀង

សេចក្តីដំណាលថា: ព្រាហ្មណមហាសាលម្នាក់នៅក្រុងសាវត្ថី មានទ្រព្យ ៨ សែនកហាបណៈ មានកូនប្រុស ៤ នាក់ ។ កាលកូននោះមានវ័យវឌ្ឍន៍ការចំរើនដំឡើង គាត់បានរៀបចំអាវាហមង្គលរួចហើយ ក៏ចែកសម្បត្តិឲ្យ ៤ សែន, កូនកូនម្នាក់ៗ ត្រូវបានមួយសែនកហាបណៈ ។ កាលចំណេរដំណាលមក នាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះ ធ្វើកាលកិរិយាទៅ គាត់នៅតែតាមតែម្នាក់ឯង ។ កូនទាំង ៤ នោះក៏ប្រឹក្សាគ្នាថា: "បើឪពុកយើងយកប្រពន្ធទៀត មុខជាមានកូនមិនខាន, ទ្រព្យ ៤ សែននឹងក្លៀវអាករផ្សេង។ ដែលនៅកងក៏កណ្តាប់ដៃគាត់។ មុខជាចែកឲ្យតែកូនប្រពន្ធចុងទាំងអស់, បើដូច្នេះគួរតែយើងទៅនាំយកគាត់មកចំនុកបំរុង" ថាហើយក៏នាំយកបិតាមកចំនុកបំរុង ដោយកិច្ចមានគត់ច្រចាប់ដូនគោជ-នាហានឹងគ្រឿងស្លៀកពាក់ជាដើមដោយគោរព ។ ថ្ងៃមួយ កាលព្រាហ្មណ៍ក្រោកពីដេកក៏វេលាថ្ងៃ, ពួកកូនមកជួបជុំគ្នាហើយនិយាយអំពីទោសនៃការនៅគ្រប់គ្រងផ្ទះ ដោយឡែកៗពីគ្នា រួចនិយាយអង្វរថា: "លោកឪពុក! យើងជាកូនទាំងអស់គ្នានឹងបំរើលោកឪពុកតាមទំនងនេះជារៀងអស់ជីវិត សូមកុំព្រួយឡើយ តែសូមលោកឪពុកចែកទ្រព្យសម្បត្តិ

ដែលនៅសល់តាំងអម្បាលម៉ានដល់យើង តាំងអស់គ្នាម្ភងខៀត ។ ។
ព្រាហ្មណ៍តែមថែកឲ្យកូន ក្នុងម្នាក់ៗឃ្លាន ១ សែនខៀត នៅសល់តែ
សំពត់ ១ ចង្កេះប៉ុណ្ណោះ ហើយចុះទៅនៅក្នុងផ្ទះកូនច្បងបង្អស់ គាល់នៅ
ឃ្លានពីរបីថ្ងៃ កូនប្រសាស្រីនោះកើតសេចក្តីធុញគាន់ធឹងឥតក្រែក ក៏
និយាយឧដាន់ថា: "លោកឥតថែកខ្លួនឲ្យដល់កូនច្បងតែមតែ ១ រយ ១
ពាន់កហាបណៈ ថាច្រើនណាស់ហើយ ឯកូនឯខៀតអាចឲ្យ ២ សែន
ម្នាក់ៗ, លោកឥតប្រហែលមិនស្គាល់ផ្លូវទៅគាន់ផ្ទះកូនគាំងនោះឬ? ឃ្លាន
ជាមិនទៅជាន់ផ្ទះគេ" ។ ព្រាហ្មណ៍ពុដ្ឋនោះ តូចចិត្តក៏ទៅគាន់ផ្ទះកូន
ឯខៀត, មិនយូរប៉ុន្មាន ត្រូវកូនប្រសាស្រីគាំងនោះបណ្តេញចេញឲ្យចាកផ្ទះ
តាមទំនងដូចគ្នា ។ គាត់ត្រាំនៅមិនឃ្លានក៏ចេញទៅបួសស្មៀកសពាក់ស
ដើរសូមទានតាមថែកល្អកប្រឧផ្ទះបុគ្គលដទៃ, ទៅជាស្តាំងស្តមរីងរៃព្រោះ
មិនបានកោដនាហារនឹងជំណែកស្រួល ទឹកអាណិតអាសូរខ្លួនថា: "ខ្ញុ!
អាត្មាអញចាស់ឡើងគាន់តែលំបាកខ្លាំងឡើង មិនសមបើកូនលះលែង
អញឲ្យដើរសូមទានគេឥសោះ ក៏មិនទឹកអាណិតអញដែលខំបីបាច់ថែ
រក្សាចិញ្ចឹមវាតាំងពីតូចមក មិនដែលឲ្យមានមោះមែរតុស្ងាន; ឃ្លានពុទ្ធ
ព្រះសមណគោតម មានព្រះកត្តុវន្តសំដីពីកេះ ប្រសប់កន្តាខ្លួល
រាក់ទាក់ បើដូច្នោះមានតែអាត្មាអញចូលទៅវត្តព្រះសមណគោតមចុះ"
លុះគិតហើយ ក៏ទៅគាន់សំណាក់ព្រះសាស្តាគ្រាបថ្វាយបង្គំព្រះអង្គដោយ

គោរព ។ ព្រះដ៏ទ្រង់ត្រាស់សួរថា: "នែព្រាហ្មណ៍! ហេតុអ្វីបាន ជាអ្នកមានសម្បុរសរីរៈនឹងសំណែកបំពាក់សៅហ្មងដូច្នេះ" ។ -បពិត្រ ព្រះគោតមដ៏ចំរើន! ខ្ញុំព្រះអង្គមានកូនប្រុស ៤ នាក់ ឥឡូវនេះវត្តរំ គំនិតជាមួយនឹងប្រពន្ធបណ្តេញខ្ញុំចោល ។ -ម្នាលព្រាហ្មណ៍! បើដូច្នោះ អ្នកចូរស្តាប់គាថានេះ ហើយសូត្រកន្លងនូវប្រជុំជន ដែលមានកូនរបស់អ្នក គាំងនោះអង្គុយនៅជាមួយផងចុះ:

ខ្ញុំត្រេកអរដោយកូនឯណាដែលកើតមកហើយផង ធ្លាប់ឮ សេចក្តីចំរើនដល់កូនឯណាផង កូននោះគប្បីសមគំនិតជាមួយនឹង ប្រពន្ធ ហើយបណ្តេញខ្ញុំចោលដូចជាឆ្កែបណ្តេញចោរ; ក៏កូន ជាអសប្បុរសលាមកគ្រាន់តែហៅគេខ្ញុំថាឪពុកប៉ុណ្ណោះ ប៉ុន្តែវ័យ ចង់ខ្ញុំដែលមានវ័យចាស់ជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ, (កូនខ្ញុំ នោះ) ប្រៀបដូចការក្ងែក ដែលមកដោយរូបជាកូន, ឪពុក ចាស់របស់កូនពាល តែងដើរសូមទានប្រហជ្ញអ្នកដទៃ ដូចជា សេះចាស់ប្រើថ្ងាស់មិនកើតគេនាំចេញចាកចំណី, ឈើច្រត់របស់ ខ្ញុំនេះប្រសើរ កូនដែលមិនស្តាប់បង្គាប់មិនប្រសើរឡើយ, ដ្បិត ឈើច្រត់នេះអាចការពារគោគាចក៏បាន ការពារឆ្កែគាចក៏បាន ច្រត់ ខ្មៅងងឹតក៏ធ្លាប់ធឹតក៏បាន សូម្បីបុរសក្នុងទីងងឹតក៏ជ្រាបក៏បាន បុគ្គល ក្លាត់អណ្តែតនឹងប៉ះខ្ជួនបានដោយការគាត់នៃឈើច្រត់ ។

ព្រាហ្មណ៍ចាស់ក៏ព្រមរៀន លុះរៀនគាថានេះចប់ហើយ ក៏ចូលទៅកាន់ពេធប្រដុំរបស់ពួកព្រាហ្មណ៍ ដែលមានកូនទាំង ៤ នាក់អង្គុយនៅជាមួយផង ហើយសូត្រគាថានេះ ។

"សេចក្តីដំណាលថា: កូនដំនាន់នោះ ចរិយាវត្តរបស់អ្នកស្រុក គេបញ្ញត្តថា: បើកូនណាមួយបានទទួលមត៌កពីមាតាបិតាហើយ មិនចំនុកបំរុងថែទាំមាតាបិតាវិញទេ ត្រូវគេប្រហារជីវិតចោល" ។

គាន់តែតាព្រាហ្មណ៍ សូត្រចប់គាថាភ្លាម, ពួកព្រាហ្មណ៍ទាំងនោះ ផ្អើលធោធ្លោក្រែកក្រើនរកដំបងព្រនង់ប្រហារនឹងវាយកូនតាព្រាហ្មណ៍ទាំង ៤ នោះចោល ។ កូនព្រាហ្មណ៍ភ័យខ្លាំងទើបក្រាបទៀបជាតាបិតាហើយសូមទោសបាននាំបិតាទៅចំនុកបំរុង: កូនម្នាក់ៗ បានឲ្យសំពត់ ១ គូ ទឹងនិច្ចកត្តទៀត ។ តាព្រាហ្មណ៍លុះបានសេចក្តីសុខហើយ ក៏ទឹកដល់គុណព្រះសាស្តាដែលបានបង្ហាញគាថា ទើបនាំយកសំពត់ ៣ គូ ទឹងនិច្ចកត្តទៅថ្វាយព្រះដ៏មានព្រះភាគ; ព្រះអង្គទ្រង់ទទួលយកទេយ្យវត្ថុនោះដោយសេចក្តីអនុគ្រោះចំពោះព្រាហ្មណ៍ ។

ថ្ងៃក្រោយមក, ព្រះជិនស្រីស្តេចយាងមកបិណ្ឌបាតផ្ទះកូនព្រាហ្មណ៍ទាំងនោះ ទ្រង់សំដែងធម៌សរសើរបុគ្គលដែលចិញ្ចឹមមាតាបិតាដោយអនេកបរិយាយថា: "អ្នកទាំងឡាយដែលចំនុកបំរុងមាតាបិតា ជាការប្រពៃពេកណាស់ ត្រូវតាមទំនៀមគន្ធព្វរបស់អ្នកប្រាជ្ញពីបុរាណមកលោកឆ្ងាប់ប្រតិត្តសន្ធំមិនដែលលះបង់ឡើយ" ទើបព្រះអង្គនិទានរឿងដូចតទៅនេះ:

ក្នុងគាលគន្ធវិលេបនៈហើយ គាលនោះពោធិសត្វកើតជាដំរីឈ្មោះឆទន្តបាលករ៉ា មានរាយរ៉ាសស្តុះ មានតន្ត្រីយពេញលេញ គួរពិតពិលរំមើលមើលនៃក្អែកអ្នកដង ទៅក្នុងព្រៃហិមពាន្តជាមួយនឹងមាតាចាស់ដងនឹត ខឹងហ្វូងដំរីនេះរឿតជាច្រើន ។ ថ្ងៃមួយពោធិសត្វកើតសេចក្តីធុញគ្រាន់នឹងភ្លុកបំពែរ ព្រោះមិនបានបំរើមាតាដែលខ្វាក់ងងឹតងងល់ដោយគោរព រើបកៀសខ្លួនទាំយកមាតាទៅលាក់ក្នុងញកក្នុចណ្ណោះណ: ដើរស្វែងរកផ្លែឈើមើមឈើនឹងស្មៅខ្ចីដាដើម មកបញ្ចុកមាតាកាលថ្ងៃ ។

ចំណោចិរកាលតមកវាងក្រៃយ, ព្រានព្រៃម្នាក់ទៅក្រុងពារាណសី ដើរបោកញ៉ាំសត្វ ដល់ត្រង់កន្លែងនោះក៏វង្វេងផ្លូវ ស្រែកយំក្តែងៗកណ្តាលព្រៃ ។ ពោធិសត្វនឹកអាណិតអាសូរក៏ចាប់បុរសនោះឲ្យជិះលើខ្នងនាំទៅតាន់ក្រុងពារាណសីវិញ ។ រីឯបុរសនោះ ជាមនុស្សចិត្តអាក្រក់ទ្រុស្តមិត្រ អកតញ្ញូ ។ កាលដែលដំរីមង្គលរបស់ស្តេចពារាណសីស្លាប់ទៅ ទ្រង់ឲ្យរាជបុរសប៉ាវតង់ខួងកេរ៉ែ រកដំរីដែលមានមាឌធំសក្តិសមគួរយកធ្វើជាព្រះទីនាំងប្តូរ ។ បុរសនោះប្រាប់រាជបុរសតាមទំនងដែលខ្លួនឃើញដំរីពោធិសត្វទៅក្នុចណ្ណោះណ: ក៏ដើរជាមគ្គទេសក៍នាំគេទៅចាប់ពោធិសត្វមកថ្វាយ ។ ព្រះបុរោពារាណសីទ្រង់ទតឃើញកាលណា មានព្រះហឫទ័យត្រេកអរសោរ ទ្រង់បង្គាប់ឲ្យគេនាំទៅតាន់ពេធដំរី ហើយបិទ

ប៉ាំងកំនន ព្រោះតែគ្រឿងក្រអូបផ្សេងៗហើយឲ្យចំណីដែលមានរស
ឆ្ងាញ់ ។ តែធនឋាលកៈមិនព្រមបរិភោគសោះ អស់ភ្លេះល្ងាច ទើប
ព្រះពុទ្ធទ្រង់ត្រាស់សួរដំរីថា: "ម្នាលគោតមសោះ អ្នកមានហេតុអ្វី ឃានជាអ្នកមិនបរិភោគ
ចំណីនេះអ្នកឈឺក្តៅក្តៃ ឬឈឺថ្លាត់ក្នុងខ្លួនឬណា?" ។ - បពិត្រព្រះ
នាថ្លៃពិនន្ទរបស់តី! ឃានជាខ្ញុំមិនបរិភោគចំណីនុ៎ះ ព្រោះចង់ទៅបរិមាគា
ជ្ឈិតគាត់ចាស់គ្រាំគ្រាវែមទ្រមងងឹតងងល ដើរទៅណាមកណាមិនរួច,
កាលខ្ញុំទៅជាមួយតែងហុចទឹកចំណីកាលថ្ងៃ បើឥតខ្ញុំហើយ មុខជា
ស្លាប់ទៅកន្លែងនុ៎ះមិនខាន ឯស្រ័យហេតុនោះ ឃានជាខ្ញុំមិនបរិភោគ
ចំណី ស៊ូប្រថុយស្លាប់ បើរស់ទៅមិនគាប់ទេ ស្លាប់ទៅប្រសើរជាង ។
ដោយអំណាចអានិសង្សដែលធនឋាលកៈទំនុកបំរុងមាតា ក៏បណ្តាល
ទឹកព្រះហឫទ័យស្តេចឲ្យអាណិតអាសូរ ទើបទ្រង់ប្រើឲ្យហ្នាំយឥតទៅវិញ
តែងតែកន្លែងដដែលវិញ ។

ចំណែកមេដំរីដែលទៅមាញកគ្នុនោះ ដល់ខ្លួវសេចក្តីទុក្ខវេទនា
ពន់ប្រមាណ ព្រោះត្រាត់ឮបាសថាកកូនទន្ទឹងអត់ទឹកចំណី ក៏ខ្លួញយំរៀប
រាប់ថា: "ឱ! កូនមាសមេតែមួយ អ្នកទៅឯណាបាត់សូន្យឈឹងម្ល៉េះ
ប្រហែលជាត្រូវព្រានវៃចាប់ស្លាប់ ឬគេវាត់យកទៅធ្វើជាគោហនៈ
ម្ល៉េះសមបើស្មៅអំពៅវៃ ដើមក្រៃតន់លាស់ខ្ចប់ខ្ចុល យ៉ាងណា

ទៅអេះ" ។ តាលោះយាងដល់ហើយថ្លែងប្រាប់រឿងនោះសព្វគ្រប់
មេដ៏វិមានចិត្តត្រេកអរហួសខ្លាំងក្នុងពេលដល់ស្តេចតាពណាសីថា : " ព្រះ
ពជាអង្គឯណា ខ្ញុំបានលែងកូនខ្ញុំដែលជាអ្នកគោរពកោតក្រែងចាស់
ព្រឹទ្ធាចារ្យ សូមឲ្យព្រះពជានោះបានចំរើនដោយសិរីសម្បត្តិក្នុងវេជន
គាស៍ សូមឲ្យមានព្រះជន្ម យូយឺនយូរអស់រយៈវស្សា" ។

កង់ពុទ្ធសាសនា, ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់លើកសរសើរបុគ្គល
ជាមាតាបិតានឹងបុត្រធីតាដែលបំរើមាតាបិតានោះ ដោយអនេកប្បការ ដូច
ន័យមានមកកង់សព្រហ្មកសូត្រ កង់គម្ពីរអង្គុត្តរនិកាយតិកនិបាត ថា, មាតា
បិតាឈ្មោះថា, ព្រហ្ម" ឯង ថា "បុព្វទេវ" ផង ថា "បុព្វាចារ្យ" ផង ថា
"អាហុនេយ្យបុគ្គល" ឯង របស់កូនប្រុសស្រី ។ បានជាមាតាបិតា ឈ្មោះ
ថា :ព្រហ្ម" ព្រោះលោកមានព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧ-
បេក្ខា ផ្សាយស្រោចស្រពលើកូនប្រុសស្រី ។ បានជាឈ្មោះថា "បុព្វទេវ"
សេចក្តីថា វិសុទ្ធិទេព គឺព្រះឱណាស្រព លោកមិនអើពើប្រកាន់កំហុស
ដែលជនតាលង្ហើបំពានលើលោក មានតែប្រាប់នូវសេចក្តីចំរើនដល់
បុគ្គលតាលនោះតែម្យាង បើគេគោរពបូជាដល់លោក រមែងបានផលា-
ន៍សង្ឃឹមច្រើន យ៉ាងណា : មាតាបិតាក៏មិនប្រកាន់កំហុសរបស់កូនប្រុស
ស្រី លោកប្រាប់តែសេចក្តីចំរើនដល់កូន បើកូនណាគោរពប្រតិបត្តិ
បូជា រមែងបានផលានិសង្សច្រើន យ៉ាងនោះដែរ ។ (មាន៣)

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ - ឃុន នាមឆាយាឥន្ទត្ថេរ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៦ ជាចៅអធិការវត្តគង្គា ឃុំតាំងក្រសាំង ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ បែន - ផង់ នាមធម្មាយាផលត្ថេរ កើតឆ្នាំវក អាយុ ២៩ វស្សា ៨ ជាចៅអធិការវត្តឯកលិងផល ឃុំចោងមោង ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មៀច - វស់ នាមធម្មាយាសុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៤៥ វស្សា ២៣ ជាចៅអធិការវត្តសំរោង ឃុំដីដុច ស្រុកចាំក្នុ ខែត្រតៃត្រែង ។

សញ្ញាប័ត្រលេខ ៦៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ - រ៉ូង នាមធម្មាយា ឥន្ទមុនិត្ថេរ កើតឆ្នាំចោះ អាយុ ៣៥ វស្សា ១៤ ជាគ្រូសូត្រធ្វេង វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ង - រត់ នាមធម្មាយា វិនយត្ថេរ កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៨ ជាចៅអធិការវត្តព្រៃចរ័ត្ន ឃុំចាម ស្រុកកំពង់ត្រែក ខែត្រដដែល ។

. សញ្ញាប័ត្រលេខ ៦៨៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
សោម - ព្រំ នាមនាយាសុវណ្ណកេសរ កើតឆ្នាំច អាយុ ៥២ វស្សា ២៧
ជាចៅអធិការវត្តបេង ឃុំ - ស្រុក - ខេត្តដដែល ។

. សញ្ញាប័ត្រលេខ ៦៨៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ហុក - ផេត នាមនាយាធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៧៣ វស្សា ៥២
ជាចៅអធិការវត្តទឹកជុំ ឃុំចោងមោង ស្រុកទឹកជុះ ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៦៨៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ជុម - ឈុម នាមនាយាគីរីសុធម្ម កើតឆ្នាំកុរ អាយុ ៣៩ វស្សា ១៧
ជាគ្រូសូត្រស្តាំ វត្ត - ឃុំ - ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
អ៊ុក - សាម នាមនាយាធម្មសិរីបញ្ញា កើតឆ្នាំជូត អាយុ ៦៦ វស្សា ៥
ជាគ្រូសូត្រធ្វើវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៨៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ជួន - ផាន់ នាមនាយ... កើតឆ្នាំជូត អាយុ ៦៦ វស្សា ៥ ជាគ្រូសូត្រ
ធ្វើវត្តជ្រោយអម្បិលគោច ឃុំមៀន ស្រុកកៃពឈរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៩០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ហុង - សេង នាមនាយាផោតញ្ញាណោ កើតឆ្នាំមមី អាយុ ៣៣
វស្សា ៧ ជាចៅអធិការវត្តអញ្ចាញ ឃុំបូស្សីគ្រាក ស្រុកមង្គលបូរី
ខេត្តបាត់ដំបង ។

(មានត)

ECOLE FRANÇAISE
(BIBLIOTHÈQUE)

កែពាក្យខុសក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៤០

សៀវភៅលេខ ១

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
រវាង ៧ ថ្ងៃ	រវាង ៣ វេ	៦៤	៣

សៀវភៅលេខ ៧

កែត្បាន្ទុកាព	កត្បាន្ទុភាព	៤៨៤	១៩
ព. ស. ១០១១	គ. ស. ១០១១	៤៨៩	១៩
ព្រឹត្តិការ	ព្រឹត្តិការណ៍	៤៩០	១៦
នៅមហានគរ	នៅមហានរក	៤៩០	១៧
ជូចនិយដ្ឋាន	ឋូជនិយដ្ឋាន	៤៩១	១
Olifarchie	Oligarchie	៤៩២	៧
ស្រុះស្រុល	ស្រុះស្រួល	៥០២	១៧

សៀវភៅលេខ ៨

គ្រងវៃគ្រ ១	គ្រងពិភព	៦០១	១១

1461

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៃ អក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសង្ឃ ស្ង - ហាយ
ក្រុមជំនុំព្រះវិន័យ នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ពុទ្ធសាសនបណ្ឌិត្យ	សេចក្តីដូចដំណឹង រៀងទស្សនាវដ្តី	៣២១
ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថៃន	ព្រះរាជក្រឹត្យ ក្រមទេសកវិយោ (តមក)	៣២៥
លោក ម៉ុញ - តាំគ្រី	ស័ព្ទបាភាំងប្រែជាខ្មែរ (តមក)	៣៣១
លោកសាង - សាភិត លេខាធិការ	រឿងព្រៃតភូមា (តមក).....	៣៣៦
អ្នកឧកញ៉ាវិបុលរាជសេនា ង្វ - ពន	រឿងសាមកុក (តមក)	៣៤៤
— ទេពតិទ្ធ ឈឹម - ក្រសេម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).....	៣៥១
អ្នកអង្គម្ចាស់ក្សត្រី ន. សុភាតារី	សារតារវត្តអង្គារសេ (ត-ចប់)	៣៥៦
លោកផែង - ដ្រែ	ប្រវត្តិរបស់អេសុប (តមក)	៣៦៣
ផ្នែកសាសនា		
អ្នកឧកញ៉ាទេពតិទ្ធ ឈឹម ក្រសេម	ប្រវត្តិព្រះកែវមរកត (ត-ចប់)	៣៦៩
សាមណេរ គក - គីឡេង	រឿងតាងចងាចារ (ត-ចប់)	៣៧៩
លោក អ៊ុម - គយ សាស្ត្រាចារ្យ	ប្រវត្តិព្រាហ្មណ៍ចាស់ (ត-ចប់)	៣៨៦
កំណត់ទំនឹងប្រវត្តិការណ៍		
ពុទ្ធសាសនបណ្ឌិត្យ	ពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យ ដ្ឋិតមកជារដ្ឋាភិ-បាលខ្មែរ	៣៩២

ឆ្នាំទី ២២ — លេខ ១០ ខែតុលា ឆ្នាំ ១៩៥០ — ដំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

1461

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័ឃ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសង្គា ស្សរ - ហាយ
ក្រុមដំនុំព្រះវិន័យចំណិក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ពុទ្ធសាសនបណ្ឌិត្យ	សេចក្តីដូចដំណឹង រឿងទស្សនាវដ្តី	៣២១
ហ្វូងឥតទ្វេមន្ត្រី ញ៉ុក - ថែង	ព្រះរាជក្រឹត្យ ក្រមទសកវិយោ (តមក)	៣២៥
លោក ម៉ុញ - នាំគ្រី	ស័ព្ទបារាំងប្រែជាខ្មែរ (តមក)	៣៣១
លោកសាង - សាភិត លេខាធិការ	រឿងព្រៃគភូមា (តមក).....	៣៣៦
អ្នកឧកញ៉ាវិបុលរាជសេនា ង្វូ - ពត	រឿងសាមកុក (តមក)	៣៤៤
— ទេពតិទ្ធ ឈឹម - ក្រសេម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).....	៣៥១
អ្នកអង្គម្ចាស់ក្សត្រី ន. សុភាតារី	សាវតារវត្តអង្គរស (ត-ចប់)	៣៥៦
លោកផែង - ដ្រែ	ប្រវត្តិរបស់អេសុប (តមក)	៣៦៣

ផ្នែកសាសនា		
អ្នកឧកញ៉ាទេពតិទ្ធ ឈឹម ក្រសេម	ប្រវត្តិព្រះកែវមរកត (ត-ចប់)	៣៦៨
សាមណេរ ពក - គីឡេង	រឿងតាងចង្ការ (ត-ចប់)	៣៧៩
លោក អ៊ុម - ឆយ សាស្ត្រាចារ្យ	ប្រវត្តិព្រាហ្មណ៍ចាស់ (ត-ចប់)	៣៨៦

កំណត់ទិនប្រវត្តិការណ៍		
ពុទ្ធសាសនបណ្ឌិត្យ	ពិធីផ្តើមពុទ្ធសាសនបណ្ឌិត្យ ដ្ឋានមកាធរដ្ឋាភិ-
បាលខ្មែរ	៣៩២

ឆ្នាំទី ២២ — លេខ ១០ ខែតុលា ឆ្នាំ ១៩៥០ — ដំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire

Institut Bouddhique — Annonce de la Revue Kambujà Suriyà 1950 721

Luong Nibandhamantri Nhok-Thèm — Edit royal: Kramadasabhariyâ(suite) 725

M. Menh-Nakry ancien député — Recueil des mots traduits par la Commission Culturelle (suite) 731

M. Sang-Savath Secrétaire au Ministère des Finances — Contes birmans (suite)..... 736

Neak Oknha Vibularaja-séna Nou-Kân — Histoire de SAMKOK (suite)..... 744

Neak Oknha Debabidura Chhim-Krasem — Histoire du Royaume du Cambodge (suite)..... 751

Contesse Norodom Sukhanari, secrétaire de la Commission des Mœurs et Coutumes — Notice historique de Vat Attharasa (suite et fin) 756

M. Pheng Chrieu, professeur au Collège des Jeunes Filles — Biographie d'Esope (suite)..... 763

Partie religieuse:

Neak oknha Debabidura Chhim-Krasem — Historique du Bouddha d' Emeraude (suite)..... 768

Samanera Kok-Kileng — Histoire de Neang Patâcâra (poème) (suite et fin) 779

M. Oum Koy professeur à l'Ecole supérieure de Pali — Histoire d'un vieux brahman (suite et fin)..... 786

Notes et Chroniques

Institut Bouddhique — Cérémonies de transfert de l'Institut Bouddhique au Gouvernement Royal. 792

BIBLIOTHÈQUE NATIONALE
DÉPARTEMENT DES IMPRIMÉS
RÉSERVE FRANÇAISE
EXTRÊME-ORIENT

សេចក្តីផ្តួចផ្តើម
អំពីពុទ្ធសាសនបណ្ឌិត្យ
រឿង ទស្សនាវដ្តី កម្ពុជសុរិយា

សូមដំរាបជូនដំណឹងដល់បងប្អូនរួមជាតិចាំង ឲ្យាយ !

ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៤០ នេះ អស់លោកអ្នកបានបុះឈ្មោះជាវ មានចំនួនច្រើនជាងឆ្នាំមុនៗ ។ ពុទ្ធសាសនបណ្ឌិត្យបានយល់ឃើញជាក់ស្តែងថា អស់លោក អ្នកស្រឡាញ់អក្សរសាស្ត្រ ចាំងឧបត្ថម្ភអក្សរសាស្ត្របស់ជាតិ ឲ្យលូតលាស់ចំរើនឡើងដោយពិតៗ ។ ភិច្ចដែលបងប្អូនរួមជាតិស្ម័គ្រចុះឈ្មោះជាវច្រើនឡើងៗ នេះ ឈ្មោះថាឲ្យកម្លាំងដល់ពួកអ្នកនិពន្ធក្នុងគ្រួមយើង ឲ្យចំតែងចំរៀបរៀងនូវរឿងក៏ៗ ថ្មីកៗ ដែលមានសារប្រយោជន៍ច្រើន ចាំងចំរៀបចំរបៀបពាក្យពេចន៍ឲ្យរឹងរឹតតែពីរោះចាប់ចិត្តជាកិរិយាកាពឡើង ។ យើងមានសង្ឃឹមថាអស់លោក - អ្នក មុខជានឹងបុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយា ក្នុងឆ្នាំ ១៩៤១ តទៅទៀត ហើយនឹងជួយផ្សាយដំណឹងអំពីប្រយោជន៍នៃទស្សនាវដ្តីយើង ក ។ ទៅដល់បងប្អូនរួមជាតិដែលនៅជិតខាងជាពុំខាន ។

ឯរឿងក៏ៗ ចាំងផ្នែកអក្សរសាស្ត្រចាំងផ្នែកសាសនា ដែលយើងយល់ឃើញថាមានប្រយោជន៍សំខាន់ដល់បងប្អូនរួមជាតិ ហើយបានគ្រោងទុកបំរុងនឹងប្រោះពុម្ពក្នុងឆ្នាំ ១៩៤១ ដូចមានរាយមាតិកា តទៅនេះ ៖

ផ្នែកអក្សរសាស្ត្រ:

១ – អក្សរសាស្ត្រខ្មែរ (គោលចារឹកខាងផ្នែកអក្សរសាស្ត្រ ព្រម
ទាំងពាក្យកាព្យឃ្លោងចាស់ៗ ឬទំនើបថ្មី) ។

២ – ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា នៅមានចោះពុម្ពតទៅ
ទៀត ។

៣– ឯកសារ (រឿងរ៉ាវសំខាន់ៗ ដូចសិលាចារឹកជាដើម) ។

៤ – រឿងសាមកុក នៅតែចោះពុម្ពតទៅទៀត គ្រាតែចប់ ។

៥ – វប្បធម៌(ពាក្យប្រាកដែលជាខ្មែរបស់គណៈកម្មការវប្បធម៌)។

៦ – សុភាសិតផ្សេងៗរបស់ជាតិយើងនឹងនានាជាតិ ។

៧ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៨ – ទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ ។ល។

ផ្នែកសាសនា:

១ – ដំណឹងផ្សេងៗក្នុងព្រះពុទ្ធសាសនា ។

២ – ធម្មទេសនា ដែលមានអត្ថរសប្លែកៗ ។

៣– សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ – នឹងដើរសម្លែងរឿងក្នុងព្រះសូត្រខ្លះ ដែលជាផ្លូវប្រែតិបត្តិ ។

ប្រយោជន៍នៃទស្សនាវដ្តីកម្ពុជសុរិយា

បងប្អូនរួមជាតិទាំងឡាយជ្រាបស្រាប់ហើយថា ទស្សនាវដ្តីនឹង
សារពត៌មាន ក្នុងប្រទេសយើង មានមិនលើសពី ២-៣ ឈ្មោះ

ប៉ុណ្ណោះ ។ ចំនួននេះបើយកទៅធៀបនឹងចំនួនទស្សនាវដ្តី សារពត៌មាន ក្នុងប្រទេសគេជាតិខាងប្រទេសយើង ឃើញថាខាងយើងតិចជាងគេឆ្ងាយណាស់ ស្ទើរតែកាប់ថាមាននឹងគេពុំបាន ។ ខាងយើងដែលមានបញ្ជាបករណ៍ទាំងនេះតិច មកពីយើងខ្វែរអ្នកស្នេហ៍អានមានចំនួនតិចនាក់, ខាងគេដែលមានបញ្ជាបករណ៍ច្រើន មកពីជាតិគេមានអ្នកចូលចិត្តអានច្រើន ។ បញ្ហាដែលជាផលកើតមកអំពីការអានច្រើននឹងការអានតិចតែងអនុវត្តទៅតាមគ្នា គឺបើក្នុងប្រទេសណា មានអ្នកអានច្រើននាក់ក្នុងប្រទេសនោះ អ្នកចេះដឹងក៏មានច្រើន; បើអ្នកអានមានតិច អ្នកចេះក៏មានតិច ។ ចំពោះរូបមនុស្សម្នាក់ៗ ក៏មានន័យដូចគ្នា គឺអ្នកណាអានច្រើន អ្នកនោះចេះដឹងច្រើន, អ្នកអានតិច ចេះដឹងតិច, អ្នកមិនអានសោះ ក៏មិនចេះសោះ សមដូចបុរាណសុភាសិតថា "បើអានតិចច្រើន នឹងចំរើនសព្វថ្ងៃទៅ ដូចឃ្មុំដប់ទឹកនៅ ផ្កាឈើត្រៀកកូមិថាន" ។ ព្រោះថាទស្សនាវដ្តី សារពត៌មាន ជាឃ្លាំងវិជ្ជា មានមុខការខាងបណ្តុះដាំផ្សាំប្រជាជនៃអ្នកអានឲ្យដើរទាន់សម័យ ។

មែនពិត ទស្សនាវដ្តីយើងហើយនឹងអ្នកអាន ឈ្មោះថាឲ្យកម្ចាត់ផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក ។ តាមន័យនេះ ឃើញថាបងប្អូនរួមជាតិដែលចេញសៅហ្មុយជាវទស្សនាវដ្តីយើង បានផលជា ៣ ចំណែក គឺ :

១ — ជួយទស្សនាវដ្តីយើងឲ្យមានអាយុស្ថិតនៅយូរអង្វែង

២ — តាលអស់លោក - អ្នកបានកាន់ហើយ នឹងកើតមានប្រាជ្ញាភ្លឺស្វាងកង់ផ្លូវលោកផ្លូវធម៌

៣ — ផលជាកំពូល គឺអស់លោក - អ្នកនឹងមានកេរ្តិ៍ឈ្មោះថាជាអ្នកចាក់ទឹកស្រោចដីរឲ្យអក្សរសាស្ត្រខ្មែរយើង ដុះលូតលាស់ចំរើនទាន់តាលសម័យ ឲ្យមានទឹកមុខស្មើនឹងអក្សរសាស្ត្រនានាជាតិ ។

ហេតុនេះ សូមអស់លោក - អ្នកដែលមានចំណងជាវទស្សនាវដ្តីយើងប្រចាំឆ្នាំ ១៩៥១ សូមផ្ញើឈ្មោះចុះនាមទីលំនៅនឹងប្រាក់ចំនួន ១៤៥ រៀល ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ កុំពេញ ក្នុងពេលឆាប់ៗ ។

ពុទ្ធសាសនបណ្ឌិត្យ កុំពេញ

Adresse:

M. le Secrétaire Général
de l'Institut Bouddhique
à Phnom-Penh

ព្រះភគវន្តកថា

កម្មទស្សនវិយោ

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្ដា ' (ចៅពញាស្ទរ) ព. ស. ១៦៩៣

ហ្លួងធិពន្ធមន្ត្រី ញាក-ថែម រួបរួម

(ភាគ)

បើចៅដែលគេថានោះ មានតំណាត់ចំណាំថាន់ខ្លួតឈ្នះឯកខ្លួតទោខ្លួត តើខ្លួតនោះឲ្យយកអស់ខ្លួនមកបែងជាភាគ ៣ ចោលភាគ ២ ឲ្យយក ភាគ ១ ឲ្យចៅដែលតំណាត់ចំណាំគេជាដំពាក់សងរបស់ខ្លួន ដែលតំណាត់មកពិន័យចៅដើមគ្គី ១ ជា ២ ហោង ។

មាត្រា ១ (សោត) ទោះអ្នកផងដំពាក់សារតើបំណុលនៃអ្នកផង បើម្ចាស់បំណុលនោះស្លាប់ នៅតែតំណាត់ចំណាំដំពាក់សារតើរបស់ខ្លួន នៅ (នឹង) ចៅនោះ អានោះ នាងនោះ មេនោះ មានបងប្អូនកូនកួយ ចៅភ្នែចដែលស្លាប់នោះដឹងផងគ្គី ចុះនៅតារាលវាសនូវឡើយ ប្រពន្ធ ចៅដែលដំពាក់បំណុលនោះដឹងផង នោះហៅថាសាក្សី ទើបឲ្យតារអំពីចៅនូវអាមេមានតួ បើតួប្រែកែកថា ពុំមានដំពាក់អ្វីៗ ឡើយ ទើបប្រពន្ធកូនចៅបងប្អូនភ្នែចស្លាប់នោះប្តឹងចៅត្រែម ឲ្យអាជ្ញាអ្នកតណ្ហាល នៅប្រកោះតួដែលដំពាក់របស់ខ្លួនគេនោះមកបង្គាប់ឲ្យកត់ពាក្យ ដោយដំណើរ បើរកនៅ (ឃើញ) ច្រកដមែន ដូចគេប្តឹងហើយ ឲ្យលក់

សុរិលបង់ ។ ប្រើប្រាស់យកយ៉ាងដំអម្ចាស់ទ្រព្យវិញស្មាប់ ឲ្យលក់សុរិលបង់ ហើយឲ្យបែអស់ទ្រព្យរបស់ប្រពន្ធកូនជារបៀបហោង ។ បើរបួសពុំពិការ សាគង់រូបរស់ពុំស្លាប់ឡើយ ឲ្យលក់ជាច់សុរិលហោង ឲ្យខុនក្នាក់ជារ ហូតយកខ្លាត់ព្រៃឃ្មាំងពុះគ្រែងហោង ។

មាត្រា ១ (សោត) ទោះអ្នកជងអន្ទង់ចោរក្តី បបួលចោរក្តីឲ្យទៅប្លន់ជាញ់ចាក់គាប់សម្ងាប់គេនោះក្តី ទោះគេចាប់ចោរនោះបានក្តី បើអាចោរវាស់សន្លាក្តី វាបបួលអន្ទង់គ្នាក្តី វាថាគេជួលក្តី ឲ្យចៅពញាជាញ់ចាក់គាប់ ប្រែឲ្យចាប់កែនាងនោះអានោះមេនោះ ទើបឲ្យចៅត្រមឲ្យអាជ្ញាអ្នកកណ្តាលទៅចាប់ដែលជួល ដែលបបួល (ចោរ) ប្រែមកកត់ពាក្យខ្លួវអស់ដំនុំហើយ ទើបឲ្យដំនុំពិចារណាពាក្យអាចោរ ប្រែខ្លួវអាចោរអន្ទង់ខ្លួវអាចោរបបួល នៅខ្លួនចោរដែលជួល បើដំនុំហើយ បានជាអន្ទង់ចោរក្តីអន្ទង់ខ្មោចក្តី ឲ្យលក់សុរិលបង់ ។ បើប្រែកែកឲ្យចាប់ឆ្មែត បើបានខ្លួតឈ្នះឯកខ្លួតហើយ ចាញ់ទោខ្លួតខ្លួវត្រីខ្លួត ឲ្យសងពេញជ្រាកដជាចោរតាមព្រះច្បាប់ទោះបានខ្លួតចាញ់ឯកខ្លួតនៅត្រីខ្លួត ឲ្យបែងទ្រព្យនោះជាភាគ ៣ ភាគ ១ ទោល យកភាគ ២ មកឲ្យចៅដែលកំណាត់ចំណាំគេថាជំពាក់នោះ សងរបស់ទ្រព្យគួនោះហោង កុំឲ្យពិន័យឡើយ ជ្រួតឥតដំណឹងម្ខាង ។ បើមានកំណាត់ចំណាំខ្មោចជំពាក់សារតើទ្រព្យរបស់ខ្លួវចៅនោះ ខ្លួវអានោះ នាងនោះ តែអស់បងប្អូនប្រពន្ធខ្មោចនោះ

ជិនផង ហើយអស់បង់ប្អូនប្រពន្ធកូនចៅដែលកំណត់ចំណាំខ្មោចថាដំណាក់នោះ គេពុំដឹងផងនោះឥតសាក្ស៊ី កុំឲ្យដឿកំណត់កត់ចំណាំនោះឡើយ ។

មាត្រា ១ (សោត) គោះចោរហានេយ្យ៌ គោះចាញ់ចាក់កាប់សម្លាប់គេនឹងជាវនឹងសំពែង កាំភ្លើង នឹងស្នានឹងធ្នូ នឹងសម ចង្រៃប់ ឆ្កែ មូលស្នូរ កន្ទុរ បើពុំបានស្លាប់ប៉ុន្តែរបួសជាទម្ងន់ ពិការនឹងធ្វើព្រះពជគារពុំបាននោះទុកស្មើស្លាប់ ឲ្យរកចោរឯណាដែលចាញ់ចាក់កាប់គេនោះឲ្យសម្លាប់ហើយរឹបអស់របស់ទ្រព្យប្រពន្ធ (កូន) ថ្លាត់ថ្លាយហោង ។ បើអាចោរឯណាវាជាគ្នានឹងអាចោរនោះ ឲ្យគេដើមក្តីប្តឹងឲ្យគោះចាប់មកដណ្តឹងពិចារណាបើវាប្រែកថាខេ ពុំបានចាញ់ចាក់ ពុំបានលួចរបស់ទ្រព្យចង្អុលនោះ ឲ្យប្រកាន់ចាប់ខ្នោត បើដើមក្តីបានគ្រឹខូតឯកខូត បើចុងក្តីនូវចោរបានគោខូតនោះ ឲ្យយកគោខូតនូវគ្រឹខូតទុកជាស្មើគ្នា ឲ្យយកឯកខូតគេដើមក្តីជាឈ្នះ ហើយឲ្យយករបស់ទ្រព្យមកបែងជាភាគ ៣ ភាគ ១ ចោល យកភាគ ២ ឲ្យសងគេហោង ឲ្យខុនភ្នាក់ងារកាត់ថ្លៃទ្រព្យរបស់ ១០ យក ២ ឯខ្លាត់ស្មុកគោងទ្រពងនោះឲ្យហូតយកតម្លឹង ៣ ជ្រុតមុខងារចូលគ្នាហោង (១) ។

មាត្រា ១ (សោត) គោះអ្នកផងធ្វើសាលាលើកខ្មោច គោះនាហ្លឺន ដំទាវ នាង៥ុនណាង៥ នូវបារគូបុរោហិតបែងសាលាគ្រឹះនោះ ខុន ១ ភ្នាក់ងារហូតយក (ខ្លាត់) ថ្លាត់ថ្លាយកម្លឹង ១២ សាលាសំរាំ

តម្លឹង ៥ ធ្វើរាជធូបខ្មោចដំគល់ផ្ការាល់ដីឲ្យយកតម្លឹង ៧ ធ្វើជារាជនឲ្យយក តម្លឹង ៦ ។ បើបានច្រាប់ តម្លឹង . . . ក៏បាន ចាត ៦ ក៏បាន បើផ្ការាជ អាកាសសាលានាំជាដួលដាវធ្វើនោះ ពុំបានច្រាប់ ឲ្យយកក្រយាពិន័យ អំពីអាដែលដួលមកបែងយកតាមដូចការោតម្រែត ឯក្រយាពិន័យការោត ដណ្តើងដួលនោះទុកស្មើប្រើចោរហោង ឲ្យខុនក្នាក់ងារហួតខ្លាត់មុខងារ តម្លឹង ៣ យក (ជាក់) ព្រះឃ្លាំងពុះគ្រឿងហោង(២) ។

មាត្រា ១ (សោត) នរអ្នកផងឈ្លោះគ្នាប្រកាយគ្នានឹងដំបងឈើ ឬស្បៃដែលជាំជាម នោះពិន័យតម្លឹង ១២ ដើងកោះស្លឹង ១០ ខុនក្នាក់ងារ ហួតខ្លាត់តម្លឹង ៣ ឯខ្លាត់ព្រះឃ្លាំងពុះគ្រឿងហោង ។ បើខ្ញុំគេនឹងខ្ញុំគេ ឈ្លោះប្រកាយកាយគ្នាដល់ជាំជាម ឲ្យយកខ្លាត់ចាត ៦ ដើងកោះចាត ៥ និមួយខ្លួនហោង(៣) ។

មាត្រា ១ (សោត) នរអ្នកផងសាហាវដេរប្រពន្ធកូនគេ ឲ្យពិន័យ តម្លឹង ១២ ដើងកោះស្លឹង ១០ ខុនក្នាក់ងារហួតខ្លាត់តម្លឹង ៣ ព្រះឃ្លាំង ពុះគ្រឿងហោង ។ បើស្រីដេរប្រុសតម្លឹង ៦ ដើងកោះស្លឹង ១០ ឲ្យខុន ក្នាក់ងារហួតយកខ្លាត់ចាត ៦ ហោង ។

មាត្រា ១ (សោត) គោះអ្នកផងស្នងអន្ទកវនឹងគ្នា ចាន់កូន ១ ក្តី

---

១ - ២ - ៣ ទាំងប៉ុន្មានមាត្រានេះ មិនសមមកចាប់ចាញ្ជូលក្នុងក្រមទេ សភារិយាទេ ព្រោះ ទំយាយតែអំពីរៀងចោរខ្លួយឬឈ្លោះទាស់នៃងគ្នាឯង ។

កូន ២ ក្តី (ហើយ) ប្រែលែងលែងគ្នាវិញ ឲ្យយកខ្លាត់ចាន ៦ ដើង កោះស្មឹង ១០ និមួយតួហោង ។

មាត្រា ១ (សោត) នារីស្រីឈ្លោះគ្នាដេរវាយគ្រែចៅដាំជាមនោះ ឲ្យពិន័យតម្លឹង ១២ ដើងកោះស្មឹង ១០ ។ បើឈ្លោះប្រែកែកដេរ តែពុំបានវាយគ្នាដាំជាមនោះ ឲ្យពិន័យតម្លឹង ៦ ដើងកោះស្មឹង ១០ ខុនក្លាក់ងារហូតខ្លាត់ចាន ៦ ហោង ។

មាត្រា ១ (សោត) គោះប្រុសផងចងកស្លាប់នោះ ឲ្យខុនក្លាក់ងារ កោះយកអ្នកដែលនៅជាមួយនឹងអ្នកចងកឯង មកជណ្តឹងពិចារណាវាក បើឥតគោស ចងកស្លាប់ខ្លួនឯងនឹងខ្សែវល្ល៍ ឲ្យខុនក្លាក់ងារហូតយកខ្លាត់ អំពីកូនប្រពន្ធបងប្អូនដែលនៅជាមួយតម្លឹង ៣០ ។ បើគេគោសឃើញ ជាមានគោសមែន ឲ្យយកជញ្ជាំង ៣ ថ្នាត់ថ្នាយ បើចងកនឹងសំពត់ អម្បោះ សូត្រ ព្រៃ ខ្សែព្រាលនោះ ចូលមុខងារឲ្យ (យក) ខ្លាត់ ដើមឈើតម្លឹង ៣ ទូវដើងកោះស្មឹង ១០ ហោង ។ បើស្រីចងកស្លាប់ នឹងខ្សែវល្ល៍ ឲ្យខុនក្លាក់ងារយកដាំង ៧ តម្លឹង ៥ បើគេគោសឃើញ ជាមានគោសមែនអំពីអ្នកដែលនៅ ។ បើឥតគោសហើយចងកនឹងខ្សែ ព្រាល អម្បោះ សូត្រព្រៃនោះ ឲ្យខុនក្លាក់ងារហូតយកខ្លាត់ ដើមឈើ ចាន ៦ ទូវដើងកោះស្មឹង ១០ ហោង ។

មាត្រា ១ (សោត) ខោះប្រុសប្តីដេរប្រពន្ធសាហាវនឹងចិត្តឥតខោសឥតគំនាប់ខោះ ឲ្យពុនក្នាក់ងារហួតយកខ្លាត់តម្លឹង ៣ ដើងកោះស្វឹង ១០ ហោង ។ បើស្រីប្រមាថប្តីឥតខោសឥតគំនាប់ ឲ្យហួតខ្លាត់តម្លឹង ៥ ដើងកោះស្វឹង ១០ ហោង ។

មាត្រា ១ (សោត) ខោះស្រីឯងប្រឈ្មោះប្រកាយដេរកាយគ្នាជណ្តើមប្តីជណ្តើមសង្សារ បើប្តីកូដមែនជាលួចប្តីលួចសង្សារគ្នាមែន ឲ្យយកកាំបិតស្វាន្ទូរអម្បែងចាន ចូរមុខចូរទ្រនាង បើលោះកាំបិតស្វាន្ទូរអម្បែងចានជាប្តីតម្លឹង ៥ ន្ទូរដើងកោះស្វឹង ១០ ។ បើពុំប្តីកូដជាខោះជាសាហាយ ខោះស្រីសាហាយដេរនឹងអំណាចឲ្យពិន័យជាប្តីតម្លឹង ១២ ដើងកោះស្វឹង ១០ និមួយៗពុនហោង ឲ្យពុនក្នាក់ងារហួតយកខ្លាត់តម្លឹង ៣ និមួយតួ ព្រះឃ្លាំងតម្លឹង ៦ ជាង ១ ថ្លាត់ថ្លាយហោង ។

មាត្រា ១ (សោត) នរអ្នកដងប្រលែងលែងគ្នាក្តី លួចប្រពន្ធគេពុំបាននាំរត់ក្តី ខោះកាចនឹងកូនក្រមុំគេនឹងខ្ញុំគេពុំបាននាំរត់ក្តី ខោះកាចហើយបាននាំរត់ក្តី បើមានមេអណ្តើកមេនាំការប្រពន្ធគេកូនក្រមុំគេខ្ញុំគេក្តី ខោះត្រូវក្រយាពិន័យអាប្រុសន្ទូរមេស្រីដ៏កាចខោះ តែគុណចតុគុណត្រូវមេអណ្តើកមេនាំការភាគ ៨ បើជួយនាំរត់ខោះភាគ ៧ បើមានគេឲ្យលាក់បំពួនទៅផ្ទះទៅព្រៃក្តី ខោះត្រូវភាគ ៦ បើឲ្យអង្គរស្បៀងស្មាមួខោះត្រូវភាគ ៥ ត្រូវអាប្រុសភាគ ១០ ។ (មាន៣)

សព្ទចាក់ផ្សែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

លោកមិញ - ផាគ្រី រួបរួម

(ត្រឹមក)

Simple (un homme simple) = សាមញ្ញ , ភបសា

Simplicité = សេចក្តីភបសា

Emancipation = អត្តាចិនភាព (ការផុតពីអាណា-
ព្យាបាល)

Libération = សេរីភា

Chancelier = សង់សឺលីយេរ

Pionnier = អ្នកត្រួសត្រាយ

Clergé = សហធម្មិក (បព្វជិតដែលប្រព្រឹត្ត
ធម៌ត្រូវគ្នា)

Reportage = ការយកពត៌មាន

Faveur = អនុគ្រោះ

Avis favorable = យោបល់យល់ព្រម

Temps opportun = កាលគួរ

inopportun = កាលពុំគួរ

Diabète = មជ្ឈហោមរោគ (រោគទឹកមូត្រផ្អែម)

Corp franc khmer = កងឯករដ្ឋខ្មែរ

Ridicule = ដែលគួរសើចចំអក

Scrupule = កាសង្កា (សេចក្តីរង្គៀសចិត្ត)

Remords = វិប្បដិសារ (សេចក្តីស្តាយក្រោយ)

Le Repentir = វិប្បដិសារ (សេចក្តីស្តាយ, មនៃ, ក្រោយ)

Le Rendez-Vous = ការណាត់ជួបគ្នា, ទីណាត់ជួបគ្នា

11 — 10 — 49

Caprice = កបិចិត្ត, ចិត្តសាក់

Echéance = ថ្ងៃសងបំណុល, ឥណប្រតិទាន

Scène = ឈុត, វិការដ្ឋាន

Classement annuel = ការចាត់ថ្នាក់ប្រចាំឆ្នាំ

Classement hebdomadaire = ចាត់ថ្នាក់ប្រចាំសប្តាហ៍

25 10 49

Commandant du Secteur Sud = អ្នកបញ្ជាការយ៉ាងតំបន់

— du Quartier — — សង្កាត់

— du sous Quartier — — សង្កាត់រង

Vigilance = អប្បមាទ

Négligence = សេចក្តីប្រមាទ

Maltraiter = ធ្វើទុក្ខ, ធ្វើបាប

Offense = ការប្រមាថ

Escadron = អស្សានីក

Torturer = ធ្វើទារុណកម្ម

28 10 — 49

Fragment = បំណែក, ផ្នែក

Fragments de la pièce = ផ្នែករឿងល្ខោន

Pièce en un acte = រឿងល្ខោនកឯង្កមួយ

Biographie = ជីវប្រវត្តិ

Table des matières = បញ្ជីមាតិកា, បញ្ជីរឿង

A cause de = ដោយ ឬ ព្រោះហេតុតែ

Au profit de = ជាគំរាជល់, ជាប្រយោជន៍ដល់

Au détriment de = ជាការនាំឲ្យ . . ខូច

8—11—49

Artiste = សិល្បការ

Beaux-Arts = វិចិត្រសិល្ប

Ministère des Beaux-Arts = ក្រសួងសិល្បការ

Contre-seing = ហត្ថលេខាអម

Contresigner = ចុះហត្ថលេខាទទួ

Adaptation = ការយកលំនាំ

Imitation = តែមាប់

Imiter = តែាប់

Expédition des Affaires courantes. = កម្ចប់ចាត់ការសាមញ្ញ

15—11 49

Populaire = ប្រជាមានិត, សាមញ្ញ

Requérir = ប្តឹងតវ៉ា

Requérant = អ្នកប្តឹងតវ៉ា

Suggérer = ឲ្យយោបល់, ណែនាំ

Suggestion = ការឲ្យយោបល់, ការណែនាំ

Leçon = មេរៀន

18—11—49

Observer = តត់សំគាល់, សង្កេត, កាន់, ប្រតិបត្តិ

Observation = កំណត់សំគាល់, ការសង្កេត, ការកាន់, ការប្រតិបត្តិ

Internat = អន្តរសិក្សាគារ

Externat = ពហិរសិក្សាគារ

Forfait = ការមៃ្តផ្តាច់

Forfaitaire = ដែលមៅផ្តាច់

Sacrifice = ពលិកម្ម

Sacrifier = ធ្វើពលិកម្ម

22 11—49

Disposition = បទបញ្ញត្តិ

Principe = គោលការណ៍

Candidature = បេក្ខភាព

Charte = ធម្មនុញ្ញ

25—11—49

Le contrôle de l'Immigration = ក្រមត្រួតត្រាជនចូលស្រុក

Prérogative = បុព្វសិទ្ធិ

Modalité = បែបបទ

Compétence = សមត្ថកិច្ច, សមត្ថកម្ម, សមត្ថភាព

Des hautes parties contractantes = ឧត្តមភាគីគូសញ្ញា

Etendue = វិសាលភាព

Coordonner = សម្របសម្រួល

Règlementer = ដាក់បទបញ្ជា

Service des transmissions = ក្រមនាំសារ

Plan d'équipement = ផែនការណ៍សម្រាប់បរិភោគ

Transfert = ការផ្ទេរ

26—11—49 (មានត)

លោក សាង - សាភ័ត លេខាធិការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

ថាហើយនាងនៅស្ងៀមទន្ទេញមុខកើតទុក្ខយ៉ាងខ្លាំង ។ លុះនាងជូដាម៉ាសារីជាកូនលោកវរម្ន្ត្រីឮដូច្នោះហើយ ក៏នឹកក្នុងចិត្តថា: "អញយល់ហើយ ស្រីនេះក្បត់ចិត្តប្តីខេត្តើ ប៉ុន្តែស្រីនេះស្អាយក្រៃយ៉ាងពន់ពេក" ។ នាងក៏បង្ខំឲ្យស្រីនេះចេញពីកន្លែងនោះទៅ ហើយបានពោលពាក្យគួរសមរកពីរបីម៉ាត់ផង រួចមានបង្គាប់ឲ្យស្នៀនរបស់នាងសរសេរសេចក្តីដែលនាងបានពិភាក្សាជាមួយជនម្នាក់ៗ ដែលយើងបាននិទានមកហើយនេះ ។ លុះតាលណាតពុករបស់នាងបានស្តាប់សេចក្តីសព្វគ្រប់ហើយ លោកមានចិត្តត្រេកអរជាពន្លឹក ហើយបាននាំកូនក្តីទាំងអស់ទៅគាល់ព្រះករុណាជាអម្ចាស់ដ៏វិតលើតូង ដោយសារលោកបានផ្តាំបការពិតអំពីមាត់អ្នកដែលមានភោសទាំងពីរ ។

ព្រះករុណាទ្រង់ចេញព្រះពជ្រកិត្យមួយតាមពាក្យដែលនាងជូដាម៉ាសារីបានរៀបចំជាមុនមកដូច្នេះថា "ប៉ាយតាដែលមិនមែនប្តីនោះហើយដែលរៀបនឹងក្បត់ចិត្តនាងជាសហាយ ត្រូវទោសដល់ស្លាប់ខ្លួន, ក៏ប៉ុន្តែដោយអញអាណិត អញលើកទោសនេះឲ្យ, ឲ្យវាចេញពីព្រះពជធានីកុំ

បង្អង់ឡើយ, ឯកូនប្រុសរបស់មហាសេដ្ឋីដែលឥតគិតដល់ទ្រព្យសម្បត្តិ ហើយដែលមិនចេះក្រឡេកចិត្តសន្យានោះគឺជាប្តីរបស់នាងពិត, បុរសរូបនេះមានភរិយាគួរឲ្យសរសើរគ្រប់គ្នា; ឯចំណែកខាងនាងភរិយាដែលយំសោកនៅមុខអញនេះត្រូវគោរពសំឡាប់ដែរ ព្រោះបានធ្វើឲ្យឈ្មោះប្តីរបស់ខ្លួនអាប់អោនជាពន់ពេក, ប៉ុន្តែប្តីនាងនេះអភ័យទោសឲ្យ, អញក៏អត់ទោសឲ្យដែរ ព្រោះនាងនេះបានធ្វើបាបការពិត ដល់បុត្រីរបស់លោកវរជនមន្ត្រី ដោយបាននិទានយ៉ាងក្បោះក្បាយអំពីផ្ទៃឈើទុំដែលមិនអាចក្លាប់ទៅកន្លែងដែលជ្រុះវិញ នឹងអំពីកូនក្មេងដែលមិនអាចបួលទៅក្នុងផ្ទៃមាតាវិញបាន, នេះជាដំបូន្មានរបស់ព្រះអាទិត្យគ្រាយទៀតឥឡូវនេះអញឲ្យរួចខ្លួនចុះ” ។

ក្នុងពេលនោះ ទេវតាដែលរក្សាស្មូតច្នៃត្រៃស្រែកដោយឡើងដោយការបានឮព្រះអង្គមានព្រះបន្ទូលដូច្នោះ ។ ឯព្រះគុណាភ័ព្ទដ៏លើសកូនស្រីនៃលោកវរជនមន្ត្រីជាអគ្គមហេសី ដោយសារនាងបានប្រែចិត្តជ្រាយយ៉ាងអស្ចារ្យក្នុងរឿងនេះ ។

សុភាពបុរសទាំងឡាយ ! អ្នកគោរងធ្វើអង្គតឲ្យយ៉ាងម៉ត់ចត់ដូចនាងធូដាម៉ាសារី ក្នុងការលួចប្តូរ, ការចោកចាស់ ឬក្នុងការក្បត់ចិត្តដែលគេបញ្ជាសំណុំរឿងដល់សាលារបស់អ្នក; គោរងអ្នកបំភ្លឺឲ្យច្បាស់យ៉ាងប្រសប់ដូច្នេះហោង ។

៣ – ជាងសូនឆ្នាំង ឆ្នឹង អ្នកបោកខោអាវ

"បាចដួលឈរលើទួលច្រាសខ្សល់
ដួលរលៃហ៊ែរមកដល់អ្នកបាចវិញ
អ្នកឈ្នានិះរះឲ្យគេកើតទុក្ខម្ញេញ
ទុក្ខនោះចេញកើតមានពេញអ្នកឈ្នានិះ"

សេចក្តីឈ្នានិះពាក្យបាចឲ្យគេមានទុក្ខ នឹងនាំឲ្យខ្លួនមានទោសទុក្ខវិញ ដូចមានរឿងជាងសូនឆ្នាំងតទៅនេះ:

កន្លងកាលដ៏កន្លងទៅយូរអង្វែងហើយ ក្នុងសាសនាព្រះពុទ្ធព្រះនាមធូមីយ៉ាទ: "Thourmayda" បានជាងសូនឆ្នាំងម្នាក់ តាំងទីលំនៅនាមាត់ទន្លេគង្គាជិតផ្លូវអ្នកបោកខោអាវម្នាក់ ដែលមានកេរ្តិ៍ឈ្មោះល្អកន្លងមក ។ អ្នកបោកខោអាវនេះ ជាមនុស្សធ្វើការល្អ មានចិត្តសុភាពរាបសា អ្នកឯទាំងពួងតែងមកទិញដូរផ្លែគាត់ច្រើនណាស់ ។ គាត់ជាអ្នកមានទ្រព្យ ហើយសប្បាយជាប្រសើរផង ។ ចំណែកជាងសូនឆ្នាំងវិញ មិនសូវមានធនធានទេ ហើយមានចិត្តឫស្យាច្រណែននិន្ទានឹងអ្នកបោកខោអាវយ៉ាងខ្លាំង ។ នៅថ្ងៃមួយ ដោយឥតគិតវែងឆ្ងាយ ជាងសូនឆ្នាំងសុខចិត្តបំបែកសេចក្តីមេត្រី ដែលមានជាប់ឯជាយូរអង្វែងណាស់មកហើយរវាងខ្លួនឯងជាងបោកខោអាវ, គាត់នឹកថាធ្វើដូច្នេះគ្មានទាស់ខុសអ្វីទេ ។

ឯចំណែកអ្នកបោកខោអាវវិញ គឺតែងតែខំប្រឹងធ្វើការប្រព្រឹត្តល្អជានិច្ច ហើយគ្មានចាប់ភ្លឹកនឹកនាឡើងអំពើដែលជាងស្ងួនធ្មាំងប្រព្រឹត្តនោះសោះ ។ គាត់រស់នៅជាសុខសប្បាយដូចធម្មតា ។ ជាងស្ងួនធ្មាំងមានគំនិតចង់ចាក់រុកអ្នកបោកខោអាវ: គាត់គិតថាគោងតែឲ្យទឹកប្រមាត់គូសត្រូវបស់គាត់នេះបែកធ្លាយដោយហេតុណាមួយ ។ លុះគិតយ៉ាងដូច្នោះហើយគាត់ក៏ឡើងទៅគាល់ស្តេចផែនដី ដែលជាក្សត្រិយ៍មួយ មានព្រះហឫទ័យក្លាហាន ប៉ុន្តែមិនឈ្លាសវៃទេ ។ ជាងស្ងួនធ្មាំងក្រាបទូលថា "ដំរីរបស់ព្រះករុណាជាម្ចាស់ដ៏វិសេសលើសគេ ជាដំរីពណ៌ខៀវសុទ្ធ ប៉ុន្តែទូលព្រះបង្គំដឹងជាក់ថា: អ្នកបោកខោអាវដែលជាអ្នកនៅជិតខាងទូលព្រះបង្គំអាចចេះដែងដំរីឲ្យមានពណ៌ផ្សេង ។ ឃាន, បើសិនណាព្រះករុណាមានព្រះរាជឫទ្ធានុភាពបង្គាប់អ្នកបោកខោអាវនោះតែមួយព្រះឧស្ន៎ មុខជាឃានដំរីសដូចឈ្មោះ ស៊ិនបីអូស៊ិន "Tsinbioushin" ពុំខាន ។

ដែលជាងស្ងួនធ្មាំងក្រាបទូលដូច្នោះ ឥតឃានគិតថា ព្រះករុណាមានព្រះហឫទ័យចង់ឃានដំរីសនោះឡើយ ប៉ុន្តែគាត់ទឹកថា មុខជាស្តេចទ្រង់បង្គាប់ឲ្យជាងបោកខោអាវធ្វើតាមពាក្យញុះញង់របស់គាត់ពុំខាន, រួចគាត់នឹកទៀតថាទៀងតែជាងបោកខោអាវនេះ នឹងធ្វើដំរីខៀវឲ្យទៅជាដំរីសពុំគេតទេ; កាលបើដូច្នេះ ជាងបោកខោអាវមុខជាត្រូវទោសហើយលែងមានអ្នកចូលទិញដូរក្នុងផ្ទះច្រើនទៀតពុំខាន, គឺទៅគាត់នឹងឃានសុខសប្បាយដោយសារជាងបោកខោអាវប៉ុនែ្ត ។

ព្រះពុទ្ធការលែងស្តាប់សព្វសេចក្តីហើយ, ដំបូងស្តេចទ្រង់ឆ្ងើងធ្ងល់ជាពន់ពេក ហើយទ្រង់អស់សំណើចផង, ប៉ុន្តែយូរបន្តិចមកបែរជាមានព្រះហឫទ័យចង់ឮបានដំរាសមួយ ។ ស្តេចទ្រង់នឹកថា ជាងសន្ធឹងប្រហែលជានិយាយតាមហេតុពិតមែន បើអញគិតឲ្យជ្រៅទៅគួរតែល្បងមើល ព្រោះមិនជាការណ៍ខាស់ខុសខាតខូចអ្វីទេ ។

ឃើញទេ! ស្តេចអង្គនេះ ជាក្សត្រិយ៍មួយគ្មានប្រាជ្ញាបន្តិចសោះ ។ ដោយឥតគិតវែងឆ្ងាយ ព្រះពុទ្ធក៏ទ្រង់បង្គាប់ឲ្យគេទៅហៅអ្នកប៉ោកខោអាវមក ហើយទ្រង់ត្រាស់ឲ្យជាងនេះធ្វើដំរីព្រះអង្គឲ្យស ។

ដំបូងអ្នកប៉ោកខោអាវចង់អស់សំណើចនឹងស្តេចដូចអ្នកផងទាំងពួង, រួចចង់ទូលព្រះអង្គឲ្យបានជ្រាបថា "រឿងប៉ាំបែបនេះ ល្អមើលណាស់ហេតុម្តេចក៏ព្រះអង្គមានព្រះបន្ទូលយ៉ាងដូច្នោះ", ប៉ុន្តែដល់ឃើញព្រះភ័ក្ត្រព្រះអង្គស្មើ, គាត់ក៏នឹកថា "ស្តេចអង្គនេះគាចហើយល្ងង់ផង, ហេតុដូច្នោះគោងតែអាត្មាអញនៅស្ងៀមវិញ រួចធ្វើបុក្ខរបែបនឹងធឹងផង" ។ លុះបានដឹងថា នាយស្មន្តឆ្នាំងជាអ្នកនាំរឿងនេះមកទូល, គាត់បែរមុខមើលទៅអ្នកស្រុកទាំងពួងដែលចាំស្តាប់ ហើយនិយាយថា: "សូមទ្រង់ព្រះមេត្តាជ្រាស! ខ្ញុំព្រះបង្គំនឹងចំប្រឹងខ្នះខ្នែងធ្វើតាមព្រះបន្ទូលឲ្យបាន, ប៉ុន្តែសូមព្រះអង្គជ្រាបថា: កងកិច្ចការរបស់ខ្ញុំព្រះបង្គំត្រូវយករបស់ដែលគេចង់ធ្វើឲ្យសនោះ ទៅជ្រលក់ទឹកមួយស្របក់កង

ផើងមួយដែលមានសាច់ រួចអំពីនោះទៅទូលព្រះបង្គំដុសសំអាតឲ្យស, អាស្រ័យហេតុនេះ ទូលព្រះបង្គំត្រូវលាងដំរីព្រះអង្គយ៉ាងដូច្នោះដែរ; ប៉ុន្តែធ្វើម្តេចទៅ បើទូលព្រះបង្គំគ្មានផើងណាឲ្យធំល្មមទទឹងធ្វើការនេះ" ។

ព្រះពជាមិនបានគិតវែងឆ្ងាយទេ ទ្រង់ឈ្វេងយល់ថា: មានតែជាងសូនឆ្នាំងទើបអាចធ្វើផើងបែបនោះបាន, ទ្រង់ក៏គ្រាស់ហៅជាងសូនឆ្នាំងមក ហើយទ្រង់មានព្រះបន្ទូលថា: "នាយសូនឆ្នាំង! យើងត្រូវធ្វើតាមពាក្យរបស់អ្នក ដើម្បីឲ្យដំរីយើងមានពណ៌សឡើង, ប៉ុន្តែមុនទទឹងធ្វើការនេះ អ្នកបោកខោអាវត្រូវការផើងមួយយ៉ាងធំ ដើម្បីដុតដំរីនោះ. ហេតុដូច្នេះ យើងបង្គាប់ឲ្យអ្នកធ្វើផើងមួយឲ្យយើង" ។

ជាងសូនឆ្នាំងលុះបានឮព្រះបន្ទូលយ៉ាងដូច្នោះ ក៏តក់ស្លុតយ៉ាងខ្លាំង ។ ម្តងគាត់គិតថា កុំខ្លាចស្តេចក្រោធ ត្រូវទូលព្រះអង្គតាមដំណើរទៅ, ប៉ុន្តែគាត់មានចិត្តឈ្លានិះជាពន់ពេក ទើបគាត់សម្រេចថា ត្រូវតែល្បងធ្វើផើងតាមព្រះបន្ទូលឲ្យចាស់តែបាន ។ គាត់ទៅពឹងពាក់មិត្តទទឹងក្រមញាតិរបស់គាត់ទាំងអស់ ។ គាត់ប្រមូលដីឥដ្ឋបានជាច្រើន ខុតគក្អែងសូនចម្បាររបស់គាត់ រួចគាត់ខំប្រឹងធ្វើបានផើងមួយយ៉ាងធំ អស់ពេលជាច្រើនថ្ងៃ ។ គាត់យកផើងនេះទៅថ្វាយព្រះករុណា, ព្រះអង្គមានព្រះហឫទ័យរីករាយជាខ្លាំង ហើយទ្រង់ប្រគល់ផើងនោះឲ្យទៅអ្នកបោកខោអាវយ៉ាងប្រញាប់ ។ ឯអ្នកបោកខោអាវ

ក៏យកផើងនោះទៅដាក់ទឹក ដាក់សាប៊ូជាច្រើន ហើយគ្រាបខ្លួលថា រួចស្រេចអស់ហើយ ។ ក្រោយមក ពួកកងសេនាក៏នាំសត្វដ៏ស្ងួតនោះមកដល់ ។ ឯទ្រម៉ក់ចាននាំដំរីចូលទៅ ។ ដំរីគ្រាន់តែជាក់ផើងបន្តិចទៅកងផើង ។ ក៏បែកភ្ជាយជាមួយតាន់ចំណែក ។


គេបាននាំរឿងនេះទៅគ្រាបទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង, ព្រះរាជាទ្រង់ចាន់គ្រាស់បង្គាប់ឲ្យដាំងស្ងួនឆ្នាំងធ្វើផើងមួយទៀត ។ ឯផើងទី ២ នេះក៏បែកភ្ជាត់ភ្ជាយទៀត, រួចផើងទី ៣, ផើងទី ៤ នឹងផើងជាច្រើនទៀត ដែលខ្លួលត្រង់សំណាងដូចផើងមុន ។ ។

ដួនតាលផើងដែលធ្វើថ្មីនោះគ្រាស់ពេករកដាំទឹកឲ្យពុះពុំកើត ដួនតាលផើងនោះស្តីងពេក ដំរីគ្រាន់តែជាក់ផើងលើបែកខ្លួចខ្លី ។ ជាងស្ងួនឆ្នាំងលុះខំធ្វើការដ៏លំបាកនេះកាលណាចូលទៅ ក៏ចាយទ្រព្យខ្លះខ្ជាយឡើង ។ តាលតែងាតលិចលង់គ្មានសល់អ្វីសោះ ។ គាត់មុខជាស្ងាប់ដោយអត់ឃ្លាន បើសិនណាអ្នកបោកខោអាវដែលមានចិត្តដ៏ប្រសើរខ្ពង់ខ្ពស់ មិនជួយទាំងមិនហុចដៃដើម្បីផ្សះផ្សារឿងនេះ ។

ជាងស្ងួនឆ្នាំងយកកន្ទួនឯងទៅលអន្លាក់ នេះគឺចង់បោកគេ រួចត្រូវគេបោកវិញ ។ មានមនុស្សជាច្រើន ដែលមានគំនិតអាក្រក់ ប៉ងបំផ្លាញគេ ហើយគ្រោយមកដឹងខ្លួនថា បាបកម្មនេះត្រឡប់មកលើខ្លួនឯងវិញ ។ នេះជាសេចក្តីវិនិច្ឆ័យប្រកបដោយសុចរិតយុត្តិធម៌មួយយ៉ាង

ស្តែងណាស់ ។ ដូច្នេះយើងគោះបីក្រែបុលំបាកយ៉ាងណាក៏ដោយ យើងមិនត្រូវចិញ្ចឹមចិត្តឈ្នានីះនឹងអ្នកឯទៀត ដែលរស់នៅគាន់បើជាងយើងទេ, គោងយើងចៀសវាងអ្នកណាដែលមានទុក្ខដោយការប្រព្រឹត្តិអំពើច្រណែនដ៏អាក្រក់នេះ; នៅនាលោកិយនេះមនុស្សម្នាក់ ។ សឹងមានវាសនាខុសគ្នាតែរៀងខ្លួន ជួនកាលវាសនានាំឲ្យសប្បាយ ជួនកាលនាំឲ្យទុក្ខ, ឯចំណែកឲ្យដែលមនុស្សយើងត្រូវជួបជាហើយជាឲ្យដឹងជាប់តាមខ្លួនទៅអនាគតជាតិទៀតជាន់ខ្លាំង: ការប្រព្រឹត្តិជាសុចរិត យុត្តិធម៌ ។

(មានត)



កណ្ឌទី ៧

អ្នកឧកញ៉ាវរុលរាជសេនា ឆ្លូ-កន ប្រែរៀបរៀង

(ត១ក)

រឿងសាមកុកមុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះទុយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ឯអង្គអ៊ុនខោះ លុះបានឃើញលីចុ៉ាមកកេដល់ផ្ទះហើយ ទើបចេញទៅទទួលឲ្យចូលមកនិយាយការខាងក្នុងវិញផ្ទះ ហើយឲ្យលើកអាហារមកបរិភោគជាមួយគ្នា ។ លុះបរិភោគរួចស្រេចហើយ លីចុ៉ាដំកបថា ខ្ញុំខ្ញុំបានគ្រាន់តែជាទីនាយឧាហានមហាឧបភដ ចំណែកលោកជានាហ្នឹងមានបណ្ដាសក្តិធំក្នុងហ្នឹង ហេតុម្ដេចបានជាលោកឲ្យយកវេបសាទៅឲ្យខ្ញុំបានល្អម្ល៉េះ ? ខ្ញុំបានជាអ្នកតូចមិនគួរលោកពាក់អានដល់ប៉ុណ្ណេះទេ ។ អង្គអ៊ុនតបថា សព្វថ្ងៃនេះ ខ្ញុំសំឲ្យតែមើលក្នុងទីក្រុងនឹងខេត្តក្រៅទាំងអស់ នឹងកេអ្នកឯណាឲ្យខ្លាំងពូកែស្មើនឹងអ្នកគ្មានសោះ ខ្ញុំឲ្យវេបសាន់នេះ

ព្រោះស្រឡាញ់ថ្លៃដៃអ្នកកូនការពាហាន ។ លីចោ"ចាន់ស្តាប់ក៏មានសេចក្តីត្រេកអរណាស់ ។ អង់អ៊ុនចាត់ស្រាគំនាប់លីចោ" ហើយនិយាយបញ្ជោរសេរសើរលីចោ"ជាអនេកប្រការ ទើបបណ្តេញមនុស្សបំរើឲ្យដើរចេញអស់ នៅសល់តែពួកស្រីបំរើ ៤ នាក់ ។ អង់អ៊ុនប្រើស្រីនោះឲ្យទៅហៅនាងតៀវសៀនចេញមក, ស្រីបំរើ ២ នាក់ក៏ចូលទៅអញ្ជើញនាងតៀវសៀន ហើយហែហមចេញមក ។

លីចោ"ឃើញនាងតៀវសៀន មានរូបភាពនឹងដំណើរវាញ៉ងញ៉ងស្រស់ល្អណាស់ អត់ត្រាមិនបានក៏សួរអង់អ៊ុនថា នាងនេះជាកូនអ្នកឯណា ? ។ អង់អ៊ុនថ្កាប់ថា " នាងតៀវសៀននេះជាបុត្រីរបស់ខ្ញុំ, សព្វថ្ងៃនេះខ្ញុំបានសេចក្តីសុខរនាងធ្វើពាធការបាន ដោយបុណ្យអំណាចមហាឧបពាធនឹងអ្នក ។ ក៏មានសេចក្តីពាប់អានមេត្តាដល់ខ្ញុំដូចសាច់ញាតិជាច្រើនដង ហេតុនេះទើបខ្ញុំឲ្យហៅបុត្រីខ្ញុំចេញមក ដោយសេចក្តីប៉ុនប៉ងនឹងលើកដួងអ្នកឲ្យធ្វើជាភរិយា ដើម្បីទុកជាទីបញ្ចាំចិត្តដោយស្មោះត្រង់ " ថាហើយបង្គាប់នាងតៀវសៀនឲ្យចាក់ស្រាគំនាប់លីចោ" ។

ឯនាងតៀវសៀនបានចាក់ស្រាលើកដួងទៅលីចោ" ហើយប្រើភរិយាចោលដើមក្អែកចុងក្អែក ទៅឲ្យលីចោ"ស្គាល់បានថាមានចិត្តស្និទ្ធស្នាញ ។ ចំណែកខាងអង់អ៊ុនពុតធ្វើជាស្រវឹងស្រា ហើយនិយាយទៅកាន់នាងតៀវសៀនថា ឥពុកចាស់ដកហើយកំឡាំងសោតក៏ថមថយ

ដើរស្រាតែបន្តិចបន្តួចស្រាប់តែរំលងអស់មុខមាត់ កូនទៅគួរសមបំរើបំពាស់ជំនួសវិញចុះ ។

ពេលនោះលីចុ៉ាបានអស្ចារ្យនាងតៀវសៀនឲ្យអង្គុយលើកៅអី ។ នាងតៀវសៀនក្រែងធ្វើជារឿងខ្មាសមិនព្រមអង្គុយ ទើបគំនាប់បិតាហើយលាចូលទៅកន្លែងបន្ទប់វិញ ។ អង្គអ៊ុនថា កូនអើយកុំអៀនខ្មាសអ្វី លីចុ៉ាគេមានមេត្តាករុណាដល់យើងដូចសាច់ញាតិពិតប្រាកដ ចូរកូនអង្គុយចាក់ស្រាជូនគេតាមត្រូវការចុះ ។ នាងតៀវសៀនរៀបខ្លួនអង្គុយលើកៅអីប្រហអង្គអ៊ុន ហើយចាក់ស្រាគំនាប់លីចុ៉ា, ការចាក់ស្រាជូនវៃលាណាតែងចោលកន្ទុយក្អែកទៅប៉ះនឹងក្អែកលីចុ៉ា ។ ឯលីចុ៉ាបានទទួលពែងស្រាហើយ តែងក្រឡេកក្អែកទៅជូបនឹងក្អែកនាងតៀវសៀនជានិច្ច, ក្នុងដួងចិត្តគិតគូរប្រដិព័ន្ធស្នេហាស្រឡាញ់នាងពន់ពេកណាស់ ។ អង្គអ៊ុនឃើញកិរិយាលីចុ៉ាមានចិត្តស្និទ្ធស្រឡាញ់កូនខ្លួនដូច្នោះ ក៏មានសេចក្តីសោមនស្សជាពន្លឹកហើយថា ខ្ញុំសព្វថ្ងៃជាមន្ត្រីមានយសស័ក្តិធំក្នុងរាជការក៏ពិត តែថាខ្លួនក៏កាន់តែដល់ពេលវេលាពណាស់ហើយ ឧបមាដូចជាដើមឈើដែលដុះក្បែរមាត់ច្រាំង ខ្ញុំនឹងលើកបុត្រីនេះជូនជាកិរិយាតូចរបស់អ្នកដើម្បីប្រយោជន៍នឹងបានពុកអ្នកផ្អែបកាយជាទីពឹងតទៅ; ដែលខ្ញុំថាយ៉ាងនេះតើអ្នកយល់ឃើញដូចម្តេច បើជាសេចក្តីមិនសមគួរ កុំអ្នកប្រកាន់ទោសពៃរ៍អ្វីឡើយ ។ លីចុ៉ាបានស្តាប់ហើយក្រោកលុតជង្គង់តំនាប់

អង្គអ៊ុនហើយនិយាយថា ដែលលោកឪពុកអាណិតមេត្តាខ្ញុំតាំងម្ល៉េះ ព្រះគុណធ្ងន់ជាខ្លាំងបំផុតនឹងរកប្រៀបផ្ទឹមពុំបាន តោះបើដូចម្តេចខ្ញុំបានទឹងធ្វើសេចក្តីតបស្នងសងគុណលោកឪពុកតទៅ ។ អង្គអ៊ុនតបថា កូនេះខ្ញុំលើកជូនជាសិទ្ធិដល់អ្នកហើយ ប៉ុន្តែសុំឲ្យខ្ញុំបង្អង់រើសរកឫក្សពារពេលាថ្ងៃណាដែលល្អនឹងបញ្ជូនបុត្រីនេះទៅដល់ទីលំនៅអ្នកតែម្តង ។ លីហ៉ុ"ទទួលថា " ការនេះតាមតែលោកឪពុកគិតគួរចុះ " ថាហើយក៏ក្រោកឡើងប្រែនឹងលាអង្គអ៊ុន ។ អង្គអ៊ុនចាប់ដៃយាត់ថា កុំអាលសិន ដ្បិតចិត្តខ្ញុំចង់អញ្ជើញអ្នកឲ្យនៅសម្លាន្តនិយាយលេងបន្តិច តែក្រែងមហាឧបរាជត្រូវការរកអ្នក ។ លីហ៉ុ"តបថា " លោកឪពុកមានប្រសាសន៍នោះខ្ញុំបានអរគុណណាស់ តែថាថ្ងៃនេះខ្ញុំបានមានកិច្ចផ្សេង ចាំដល់ថ្ងៃក្រោយសឹមមកនៅទទួលទានដំណេកលេងឲ្យយូរ " ថាហើយក៏លាអង្គអ៊ុនចេញទៅ ។

លុះពេលព្រឹកថ្ងៃក្រោយ អង្គអ៊ុនចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ មិនបានឃើញលីហ៉ុ"ចូលទៅគាល់ជាមួយនឹងតាំងតុ:ផង ។ អង្គអ៊ុនលុតជង្គង់គំនាប់តាំងតុ:ហើយដំរាបថា សព្វថ្ងៃនេះខ្ញុំបានសេចក្តីសុខច្រើនសាកទុក្ខភ័យអន្តរាយតាំងពាយតាំងពួង ព្រោះព្រះគេជព្រះគុណមហាឧបរាជឃុំគ្រងរក្សាខ្ញុំបាន នឹងរកវាសអ្វីថ្លៃថ្លាដាំតបស្នងសងគុណគ្មាន រៀលព្រឹកថ្ងៃនេះខ្ញុំបានសូមអញ្ជើញលោកទៅពិសា

ក្រយាទៅផ្ទះខ្ញុំបាទជាសប្បាយម្ដង; ដែលខ្ញុំបាទដំណរនេះ ទោះបីខ្ញុំស្លាប់ក្តី បែការម្ដេច សូមលោកមានសេចក្តីអនុញ្ញាតទោស ។ តាំងតុ:បានស្តាប់មានសេចក្តីសោមនស្សត្រេកអរខ្លួលថា ដែលលោកពប់អានខ្ញុំចង់ឲ្យខ្ញុំទៅខ្លួលគានអាហារឯផ្ទះលោកនោះ ខ្ញុំអរណាស់ ចាំដល់ពេលថ្ងៃត្រង់ខ្ញុំនឹងទៅ ។ អង់អ៊ុនបានឮដូច្នោះហើយ ក៏លាតាំងតុ:ទៅរៀបចំតីលំនៅនឹងគោជនាហារបំរុងទុកជាស្រេច ។

លុះដល់ពេលថ្ងៃត្រង់តាំងតុ:ចេញចាកទីគាល់ ក៏ឡើងរថមានគាហានហែហមអមជាក្បួនតម្រង់ទៅផ្ទះអង់អ៊ុន ។ ចេញទៅខ្លួលគំនាប់ដល់ត្រៃផ្ទះ ហើយអញ្ជើញតាំងតុ:ឲ្យឡើងទៅកាន់ទីកន្លែងដែលរៀបក្រយាហារ ។ អង់អ៊ុនលុតជង្គង់ចាក់ស្រាគំនាប់តាំងតុ: ។ ខ្លួលហើយហាមថា លោកកុំលុតជង្គង់គំនាប់ខ្ញុំដូច្នោះ ចូរអង្គុយតាមទីសមគួរចុះ ។ អង់អ៊ុនធ្វើជាតុនបន្ទន់ខ្លួន ហើយនិយាយលើកសរសើរតាំងតុ:ជាច្រើនប្រការ ។ តាំងតុ:បានឮហើយលើកស្រាផឹកញ៉ាំមញ៉ែមញ៉ែមក្អកត្រេហែមខ្មែងជាពេះកាយសប្បាយចិត្តណាស់ ចាប់បរិភោគអាហារជាមួយនឹងអង់អ៊ុនតាល់តែថ្ងៃរសៀល ។ រួចអង់អ៊ុនអញ្ជើញតាំងតុ:ទៅអង្គុយកន្លែងស្ងាត់ តាំងតុ:អស់ចិត្តមិនមានគំនរឆ្អែសសង្ស័យ ។ ពេលនោះអង់អ៊ុនដេញមនុស្សប្រុសស្រីបំរើឲ្យចេញទៅក្រៅអស់ ហើយនិយាយថា កាលអាយុខ្ញុំបាទបាន ២៥ ឆ្នាំ ខ្ញុំបាទបានរៀនក្បួនហោរ៉ាសាស្ត្រ

ស្រុកសម្រាប់ព្រះមហាក្សត្រនឹងផ្តាយតាំងពួង ឥឡូវនេះខ្ញុំបានឃើញ
ផ្តាយសម្រាប់ព្រះមហាក្សត្រនោះសៅហ្មង ឃើញផ្តាយមហាឧបភដមាន
រស្មីដ៏រុងរឿង ខ្ញុំបានពីគ្រោះឃើញថា ព្រះថៅហៀនតេសព្វថ្ងៃនេះនឹង
វិនាសសាបសូន្យជាធាប់ រាជសម្បត្តិនោះគង់នឹងបានដល់មហាឧបភដ
ជាប្រាកដ ។ តាំងតុ:បានស្តាប់ដូច្នោះ មានសេចក្តីសោមនស្សត្រេក
អរសួរថា ខ្លួនខ្ញុំនឹងដល់ស្មេតច្ឆត្តពិតឬ? ខ្ញុំមិនទាន់ឃើញផងទេ ។
អង្គអ៊ុនតបថា ទំនៀមបូរាណថាបើអ្នកឯណាគ្មានដំរេះប្រាជ្ញានឹងបុណ្យ
វាសនាហើយ កំរមែងចាញ់អ្នកមានបុណ្យមានតំរេះប្រាជ្ញា ខ្ញុំបានឃើញ
ដូច្នេះ ហេតុម្តេចលោកថាមិនទាន់ឃើញផងដូច្នោះ? ។

តាំងតុ:តបថា បើខ្ញុំបានរាជសម្បត្តិពិតដូចពាក្យលោកថា, ខ្ញុំនឹង
តាំងលោកឲ្យធ្វើជាមហាឧបភដដំនួសខ្ញុំ ដើម្បីជាបំណាច់ផ្សាន់មាត់
ដែលទំនាយនោះ ។ អង្គអ៊ុនធ្វើជាត្រេកអរពេកយសប្បាយចិត្តណាស់
ដល់វេលាត្រលប់ឲ្យអុដប្រទីបផ្សាលក្នុងទីគ្រីហាស្ថាន ហើយឲ្យលើក
ក្រយាហានឹងស្រាមកលៀងតាំងតុ:ម្តងទៀត ។ ពេលដែលតាំងតុ:កំពុង
បរិភោគអាហារនោះ អង្គអ៊ុនឲ្យពួកពិណពាទ្យមហោរីប្រគំ មានឯង
រចុំចេញមករៀងរាំគំនាប់ ឲ្យនាងតៀវសៀនរាំបំរើតាំងតុ:ក្បែរៗ ខ្លួន ។
ឯតាំងតុ:ដែលប្រកបដោយចិត្តស្រឡាញ់រូបសំឡេងនៃស្រីកញ្ញា លុះ
ក្រឡេកទៅត្រាឃើញរូបនាងតៀវសៀនស្រស់ជាងអស់ស្រីឯទៀត

ក៏ឆ្ងៀតគន់មើលមិនដាក់ភ្នែក ទើបស្រែកហៅឲ្យចូលមកដិតហើយសួរ
អង្គអ៊ុនថា នាងនេះឈ្មោះអ្វី ? ។ អង្គអ៊ុនដំកបថា ឈ្មោះនាងតៀវ
សៀនជាកូន ខ្ញុំសុំគេមកចិញ្ចឹមតាំងពីតូច ។ តាំងតុ:សួរថា ចេះច្រៀង
ដែរឬទេ ? ។ អង្គអ៊ុនដំកបថា "ចេះច្រៀងពីកេះណាស់" ថាហើយ
បង្គាប់ឲ្យនាងតៀវសៀនស្រែកច្រៀងទទួលតាមចំនុកក្លែង ។

នាងតៀវសៀនស្រែកច្រៀងភាយចំនុកថា "ស្រីរូបល្អស្រស់ច្រៀង
សំឡេងពីកេះ បបូរមាត់មានសម្បុរក្រហមដូចផ្លែទន្ទាប់ ធ្មេញសម្រស់ឲ្យ
ស្រស់ឡើង ខ្នងភាក់កងយ៉ុក ២ ទោះបីមិនមានក្បាច់ជារូបអ្វី មើលទៅ
កង់ហើយខ្នងសាប់ស៊ីគ្នា ធម្មតាគ្រាប់ម្រេចតូចពិត កាលបើលិណទៅ
ដល់អណ្តាតហើយតែងមានជាតិហិរក្តៅ" ។

តាំងតុ:កាលបានស្តាប់នាងតៀវសៀន ច្រៀងរៀបរាប់ចំនុកដូច្នោះ
ក៏មានសេចក្តីសំគាល់ថាជាចម្រៀងពីកេះចាប់ចិត្ត ព្រោះមិនបានសង្កេត
ក្នុងកលទុបាយនៃស្ត្រី ។ អង្គអ៊ុនបង្គាប់ឲ្យនាងតៀវសៀនចាក់ស្រាជូន
តាំងតុ: ។ ទទួលហើយសួរថា នាងឯងអាយុប៉ុន្មានហើយ ? ។ នាងធ្វើយ
ដំកបថា ខ្ញុំម្ចាស់មានអាយុ ១៦ ឆ្នាំហើយ ។ តាំងតុ:ឃើញរូបភាពស្អាត
ល្អ ទាំងច្រៀងក៏ពីកេះទៀត ក៏ចាប់ចិត្តក្លួចកើតប្រដិព័ទ្ធស្រឡាញ់ពេញ
ប្លុងខ្លួយ ទើបនិយាយថា នាងឯងរូបស្អាតល្អដូចស្រីទេពអប្សរកញ្ញានឹង
រកស្រីណាប្រៀបផ្ទឹមពុំបាន ។

ភាគទី ២

សម័យឧត្តរង្គ

អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(តទៅ)

ទើបគ្រាស់ឲ្យភ្នាក់ងារយកគម្ពីរព្រះត្រៃបិដក នឹងព្រះកែវមរកតប្រតិស្ឋានទុកក្នុងក្រុងយសោធរបុរៈ[1] រំលោះនោះ ព្រះបាទទុទយាទិត្យវរ្ម័នទ្រង់ប្រាប្តថា នឹងឲ្យភ្នាក់ងារចារព្រះត្រៃបិដកនោះផ្លូវជាក់មកជាអក្សរខ្មែរទុកជាសម្បត្តិរបស់ខ្មែរ តែចារបានត្រឹមណា ចប់ឬមិនចប់ មិនអាចដឹងបានជាជាក់លាក់ ។

ចំណែកឯព្រះបាទអនុរុទ្ធ កាលស្តេចដល់ព្រះនគរហើយ មិនឃើញសំពៅព្រះត្រៃបិដកទៅដល់, ទ្រង់រង់ចាំមើលជាយូរវៀងតមក

---

១ តាមពាក្យបញ្ជាក់មាថា ឯគម្ពីរព្រះត្រៃបិដកនឹងព្រះកែវមរកត បានគង់ណែនាំមកដល់ប្រទេសកម្ពុជាក្នុងរជ្ជកាលព្រះបាទធនញ្ជ័យគោរព្យរាជ - ព្រះមហាក្សត្រិយ៍អង្គនេះ គ្រាស់ឲ្យយកព្រះត្រៃបិដកទៅដំកល់ទុកនៅប្រាសាទនគរវត្ត ហើយទ្រង់រៀបប្រាសាទនេះថ្វាយជាវត្ត ទើបគេហៅថាប្រាសាទនគរវត្ត, គ្រាស់ឲ្យសាងប្រាសាទ ១ នៅមុខព្រះបរមរាជវាំង ហើយឲ្យយកព្រះកែវមរកតទៅប្រតិស្ឋានទុកនៅទីនោះ ។ ប្រាសាទនោះទើបមានឈ្មោះថាប្រាសាទកែវ ។ តាមសេចក្តីពិសោធន៍របស់យើងឃើញថា រំលោះនោះប្រាសាទនគរវត្តមិនទាន់សាងនៅឡើយ ក្រោយនោះ ៣ រជ្ជកាលទើបបានសាង ។ ឯប្រាសាទកែវសាងក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ ផ្លូវបានពេលហើយ ។

ទៀត កំមិនឃើញគេដល់ ទើបគ្រាស់ឲ្យភ្នាក់ងារស៊ើបសួរតាមមាត់សមុទ្រខាងត្បូង. កន្លងមកជាយូរខែទើបបានដំណឹងថា សំពៅនោះរសាត់ទៅដល់ប្រទេសកម្ពុជា ដូចពោលមកហើយ ។ លំដាប់នោះឯងព្រះបាទអនុរុទ្ធមហារាជក៏ទ្រង់តែងសាសនទូត ឲ្យនាំរាជសារមកគាន់ក្រុងយសោធរបុរៈ សុំយកសំពៅព្រះត្រៃបិដកព្រះកែវមរកត ព្រមទាំងមនុស្សដែលមកក្នុងសំពៅនោះទៅវិញ[1] ។

ព្រះបាទធម្មាសោកទ្រង់ជ្រាបតាមព្រះរាជសារនោះហើយ ក៏ទ្រង់អនុញ្ញាតថ្វាយតាមសំណូ រៀវតែព្រះកែវមរកតទ្រង់យកខុក ព្រោះទ្រង់ជ្រះថ្លាខ្លឹងព្រះកែវមរកតនោះជាយ៉ាងវិសេសពេក ទ្រង់បានតបព្រះរាជសារទៅព្រះបាទអនុរុទ្ធវិញតាមដំណើរ ។ ព្រះបាទអនុរុទ្ធកាលបានព្រះត្រៃបិដកទៅវិញ ដូចព្រះរាជបំណង ក៏ទ្រង់សោមនស្សខ្លាំងណាស់, ចំពោះព្រះកែវមរកត ទ្រង់ពេញព្រះរាជហឫទ័យនឹងថ្វាយព្រះបាទធម្មាសោកជាកិច្ចបដិការៈ ។ ក្រោយនោះមក ៣ ឆ្នាំ (ព.ស. ១៥៥៩) ព្រះបាទអនុរុទ្ធក៏សោយទិវង្គតក្នុងវ័យមិនទាន់ទ្រង់ជរាណាស់ទេ ។

ព្រះកែវមរកត ជាវត្ថុសក្តិសិទ្ធិ ជាវត្ថុអស្ចារ្យក្នុងលោក ព្រះអង្គអណ្តែតពីលង្កាមកស្ថិតនៅកន្លងប្រទេសកម្ពុជាអស់រយៈជាយូរឆ្នាំ ទើប

• ព្រះបាទអនុរុទ្ធមិនដែនមានឬទ្វី ដល់ទៅគង់សេះសហោះមកក្រុងយសោធរបុរៈ មិនដែនមានឬទ្វីដល់ទៅបន្ទោបស្សរៈធ្លុះផែនឬឬអ្វី ។ ធ្វើបានសំដែងក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាស្មោះទេ ។

ជានៅស្ថិតនៅក្នុងប្រទេសដទៃ ដូចជានឹងមានក្នុងសេចក្តីកត់ហេតុទៅខាងក្រោយជាថ្មីទៀត ។

ព្រះមហាឧបាសកអ្នកគ្រប់គ្រងរដ្ឋភារតី ក្នុងរជ្ជកាលនេះ ជាកដព្រះនាមថា «ព្រះអាទិត្យវង្ស» ប្រហែលជាមានព្រះនាមដើម «ព្រះនាកយណ៍» សឹងជាព្រះឧរសរបស់ព្រះចន្ទ្រៈថាតិ ស្តេចចេញពីក្រុងលវបុរៈទៅគាំងព្រះពាជធានីថ្មីនៅវត្តដើម តំបន់បឹងស្នោ (ណងស្នោ) សឹងមិនឆ្ងាយប៉ុន្មានអំពីក្រុងលវបុរៈ ហើយឲ្យឈ្មោះព្រះពាជធានីថ្មីនេះថា ស្រីអយុធ្យា ព្រោះសេចក្តីពិតប្រហែលគ្នានឹងក្រុងអយុធ្យារបស់ព្រះរាមនៅក្នុងដែនកោសល, ឈ្មោះនេះទើបកើតមានគ្រឹមរជ្ជកាលព្រះអាទិត្យវង្សនេះឯង ។

ព្រះមហាឧបាសកអ្នកគ្រប់គ្រងរដ្ឋដទៀតក្នុងសម័យជាមួយគ្នានេះ ព្រះនាម «ព្រះរាមរាជ» ស្តេចគង់នៅកំពែងពេជប្បុរកោសម្ពីដែលឧរសព្រះរាមរាជនេះ ព្រះនាម «មណ្ឌរាជ» បានមកកាន់កាប់ក្រុងលវបុរៈ តែមិនមែនជាឧបាសកទេ នៅក្នុងបង្គាប់ព្រះអាទិត្យវង្ស ។

ការកសាង: ព្រះចាន្ទរយាទិត្យវរ្ម័ន ទ្រង់ចាប់កសាងវត្តស្ថានតាមដែលដឹងបានក្នុងវេលានេះ គឺប្រាសាទសិលាឈ្មោះថា «ហេមាទ្រិ» (ភ្នំមាស) ជាទេវស្ថាន ដែលពាក្យសាម័ញ្ញហៅ «ចាតួន» នៅក្នុងកំពែងក្រុងយសោធរបុរៈ ពីក្នុងឆ្នាំ ៣. ស. ១៥៩៣ ។

តាមសេចក្តីកត់ហេតុរបស់ជាវគាគួន (ឡូតចិន) ដែលមកស្រុកខ្មែរក្នុងរវាង ព.ស. ១៨៣៨ ដល់ ១៨៤០ ថាជាប្រាសាទមាសមានលក្ខណៈល្អជាបំផុត ។ តាមដែលឃើនពិនិត្យមើលក្នុងវេលានេះ ឃើញមានស្នាមចំបាស់មែន ។ ប្រាសាទសំលាដែលសាងក្នុងសម័យជាមួយគ្នានេះ គឺ ប្រាសាទមេបុណ្យខាងលិច និងប្រាសាទវត្តខ្នារ ។

ព្រះបាទយសោវរ្ម័នទី ២ ស្តេចសុគតនៅក្នុងរាជសម្បត្តិ ដល់មកក្នុងឆ្នាំ ព.ស. ១៦០៨ ក៏សោយទិវង្គត, រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "យសោវរបទ" ។ ទ្រង់គ្មានព្រះរាជនុសេចក្តួលគ្រងរាជសម្បត្តិស្នងព្រះអង្គ រាជសម្បត្តិទើបបានទៅព្រះអនុជាធិរាជហសិវរ្ម័ន ។

ព្រះចានហសិវរ្ម័នទី ៣

ព.ស. ១៦ ៩-១៦៣២. ត.ស. ១០៦៦-១០៨៩ ។

កាលព្រះបាទយសោវរ្ម័នទី ២ សោយទិវង្គតហើយ រាជការបានអញ្ជើញព្រះអនុជាធិរាជ ព្រះនាម "ហសិវរ្ម័ន" ដែលមានវ័យប្រហែលផុតមជ្ឈិមវ័យទៅហើយឲ្យឡើងគ្រងពិភពតមក មានព្រះបរមនាមថា "ព្រះបាទហសិវរ្ម័ន" រាប់ជាទី ៣ ។ ព្រះអង្គមានព្រះអគ្គមហេសីព្រះនាម "ជយរាជទេវីមាណី" តែគ្មានព្រះរាជនុសេ ព្រះរាជធីតាទេ ។

ការផែនដី : ព្រះបាទហសិវរ្ម័នកាលទ្រង់បានឡើងសោយរាជ្យថ្មីៗនោះ មានការណ៍ក្បត់ផែនដី ដើម្បីដណ្តើមយករាជបល្ល័ង្ក, ឯអ្នក

បង្កការណ៍ក្បត់នោះគង់ជាព្រះពជវង្ស តែព្រះនាមដូចម្តេច មិនច្បាស់ក្នុងក្បវត្តិសាស្ត្រនេះ ។ ព្រះបាទហសិរ៉ាន្ទ្រទង់ជ្រាបហើយ ក៏គ្រាស់បញ្ជូនព្រះពជសេនាធំ ១ នាក់លើកទំពៅទៅកម្ចាប ចាន់សម្លាប់បន្តិចទៅ ។

ការព្រះសាសនា : ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់ពប់អានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា ទ្រង់មានព្រះបុរោហិតងារជា "កម្រែតេង៍អញគ្រូស្រែទិព្រះបណ្ឌិត" ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធីផ្សេង ។ ថ្វាយ ។ ការកសាង មិនច្បាស់ជាថាទ្រង់បានសាងអ្វីជាសំខាន់ទុកទេ ព្រោះក្នុងរជ្ជកាលនេះ មានអសន្តិសុខរហូតដល់ផុតរជ្ជកាល ។

ក្នុងគ្រានោះ (មិនច្បាស់ជាឆ្នាំណា) ព្រះបាទហសិរ៉ាន្ទ្របានទទួលព្រះពជសារស្តេចក្រុងចិន ១ ច្បាប់ថ្វាយថា វេលានេះជា. ព្រះពជអាណាខែត្រចិន ត្រូវស្តេចយួនព្រះនាម "លីញ្ញង់តុង" លើកទំពៅទៅវាយ ។ សេចក្តីតមក ស្តេចក្រុងចិនទ្រង់រំលឹកអំពីពជសម្ពន្ធមិត្តរវាងខ្មែរនឹងចិនដែលមានមកក្នុងឆ្នាំ ម. ស. ៩៨៣, ព. ស. ១៤៦៤ នោះផង; ក្នុងទីបំផុត ស្តេចក្រុងចិន សូមឲ្យព្រះមហាក្សត្រិយ៍កម្ពុជាទៅជួយកំចាត់យួន ។ ព្រះបាទហសិរ៉ាន្ទ្រទង់ជ្រាបដូច្នេះហើយ ក៏គ្រាស់បង្គាប់សេនាបតីទាំងពាហានឲ្យរៀបកងទ័ព នឹងលើកទៅជួយចិន; កាលច្បាំងមានជ័យជំនះដូចបំណងស្រេចហើយ លើកទ័ពត្រឡប់មកព្រះនគរវិញ ។

សាវតារវត្តអង្គារស

នៅលើភ្នំពូលភ្នំព្រះរាជទ្រព្យ ស្រុកឧដុង្ក ខេត្តកណ្តាល

អ្នកអង្គម្ចាស់កុត្រ ឧពោត្តម - សុខាចារី

ធ្វើការនៅគ្រែសួងពុទ្ធសាសនបណ្ឌិត្យ កំពេញ

រៀបរៀង

(ភ្ងាន់លេខ ២ ៣៤៥)

ព្រះរាជាប្រទេសខ្មែរខ្លះព្រួយព្រះរាជហឫទ័យណាស់ ក៏ត្រាស់បង្គាប់ឲ្យអស់នាមុឺនមុខមន្ត្រីរិះគិតរកប្រស្នាចំនួនេះ ។ ប៉ុន្តែក្នុងចំណោមមន្ត្រីរបស់ទ្រង់ចាំងប៉ុន្មាន តុំមាននរណាមួយនឹងអាចដោះស្រាយប្រស្នានោះបានឡើយ ។ ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យចាំរកអ្នកមានប្រាជ្ញាដោះស្រាយ ។ នៅសម័យនោះ មានអ្នកតង្វាលគោម្នាក់បានឃើញគេប្រកួតគ្នាដុំៗ ក៏ចូលទៅឈរស្តាប់ហើយនិយាយថា "ប្រស្នាចំនួន ៣ នេះងាយដោះស្រាយសោះ: ប្រស្នាទីមួយដែលធ្វើដៃចាំងពីរវង់មូលនោះ គឺអង្រឹតត្រី, ប្រស្នាទីពីរដែលក្តាប់ដៃលើកទៅលើនោះ គឺស្នែងតែមួយ; ប្រស្នាទីបីដែលលាមដៃហើយចុះដៃត្រង់ទៅមុខនោះ គឺថារកបានត្រី ៩" ។ អ្នកដែលបានស្តាប់តុំចាំងប៉ុន្មាន ក៏នាំគ្នាពិចារណាសួរបុរសនោះថានិយាយលេងឬដូចម្តេច? ។ បុរសនោះក៏ឆ្លើយប្រាប់គេវិញថា ប្រស្នាចំនួន ៣ នេះប្រាកដជាប្រ

ដូច្នេះ ។ អ្នកស្រុកគេក៏នាំពាក្យនោះទៅដំណឹងដល់មន្ត្រីដែលចាំវាគង, មន្ត្រីនោះក៏នាំបុរសគង្វាលគោទៅថ្វាយស្តេច ។ ព្រះពាជាទ្រង់មានព្រះពាជឫង្ការសួរបុរសនោះ អំពីសេចក្តីដោះស្រាយប្រស្នាទាំង ៣ នេះ; បុរសគង្វាលគោក្រាបបង្គំទូលព្រះពាជាដោយសាត់ថា:

ប្រស្នាទី ១ ប្រែថា មានផែនដីមួយគីប្រទេសខ្មែរយើង ។

ប្រស្នាទី ២ ប្រែថា មានស្តេចមួយព្រះអង្គសោយពាជសម្បត្តិនៅលើផែនដីនោះ ។

ប្រស្នាទី ៣ ប្រែថា មានរដ្ឋមន្ត្រី ៥ នាក់ធ្វើការមើលសុខទុក្ខពួកស្រែរងពីព្រះពាជាមក ។

លុះដល់ថ្ងៃដែលបានកំណត់ មន្ត្រីចំនួនក៏ចូលមកគាល់ព្រះពាជាទូលសុំសេចក្តីដោះស្រាយប្រស្នានោះ ។ ព្រះពាជាមានព្រះពាជឫង្ការត្រាស់ហៅអ្នកគង្វាលគោឲ្យមកដោះស្រាយប្រស្នា ។ នៅវេលានោះ អ្នកគង្វាលគោក្រាបថ្វាយបង្គំព្រះពាជារួចហើយក៏ដោះស្រាយប្រស្នាទាំង ៣ នោះ ចំពោះមុខអស់ពួកមន្ត្រីខ្មែរ - ចិនថា:

ប្រស្នាទី ១ គឺ បក្រក់ឲ្យមួយគីបក្រក់ឲ្យដែលយើងនៅសព្វថ្ងៃ ។

ប្រស្នាទី ២ " មានភ្នំព្រះសុមេរុមួយដ៏ធំវែកលែង ។

ប្រស្នាទី ៣ " មានព្រះ ៥ អង្គត្រាស់រួចមកហើយ ។

លុះចប់ហើយ, មន្ត្រីចំនួនក៏ទូលយល់ព្រមថា សេចក្តីដោះ

ស្រាយនៃប្រស្នាខាងក្រោមនេះត្រូវហើយ រួចទើបគ្រាបបង្គំលាព្រះពុទ្ធ ប្រទេសខ្មែរយើងទៅទូលស្តេចខ្លួនវិញ ។ ព្រះពុទ្ធក្រែងចិនក៏សុំចង់មុត្តមេត្រីនឹងប្រទេសកម្ពុជាតាំងពីសម័យនោះដរាបមក ពុំហ៊ានរករឿងហេតុអ្វីទៀតឡើយ ។ ឯចំណែកបុរសគង្វាលគោនោះសោត ព្រះពុទ្ធប្រទេសយើងទ្រង់ប្រោសព្រះពុទ្ធានុសម្បត្តិទៀងជាច្រើន ហើយតាំងគោរម្យងារជា "ធនញ្ជ័យកោរព្យពជ្ឈ" ជាងារនៅក្នុងសម័យនោះ ហើយដែលយើងសព្វថ្ងៃហៅថា "នាយកវដ្ដមន្ត្រី" ។

តមកជាយូរអង្វែង ព្រះវិហារអង្គរសេក៏ចាក់បែកខ្ទេចខ្ទីខ្ទួចខាតអស់ នៅសល់តែសីមានឹងព្រះពុទ្ធរូប, ប្រទេសកម្ពុជាក៏ចេះតែអាប់ខ្មួនបន្តិចម្តងៗ ដរាបមក ។ លុះនៅក្នុងសម័យលង្វែក ព្រះចន្ទពុជាដែលជាស្តេចទ្រង់ធម៌ ទ្រង់គ្រាស់បង្គាប់ឲ្យកសាងព្រះវិហារនោះជាថ្មី, ចំណែកព្រះពុទ្ធរូបនៅនឹងដដែលតុំមានតែប្រែឡើយ គ្រាន់តែជួសជុលបន្តិចបន្តួចប៉ុណ្ណោះ ។

រឿងព្រះវិហារត្តគង្វាសនេះចប់តែប៉ុណ្ណោះ

ចំណែកខម្ចាប់ខំខ្មៀមខ្មែរយើង គេជ្រើសរកទីណាដែលខ្លួលខ្ពស់មិនលិចទឹកសម្រាប់ធ្វើព្រះវិហារ ធ្វើវត្ត, គេពុំសូវកសាងវត្តនៅទីទំនាបឡើយ ។ នៅទីភូមិនីមួយៗ គេតែងតែសាងវត្តនៅពីមុខភូមិដរាប ភូមិអ្នកស្រុកត្រូវនៅពីក្រោយវត្ត ។ វត្តអារាមដែលជាទីលំនៅរបស់ពួក

បព្វជិតជាអ្នកប្រតិត្តធម៌ គេច្រើនតែធ្វើឲ្យឆ្ងាយពីទីកូមដែលមានមនុស្ស
កុះករ ចម្ងាយប្រមាណ ៥០០ ធ្នូ ក្នុងមួយធ្នូប្រវែងប្រហែលជា ២ ម៉ែត្រ.
ដូច្នេះបើគិតជាម៉ែត្រវិញ វត្តត្រូវនៅឆ្ងាយពីកូមិចំនួន ១ គីឡូ ។ គេធ្វើ
របៀបនេះដោយយល់ឃើញថា ពួកបព្វជិតជាអ្នកត្រូវសង្រួមកាយ-វាចា-
ចិត្ត កាន់នូវសេចក្តីសូចស្ងាត់ ដូច្នេះត្រូវនៅឲ្យឆ្ងាយពីទីដែលមានមនុស្ស
កុះករ ដែលជាទីនាំឲ្យរំខានដល់អ្នកបួស ។ ម្យ៉ាងទៀតប្រហែលជាគេ
និយមធ្វើតាមរឿងមួយ ដែលមានតាំងពីកាលព្រះពុទ្ធអង្គ គង់ព្រះជន្ម
នៅឡើយ គឺរឿងវត្ត "ជេតវន" ដែលអនាថបិណ្ឌិកមហាសេដ្ឋីបាន
ទិញដីកូមិនៅឆ្ងាយពីក្រុង អំពីព្រះអង្គម្ចាស់ជេត ហើយកសាងព្រះ
វិហារ ដាក់នាមអ្នកម្ចាស់កូមិជានាមវត្តជាប់រហូតមកដល់សព្វថ្ងៃនេះ ។
គេសាងព្រះវិហារមិនឲ្យឆ្ងាយពីកូមិ-ពីក្រុងពេក ដើម្បីជាការងាយដល់
ព្រះសង្ឃនិមន្តបិណ្ឌបាត នឹងដល់គ្រហស្ថធ្វើបុណ្យផង ។

លុះគេរកទីកន្លែងបានកាលណាហើយ គេក៏ចាប់ធ្វើពិធីកសាង
វត្ត ។ ដំបូងគេសូត្រស្មូតីប្រកាសប្រាប់អ្នកខាងឯឲ្យដឹងថាទីនេះ។
មានទំហំប៉ុន្មាន។, បណ្តោយ ទទឹងប៉ុន្មាន។ នេះសូមឲ្យសំគាល់ថាជាទី
វត្តអាចមចាប់តាំងពីថ្ងៃដែលបានប្រកាសនោះតទៅ ។ ឯឫក្សពារពេលា
ខែថ្ងៃដែលគេបានចាប់ផ្តើមសាងវត្តនោះ ដូនកាលគេយកឆ្នាំ-ខែ-ថ្ងៃ
កំណើតបព្វជិត១អង្គ ដែលគេប្រឹងនិមន្តឲ្យមកធ្វើជាចៅអធិការវត្តនោះ,
ដូនកាលគេយកខែ-ឆ្នាំ-ថ្ងៃកំណើតរបស់អ្នកសាងវត្ត មកគន់គូរមើល ។

សេនាសន: ដែលគេត្រូវចាប់ធ្វើមុនគេក្នុងវេលាសាងវត្តដំបូងគឺព្រះវិហារ តមកកុដិលោកចៅអធិការ ។ ឯកុដិលោកចៅអធិការនេះ គេច្រើនធ្វើនៅចំហៀងឈៀងពីក្រោយព្រះវិហារបន្តិច ឬនៅចំពីក្រោយស្មោះ គេពុំដែលហ៊ានធ្វើខ្ទឹម ឬ ពីមុខព្រះវិហារទេ ដោយគេខ្លាចបាញ់ព្រះបារមីព្រះពុទ្ធអង្គ, ក្រោយមកគេចាប់សង់កេនានាន់ រួចទើបសង់បង្គន់ជាទីបំផុត ។

ក្រោយដែលគេបានសាងសេនាសន: សំខាន់ៗ ដូចបានពយាករណ៍លើនេះ; គេនិមន្តព្រះសង្ឃយ៉ាងតិចត្រឹម ៥ អង្គ ។ ហេតុដែលបានជាកំណត់ចំនួនយ៉ាងនេះ ដ្បិតចំនួនបព្វជិតដែលតិចជាង ៤ អង្គនោះ គេមិនអាចហៅថាព្រះសង្ឃបានឡើយ ព្រោះពុំអាចនឹងធ្វើសង្ឃកម្មតាមច្បាប់ព្រះពុទ្ធសាសនាបានទេ ដូច្នេះវត្តក៏មិនកើតឡើងហៅថាវត្តបានដែរ ។

លុះគេសាងវត្តរួចស្រេចកាលណាហើយ គេធ្វើពិធីបញ្ចុះសីមានឹងឆ្ងាយ ។ ឯសីមានោះមានពីរយ៉ាងគឺ: មួយយ៉ាងហៅថា "សីមាទឹក" មួយយ៉ាងទៀតហៅថា "សីមាគោក" ។

ក) ឯសីមាទឹកនោះគឺ គេជីកអូរប្រឡាយទឹកនៅជុំវិញទីដីដែលគេសន្មតខ្មុកជាព្រំប្រទល់វត្ត ជាទីកន្លែងដែលគេត្រូវគោរព, នៅក្នុងអូរនោះគេជីករណ្តៅ ៨ នៅជុំវិញវត្តឆ្ពោះទៅគ្រប់ទិសទាំង ៨, នៅក្នុងព្រះវិហារ

គេជីករណ្តៅមួយដែរ នៅចំពីមុខព្រះពុទ្ធរូបដ៏តបស្លុងព្រះ, ហើយគេចងព្យួរថ្មមួយដុំៗ (ទម្ងន់យ៉ាងតិចត្រឹម ៦០ នាឡិ) នៅលើមាត់រណ្តៅចំនួន ៨ នោះ ។ គេនិមន្តព្រះសង្ឃទៅសូត្រធម៌នៅត្រង់រណ្តៅចាំងនោះហើយ លុះដល់ពេលវេលាដែលត្រូវការ គេធ្វើកិច្ចសញ្ញាអ្វីមួយឲ្យបានដឹង (ដូចជាកាយគង ជាដើម) ដើម្បីឲ្យគេកាត់ខ្សែទម្លាក់ដុំថ្មដែលគេសន្ធតហៅថាសីមានោះទៅក្នុងរណ្តៅបានត្រមត្រូវគ្នា ។

๑) សីមាគោក គឺសីមាដែលគេបញ្ចុះនៅលើគោក ពុំមានជីករណ្តៅអូរឲ្យដក់ទឹកបានឡើយ ។ សីមាចាំងនេះ ខ្លះគេបញ្ចុះនៅឯបង់វត្តក៏មាន ខ្លះគេបញ្ចុះនៅលើខឿនព្រះវិហារក៏មាន ខ្លះទៀតបញ្ចុះនៅក្នុងព្រះវិហារក៏មានដែរ តាមតែចិត្តអ្នកសាងវត្តចង់ធ្វើនៅទីណាក៏បានឲ្យតែទីនោះចុះល្មមព្រះភិក្ខុសង្ឃ ๒๑ រូបអង្គុយដាក់ដ៏មូល ឃ្លាតឆ្ងាយអំពីគ្នាមួយត្រដាងដៃ ។ ឯពិធីបញ្ចុះសីមានោះមានរបៀបដូចជាពិធីបញ្ចុះសីមាទឹកដែរ ។ សីមាដែលនៅចំមុខព្រះកន្ត្រៃព្រះជិតបស្លុងនោះ ហៅថា "សីមាគិល" ។

នៅទីបំផុត, គេរៀបចំធ្វើបុណ្យឆ្លងព្រះវិហារ ។ ឯបុណ្យនោះកាលដំបូងគេនិមន្តព្រះភិក្ខុសង្ឃជាច្រើនរូបមកសូត្រមន្តចំរើនព្រះបរិត្ត ។ នៅលើគោកឬតុមួយគេមានរៀបផ្ទៃឈើនឹងនំចំណី ๔ ចានតូច ។ ដាក់ជា ๔ ជ្រុង ហើយមានធ្វើជមតូច ๔ ដែលមានដោតស្លឹកមូលឬស្លឹកខ្ទះជា

៣ ជ្រុងជាក់នៅក្នុងគោកនោះដែរ, នៅចំកណ្តាលតុគេជាក់ទឹកមួយផ្តិលដែលគេចងមែកឈើព្រមទាំងស្លឹកបណ្តែតនៅក្នុងនោះ ។ លុះលោកសូត្រធម៌ចប់រួចស្រេចកាលណា គេយកទឹកនោះទៅប្រសំពេញតែទឹកខ្វែងក្នុងព្រះវិហារ ។ នៅវេលាព្រឹកគេនិមន្តព្រះសង្ឃមកសូត្រធម៌ហើយប្រគេនចង្ហាន់ធាន់ ។ លុះដល់ពេលរសៀលគេធ្វើមង្គលទាន គឺទេសនាសង្គាយនាគ្រែ ៣ ជាកិច្ចបង្ហើយបុណ្យ ។

ពិធីធ្វើចប់តែប៉ុណ្ណេះ

នៅព្រះវិហារនីមួយ ។ គេបានសង្កេតឃើញមានធ្វើរូបគ្រុឌ្យ៉ាបដំបូលព្រះវិហារ រូបនាគលូនវែងលាលៅលើដំបូល, រូបយក្ខគន្ធព្វកាន់ដំបងឈរចាំនៅមាត់ទ្វារ, ពជហង្សទំនៅកំពូលក្បាលទ្វារ - ។ល។ ឯរូបសត្វទាំងអស់នេះ ពុំមានរឿងរ៉ាវអ្វីទាក់ទងដល់ការកសាងវត្តទេ ប៉ុន្តែគេតែងនិយមយកទៅតាំងនៅព្រះវិហារ ដោយសត្វទាំងនោះមានវិជ្ជាល្បីល្បាញក្នុងរឿងរ៉ាវបុរាណខ្មែរយើង ទើបបានគេយកមកធ្វើជារបស់តាំងលំអនៃព្រះវិហារ ហើយជាក់តាមទឹកខ្វែងឲ្យសមរម្យតាមសភាពរូបកាយរបស់សត្វទាំងនោះ កុំឲ្យជាទីទើសខ្វែងជាទីរំខានដល់ទឹកខ្វែងនឹងទស្សនាផង ។

ប្រវត្តិរបស់អេសុប

លោក ផេង - ជ្រឿ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារីភ្នំពេញ

ប្រែពីជាវ៉ាន់មកជាខ្មែរ

(ត្រួត)

សង្ឃឹមមានប្រពន្ធមួយជាស្រីចិត្តមួម្ចូអាក្រក់ពេកណាស់ គ្មាននរណាចេះធ្វើឲ្យត្រូវចិត្តឡើយ ហើយជាស្រីខឹងច្រើនផង ។ ម្តើសង្ឃឹមនាំអេសុបយកទៅប្រគល់ឲ្យនោះមុខជាខឹង ដោយគិតស្មានថាគេយកមនុស្សដូច្នេះទៅចំអកឲ្យ ។ សង្ឃឹមចង់សើចលេងនឹងប្រពន្ធរបស់ខ្លួនក៏ទៅនិយាយប្រាប់មុនថា : អញទិញបានមនុស្សម្នាក់ រូបរាងល្អចំឡែក រកប្រុសណាល្អដូចគ្មាន ។ ពួកជាវស្រី ។ របស់ប្រពន្ធសង្ឃឹមគិតចង់ជាណ្តើមគ្នាឲ្យនៅចំរើជាមួយ ។ តែលុះអេសុបមកដល់កាលណា ខ្លះយកដៃខ្ទប់មុខ ខ្លះរត់ចេញ ខ្លះស្រែកថា យ៉ីអីចេះ ! ។ ចំណែកនាងប្រពន្ធស្រែកថា: ចង់ដេញអញឲ្យចេញពីផ្ទះឬ ឬបានជាយកមនុស្សមុខខ្មៅចម្លឹងមក ? ។ ព្រោះលោកសង្ឃឹមឈប់ទៅមករកនាងនេះជាយូរណាស់ផង ។ ការប្រឈ្លោះគ្នាមួយម៉ាត់ជាពីរម៉ាត់ រហូតដល់នាងប្រពន្ធសុំឲ្យចែកទ្រព្យសម្បត្តិគ្នា ដើម្បីទៅផ្ទះរបស់ឪពុកម្តាយខ្លួន ។ ប៉ុន្តែដោយអំណាចនៃការអត់ធ្មត់របស់លោកសង្ឃឹម ទើបជាជ្រៃនៃអេសុបដែលធ្លាតកង់កាន់និយាយ, ស្វាមីភរិយាក៏បានស្រុះស្រួលគ្នាឡើងវិញ ។

ថ្ងៃមួយលោកសង្ឃនឹងអេសុបទៅឯសួនច្បារមួយ ដើម្បីកេងិញ បន្លែ ។ នាយច្បារបាចស្មៅមួយក្តាប់ ហើយសូមឲ្យលោកសង្ឃអធិប្បាយឲ្យស្តាប់ថា: បុះបន្លែដែលខ្ញុំខំប្រឹងដាំហើយស្រោចទឹកពាល់ថ្ងៃហេតុអ្វីក៏ចេះតែមិនសូវលាស់ល្អ ចំណែកស្មៅលាវលិចាំងឡាយគ្មានអ្នកណាដាំ គ្មានអ្នកណាស្រោចទឹកថែរក្សាសោះ ក៏ចេះតែលាស់ល្អអ្វីម្ល៉េះ? ។ សង្ឃទាល់ច្បាជ្រៅស្មៀម, អេសុបឃើញអាការរបស់ម្ចាស់ដូច្នោះសើចញឹម ។ ចាប់ដៃម្ចាស់ទាញមកកៀនរបង ហើយនុនក្បែរច្បាប់ថា: សូមលោកឆ្លើយតបទៅនាយច្បារថា : បញ្ហាបែបហ្នឹងមិនគួរដល់ខ្លួនខ្ញុំទេ ឲ្យតែក្មេងរបស់ខ្ញុំវាធ្វើយដួសក៏បានដែរ ។ សង្ឃបានទៅនិយាយច្បាប់នាយសួនច្បារតាមពាក្យអេសុប ហើយដើរលេងធ្វើព្រងើយទៅកែ្សរបង ។ អេសុបអធិប្បាយច្បាប់នាយសួនច្បារជាពាក្យឧបមាឧបមេយ្យថា : ដីដូចស្រីមេម៉ាយមានកូន ហើយយកប្តីពោះម៉ាយមានកូនដែរ : នាងនេះតែងតែមានចិត្តស្នេហាចំពោះកូនដើមរបស់ខ្លួនជាងកូនរបស់ប្តី បើបានវត្ថុអ្វី ។ តែងតែបួចយកឲ្យកូនរបស់ខ្លួនស៊ីច្រើនជាងកូនរបស់ប្តី: ចំណែកដីក៏ដូចស្រីមេម៉ាយនេះដែរ ។ នាយច្បារដែលពេញចិត្តនឹងពាក្យឧបមានេះ ក៏ឲ្យអេសុបយកតាមចិត្តនូវបន្លែដែលមាននៅក្នុងសួន ។

មិនបានកន្លងយូរបានប៉ុន្មានថ្ងៃ សង្ឃនឹងកិរិយាសាស់ខែងគ្នាទៀត ។ លោកនេះអញ្ជើញទៅពិសាលៀងគោជនាហារ បានយកបង្អែមយ៉ាង

ឆ្វេញ់ទុកមួយចំណែក ហើយប្រាប់អេសុបថា "ចូរឯងយកវត្ថុនេះទៅឲ្យ
នាងជាសំឡាញ់របស់អញ ។ អេសុបមិនយកទៅឲ្យប្រពន្ធរបស់ចៅហ្វាយ
នាយត្រឡប់ជាយកទៅឲ្យមេឆ្កែចិញ្ចឹមស៊ីវិញ ។ សង្ឃឹះដែលត្រឡប់មក
វិញ សួរកវិយាថា: ម៉េចអូនឯងញ៉ាំបង្អែមឆ្វេញ់ឬទេ? ។ កវិយាធ្វើ
ក្អែកឡឺងឡង់សួរថា: បង្អែមនៅឯណា? ។ ប្តីថា: អញឲ្យអេសុបយកមក
ឲ្យ ។ សង្ឃឹះសួរអេសុបថា: អញមានប្រាប់ឯងថាចូរយកបង្អែមនេះទៅ
ឲ្យនាងជាសំឡាញ់របស់អញឬទេ? ។ អេសុបឆ្លើយថា: មែន ប៉ុន្តែនាង
ជាសំឡាញ់របស់លោក មិនគឺប្រពន្ធរបស់លោកទេ ដែលគ្រាន់តែមាន
រឿងហេតុអ្វីបន្តិចបន្តួចក៏លែងលះគ្នា គឺបាកដជាមេឆ្កែឯណោះទេ បាន
ហៅថាសំឡាញ់របស់លោកមែន ព្រោះតែបើលោកវាយក៏ដោយ ដេរ
ក៏ដោយ វាចេះតែមករកលោកវិញ មិនចេះទឹងសម្បាតបន្ទឹងលោក ។
សំដីប៉ុណ្ណោះធ្វើឲ្យសង្ឃឹះកេរយកគោសមិនកើត ។ ចំណែកខាងប្រពន្ធដែល
ទឹងតែក៏រត់ទៅកាន់ផ្ទះរបស់ឪពុកម្តាយ សូម្បីសំឡាញ់ឬបងប្អូនណាមក
និយាយឲ្យស្រុះស្រួលក៏មិនព្រម ។ ឃើញការណ៍ដូច្នោះ អេសុបគិតធ្វើ
កលមួយដើម្បីនឹងឲ្យកវិយានៃចៅហ្វាយរបស់អាត្មាត្រឡប់មកផ្ទះវិញ ។
លោកយកកញ្ចេមួយទៅផ្សារ ហើយធ្វើជាទិញបន្លែនឹងអីវ៉ាន់យ៉ាងច្រើន ។
កំពុងតែរៀបរបៀនឹងទិញទំនិញ លោកប្រទះនឹងជាវស្រីរបស់ប្រពន្ធនៃ
លោកសង្ឃឹះ ។ នាងនេះសួរថា: ឯងទិញអីវ៉ាន់ធ្វើអ្វីក៏ច្រើនម្ល៉េះ? ។

លោកឆ្លើយថា: អញ្ចឹងយកទៅគិតរៀបអាពាហ៍ពិពាហ៍ជូនលោកសង្ហុះទៀត ដ្បិតប្រពន្ធរបស់លោកទៅផ្ទះនឹពុកម្តាយហើយ លោកត្រូវតែរកប្រពន្ធថ្មីទៀត ។ ប្រពន្ធរបស់លោកសង្ហុះបានដំណឹងដូច្នោះ ដោយសេចក្តីច្រណែនឬប្រច័ណ្ឌត្រឡប់មកផ្ទះវិញជាប្រញាប់ ហើយឈប់ទឹងនឹងប្តីនៃខ្លួន ។ មិនមែនជាឥតគំនុំសោះទេ ដែលអេសុបចេះតែរកឿងធ្វើទៅម្ចាស់របស់ខ្លួនឯងជានិច្ចជាកាល ហើយអង្វាលទឹងដោះសាទោសនៃខ្លួនវិញ ដោយសារខ្លួនមានប្រាជ្ញាវាងវៃ; លោកសង្ហុះមិនមែនជាមិនទឹងឡើយ ។

ថ្ងៃមួយជាថ្ងៃបុណ្យ ចៅហ្វាយរបស់លោករៀបស៊ីលៀងហៅពួកមិត្តភ័ក្តិជាច្រើនមកស៊ីផឹក ហើយប្រាប់លោកឲ្យទៅទិញម្ហូបអ្វីដែលល្អជាងគេយកមកធ្វើឲ្យភ្ញៀវស៊ី ។ អេសុបគិតក្នុងចិត្តថា: ម្តងនេះអញទឹងបង្រៀនម្ចាស់អញឲ្យស្គាល់ឲ្យចេះអធិប្បាយសព្វគ្រប់ នូវដំណើរដែលអ្នកត្រូវការប្រាថ្នា កុំឲ្យតែមានការអ្វីចេះតែធ្វើលាក់ទៅលើតែបាវប្រាវពេក ។ អេសុបទៅផ្សារទិញសុទ្ធតែអណ្តាតយកមកធ្វើម្ហូបឲ្យភ្ញៀវស៊ី ។ ដំបូងពួកភ្ញៀវសរសើរថាម្ហូបនេះឆ្ងាញ់មែន លុះយូរបន្តិចទៅស៊ីតែអណ្តាតជាដែលក៏ត្រឡប់ជាបាត់ឆ្ងាញ់ ។ សង្ហុះទឹងហៅអេសុបមកសួរថា: អញ្ចឹងប្រាប់ឲ្យឯងទិញរបស់ល្អៗហេតុអ្វីក៏ឯងទិញសុទ្ធតែអណ្តាតយកមកធ្វើឲ្យគេស៊ី ? ។ លោកឆ្លើយថា: របស់អ្វីល្អជាងអណ្តាត! អណ្តាតហ្នឹងហើយជាខ្សែ

សំរាប់ចង់ស្គាននមេត្រីរវាងជាតិនានារបស់មនុស្សក្នុងលោក ជាកូននៃ
នៃវិជ្ជាទាំងឡាយ ជាគួរនៃពាក្យសត្យនឹងសេចក្តីស្រុះស្រួលដោយសារ
អណ្តាតហ្នឹងហើយ គេអាចតាំងទីក្រុងហើយរៀបចំឲ្យបានស្អាត គេរៀន
ចំណេះផ្សេងៗ គេនិយាយពន្យល់ គេអាចតាំងខ្លួននៅតណ្តាលទី
ប្រជុំធំៗ បាន គេពោលសរសើរនូវគុណ របស់ព្រះជាម្ចាស់ដែលជា
ករណីយកិច្ចឯក ដែលមនុស្សត្រូវបំពេញមុនករណីយកិច្ចទាំងពួង ។
សង្ឃរតនៈរកឿងចាប់លោកឲ្យបាន ព្រោះខឹងនឹងសំដីរបស់លោកត្រូវគេត
រកឆ្លើយដោះមិនរួចក៏ច្រាប់ទៀតថា: ចូរឯងទៅទិញវត្ថុអ្វីដែលអាក្រក់ជាង
គេយកមកឆ្លើម្ហូបទៀត ស្អែកអញហៅក្បៀរមកស៊ីលៀងទៀត ។

ព្រឹកឡើង អេសុបស្ងូសុទ្ធតែអណ្តាតដដែល ហើយអធិប្បាយ
ច្រាប់ថា អណ្តាតគឺជាមេនៃជម្ងឺរាំងឡាយ ជាមេចិញ្ចឹមនូវរឿងក្តី
ជាប្រភពនៃការបំបែកបំបាក់គណៈនឹងចំបាំង, មួយទៀតអណ្តាតដែលគេ
ពោលថាជាគួរនៃសេចក្តីពិត ក៏អណ្តាតនេះឯងដដែល ជាគួរនៃសេចក្តី
បំភាន់ ហ៊ុយបើថាឲ្យអាក្រក់ជាងនេះទៅទៀត គឺជាមេនៃពាក្យបង្កាច់
ដោយសារអណ្តាតគេអាចបំផ្លាញទីក្រុង គេធ្វើឲ្យផ្ទឹតាមនូវតុអាក្រក់
ទាំងឡាយ កាលណាគេនិយាយថា អណ្តាតសម្រាប់ពោលសរសើរ
គុណរបស់ព្រះជាម្ចាស់ គឺអណ្តាតហ្នឹងដដែល សម្រាប់ពោលត្មះតិះ
ដៀលគុណរបស់ព្រះជាម្ចាស់ដែរ ។

អ្នកឧកញ៉ា ទេពពិទូរ ក្រសែម គន្ធបណ្ឌិត រៀបរៀង

(ត ចប)

កាលទៅដល់ហើយ ស្តេចត្រមដោយព្រះពជបរិពារចូលទៅគាល់ព្រះបាទលង្កិស្សរាជ។ ទ្រង់ធ្វើបដិសណ្ឋារៈ ដោយមេត្រីចិត្តយ៉ាងខ្ពស់រួចហើយស្តេចទៅគាល់ព្រះមហាសង្ឃបរិនាយក នៅមេឃគិរីមហាវិហារដែលជាទីសិក្សាយ៉ាងធំ ហាក់ដូចជាមហាវិទ្យាល័យបរិយត្តិធម៌ក្នុងសម័យនោះ សុំចំឡងព្រះត្រៃបិដកដ៏ជាកាសាបាលី ១ ចប់ នឹងជាកាសាលង្កា ១ ចប់ទៀត ។

កាលបើចំឡងចប់ហើយ ព្រះបាទអនុរុទ្ធគ្រាស់សុំព្រះកែវមរកតយកទៅទុកជាទីលើក, ព្រះបាទលង្កិស្សរាជក៏ត្រមថ្វាយ ។ ព្រះបាទអនុរុទ្ធក៏គ្រាស់ឲ្យជញ្ជូនព្រះត្រៃបិដកកាសាបាលីជាក់សំពៅ ១, ឲ្យជញ្ជូនព្រះត្រៃបិដកសម្រាយនឹងព្រះកែវមរកតជាក់សំពៅ ១, ចំណែកព្រះអង្គស្តេចទៅតាមសំពៅដែលជាក់ព្រះត្រៃបិដកបាលី, សំពៅទាំងពីរក៏បើកចេញចាកគោះលង្កា សំដៅមកប្រទេសភូមា; តែកាលមកដល់កណ្តាលសមុទ្រ, សំពៅដែលផ្ទុកព្រះត្រៃបិដកសម្រាយនឹងព្រះកែវមរកត ជាន់ត្រូវខ្យល់ព្យុះបោកបក់រសាត់មកជាប់នៅត្រើយសមុទ្រ ត្រង់ជាយខែត្របន្ទាយមាសនៃប្រទេសកម្ពុជាភាគខាងត្បូង ។

ក្រមការខែត្រចាប់សំពៅនេះបាន ក៏នាំយកគម្ពីរព្រះវិន័យបិដក សម្រាយនឹងព្រះកែវមរកតទៅថ្វាយព្រះមហាក្សត្រិយ៍ព្រះនាម ព្រះបាទ សូរ្យវ័ន្ទទី ១ នៅក្រុងស្រីយសោធរបុរៈ, ទ្រង់សោមនស្សណាស់ឲ្យ ទទួលដំកល់ទុកក្នុងព្រះវិហារ ១ ខាងក្នុងព្រះបរមរាជវាំង ។

ក្រោយនោះ ពតិមានេះបានជ្រាបទៅដល់ព្រះបាទអនុរុទ្ធ ។ ក៏ គ្រាស់ប្រើព្រះរាជបំរើឲ្យនាំព្រះរាជសារមកសូមយករបស់អំបាលនោះទៅ វិញ ។ ព្រះបាទសូរ្យវ័ន្ទទី ១ គ្រាស់ឲ្យប្រគល់ឲ្យទៅវិញទាំងអស់ រៀរ តែព្រះកែវមរកត ទ្រង់យកទុក ។ ព្រះកែវមរកតបានមកស្ថិតនៅក្នុង ប្រទេសកម្ពុជាដោយអាការយ៉ាងនេះ ។

រយៈទី ៤

ព្រះកែវមរកតចេញចាកក្រុងស្រីយសោធរបុរៈ ទៅស្ថិតនៅក្រុងស្រីអយុធ្យាជាបច្ចន្តរដ្ឋរបស់កម្ពុជា

ពី ព. ស. ១៦២៣ ដល់ ១៦៤០

កាល ព. ស. ១៦២៣ ក្នុងរដ្ឋកាលព្រះបាទហរិវ័ន្ទ[1] ទី ៣, ក្រុងស្រីយសោធរបុរៈត្រូវទឹកលិចធំយ៉ាងខ្លាំង ទាំងត្រូវចាម្ប៉ាលើកទ័ព ដើរឆក់យកមកវាយទៀតផង ។ ព្រះបាទហរិវ័ន្ទគ្រាស់ឲ្យក្រាក់ជារាជញ្ជូន ព្រះរាជទ្រព្យសំខាន់ៗ នឹងព្រះកែវមរកតជាកំពូល - សំពៅ ស្តេចព្រម

---

១ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាហៅក្សត្រិយ៍អង្គនេះថា «សេដ្ឋាធិរាជ» ។

ដោយព្រះពជវង្សានុវង្ស នឹងមន្ត្រីខ្លះទៅសំចតនៅដើងកុំដងវែកដែលទឹកមិនបានលិចដល់ ។

គ្រានោះ ព្រះអាទិត្យវង្សជាមហាឧបពជខ្មែរដែលគង់នៅក្រុងស្រីអយុធ្យា កន្លងផុតពីតំបន់នេះហើយ ក៏ស្តេចមកដល់ភ្នំយាងចុះទូកព្រះទីនាំង ព្រមដោយពួកឥសាហានដើងទឹកនឹងទូកធំៗឯទៀតជាច្រើន មកទទួលព្រះចៅហស៊ីវង្ន័យកទៅឯក្រុងស្រីអយុធ្យា ឲ្យផុតអំពីសេចក្តីអន្តរាយ ។

ក្រោយដែលព្រះចៅហស៊ីវង្ន័ស្តេចយាងផុតទៅហើយ ទ័ពចាម្ប៉ាក៏ចូលលុកក្រុងស្រីយសោធរបុរៈ ដណ្តើនយកទ្រព្យសម្បត្តិនឹងជុតផ្ទះសំបែងអស់ជាច្រើន ។ កាលចាម្ប៉ាលើកទ័ពត្រឡប់ទៅវិញហើយ មានព្រះពជវង្ស ១ ដែលមិនស្គាល់ព្រះនាមបានរួបរួមសេនារហ៍ពលតាំងខ្លួនជាព្រះពជាទៅដើងកុំដងវែក ។ គ្រានោះ មានព្រះពជវង្ស ១ អង្គទៀតព្រះនាមជយវង្ន័ គឺព្រះចៅហជយវង្ន័ទី ៦ ទ្រង់រួបរួមកងទ័ពបានជាច្រើនហើយ ក៏លើកចូលទៅគ្រងក្រុងស្រីយសោធរបុរៈ. . . ។

ចំណែកព្រះចៅហស៊ីវង្ន័ទី ៣ កាលទ្រង់ជាបថា ព្រះចៅហជយវង្ន័ទ្បើងគ្រងរាជបល្ល័ង្កនៅក្រុងស្រីយសោធរបុរៈហើយ ក៏អស់ផ្លូវដែលនឹងគិតត្រឡប់មកព្រះនគរវិញ ទ្រង់តាំងព្រះពជហ្ន័យថានឹងគង់នៅឯនគរស្រីអយុធ្យាតទៅមៀត តែព្រះពជបំណងនេះមិនបានសម្រេចបានទេ

ដោយអាយុខ័យមកដល់ ព្រះអង្គក៏សោយទិវង្គតក្នុងឆ្នាំនោះទៅ ។ ព្រះនាងជយភដ្ថមណីជាអគ្គមហេសី ទ្រង់គង់នៅនគរស្រីអយុធ្យា រហូតដល់រដូវក្ដាំង ទើបទ្រង់លាព្រះអាទិត្យវង្ស ត្រឡប់មកព្រះនគរវិញ, ព្រះអាទិត្យវង្ស មុននឹងវៀបក្សូនដូនព្រះពជដំណើរ បានគ្រាបទូលសូមព្រះកែវមេរកតទុក, ព្រះនាងក៏ព្រមព្រះពជទានតាមសុំ ព្រោះព្រះអាទិត្យ-វង្ស បានធ្វើឧបការៈចំពោះព្រះនាងជាច្រើន ដូចពោលហើយ ។

ព្រះកែវមេរកតបានចេញចាកក្រុងស្រីយសោធរបុរៈ ទៅស្ថិតនៅនគរស្រីអយុធ្យាដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ដោយអាការយ៉ាងនេះ ។

រយៈ ទី ៥

ព្រះកែវមេរកតចេញចាកនគរស្រីអយុធ្យា ទៅស្ថិតនៅនគរកំពែងពេជ្រឬហៅនគរកោសម្ពី

ព.ព. ស. ១៦៤០ ដល់ ១៦៦០

កន្លះវេនប្រមាណ ៣ ស. ១៦០០ ថ្ងៃយ មានព្រះមហាឧបភដ្ថខ្មែរ ១ អង្គព្រះនាម "កមភជ" នៅនគរកំពែងពេជ្រក្នុងរដ្ឋដែលដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ជាមហាមិត្តដ៏តឹងតែនឹងព្រះអាទិត្យវង្ស បានមកសុំយកព្រះកែវមេរកតអំពីព្រះអាទិត្យវង្ស ទៅទុកបូជានៅនគរកំពែងពេជ្រ ។ កាលយកទៅមិនយូរប៉ុន្មាន ព្រះមណ្ឌភជជាឧរសព្រះកមភជនៅលវបុរៈ (លពបូរី) ក្នុងហានៈជាចៅហ្វាយស្រុក បានទៅ

សុំយកព្រះកែវមរកតអំពីព្រះរាមមកជជាព្រះរាជបិតា ទៅខុកបូជានៅលវបុរៈ ។ តែយកទៅមិនយូរប៉ុន្មាន ក៏និមន្តយកទៅថ្វាយព្រះរាជបិតាវិញ, ព្រះរាមរាជ្ជទង់ប្រតិស្ឋានខុកនៅក្នុងព្រះវិហារធំ ១ នៅក្រុងកំពែងពេជ្រ នៅរហូតដល់ឆ្នាំ ព.ស. ១៦៦០ ។

ព្រះកែវមរកតបានទៅប្រតិស្ឋាននៅនគរកំពែងពេជ្រដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា ដោយអាការយ៉ាងនេះ ។

សរុបរវៀងដែលព្រះកែវមរកតមកស្ថិតនៅក្នុងកម្ពុជរដ្ឋ

នៅក្រុងស្រីយសោធរបុរៈ	៦៣	ឆ្នាំ
នៅនគរស្រីអយុធ្យា	១៧	ឆ្នាំ
នៅនគរកំពែងពេជ្រ	២០	ឆ្នាំ
រួមជា	១០០	ឆ្នាំគត់

រយៈទី ៦

ព្រះកែវមរកតបេញចាកនគរកំពែងពេជ្រ ទៅស្ថិតនៅយោនកនាគនគរ (ជៀងសែន) រួមទាំងនគរជៀងវ៉ាយ និងនគរទេលាង្គ

ចាប់ពី ព.ស. ១៦៦០ ប្រមាណដល់ ២០២០

ចាប់តាំងពីឆ្នាំ ព.ស. ១៦៦០ ព្រះកែវមរកតរបស់យើងបានគ្រាក់ទៅនៅក្នុងកណ្តាប់ដៃជាតិដទៃ ។ ដោយក្នុងរវាង ព.ស. ១៦៥១

ដល់ ๑๖๕๖ ជារដ្ឋការព្រះបាទនរណន្ទ្រវ័ន្ទទី ๑ សោយរាជ្យនៅ
ក្រុងស្រីយសោធរបុរៈនោះ ទ្រង់ខ្វាយព្រះតេជានុភាព ជាហេតុឲ្យ
មានការណ៍បះបោរក្នុងព្រះនគរ មិនត្រឹមតែក្នុងព្រះនគរទេ ស្រុកចំណុះ
ខ្លះក៏បះបោរឡើងដែរ ដើម្បីតាំងឥស្សរភាពឡើង ; ដោយចំពោះជាតិថៃ
(សៀម) មានបុរស ๑ នាក់ឈ្មោះព្រហ្មរាជ ជាបុត្រពង្គរាជ បាន
លបតាំងឥស្សរភាពឡើងនៅស្រុកយោនក ជឿនសែន[๑] ប្រមាណ
ក្នុងរវាង ព. ស. ๑๖๔๐ - ๑๖๕๐ ។

មកក្នុងឆ្នាំ ព. ស. ๑๖๕๖ ព្រះបាទសុរ្យវ័ន្ទទី ๒ ជារីរបុរសទ្រង់
បានសោយរាជសម្បត្តិជាតំណមកអំពីព្រះបាទនរណន្ទ្រវ័ន្ទទី ๑ ទ្រង់
វៀលក្រមាបអសន្តិសុខខាងក្នុងអស់រយៈ ๔ - ๕ ឆ្នាំ ទំរាំតែបានសាន្ត
ត្រាណ ។ វេលានោះ (ព. ស. ๑๖๖๐) ព្រះព្រហ្មរាជឃើញខាងក្នុង
ប្រទេសរឹតតែរឹងមាំជូរចត់ ក៏ឆក់យកឧកាសនោះរួបរួមកងទ័ពលើកមកសង្កត់
សង្កិនពស្ត្រ នៅជាយតាមព្រះពាជអាណាចក្រកាគងាលិច រហូតមកដល់
នគរកំពែងពេជ្រ ដោយរាជការខ្មែរដែលនៅប្រចាំរដ្ឋនោះមិនដឹងខ្លួន ។
ព្រះព្រហ្មរាជបានចូលទៅជួបនឹងព្រះពាមពាជ មហាឧបរាជខ្មែរនៅក្រុង
កំពែងពេជ្រ, បានឃើញព្រះតែវមកគគនៅក្នុងព្រះវិហារក៏សុំយកទៅ ។
ព្រះពាមពាជទើសចាល់ ក៏តោងលើកឲ្យទៅចាំងមិនស្ទុះ ។

๑ចូលមើលសេចក្តីពិស្តារក្នុងព្រះរាជពង្សាវតារក្រុងរដ្ឋការព្រះបាទនរណន្ទ្រវ័ន្ទទី ๑ ។

ព្រះព្រហ្មកដ កាលបានព្រះតែវមែរតតហើយ មានសេចក្តីព្រួយដោយគ្រែងខ្វែរលើកទំពៅដណ្តើមយកមកវិញ ក៏គិតធ្វើទុយ៉ំបំបាត់កស្តុតាង ដោយយកទុយ៉ំអមកបូកស្រោបព្រះតែវមែរតតនោះជិត ឲ្យមើលឃើញជាព្រះពុទ្ធរូបធម្មតា ហើយយកទៅលាក់ទុកយ៉ាងគត់មត់ ។

ចំណែកព្រះបាទសូរ្យវរ្ម័នទី ២ កាលទ្រង់កម្រាបអសន្តិសុខខាងក្នុងបានរាបរាបហើយ ស្តេចលើកទំពៅគ្រាបការណ៍បះបោរនៅតាមស្រុកចំណុះតាំងប៉ុន្មានឲ្យស្ងប់រាបរាបដូចដើមវិញ ; ពួកថៃ (សៀម) ដែលមានព្រះព្រហ្មកដជាប្រមុខ ក៏ត្រឡប់មកនៅក្រោមឥទ្ធិពលរបស់ព្រះអង្គតមកទៀត ។

មានពាក្យប្រជាសួរថា : កាលព្រះបាទសូរ្យវរ្ម័នទី ២ បានគ្រប់គ្រងជាតិថៃដូចដើមវិញហើយ ហេតុម្តេចក៏មិនស្រាវជ្រាវយកព្រះតែវមែរតតមកវិញ ? ។ មានពាក្យដោះស្រាយថា : ១ - ព្រោះព្រះព្រហ្មកដយកទៅធ្វើបំបាត់ជានដូចបានគោលហើយ បើទុកជាស្រាវជ្រាវក្តីក៏មិនងាយនឹងឃើញមកវិញ ; ២ - ព្រោះព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់កាប់អានសាសនាព្រាហ្មណ៍លទ្ធិវៃស្ណវៈ រឿងព្រះតែវមែរតតទ្រង់មិនបានយកព្រះពាដប្លាទ័យទុកដាក់ប៉ុន្មាន, ដោយហេតុនេះ ព្រះតែវមែរតតទើបកប់នៅក្នុងស្រុកយោនកដៀងសែន ។ កាលព្រះព្រហ្មកដសុគតហើយ ព្រះតែវមែរតតក៏ត្រូវនិមន្តទៅប្រតិស្ឋាន ទុកនៅដៀងព័យតមកទៀតអស់រយៈពេលជាយូរឆ្នាំ តែនៅដោយស្ងាត់កំបុំដ ។

ព្រះកែវមរកតបានរបូតពីកណ្តាប់ដៃខ្មែរ ធ្លាក់ទៅនៅក្នុងកណ្តាប់ដៃជាតិដទៃ ដោយអាការយ៉ាងនេះ ។

រយៈពេល ៧

ព្រះកែវមរកតបេញ្ចាកជៀងវ៉ាយ ទៅស្ថិតនៅនគរជៀងម៉ៃ

ច្រមាណក្នុង ព. ស. ២០២០ ដល់ ព. ស. ២០៩២

ក្នុងរវាង ព ស. ១៩៨៥ ដល់ ២០២៦ ដែលជារជ្ជកាលព្រះបាទតិ-លោកពាជ ព្រះចៅក្រុងជៀងម៉ៃ (ជាតិលាវ) សឹងមានអំណាចគ្របមកដល់ជៀងវ៉ាយ, គ្រានោះមានកិក្ខុចាស់ ១ រូប នៅក្នុងវត្ត ១ ក្នុងស្រុកជៀងវ៉ាយ តែងតែទៅចោសព្រះវិហារជារឿយៗ តែកិក្ខុនោះមិនបានដឹងថាព្រះកែវមរកតនៅក្នុងព្រះវិហារនោះទេ ។ នាថ្ងៃមួយកិក្ខុនោះបានទៅចោសដូចកាលសព្វដង ទទួលបទនៃព្រះពុទ្ធរូប ១ អង្គ របេះបាយអដែលគេស្រាបឃើញជាព្រះកែវ, បានប្រាប់ដំណឹងនេះដល់ចៅអធិការវត្តនឹងអ្នកដទៃៗទៀត ។ គេក៏ផ្តើលនាំគ្នាមកមើលឈួរ ហើយនាំគ្នាគេះបាយមកចេញឃើញជាព្រះពុទ្ធរូបកែវមរកត ។

សេចក្តីនេះមិនស្ងាត់ប្រាត់ បានជ្រាបដល់ព្រះចៅតិលោកពាជ។ ទ្រង់សោមនស្សណាស់ត្រាស់ឲ្យក្រាក់ងារ យកដំរីមកទទួលនិមន្តព្រះកែវមរកតយកទៅឯនគរជៀងម៉ៃ ។ កាលនាំទៅដល់ផ្លូវបែកទៅលំប៉ាង (នគរេ-លាង្គចាស់) នឹងផ្លូវទៅនគរជៀងម៉ៃ ដំរីក៏ផ្តើលរត់ទៅតាមផ្លូវទៅលំប៉ាង,

ខ្មែរតាញទប់នឹងញាក់ឲ្យទៅផ្លូវដៀងម៉ែដូចម្តេចក៏មិនត្រមទៅ គោង
បណ្តាយទៅតាមចិត្តវ ។ កាលទៅដល់លំចាំង ក្លាក់ជារម្នុកនាំក៏
យកព្រះកែវមរកតទៅប្រគល់ឲ្យព្រះសុវណ្ណាមាត្យ ជាទៅហ្វាយស្រុក
នៅទីនោះឲ្យរក្សាទុកជាបណ្តោះអាសន្ន ហើយទៅក្រាបទូលព្រះទៅ
តិលោកពាជតាមដំណើរ ។

ព្រះទៅតិលោកពាជកាលបើទ្រង់ជ្រាបហើយ ត្រាស់ឲ្យសាងវិហារ
នៅវត្តជោតិការាម (វត្តចេតិយហ្លួង) នៅក្រុងដៀងម៉ែជាប្រញាប់ស្រេច
ហើយ ត្រាស់ឲ្យលើកក្បួនមកនិមន្តព្រះកែវមរកតពីនគរខេលាង្គ ទៅ
ប្រតិស្ឋាននៅព្រះវិហារថ្មី ទ្រង់ធ្វើសក្ការៈបូជាដរាបលុះអស់ព្រះជន្ម ។

ព្រះកែវមរកតចេញពីដៀងព័យ ទៅប្រតិស្ឋាននៅនគរដៀងម៉ែ
ប្រមាណពី ព. ស. ២០២០ (?) ដល់ព. ស. ២០៩២ រួមវេលា
ប្រមាណ ៧២ ឆ្នាំ, ដោយអាការៈយ៉ាងនេះ ។

រឿងទី ៨

ព្រះកែវមរកតចេញចាកនគរដៀងម៉ែ
ទៅស្ថិតនៅក្រុងវៀងចន្ទន៍ប្រទេសលាវ ក្នុងកាល

ព. ស. ២១៧២ ដល់ ព. ស. ២៣២១

កាលក្នុង ព. ស ២០៩០ ព្រះដ័យដេដ្ឋាជាពាជនុរសព្រះទៅ
ពោធិសារពាជនៅក្រុងវៀងចន្ទន៍ ព្រះជន្មបាន ១៤ ឆ្នាំ បានទៅគ្រង

ពជសម្បត្តិនៅនគរជៀងមែ៉ ទ្រង់គោរពព្រះកែវមរកតខ្ចាំងណាស់ ។ លុះដល់ឆ្នាំ ព. ស. ២០៩២ ព្រះចៅពោធិសារពជជាព្រះពជបិតាសោយទិវង្គតនៅក្រុងវៀងចន្ទន៍ ។ ព្រះដ័យដេដ្ឋាក៏ស្តេចទៅថ្វាយព្រះភ្លើងព្រះបរមសពព្រះពជបិតា បានទាំងនិមន្តយកព្រះកែវមរកតទៅផង ដោយទ្រង់គិតថា ស្តេចយាងទៅនេះ ប្រហែលជាត្រូវទទួលសោយពជសម្បត្តិនៅក្រុងវៀងចន្ទន៍ផង ទើបទ្រង់និមន្តយកជាប់នឹងព្រះអង្គទៅ ។ កាលស្រេចថ្វាយព្រះភ្លើងព្រះបរមសពហើយ គេក៏អញ្ជើញឲ្យឡើងសោយពជ្ឈស្នងព្រះពជបិតាតមក មិនបានស្តេចត្រឡប់នគរជៀងមែ៉វិញទេ ។ ទ្រង់បានសាងព្រះវិហារ ១ យ៉ាងធំ សម្រាប់ប្រតិស្ឋានព្រះកែវមរកតព្រះវិហារនោះ គង់នៅដល់សព្វថ្ងៃនេះ ។

ព្រះកែវមរកតចេញចាកនគរជៀងមែ៉ ទៅប្រតិស្ឋាននៅនគរវៀងចន្ទន៍ រហូតដល់ឆ្នាំ ព. ស. ២៣២១ ដោយអាការយ៉ាងនេះ ។

រយៈពេល ៩

ព្រះកែវមរកតចេញចាកនគរវៀងចន្ទន៍ ទៅស្ថិតនៅក្រុងធនបុរីប្រទេសសៀម

ក្នុងកាល. ព. ស. ២៣២១

កាលព្រះចៅតាកសុំនសោយពជ្ឈបាន ១១ ឆ្នាំ គឺក្នុងឆ្នាំ ព. ស. ២៣២១ បានតាំស់ប្រែព្រះចៅព្រះយ៉ាចក្រី (ដួង) ជាមហាក្សត្រិយ៍សឹក

ឲ្យលើកទ័ពទៅកម្ចាបក្រុងសតនាគនហុត រហូតដល់ក្រុងវៀងចន្ទន៍ ។ កាលព្រះមហាក្សត្រិយ៍សឹកទៅដល់ក្រុងវៀងចន្ទន៍ បានឃើញព្រះកែវមរកតនៅក្នុងព្រះវិហារព្រះកែវ ក៏និមន្តយកមកថ្វាយព្រះចៅតាកសុិន ។ ទ្រង់ទទួលប្រតិស្ឋានទុកនៅក្រុងធនបុរីអស់រៀលា ៧ ឆ្នាំ ។

កាលព្រះចៅតាកសុិនទិវង្គតហើយ ព្រះចៅព្រះយ៉ាចក្រី (ដួង) បានឡើងសោយរាជ្យតមក ទ្រង់បានធ្វើមកសាងព្រះពជ្រកំផែងនៅត្រើយខាងកើត (គឺនៅបាងកកសព្វថ្ងៃនេះ) ហើយសាងព្រះវិហារ ១ នៅក្នុងកំពែងព្រះពជ្រកំផែងទិសខាងត្បូង សម្រាប់ប្រតិស្ឋានព្រះកែវមរកតនោះ ហៅថា វត្តព្រះស្រីរតនសាស្តាពាម ។ ព្រះកែវមរកត៍ស្ថិតក្នុងក្រុងទេព (បាងកក) ដរាបដល់សព្វថ្ងៃនេះ ។

ព្រះកែវមរកតចេញចាកក្រុងវៀងចន្ទន៍មកស្ថិតនៅបាងកក ដោយអាការយ៉ាងនេះ ។

បូកបញ្ចូលអាយុព្រះកែវមរកត តាំងពីសាងមកដល់បច្ចុប្បន្នកាលនេះប្រមាណ ២៤៨០ ឆ្នាំថ្មី ។

ប្រវត្តិព្រះកែវមរកតចប់ដោយសង្ខេបតែប៉ុណ្ណេះ

សាមណេរ គក - គីឡែង វត្តឧណ្ណាលោម ភ្នំពេញ

ប្រែរៀបរៀង ជាកាព្យពាក្យ ៧

ឃុនសុវត្ថិវេធី យូរ - អ៊ុន ពិនិត្យកែ

(ត ចប់)

កន្លែណានោះបុរសជាស្វាមី អស្ចង្កៀតស្មើព្រះសុរិយា
ចេញមកដល់ខ្ទមគេថ្ងាប់ថា ប្រពន្ធយោគាទៅស្រុកហើយ ។
ទើបប្តីកិតភ័យប្រឹងរត់តាម ទឹកភ្នែកហូរហាមពុំមានស្បើយ
ទួញថានុច្ចនសង្ឃារអើយ ម្តេចឡើយកាត់ចិត្តចាកស្នេហា ។
ប្រហែលជាប្អូនមិនអាណិត អាសូរដល់ចិត្តបងទេវ៉ា
កំពុងស្រឡាញ់ពេញចិន្តា ម្តេចប្អូនស្នេហាជាច់អាល័យ ។
ទួញហើយរត់តាមទាន់យប់នោះ តែអកុសលគ្រោះកាចចង្រៃ
បណ្តាលក្ងៀងផ្តរព្យុះខ្លាំងក្រៃ ស្រែទន់ដើងដៃភ័យមហិមា ។
នាងឈឺពោះដេកលើផែនដី ឯប្តីកិតភ័យស៊ុះម៉ីមា
នាងដេកស្រែកទួញក្នុងព្រឹក្សា ឥតមានអ្នកណាបានដឹងឡើយ ។
ពេលក្ងៀងនោះនាងប្រសូតកូន ក្នុងព្រៃស្ងាត់សូន្យយំព្រួយ
លុះនាងប្រសូតកូនរួចហើយ ញាប់ញ័រឥតស្បើយសព្វកាយា ។
កូនតូចកូនធំយំក្តែង ។ អាសូរសំឡេងកុមារ

ក្នុងពត្រីស្ងាត់នាព្រឹក្សា ភ្ញៀងផ្គរសង្ឃរាពួរខ្លារខ្លា ។
នាងគ្រាបក្រែងកូនតាំងពីពេលវ្ស ច្រត់ក្បាលដង្កត់ប្រឹងការពារ
ចំណែកស្វាមីភ័យសុះសារ ទៅពុំយូរយារកាប់ទស ។
ដើម្បីដុតអាំងកំដៅច្បាណ បដាចារកល្បាណក្នុងកាលនោះ
ដើរទៅពាស្អុបរកកាប់ទស មានពស់វែកមួយពិសយ៉ាងខ្លាំង ។
ក្អសូរចេញមកចឹកចិញ្ចើម ពីសតែ់ពេលថ្ងើមជាច់ដីវង្គ
ស្ងាប់ស្តូកដេកស្តឹងរូបរឹងគាំង រូបអើយអនិច្ចំកុងព្រឹក្សា ។
ចំណែកកវែយាចាំយូរពេក ស្ងាត់សូន្យវាវែកក្នុងចិន្តា
ទន្ទឹងស្វាមីខ្លាំងពេកណា ហើយបីបុត្រាដើរទៅតាម ។
ដឹកដៃកូនធុំបីកូនខ្ចី ជាស្រីស្រែកឮញាក្អែកហោម
ប្រញាប់ប្រញាល់ត្រាច់គន់ស្នាម ដើរតាមស្រែកហៅរកសាមិកា ។
នាងបានឃើញប្តីដេកស្តូកស្តឹង ឥតដឹងស្មារតីកុងព្រឹក្សា
នាងលូកដៃស្អុបសព្វកាយា ដឹងថាប្តីក្រែយដួចោះហើយ ។
នាងអួលអាក់អន់ស្ទើរធ្លាក់ថ្ងើម ដង្ហើមធុញថប់ឥតមានស្បើយ
ខ្លួញថាទុះទុស្វាមីអើយ ស្ងាប់ហើយចោលខ្ញុំនៅកំព្រា ។
អ្នកធ្លាប់រស់នៅរួមសុខទុក្ខ ពីនេះទៅមុខប្អូនវេទនា
មិនគួរអ្នកមកក្រែយដន្ធា ឲ្យប្អូនកំព្រាដូច្នេះសោះ ។
អ្នកស្ងាប់ចោលប្អូនគូពិសី ចោលតាំងកូនខ្ចីនៅជុំវិញ

ចោលតាំងកូនច្បងឲ្យក្រៀមក្រោះ ឲ្យប្អូនវង់គ្រោះខ្លុកស្ទើរក្ស័យ ។
បើនៅជាមួយអ្នកជាខ្មោច វែងខ្មោចផ្សាចិត្តពន់ពេកក្រៃ
នឹងទៅចោលអ្នកចិត្តអាល័យ អ្នកនៅក្នុងព្រៃតែម្នាក់ឯង ។
អ្នកមានតែសត្វជាបរិវារ នៅតែឯការវែងកណ្តែង
មានតែហ្វូងសត្វដើរខ្វាត់ខ្វែង ចំបែងចិត្តណាស់ណាមាសថ្លៃ ។
ណ្តើយចុះប្អូនសូមលាអ្នកទៅ សំដៅមាតុភូមិតាមនិស្ស័យ
ធ្វើម្តេចកម្មយើងកាចចង្រៃ ឲ្យអ្នកប្រុសថ្លៃក្ស័យចោលទៅ ។
នាងលាខ្មោចប្តីស្រែចកាល់ណា ខំនួញសោកាសែនក្តួលក្តៅ
អាក់អួលក្តុកក្តួលចុកណែននៅ ខំកាត់ចិត្តទៅក្នុងព្រៃក្សា ។
ដៃឆ្វេងនាងដឹកដៃកូនច្បង ដៃស្តាំត្រកងកូនពៅណា
សម្រក់ទឹកភ្នែកខន់កាយា ដើរក្នុងព្រៃក្សាខ្លាចសត្វផង ។
កូនតូចកូនធំស្រែកយំថ្ងូរ គួរឲ្យអាសូរពេកកន្ទុង
នាងខ្លួញលួងលោមកូនតាំងសង តែវល្លង្គាយអើយនាងកុំយំ ។
កូនអើយន៎ុះហ្ន៎សត្វសាកា ក៏នាំឈ្មោលញីស៊ីបេកខ្ញុំ
ដូចម្តាយកាលដើមនៅជួបជុំ ឥឡូវនេះមុំមណ៌ជីវ ។
កូនអើយអ្នកមើលន៎ុះសត្វខ្វែង ក៏ហើរខ្វាត់ខ្វែងឃ្លាតឪគ្នា
ដូចម្តាយបែកឪពុកចា កំព្រាខ្លាចផ្សាពុំមានស្ទើរ ។
កូនច្បូរមើលសេកហើរតាំងគូ បីដូចម្តាយស៊ូចញ្ចឹមកហើយ

តាំនោកបិតាកូនត្រាណាត្រើយ កូនអើយឥឡូវម្តាយខ្វោចផ្លា ។
កូនចូរមើលស្វាឧបមេវ៉ា ដូចកូនស្លូនភ្លូនឆ័មាតា
ម្តាយប័ថ្នាក់ថ្នមដឹកដៃបា អនិច្ចាចិត្តណាស់ណាកូនម្តាយ ។
កូនអើយកុំយំមើលត្រីក្បៃត្រៃ ឈើខ្ពស់ទ្រៃឈើមែកត្រសាយ
មានខោចឈ្មោលញីលោតប្រញាយ ចេះផលតាំងឡាយប្រទៀងគ្នា ។
មើលដើមសុទ្រីដុះប្រកិត សុទ្រីកំចិត្តទ្រាវេទនា
ដើមស្តៅម្តាយស្តាយឥតគណនា មិនគួរឃ្លាតឃ្លាបិតាអ្នក ។

កូនអើយតីថ្ងៃនេះទៅមុខ ខ្លួនម្តាយបានទុក្ខព្រួយឥតអាក់
ដូចដែនថ្នំធំគេលើកដាក់ ចំលាក់លើខ្លែងធ្ងន់ណាស់ណា ។
ទុក្ខម្តាយក៏ធ្ងន់យ៉ាងនោះដែរ មិនស្រាកមិនល្អែតីកាយា
កូនអើយកុំយំកុំសោកា អាណិតមាតាណាមាសម្តាយ ។

លុះនាងដើរផុតព្រៃនោះទៅ ឃើញស្ទឹងមួយនៅជិតមិនឆ្ងាយ
នាងកំតក័យខ្លាំងញ័រអង្គកាយ ត្រីផងតាំងឡាយហែលត្រៀបត្រា ។
នាងដាក់កូនធំត្រើយអាយខ្លី ហើយប៉ីកូនខ្លីឆ្លងស្ទឹងថ្លា
ដល់ត្រើយហើយបេះស្លឹកត្រីក្បា ក្រាលផ្តេកបុត្រាហើយត្រឡប់ ។
មកយកកូនធំនៅត្រើយអាយ កំតក័យកងកាយញ័រចំប្រប់
នឹកព្រួយក្នុងចិត្តសែនធុញថប់ ត្រឡប់បៃមុខមើលកូនខ្លី ។
មានសត្វខ្លែងមួយធំចំឡែក ធំប្លែកជាងសត្វខ្លែងប្រក្រតី

ហើរវិលក្រឡឹងជិតកូនខ្លី រំពៃគិតស្មានថាម៉ែសា ។
នាងឃើញទះដៃស្រែកដេញខ្វែង កូនធំនោះឯងគិតស្មានថា
ម្តាយបក់ដៃហៅរកអាគ្នា ស្រាប់ចុះទឹកលង់ស្លាប់ទៅ ។
បំណែកកូនខ្លីខ្វែងឆាបយក ទៅលើពពកខ្ពស់សន្ធៅ
នាងសុះឆ្លូវក្នុងទឹកជ្រៅ ស្លាប់កូនគ្មាននៅសល់មួយឡើយ ។
មុខគួរអោសូវនាងណាស់សា វែកខ្លួញយំថាមាសម្តាយអើយ
ម្តាយបាននរណាពឹងជាត្រើយ កូនអើយអ្នកស្លាប់ចោលមាតា ។
ម្តាយខំដឹកដៃពថ្លាក់ថ្ម ម្តាយខំបីបមថែរក្សា
ឥឡូវកម្មកូនសូន្យដីវ៉ា ព្រាត់ចោលមាតាស្លាប់ឆាត់ឈឹង ។
ពីថ្ងៃនេះទៅខ្លួនមាតា ពុំក្សាន្តចិត្តទុក្ខគានតឹង
ស្លាប់កូនស្លាប់ប្តីកម្មអ៊ីហឹង បើម៉ឹងទ្រូងម្តាយធ្លាមេ្តចបាន ។
រួចទើបនាងធ្វងផុតស្ទឹងនោះ ដើរឆ្ពោះទៅជួបប្រុសឯកា
នាងសួរថាអ្នកមកពីណា ? គេថាខ្ញុំមកពីសាវត្ថី ។
នាងសួរថាអ្នកស្គាល់បិតា ញាតិកានៃខ្ញុំដែរឬអី ?
គាត់ជាអ្នកមានធនធានលើ ធ្លើជាសេដ្ឋីក្រុងនេះណា ។
ប្រុសនោះឆ្ងល់ថាម្តេចស្រី សេដ្ឋីបិតានឹងមាតា
នៃអ្នកក្លើងឆេះស្លាប់អាគ្នា យប់មិញនេះណាគ្មានសល់ឡើយ ។
ឃ្លាំព្យុះបក់ផ្ទះក្លើងឆេះអស់ គ្មានសល់របស់អ្វីសោះហើយ
ខ្ញុំកំពុងស្តាយពុំបានស្បើយ មើលចុះនុ៎ះហើយឃើញតែផ្សែង ។

នាងស្តាប់សំដីចប្បាស់ទេះដើមទ្រូង ស្រែកឲ្យរលូងឮក្តែង ។
ទុកមកអ្វីឲ្យផលជាក់ស្តែង អញពេញចំបែងទ្រូងខ្ញោចផ្សា ។
ស្ងាប់ឥពុកម្តាយកូនសូន្យឈឹង មិនដឹងជាពឹងអ្នកឯណា
មានតែខ្លួនមួយព្រួយចិត្តា នេះចំជាទុក្ខស្ទើរប្រែះ ។
នាងព្រួយច្រែងត្រែតឆ្គត់វង្វេង កម្មព្រៃងមកផ្តល់កង់ពេលនេះ
ក្ងេចសំពត់អាវរបូតរបេះ គ្មានចេះការពារកេរ្តិ៍និន្ទា ។
អ្នកផងឃើញអាក្រាតដូច្នោះ អៀនខ្មាសកង់ពោះមហិមា
ទើបដេញចោលនាងតែពាល់គ្នា គួរឲ្យវេទនាអនេកលន់ ។
ជួនជាគ្រានោះព្រះសាស្តា កំពុងទេស្នាក្រាសពួកជន
ដោយហេតុកុសលពីជាតិមុន បន្ទន់ចិត្តនាងឲ្យដើរចំ ។
ដល់ហើយឈរក្រោយក្រមបរិស័ទ្យ ដៃលកាត់មកស្តាប់ធម៌ទុត្តម
បរិស័ទ្យឃើញដូច្នោះដេញបង្ខំ កុំឲ្យឈរយំជិតសាស្តា ។
ព្រះអង្គកាលទតឃើញហេតុនោះ ទ្រង់មានអនុគ្រោះត្រាស់តបថា
កុំឃាត់នាងបជាចាក បើកឲ្យយាត្រាចូលមកអាយ ។
មហាជនលែងដេញលែងឃាត់ខាំង នាងដើរចូលទាំងអាក្រាតកាយ
អង្គុយចំកន្លែងស្រស់ពណ្ណរាយ ស្តាប់ធម៌សូប់កាយសូប់ចិត្តា ។
លុះស្តាប់ធម៌ព្រះប្រៃស្មារតី ជាស្រីលែងឆ្គត់លែងលា
ពួកជនឲ្យសំពត់ពាន រុំព័ទ្ធកាយារំពេចខ្លី ។
លុះនាងស្វែកហើយទូលព្រះអង្គ សូមទ្រង់ព្រះសង្ឃគ្រាបណី

ដ្បិតខ្ញុំកំសត់លើសអស់ស្រី
មានប្តី។ ស្ងាប់ក្នុងព្រឹកឯ ។
កូនប្រុសធំលូនលង់ទឹកស្ងាប់
កូនខ្ចីខ្ចៃឆបាប់ជាកកូ
ចំណែកមាតានឹងបិតា
ក្សិណាក្សយដីរ៉ាអស់សូន្យឈឹង ។
ខ្លួនខ្ញុំនេះគ្មានអ្នកឯណា
ពំនាក់អាត្មាគ្រាន់ទីពឹង
ឲ្យបាត់ទុក្ខព្រួយក្នុងគ្រាហ្នឹង
សូមពឹងព្រះអង្គស្មើជីវិត ។
ព្រះពុទ្ធទ្រង់មានពុទ្ធដីកា
នែបជាចាកនាងកុំគិត
ទីពឹងទាំងនោះឃើញខុសពិត
ចូរគិតលះបង់ដោយប្រាជ្ញា ។
របស់ទាំងនោះតែងវិនាស
និកសព្រាត់ប្រាសជាធម្មតា
ចំណែកមនុស្សសត្វសង្ខារ
គ្មានអ្នកឯណាបានសុខឡើយ ។
នេះព្រោះតែសាងកម្មអកុសល
ឲ្យបានទុក្ខលំបាកមិនមានស្បើយ
ដូច្នេះចូរនាងកុំកន្តើយ
ចូរធ្វើឲ្យស្បើយចាកទុក្ខា ។
ចូរនាងទីពឹងដល់ព្រះពុទ្ធ
ព្រះធម៌បរិសុទ្ធសឹងថ្លៃថ្លា
ទីពឹងព្រះសង្ឃទ្រង់សីលា
ឥឹងរួចទុក្ខាពុំខានឡើយ ។
ព្រះអង្គសំដែងទ្រង់ប្រកាស
លុះចប់ទេសនាពេលណាហើយ
នាងលុះសោតាបន្នសុខស្បើយ
រួចហើយសុំបួសពេលនោះណា ។
បជាបតិកុនី
ជាស្រីមិនយូរកាលវេលា
សម្រេចអរហត្តក្នុងចិត្តា
ដោយសារទីពឹងព្រះពុទ្ធថ្លៃ ។
រឿងនាងបជាបតីនេះឯង
ខ្ញុំតែងសង្ខេបបំប្រួញន័យ
ថ្នេះសូមអស់លោកឲ្យអភ័យ
ទោសពៃរ៍កុំបីនិន្ទាអើយ ។ (ចប់)

លោក អ៊ុម-គយ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់

(ត ចប់)

ជានឈ្មោះថា "បុព្វាចារ្យ" ព្រោះលោកជាគ្រូអាចារ្យបង្ហាត់បង្រៀន មានបង្រៀនឲ្យចេះនិយាយស្តីដឹងគួរសម ស៊ីចុក ដេកដើរជាដើម មុនជាងគ្រូអាចារ្យឯទៀត ។ ជានឈ្មោះថា "អាហុនេយ្យបុគ្គល" ព្រោះមាតាបិតា គួរដើម្បីទទួលគ្រឿងបូជា ដែលកូនប្រុសស្រីលើកមកជូន គឺថាបុត្រធីតាណាជានបូជាលោកហើយ រមែងជានផលានិសង្សច្រើន ដូចជាជានបូជាចំពោះព្រះអរិយបុគ្គល ។

ចំណែកខាងការធ្វើអាក្រក់ គឺសំឡាប់មាតាបិតា លោកចាត់ចូលក្នុងអនន្តរិយកម្ម ។ នោះមាន ៥ យ៉ាងគឺ មាតុឃាត (សំឡាប់មាតា) ១ បិតុឃាត (សំឡាប់បិតា) ១ អរហន្តឃាត (សំឡាប់ព្រះអរហន្ត) ១ លោហិតុប្បាទ (ធ្វើព្រះលោហិតនៃព្រះសម្មាសម្ពុទ្ធឲ្យបែកចេញ) ១ សង្ឃភេទ (បំបែកសង្ឃ) ១ ។ ការសំឡាប់មាតាបិតានេះ ជាអំពើមានទោសធ្ងន់បំផុតប៉ុនទឹងទោសសំឡាប់ព្រះអរហន្តដែរ ព្រោះមាតាបិតាជាព្រះអរហន្តរបស់កូនប្រុសស្រី ។ ការធ្វើល្អឬអាក្រក់ចំពោះមាតាបិតា ក៏ជានផលច្រើន ដូចជាធ្វើល្អឬអាក្រក់ ចំពោះព្រះអរហន្តវីណាស្រេចដែរ ។ ព្រោះហេតុនោះ សាធុជនគួរតែគោរពកប់អានបូជា

ចំពោះព្រះអរហន្តដែលនៅជាមួយនឹងយើងកាលថ្ងៃ ពិតមែនតែយើងគ្មានមកមិនទាន់ព្រះអរហន្តជាខ្លាំងស្រួលលោកឋានិញ្ជានហួសទៅហ៊ុយ យើងមិនបានថ្វាយបង្គំបូជាដោយចតុប្បច្ច័យ, ប៉ុន្តែបើមាតាបិតាយើងនៅរស់ យើងមិនមែនឈ្មោះថា ត់តភ័ព្វសំណាងទេ ឈ្មោះថាមានលាភហើយ ព្រោះលោកជាព្រះមួយរបស់បុគ្គលតាកាលរួប ។ ដូច្នេះយើងគួរកុំព្រងើយកន្តើយ កុំធ្វើឲ្យលោកអន់អាក់ត្រណាក់ចិត្ត គប្បីថ្វាយបង្គំបូជាដោយគ្រឿងសក្ការៈផ្សេង ។ សមដូចពុទ្ធភាសិតថា:

តស្មា ហិ ឯេ នមស្សេយ្យ សក្កច្ចេយ្យ ច បណ្ឌិតោ
អន្នេន.អថោ ចាឯេន វត្ថេន សយនេន ច
ឧច្ចាឯនេន នភោមនេន ចាទានំ ដោឯនេន ច ។

"ព្រោះហេតុនោះ កូនប្រុសស្រីជាបណ្ឌិត គប្បីថ្វាយបង្គំនូវមាតានឹងបិតានោះផង គប្បីកាប់អាននូវមាតានឹងបិតានោះដោយចំណីទឹក សំពត់ ទីដេក គ្រឿងក្រអូប គ្រឿងគក់ ទឹកលាងដើងផង" ។

អ្នកដែលទំនុកបំរុងចិញ្ចឹមមាតាបិតា រមែងមិនថ្លុះធ្លាយធ្លាក់ខ្លួនទៅក្នុងទីទាបថោកឡើយ រមែងបានចំរើនដោយបុណ្យយសសក្តិដ៏ខ្ពង់ខ្ពស់ដោយលំដាប់ដូចព្រះចន្ទខាងខ្នើត នឹងបានទទួលពាក្យសរសើរអំពីសំណាក់អ្នកប្រាជ្ញ លុះដល់រំលាងបញ្ចក្ខន្ធទៅ រមែងបានទៅកើតកន្លែងសួគ៌សមដូចពុទ្ធភាសិតថា:

យោ មាតរំ វិតរំ វា　　មញ្ញោ ឆម្មេន ចោសតិ
តាយ នំ ចាវិចវិយាយ　　មាតាបិត្ថូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ　　បេច្ច សគ្គេ បមោទតិ។

“អ្នកឯណា ចិញ្ចឹមមាតា ឬ បិតា ដោយធម៌, ព្រោះការប់រើប្រដៅបត្តិចំពោះមាតាបិតានោះ ពួកបណ្ឌិតតែងសរសើរអ្នកនោះក្នុងលោកនេះ លុះអ្នកនោះក្បុំយជីវិតទៅ រមែងរីករាយក្នុងស្ថានសួគ៌ទៀត” ។

អ្នកដែលចំនុកបំរុងមាតាបិតានោះ មិនមែនគ្រាន់តែបានទទួលពាក្យសរសើរអំពីអ្នកប្រាជ្ញក្នុងលោកនេះទេ សូម្បីពួកទេវតាក៏គង់តែសរសើរបុគ្គលនោះដែរ សមដូចព្រះពុទ្ធនិពន្ធកាសិតថា :

មាតាបេតំភរំ ជន្តុំ　　កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សក្ខិលសម្ភាសំ　　បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ　　សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវត្តឹសា　　អាហុ សប្បុរិសោ ឥតិ។

“ពួកទេវតា ក្នុងជាន់ត្រៃត្រឹង្ស តែងហៅនូវជនប្រុសស្រីដែលចិញ្ចឹមមាតាបិតា, ប្រព្រឹត្តកោតក្រែងបុគ្គលជាធំក្នុងត្រកូល, មានសំដីពីពោះ, ពោលពាក្យនាំឲ្យគើតមិត្រ, លះបង់ពាក្យញុះញង់, ប្រាសចាកសេចក្តីកំណាញ់, មានពាក្យសត្យ, គ្របសង្កត់សេចក្តីក្រេវក្រោធ នោះថាជាសប្បុរស” ។

មិនមែនគ្រាន់តែបានទទួលគោរម្យងារថា "សប្បុរស" ប៉ុណ្ណោះឡើយ សូម្បីខ្លួនមានគ្រោះថ្នាក់គួរដល់ស្លាប់ ក៏គង់រួចចាកសេចក្តីស្លាប់នោះបាន តួយ៉ាងដូចព្រះពោធិសត្វកាលកើតជាមន្ទិយម្រឹគ ។

សេចក្តីដំណាលថា: ព្រះមហាក្សត្រមួយអង្គសោយរាជ្យក្នុងក្រុងសាកេត នាគោសលរាស្ត្រ មិនប្រកបដោយទសពិធរាជធម្ម តែងនាំបណ្តាក្រស្តេចបរបាញ់សត្វតាំងរដូវប្រាំងវស្សា ។ ពួករាស្ត្រមិនអាចធ្វើការរបររកស៊ីបានឡើយ ទើបនាំគ្នាធ្វើយ័ញ្ញក្នុងទីព្រាន ហើយកៀងម្រឹគបញ្ចូលក្នុងយ័ញ្ញនោះ ដើម្បីឲ្យស្តេចងាយបាញ់ផង ខ្លួនក៏បានឱកាសធ្វើការងារផង ។ គ្រានោះ ព្រះពោធិសត្វកើតជាមន្ទិយម្រឹគ បាននាំពង្រត់មាតាបិតាភៀសចេញពីព្រៃធំទៅពួនសម្ងំក្នុងគុម្ពតឈើតូច, កាលគេលើកព្រៃដល់ទីនោះ, បានលះបង់ជីវិតជូនមាតាបិតា ហើយរត់ទៅម្នាក់ឯងចូលទៅក្នុងយ័ញ្ញនោះ ។

តស្មឹ ខណៈ ក្សត្រាណោះព្រះពាជាតែងបាញ់ម្រឹគក្នុងយ័ញ្ញនោះតាមវេន ក្នុងមួយថ្ងៃមួយៗ ។ ថ្ងៃមួយត្រូវវេនម្រឹគពោធិសត្វក៏ចេញមកឈរទៀបមាត់ទ្វារ ហើយផ្សាយមេត្តាចិត្តចំពោះស្តេច ។ ដោយគុណដែលបានទំនុកបំរុងលះជីវិតជូនមាតាបិតានឹងមេត្តាធម៌នោះ ព្រះពាជាមិនអាចបាញ់បាន ទើបទ្រង់លាន់ព្រះឧស្សាថា "ឧ! ស្នាដៃដែលធ្វើពីកំណាត់ឈើ ជារបស់ឥតចិត្តវិញ្ញាណទេ ម្តេចក៏ពាំដឹងថាម្រឹគនេះមានគុណធម៌ល្អ


ក្នុងខ្លួន អាត្មាអញជាមនុស្សត្រឡាំង ម្តេចក៏មិនដឹងគុណធម៌របស់ម្ចីគុនេះសោះ” ទ្រង់ប្រទានឱ្យអភ័យដល់នន្ទិយម្ចីគត្រមាំងពួកម្ចីគដ៏សេស ។ រីឯនន្ទិយម្ចីគទូន្មានព្រះពជាថា “បពិត្រមហាពជ! ចាប់តាំងពីថ្ងៃនេះទៅ សូមទ្រង់លះបង់អគតិទាំង ៤ ចេញ ហើយសោយពជ្រប្រកបដោយទសពិធពជធម៌ ១០ ប្រការ” រួចពោលពាក្យជាគាថាថា :

ចាគំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ
អក្កោធំ អវិហឹសញ្ច ខន្តិ ច អវិរោធនំ
ឯត្ថេតេ កុសលេ ធម្មេ បិតេ បស្សាហិ អត្តនិ
តតោ តេ ជាយតេ ប៊ីតិ សោមនស្សញ្ចនប្បកំ ។

“(បពិត្រមហាពជ) សូមព្រះអង្គទ្រង់ពិចារណានូវកុសលធម៌គឺទសពិធពជធម៌ ១០ ប្រការនេះគឺ ការឲ្យទាន ๑, ការរក្សាសីល ๕ ជានិច្ច ឬរក្សាសីល ๑๐ មួយដងមួយកាល ๑, ការចំណាយព្រះពជទ្រព្យនុកបំរុងព្រះនគរ ๑, មានសេចក្តីត្រង់ ๑, មានសេចក្តីទន់ភ្លន់សុភាពរាបសា ๑, ការកាន់ឧបោសថសីលតាមកាលកំណត់ ๑, មិនកំដៅពោលអាលអ្នកដទៃ ๑, មិនបៀតបៀនអ្នកដទៃ ๑, មានសេចក្តីអត់ឱន ๑, មិនបំពានលើច្បាប់លើធម៌ ๑ ដោយព្រះអង្គឯង, ព្រោះការ

ប្រតិត្តិនូវទសពិធធម៌ទាំង ១០ នោះ ប៉ិតនឹងសោមនស្ស
រមែងកើតដល់ព្រះអង្គជានិច្ច ។

ធម៌ទាំង ១០ នេះសំរាប់ព្រះរាជាប្រតិត្តផ្ទាល់ព្រះអង្គ ព្រមទាំង
ណែនាំសេនាបតីនាម្ចាំនមុខមន្ត្រីតូចធំ នឹងពួកក្សត្រឲ្យប្រតិត្តតាមផង ។
ឯវិមាយំ ធម្មទេសនា សង្ខេបេន សមត្តា ធម៌ទេសនានេះសូម
សន្មតថាចប់ដោយសង្ខេប សមគួរដល់កាលវេលា ឯវំ ដោយនូវប្រការ
អំបាលនេះហោង ។



សុភាសិត

អ្នកមានបំណោះវិជ្ជាល្អ ប៉ុន្តែមិនប្រតិត្ត
ឲ្យសមគួរនឹងវិជ្ជានោះ នឹងឈ្មោះថាជា
មនុស្សល្អ្លែមិនបាន ។

យូរ-អ៊ុន

ពិធីផ្ទេរព្រះពុទ្ធសាសនបណ្ឌិត្យ
ជូនមកកាន់រដ្ឋាភិបាលខ្មែរ

នៅថ្ងៃ ១៤ ខែតុលា ឆ្នាំ ១៩៩០ ក្នុងវេលាព្រឹកម៉ោង ៩ ទឹង ១៥ នាទី មានធ្វើពិធីផ្ទេរព្រះពុទ្ធសាសនបណ្ឌិត្យជាឧត្តរិក ជូនមកកាន់រដ្ឋាភិបាលខ្មែរ ។ ពិធីនេះធ្វើនៅក្រោមព្រះរាជាធិបតី នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ដើម្បីឲ្យយើញនូវអត្ថរសនៃអធិបតេយ្យភាពក្នុងប្រទេស ដែលជាផលនៃសន្ធិសញ្ញា ចុះថ្ងៃ ៨ ខែវិច្ឆិកា ១៩៨៩ ។

ក្នុងថ្ងៃដែលធ្វើពិធីនេះ មន្ទីរព្រះពុទ្ធសាសនបណ្ឌិត្យ មានការតាក់តែងដោយគ្រឿងលំអផ្សេងៗ : ខ្លោងទ្វារខាងកើតរចនាដោយកម្រងផ្កាទឹងស្ទឹកវ្រកជាតិ ដ៏ប្រជាប់ដោយទង់ជាតិខ្មែរ - ចាក់ឆ ។ នៅទីថ្កល់ប្រជុំខ្លោងទ្វារនេះ មានកងឥស្សរជនក្រុមរក្សាព្រះអង្គ ទឹងក្រុមក្មេងព្រះរាជទ្រព្យឈរនៅចាំធ្វើគារវកិច្ច ។ ខាងក្នុងនៃមន្ទីរក៏ប្រជាប់ដោយកម្រងផ្កាស្ទឹកវ្រកជាតិទឹងទង់ជាតិ គួរឲ្យទស្សនាដូចខាងក្រៅដែរ តែត្រង់ស្លែងធំដ៏ខ្ពស់ខ្ពូលាយនោះ រៀបចំជាទីសម្រាប់សន្និបាត សឹងពាសពេញទៅដោយតុទឹងកៅអី ដែលមានគ្រាលព្រំយ៉ាងល្អជាច្រើនាប់ ។

ការរៀបចំតាក់តែងមន្ទីរដោយគ្រឿងលំអក្នុងពិធីនេះ ជាស្នាដៃនៃព្រះតេជព្រះគុណ មាស - ហៀល រដ្ឋមន្ត្រីក្រសួងធម្មការទឹងសិល្បការ ពប់ថាជាកំសួតាងឲ្យយើញថា លោកពេញចិត្តជាទីបំផុតនឹងពាក្យការចាក់ឆ ដែលផ្ទេរក្រសួងនេះមកឲ្យពាក់ព័ន្ធរដ្ឋាភិបាលខ្មែរវិញ ។

លុះដល់ពេលដែលកំណត់ថ្ងៃវេជ្ជបដុំហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, លោកកុម្មិស្សែរដឹឡាវេពុយពួកត្រូវបានចាត់តម្កល់ជារដ្ឋមន្ត្រីក្រសួងមហាឧត្តមមុនីពង្ស នាយករដ្ឋមន្ត្រី, សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះធម្មលិខិត ខុត្តមប្រីក្សា, ព្រះគ្រូអរិយកស្សប អ៊ិច ជាតំណាងសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ, សមាជិករដ្ឋាភិបាល, ព្រះសង្ឃជាច្រើនអង្គ ព្រមទាំងឥស្សរជនខ្មែរ - ចាំពាំងជាច្រើននាក់ទៀត ចូលរួមដង្ហែ - អញ្ជើញទៅប្រថាប់ - គង់ - អង្គុយលើអាសនៈ (កៅអី) ដែលរៀបចំរុងទុក ក្នុងកិច្ចដ៏ថ្លៃថ្លានេះ ។

ក្នុងពេលដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងមកដល់ហើយ, នោះលោកបិស់សឺលិយេ ជាអភិក្សនៃសារមន្ទីរអាល់ប៊ែរសារ៉ូ ចូលថ្វាយនូវសុន្ទរកថាមួយក្នុងនាមនៃរដ្ឋាភិបាលចាំពាំង រៀបរាប់អំពីប្រវត្តិនៃពុទ្ធសាសនបណ្ឌិត្យ ដែលតាំងពីកើតមក តែងបានសេចក្តីចំរើនតុំដែលជាច់ ហើយមានពន្ធឹនាមខ្ចរខ្ចាយខ្ចរខ្ចៅដល់ប្រទេសជិតខាង ។

បន្ទាប់មក ព្រះតេជព្រះគុណ មាស - ហែល ជារដ្ឋមន្ត្រីក្រសួងធម្មការនិងសិល្បការ ចូលសូត្រនូវសុន្ទរកថាមួយ ថ្វាយសេចក្តីគ្រែតអរចំពោះរដ្ឋាភិបាលចាំពាំង ដែលបានផ្តួរវិជ្ជាស្ថាននេះ ។

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃចាំងឡាយសូត្រធម៌ជយន្តោដូនពរស័ព្ទសាធុការឲ្យអង្គការនេះបានចំរើនតរៀងទៅ ។

ក្នុងខ្លឹមសារ សេចក្តីកត់ហេតុសម្រេចអំពីការផ្លាស់នេះ ។

សុន្ទរកថានៃលោកប៊ីស់ស៊ីលីយេរ

អភិរក្សនៃសារមន្ទីរ អាល់ប៊ែរស៊ូ កាន់តំណែងបណ្តោះអាសន្នជាអគ្គលេខាធិការ នៃក្រុមពុទ្ធសាសនបណ្ឌិត្យ ។

ព្រះករុណាជាម្ចាស់ជីវិតលើត្បូង,

លោកស្នងការនៃសាធារណរដ្ឋ,

សម្តេច,

ខ្ញុំ,

ព្រះថេរានុត្តេរៈ,

ព្រះតេជព្រះគុណ,

អ្នកស្រី លោកអ្នកទាំងឡាយ,

ក្នុងព្រឹត្តិការណ៍ដ៏ឧឡារិកដែលមានមកក្នុងកាលឥឡូវនេះ ហើយចំពោះកិត្តិយសដែលខ្ញុំត្រូវទទួលក្នុងការសូត្រសុន្ទរកថា ក្នុងនាមនៃរដ្ឋាភិបាលជាកំង ខ្ញុំមិនអាចផ្ញើឲ្យចិត្តដែលរំជួលខ្ទាំងរបស់ខ្ញុំឲ្យស្ងប់ទៅបាន ... ;

ខ្ញុំខ្ញុំអភិបុពណ៌ត្តុ, តែដោយចៃដន្យក្នុងទេសកាល, ទៅជាបានមកតបប្រសព្វនឹងក្រុមបណ្ឌិត្យដែលបានសិក្សាខាងភាសាសំស្ក្រឹត នឹងបាលី

ថែមទាំងខ្លួរៀបចំខាងការផ្សះផ្សាក្រុមពុទ្ធសាសនបណ្ឌិត្យ ៗ ដោយដំណើរកិច្ចការ
កម្ពុជវដ្ត; ពុទ្ធសាសនបណ្ឌិត្យនេះខ្ញុំកម្រនឹងខ្លួលចុះហត្ថលេខាខ្លះទៅ
លើលិខិតក្នុងកិច្ចការផ្សេង ។ ប៉ានជាសេចក្តីវិភាវរចិត្តខ្លាំងរបស់ខ្ញុំនេះ
គួរទុកជាធម្មានុរូបប៉ាន ហើយខ្ញុំសូមខ្លួលសារភាពដោយសេចក្តីអៀន
ខ្មាស ថាកិច្ចដែលផ្សះនេះប្រកបដោយសង្ឃឹកភាព គឺការៈច្របូកច្របល់
បន្តិច ។ ហេតុម្តេចប៉ានជាកិច្ចការទាំងនេះទើបនឹងខ្លួលអន្តរាត្តន៍ក្នុង
ពេលថ្ងៃនេះ, ក្នុងកាលបរិច្ឆេទដូចជាយឺតយូរបន្តិច ? ដោយមានទេស
កាលដែលច្បាស់ចាកពីឆន្ទៈរបស់យើង ព្រមទាំងការរៀបចំសម្ភារៈក្នុង
កិច្ចផ្សះអង្គការមួយ ដូចពុទ្ធសាសនបណ្ឌិត្យ ដែលមានសារៈប្រយោជន៍
ហើយត្រូវប្រើរយៈវេលាអស់យូរគាលជាសម្បើមអស្ចារ្យ នេះឯងជា
ហេតុនាំឲ្យបន្តយថ្ងៃផ្សះនោះរហូតមកដល់ពេលនេះ ។

តាមសេចក្តីពិត ទោះបីលិខិតជាផ្លូវការដែលសម្រេចនូវរបៀប
ប្រតិបត្តិការទើបនឹងចុះហត្ថលេខានៅថ្ងៃនេះ តែចំណែកខាងប្រទេស
ប៉ាងឯប៉ានព្រមព្រៀងភ្លាម នូវបែបបទជាវិធីប្រតិបត្តិតាំងពីមុនថ្ងៃចុះ
ហត្ថលេខា ក្នុងកិច្ចព្រមព្រៀងនោះ, ទាំងមុនសេចក្តីសម្រេចក្នុងសន្ធនា-
ការនូវកិច្ចព្រមព្រៀងនេះទៀត ។ តាំងពីលោកម៉ារទីន អគ្គលេខាធិការ
នៃក្រុមពុទ្ធសាសនបណ្ឌិត្យ ចាកចេញពីប្រទេសកម្ពុជានៅថ្ងៃ ២៧ ខែ
មុកាមុននេះ, លោកស្រី ប៊ូរ-ម៉ាស្សារ៉ូ, រួចតមក ខ្លួនខ្ញុំគ្រាន់តែជាអ្នក
ខ្លួលការៈខាងចាត់កិច្ចការសាមញ្ញប៉ុណ្ណោះ ។

វិធានការនេះ គឺមានជាប់តមក ក្រោយដែលបានប្រគល់សាលាបាលីជាន់ខ្ពស់ ពីថ្ងៃ ៣១ ខែធ្នូ ១៩៤៨, បញ្ជាក់ឲ្យឃើញនូវសេចក្តីខ្នះខ្នែងរបស់រដ្ឋាភិបាលបារាំង ដែលមានបំណងចង់ផ្តេរវិញ្ញាស្ថានទាំងពីរ ដែលជាមូលដ្ឋានពិតប្រាកដនៃវប្បធម៌ខ្មែរ ។

គេទុកជាយល់ឮស, បើមានគេយល់ថាកម្មវិកាតដែលនាំពុទ្ធសាសនបណ្ឌិត្យទៅកាន់វឌ្ឍនធម៌ជាប្តីនេះ គ្រាន់តែជាប្រតិបត្តិការត្រឹមរដ្ឋបាលមានការគេមនាគមន៍ខាងគ្រឿងសម្ភារៈ គឺបណ្ណាល័យមួយ មានសៀវភៅច្រើនល្មម សារមន្ទីរមួយជាបង្គរ, មានបុគ្គលិក, មន្ទីរព្រមទាំងគ្រឿងសង្ហារិមនឹងទីទុកឯកសារប៉ុណ្ណោះ ។ ទុកជាមិនបានយល់ជាក់ច្បាស់នូវកិច្ចការខាងផ្លូវប្រជាជ័ស្តុរុមដែលអង្គការនេះ បានបំពេញហើយនឹងសារៈប្រយោជន៍សំខាន់នៃចំណេះផ្សេងៗ ដែលបានអប់រំក្នុងវិញ្ញាស្ថាននេះ ។ ក្រុមដំនុំព្រះតែបដកនឹងក្រុមដំនុំទំនៀមទម្លាប់បានដំណើរកិច្ចការទាំងនេះ ផ្សាយទៅមិនសូវបានជ្រួតជ្រាបដល់ប្រជាជនគ្រប់ៗគ្នាទេ, តែបើតាមគោលការណ៍នៃវិញ្ញាស្ថានទាំងពីរ មានរបៀបពិតប្រាកដដូចវិញ្ញាស្ថានខាងមជ្ឈិមប្រទេស ។ សេចក្តីពន្យល់ខាងលើនេះ នៅមិនទាន់គ្រប់គ្រាន់បរិបូណ៌ល្មមបំភ្លឺនូវអត្ថន័យឲ្យបានពេញលក្ខណៈចំពោះពុទ្ធសាសនបណ្ឌិត្យ ដែលជាទីប្រជុំនៃច្បាប់ប្រពៃណីខាងផ្លូវប្រជាជនឹងប្រជាជាតិ ដែលគេទុកជាបដិមាតំណាងនាមនឹងរូបនៃ

ជាតិខ្មែរទាំងមូល ជាមូលដ្ឋាននៃសេចក្តីស្វាងរុងរឿងដែលកើតមកពីអចលនៈទ្រព្យ, ពីចិត្តាជាបឋម, ព្រមទាំងវប្បធម៌ដែលស្ថិតនៅដោយសេចក្តីស្មោះស្ម័គ្រតាមលទ្ធិបូរាណពីអតីតកាល ។

ពុទ្ធសាសនបណ្ឌិត្យបានស្ថាបនាឡើងពីឆ្នាំ ១៩៣០ ដោយបានប្រែក្លែងបណ្ណាល័យ ដែលមានព្រះរាជប្រកាស ១៩២១ ចាត់តាំងពីមុនមក ។ ពុទ្ធសាសនបណ្ឌិត្យនេះបានដំណើរការតមក ចំរើនរីកវឌ្ឍនាការតាមលំដាប់ គ្មានឧបសគ្គអ្វីមករាំងរាឡើយ ។ វិជ្ជាស្ថាននេះតែងរក្សាទូរទៅតិត្យានុភាព ដែលជាប់ទាក់ទងទៅនឹងលទ្ធិដែលល្បីល្បាញក្នុងសកលលោក ព្រមទាំងអភិបាលទុកនូវគ្រឹះតំណែលនៃស៊ីវិល័យពីសម័យបុរាណ តែមិនអាចជួបប្រទះនឹងគ្រោះថ្នាក់ ឬវិបត្តិផ្សេងៗ ដូចជាវិជ្ជាស្ថានឯទៀតដែលមានបំណងហួសមាឌ ឬមានសភាពប្លែកពីធម្មជាតិតែងធ្លាប់តប់ប្រមូរនោះឡើយ ។

ពុទ្ធសាសនបណ្ឌិត្យនេះកើតឡើងដោយ "ព្រះរាជបំណងនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូងនៃកម្ពុជរដ្ឋនឹងហួងឬបាបង" ដើម្បីនឹងបំពេញកិច្ចទៅតាមសេចក្តីត្រេកអរដ៏ជ្រាលជ្រៅនៃពួកពុទ្ធបរិស័ទ ។ វិជ្ជាស្ថាននេះ ស្ថាបនាឡើងដើម្បីជាចំនួយដល់សាលាចាស់ជាន់ខ្ពស់នឹងព្រះរាជបណ្ណាល័យ ។ វិជ្ជាស្ថាននេះមានឈ្មោះថា "វិជ្ជាស្ថានសម្រាប់ការសិក្សាខាងពុទ្ធសាសនាហីនយាន" ជានផ្សាយវត្តមគ្គភាពរហូតដល់ប្រទេសលាវកម្ពុជា

ត្រមាំង ក្រុមជនជាតិខ្មែរខាងប្រទេសកូស៊ីន ។ ដល់មក គ.ស. ១៩៣៣ ពុទ្ធសាសនបណ្ឌិត្យនេះត្រឡប់ទៅជាមាននាមថា "វិជ្ជាស្ថាន សម្រាប់ការសិក្សាខាងពុទ្ធសាសនា" ហើយមានបេសកកម្មត្រង់ការណែនាំត្រមាំង ប្រមូលនូវវត្ថុធាតុផ្សេងៗ ចំពោះការសិក្សាខាងព្រះពុទ្ធសាសនាហីនយាន ។ ដល់មក ខែកុម្ភៈ ១៩៤៣ វិជ្ជាស្ថាននេះប្រែនាមថា "ពុទ្ធសាសនបណ្ឌិត្យតំណាងចិន" ហើយបានទទួលព័ត៌មានពីព្រះពាជបណ្ណាល័យនូវអំណោយផ្សេងៗមានសៀវភៅជាច្រើនផ្នែកខាងវិទ្យាសាស្ត្រ ។ តាំងពីនោះមក, វិជ្ជាស្ថាននេះបានក្សាទុកនូវសៀវភៅផ្នែកខាងភាសាសាស្ត្រ (Philologie) សាសនា, ប្រវត្តិសាស្ត្រ, បុរាណវត្ថុវិទ្យាខាងបូព៌ាប្រទេស ហើយក៏បានចាត់ចែងបោះពុម្ពសៀវភៅ ក្នុងនាមនៃព្រះពាជបណ្ណាល័យនឹងសាលាបាលីជាន់ខ្ពស់ទុកដូចជារបស់ខ្លួន ។ គ្រោងការណ៍ដែលធ្វើនេះ នាំឲ្យវិជ្ជាស្ថានដែលមានសភាពទន់ខ្សោយនៅឡើយសម្រេចបានតាមបំណង ។ ឥឡូវនេះ, វិជ្ជាស្ថាននេះគេទុកជាអង្គការសេរីការបស់រដ្ឋសេរីការហើយ ជាស្ថានទីកម្មិកភាពនៃវប្បធម៌មានប្រយោជន៍ដ៏សំខាន់បំផុត ។ ពិតមែនតែមានវិបត្តិសម្ភារៈនឹងសីលធម៌ដែលសកលលោកទើបនឹងបានឆ្លងរួចមកហើយ, ដែលមានកំសួលកាលជាលមកដល់វិជ្ជាស្ថាននេះ តែការចម្រើនវ័យវឌ្ឍនាការក៏បានធ្វើដំណើរទៅតាមលំដាប់ឥតឈប់ឈរសោះឡើយ ។ ការបោះពុម្ពព្រះត្រៃបិដកជាស្នាដៃឯក

សម្បើមអស្ចារ្យ ដែលវិជ្ជាស្ថាននេះបានចាត់ឲ្យផ្ញើនផ្ញត់តាមច្បាប់ដើម ព្រមទាំងឲ្យបកប្រែនូវវិន័យព្រះពុទ្ធសាសនា ជាភាសាបាលីមានចំនួនសៀវភៅទាំងអស់ ១១០ ដែលអាត់ខានបោះយូរហើយ, ឥឡូវទើបនឹងរើបោះពុម្ពជាថ្មី នូវភាគ ៣៦ នឹង ៣៧ កងរយៈវេលាពីរបីឆ្នាំមុននេះ ។

រថយន្តបណ្ណាល័យដែលមាននាមថា រថយន្តកំសាន្ត ឬ វិស្រមៈ (Auto des loisirs) បាននាំប្រតិសព្ទកម្មិកភាពនៃពុទ្ធសាសនបណ្ឌិត្យ ដោយស្មោះស្ម័គ្រទៅផ្សាយទូទៅតាមភូមិ, ឥឡូវទុំៗត្រៃមគ្គាគ្រាលាយបាត់ទៅហើយ ។ ដោយហេតុមានទេសកាលដ៏លំបាកខ្លាំង រថយន្តនេះមិនអាចរកវថយន្តឯទៀតមកជំនួសបាន ហើយគួរឲ្យស្រយុតចិត្តពន់ពេកបើកាលណាគេយល់អំពីសារៈប្រយោជន៍សំខាន់ ដែលរថយន្តនេះបានធ្វើ ។ ត្រូវយើងទៅសង្កេតតាមវត្តអារាម ដែលស្ថិតនៅឆ្ងាយពីទីក្រុងដូចជាខ្ញុំបានធ្លាប់តបប្រសព្វម្តងមួយកាល, ដើម្បីនឹងត្រេកយកនូវអារម្មណ៍ដែលនាំឲ្យកើតសេចក្តីសង្វឹម ព្រមទាំងការគមនាគមន៍ពិតជាក់ជាងចិន្តាចំពោះរថយន្តនេះក្នុងកាលជាអនាគត ។

ខ្ញុំបានបង្ហាញនូវសេចក្តីលំបាកដែលក្រុមដំនុំព្រះវិត្តបិដកបានជួបប្រទះពីមុនមកក្នុងការបោះពុម្ពព្រះវិត្តបិដកនេះ តែសេចក្តីលំបាកទាំងនេះ មិនអាចជាឧបសគ្គកាំងកន់នូវសេចក្តីព្យាយាមសមាដិកនៃក្រុមដំនុំនេះដែលបានអប់រំទៅតាមវិន័យដ៏វិសេសវិសាលពន់ពេក ។

ចំណែកខាងក្រុមដំនុំទំនៀមទម្លាប់បានស្ថាបនាឡើងក្នុងរយៈពេលពីរ - បីឆ្នាំមុននេះ មកពីមានដើមគំនិតនិយមថៅតាមបូកណាគតិក្រុមដំនុំនេះ, ដោយមានលោកស្រី ប៉ូរេ - ម៉ាស្សីរ៉ូ ជាអ្នកញ៉ាំងកម្មិកភាព បានសម្រេចនូវស្នាដៃមួយនេះ ដែលគេកំណត់ទុកជាវិជ្ជាស្ថាននៃប្រជាជាតិពិពណ៌នា (ethnographie) ហើយបានរៀបចំនឹងរួបរួមនូវឯកសារផ្សេង ៗ ថៅតាមវិធីទំនើប ៗ ពីឆ្នាំមុន លោកស្រីបានប្រមូលឯកសារ ៣.៦០០ ច្បាប់ហើយបានយកថៅថតជាបន្ទាស់ក្រដាសកុនតូច ៗ (microfilmés) ហើយក្នុងឆ្នាំនេះបានថតឯកសារចំនួន ៤.០០០ ច្បាប់ថែមទៀត ។ ចំណែកខាងបណ្ណាល័យ, មានសៀវភៅប្រមាណ ១០.០០០ ក្បាល, ខ្លះបោះពុម្ព, ខ្លះសរសេរដៃ, ច្រើនជាសៀវភៅមានតម្លៃ ។

គីតយន្តដ្ឋាន (Discothèque) មានប្រមាណ ៣០០ ជាសកុដជាមធ្យោបាយដ៏ប្រសើរខាងការឃោសនា ។ តែគួរឲ្យអាណោចអាធ័មពន់ពេក, ដូចជាក្រុមដំនុំព្រះវិត្រៃបិដក, ក្រុមដំនុំទំនៀមទម្លាប់នឹងគីតយន្តដ្ឋាន ក៏បានទទួលនូវផលដ៏លំបាកនៃមហាសង្គ្រាមសកលលោកដែរ : លំបាកខាងដូរគ្នាមានគមន៍ដែលរាំងភមិនឲ្យរៀបចំនូវបណ្ណាល័យនោះឲ្យបានចំរើន, ដោយហេតុគ្មានបឋមវត្ថុជាតុ (matières premières)

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនចលំាត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក វ៉ាយ - ប៊ុក
ក្រមការ នៅពុទ្ធសាសនចលំាត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសត្ថា សួរ - ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនចលំាត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
ពុទ្ធសាសនចលំាត្យ	សេចក្តីដូនដំណាំ រៀងទស្សនាវដ្តី ១៩៥១ ...	៨០១
ហ្វូងទិពគ្គមន្ត្រី ញ៉ាក់ - ថៃម	ព្រះរាជក្រិត្យ ក្រមទសកវិយោ (តមក)	៨០៥
លោក វ៉ាយ - ប៊ុក ក្រមការ	ទវិទ្ធហត្ថៈគង្វ (តទៅ)	៨១៥
— —	ប្រវត្តិសាស្ត្រនៃស៊ីវិល្យខ្មែរក្រោមណ (តមក)	៨២០
លោក ម៉ុញ - តាំត្រី	ស័ព្ទដាំងប្រៃជាខ្មែរ (តទៅ)	៨២៥
លោកសាង - សាភ័ត លេខាធិការ	រឿងព្រែនភូមា (តមក)	៨២៩
អ្នកទេកញ៉ាំវិបុលរាជសេនា ឌួ - កន	រឿងសាមកុក (តមក)	៨៣៤
— ទេពពិទូរ ឈឹម - ក្រែសេម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	៨៤១
លោកផែង - ដ្រែ	ប្រវត្តិរបស់អេសុប (តមក)	៨៤៦
ផ្នែកសាសនា		
លោក វ៉ាយ - ប៊ុក ក្រមការ	ពន្ធអាស៊ីទ្ធ៍ប (តមក)	៨៥០
ឃុនបណ្ណាធុរក្ស ប៊ូ - ប៊ី	កំប្លាំងនៃពាក្យចុះញ្ជង់	៨៥៦
ព្រះគ្រូសាសនវង្ស គុយ - សូត្រ	សាសនចលំាតដាតាក (រឿងសត្វចាំស៊ីល)	៨៦៣
កំណាត់ទីផ្សារប្រវត្តិការណ៍		
ពុទ្ធសាសនចលំាត្យ	ពិធីផ្ទេរពុទ្ធសាសនចលំាត្យ ជូនមកពាក់ព័ន្ធកិច្ច-បាលខ្មែរ	៨៧៦

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Institut Bouddhique	Annonce de la Revue Kambujà Suriyà 1951	801
Luong Nibandhamatri Nhok-Thèm	Edit royal : Kramadasabhariyà (suite et fin)	805
M. Ray-Buc Kromokar —id—	Paroles de Gandhi (suite)	815
	Histoire de l'ancienne civilisation Khmère (suite)	820
M. Menh-Nakry ancien député	Recueil dès mots traduits par la Commission Culturelle (suite)	825
M. Sang-Savath, Secrétaire au Ministère des Finances	Contes birmans, (suite)	829
Neak Okna Vibularaja-séna Nou-Kân	Histoire de SAMKOK (suite)	834
Neak Okna Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite)	841
M. Pheng Chrieu, professeur au Collège des Jeunes Filles	Biographie d'Esope (suite)	846

Partie religieuse :

M. Ray-Buc Kromokar Khun Pannanuraksa Bou-Po	La lumière de l'Asie (suite)	851
Preah Krou Sasanavongsa Kuy-Saut	Les effets de la calomnie	856
	Sasapanditajataka	863

Notes et Chroniques

Institut Bouddhique	Cérémonies de transfert de l'Institut Bouddhique au Gouvernement Royal.	872

សេចក្តីផ្តួចផ្តើម

អំពីពុទ្ធសាសនបណ្ឌិត្យ

រឿងទស្សនាវដ្តី ភក្តីសុរិយា

សូមជំរាបជូនដំណឹងដល់បងប្អូនរួមជាតិទាំងឡាយ !

ទស្សនាវដ្តីភក្តីសុរិយា ឆ្នាំ ១៩៥០ នេះ អស់លោកអ្នកបានចុះឈ្មោះជាវ មានចំនួនច្រើនជាងឆ្នាំមុនៗ ។ ពុទ្ធសាសនបណ្ឌិត្យបានយល់ឃើញជាក់ស្តែងថា អស់លោក-អ្នកស្រឡាញ់អក្សរសាស្ត្រ-ទាំងខុបត្តម្ភអក្សរសាស្ត្របស់ជាតិ ឲ្យលូតលាស់ចំរើនឡើងដោយពិតៗ ។ កិច្ចដែលបងប្អូនរួមជាតិស្ម័គ្រចុះឈ្មោះជាវច្រើនឡើងៗ នេះ ឈ្មោះថាឲ្យកម្ងាន់ដល់ពួកអ្នកនិពន្ធក្នុងក្រុមយើង ឲ្យទំនងរៀបរៀងនូវរឿងរ៉ាវថ្មីកៗ ដែលមានសារប្រយោជន៍ច្រើន ទាំងទំរៀបចំរបៀបពាក្យពេចន៍ឲ្យរឹងរឹតតែពីរោះចាប់ចិត្តជាកំរៃក្លាភាពឡើង ។ យើងមានសង្ឃឹមថាអស់លោក-អ្នក មុខជានឹងចុះឈ្មោះជាវទស្សនាវដ្តីភក្តីសុរិយា ក្នុងឆ្នាំ ១៩៥១ តទៅទៀត ហើយនឹងជួយផ្សាយដំណឹងអំពីប្រយោជន៍នៃទស្សនាវដ្តីយើង តៗទៅដល់បងប្អូនរួមជាតិដែលនៅដិតខាងជាពុំខាន ។

ឯរឿងរ៉ាវ ទាំងផ្នែកអក្សរសាស្ត្រទាំងផ្នែកសាសនា ដែលយើងយល់ឃើញថាមានប្រយោជន៍សំខាន់ដល់បងប្អូនរួមជាតិ ហើយបានគ្រោងទុកបំរុងនឹងចុះពុម្ពក្នុងឆ្នាំ ១៩៥១ ដូចមានកាយមាតិកាតទៅនេះ ៖

ផ្នែកអក្សរសាស្ត្រ៖

១ – អក្សរសាស្ត្រខ្មែរ (គោលចារិកទាំងផ្នែកអក្សរសាស្ត្រ ព្រមទាំងពាក្យកាព្យឃ្លោងចាស់ៗ ឬទំនើបថ្មី) ។

២ – ព្រះពុទ្ធសាសនាប្រទេសកម្ពុជា នៅមានចោះពុម្ពតទៅទៀត ។

៣– ឯកសារ (រឿងព័រសំខាន់ៗ ដូចសិលាចារិកជាដើម) ។

៤ – រឿងសាមកុក នៅតែចោះពុម្ពតទៅទៀត គ្រាតែចប់ ។

៥ – វប្បធម៌(ពាក្យឃ្លាពាំនៃប្រែជាខ្មែរបស់គណៈកម្មការវប្បធម៌)។

៦ – សុភាសិតផ្សេងៗ របស់ជាតិយើងនិងនានាជាតិ ។

៧ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៨ – ទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ ។ល។

ផ្នែកសាសនា៖

១ – ដំណឹងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ។

២ – ធម្មទេសនា ដែលមានអត្ថរសច្រើនៗ ។

៣ – សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ – ទឹងជ្រៅរបៀងក្នុងព្រះសូត្រខ្លះ ដែលជាផ្លូវប្រតិបត្តិ ។

ប្រយោជន៍នៃទស្សនាវដ្តីកម្ពុជសុរិយា

បងប្អូនរួមជាតិទាំងឡាយជ្រាបស្រាប់ហើយថា ទស្សនាវដ្តីនឹងសារពត៌មាន ក្នុងប្រទេសយើង មានមិនលើសពី ២-៣ ឈ្មោះ

ប៉ុណ្ណោះ ។ ចំនួននេះបើយកទៅធៀបនឹងចំនួនទស្សនាវដ្តី សារពត៌មាន ក្នុងប្រទេសគេជិតខាងប្រទេសយើង ឃើញថាខាងយើងតិចជាងគេឆ្ងាយណាស់ ស្ទើរតែកប់ថាមាននឹងគេពុំបាន ។ ខាងយើងដែលមានបញ្ហាបកវណ៌ពាំងនេះតិច មកពីយើងខ្វែងអក្ខរាំគ្រាមានមានចំនួនតិចនាក់; ខាងគេដែលមានបញ្ហាបកវណ៌ច្រើន មកពីជាតិគេមានអក្ខរាចូលចិត្តអានច្រើន ។ បញ្ហាដែលជាផលកើតមកអំពីការអានច្រើននឹងការអានតិចតែងអនុវត្តទៅតាមគ្នា គឺបើក្នុងប្រទេសណា មានអ្នកអានច្រើននាក់ក្នុងប្រទេសនោះ អ្នកចេះដឹងក៏មានច្រើន; បើអ្នកអានមានតិច អ្នកចេះក៏មានតិច ។ ចំពោះរូបមនុស្សម្នាក់ៗ ក៏មានន័យដូចគ្នា គឺអ្នកណាអានច្រើន អ្នកនោះចេះដឹងច្រើន, អ្នកអានតិច ចេះដឹងតិច, អ្នកមិនអានសោះ ក៏មិនចេះសោះ សមដូចបុរាណសុភាសិតថា "បើអានតិចច្រើន នឹងចំរើនសព្វថ្ងៃទៅ ដូចឃ្មុំដប់ទឹកនៅ ផ្ការឈើគ្រែកគួមិថាន" ។ ព្រោះថាទស្សនាវដ្តី សារពត៌មាន ជាឃ្លាំងវិជ្ជា មានមុខការខាងបណ្តុះជាំផ្សាំប្រជាជនៃអ្នកអានឲ្យដើរទាន់សម័យ ។

មែនពិត ទស្សនាវដ្តីយើងហើយនឹងអ្នកអាន ឈ្មោះថាឲ្យកម្ចាំងផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក ។ តាមន័យនេះ ឃើញថាបងប្អូនរួមជាតិដែលចេញសោហ៊ុយដារទស្សនាវដ្តីយើង ប្រាន់ផលជា ៣ ចំណែក គឺ:

១ - ជួយទស្សនាវដ្តីយើងឲ្យមានអាយុស្ថិតនៅយូរអង្វែង

២ - កាលអស់លោក - អ្នកបានអានហើយ នឹងកើតមានជ្រាប់ក្នុងស្មារតីក្នុងផ្លូវលោកផ្លូវធម៌

៣ - ផលជាកំពូល គឺអស់លោក - អ្នកនឹងមានភ្នែកឈ្លោះថាជាអ្នកចាក់ទឹកស្រោចដីឲ្យអក្សរសាស្ត្រខ្មែរយើង ដុះលូតលាស់ចំរើនជាន់កាលសម័យ ឲ្យមានទឹកមុខស្មើនឹងអក្សរសាស្ត្រនានាជាតិ ។

ហេតុនេះ សូមអស់លោក - អ្នកដែលមានបំណងជាវទស្សនាវដ្តីយើងប្រចាំឆ្នាំ ១៩៥១ សូមផ្ញើឈ្មោះប្រុនាមទីលំនៅនឹងប្រាក់ចំនួន ១៤៥ រៀល ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ កុំពេញ ក្នុងពេលឆាប់ៗ ។

ពុទ្ធសាសនបណ្ឌិត្យ កុំពេញ

Adress :

M. le S crétaire Général
de l'Institut Bouddhique
à Phnom-Penh

ព្រះរាជក្រិត្យ

ក្រមទេសរាំយ៉ា

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះដ័យចេស្តា (ចៅ ញាសូ) ព.ស. ១៦៩៣

ហ្លួងធិពន្ធមន្ត្រី ញ៉ាក-បៃម រួបរួម

(ត-ចប់)

បើនាំម្រែត់ទៅដល់ម្តាយអាពុកបង់ប្អូនសាច់ញាតិអាប្រុសនោះហើយ បើម្តាយអាពុកបង់ប្អូនសាច់ញាតិចង់ដៃកូនគេផ្សំនឹងកូនឯងនោះ. ត្រូវម្តាយអាពុកបង់ប្អូនសាច់ញាតិ (ពិន័យ) អង្គពហូស័ក្តិដីង ៣ តម្លឹង ១៧ ពិន័យអាប្រុសនាំរត់នោះជាច់សុរិលហោង ។ ឲ្យខុនហូតយកខ្នាត់តម្លឹង ៣ នីមួយខ្លួន ខ្នាត់ព្រះឃ្លាំងពុះគ្រឹងនីមួយខ្លួនហោង ។ បើម្រែត់កូនគេខ្ញុំគេ ហើយបើកូនគេខ្ញុំគេ.ហ្លាប់នៅព្រៃ ពុំបានដល់ស្រុកដល់ភូមិនោះឲ្យពិន័យតែអាប្រុសនោះជាច់សុរិលហោង ។ ព្រះឃ្លាំងពុះគ្រឹងហូតខ្នាត់ខុនភ្នាក់ងារតម្លឹង ៣ បើម្រែត់ទៅដល់ស្លាប់នៅផ្ទះនៅភូមិនៅស្រុកគេនោះឲ្យពិន័យអាប្រុសដ៏នាំម្រែត់តម្លឹង ៣០ ឯអ្នកបង្កាត់បន្សាំ តម្លឹង ១៩ តាមប្រការហោង ។

មាត្រា ១ សោត បើអ្នកនង់ចាប់ប្រពន្ធគេតាំងអំណាច (ដោយស្នាន) ថាជាកូនក្រមុំនោះ ត្រូវក្រយ៉ាពិន័យដីង ៣ តម្លឹង ១៧ ។ បើចាប់កូនក្រមុំគេខ្ញុំគេនោះ យកស័ក្តិមេបាអម្ចាស់មកពិនិយ. បើស័ក្តិ

ប្រុសនោះច្រើនឲ្យយកទំនិញខ្លួនឯង ឲ្យហួតខ្លាត់ព្រះឃ្លាំងពុះគ្រឹងជាក់ថ្លាយ ខ្លាត់ខុនក្នាក់ងារតម្លឹង ៣ ។ បើម្រែត់កូនគេចៅគេខ្ញុំគេ បើម្តាយអាពុកអម្ចាស់ស្រីនោះពុំចឹងទេ ឲ្យប្រុសនោះទៅសំពះហើយយកខាន់ស្លាតិចក្តី ច្រែន (ក្តី) នោះសឹងយកខ្លាត់ព្រះឃ្លាំងបែងអំពីកងខាន់ស្លានោះឯង ។ បើម្តាយអាពុកម្ចាស់ ពុំលក់ពុំយកខាន់ស្លាអំពីប្រុសនោះទេ្លយ សឹងកាប់អានទៅវិញទៅមកនោះ ឲ្យហួត (ខ្លាត់) ព្រះឃ្លាំងអំពីប្រុសតម្លឹង ៥ ឲ្យយកអំពីស្រី ៤ ខុនក្នាក់ងារយកខ្លាត់អំពីប្រុសបាទ ១០ យកអំពីស្រីបាទ ៦ ខ្លះដងកោះស្មើ ១០ ទីមួយខ្លួនហោង ។

មាត្រា ១ សោត បើសេចក្តីខ្ញុំគេម្រែត់ បើអ្នកផងបង្កាត់បន្ទាំឲ្យគ្រឹង ... ឲ្យបាយម្ហូបឲ្យអង្គរស្បៀង ស្លាម្ហូទឹកផឹកក្តី ដណ្តើមទៀងសម្បជ្ញផងគ្នាក្តីនោះតួខ្ញុំកុំដរ គោក្របីដំរីសេះក្តី បើចម្ងន់ទឹងខ្លួនទឹងក្បួន ទឹងក្របី មានគេជួលម្រែត់អំពីម្ចាស់នោះក្តី ឲ្យខុនក្នាក់ងារយកខ្លាត់ព្រះឃ្លាំងជាដង្វាយ តាមច្បាប់ខុនក្នាក់ងារ តម្លឹង ៣ បាទ ៦ កំបាន តាមតិចច្រែន ។ បើកូនគេ ចៅគេ ខ្លួកគ្មានខ្លួបំពេស ខ្លួខ្ញុំគេយកមកលក់នោះ ខុនក្នាក់ងារហួតយកខ្លាត់តម្លឹង ៣ កំបាន បាទ ៦ កំបាន តាមតិចច្រែនហោង ។

មាត្រា ១ សោត បើអ្នកផងអ្នកជាខ្ញុំគេក្តី បើប្រែកែកប្រាក់យប្រែឈ្មោះគ្នាជាលក់តប់ខ្ញុំក្រែទៅ ចាប់ក្បាលចាប់ដៃគាញសក់ជាយខ្នើងដំបងបែក

ជាំជាម ឲ្យពិន័យតម្លឹង ១២ ហូតយកខ្ចាត់ព្រះឃ្លាំងតម្លឹង ៦ ខុនក្នាក់ងារ ហូតយកខ្ចាត់តម្លឹង ៣ ដើងកោះស្លឹង ១០ ន័មួយគួរហោង ។ បើក្រយា ពិន័យតម្លឹង ៩ តម្លឹង ៤ តម្លឹង ៣ ជា ១ ៦ ខ្ចាត់ដំនុំបានមកខុនក្នាក់ងារ ទុកញ៉ាសុភាទេពបតីនៅស្រុកគ្រៅ បើក្រយាពិន័យតម្លឹង ១៩ ឲ្យបែង ជាភាគ ៣ ភាគ ១ ព្រះឃ្លាំង ភាគ ២ ឲ្យខុនក្នាក់ងារនូវចៅហ្វាយស្រុក ហូតចែកតាមព្រះច្បាប់ ។ បើពិន័យដើង ១ ហូតយក (ខ្ចាត់) តម្លឹង ៨ ជាព្រះឃ្លាំង បើក្រយាពិន័យ ... [1] ៣០ ឲ្យខុនក្នាក់ងារហូតតម្លឹង ៣ នូវសំណាលដើងតម្លាច់ដែសរួចហើយ ឲ្យពុះគ្រឹងជាព្រះឃ្លាំងថ្វាយ ។ បើក្រយាពិន័យដើង ២ ដើង ៣ ដើង ៤ ជាងពីនោះក្តី សឹងហូតយកព្រះឃ្លាំងពុះគ្រឹងហោង ខ្ចាត់ខុនក្នាក់ងារតម្លឹង ៦ ហោង ។

មាត្រា ១ សោត បើអ្នកផងមានគេចាញ់ចាក់កាប់ស្លាប់ក្តី របួសក្តី ពិការក្តី បើមានគេចាញ់សត្វស្រុកដើង ៤ ដើង ២ ក្តី សត្វត្រូវអង្គាក់ក្តី ត្រូវអង្គប់ខ្លាក្តី បើចាក់ទឹងគាំចិតចោះគ្នាទឹងលំពែងក្តី មនុស្សក្តី សត្វដើង ៤ ក្តី ដើង ២ ក្តី បើមានគេវាយចោលចោះទឹងតំបងឫស្សី ឈើដឹង ផ្តៅ ពកខ្លៃនោះ ឲ្យខុនក្នាក់ងារហូតយកព្រះឃ្លាំងពុះគ្រឹងជាដង្វាយ ខ្ចាត់ខុនក្នាក់ងារ តម្លឹង ៣ ដើងកោះស្លឹង ១០ ហោង ។

---

១ ត្រង់ណេះដូចជាយ៉ាងណា ? មាត់ តម្លឹងឬដើង ? តែតាមទំនងសេចក្តីខេះគួរបំពេញ ជាតម្លឹង ៣០ ?

មាត្រា ១ (សោត) គោរសេចក្តីផ្ញើទ្រព្យរបស់ សេចក្តីថាស់បង់ប្អូនអ្នកធំអ្នកតូចក្តី សេចក្តីអ្នកដង៏ខុសនឹងអ្នកធំនឹងអ្នកតូចនឹងដំណាវ នាងខុនណាង នឹងទុកញ៉ា ព្រះ ហ្នឹង ដី ថៅក្តី សេចក្តីសារពើរកេយប់ថ្ងៃក្តី អ្នកដង៏ដើរខាងរបងគេបាត់របស់គេក្តី សេចក្តីស្រមែគ្នា ១ សេចក្តីក្លាល់គ្នា ១ សេចក្តីសើសទ្រព្យគេ ១ សេចក្តីប្រឡង់គ្នា ១ សេចក្តីតិះដៀលគ្នា ១ សេចក្តីថាគេជាប់ដំពូកជាអាយ័តជាជន៏ពារ ១ សេចក្តីពាំងនេះបើគេមកប្តឹង៏ថៅហ្វាយស្រុក ភ្នាក់ងារស្រុក ពាំងអម្បាលណោះឲ្យថៅហ្វាយស្រុក នូវខុនភ្នាក់ងារ នូវថៅពញាធម្មាពិភ័ក្តិដំនុំពិចារណា បើឯណាពុំត្រមចូលចិត្តនៅឡើយ ឲ្យថៅហ្វាយ (ស្រុក) ឲ្យដំណើរថៅក្តីពាំងសង៏ខាង នូវកំណត់ពាក្យមកដៃថៅធម្មាពិភ័ក្តិ នាំចូលទៅដល់ឲ្យទុកញ៉ាសុកាធិបតី សុតាមន្តិ៏ ដំនុំពិចារណាតាមព្រះច្បាប់ ។

មាត្រា ១ សោត បើប្រុសលែង៏ស្រី ឲ្យហូតខ្នាត់តម្លឹង ៣ ដើង គោរសូវ៏ ១០ ន័មួយខ្នុន ។ បើស្រីពុំលែង៏ឡើយ ឲ្យចែករបស់សម្បជ្ជស្មើគ្នាហោង ។ លាង៏ខ្នាសឫទ្ធ ៦ ហោង ។

មាត្រា ១ (សោត) បើស្រីផង គោរប្តីស្លាប់មុនពុំទាន់លើកខ្នោចទៅឡើយ ល្អីកតែនាង៏នោរទៅមានអន្ធករមានប្តីពុំទាន់លើកខ្នោច ពុំទាន់បញ្ចុះធាតុទៅឡើយ នោរព្រះកែត្យដីកាឲ្យពិន័យពេញបណ្តាស័ក្តិ ដូចប្តីទៅរស់ធ្វើទោសតាមច្បាប់ ឲ្យខុនភ្នាក់ងារហូតយកខ្នាត់តម្លឹង ៦ ហូតយក

(ខ្វាត់) ព្រះឃ្លាំងពុះគ្រឹង ឯទ្រព្យរបស់វិបជាដង្វាយអស់ហោង នេះ ហៅកន្ទុងខ្ចប់ ។ ១ សោត បើប្តីស្លាប់មុនពុំទាន់បញ្ចុះធាតុ នាំធាតុប្តី ទៅផ្ទើនៅវត្តអ្នកព្រះសង្ឃក្តី នៅផៃព្រក្តី ព្រះត្រៃត្សដីកាឲ្យពិន័យទាំងស្រី ទាំងប្រុសពេញបណ្តាស័ក្តិ ដូចប្តីនៅរស់ ឲ្យប្រាណីទឹកដោះតម្ងឹង ៤ យកខ្វាត់ព្រះឃ្លាំងពុះគ្រឹង ខ្វាត់ខុនក្នាក់ងារតម្ងឹង ៨ ឯទ្រព្យរបស់ជា ដង្វាយអស់ហោងនេះហៅកន្ទុងធាតុហោង ។ បើបញ្ចុះធាតុរួចហើយ ពុំចាំរក្សាខុនក្តីដល់កម្ងឹងវែ ៨ ឡើយ ល្អឹកបើនាងនោះទៅមានអន្ទកមានប្តីនោះឲ្យខុនក្នាក់ងារអូសអស់ទ្រព្យរបស់ ខ្ញុំ គោ ក្របី ជាដង្វាយ អស់ហោង ។

មាត្រា ១ (សោត) ទោះខ្ញុំគេនឹងខ្ញុំគេលួចប្រពន្ធគ្នា ឲ្យពិន័យ ជាទ ៦ នីមួយគូ ដើងកោះជាទ ៩ នីមួយគូហោង ។

មាត្រា ១ (សោត) ទោះខ្ញុំគេនឹងខ្ញុំគេយកគ្នាហើយលែង (គ្នា) វិញ ឲ្យខុនក្នាក់ងារហូតខ្វាត់ស្ងឹង ៦ នីមួយគូ នូវដើងកោះជាទ ៩ នីមួយ គូហោង ។

មាត្រា ១ (សោត) បើខ្ញុំគេនឹងអ្នកជាយកគ្នាហើយលែង (គ្នា) វិញ ឲ្យហូតយកខ្វាត់នូវដើងកោះតាមដោយនូវខ្ញុំគេ នូវអ្នកជានោះឯង ចៅហ្វាយស្រុក នឹងហូតយកខ្វាត់ ១៩ ស្ងឹងយកស្ងឹង ១ ហោង ។ ១ សោត សារតើសេចក្តីត្រូវមុខងារទេកញ៉ាសុកាធិបតី បើមានគេប្តឹង

ចៅហ្វាយស្រុកហូតខ្ចាត់ស្រុក ១០ យក ២ បើខុនក្នាក់ងារប្តឹងចៅហ្វាយស្រុក ហូតខ្ចាត់ ១០ យក ១ ហោង ។

មាត្រា ១ (សោត) ចៅហ្វាយខូវក្នាក់ងារប្តឹងប្រកោះមកហើយផ្សំផ្គុំប្រមូលពាំងស្រែពាំងប្រុសយកគ្នាវិញ ឲ្យខុនក្នាក់ងារយកតែខ្ចាត់ស្មឹង ៦ ខូវដើងកោះស្មឹង ១០ ទីមួយតួហោង ។

មាត្រា ១ (សោត) បើប្តីប្រពន្ធបានគ្រាបសំពះម្តាយអាពុកហើយឥតគោស បើប្រលែងលែងគ្នា ឲ្យខុនក្នាក់ងារហូតខ្ចាត់តម្ងឹង ៣ ទីមួយតួ ខូវដើងកោះស្មឹង ១០ ទីមួយតួហោង ។ បើប្រពន្ធបានផឹកកំណាត់ហើយឥតគោសលែងគ្នា ឲ្យខុនក្នាក់ងារយកខ្ចាត់បាទ ៦ ទីមួយតួ ដើងកោះស្មឹង ១០ ទីមួយតួហោង ។ បើប្រុសចង់លែង ស្រីពុំចង់លែង ឲ្យចែករបស់ស្មើគ្នា ហូតខ្ចាត់ ១០ យក ១ ។ បើស្រីចង់លែង ប្រុសពុំចង់លែង ឲ្យចែករបស់ (ទ្រព្យ) បានប្រុសភាគ ៣ ស្រីភាគ ១ ។ បើលែងស្មើគ្នា ឲ្យចែករបស់ជាភាគ ៣ ភាគ ២ បានប្រុស ភាគ ១ បានស្រីហោង ខុនក្នាក់ងារ ១០ ហូតយក ១ ហោង ។ បើប្រពន្ធជណ្តើងស៊ីស្វាសង្គត់ហិបភៅហើយ ឥតគោសលែងគ្នា ឲ្យខុនក្នាក់ងារយកខ្ចាត់តម្ងឹង ៣ ទីមួយតួ ដើងកោះស្មឹង ១០ ទីមួយតួហោង ។ បើជាស្នេហ៍អន្ធកនើងគ្នា ហើយបានសំពះខ្មោចមេបាហើយ ឥតគោសលែងគ្នាវិញ ឲ្យខុនក្នាក់ងារហូតយកខ្ចាត់បាទ ៦ ខូវដើងកោះស្មឹង ១០ ទីមួយតួហោង ។

មាត្រា ១ (សោត) ពោះស្រីផងខុសកាចនឹងប្តីគេហើយ ប្រពន្ធគេដឹងហើយគេដណ្តឹង (សួរ) បើថ្កាប់គេដោយពិត ថាខុសកាចនឹងប្តីគេមែនហើយ ឲ្យស្រីនោះអណ្តាប់ស្រោដបស្មាម្ខាង ១ មកសំពះស្មាលោសនឹងប្រពន្ធគេសះឥតលោសឡើយ ។ ពោះខុសកាចនឹងប្តី (គេ) ហើយអាចចង់ចិត្តឈ្មោះប្រកែកសាហាវនឹងប្រពន្ធគេ ថាខ្លួនឯងពុំខុសឡើយ ល្អឹតបើរកទៅឃើញយល់ថាខុសកាចមែននោះ ឲ្យដំស្រីនោះនឹងព្រ័ត្រកណ្តាលផ្សារ ហើយឲ្យហែកសំពត់ធ្លាប់ ៤ ឲ្យស្ងៀក ហើយយកដាលក្បែកក្រួចច្រកក្បាលដល់ផ្ងួលស្មាមុខ ហើយដំឡើងដើងរនោល បើនឹងលោះខ្លួនដាច្រាក់តាមដោយព្រះច្បាប់ ជាចោរលួចប្តីគេនោះហោង ។ ឲ្យខុនក្នាក់ងារហួត (ខ្នាត់) តម្លឹង ៦ ខ្នាត់ព្រះឃ្លាំងពុះគ្រឹងហោង ។ ១ សោត បើប្រពន្ធស្លាប់មុនប្តី ហើយប្តីនោះពុំទាន់បានលើកខ្នោចប៉ាច់ភ្លុះជាតុប្រពន្ធនោះឡើយ បើទៅមានអន្ធករយកប្រពន្ធទៀតឥតសប្បុរសឥតធម៌ ឲ្យខុនក្នាក់ងារហួតខ្នាត់តម្លឹង ៣ ទូវដើងកោះស្លឹង ១០ អំពីប្រុសនោះហោង ។

មាត្រា ១ (សោត) ពោះទៅលួចខ្ញុំគេ (យក) ទៅលក់ មានអ្នកដទៃគេទៅលោះបង្វែងទៅអំពីម្ចាស់ខ្ញុំនោះ បើដណ្តឹងខ្ញុំនោះឃើញថាឥតស្គាល់ថាជាម្ចាស់ឥ ឲ្យប្តឹងចៅក្រមព្រះសូកាឲ្យពិចារណាបានគួម្ចាស់ឯគ្រោយ ។ បើចាប់បានគួចោរដែលលួចទៅលក់នោះ ឲ្យពិន័យ ១ ជា ២

កុំប្រាណីឡើយ ឯខុនក្ដាក់ងារហូតខ្ញាត់តម្លឹង ៣ ដើងកោះស្លឹង ១០ ខ្ញាត់ ព្រះយ៉ាំងតម្លឹង ៦ ជាទ ១ ហោង ។

មាត្រា ១ (សោត) គោះចៅក្រមផងដំនុំសេចក្ដីផងតាំងពួង គោះនឹងប្រកាន់ចាប់ន្នោតក្ដី គោះឲ្យដណ្ដឹងបន្ទាល់ក្ដី គោះឲ្យដណ្ដឹងនឹងសត្យាប្រណិធានក្ដី នឹងឲ្យស្បថក្ដី បើសរសេរខ្លួតលើកទឹកក្អមអង្គរសៀនខៀនប្រាក់មកហើយ ចៅម្ខាងប្រែពាក្យធ្វើយថា តុំចូលតុំទទួលន្នោតក្ដី នោះយកអង្គរសៀនខៀនទូវសត្យាប្រណិធានមកហើយ បើអ្នកក្ដីម្ខាង។ ប្រែធ្វើយថា តុំចូលតុំទទួលស្បថក្ដី គោះនឹងយកបន្ទាល់ឲ្យដណ្ដឹងបន្ទាល់ក្ដី នឹងឲ្យស្បថប្រណិធានក្ដី នឹងឲ្យដណ្ដឹងទទេក្ដី បើយកសត្យាប្រណិធានទូវអង្គរសៀនខៀន ទូវអ្នកបន្ទាល់មកហើយ ឯអ្នកក្ដីម្ខាង។ ប្រែធ្វើយថាតុំទទួល តុំចូលចិត្ត តុំទទួលដណ្ដឹងវិញ នោះឲ្យចៅក្រមទុកសេចក្ដីថាចាញ់ឲ្យពិន័យតាមច្បាប់ហោង ។

មាត្រា ១ (សោត) គោះប្ដីប្រពន្ធឈ្លោះគ្នា បើប្ដីដំប្រពន្ធរត់ចៅចង្កសា្ទប់ បើរត់ចៅប្រាកដពិតឥតគោសប្រុសនោះឡើយ ឲ្យខុនក្ដាក់ងារហូតយកខ្ញាត់ដើមឈើជាទ ៦ ដើងកោះស្លឹង ១០ អំពីប្ដីបងប្អូនអ្នកនៅរស់ផ្ទះជាមួយហោង ។ បើប្រុសចៅចង្កសា្ទប់ ឲ្យហូតខ្ញាត់តម្លឹង ៣ ទូវដើងកោះស្លឹង ១០ អំពីប្រពន្ធបងប្អូនដែលរស់នៅ បើឥតគោស ។

មាត្រា ១ (សោត) គោះប្រពន្ធដំប្តី ឈ្មោះនឹងប្តីវិញ ព្រះក្រឹត្យដីកាឲ្យដំប្រពន្ធនោះ ១០០រំពាត់ បើលៀរំពាត់ ១ ជាប្រាក់បាន ១ ឲ្យគ្រប់រំពាត់ចាំងអស់ ឲ្យខុនក្នាក់ងារ (ហ្លួត) យកខ្លាត់តម្លឹង ៣ ខ្លូវដើងកោះស្លឹង ១០ ខ្លាត់ព្រះឃ្លាំងពុះគ្រឹងហោង ។


មាត្រា ១ (សោត) បើសេចក្តីអាជ្ញានាំព្រះបន្ទូលខ្លូវសំបុត្រចេញចូលទៅ គោះអាជ្ញាខុសនឹងអ្នកស្រុក (?) ខុសនឹងអាជ្ញាក្តី ដណ្តើមខ្ញុំខ្លូវរបស់សម្បជ្ជផងគ្នា សេចក្តីចែកផ្នែកមេផ្នែកបាក្តី គោះសេចក្តីប៉ាគ្នាជាខ្ញុំជាដំពូក ជាបំពេស ជាអាយ័តក្តី សេចក្តីថាយកសារពីគុណអំពីគ្នាក្តី បើរើសខ្យរបស់គេក្តី ដំពាក់អ្វីៗ គ្នាក្តី សេចក្តីសង្រ្កោះលោះញាតិក្តី សេចក្តីផ្តាច់អាយាត់បំពេសក្តី សេចក្តីយកខ្លួនទៅបញ្ចាំខ្យរគេ យកកំឡាំងខ្យរគេទាំងអម្បាលណោះ ឲ្យខុនក្នាក់ងារយកខ្លាត់ក្រយាពិន័យតិចច្រើននោះហោង ។ បើបានជាខ្លាត់ព្រះឃ្លាំងឲ្យបែងជាភាគ ៣ ភាគ ១ បានចៅហ្វាយស្រុក ភាគ ២ បានទុកញាសុភាខេពបតិ ។ សេចក្តីរឹបជាន់សារពើខ្យរគេ ១ សេចក្តីញាតិអាស្រ័យរកគ្នាឡើងចុងដូងចុងគ្នោតឡើងសារពើរណើផង គោះធ្លាក់ស្ងាប់ក្តី គោះរបួសពិការក្តី ១ គោះសេចក្តីត្រូវខ្មោចមេបានឹងឲ្យប្រុសសំពះខ្មោច ១ សេចក្តីចូលខ្ទិស ១ ចូលត្រណមហើយដម្លាត់ស្ងាប់ ១ សោតឲ្យចែករបស់សម្បជ្ជជាភាគ ៤ ភាគ ១ បានស្រី ភាគ ៣ បានប្រុស ។

បើស្រីចង់លែងប្រុស។ តុំចង់លែងស្រីឡើយ បើប្រុសចង់លែងស្រី។ តុំចង់លែងប្រុសឡើយ ឲ្យចែករបស់សម្ប័ដ្ឋជា ២ ភាគ ភាគ១ ឲ្យនប្រុស ភាគ១ ឲ្យនស្រី ។ ឯច្បាប់ឲ្យព្រះសុកាតិចារណាកគោសតំងស្រី តំងប្រុស បើស្រីគោសធ្ងន់ហើយលែងប្រុស ឲ្យដាត់តែទ្រព្យដើមចេញឲ្យ (ស្រី) ឯទ្រព្យសម្ប័ដ្ឋឲ្យនប្រុសអស់ហោង បើគោសសមគួរស្រីលែងតុំឲ្យនឡើយ បើឥតគោសប្រុសលែងឲ្យនហោង ។

មាត្រា ១ (សោត) ច្បាប់ព្រះពជ្រកិត្យ (នេះ) ត្រូវមុខងារទេកញ៉ាសុកាធិបតីតំងអម្បាលណោះ បើតុំឲ្យនច្បាប់ទុនក្នាក់ងារសុកាធិបតីឲ្យឃានដឹងនោះ ទុកជាមេឃាម្ដាយអាតុកចាំងបំបាំងមុខងារ ព្រះចាទអ្នកជាអម្ចាស់ត្រាស់ពហូស័ក្តិ ឲ្យពិន័យដីង ៣ ដម្លឹង ១៧ ហោង ។

នេះច្បាប់ទសកវិយាសូរេចចប់ម្ល៉ះឯងហោង ។

(នេះច្បាប់ទសកវិយា អ្នកទេកញ៉ាពិភ័ក្តិសេនី ចារចប់ នៅថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះនក្សត្រ ឯកស័ក ព.ស. ២៤៦០) ។



លោក រ៉ាយ - ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺន អាំង (Jeune Inde)

(ត)

---

៤៩ – ចំពោះជនជាបច្ចាមិត្រនឹងកល្យាណមិត្រ យើងមិនត្រូវយល់ថា មានសភាពផ្សេងគ្នាទេ ។

... ការពិសោធន៍ធ្វើឲ្យយើងឃើញថា បើអំណោយដ៏ប្រសើរជាឧបស័គ្គចំពោះការចំរើននៃសីលធម៌វិញទេ ត្រូវតែយើងបំផ្លាញនូវអំណោយនោះឲ្យវិនាសសាបសូន្យទៅ កុំឲ្យមានចំគ្រួញក កុំឲ្យគិតពីសំណាងដែលត្រូវសងអ្វីឡើយ ។

... ការស្រឡាញ់សំពត់បរទេស ជាហេតុឲ្យបរជាតិមានឥស្សរៈភាពលើប្រទេសរបស់ខ្លួន ពាំងជាហេតុនាំមកនូវសេចក្តីទុក្ខព្រួយលំបាក ហើយនាំឲ្យមានសេចក្តីខ្មាសអៀនក្នុងវង្សត្រកូលជាច្រើន ដែលជាផលដ៏លាមកបំផុត ។

... មុននឹងការពារនូវគុណធម៌អ្នកដទៃ ត្រូវយើងការពារខ្លួនយើង កុំឲ្យបាបធម៌លុកលុយចូលមកកន្លងសន្តានយើង ។

សេចក្តីថ្លែងពីហាយគាត

ថ្ងៃទី ១ ខែតុលា ១៩២១

៥០- ឥឡូវនេះ ប្រទេសឥណ្ឌាមានផ្លូវពីរ: ១- បញ្ចូលគោលការណ៍ដែលគេនិយមប្រើនៅមជ្ឈិមប្រទេស គឺពលកាតពីលើច្បាប់ ។ ២- រក្សាទុកនូវគោលការណ៍បូតាប្រទេស ។ ផ្លូវទាំង ២ នេះជាធម្មតិត អាចនាំទៅកាន់ជោគជ័យ ដែលមិនចេះអាប់ឧន ហើយដែលអ្នកមានកំឡាំងនឹងអ្នកទុព្វលភាពមានសិទ្ធិស្មើគ្នាចំពោះសេចក្តីយុត្តិធម៌ ។

...អ្នកណាដែលរស់នៅដោយប្រើអាវុធ អ្នកនោះមុខជាស្លាប់ទឹងអាវុធ; គេឃើញមានអ្នកចេះភោលទឹកយ៉ាងចំណានលង់ទឹកស្លាប់ក៏មាន ។

...កិច្ចការដែលធ្វើឲ្យដឿនៅមុខ មិនមែនសុទ្ធតែវឌ្ឍនធម៌ទេ ។

...គ្មានផ្លូវអ្វីរំសែសជាងផ្លូវនៃធម៌តិត ។

នវជីវន (Nava Zivan)

ថ្ងៃ ៨ ខែមិថុនា ១៩២១

៥១- អ្នកណាដែលមិនចេះពោលនូវពាក្យពិត្យ អ្នកនោះប្រៀបដូចជាប្រាក់ក្នែងក្លាយដែលគ្មានដំឡៃ ។

...ពួកបណ្ឌិតខាងវិទ្យាសាស្ត្រពោលថា: បើគ្មានពលកាតអាចកាប់បរមាណូធាតុ ដែលមាននៅក្នុងលោកឲ្យជាប់រឹងមូលគ្នាបានទេ លោកសន្ធំក៏សនេះមិនអាចស្ថិតស្ថេរនៅបាន នឹងវិនាសរបេះរាក់ព្រាត់ព្រាយ ហើយយើងនឹងមិនអាចមានជីវិតរស់នៅឡើយ, ប្រៀបដូចជាកំឡាំងភ្ជាប់ធាតុដែលមាននៅក្នុងធម្មជាតិមានសភាពជាអវិញ្ញាណក:, កំឡាំងនោះក៏ស្ថិតនៅក្នុងសត្វ ដែលមានជីវិតក្នុងពិភពលោកដែរ; កំឡាំងដែលចង

ជាតុឲ្យស្អាប់មួលគ្នា ដែលប្រមូលសត្វមានជីវិតឲ្យចេះរួមគ្នានេះ គឺសេចក្តីស្នេហា ។

... សេចក្តីស្នេហានៅត្រង់ណា ដីវភាពក៏នៅត្រង់នោះ .. សេចក្តីស្អប់នាំសត្វទៅកាន់សេចក្តីវិនាស ។

ខ្ញុំសូមឲ្យលោកអ្នកជឿជាក់ថា: យើងមិនអាចទៅកាន់សេចក្តីចំរើនបានទេ បើយើងមិនបានខុកការប្រព្រឹត្តន្ទូវធម៌ពិតថាជាសភាពមានដំឡៃបំផុត ។

បៀវត្ស ឆ័ងជំលៀ

ថ្ងៃ ៦ ខែតុលា ១៩២១

៥២ - ភរិបណ្ឌិតបានពោលដោយសង្ខេបថា: កុំឲ្យដឿនូវពាក្យណាដែលមានន័យចំគាស់ឬផ្ទុយនឹងវិចារណញ្ញាណឬផ្ទុយនឹងចិត្តយើង ។

... ខ្ញុំអាចយល់ពិតច្បាស់ជាបានថា: ការចូលមកសូមទទួលសារភាពដោយសេចក្តីល្ងង់នៃអ្នកដែលជាទីស្រឡាញ់ រមែងធ្វើឲ្យវិនាសជាងការទទួលសារភាពចំពោះរំពាត់នៃចណ្ឌាល (Tyrans) ។ អ្នកដែលនៅក្រោមបង្គាប់ចិត្តពាលមានសេចក្តីសង្ឃឹមខ្លះ, ចំណែកអ្នកដែលនៅក្រោមឫទ្ធានៃសេចក្តីស្នេហា គ្មានសេចក្តីសង្ឃឹមសោះឡើយ ។ សេចក្តីស្នេហាមានប្រយោជន៍ត្រង់ការឲ្យកំឡាំង ដល់ជនណាដែលខ្សោយភាព ។ សេចក្តីស្នេហាអាចក្លាយទៅជាសភាពលាមក ដោយការបង្ខិំជនណាដែលមិនព្រមដឿឲ្យប្រតិបត្តិតាមចិត្តខ្លួន ។

... ព្រះដែលបង្កើតមនុស្សជាតិមក ព្រះអង្គចង់ឲ្យមនុស្សនោះរស់នៅដោយសារបំពេញតាមតួការគាំងភ្លង ហើយព្រះអង្គមានព្រះបន្ទូលថា "ជនណាដែលបរិភោគការងារមិនបានធ្វើការអ្វីសោះ ជននោះគេទុកជាពួកចោរ" ។

... ខ្ញុំចូលចិត្តត្រង់ការចំពោះ ខ្ញុំចូលចិត្តធ្វើការអ្វីៗ សម្រែចចំពោះខ្លួនឯង, ខ្ញុំពេញចិត្តខាងសេរីភាព ។ តែការគាំងនេះ ខ្ញុំចង់ឲ្យបានប្រយោជន៍ដល់អាត្មន, ខ្ញុំមានសេចក្តីសង្ឃឹមថា: សម័យ "ដែកថែប" វិសេសជាងសម័យ "សិលា" ។ ចំណែកសេចក្តីយល់ឃើញនៃខ្ញុំបែបនេះមិនជាអ្វីទេ គឺយើងត្រូវព្យាយាមប្រឹងប្រាជ្ញាយ៉ាងមុះមុត នឹងអាយតនៈឯទៀតត្រង់យ៉ាង ដើម្បីនឹងធ្វើវត្តន៍នៃអាត្មន ។ ខ្ញុំគិតយល់ឃើញថា: មិនជាការពិបាកទេត្រង់ការស្មានថា មនុស្សម្នាក់បានពាក់ត្រឿងបែបតាហានតាមសម័យ រាប់រកឃើញទ្បូវត្តុដែលសំខាន់ មានសភាពស្តិតស្ទេរយូរអង្វែងចំពោះអាយុជនៃមនុស្សជាតិ ។ ខ្ញុំគិតថា ជាការងាយបំផុតត្រង់ការប្រឌិតថា អ្នកណាដែលក្រីក្រមានតែដុំគ្រួសមួយនឹងដែកគោលមួយ ដើម្បីនឹងបំភ្លឺផ្លូវដែលខ្លួនត្រចៀ, អាចសំដែងធម៌, សរសើរទ្បូវគុណនៃព្រហ្មវិហារផ្សាយទៅកាន់កពដែលរងទ្បូវសេចក្តីទុក្ខដោយថ្លៃងសារលិខិត ញ៉ាំងសត្វលោកឲ្យបានប្រកបដោយសន្តិសុខនឹងមានមនោមយិទ្ធិដ៏ក្លៀវក្លាបានកង់លោកសន្ធិភាសនេះ ។

... សេដ្ឋកិច្ចខាងនយោបាយឯណាដែលធ្វើឲ្យអត្ថភាយន៍នូវសេចក្តីសុខនៃបុគ្គលន៍មួយ។ ឬប្រជាជាតិន៍មួយ។ សេដ្ឋកិច្ចនយោបាយនោះជាការទំនាស់នឹងសីលធម៌ ហើយគេទុកជាបទឧក្រិដ្ឋពេញទំ ។ សេដ្ឋកិច្ចខាងនយោបាយឯណា ដែលធ្វើឲ្យប្រទេសមួយទៅលួចប្លន់ប្រទេសមួយ សេដ្ឋកិច្ចនយោបាយនោះជាការទំនាស់នឹងសីលធម៌ ។ គេទុកជាអំពើបទឧក្រិដ្ឋ ចំពោះអ្នកណាដែលទិញរ៉ែដែលបានមកពីការបែងចែកមិនត្រប់ត្រាន់ ហើយយកវត្ថុទាំងនោះទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ។ ខ្ញុំទុកជាអំពើបទឧក្រិដ្ឋ បើខ្ញុំបរិភោគស្រូវសាលីអាមេរិក ហើយខ្ញុំធ្វើអ្នកដឹកខាងដែលមានស្រូវសាលី មិនឲ្យមានអ្នកណាមកទិញយកទៅបរិភោគបាន ខ្ញុំទុកខ្លួនខ្ញុំជាអ្នកបង្កហេតុឲ្យអ្នកទាំងនោះអនិច្ចកម្មដោយពុំភ្លក់ភ័យ។

... មុននឹងគិតបែងចែក ត្រូវស្វែងរកឲ្យបានមកសិន ។ កិច្ចការដែលមិនត្រមនៅក្រោមបង្គាប់បញ្ជានៃពាណិជ្ជការ មិនមែនជាការជំទាស់មឹងជនជាតិអង់គ្លេស ឬនឹងលទ្ធិបច្ចឹមប្រទេសទេ; ការនេះ គឺគ្រាន់តែបំពេញកិច្ចដើម្បីនឹងតស៊ូនូវរបៀបដែលពួកជនជាតិអង់គ្លេសបានស្ថាបនានៅទីនេះ។

... កណ្តុរដែលឆ្នាំស៊ីដោយហេតុថា កណ្តុរនោះជាសត្វខ្សោយការពារខ្លួនឯងមិនបាន; មិនមែនជាការគាប់ប្រសើរត្រង់ធ្វើពលិកម្មដោយគេបង្ខំនោះទេ ។

ការងារជាតិនិត្យមាំមួន

ថ្ងៃ ១៣ ខែតុលា ១៩៦១ (ម្ភៃឆ)

លោក សិរស៍-ស៊ីវ៉ែស តែន

លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

បើព្រះមហាក្សត្រនឹងពួកមន្ត្រីជាន់ខ្ពស់ មានគេកត់ត្រាទុកដោយជាក់លាក់ក្នុងសិលាចារឹកខ្លះ ឯពួកប្រជាការដែលគេទុកជាហ៊ីនភាព គេមិនសូវមានពណ៌នាក្នុងសិលាចារឹកនោះទេ ។ ដូចជានៅប្រទេសឥណ្ឌៀពួកប្រជាការមានចែកជាក្រុមតាមវិជ្ជាជីវៈ ដែលមួយក្រុម។ ចាន់អប់រំ ។ ការដែលស្រាវជ្រាវនូវសិលាចារឹកអាចប្រមូលរឿងរ៉ាវគ្រប់យ៉ាងដែលមានសារៈសំខាន់ ជាហេតុឲ្យអ្នកប្រាជ្ញជាន់ក្រោយពិនិត្យនូវសេចក្តីប្រែប្រួលដែលកើតឡើង អំពីចំនៀមទម្លាប់ហិណ្ឌូចំពោះវណ្ណៈដែលចូលមកស្ថិតនៅអាណាចក្រខ្មែរបាន ។ ព្រះមហាក្សត្រខ្លះជាអ្នករក្សាទុកនូវប្រពៃណីផ្សេង។ ហើយនឹងរបៀបវណ្ណៈ មានព្រះពជសិទ្ធិបង្កើតជាថ្មីនូវប្រពៃណីចំនៀមទម្លាប់ប្លែកៗ ។ មានសិលាចារឹកមួយបានពណ៌នាអំពីរឿងប្រែប្រួលច្បាប់ចំនៀមទម្លាប់ជាថ្មី គឺៈ ក្រុមសង្ឃការីនៃព្រះមហាក្សត្របានជ្រើសរើសកុមារសប្រហែល ២០ នាក់សម្រាប់តវ៉ាត្រកូលចំពោះនវណ្ណៈ ហើយនាំយកទៅថ្វាយព្រះមហាក្សត្រចំពោះព្រះអគ្គី, ព្រាហ្មណ៍ទីឥន្ទាយកនៃពលរដ្ឋ; ព្រះករុណាទ្រង់ឲ្យពរ

សព្វសាធុការមានចាត់រៀបចំផ្ទាជាដង្វាយ ហើយព្រះអង្គបានថ្វាយឯកសារទូវ
ឯកសិទ្ធិដែលព្រះអង្គព្រះរាជទានចំពោះនវរណ្ណៈ សិលាចារឹកនៃឯកសិទ្ធិ
ហើយនិងសេចក្តីកាយការនៃពិធីនេះ ត្រូវបានចារឹកទុកនូវផែនមាសដែលបាន
រក្សាទុកនៅមន្ទីរឯកសារនិងផែនថ្មដែលបានរក្សាទុកនៅព្រះបរមរាជ-
វាំងនិងផែនថ្មស្ថិតនៅគ្រប់ភូមិ នៃបុរសដែលបានជ្រើសរើសយកមកជា
មេបង្គាត់ពូជគ្រប់វណ្ណៈ ។

ដោយហេតុថាយើងត្រូវការពណ៌នាអំពីភូមិ, យើងត្រូវឲ្យយល់ថា
ភូមិទាំងនោះមានចាស់ព្រឹទ្ធាចារ្យនិងពួកមន្ត្រីឃុំជាអ្នកត្រួតត្រា ដែលមាន
អធិប្បាយនៅតាមសិលាចារឹក ដើម្បីនិងបញ្ជាក់នូវបុព្វហេតុនៃកម្មសិទ្ធិដី
ភូមិត្រមទាំងចោះគោលព្រំប្រទល់ ។ ចំពោះដីវាលនៃពួកក្សេត្រករនិង
ពួកពលរដ្ឋក្នុងភូមិ, គេបានដឹងរឿងរ៉ាវបន្តិចបន្តួចមានពោលថាពួកទាំង
នេះច្រើនមានពួកក្រុមជាន់ខ្ពស់គេចាត់ឲ្យទៅធ្វើជាទាសករនៅក្នុងបូជនិ-
យដ្ឋាន, ព្រះវិហារឬអាស្រម ដោយហេតុថាពួកទុត្តមក្រុមនេះច្រើនមាន
បសាទសទ្ធាចំពោះសាសនាផ្សេង ។ សិលាចារឹកនោះបានសំដែងអំពី
បញ្ជីដែលចុះនាមពួកទាសកនេះ ដែលមិនបានដឹងថានាមឈ្មោះខ្លួនមាន
សភាពមិនពីរោះពីសារ (ឆ្កែ, ឆ្មា, ស្អប់, សំអុយ) ហើយជាពាក្យមើល
ងាយដោយត្រង់នោះអាចតស៊ូបានខ្លួរសេចក្តីប្រមាថនៃគាល ហើយរក្សា
ទុកនូវកេរ្តិ៍តំណែលមកឲ្យដនជាតិខាងក្រោយ ។

តាមវត្តធាតុដ្ឋេរ ។ នៃស៊ុរីវិឡ្ឍខ្មែរបុរាណ បើតាមធម្មជាតិនៃ
បុព្វហេតុអក្សរចារឹកនោះដែរ។ សាសនាកើតឡើងនោះយើងអាចដឹងបាន
ដោយជាក់លាក់ តែមកពីសាសនាដែលនាំឲ្យកើតទ្វារក្បាច់រចនាផ្សេង ។
នៃខ្មែរសម័យបុរាណ រឿងតែស្ថានដែលមានរចនាជាប្រធានដែល
មានសភាពជាទីគោរព, ប្រាសាទខ្មែរទាំងអស់សុទ្ធតែជាបូជនីយដ្ឋាន
ហើយកំពែងនគរក៏មានសភាពដូចគ្នា ព្រោះកំពែងនោះគឺជាកំពែង
ខាងក្រៅនៃព្រះវិហារដែលស្ថិតនៅកណ្តាលនគរ ។

តាំងពីបុព្វហេតុនៃព្រះពុទ្ធសាសនាចូលមកខ្មែរ មកដល់សតវត្សទី ៦
ហើយមកដល់សម័យអង្គរ, សាសនាឥណ្ឌាជាសាសនាគោរពព្រះសិវៈ
ឬព្រះវិស្ណុ ហើយរួបរួមទាំងពីព្រះអង្គនៅជាសាសនាហរិហរៈ ជាព្រះ
ដែលមានព្រះរូបប្រតិស្ថានដោយរូបព្រះសិវៈនឹងព្រះវិស្ណុដែលជាមូលដ្ឋាន
នៃសាសនាហិណ្ឌូ, ចំណែកខាងព្រះពុទ្ធសាសនាមានពួកនាយកជា
ច្រើន ហើយព្រះមហាក្សត្រអង្គខ្លះបានចាត់ការឲ្យគោរពជាផ្លូវការ ។
ក្នុងសតវត្ស ១២ មានការកែទម្រង់មួយចំពោះសាសនានេះខាងប្រទេស
ភូមា, លាវ, សៀម, កម្ពុជា, ដល់មកចុងសតវត្សទី ៩ ពួកជនកុបុគ្គលនៃ
ប្រាសាទអង្គរមានសទ្ធាយ៉ាងមោះមុតចំពោះសាសនានេះបានកសាងវត្តជា
ច្រើននៅខាងត្បូងស្រះធំ ដែលព្រះអង្គខ្លះបានចាត់ឲ្យជីក ។ យើង
បានស្គាល់វត្តនោះបីតាមសិលាចារឹក : វត្តមួយសម្រាប់ពួកទុបាសកដែល

គោរពព្រះសរីរៈ, វត្តមួយទៀតសម្រាប់ពួកនាយកដែលវង្វាព្រះវិស្ណុ, វត្តទី ៣ សម្រាប់ពួកពុទ្ធបរិសទ្យ ។ សាសនាគារៈជាផ្ទះគារំនៃព្រះបរមភដារំឯនឹងរដ្ឋាភិបាល គឺគារគោរពនូវព្រះស្ដេចគឺរូបស្ដេចប្រតិស្ថានទុកឲ្យប្រជាពស្ត្រគោរព ដូចជាព្រះដែលជាបដិមាករបស់ទ្វីតំណាងព្រះមហាក្សត្រដំកល់ទុកក្នុងព្រះវិហារដែលស្ថិតនៅចំកណ្ដាលព្រះរាជធានី ។ ប៉ុន្តែមិនមែនតែព្រះមហាក្សត្រមួយទេ ដែលគេទុកជាព្រះនៅលើផែនដីដែលជាមូលដ្ឋានអាចឲ្យកើតសាសនាគារៈមួយផ្ទាល់ព្រះអង្គ ។ ក្នុងសម័យអង្គរមានសិលាចារឹកជាច្រើន អាចបញ្ជាក់ឲ្យឃើញនូវសាសនាគារៈមួយចំនោះរូបចំឡាក់ដែលមានកេតនគ័ណ្ឌជាអសេខបុគ្គល ក្នុងព្រហ្មញ្ញសាសនានឹងពុទ្ធសាសនា តែរូបទាំងនោះប្រតិស្ថានឡើងជំនួសសម្មតិនាមបុគ្គលដែលមរណភាពទៅហើយ ឬបុគ្គលដែលមានជីវិតរស់នៅ ។ មានរូបចំឡាក់ជាច្រើនជាតំណាងព្រះនិណាស្រេច, អសេខបុគ្គលដែលប្រទេសកម្ពុជាសម័យបុរាណបានរក្សាទុក នូវបដិមារូបតំណាងសេខបុគ្គលខាងសាសនាហិណ្ឌូ ។ បដិមារូបទាំងនោះច្រើនមានរូបភាពជាព្រះមហាក្សត្រិយ៍ ព្រះអង្គម្ចាស់ ឬជាមន្ត្រីធំៗ ប្រតិស្ថានរូបជាព្រះគឺមានព្រលឹងចាកចេញលោកនេះ ទៅកាន់លោកខាងមុខក្លាយទៅជាព្រះ ។ ព្រះបដិមារូបនោះ មានចារឹកតាមឈ្មោះដោយបញ្ជូលនាម

បុគ្គលដែលអនិច្ចកម្មនីដ្ឋានមកព្រះបដិមាការ បង្ហាញឲ្យយើញថាសាសនាគារៈនោះជាការគោរពចំពោះបុគ្គល ។

នេះជារឿងកាសំខាន់នៃសាសនាគារៈចំពោះបុគ្គលដែលជាបុព្វហេតុនៃការកសាងប្រាសាទខ្មែរតាំងនោះ មិនមែនដូចជាព្រះវិហារយើង ដែលកើតឡើងមកពីគារៈនៃពលរដ្ឋ. គឺជាប្រាសាទដែលព្រះមហាក្សត្រព្រះកជបុត្រឬរដ្ឋមន្ត្រីកសាងឡើង ដើម្បីដំកល់ព្រះអដ្ឋិធាតុ ហើយគេទុកជាព្រះស្តូបឬចេតិយ ដែលជាហេតុនៃសាសនាគារៈចំពោះដីដូនដីតា, ចេតិយតាំងប៉ុន្មានគេស្អាងតាំងពីបុគ្គលតាំងនោះមានដីវិតរស់នៅ ។

តីមកពីរៀបពិធីក្នុងការសម្ពោធប្រាសាទតាំងនោះបានជាមានសិលាចារឹកដែលជាប្រកាសំខាន់ ដែលយើងបានស្រាវជ្រាវទុកជាវិភាគនៃមហាស៊ីវិល្យខ្មែរបុរាណ ។ សិលាចារឹកនោះមានបង្ហាញនូវគំនិតផ្សេង ។ ដោយជាក់លាក់អំពីការចាត់អង្គការនៃព្រះវិហារ ឬសមាសភាពនៃបុគ្គលិកក្នុងព្រះវិហារនោះ មានឧបាយក, សាស្ត្រាចារ្យ, បព្វជិត, អ្នកភជិត (ភ្លេងមហោស្រពក្សត្រិយ), អ្នករាំ, នាងនាដកា (រាំ), នាយគ្រូរបាល, នាយពិសេស (ចំអិនម្ហូបអាហារ), នាយក្រុងបុប្ផានឹងពួកបរិវារ, ទាសកម្មករបុរសស្ត្រីជាច្រើនដែលគេដួលទៅធ្វើបម្រើស្រែដែលជាក្តីមរតករបស់វត្តនោះ ។

(មានត)

ស័ព្ទចាក់ដែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

លោក ម៉ុញ - ង៉ាគ្រី រួបរួម

(ពមក)

Monnaie = រូបិយវត្ថុ

Territoire = អាណាខែត្រ, ផែនដី

Le mécanisme des changes = រចៀបប្តូរ

Barrière = រថាំង

Faciliter = សម្រួល

Recherche = ការស្វែងរក

Organisme sanitaire = អង្គការសុខភាព

28 – 11 – 49

Traitement = ប្រតិត្តិកម្ម

Domaine = ផ្នែកការ

Bien = ទ្រព្យសម្បត្តិ

Point de vue = ន័យ

29 11—49

Fiscalité = សារពើពន្ធ

Régime juridique = ន៊ីតិវិធី

Législation = នីតិកម្ម

Particulier = ដោយឡែក

Spécial = ពិសេស

Instance civile = បទរដ្ឋប្បវេណី

– commerciale = ពាណិជ្ជកម្ម

– pénale = អាជ្ញា

Privilège juridictionnel = ឯកសិទ្ធិខាងតុលាការ
30–11–49

Membre sociétaire = សង្គមិកសមាជិក

– souscripteur = សមាទិកសមាជិក

Ordre = សេចក្តីរៀបរយ

Garnison = យោធភូមិ
6–12–49

Directive = សេចក្តីដឹកនាំ

Conduite générale = លំនាំការប្រៃ

Lettre de créance = សារតាំង
9–12–49

Habilité = នីតិសម្បទា

Convention = អនុសញ្ញា

Obligation civile = កិច្ចប្តេជ្ញា
20–12–49

Réciprocité = បដិការ

Organisme constitutionnel = អង្គការរដ្ឋធម្មនុញ្ញ

Droit = នីតិសាស្ត្រ

Statut personnel = លក្ខន្តិក:ផ្ទាល់ខ្លួន

Droit privé = ច្បាប់ឯកជន

Etat = សភាវៈ

Capacité = សមត្ថភាព

Le contentieux administratif = ក្រុមវិវាទខាងរដ្ឋបាល

23–12–49

Qualification = គុណវុឌ្ឍិ

Qualité = គុណសម្បត្តិ

អង្គារ ១០ – ១ – ១៩៥០

Facultatif = តាមចិត្ត, មិនចាំបាច់

សុក្រ ១៣ – ១ – ១៩៥០

Patrimoine = បេតិកភ័ណ្ឌ

អង្គារ ៣១ ធ្នូ ១៩៤៩

Commandement en chef = អគ្គបញ្ជាការ

Officier des cadres Cambodgiens = នាយទាហានជាតិខ្មែរក្នុងក្របខ័ណ្ឌ

Sans aucune discrimination = ដោយឥតរើសថ្នើងអ្វីឡើយ

Commande = បញ្ជាទិញ

សុក្រ ៣ កុម្ភ ១៩៥០

La Légionétrangère = កងសាបរទេស

Servitude = បរិចារភាព

Recrutement = ការជ្រើសរើស

អង្គារ ៧ កុម្ភ ១៩៥០

Permanence = និច្ចការ, និច្ចកាល, អចិន្ត្រៃយភាព

Permanent = ជានិច្ច, អចិន្ត្រៃយ

សុក្រ ១០ កុម្ភ ១៩៥០

Croix-Rouge = កាកបាទក្រហម

Parité = យុគភាព, ការធៀបតម្លៃ(ប្រាក់)

អង្គារ ១៤ កុម្ភ ១៩៥០

Hamonie = សុខដុម

Droit de préemtion = សិទ្ធិបុព្វក្រ័យ

Portée = ជួរភាព

សុក្រ ១៧ កុម្ភ ១៩៥០

លោក សាង - សាភីត លេខានុការ ក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តទៅ)

---

៨ – សេចក្តីស្នេហាពិត

"គ្មានពលិកម្មឯណាមួយអាចផ្កុតទម្ងន់ទៅលើទឹកចិត្តដែលស្រឡាញ់ពិតបានឡើយ" ។

គ្មានពលិកម្មឯណាមួយអាចផ្កុតទម្ងន់ទៅលើទឹកចិត្តដែលស្រឡាញ់ពិតបានឡើយ ។ ជនណាមានទុក្ខធំបំផុត ជននោះធ្វើពលិកម្មដោយសប្បាយបំផុតដែរ ។ នេះជាសញ្ញារបស់សេចក្តីស្នេហាពិត ។

នៅក្នុងពេលដដែល ដែលមានរឿងរបស់យើងនេះ គឺក្នុងសាសនាព្រះពុទ្ធកូណាគង្គ (Gaunagong) ដែលទ្រង់គង់ព្រះជន្មបានបីមុឺនព្រះវស្សា ។ នៅក្នុងស្រុកកម្ពុត្សា (Kambautsa) មានសេដ្ឋី ៤ នាក់ ចង់ស្តាន់មេត្រីនឹងគ្នាយ៉ាងមុតមាំ ។ បណ្តាសេដ្ឋីទាំង ៤ នោះ សេដ្ឋីបីនាក់មានកូនប្រុសមួយៗម្នាក់ ។ ឯសេដ្ឋីទី ៤ មានកូនស្រីមួយ ដែលមានរូបឆោមយ៉ាងល្អឆើតឆាយ ។

កូនកំឡោះនៃសេដ្ឋីទាំងបីនាក់ មានចិត្តស្រឡាញ់នាងនោះជាពន់ពេក ហើយបានចូលខ្លួនទៅដណ្តឹងដល់ឪពុកម្តាយរបស់នាងតែ

រៀងខ្លួន ។ កន្លងពេលនោះតទៅភរិយារបស់នាង មុននឹងសម្រេចរឿងនេះ, ដោយការចង់ដឹងចិត្តបុរសទាំងបី ទើបសួរខ្សែអក្សរទាំងនោះថា: បើសិនណាមានកម្មអាក្រក់មកផ្តាច់ដីវិតកូនស្រីរបស់ខ្ញុំ មុនពេលដែលមិនទាន់ដល់អាយុរៀបការ តើអ្នកណាគិតយ៉ាងណាខ្លះ? បើអ្នកណាគិតត្រូវគួរសម ខ្ញុំនឹងឲ្យកូនស្រីរបស់ខ្ញុំទៅអ្នកនោះ! ។

ចំនួនថ្ងៃក្រោយមក បុរសទាំងពីរបានផ្ញើសំបុត្រធ្វើយមកឪពុកម្តាយរបស់នាងរៀងខ្លួន ។ បុរសទី ១ និយាយថា: បើសិនណាកញ្ញាក្រក់នាងស្លាប់មុនអាយុ ១៥ ឆ្នាំ ខ្លួនខ្ញុំនឹងបានាយកឆ្មោចនាងទៅបូជានៅកន្លែងមួយដែលធ្វើនឹងដៃឯង រួចខ្ញុំនឹងធ្វើបុណ្យឲ្យនាងតាមព្រះពុទ្ធប្រៃណីអំពីបុពណ ។ បុរសទី ២ សន្យាថា: បើសិនណានាងមានវាសនាអាក្រក់អស់អាយុមុនពេលរៀបមង្គលការ ខ្ញុំនឹងប្រមូលជាតុនាងដែលធ្វើឈាបនកិច្ចរួចហើយ យកទៅបញ្ចុះកន្លែងផ្សារមួយយ៉ាងល្អអស្ចារ្យ ដែលមានដើមអម្ពិលទឹកមានមូលប្រែឈឹងត្រៃឈៃ ។ ចំណែកខាងបុរសទី ៣ និយាយយ៉ាងខ្លីថា: បើសិនណាគ្រានោះមានមកដល់ប្អូនាង ខ្ញុំនឹងយកជាតុនាងទៅបញ្ចុះកន្លែងផ្សារមួយ រួចដេកនៅទីនឹងផ្សារនោះជាអចិន្ត្រៃយ៍ តាំងយប់តាំងថ្ងៃតាល់តែស្លាប់បង់ដីវិតទៅ ។ ឪពុកម្តាយរបស់នាងអានចប់ហើយងក់ក្បាល ដោយពេញចិត្តនឹងពាក្យចំឡើយនៃសេដ្ឋីបុត្រទាំងបីនាក់នេះ ។

តួរអនិច្ចា ហ៎! កន្លងពេលនោះ វាសនាបណ្តាលឲ្យនាងស្លាប់មុនអាយុ

១៥ ឆ្នាំមែន ។ ឪពុកម្ដាយរបស់នាងកើតទុក្ខជាអនេក ចានអង្វរឲ្យបុរសទាំងបីបំពេញកិច្ចសន្យារបស់ខ្លួនក្នុងគ្រានោះ ។ បុរសទាំងបីក៏ចានធ្វើដោយឥតរួញរាឡើយ ។ បុរសទី ១ យកវបនាងទៅបូជា ។ បុរសទី ២ យកគ្នឹងនឹងដៃទៅជាក់កងផ្សារមួយយ៉ាងល្អ ។ រួចបុរសទី ៣ ទៅដេកទៅនឹងផ្សារនោះទាំងយប់ទាំងថ្ងៃ ។

ដល់ឃ្លាថ្ងៃក្រោយមក មានអ្នកសច្ចំម្នាក់ដែលដើរកងកៃពហិមពាន្ត ចានឃើញបុរសអង្គុយតែនឯង មានទឹកមុខស្រងូតស្រងាត់សំឡឹងមើលផ្សារនាង ។ លោកឈប់ហើយសួរទៅបុរសនោះថា : តើអ្នកអង្គុយធ្វើអ្វីនៅទីនេះ ។ បុរសប្រថុយស្ងាប់និយាយមួយ។ ច្បាប់លោកវិញសព្វសេចក្ដីអំពីសេចក្ដីមរណៈរបស់នាងនឹងអំពីពាក្យសន្យារបស់ខ្លួនដែលថាសុខចិត្តដេកនៅនឹងផ្សារបស់នាងដល់ស្ងាប់ជីវិត ។ អ្នកសច្ចំមានចិត្តអាណិតបុរសនោះជាពន់ប្រមាណដោយឃើញថាបុរសនេះស្រឡាញ់នាងពិត ។ រួចលោកសួរថា: តើចៅឯងសប្បាយចិត្តឬទេ បើសិនណានាងនេះរស់ឡើងវិញ? ។

បុរសនោះយំមានទឹកភ្នែកហូរស្រស្រាក់ឆ្លើយវិញថា: ចិត្តខ្ញុំច្បាស់ជាំបំផុតត្រង់ឲ្យនាងរស់ឡើងវិញ ។ ក្នុងពេលនោះ អ្នកសច្ចំក៏សូត្រអាគមគាថាឡើង ដុំមួយស្របក់ស្រាប់តែនាងលេចចេញពីក្នុងដីឡើងល្អឯករកអ្វីប្រៀបពុំបាន ។ នាងឥតនិយាយអ្វី ស្រាប់តែដើរតម្រង់ទៅផ្ទះរបស់ឪពុកម្ដាយនាងវិញ ។ ឯឪពុកម្ដាយរបស់នាងដូចអ្នកផងក៏ជាបស្រាប់ហើយ គាត់មានចិត្តសប្បាយឥតឧបមា ។

លុះគាលណាបុរសទី ១ ដឹងរឿងដំបូងឡែកនេះក៏ទៅរកឥពុកម្តាយ របស់នាងដែលកំពុងសប្បាយ ហើយនិយាយថា: ខ្ញុំបានយករូបនាង ទៅជូតខ្លួនខ្ញុំ រួចខ្ញុំបានផ្ញើបុណ្យបញ្ជូនឲ្យនាងតាមប្រពៃណី; តែឥឡូវ នាងសង្ឃឹងវិញហើយ តើនាងត្រូវបានមកខ្ញុំមែនឬទេ? ។

បុរសទី ២ ថា: ខ្ញុំបានយកធាតុនាងទៅបញ្ចុះកងផ្សារមួយយ៉ាងល្អ ឯរូបនាងដែលសង្ឃឹងវិញនេះត្រូវបានមកខ្ញុំ ។

បុរសទី ៣ និយាយថា: ខ្ញុំបានដេកនៅលើផ្សារបស់នាង, ខ្ញុំបាន អង្វរអ្នកសង្ឃឹមឲ្យជ្រោសនាង តើខ្ញុំគ្មានអំណាចអ្វីលើនាងទេឬ? បើខ្ញុំមាន គុណលើរូបនាងយ៉ាងដូច្នេះ; ប៉ុន្តែយើងកុំឈ្លោះគ្នា ព្រោះយើងដឹងចិត្ត គ្នាស្រាប់ហើយ យើងមិនគាចសម្រេចការណ៍នេះបានដោយខ្លួនយើងទេ, យើងត្រូវនាំគ្នាទៅរកព្រះនាងវត្តិយានី ធូដាម្ន៉ាសារី (Thoudamna sari) ព្រះនាងជាស្រីមានប្រាជ្ញាហើយសុចរិតត្រឹមត្រូវផង, បើអ្នកទាំងអស់គ្នា សុខចិត្ត យើងត្រូវទៅប្តឹងឲ្យព្រះនាងសម្រេចរឿងនេះឲ្យ ។

ឯឥពុកម្តាយរបស់នាងនឹងរូបនាងក៏ព្រមព្រៀងឲ្យបុរសទាំងបីទៅ ប្តឹងព្រះនាងវត្តិយានី ដោយតតបង្អង់ឡើង ។

ព្រះនាងលុះគាលណាបានស្តាប់សំឡេងក្តីហើយ បាននិច្ឆ័យ សេចក្តីដូចតទៅនេះ:

"ខ្ញុំបានស្តាប់យល់អស់ហើយ; បុរសទី ១ លុះគាលណានាង ស្លាប់បានយករូបនាងទៅជូត, ដល់អណ្តាតភ្លើងឆាបឆេះឡើង បុរសរូបនេះ

ទៅជាត់ទៅដោយតតិតអ្វីទៀតសោះ ។ បុរសទី ២ បានរើសឯតុនាង ទៅដាក់កន្ទងផ្ទះមួយយ៉ាងស្អាតស្អម្ភ. ដល់កាលណាដាក់រួចហើយ បុរសរូបនេះទៅកេស៊ីជាត់ទៅ ។ ឯបុរសទី ៣ មិនបានទៅណាមកណា ដូចតេឯទៀតទេ, ប៉ុន្តែរូបនេះលែងរវល់នឹងការងារក្នុងលោកយើងនេះ ហើយទៅដេកនៅលើផ្ទះរបស់នាង ទាំងយប់ទាំងថ្ងៃ មិនគិតខ្វាចដល់ទំនៀមទម្លាប់ស្រុកយើងដែលថ្លែងថា បើមនុស្សណាទៅយាមផ្ទះខ្មោច ត្រូវភ្ញាក់មនុស្សនោះត្រូវហូតងារ ហើយបំបែកចេញពីសញ្ជាតិចំនួន ៧ តំណ ។ អាស្រ័យហេតុនេះ សេចក្តីស្នេហារបស់បុរសនេះមានធំជាងអ្នកទាំងពីរនាក់, គឺរូបបុរសនេះហើយដែលត្រូវបាននាង ដើម្បីតបស្នងដល់សេចក្តីមេត្រីរបស់គេ; មួយទៀតដោយសារតែដេកនៅទីធ្លាផ្ទះនេះហើយបាននាងរស់មានជីវិតឡើងវិញយ៉ាងប្លែកអស្ចារ្យនេះ, បុរសនេះនឹងមិនចោលនាងក្នុងពេលដែលនាងមានវិបត្តិ; មានតែរូបបុរសមួយនេះទេ ដែលអាចរក្សានាងដោយសុស្ថីដរាបតទៅ" ។

នេះហើយសេចក្តីអាសាត់របស់ព្រះនាងឧត្តិយានី ។ បន្ទាប់ពីនោះមក គេរៀបពិធីមង្គលការអាពាហ៍ពិពាហ៍ឡើងដោយអ៊ឹកធឹក ។

សុភាចារបុរសទាំងឡាយ ! អ្នកត្រូវធ្វើតាមសន្តិចរិយានេះ ។ អ្នកគោងដឹងថាការសង្គ្រាមមានច្បាប់ ។ មួយទៀត ត្រូវដឹងដំរៅនៃសេចក្តីស្នេហាដោយទំហំពលិកម្មដែលជាប់នៅលើរបស់ដែលគេស្រឡាញ់ ។

(មានត)

កណ្ឌទី ៧

អ្នកឧកញ៉ាវិរុលរាជសេនា ឆ្លងកន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

នាងតៀវសៀនបានឮដូច្នោះ ក៏តែតែឡើកលមាយាឲ្យតាំងតុៈចាប់ចិត្ត ឡើងវិញ ។ រាងអ៊ុនយីញាដូច្នោះគ្រាកលុតដល់ដីគំនាប់តាំងតុៈហើយ ថា សព្វថ្ងៃនេះខ្ញុំបានមានសេចក្តីសុខព្រោះបុណ្យគុណអំណាចលោក ខ្ញុំបានធំឯកអ្វីតបព្រះគុណគ្មាន មានតែនាងតៀវសៀនជាកូនចិញ្ចឹមនេះ ខ្ញុំបានក៏ស្រឡាញ់ទុកដូចជាកូនបង្កើត ខ្ញុំបានសូមលើកជូនជាស្រេចដល់លោក ។ តាំងតុៈបានឮដូច្នោះ ក៏មានសេចក្តីត្រេកអរជាពន្លឹកទើបតប ថា ដែលលោកមានដួងចិត្តគំនលើកនាងតៀវសៀនឲ្យដល់ខ្ញុំនោះ ខ្ញុំនឹងតបស្នងសងគុណលោកតទៅ ។ អង់អ៊ុនទើបឲ្យចាត់ចែងគ្រឿងបរស់ជាគ្រឿងសំពត់អាវសាវៃស្បែដ៏មានដំឡៃ រៀបដំណើរឲ្យនាងតៀវសៀន

ជារៀង ហើយឲ្យឡើងជិះរថ ចាត់ឲ្យមនុស្សម្នាហែហមទៅដល់លំនៅ
ឋានតាំងតុះ ក្នុងស្រុកក្រុងនៅវេលាយប់នោះ ។

. ឯតាំងតុះនោះកាលឃើញអង្គអ៊ុនចាត់ប្រែមនុស្សម្នា ឲ្យនាំខ្លួននាង
តៀវសៀនទៅឲ្យដូច្នោះ ក៏លាអង្គអ៊ុនចេញទៅ ។ ក្នុងពេលនោះ
អង្គអ៊ុនក៏ជូនដំណើរតាំងតុះទៅដល់ផ្ទះហើយលាត្រឡប់វិលមកវិញ, ចេញ
មកដល់ពាក់កណ្តាលផ្លូវខ្លួលជួបនឹងលីចោ"ជិះសេះកាន់ខ្លួនមកពីមុខ ។
លីចោ"ឈប់ចាប់ជាយអាវអង្គអ៊ុនហើយសួរថា នាងតៀវសៀននោះខ្លួន
លើកឲ្យជាភរិយាយើងហើយ ហេតុម្តេចក៏បញ្ជូននាងទៅឲ្យមហាឧបរាជ
វិញ ដែលខ្លួនធ្វើដូច្នេះនឹងបញ្ឆោតយើងលេងឬ? ។

អង្គអ៊ុនតបថា ទីនេះជាកណ្តាលផ្លូវ ខ្ញុំនឹងជំរាបអ្នកឲ្យអស់សេចក្តី
មិនបាន សុំអញ្ជើញអ្នកទៅផ្ទះខ្ញុំមួយរំពេចសិន ខ្ញុំនឹងជំរាបរឿងនេះឲ្យបាន
ជ្រាប ។ លីចោ"តាមទៅដល់ផ្ទះអង្គអ៊ុន ។ នាំលីចោ"ឡើងទៅលើលែ្វងផ្ទះ
ហើយនិយាយថា អ្នកកុំអាលខឹងសំបានឹងខ្ញុំ ។ នឹងជំរាបឲ្យជ្រាប: កាល
ពីព្រឹកមិញ ខ្ញុំបានចូលទៅគាល់ព្រះចៅហៀនតេ · មហាឧបរាជបាន
និយាយនឹងខ្ញុំថា មានកិច្ចនឹងត្រូវការចង់ទៅរកខ្ញុំឯផ្ទះក្នុងពេលថ្ងៃត្រង់,
ខ្ញុំបានរៀបក្រយាហារទុកជូនពិសា, លុះមហាឧបរាជទៅពិសាហើយ
ឈ្វេចសួរខ្ញុំថា មានគេទៅដំណាលថាខ្ញុំលើកនាងតៀវសៀនជាកូនឲ្យធ្វើជា
ភរិយាអ្នក, ខ្ញុំបានទូលថាមែន, មហាឧបរាជថាចង់សុំមើលខ្លួន, ខ្ញុំឲ្យ

នាងតៀវសៀនចេញមកគំនាប់, មហាឧបាសិកាបានឃើញរូបកាងហើយថា ដែលខ្ញុំលើកកូនឲ្យអ្នកជាបុត្រធម៌មហាឧបាសិកានោះ មហាឧបាសិកាមានសេចក្តីពេញចិត្តណាស់ និយាយទន្ទឹងខ្ញុំថា ថ្ងៃនេះឫក្សាល្អហើយនឹងសុំយកកូនឯងនាងតៀវសៀនទៅរៀបការនឹងអ្នកជាកូន ឲ្យទៅរួមសុខទុក្ខនឹងគ្នាតាមប្រពៃណី; ដែលមហាឧបាសិកាថាដូច្នេះ អ្នកចូរគិតមើលទៅចុះ ខ្ញុំជាអ្នកតូចនឹងអាចដែរទទឹងបានឬ? ខ្ញុំទើបបញ្ជូនកូនឲ្យទៅ ។

លីចាំបានស្តាប់ទើបឆ្លើយថា "ខ្ញុំបាទដែលគ្រែធនឹងលោកនោះខុសហួសទៅហើយ សូមឲ្យលោកអភ័យទោសចុះ" ថាហើយលាទៅវិញ ក្នុងវេលាយប់នោះស្លូតទៅដល់ផ្ទះតាំងតុ: ហើយចាំស្តាប់ដំណឹង ជាតាំងតុ:នឹងគិតរៀបការឲ្យមែនប្រយោជន៍បានជាមិនមានភ្លាអ្វីសោះ ។ លុះព្រឹកឡើងលីចាំឡើងចូលទៅកន្លែងផ្ទះសួរស្រីបំរើថា មហាឧបាសិកានៅឯណា ? ។ ពួកស្រីប្រាប់ថា លោកមិនដឹងទេឬ យប់មិញមហាឧបាសិកាបានស្រីរូបល្អម្នាក់មក ឥឡូវកំពុងសម្រាន្តនៅឯក្នុង ។ លីចាំបានស្តាប់ដូច្នោះនឹកក្តៅឈួលកន្ធរចិត្ត ទើបដើរចូលទៅអែបស្តាប់ក្បែរជញ្ជាំង ។ ឯនាងតៀវសៀនគ្រោកតាំងតុ: ចេញទៅលប់មុខ ក្រឡេកឃើញស្រមោលចូលទៅតាមបង្អួច ក៏អើតចេញទៅមើលឃើញលីចាំ ។ នាងតៀវសៀនធ្វើជាយំ ហើយយកសំពត់ជូតទឹកភ្នែក ។ លីចាំឃើញដូច្នោះ រឹតតែមានចិត្តខឹងក្តៅនឹងតាំងតុ:ខ្លាំងណាស់ ទើបដើរត្រឡប់ចេញទៅខាងក្រៅ ។

កាលតាំងតុ:ក្បាត់ឡើងចេញទៅខាងមុខ, លីចោ"ក៏ឡើងទៅរៀតាំងតុ:សួរថា ថ្ងៃនេះមានការកជការអ្វីខ្លះ? លីចោ"ឆ្លើយដោយសំឡេងខ្ទេាះថា គ្មានការអ្វីទេ ។ តាំងតុ:ក៏នៅស្ងៀមហើយបរិភោគអាហារ ។ លីចោ"ចូលទៅឈរតើខាងក្រោយតាំងតុ:តាមទម្លាប់ ។ ឯនាងតៀវសៀនផាត់សក់ចេញហើយងាកមុខមើលទៅឃើញលីចោ" ធ្វើជាចោលភ្នែកក្រឡេកទៅប្រទះនឹងភ្នែកលីចោ" ។ រីតែមានសេចក្តីអាណិតស្រឡាញ់ជាច្រើន ។ ឯតាំងតុ:ដូនជាចោលភ្នែកក្រឡេកទៅឃើញជាក់ជាលីចោ" សំឡឹងមើលនាងតៀវសៀនច្រើនដងដូច្នោះ ក៏មានចិត្តច្រណែន ទើបនិយាយនឹងលីចោ"ថា ថ្ងៃនេះគ្មានការអ្វីទេ បើត្រូវការទៅផ្ទះ ក៏ទៅចុះ ។ លីចោ"ឮដូច្នោះក្រឡេកមើលទៅមុខនាងតៀវសៀនម្តងទៀត. ហើយដកដង្ហើមធំរួចចុះទៅ ។

កាលតាំងតុ:ចាននាងតៀវសៀនមកទុកនោះ ក៏មានសេចក្តីស្រឡាញ់ពេញចិត្តវង្វេងជាប់ក្នុងកាមដោយមាតុគ្រាម ក៏ក្រេចចេញមកនិយាយការជាង ១ ខែថ្មាយ ។ ពេលណាដែលតាំងតុ:មានជម្ងឺឈឺ, នាងតៀវសៀនតែងមានសេចក្តីទុក្សាហ៍ គក់ច្រចាប់បំរើបម្រាសតាំងតុ: មិនឲ្យមានសេចក្តីខាស់ឆ្អែតគំនិតឡើយ ។ តាំងតុ:រីតែមានសេចក្តីស្រឡាញ់ពេញចិត្តនឹងនាងតៀវសៀនខ្លាំងឡើងទៀត ។

មានថ្ងៃ ១ លីចោ"ចូលទៅសួរដល់ខាងក្នុងផ្ទះ តាំងតុ:កំពុងតែដេកលក់ នាងតៀវសៀនឃើញលីចោ"ចូលមកងាកខ្នងចេញទៅខាងក្រៅមុន

ធ្វើកលមាយាយកដៃចង្អុលទៅត្រង់តាំងតុ: ហើយចង្អុលទៅដើមទ្រូងរបស់ខ្លួន ហើយយំអណ្តឹតអណ្តកកន្ទឹរនោះ ។ លីចោ៉ដឹងកូនកិរិយាដែលនាងតៀវសៀនធ្វើខេះ តែតែមានសេចក្តីស្នេហាស្រឡាញ់ឡើងបែរជាស្អប់ខ្ពាញ់ទឹងតាំងតុះទៅវិញ ។

ចំណែកតាំងតុះភ្ញាក់ឡើងឃើញលីចោ៉ចូលទៅ កំលបលួចគយគន់មើលអាកប្បកិរិយា ឃើញលីចោ៉លួចសំឡឹងទៅនាងតៀវសៀនខាងក្បែរមុងដូច្នោះ ក៏ទឹងណាស់ស្រែកគំហកថា "នែអាលីចោ៉អាអប្រិយ! អញទំប្រើឯយកឯងមកបិញ្ចឹមក្បាខុកដូចជាកូនបង្កើត .បង់កំឡាំងសោះ, អាឯងចិត្តធំហានលួចស្រឡាញ់ប្រពន្ធអញ" ថាហើយបង្គាប់ស្រីបំរើឲ្យបណ្តេញលីចោ៉ចុះពីលើផ្ទះហើយថ្កាប់ថា តាំងពីថ្ងៃនេះទៅ កុំឲ្យវាចូលមកផ្ទះអញទៀត ។ តែលំនោះលីចោ៉មានសេចក្តីអៀនខ្មាសណាស់ទឹកភ្នែកនស្រក់តួចចិត្តចុះដើរចេញពីផ្ទះតាំងតុះទៅ ដល់បានពាក់កណ្តាលផ្លូវដួបប្រទះនឹងលីយូ ហើយបាននិយាយរឿងរ៉ាវថ្កាប់លីយូសព្វគ្រប់ថា "តាំងតុះមានចិត្តរំលោភលួចយកប្រពន្ធរបស់ខ្ញុំនផង ដេរប្រមាថបណ្តេញខ្ញុំនថែមទៀតផង" លុះថ្ងៃរឿងខ្ញុំថ្កាប់សព្វគ្រប់ហើយ ក៏គំនាប់លាលីយូដើរសំដេរទៅកាន់ផ្ទះ ។ ឯលីយូបានស្តាប់ពាក្យលីចោ៉ថ្កាប់សព្វគ្រប់ហើយនឹកតូចចិត្ត ទំដើរស្រូតរូតរាស់ទៅដល់ផ្ទះតាំងតុះ ហើយចូលទៅដំកបថា លោកមានសេចក្តីថ្នាក់តិតការធំដុំ

ចុះហេតុម្តេចមកតាស់ខែងនឹងលីចោ" ដោយសេចក្តីមិនមានខ្វីមសារដូច្នេះ
បើលីចោ"បែកចិត្តចេញពីលោកហើយ លោកនឹងយកនរណាធ្វើជាកំលាំង
តទៅបាន ។ តាំងតុះព្រលីយូថាដូច្នោះក៏ព័យាន្តស្តុកចិត្តហើយថា
ដែលលីចោ"ខឹងនឹងយើងនោះ អ្នកនឹងឲ្យយើងគិតដូចម្តេចឲ្យបានស្រួល
ឡើងវិញ ។ លីយូដំកបថា សូមឲ្យលោកកេខ្ញុំនលីចោ"មក ហើយ
យកមាសច្រាក់នឹងគ្រឿងបស់ដែលមានដំឡៃឲ្យលីចោ" ហើយនិយាយ
ល្បួងលួងលោមថ្នមចិត្តឲ្យស្រួល ច្រវែលជាលីចោ"នឹងមានចិត្តគិត
ស្រឡាញ់លោកឡើងវិញ ។ តាំងតុះស្តាប់ហើយក៏យល់ព្រមជាមួយផង ។

លុះព្រឹកឡើងតាំងតុះឲ្យបំរើទៅហៅខ្ញុំនលីចោ"មកដល់និយាយថា
"កូនវេលាថ្ងៃម្សិលមិញបិតាមិនសប្បាយខ្ញុំនមានជម្ងឺឈឺក្តៅក្រហាយសព្វ
សាច់ ដូចជាក្តៅស្វាតី បានជាខឹងស្តីឲ្យកូនដូច្នេះដូច្នោះហួសទៅហើយ
កូនអើយអ្នកកុំប្រកាន់ទោសបិតាឡើយ" ថាហើយលើកមាស ១០
ដញ្ជីង ព្រៃយ"ងល្អ ២០ ជាប់ឲ្យលីចោ"។ គំនាប់ខ្ញុំលហើយយកទៅ ។
តាំងពីថ្ងៃនោះរៀងមក លីចោ"តែងទៅមករកតាំងតុះតាមទម្លាប់ដូចដើម
តែចិត្តនោះនៅនឹករលឹកនាងគៀវសៀនមិនមានភ្លេច ១ វេលា ។ លុះ
យូរមកតាំងតុះជាជម្ងឺហើយក៏ចូលទៅគាល់ព្រះចៅហៀនតេ ។ លីចោ"
ដឹះសេះកាន់ខ្ញុំនតាមទៅជាមួយផង, ពេលដែលតាំងតុះកំពុងអង្គុយគាល
លីចោ"លបចេញទៅឡើងសេះដឹះបំផ្លាយទៅដល់ផ្ទះតាំងតុះ ចងសេះខ្ទុក

ទៅមុខផ្លូវហើយ គាត់ខ្លួនឯងចូលទៅរកនាងតៃវ៉ែសៀនខាងស្លែងក្តង ។ នាងតៃវ៉ែសៀនគ្រាឡែកយើញដូច្នោះ ក៏ដាមានចិត្តអាល័យណាស់គំនាប់ហើយថា បើយើងនឹងនិយាយគ្នាក្តងវិនេះខ្លាចគ្រែងតាំងតុះមកខាន់នឹងគែខ្លួនលំបាក បើដូច្នេះសូមអញ្ជើញអ្នកទៅចាំខ្ញុំឯកន្លែងគ្រែដាក់ក្តងសួនឆ្លា ខ្ញុំនឹងចុះទៅតាមឥឡូវនេះ ។ ឯលីចោ៉កចុះទៅតាមសញ្ញា ។

នាងតៃវ៉ែសៀនក៏ចុះទៅតាមលីចោ៉ហើយអង្គុយជាមួយគ្នាតែក្បែរមាត់ស្រះ តែកចេះតែសំឡឹងមើលផ្លូវគ្រែងតាំងតុះមកខាន់ ។ នាងតៃវ៉ែសៀនធ្វើកលឧបាយស្ទុះទៅឧបង់ដល់លីចោ៉ ហើយគ្រាបខ្ជិញយំថា "ខ្ញុំនឹងខ្ញុំជាកូនមង្ឃអ៊ុនៗឥតុកខ្ញុំពប់គាន់ស្រឡាញ់អ្នកដូចជាកូនបង្កើត បានលើកខ្ញុំឲ្យជាកវិយាអ្នក ខ្ញុំមានសេចក្តីត្រែកអរណាស់ ដែលមហាឧបាជទៅខ្លួលយកខ្ញុំមកថា នឹងរៀបការអ្នកនឹងខ្ញុំឲ្យបានជាស្វាមីកវិយានៅជាមួយគ្នា, លុះមកដល់ផ្លូវមហាឧបាជមិនឃើញធ្វើតាមពាក្យថា, ត្រឡប់កំហែងខ្ញុំរួមប្រវែណីដូច្នេះ ទ្រង់របស់ខ្ញុំមានតែសេចក្តីក្រែងដំណាំជានិច្ច ប្រហែលជាង ១ ខែក្នុយហើយ គិតថានឹងអត់ដង្ហើមឲ្យស្វាប់ទៅពុំគាប់ ព្រោះមិនខាន់បានដឹកបណាអ្នក ត្រមាំងប្រាប់ទុក្ខដែលមានក្នុងទ្រូងខ្ញុំ ឥឡូវបានដួបហើយ ខ្ញុំសូមលាអ្នកស្វាប់វិលានេះ នឹងគ្រាសៅទាំឲ្យរងកម្មចិត្តឥតអំពើ បើខ្ញុំមិនធ្វើឲ្យអ្នកយើញដូច្នោះ មិនពិតជាត្រែងប្រាកដ" ថាហើយក៏ស្ទុះចុះពីលើត្រែលោតតំរង់ទៅក្នុងស្រះឲ្យស្វាប់ ។ (មានត)

ភាគទី ២

សម័យឧកញ៉ាខេមពិន្ទ្រ ឈឹម - ក្រសេម រៀបរៀង

(តទៅ)

រឿងអសន្តិសុខក្នុងប្រទេស តាំងពីព្រះបាទហស៊ិរ៉ាន់ឡើងសោយរាជ្យ ចេះតែមានហូរហែជាដរាបមក ។ ខ្មែរនេះជាទុកាសឲ្យប្រទេសជិតខាងសំឡឹងរកផលប្រយោជន៍ ដូចដែលធ្លាប់មានមកហើយ, ក៏តែថា គ្មានប្រទេសណាដូចប្រទេសចាម្ប៉ាទេ ។ ចាម្ប៉ាបានតាំងខ្លួនជាគូបដិបក្ខនឹងខ្មែរ បានព្យាយាមលើកទ័ពមកវាយខ្មែរជាច្រើនលើក ដូចមានពោលមកខាងដើមជាច្រើនលើកហើយ ។ មកក្នុងរដ្ឋកាលនេះ ចាម្ប៉ាក៏លើកទ័ពមកវាយខ្មែរទៀតយ៉ាងខ្លោចខ្លី ។

សង្គ្រាមចាម្ប៉ាគ្រាទី ២

ក្នុងរដ្ឋកាលនេះ ប្រទេសកម្ពុជាបានទទួលគ្រោះថ្នាក់ជាយ៉ាងធ្ងន់ដោយស្នាដៃចាម្ប៉ា គឺក្នុងឆ្នាំ ៣. ស. ១៦២១ ចាម្ប៉ាបានលើកទ័ពមកវាយយ៉ាងធំអស្ចារ្យ ដុតផ្ទះសំបែងអស់ជាច្រើន តែចូលក្រុងពុំបានដោយកងទ័ពខ្មែរទប់ជាប់ ហើយដេញចាយទៅវិញ ។

សង្គ្រាមចាម្ប៉ាគ្រាទី ៣

កន្លងមក ៣ឆ្នាំ គឺក្នុង ព. ស. ១៦២៤ ប្រទេសកម្ពុជាត្រូវខ្លួចគ្រោះថ្នាក់ពីត្រែត គឺត្រូវទឹកធំលិចយ៉ាងខ្លាំង ពាំងទីត្រែងយសោធរបុរៈ កំលិចដែរ ប្រជាកស្តែត្រូវបង់ដីវិត ទឹងខ្លួចខាតរបស់ទ្រព្យជាច្រើន ។ ចំណែកខាងចាម្ប៉ាកាលបានដំណឹងនេះហើយ ក៏ម្ចីម្នាលើកទ័ពទូកយ៉ាងធំ មកវាយប្រទេសកម្ពុជា ប្លន់ថែមទៀត ។ វេលានោះខាងកជការខ្មែរគ្មានអ្វីទប់ទល់ចាម្ប៉ាបានទេ ដោយហេតុ

១ – ត្រូវច្បាំងដោយទូក, ទូកចំបាំងខ្មែរកងវេលានោះគ្មាន, ទូកចំបាំងដែលគ្រប់សាង សន្សំទុកសម្រាប់ការពារប្រទេសដូចកងរដ្ឋការព្រះបាទជយវរ្ម័នទី ២ ទឹងព្រះបាទយសោវរ្ម័នទី ១ ជាដើមនោះ បានខ្លួចខាតអស់ទៅហើយ កងរដ្ឋការតៗមក ឃើញហាក់ ដូចជាធ្លេសកងរឿងនេះ ទើបខ្លះប្រើ ។

២ – ពួកសេនាធាហានឬពួកប្រជាកស្តែវេលានោះ ត្រូវទឹកធំលិចគិតតែផ្គត់ផ្គង់ដីវិតរបស់ខ្លួនរៀងខ្លួន មិនអាចនឹងមកជួយការពារបាន ។

៣ – ព្រះបាទហស៌វរ្ម័នទ្រង់ព្រះជកញ្ជូសណាស់ទៅហើយផង ប្រហែលជាគ្មានអ្នកណាជាមេគំនិតគិតទប់គ្រោះថ្នាក់ ដែលហូរចូលមកយ៉ាងរួសរាន់នេះបាន ។

កាលទ្រង់ជ្រាបដំណឹងសឹកនេះហើយ ក៏គ្រាស់ឲ្យព្រះកជវង្សានុវង្ស

ទឹងពួកមន្ត្រីធំតូចខ្លះ នាំគ្នាចុះខ្លួកតាមដែលមាន ត្រមង់ជញ្ជូនព្រះ
ភជ្ជៃព្យដែលមានខ្លឹមសារ .. ហើយទឹងរបស់សម្រាល ។ ដែលល្មមដឹក
ជញ្ជូនយកទៅបាន ។ ព្រះតែរមែកតដែលជារបស់មង្គល ក៏ត្រូវនិមន្ត
ចុះខ្លួកទៅដែរ ស្រែចហើយទ្រង់ត្រាស់ឲ្យចែវ-អុំទៅសំចតនៅដើង
ភ្នំដងរែកដែលទឹកមិនបានលិច ។

កាលព្រះមហាក្សត្រិយ៍ទឹងពួកបរិពារចេញផុតទៅហើយ កងទ័ព
ចាម្ប៉ាក៏ទៅដល់ព្រះមហានគរ ។ ទ្វារព្រះមហានគរទាំង ៨ ទិស កងវេលា
នោះចំហ គ្មានឥហានសូម្បី ១ នាក់នៅការពារទេ ។ ទ័ពចាម្ប៉ាលើកចូល
ទៅដោយងាយ ឥហានចាម្ប៉ាបានទៅរុករើព្រះភជស្ថានគ្រប់អន្លើ របស់
ណាដែលត្រូវការ ក៏នាំគ្នាជញ្ជូនដាក់ខ្លួកយកទៅ របស់ណាមិនត្រូវការ
ក៏បំផ្លាញចោលខ្ទេចខ្ទីអស់ ស្ទើរតែគ្មានអ្វីសល់នៅ ហើយក៏លើកទ័ព
ត្រឡប់ទៅវិញ ។ ចាម្ប៉ាមានសេចក្តីឥស្សាឈ្នានិះខ្មែរជាបំផុត ក្នុងរឿង
ដែលខ្មែរមានសម្បត្តិជាងនឹងវុងរឿងថ្លៃថ្លាជាង ។ ទ័ពចាម្ប៉ាដែលលើក
មកវាយប្រទេសខ្មែរកាល់ៗជង គ្មានអ្វីក្រៅពីមកជុតបំផ្លាញផ្ទះសំបែង
ហើយទឹងជញ្ជូនយកទ្រព្យរបស់ទៅទេ ទំនងដូចជាទ័ពចោរប្លន់ ។

និយាយពីព្រះអាទិត្យវង្ស ក្សត្រិយ៍មហាឧបភជរបស់ខ្មែរដែលគ្រប់
គ្រងរដ្ឋទ្វារវតី សឹងគង់នៅស្រីអយុធ្យា កាលទ្រង់ជ្រាបតាមានសឹក
ទឹងទីកធំលិចព្រះមហានគរយសោធរបុរៈដូច្នេះហើយ ក៏ត្រាស់ឲ្យឥហាន
រៀបទូកព្រះទីនឹង ទឹងទូកសម្រាប់សេនាឥហានតាមដែលមាន ហើយ

ស្តេចចុះទូកព្រះទីន័ងព្រមដោយសេនាគាហាន មកកាន់ព្រះមហានគរ ដើម្បីនឹងជួយការពារគ្រោះថ្នាក់អំបាលនោះ ។ កាលស្តេចមកដល់ដីតក្នុងនវែក ក៏បានដំណឹងថា ព្រះបាទហសិរ៉ែន្ទ្រព្រមដោយពលបរិពារ ស្តេចចេញមកសំចតនៅដើងក្នុងនវែកហើយ ក៏ទ្រង់ធ្វើងចូលទៅថ្វាយបង្គំព្រះមហាក្សត្រិយ៍ ហើយក្រាបទូលអញ្ជើញស្តេចឲ្យទៅគង់ឯក្រុងស្រីអយុធ្យា ។ ព្រះបាទហសិរ៉ែន្ទក៏ព្រមតាម, ក្សួនទូកព្រះទីន័ងក៏លឿនលយទៅដល់ក្រុងស្រីអយុធ្យា (១) ។

---

១ សេចក្តីព្រួយសង្កេតៈ ព្រះរាជពង្សាវតារក្រុងកម្ពុជាគ្រប់ៗ ច្បាប់ថា ក្រុងនគរធំត្រូវទឹកធំលិចខោះក្នុងរដ្ឋកាលព្រះបាទសេនករាជ ។ ហេតុដែលទឹកលិច បណ្តាលមកពីទោសដែលសម្ងាប់ក្មួនបុរេហិត ។ សេចក្តីថា សម័យមួយខោះព្រះរាជទារសព្រះបាទសេនករាជក្រសាលរុងក្បាលទៀ ហើយក្មួនបុរេហិតលេងពីងពាង ។ ពីងពាងក្មួនបុរេហិតបានទាំសម្ងាប់រុយរបស់ព្រះរាជកុមារ ព្រះនាមសីហនុ ។ ព្រះរាជកុមារទ្រង់ព្រះកន្សែង ពលៀងលួងលោមយំាងណាក៏មិនព្រមស្ងៀម ។ ដ្រាបដល់ព្រះរាជចំការ្រាស់ឲ្យយកក្មួនបុរេហិតទៅដ្រិមុជទឹកស្លាប់បង់ ។ ទោសខេះឯង ដែលបណ្តាលឲ្យទឹកលិចនគរធំ ។ ឯរឿងចំចាំងាចម្ប៉ាន់ខ ពោលធិល់ ។

ចំណែកព្រះរាជពង្សាវតារច្បាប់ខេះថា ព្រះមហាក្សត្រិយ៍សោយរាជ្យក្នុងវិលោះ គឺព្រះបាទ ហសិរ៉ែន្ទទី ៣ ឮនព្រះរាជទារសព្រះរាជធីតាទេ ។ រឿងរុយ - ពីងពាងឮនទេ មានតែរឿងទឹកធំលិច ខឹងរឿងទឹកចាម្ប៉ា ។

យោបល់យើងថា រឿងរុយ - ពីងពាង បើពុកដាមានពិត យើងជឿដាក់ថា ព្រះមហាក្សត្រិយ៍របស់យើងខោះព្រះបាទដ្ឋិបម្តេចក៏ដោយ ឥង់ដាមិនមានព្រះរាជហឫទ័យឃោរឃៅ ធិល់ទៅសម្ងាប់ក្មួនក្មេងដែលមិនទាន់ដឹងក្តីដូច្នេះទេ ។

ព្រះអាទិត្យវង្សបានចាត់ទីកន្លែងថ្វាយគង់តាមសមគួរ រហូតដល់ទៅពួកព្រះពជវង្សានុវង្សនូវកជបរិពារ ក៏ទ្រង់ឲ្យចាត់ទីកន្លែងឲ្យសំណាក់អាស្រ័យនៅទៀតគ្រប់គ្នា ។

គ្រាយដែលព្រះមហាក្សត្រិយ៍ចេញទៅ ព្រះនគរក៏នៅចំហាទេដាយូរខែ ជាហេតុឲ្យអ្នកលោភយសបានឱកាស ខ្លះខ្លាយរកប្រយោជន៍ផ្ទាល់ខ្លួន ។ គ្រានោះ ប្រាកដថា មានបុគ្គល ១ នាក់ដែលគេមិនស្គាល់ឈ្មោះ តែប្រហែលជាជាតិក្សត្រិយ៍ ព្រមដោយព្រាហ្មណ៍មួយនាក់ ជាអ្នកលោភយសលើសលន់ បានផ្តើមរួបរួមសេនាអេហ៎ពលបានជាច្រើនហើយ ក៏ទៅតាំងទីសំណាក់ព្រះនគរនៅខាងជើងក្នុងដងវែកដោយបំណងនឹងគ្រប់គ្រងកម្ពុជរដ្ឋ ។

ក្នុងពេលជាមួយគ្នានោះ មានព្រះពជវង្ស ១ អង្គព្រះនាមជយវ៌្មន កាលទ្រង់ជាបហេតុនេះ ក៏ទ្រង់ធក់យកឱកាសដ៏ខ្វីនោះ រួបរួមសេនាគាហានច្រើនហើយ ក៏លើកចូលទៅគ្រងបល្ល័ង្កនៅក្រុងស្រីយសោធរបុរៈបានមុន ។ កាលទ្រង់ចូលទៅតាំងស៊ុបសួនហើយ ទ្រង់ក៏លើកទ័ពទៅកំចាត់អ្នកតាំងនគរនៅខាងជើងក្នុងដងវែកបង់ ។ តាមដំណឹងថា ទ្រង់សម្លាប់អ្នកម្ចាស់នគរនោះបាន ហើយស្តេចលើកទ័ពត្រឡប់មកព្រះនគរវិញ ។

(មានត)

ប្រវត្តិរបស់អេសុប

លោកផេង - ជ្រឿ សាស្ត្រាចារ្យនៅអនុវិទ្យាល័យនារី ភ្នំពេញ

ប្រែពីបារាំងមកជាខ្មែរ

(ភាគ៣)

មានសំឡាញ់របស់សង្ឃរូម្នាក់ បានឮសេចក្តីអធិប្បាយដូច្នោះក៏មានវាចាថា "អ្នកបំរើរបស់លោកនេះ ចំជាមានប្រយោជន៍ដល់លោកពេក ព្រោះវាបុនប្រសប់រកអ្នកឯណាស្មើគ្មាន គឺវាចេះញ៉ាំងទន្ទីសេចក្តីអត់ធន់របស់អ្នកជ្រាជ្រៅតាំងនៅឯបាន ។ អេសុបឆ្លើយថា លោកចាំបាច់មានប្រសាសន៍ឲ្យនឿយព្រួយអំពីរឿងនេះ ។ សង្ឃរូមឮសំដីដូច្នោះ មិនពាន់អស់ចិត្ត នៅចង់ចាប់លោកទៀត ក៏ប្រាប់ថា: ចូរឯងទៅរកមនុស្សណាដែលមិនចេះព្រួយនឹងអ្វីសោះ យកមកឲ្យអញឲ្យបានកុំខាន ។

ស្អែកឡើង អេសុបទៅឯទីផ្សារ ចាំគយគន់មើលមនុស្ស, លោកបានឃើញអ្នកស្រែម្នាក់ បើឈរមើលអ្វី មើលដូចគ្មានគិតគ្មានពិចារណា នៅត្រងើយកន្តើយដូចថ្មអកតា ។ លោកនាំអ្នកនោះទៅឯផ្ទះប្រគល់ឲ្យចៅហ្វាយរបស់លោកហើយប្រាប់ថា: ហ្នឹងហើយមនុស្សមិនចេះព្រួយ ដែលលោកត្រូវការចង់ឃើញ ។ សង្ឃរូមប្រើប្រពន្ធឲ្យទៅដាំទឹកឲ្យក្តៅអ៊ុន ។ ហើយយកមកលាងជើងរបស់អ្នកដំណើរដោយខ្លួនឯង ។ អ្នកនេះពោះបីដឹងថាការធ្វើយ៉ាងហ្នឹងមិនគួរដល់អាត្មាទេ ក៏នៅតែស្ងៀម

បណ្តាយតាមតែគេធ្វើដូចម្តេចក៏ដោយ ហើយគ្រាន់តែនឹកថា: ប្រហែលជាលប់ស្រុករបស់គេធ្វើដូច្នេះដឹង! ។ រួចគេហៅវាឲ្យទៅអង្គុយត្រង់កន្លែងយ៉ាងស្អាតជាកន្លែងកិត្តិយសរបស់គេ; អ្នកស្រែចេះតែអង្គុយគ្មានប្រែកែក ។ ពេលចប់ សង្ឃុះគិតតែពីស្តីឲ្យចុងភៅ: សម្លប៉ុន្មានចេះតែមិនឆ្ងាញ់ចាំងអស់ ម្ហូបណាឆ្ងាញ់ល្មមខ្លួនឯង លោកថាប្រៃពេក ម្ហូបណាប្រៃលោកថាល្មម ។ អ្នកស្រែខឹងបើសង្ឃុះថាអ្វីក៏ដោយគិតតែពីស៊ីពេញ ។ មាត់ឃ្មុំ ។ មិនរវល់ថាអ្វីសោះ ។ ពេលបង្អែមគេយកនំដែលប្រពន្ធរបស់លោកធ្វើមកដាក់លើតុ ។ សង្ឃុះពោលថា: ចុះនំនេះអីក៏គ្មានឆ្ងាញ់សោះ ។ តែនំនោះឆ្ងាញ់មានទុជាវរសយ៉ាងប្រៃពេក ។ រួចលោកមានប្រសាសន៍ថា: ខ្ញុំមិនដែលឃើញអាណាធ្វើនំអីក៏អាក្រក់ម្ល៉េះត្រូវយកអ្នកដែលៈធ្វើនំទៅជុតក្លឹងចោល ព្រោះវាធ្វើអ្វីមិនដែលបានល្អសោះ ចូរគ្រាប់ឲ្យអ្នកណាយ៉ាកចាប់ខ្សែមក អញនឹងជុតមេចង្រៃនេះចេញ ។ អ្នកស្រែលោតធ្លើយថា: ឈប់ ។! ចាំខ្ញុំទៅយកប្រពន្ធរបស់ខ្ញុំមកជុតជាមួយផង កុំឲ្យពិបាកធ្វើគំនរច្រើនកន្លែង ។ សំដីរបស់អ្នកស្រែនេះ នាំឲ្យសង្ឃុះខាល់គំនិត ឈប់សង្ឃឹមក្នុងការយកខោសចំពោះអេសុបតាំងពីថ្ងៃនេះតទៅ ។

ម្យ៉ាងទៀតមិនត្រឹមតែនាយចៅហ្វាយរបស់លោកឡើយ ដែលលោកធ្វើឲ្យមានរឿងគួរឲ្យអស់សំណើច ហើយនឹងពោលពាក្យយ៉ាង

ត្រូវតែគួរឲ្យសរសើរ លោកមានន័យយ៉ាងនឹងអ្នកដទៃទៀតដែរ។ សម័យមួយ អេសុបទៅផ្សារចុងជួបនឹងសុភាពបុរសម្នាក់ ។ អ្នកភាត់ដាវពេជ្រនេះសួរលោកថា: ចុះឯងទៅណាមកណា? ។ ពេលនោះមិនដឹងជាអេសុបកំពុងតែស្ទុងចិត្តកន្ត្រាក់អារម្មណ៍ប្លែកឬ កំពុងតែគិតអ្វីជាប់ចិត្តស្រាប់តែឆ្លើយតបទៅកេះលោកសុភាថា: ខ្ញុំមិនដឹងជាទៅណាមកណាទេ ។ លោកសុភាស្មានជាអេសុបនិយាយកោងគ្មានសេចក្តីគោរពកោតក្រែង ក៏ឲ្យគេនាំលោកយកទៅដាក់គុកប្រដៅ ។ ពេលដែលអ្នកឆ្មាំទ្វារពៀបនឹងបញ្ចូលលោកទៅក្នុងគុក លោកនិយាយឡើងថា: ម្តេច! លោកមិនយើញទេឬ? សំដីដែលខ្ញុំដំរាបលោកអម្បាញ់មិញចំពេញជាត្រូវអស់យ៉ាង គឺខ្ញុំដឹងថាគេបញ្ជូនខ្ញុំឲ្យទៅតាមកន្លែងដែលខ្ញុំបាទត្រូវការ ។ លោកសុភាឮសំដីប៉ុណ្ណោះក៏ឲ្យគេដោះលោកលែង ហើយនិយាយថ្កាប់ថ្កូរថា: អ្នកមានភ្នែកម្នាក់ឈ្មោះអេសុបចំជាមានបញ្ញាវាងវៃមែន ។

សង្កេតដែលយើញអេសុបមានប្រយោជន៍នឹងហុចក្តីឈ្មោះឲ្យដល់ខ្លួន ក៏ឈប់រង់ឲ្យលោកដើរចេញហួសពីអាត្មា ។

ថ្ងៃមួយសង្កេតនឹងកូនសិស្សទាំងឡាយរបស់គាត់នាំគ្នាជឹកស្រាលេងសប្បាយ ។ អេសុបជាអ្នកបំរើក្បែរ លុះយើញគេជឹកខ្លាំងពេក គ្រូក៏ស្តីគ្នាទឹងសិស្ស, លោកមានប្រសាសន៍ពន្យល់ថា: ការជឹកស្រានេះមានញ្ញាក់ទី ១ នាំឲ្យឆ្ងាញ់, ទី ២ ស្រវឹង, ទី ៣ នាំឲ្យកាចមិនដឹងខុសត្រូវ។

គ្រូធំងសិស្សទាំងឡាយមិនអើពើនឹងសំដីរបស់លោកសោះ គិតតែនាំគ្នាផឹក ។ សង្ឃុះផឹកបាល់តែស្រវឹងវង្វេងស្មារតី ហើយអួតខ្លួនថា: ស្អែកនេះនឹងអាចផឹកទឹកសមុទ្រទាំងអស់បាន ។ ពួកភិក្ខុវិញជូរឆ្ងោះនាំគ្នាសើច ។ សង្ឃុះឆ្លើយឡើងថា: ខេតុំសើច! អញនិយាយមែនខែន អញហ៊ានភ្នាល់ដាក់ផ្ទះរបស់អញហ្នឹង ស្អែកបើកដជាអញអាចផឹកទឹកសមុទ្រទាំងអស់បាន ។ ដើម្បីធ្វើឲ្យគេជឿជាក់ សង្ឃុះដោះចិញ្ចៀនដែលពាក់នៅដៃឲ្យគេកាន់ទុកជាបញ្ចាល់ ។

លុះព្រឹកឡើងចៅហ្វាយរបស់លោកស្វាងពីស្រវឹង ភ្ញាក់ខ្លួនដោយបាត់ចិញ្ចៀនពីដៃដែលជាទីពេញចិត្ត ។ លោកថ្កុំថ្កើចៅហ្វាយរបស់លោកថា: ចិញ្ចៀនហ្នឹងអន្តរាយហើយ ព្រមទាំងផ្ទះផង ព្រោះលោកបានភ្នាល់នឹងគេថា នឹងផឹកទឹកសមុទ្រទាំងអស់បាន ។ ពេលនេះអ្នកជ្បាងខាងទស្សនវិជ្ជាភ័យខ្លួន អង្វរអេសុបឲ្យជួយ តើធ្វើដូចម្តេចនឹងដោះខ្លួនរួច? ។ អេសុបប្រាប់ឲ្យឆ្លើយដូចសេចក្តីខាងក្រោមនេះ ៖

ដល់ពេលសន្យា ពួកមនុស្សទាំងឡាយក្នុងស្រុកសាមូស នាំគ្នាទៅឯមាត់សមុទ្រ ដើម្បីចាំផ្ញាល់ទូវិលោកសង្ឃុះ ។ អ្នកគូភ្នាល់គិតថាឈ្នះជាស្រេច ។ សង្ឃុះក្រោកឈរឡើង ហើយនិយាយនៅកណ្តាលប្រជុំជនទាំងឡាយថា: នែ លោក! អ្នកទាំងអស់គ្នាចាំស្តាប់ ខ្ញុំពិតជាបាននិយាយភ្នាល់ថាអាចផឹកទូវទឹកសមុទ្រទាំងអស់មែន តែមិនមែនផឹក

តាំងទឹកខន្ទេប៉ុន្មានដែលហូរធ្លាក់មកក្នុងសមុទ្រនោះផងឡើយ ។ ហេតុនេះឈ្មោះណាដែលក្តាល់ទឹងខ្ញុំ ត្រូវបង្ហិលផ្លូវទឹកនៃខន្ទេតាំងប៉ុន្មាននោះចេញ. ខ្ញុំនឹងផឹកទឹកសមុទ្រឲ្យមើល ។ មនុស្សតាំងអស់នាំគ្នាគោតបញ្ញារបស់សង្ឃដែលចេះអាចដោះខ្លួនរួចក្នុងគ្រាក្រ ។ កូនសិស្សតាំងឮយ អ្នកក្តាល់បបួលគ្នាសុំខមាទោសលោកគ្រូ ហើយខលួសសុះចិត្តយ៉ាមចាញ់ ។ រួចគេនាំគ្នាជង្រែលោកគ្រូគគ្រឹកគគ្រែងត្រឡប់ទៅផ្ទះវិញ ។

ដើម្បីតាតុណបំណាច់ អេសុបសុំចេញជាកូដ្ឋិសបុគ្គល ។ ចៅហ្វាយរបស់លោកមិនព្រមឲ្យចេញ ហើយថ្កាប់ថា: ពេលនេះមិនល្អ ប៉ុន្តែល្អើយចុះបើចង់ចេញណាស់ អញក៏ព្រមឲ្យចេញដែរ តែឯងប្រយ័ត្នប្រផ្លុសក្នុង ពេលចេញពីផ្ទះទៅ បើល្អគឺឃើញមានសត្វអន្ទេបពីរដំខន្ធឹមគ្នាបើយើញតែមួយ គឺមុខជាមិនរួចពីធ្វើជាចាវអញទៀតឡើយ ។ អេសុបដើរចេញទៅក្តាម ។ គ្រាន់តែដល់ក្រៅរបង លោកឃើញអន្ទេបពីរដំប្រចឹកនៅពីមុខ ។ ឃើញដូច្នោះលោកប្រញាប់ត្រឡប់ចូលមកផ្ទះ ថ្កាប់ចៅហ្វាយរបស់លោកថា: ខ្ញុំបានឃើញអន្ទេបពីរ ។ សង្ឃុះចេញទៅរកមើល ហើយឃើញតែអន្ទេបមួយ អាមួយទៀតហើរទៅបាត់ ។ ចៅហ្វាយរបស់លោកខឹងឈួលហើយនិយាយថា: អាឯងប៉ះកន្តុអញជាទិច្ច ចូរអាណាយកតំបាត់បង្ហាមកវាយអានេះ ។ គេកំពុងតែវាយលោក ស្រាប់តែមានមនុស្សម្នាក់មកអញ្ជើញសង្ឃុះទៅស៊ីលៀង ។

La Lumières de l'Asie

លោកស៊ីរ - អេតវ៉ាំងអារណ្ណូលដ៏ តែង

លោក ប៉ាយ - ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(ពន្ធ)

ព្រះពោធិសត្វមាន ...បន្ទូលដោយពាក្យទន់ភ្លន់ ប្រកបដោយព្រះទ័យ អាណិតអាសូរពន់ពេក ។ សភាពដ៏វិសេសវិសាលយ៉ាងនេះ ប្រកប ដោយព្រះទ័យករុណាធំសុចរិតធម្មិទ្ធិទ្ធ ព្រះអង្គកន្ធរពេលនោះ បាន ជាពួកព្រាហ្មណ៍ចាន់លះបង់ដៃ ដែលប្រឡាក់ដោយលោហិតចាកចេញ ពីសន្ធាន ហើយព្រះមហាក្សត្រិយ៍ចូលទៅជិតព្រះពោធិសត្វលើកព្រះ ហស្តធ្វើអញ្ជលិកម្មគោរពចំពោះព្រះអង្គ ។

តែព្រះពោធិសត្វបានសំដែងថា: លោកមុខជាបាននូវសេចក្តីសុខ បើ សត្វទាំងអស់មាននូវសេចក្តីមេត្តាករុណាអាណិតអាសូរគ្នាទៅវិញទៅមក ហើយបរិភោគ តែរបស់បរិសុទ្ធស្អាត គ្មានប្រឡាក់ដោយលោហិត គឺគ្រាប់ដែលមាន សម្បុរដូចមាស, ផ្លែឈើមានស្មានភាពភ្លឺ, ស្មៅដែលមានក្លិនរស ដែល ដុះនៅពាសពេញក្នុងលោក; ទឹកដែលមាននៅលើផែនដីល្អមត្រៃប់គ្រាន់ ឲ្យសត្វផឹកបាន ។ ពេលភាពនៃព្រះតថាគតព្រះពោធិសត្វប្រកបដោយពាក្យ ពីពេះអស្ចារ្យ ធ្វើពួកព្រាហ្មណ៍ឲ្យដឿងាក់ឮស្កប់ក្នុងចិត្ត, ត្រឡប់ជារំលឹង

ឯនន្ទវៀបូជនីយដ្ឋានដែលមានគ្រឿងសក្ការៈអុជ ហើយគ្រាត់ដែកដែលសម្រាប់ធ្វើពលិកម្មចោលទៅខ្ទាយ ។ ដល់ថ្ងៃស្អែកឡើង, ព្រះមហាក្សត្រិយ៍មានព្រះរាជឧទ្ទារទៅភ្ជុកអាមាត្យឲ្យស្រែកប្រកាស ក្នុងព្រះរាជអាណាចក្រ, ហើយទ្រង់ត្រាស់បង្គាប់ឲ្យធ្វាក់ជាអក្សរនៅផែនថ្ម នឹងតស់សសរថា: "នេះជាព្រះរាជបញ្ញត្តិព្រះករុណាជាម្ចាស់ដីវិតលើត្បូង: តាំងពីមុនមកដល់បច្ចុប្បន្ននេះ, គេបានពិឃាតសត្វ ដើម្បីនឹងបូជាយ័ញ្ញបូបរិភោគជាអាហារ, តែពីថ្ងៃនេះតទៅ ហាមផ្តាច់មិនឲ្យសម្លាប់សត្វសម្បូបរិភោគសាច់សត្វ ព្រោះយើងបានយល់ថា ជីវភាពមានតែមួយ ហើយសេចក្តីមេត្តាសម្រាប់ប្រើទៅសត្វណាដែលគួរមេត្តា" ។ នេះជាព្រះរាជបញ្ញត្តិព្រះមហាក្សត្រិយ៍បានប្រកាសឡើង, ហើយតាំងពីកាលនោះមក, សត្វដែលមានជីវិតបានទទួលសេចក្តីសុខ គឺព្រះពោធិសត្វព្រមទាំងសត្វជាបរិវារព្រះអង្គ នឹងបក្សាទាំងប៉ុន្មានដែលស្ថិតនៅប្រជុំនគរគង្គា, ជាទីដែលព្រះអង្គបានទេសនាដោយព្រះទ័យករុណាដល់សត្វទាំងនោះ នឹងព្រះសូរសៀងពីពោះអស្ចារ្យ ។

ព្រោះព្រះទ័យព្រះពោធិសត្វប្រកបដោយព្រហ្មវិហារចំពោះសត្វដែលមានជីវិតនៅក្នុងលោក ដែលទទួលនូវសេចក្តីសុខ - ទុក្ខដូចយើងទាំងអស់គ្នា; មានសំដែងក្នុងគម្ពីរពីបុរាណកាល, តាំងពីព្រះសម្មាសម្ពុទ្ធព្រះអង្គបានយោនយកកំណើតជាព្រាហ្មណ៍ម្នាក់នៅកុំមុន្ទ? (មុណ្ឌ:) នៅដីត

កូមិតាលិទ្ធ ? (ទលិទ្ធគ្រាម), កូមិភាគក្នុងប្រទេសលំបាកដោយគ្មានភ្លៀង, ស្រូវដុះមិនទាន់ខ្ពស់ល្មមឲ្យបក្សាគ្រួចច្រូតបាន, ទទួលស្ងាប់មួយរំពេច; នៅតាមដងព្រៃភាគខ្លះ ចេញចំហាយក្តៅដប់ទឹករ័ងអស់ពីចិត្តពាង, ស្មៅទឹងរុក្ខាលតាវល្លីនៅដាមានសភាពស្វាំងក្រៃម, ហើយពួកសត្វដែលនៅក្នុងព្រៃក្នុងគេមរង្គើងផ្លូវ ដោយទំនេរអាហារបរិភោគ ។ ក្នុងពេលនោះព្រះពោធិសត្វទ្រង់បានទតឃើញតាមដងផ្លាំងដែលមានចំហាយក្តៅហុយ មានវល្លី "នុល្ហ:" ដុះព័ទ្ធ នូវខ្លាញ់មួយស្លាំងស្តុមដោយអត់អាហារស្ទើរតែនឹងមរណា, និន្នាលើផែនសិលា, សេចក្តីស្រេកឃ្លានបញ្ចេញឥទ្ធិពល, ចក្ខុមានរស្មីពណ៌ក្រៃតង, ដីភ្លូប្រាសទៅក្រៃមសូតលឿនវែងចេញពីមាត់ហាហត់ស្ទើរផុតដង្ហើម, ថ្ពាល់មានតែស្បែកជ្រួញជ្រីវ, ស្បែកមានគំនូរឆ្អែតជ្រាក់យូរយារ, តាមឆ្អឹងជំនីរដូចជាផ្ទាំងដែលពុកផុយ ដោយសារភ្លៀងមិនអាចតុបនូវដំបូលគេហដ្ឋានបាន ។ ខ្លានោះមានកូនតូច ។ ពីរ, ស្រេកឃ្លានអាហារ, ដើរចុះឡើង ហើយក៏ដញ្ជក់ដោះដែលគ្មានទឹកដោះមួយដំណក់ ។ ចំណែកខាងម្តាយវា ស្គមនៅតែឆ្អឹងខ្ចីកូនតាំងពីរដោយមុទិតាចិត្ត ហើយបង្ហាញឆ្អឹងជំនីរទៅកូនតាំងនោះ ស្រេកកេះចុកណែនដល់ចំពង់ក ដោយសេចក្តីស្នេហាលើសសេចក្តីស្រេកឃ្លានទៅទៀត ហើយដួងភ្លើងមានស្រេកខ្លាំងលាន់ឮរំពងដូចជាសត្វផ្តរយកច្រមុះរុញទៅនឹងដីខ្លាច ។

ព្រះបរមគោធិសត្វ ទ្រង់ឮនូវខ្លាទោះហើយ ទ្រង់កំមានមេត្តាករុណាពន់ពេក រោយមានទំស្រ័យសាធជាតុទ្ធភូមិ ហើយទ្រង់ព្រះតម្រិះថា: "មានតែមេធ្លាប់ឃាយមួយយ៉ាង ដើម្បីទំនិញស្រោចស្រង់សត្វសាហាវដែលទៅកន្លងនៃព្រៃនេះ, ដល់ព្រះសុរិយាអស្តង្គត សត្វទាំងនេះមុខជាស្លាប់មិនខានដោយអត់អាហារ ។ គ្មានចិត្តអ្នកណាទោរទន់ទៅកាន់សត្វដែលមានសភាវប្រឡាក់លោហិតជានិច្ច ហើយសត្វនេះដែលស្កាំងស្កម តែមកតែតិមិនបានបរិភោគឈាម ។ ព្រោះហេតុដូចនេះ, បើអញឲ្យជីវិតសត្វនេះឃ្លាន ដោយហេតុថាគ្មានបុគ្គលណាខ្លួលខ្លុតក្រៃពីអញ, ដោយសេចក្តីមេត្តាជាយ៉ាងនៃកែពេក ខ្លួនអញមុខជានឹងសម្រេចទៅតាមយថាកម្មកន្លងនេះមិនខានទេ" ។ ព្រះបរមពោធិសត្វលុះទ្រង់ព្រះតម្រិះដូចនេះរួចហើយ ក៏ហុចបង់ចោលព្រះសុពណ៌ចាគា, ដំបងទឹងនៃខ្សែអំបោះតិសិដ្ឋ (Cordon Sacré) ឈ្នួតក្បាលទឹងសំពត់ពោះសេយ្យាពស្តើ រួចទ្រង់ចាកចេញពីគុម្ពោតនៃព្រៃនោះ យាងមកតាមដីឡាប់មានព្រះបន្ទូលថា: "នេះមេខ្លាអើយ! នេះជាអាហារបស់អ្នក" ។ ក្នុងមួយរំពេច, ស្រាប់តែខ្លាញីដែលរៀបនឹងស្លាប់នោះបញ្ចេញសព្ទសូរយ៉ាងខ្លាំង ហើយក៏លោតចេញពីកូនវាស្ទុះទៅលើព្រះពោធិសត្វ ដែល

---

១. ខ្សែអំបោះតិសិដ្ឋ គឺខ្សែអំបោះបីសរសៃវេញគួបគ្នា ដែលពួកឧត្តមវណ្ណតែងពាក់ជាកិត្តិយស ។ ការដែលពាក់ខ្សែអំបោះតិសិដ្ឋនេះ គឺត្រូវឲ្យមានតិចមួយរៀបចំជាឧត្តរាភិចំពោះក្មេងដំឡង់ដែលមានអាយុ ៨ ឆ្នាំ ហើយគេតាំងហាឧត្តរាជា (ទ្វិជៈ) ត្រែចា មានកំណើតពីរដង ។

ជាទុក្ខរបុគ្គលដោយពេញចិត្ត, ហើយក៏យកក្រចកដែលមានពណ៌លឿង
យ៉ាងមុតខ្លាំងហែកសាច់ព្រះអង្គនោះ ប្រៀបដូចជាព្រះខ័នមានសកាព
កោនស្រួច ហើយក៏បរិភោគនូវព្រះពោធិសត្វស្រោចដោយលោហិត
ឲ្យសពេញព្រះអង្គ ហើយខ្យល់អស្សាសបស្សាសនៃសត្វសាហាវនោះ
បញ្ចេញចំហាយក្តៅដូចក្តៅឡាយជាមួយគ្នានឹងសព្វថ្លូវនៃព្រះទ័យព្រះ
ករុណារបស់ព្រះពោធិសត្វ គួរឲ្យស្បថស្ងែនពន់ពេក ។

នេះហើយជាករុណាគុណនៃព្រះពោធិសត្វ ហើយឥតាលមុន
នោះទៀត ព្រះអង្គបានធ្វើពលិកម្មចំពោះទេវតាឥន្ទ្រហ្ម ដោយ
សេចក្តីមេត្តាករុណាជាអនេកប្បការ ។ មួយទៀតក្នុងពេលនោះព្រះបាទ
ពិម្ពិសារទ្រង់បានសវនាយល់ច្បាស់នូវភាជវង្សព្រះពោធិសត្វ ព្រមទាំង
កិច្ចដ៏ទុត្តមក្នុងការស្វះស្វែងរកធម៌; បានអង្វរឲ្យព្រះអង្គគង់នៅទីក្រុងនេះ
ហើយក៏មានព្រះរាជឧង្ការថា: "ទ្រង់មានឋានៈជាព្រះរាជបុត្រ! ទ្រង់
មិនគួរមុសរង់លំបាកអត់ឃ្លានដូចនេះទេ; ព្រះហស្តទ្រង់សមនឹងកាន់ព្រះ
ខែ្មាងគទាវុធ (Xeptre), មិនត្រូវកាន់អំបែងសូមទានគេទេ ។ សូមទ្រង់
នៅនឹងយើងទាល់តែអស់ជីវិត, យើងគ្មានព្រះរាជបុត្រគ្រងរាជ្យសោះ
ហើយសូមទ្រង់ធ្វើជាគ្រូបាធ្យាយបង្រៀនដល់យើងនូវគតិបណ្ឌិតឲ្យប្រជារាស្ត្រ
របស់យើងស្វាធ្យាយក្នុងព្រះរាជអាណាចក្រ; ទ្រង់នៅក្នុងប្រាសាទខ្ញុំ
ហើយខ្ញុំនឹងរកនាងនាដ្ឋិយានីមួយថ្វាយ" ។ (មានត)

ឃុនបណ្ណាឆ្កែ ប៊ូ - ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

រៀបរៀង

ពាក្យញុះញង់មានកម្លាំងខ្លាំងជាងខ្យល់ព្យុះដ៏ធំ អាចធ្វើមនុស្សប្តីសត្វឲ្យបែកបាក់ចាកគ្នាទៅជាពួក ។ ជុន ដូចរឿងសត្វហង្សខ្វួនមួយក្បាលពីរដែលមានក្នុងគាថាណាសារជជាតក បញ្ញាសនិបាត ថា:

ឯកស្មឹ តរិ សមយេ កច្ចកបេឡ កុសប្បបសម្ភ-
សម្ពុទ្ធសាសនេ តថា ឯកា ឥត្ថី សាមិកេន អញ្ញ-
មញ្ញំ បដិឥទ្ធចិត្តា អតិវិយ សិនេហបរិសុទ្ធចិត្តា ហោតិ ។

តិរ ជុនតុមកថា សម័យមួយ ក្នុងសាសនាព្រះកស្សបសម្ម-
សម្ពុទ្ធ ព្រះអង្គជុនត្រាស់ឡើងក្នុងកប្បនេះ គ្រានោះមានស្ត្រីម្នាក់
មានចិត្តប្រតិព័ទ្ធស្រឡាញ់ស្នេហ៍ត្រង់គ្នានឹងស្វាមីនៃខ្លួនណាស់ ។ ថ្ងៃមួយ
ស្ត្រីនោះធ្វើសក្ការបូជាប្រគេនបិណ្ឌជុនដល់ព្រះសង្ឃមានព្រះពុទ្ធអង្គជា
ប្រធាន ហើយតាំងសេចក្តីជុនថា " ខ្ញុំទៅកើតក្នុងកំណើតនានា សូមឲ្យ
ខ្ញុំលែងកើតជាស្ត្រី. ឯស្វាមីនៃខ្ញុំសូមឲ្យជុនជាបង្កើបុរសជាទីស្រឡាញ់
ស្មោលស្និទ្ធនឹងខ្ញុំ : មួយទៀត បើយើងខ្ញុំតាំងពីនោះទៅកើតជាសត្វ
តិរច្ឆាន សូមឲ្យខ្ញុំតាំងពីនោះមានសរីរៈពណ៌កាយជាប់ជាមួយគ្នាតែក្បាល
សូមឲ្យបែកចេញពីគ្នា " ។ សម្តេចព្រះបរមសាស្តាទ្រង់ធ្វើអនុមោទនា

រួចហើយ ទើបស្តេចយាងត្រឡប់ទៅកាន់វិហារវិញជាមួយនឹងភិក្ខុសង្ឃ ជាពុទ្ធបរិពារ ។

តាំងពីរលោនោះមក ស្វាម៉ដ្ឋកវិយោតាំងពីរនាក់នោះមានជីវិតរស់នៅក្នុងមនុស្សលោកអស់កាលជាយូរ, លុះដល់ក្សីយដីវិតហើយ ដោយផលបុញ្ញកម្មនេះនាំទៅឲ្យកើតជាកុមារក្នុងត្រកូលម៉ហាសេដ្ឋីមួយជាតិ, ក្នុងត្រកូលព្រាហ្មណ៍មហាសាលមួយជាតិ, ក្នុងត្រកូលខត្តិយមហាសាលមួយជាតិ ។ កុមារតាំងពីរនាក់នោះសម្រាលមកជាមួយគ្នាជាកូនភ្លោះ, កុមារដែលសម្រាលមកមុនជាបង, កុមារដែលសម្រាលមកក្រោយជាប្អូន, កុមារតាំងពីរនាក់នេះស្រឡាញ់គ្នាខ្លាំងណាស់ ។

លុះកុមារតាំងពីរនាក់នោះក្សីយដីវិតហើយ បានទៅកើតជាសត្វហង្សមាស អាស្រ័យនៅក្នុងស្រះឈូកនាព្រៃហិមពាន្ត ។ ហង្សតាំងពីរនោះមានខ្លួនជាប់គ្នា ឯក្បាលបែកចេញពីគ្នាជាពីរ ។ ហង្សក្បាលពីរនោះមានចិត្តគំនិតស្មើគ្នា នឹងទៅរកស៊ីទឹកខ្ទឹងណាក៏ព្រមព្រៀងចិត្តគ្នាទៅ មិនដែលឈ្លោះទាស់ខែងខ្ទឹងគំនិតគ្នាឡើយ ។

ថ្ងៃមួយ មានព្រានព្រៃម្នាក់គ្រាច់ទៅដល់កន្លែងដែលហង្សទៅនោះ ឃើញហង្សមាសក្បាលពីរតួខ្លួនជាប់គ្នាដូច្នោះ គំនឹកអស្ចារ្យក្នុងចិត្ត ទើបត្រឡប់មកក្រាបទូលព្រះបាទពារាណសីឲ្យទ្រង់ជ្រាប ។ គ្រានោះព្រះពោធិសត្វសោយព្រះជាតិជាព្រះបាទពារាណសី ព្រះអង្គបានទ្រង់

ព្រះសណ្តាប់សេចក្តីនោះហើយ ទ្រង់ត្រាស់ប្រទានព្រះពរដល់ទេព្យទីនឹង ស្បៃងអាហារដល់នាយព្រានហើយត្រាស់ថា "បើអ្នកចៀសយកហង្សមាសនោះមកឲ្យយើងបាន យើងនឹងឲ្យសម្បត្តិដល់អ្នកច្រើនជាងនេះទៀត" ។

នាយព្រានព្រៃទទួលព្រះពរជាតម្រាស់ហើយ ក៏ក្រាបថ្វាយបង្គំលាកាន់យកមេណ្ឌសិង្គដ្ឋចេញចាកព្រៃនគរចូលទៅកន្លែងព្រៃហិមពាន្ត ចាប់ហង្សមាសក្បាលពីរនោះបានដោយទុបាយនៃខ្លួនហើយ យកមកថ្វាយព្រះបាទពារាណសី ។ ទ្រង់ពេញព្រះទ័យបានព្រះរាជទានទេព្យទីនឹងស្រុកសួយឲ្យនាយព្រាន ព្រះអង្គទ្រង់ទទួលយកហង្សមាសដោយព្រះហស្ត ហើយប្រទានឲ្យអគ្គមហេសីយកទៅចិញ្ចឹមក្បាទុក ។ គ្រានោះ ក្បាលហង្សចាំងពីរមានរស្មីភ្លឺដូចមាស បន្ទឺសំឡេងពីរោះចាប់ចិត្ត ។ ព្រះរាជទេវីសព្វព្រះទ័យណាស់ ត្រាស់បង្គាប់ឲ្យដាក់កន្លែងក្រងមាស ប្រទានលាជទឹកឃ្មុំដាក់ថាសមាសឲ្យហង្សនោះស៊ីសព្វថ្ងៃ ។

ចំណែកខាងក្រោយមក ព្រះរាជទេវីក្រាបទូលព្រះបាទពារាណសីថា "ហង្សមាសក្បាលពីរទួនជាប់គ្នាតែមួយនោះ ប្រសិនបើបែកឲ្យដាច់ចេញពីគ្នាបាន, ហង្សមួយនឹងទុកចិញ្ចឹមក្នុងព្រះរាជនិវេសន៍ ហង្សមួយនឹងឲ្យយកទៅទុកក្នុងសួនសត្វសម្រាប់ឲ្យមហាជនមើលលេង" ។ ព្រះបាទពារាណសីទ្រង់យល់ព្រមតាមព្រះរាជទេវី ទើបបង្គាប់ឲ្យអាមាត្យចាំង

ឡាយមកប្រជុំគ្នាហើយគ្រាស់សួរថា "អ្នកណាអាចនឹងបំបែកហង្សក្បាលពីរនេះឲ្យបែកចេញពីគ្នាជាខ្លួនពីរបាន យើងនឹងឲ្យរង្វាន់ដល់អ្នកនោះ" ។ អាមាត្យម្នាក់ឈ្មោះវៃកង្ខ ១ បាយដែលនឹងបំបែកហង្សឲ្យទៅជាខ្លួនពីរបាន ក៏ក្រាបទូលព្រះរាជាសូមទទួលយកអាសានឹងធ្វើថ្វាយ ។ ព្រះរាជាទ្រង់ព្រះរាជទានទៀងជារង្វាន់ ហើយប្រគល់ហង្សមាសឲ្យអាមាត្យនោះយកទៅ ។ អាមាត្យនោះ ទទួលយកហង្សទៅចិញ្ចឹមរក្សាទុកក្នុងផ្ទះរបស់ខ្លួន ។

ចំណេរកាលខាងក្រោយមក ថ្ងៃមួយ អាមាត្យនោះចូលទៅគាល់ព្រះមហាក្សត្រហើយវិលមកផ្ទះវិញ ទុនឲ្យបដិតក្បាលហង្សម្ខាងនិយាយឃ្លាវ ។ ធ្វើដូចជាប្រាប់រឿងស្ងាត់កំបាំងហើយចៀសចេញទៅ ។ ចំណែកហង្សម្ខាងទឹកសង្វ័យ ក៏សួរហង្សជាសំឡាញ់ថា "អម្បាញ់មិញនេះអាមាត្យខ្សឹបប្រាប់អាថ៌កំបាំងអ្វីនឹងអ្នក ។ ចូរប្រាប់ឲ្យយើងដឹងផង" ។ - សំឡាញ់! ខ្ញុំគ្មានតែឮគេនិយាយ ប៉ុន្តែមិនដឹងគេប្រាប់រឿងអ្វីទេ ខ្ញុំស្តាប់មិនច្បាស់សោះ ។ - សំឡាញ់! ខ្ញុំមិនដឿអ្នកទេ រឿងនេះខ្ញុំបានឃើញច្បាស់នឹងភ្នែកខ្ញុំ អ្នកមើលងាយខ្ញុំហើយ ខ្ញុំរាប់អានថាជាមិត្តសំឡាញ់មកយូរដល់ប៉ុណ្ណោះ ដោយសំគាល់ថាចិត្តស្មោះត្រង់នឹងគ្នា អ្នកស្មានថាខ្ញុំដេកលក់មិនដឹងខ្លួនបានជាហ៊ាននិយាយប្រាប់មនុស្សដទៃឲ្យគេដឹងចិត្តអស់ ចិត្តអ្នករៀបមិនស្មោះត្រង់នឹងខ្ញុំទេ, តាំងថ្ងៃនេះទៅខ្ញុំលែងទុកចិត្តអ្នកហើយ ។

ហង្សម្ខាងទៀតនិយាយច្រាបដូចម្តេច កំហង្សម្ខាងនោះមិនដឿ
សោះ ចេះតែបែកចិត្តចេញពីគ្នាកាន់តែខ្លាំងឡើង ។ កន្លងមកពីបីថ្ងៃ
អាមាត្យនោះបានទៅនៅខ្សឹបខ្សៀវតែក្បែរត្រចៀកហង្សម្ខាងទៀត ឮតែ
ខ្សាវ។ មិនច្បាស់សេចក្តីថាជាអ្វី ដើរអាការដូចគាលទៅនៅខ្សឹបនឹងហង្ស
មុននោះ ។ ហង្សម្ខាងសាកសួរទៅ, ហង្សម្ខាងក៏ច្រាបដំណើរដូចគ្នា
ពីលើកមុន ។ ហង្សទាំងពីរលែងខ្វល់ចិត្តគ្នាលែងដឿគ្នាទៅវិញទៅមក
កើតទៅជាឈ្លោះប្រកែកធំដុំឡើងនិយាយគ្នាថា "តាំងពីយូរយារណាស់
មកហើយ សូម្បីមានទោសខុសឆ្គងមិនត្រូវចិត្តឬក៏ភ្ញាក់ភ្ញាត់យ៉ាងណាក្តី
យើងមិនដែលធ្វើអ្វីដល់គ្នាទេ ឥឡូវនេះអ្នកប្រកាន់យកតាក្យសំដីរបស់
មនុស្សដែលទើបនឹងមកជួបតែមួយរំពេចប៉ុណ្ណោះ ក៏ត្រឡប់ជាកាត់
ចោលសេចក្តីល្អដែលមានយូរណាស់មកហើយ តាំងពីថ្ងៃនេះទៅអ្នក
កុំនិយាយនឹងយើងទៀតឡើយ" ។ ហង្សទាំងពីរឈ្លោះប្រកែកគ្នាកាន់
តែតឹងសំឡេងខ្លាំងឡើងហូតដល់ដេរប្រទេចគ្នា ហើយទះស្ទាបប្រចឹក
គ្នា ។ ដោយអំណាចសេចក្តីក្រោធឹងខ្លាំងពេក សរីរកាយនៃហង្សក៏
បែកចេញជាពីរផ្នែក ។

អាមាត្យនោះឃើញហើយក៏នាំយកហង្សទាំងពីរទៅថ្វាយព្រះមហា-
ក្សត្រ, ព្រះអង្គទតឃើញក៏មានព្រះទ័យសោមនស្សណាស់ ទើបព្រះរាជ
ទានទ្រព្យនឹងស្រុកស្មួយឲ្យអាមាត្យ ហើយទ្រង់ព្រះរាជទានសត្វហង្ស

មួយឲ្យចិញ្ចឹមខុកកង់ព្រះពាដនិវេសន៍ ហង្សមួយទៀតឲ្យយកទៅចិញ្ចឹមខុកកង់សួនសត្វ រួចព្រះអង្គត្រាស់សួរអាមាត្យនោះថា "អ្នកធ្វើទុបាយដូចម្តេចបានជាហង្សបែកខ្ញុំនចេញពីគ្នាទៅជាពីរបាន" ។ អាមាត្យក្រាបទូលតាមអាការដែលខ្លួនធ្វើឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។

ព្រះបាទពាកណសីទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយ ក៏មានព្រះទ័យសង្វេគ ត្រាស់ថា "គួរឲ្យស្តុតចិត្តណាស់! ហង្សមាសក្បាលពីរខ្លួនជាប់គ្នាតែមួយ ជាសំឡាញ់ស្មោលស្និទ្ធនឹងគ្នាខ្លាំងដល់ម្ល៉ោះ កាលបើមានអ្នកដទៃទៅនិយាយញុះញង់ឲ្យបែកចាកគ្នា ក៏ប្រកាន់យកសំដីដែលញុះញង់នោះជាអារម្មណ៍ មិននឹកនាដល់ការពាក់អានស្រឡាញ់គ្នាមកយូរហើយ ត្រឡប់ទៅជាបែកចិត្តចេញពីគ្នាបាន, នឹងចាប់និយាយទៅថ្វី ដល់ហេតុដទៃ។ សូម្បីប្រជាជនទាំងពួងដែលឥតគំនិតមិនបានគិតពិចារណា ប្រកាន់យកតែពាក្យដែលគេនិយាយញុះញង់នោះជាធំហើយ ក៏មុខជាបែកចិត្តពីគ្នាមិនខានឡើយ ។

ឯមនុស្សដែលបែកចិត្តគំនិតចេញពីគ្នាមានច្រើនប្រភេទ គឺពួកខ្លះបែកគ្នាដោយការប្រកួសប៉ះយគ្នា ពួកខ្លះបែកគ្នាដោយសេចក្តីគ្រោធទំង, ពួកខ្លះបែកគ្នាដោយលាភសក្ការៈ ឬដោយសេចក្តីស្រឡាញ់នាយចៅហ្វាយរបស់ខ្លួនហើយដួយកាន់ដើង, ពួកខ្លះបែកគ្នាដោយសារដណ្តើមឆ្នើកដកថ្ម, ពួកខ្លះបែកគ្នាដោយសារមានតណ្ហាជាន:ដែលបែកខ្វែកគ្នា

ឬដែលឥតបញ្ញាគិតពិចារណា, ពួកខ្លះបែកគ្នាគ្រោះដណ្តើមយកស្រុក ទេសស្រែចំការគ្រួមិត្តគ្នា ឬដណ្តើមយកគោក្របីដំរីសេះខ្ញុំប្រុសស្រីគ្នា, ពួកខ្លះបែកគ្នាព្រោះមិនដឹងគុណកូបការ ដែលធ្លាប់មានដល់គ្នាជាយូរមកហើយ, ពួកខ្លះប្រមូលដុំរឿងបន្តិចបន្តួចបង្កើនឲ្យទៅជាច្រើនធំប៉ុនភ្នំ ធ្វើគុណច្រើនដែលមានមកហើយឲ្យវិនាសឥតចេះ ។ មនុស្សអ្នកដឿស្តាប់ពាក្យដែលគេនិយាយញុះញង់ហើយ កាលមុនដំបូងគ្រាន់តែធ្វើឲ្យកើតទោសបន្តិចបន្តួចទេ លុះយូរទៅចេះតែពូតដុំផ្សំឲ្យកើតច្រើនឡើងពាល់វេលា ដូចអ្នកបង្ហូរទឹក មុនដំបូងគេដឹកប្រឡាយទឹកឲ្យហូរតែបន្តិច ។ លុះយូរទៅទឹកនោះហូរច្រោះជ្រៅធំចេញទៅទៀត ពាល់តែក្លាយទៅជាព្រែកមួយយ៉ាងធំដូច្នោះ ។ មួយទៀតបុគ្គលអ្នកប្រព្រឹត្តញុះញង់គេដោយបិសុណាវាចា ធ្វើស្មារតីឲ្យដូចជាសម្រាមសម្រាប់បង្កាត់ភ្លើង យើញគេក្តាត់ខ្យល់តែបន្តិចបន្តួចក៏ចេះតែបង្កបង្កើតឡើងបន្តិចម្តង ។ ពាល់តែធ្វើឲ្យគេវិនាសខ្ទេចខ្ទីដូចទឹកដែលហូរទៅគាន់ស្ទឹងបឹងត្រពាំង រមែងនាំរបស់ផ្សេង ។ មានស្មៅនឹងដើមឈើជាដើមដែលដុះនៅក្បែរច្រាំងនោះឲ្យបាក់សោត់ទៅតាមផង ។ អ្នកដែលបែកបាក់គ្នារមែងធ្វើខ្លួននឹងរកដៃឲ្យវិនាស, មនុស្សដែលមិនបានតិនិត្យពិចារណាចេះតែជឿសំដីគេញុះញង់ ឈ្មោះថានាំយកហេតុខាងក្រៅមកទុកកង់ចិត្ត . រមែងមានសេចក្តីវិនាសធំ ។

រឿងសត្វចាស៎ល

សសបណ្ឌិតជាតក បុថិមន្ទវគ្គ ចតុក្កនិបាតវណ្ណនា

ព្រះគ្រូសាសនវង្ស គុយ-សូត្រ

ក្រុមជំនុំព្រះវិតែបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

រឿងនេះ ព្រះបរមសាស្តានៃយើងកាលគង់នៅវត្តជេតពន ទ្រង់សំដែងប្រារព្ធនឹងកុដុម្ពិក៍ម្នាក់ដែលនៅក្នុងក្រុងសាវត្ថី ។ កុដុម្ពិក៍នេះជាអ្នកមានសទ្ធាបានចាត់ចែងធ្វើមណ្ឌបរួចហើយនិមន្តព្រះសង្ឃ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន មកថ្វាយបរិក្ខារទាន ត្រេប់មុខឥតខ្វះអ្វី.ឡើយ ។ លុះរួចភាល់ភត្តកិច្ច ព្រះសាស្តាទ្រង់ធ្វើអនុមោទនាកថា ថា: "ការឲ្យទានបែបនេះ ត្រូវតាមក្រសែពួកអ្នកប្រាជ្ញអំពីដំនាន់ដើម ដែលអាចលះជីវិតឲ្យជាទានដល់សូមតាំងពួងបាន" ៖ហើយទ្រង់លើករឿងនោះមកសំដែងដូចតទៅនេះ :

កុងកាលកន្លងទៅហើយ ព្រះរាជាព្រះនាមព្រហ្មទត្ត សោយរាជ-សម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះ ព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ នៅអាស្រ័យក្នុងដងព្រៃ ១ ដែលមានដើងកំព្ន្ធម្ខាង មានស្លឹងម្ខាង ម្ខាងទៀតមានស្រុកបច្ចន្តគាម ។ ក្នុងអរញ្ញប្បទេសនោះ មានសត្វស្វា ១ ចចក ១ នឹងកេ ១ ជាសំឡាញ់គ្នា ចូននៅ

រួមជាមួយនឹងសត្វទន្សាយដែរ សុទ្ធតែជាបណ្ឌិត គឺជាសត្វចេះដឹង តែងនាំគ្នាស្វែងរកអាហារតាមតំបន់ដែនតែរៀងៗខ្លួន លុះរំលងថ្ងៃរសៀលល្ងាចទើបមកជួបជុំគ្នា ។ ចំណែកទន្សាយបណ្ឌិតវិញតែងតាស់ធម៌អាថ៌ឲ្យទន់ទដល់សត្វទាំង ៣ ថា "អ្នកពាល់គ្នាត្រូវឲ្យទាន ត្រូវរក្សាសីល ត្រូវធ្វើឧបោសថកម្មកុំបីខានឡើយ" ។ សត្វទាំងនោះ លុះទទួលទន់ទហើយ ក៏ចូលទៅដេកសម្ងំនៅក្នុងគុម្ពឈើ ជានិច្ចសន្ធឹងតែសព្វខ្លួន ។

ថ្ងៃមួយជាខាងក្រោយមក ទន្សាយបណ្ឌិតក្រឡេកមើលទៅលើមេឃបានឃើញព្រះចន្ទ្រ ភ្លឺក្នុងផ្ទៃអាកាស ក៏ដឹងច្បាស់ថា ស្អែកនេះជាថ្ងៃឧបោសថ ទើបហៅសត្វទាំងនោះមកប្រាប់ថា "ស្អែកនេះ ជាថ្ងៃត្រូវរក្សាឧបោសថ អ្នកទាំងអស់គ្នាចូរសមាទានសីលហើយរក្សាឧបោសថ ព្រោះអ្នកដែលរក្សាសីល ហើយឲ្យទានផង រមែងបានផលច្រើន ហេតុដូច្នោះ កាលបើមានសម្ភារៈអ្វីមួយដើរមកដល់ អ្នកត្រូវតែឲ្យអាហារដែលមានឧជារស" ។ សត្វទាំង ៣ នោះទទួលត្រមតាម ហើយក៏ទៅដេកនៅក្នុងកន្លែងរបស់ខ្លួនវិញម្នាក់ៗ ។ លុះព្រឹកព្រាងឡើង បណ្តាសត្វទាំង ៤ នោះ សត្វតោក៏គ្រាច់ទៅរកអាហារពីព្រលឹម ដើរអើតឆើត ។ សំដៅទៅតាន់ឆ្នេរទន្លេគង្គា ។ គាប់ជួនពេលនោះ មានព្រានសន្ធូចម្នាក់ចាន់ត្រីច្ចិន ៧ កាត់យកវល្ងិដោតជាច្រើនមកបំពុកក្នុងដីឡប់ទៀបមាត់ច្រាំងទន្លេគង្គា ហើយដើរចុះទៅយកត្រីខាងក្រោមទន្លេទៀត ។

ឯកេលុះធុំក្លិនត្រី ក៏កាយដ៏ខ្ពាច់អូសត្រីនោះយកមកហើយស្រែកពាំន ៣ ដងថា "ត្រីនេះមានម្ចាស់ឬទេ?" កាលមិនឃើញមានម្ចាស់ ក៏តាំយកទៅទុកក្នុងគុម្ពឈើជាទីលំនៅ រង់ចាំកាលគួរទ្រង់បរិភោគ រួចដេកពិចារណាសីលរបស់ខ្លួនសិន ។ ឯសត្វចចកបានចេញទៅរកអាហារដែរ ស្រាប់តែទៅតើបពះប្រទេនទឹងសាច់ចំនួចពីរចង្កាក់ តាំងទន្សាយឆ្មើរ ១ ទឹងទឹកដោះខាប់ ១ ជប ដែលអ្នកស្រែម្ចាស់គេដាក់ក្នុងខ្ទម ក៏ស្រែកបន្ទឺ ៣ ដងថា "របស់តាំងនេះមានម្ចាស់ឬទេ?" លុះមិនឃើញមានម្ចាស់ ក៏ពាក់ខ្សែដែលចងជបទឹកដោះឮជក មាត់តាំសាច់ចំនួចនឹងទន្សាយឆ្មើរ យកទៅទុកក្នុងគុម្ពឈើជាលំនៅខ្លួន គិតថាចាំដល់ពេលគួរសឹមអញបរិភោគហើយដេកពិចារណាសីលរបស់ខ្លួនដែរ ។ ឯតានវិញក៏ចូលទៅកាន់ដងព្រៃ បេះបានផ្លែស្វាយទុំយកមកទុកក្នុងគុម្ពៈឈើជាទីលំនៅខ្លួនហើយគិតថា "អញចាំដល់ពេលទើបរិភោគ" ក៏ដេកពិចារណាសីលរបស់ខ្លួនដែរ ។ ថ្លែងឯទន្សាយបណ្ឌិត គិតថា "ចាំដល់ពេលស្រួលអញនឹងចេញទៅស៊ីស្មៅចិញ្ចឹន តែបើមានពួកសត្វមកដើរមកកាន់សំណាក់នៃអញៗនឹងឲ្យស្មៅដល់គេដូចម្តេចកើត សូម្បីតែលុយអង្កាំជាដើម របស់អញក៏គ្មានដែរ, ប៉ុន្តែប្រសិនបើមានសត្វមកមែន អញនឹងឲ្យសាច់សរីរៈរបស់អញពុំខានឡើយ" ។ ដោយអំណាចតេជៈសីលរបស់ព្រះពោធិសត្វ លំនៅនៃសក្កទេវរាជក៏ក្តៅ ។

សេចក្តីដំណាលថា: ដោតុដែលបណ្តាលឲ្យក្តៅដល់ពិភពសក្ក-ទេវរាជ មាន ៤ យ៉ាងគឺ: ដោយសក្កទេវរាជអស់អាយុ ១, ដោយសក្កទេវរាជអស់បុណ្យ ១, ដោយសត្វឯទៀតមានអានុភាពធំធ្វើឫទ្ធានុភាពនៃទេវរាជ ១ ដោយតេជៈសីលរបស់ពួកសមណព្រាហ្មណ៍អ្នកប្រតិបត្តិធម៌ ១, កាលនោះពិភពសក្កទេវរាជក៏ក្តៅ ។

លំដាប់នោះ សក្កទេវរាជពិចារណាមើលទៅ ក៏បានជ្រាបហេតុសព្វគ្រប់ ទើបចង់ល្បងមើលស្តេចខន្ធារីយនោះ ហើយនិម្មិតខ្លួនជាព្រាហ្មណ៍ម្នាក់ ដើរចូលទៅឈរនៅជិតកន្លែងគេជាមុន ។ ក្សត្រិណានោះសត្វគេឃើញហើយក៏សួរថា "តាព្រាហ្មណ៍អើយ! តាអញ្ជើញមកមានការអ្វី?" ។ ឥន្ទព្រាហ្មណ៍តបថា "ម្ចាលអ្នកជាបណ្ឌិត! ខ្ញុំមកនេះប្រាថ្នាតែអាហារ ប្រសិនបើបានបរិភោគតែបន្តិចបន្តួច ខ្ញុំនឹងរក្សាឧបោសថហើយធ្វើសមណធម៌ដែរ" ។ គេធ្វើយថា "ប្រពៃហើយលោកតា! ខ្ញុំអាចដូនពីសាច់បាន" ហើយនិយាយចចាកអាកកជាមួយនឹងព្រាហ្មណ៍នោះដោយគាថា ថា:

សត្ត មេ ភេមិតា មច្ចា ឧឧតា ៩លមុត្តតា
៨ំ ព្រាហ្មណ មេ អត្ថំ ឯតំ កុត្វា វនេ វសាតិ ។

"តាព្រាហ្មណ៍អើយ! ខ្ញុំមានតែគ្រឹត្ថិន ៧ ដែលព្រានសន្ធូចស្រង់ពីទឹកមកពុកលើគោក ខ្ញុំមានតែរបស់នេះសូមអញ្ជើញតាឥសាមច្ចាហារនេះ ហើយទៅធ្វើសមណធម៌ក្នុងដងព្រៃចុះ" ។

ขณะนั้น สหัมบดีพรหมได้กล่าวว่า "ดีแล้วหนอ พระผู้มีพระภาคเจ้า ขอพระองค์จงประทับอยู่เถิด" แล้วท่านได้ไหว้พระผู้มีพระภาคเจ้าแล้วได้หายไปในที่นั้นนั่นเอง ครั้นพระผู้มีพระภาคเจ้าทรงทราบว่าสหัมบดีพรหมนั้นหายไปแล้ว ก็ได้ตรัสพระคาถาเหล่านี้ว่า

ขุสฺส เม เขตฺตชาลสฺส รตฺตึ กตฺวา อชากตา
มิสฺสา จ เทฺว โคชา ฆาตา ตุมฺหากมาคมา
สพฺเพ พฺราหฺมณา เมตฺถ ฆาตา กุตฺวา วเน วสาติ ฯ

"ดูก่อนพราหมณ์ทั้งหลาย ! ตัณหาดุจข่ายดักสัตว์ ที่เราทำไว้ในกลางคืนแล้ว ได้ฆ่าแพะ ๒ ตัว ที่ปนกันมาแล้วนี้ ก็เพราะอาศัยพวกท่านมาแล้ว ดูก่อนพราหมณ์ทั้งหลาย ! ท่านทั้งหลายเหล่านี้ ได้ฆ่าแล้วแล ได้ทำแล้วแล ได้ฆ่าแล้วแล ในป่าแล" ฯ

สหัมบดีพรหมนั้นได้กล่าวคาถาเหล่านี้ว่า

อคฺคุปฏฺฐากา สีตา สีตจฺฉายา มโนรมา
สพฺพา

ត្រជាក់ នឹងមួយឈើត្រជាក់ ជាទីរីករាយចិត្ត សូមអញ្ជើញតា
ពីសាបេះនេះ ចៅយ៉ានៅឆ្ងើសមណធម្មិកឆដ្ឋវត្តចុះ” ។

លំដាប់នោះ ឥន្ទ្រព្រាហ្មណ៍ឱលឱកក្យទទួលអំណរហួចហើយក៏
ដើរហួសទៅដល់លំនៅនៃទន្សាយបណ្ឌិតទៀត ហើយថ្វៃងប្រាប់អំពី
សេចក្តីត្រេកអរចង់បរិភោគអាហារ ហើយនឹងនៅរក្សាឧបោសថសីល ។
ឯទន្សាយបណ្ឌិត កាលឮពាក្យនោះហើយនិយាយថា “តាព្រាហ្មណ៍
អើយ! តាអញ្ជើញមកកាន់សំណាក់របស់ខ្ញុំ ដើម្បីអាហារនេះ ជាការ
ប្រពៃហើយ, ដ្បិតក្នុងថ្ងៃនេះខ្ញុំនឹងបានឱ្យទាន ដែលខ្ញុំមិនធ្លាប់ឱ្យ តែ
បើតាជាអ្នករក្សាសីល មិនធ្លើបាណាតិបាតទេ ចូរតាទៅដង្ហែនឧសមក
បង្កាត់ភ្លើង ឱ្យបានដាវឆើតហើយមកប្រាប់ខ្ញុំវិញ ខ្ញុំនឹងលោតទំលាក់
ខ្លួន ត្រង់កណ្តាលរងើកភ្លើងនោះ, កាលបើសរីរៈសាច់របស់ខ្ញុំឆ្អិនហើយ
ចូរតាយកមកពីសា ហើយធ្លើសមណធម្មិចុះ” ។

កាលទន្សាយពោធិសត្វបរទាជាមួយនឹងព្រាហ្មណ៍ បានពោល
គាថានេះតទៅទៀតថា:

ន សស្សស្ស តំលំ អត្ថិ ន មុក្ខា នបិ តណ្ឌុលា
ឥមិនា អគ្គិនា បក្កំ មមំ កុត្វា វនេ វសាតិ ។

“ទន្សាយមិនមានល្ងមិនមានសណ្តែកបាយទេ សូម្បីតែអង្ករ
ក៏គ្មានដែរ សូមអញ្ជើញតាពីសាសាច់ខ្ញុំដែលឆ្អិនដោយភ្លើង
នេះ ហើយទៅធ្លើសមណធម្មិកឆដ្ឋវត្តចុះ” ។

វេលានោះ ព្រះឥន្ទ្រកំតាក់តែងគំនរក្តឹង ១ សុទ្ធតែរតនៈ ដោយទេវភន្ធុភាព ហើយមកប្រាប់ពោធិសត្វវិញ ។ ខន្ធាយបណ្ឌិតក៏ត្រេកអរជាដំណើរដើរសំដៅទៅឈរជិតរតនៈគំនរក្តឹង ហើយនិយាយថា "ប្រសិនបើមានពួកសត្វល្អិតនៅជ្រកត្រង់ចន្លោះភេមរបស់យើង សូមកុំឲ្យស្លាប់ឡើយ" ទើបរលាស់ខ្លួន ៣ ដងស្រេចហើយ ក៏ដាក់សរីរៈតាំងស្រុងឲ្យជាប្រមុខនៃភាន គឺលោតចំលាក់ខ្លួនចុះទៅលើគំនរគំនរតនៈក្តឹងដែលកំពុងឆេះឆ្ការឆ្ការ ដោយចិត្តរីករាយឥតព្រួយព្រាយ ដូចសត្វពស់ហង្សចុះមកចំលើគំនរផ្កាឈូកក្រហម គួរឲ្យស្ញើចណាស់ សូម្បីតែរណ្តៅភេមសរីរៈរបស់ពោធិសត្វក៏ឥតក្តៅឬឆេះដោយក្តឹងឡើយ គឺបែរជាត្រជាក់ដូចជាគេចូលទៅកន្លែងគំនរទឹកសន្សើមវិញ ។ លំដាប់នោះ ខន្ធាយបណ្ឌិតហៅឥន្ទ្រព្រាហ្មណ៍មកសួរថា "តាព្រាហ្មណ៍អើយ! តាធ្វើក្តឹងឲ្យត្រជាក់អ្វីម៉្លេះ? សូម្បីតែរណ្តៅភេមរបស់ខ្ញុំ ក៏ឥតក្តៅឡើយ ម្តេចបានជាហ៊ានធ្វើនេះ? ។ ឯឥន្ទ្រព្រាហ្មណ៍ឆ្លើយតបថា "ន! ចៅបណ្ឌិតអើយ! ខ្ញុំឯងមិនមែនព្រាហ្មណ៍ទេ គឺជាព្រះឥន្ទ្រពិត ខ្ញុំមកនេះដោយចង់ល្បងមើលទេតើ" ។ ពោធិសត្វក៏បន្ទឹសីហនាទតបថា "បពិត្រទេវរាជ! កុំថាឡើយព្រះអង្គម្ចាស់ឯង បើទុកជាលោកសន្ធិវាសាំងមូលមកចង់ល្បងមើលគានរបស់ខ្ញុំក៏ដោយ ត្រង់របស់អ្វីដែលខ្ញុំមិនឧកចង់ឲ្យនោះគ្មានទេ" ។ លំដាប់នោះ សក្កទេវរាជពោលថា "ម្នាលសប្បបណ្ឌិត! គុណរបស់

អ្នកចូរតាំងនៅក្រោកឯអស់ ។ កំប្បកុះ" ហើយក៏ច្រចាប់តួតថ្កុំបញ្ចេញ ដំរែកទៅតួរកេសជាសេសលក្ខណៈ (គំនូរសត្វខន្ធាយ) ស្លាប់ទឹម ម៉ណ្ឌលព្រះចន្ទ រួចហើយនាំគោធិសត្វទៅឲ្យដេកនៅក្នុងតន្ទែងដដែល ហើយហោះត្រឡប់ទៅគាន់ទេវលោកវិញ ។

ឯសត្វបណ្ឌិតទាំង ៤ រូបបានព្រមព្រៀងគ្នា មានចិត្តស្មោះសរនឹងគ្នា បានញ៉ាំងសីលរបស់ខ្លួនឲ្យពេញបរិបូណ៌ ព្រមទាំងរក្សាឧបោសថ លុះអស់ជីវិតទៅក៏បានទៅកើតក្នុងស្ថានសួគ៌ទាំងអស់ ។


ព្រះសាស្តាទ្រង់ប្រជុំជាតកថា : សត្វកេភ្នក់កាលនោះ ចេះរៀលមកជាអានន្ទ. សត្វចចកបានជាមោគ្គល្លាន, សត្វស្វាបានជាសារីបុត្ត. ព្រះតន្ទុបានជាអនុរុទ្ធ, ឯខន្ធាយបណ្ឌិតបានជាតថាគតហ្នឹងឯង ។

អាសាឧកថា

ខន្ធាយបណ្ឌិតជាតកនេះ ខ្ញុំបានត្រិះរិះប្រែថ្លាស្រឡះ
ហើយរៀបរៀងមកជាសេចក្តី ខេមរៈយ៉ាងខ្ជិលមិនស្តាប់ចាន ។
គោលរឿងចតុក្កនិបាត រណ្ណនាជាអាទិ៍ដើមដាន
ខ្ញុំថ្លែងរឿងនេះតាមលំអាន អ្នកប្រាជ្ញបុពណ៌ជាន់ថាស់ ។
សូមជាតិតម្កាជាសម័យថ្មី កបដោយសិរីធាប់ហ៊ាស
សុខសាន្តសប្បាយទាំងក្មេងចាស់ ពាក្យថាខាតខ្វះកុំបីពុំ ។

សូមឲ្យសាសនាព្រះជិនស្រី រុងរឿងល្បាញល្បីខ្ចរខ្ចី
ដូចសូរិយោទ័យផ្សាយពន្លឺ ញុំាងលោកឲ្យភ្លឺដោយរស្មី ។
សូមព្រះប្រិយមហាក្សត្រិយ៍ សោយសុខសម្បត្តិលើផែនដី
សូមមានតេជះតបៈល្បី ឈ្នះជនអប្រិយសត្វទិសទស ។
សូមឲ្យពុទ្ធសាសនៈ- បណ្ឌិតប្រតិបត្តិក្សល្បីកេរ្តិ៍ឈ្មោះ
ផ្សព្វផ្សាយរង្វីល្អតតមោះ ភ្លឺឆ្ងាយសាយសុសសព្វភាព ។
ដូចកលទុកាសព្រះអាទិត្យ កំចាត់ងងឹតកងមេឃា
ឬដូចរស្មីដួងចន្ទ្រា ចេញផុតនភាស្រឡះអីយ ។

ចប់រឿងសង្ខចំាសីល



ជនពាលទុកជាអ្វី ?

ជនពាលប្រាជ្ញនិន្នាថាព្រៃស្មុក
ព្រោះផ្តល់ទុក្ខឲ្យអ្នកស្រុកធុកវេទនា,
ឬកើតមកឲ្យតែធ្ងន់ពសុធា
ព្រោះតែវិគ្រាស់នៅជៅលាមក ។

យូរ · អ៊ុន

តាំងជើងតាមទន្លេសាបនិងបណ្តាំត្បូង

ជាឯកភាពជាតិនៃសាសនាខ្មែរ

(ភាគ)

ប្រាថ្នាជាមាំឲ្យតែតយុទ្ធដ្ឋានៈនោះគាន់តែតុព្វលាភ ក្រែកអន់ខន់ខ្លួយជាលំដាប់ ដូចគ្នានឹងហេតុដែលធ្វើឲ្យស្តេចសុភដំណើរទាន់កិច្ចការបណ្ណាគារមានការចោះពុម្ពព្រះវិន័យបិដក ត្រមាំងរូបគំនូរព្រឿងត្រែងជាដើម ។ បើទុកជាមានទុបស័ត្តិទាំងនេះក៏គង់តែទស្សនាវដ្តី កម្ពុជសុរិយា "ព្រះអាទិត្យកម្ពុជរដ្ឋ" នៃក្រុមតុន្តសាសនបណ្ឌិត្យ ចេះតែនៅមានចេញផ្សាយរាត់ត្បូវតែមនាគមន៍ ចំពោះទៅគាន់តែជ្រុងនៃតុន្តសាសនាទាំងអស់ក្នុងសកលលោក ។ ចំណែកទាំងសារឧត្តម (Collection) ឯទៀតជាច្រើននៃសារមន្ទីរតូចនេះ មានសភាពសាមញ្ញ តែគួរឲ្យអាណោចអាធ័មពន់ពេកដោយឃើញថាសារឧត្តមទាំងនោះ ប្រាថ្នាមកពីអំណោយទេត្តក្រៃ ឬអំពីទិន្នកំណ្លាដោយសទ្ធាផ្សេងៗ ។ គេប្រាថ្នាទស្សនាទូវអំណោយទាំងនេះ ឃើញបរិយោកាសសូម្បីស្ងាត់នៃវត្តអាចមខ្មែរចេញផ្សាយលាយចំរុះទៅនឹងទន្ទ័យដ៏សុខុម របស់រូបក្បាច់ចំឡាក់ដែលសារមន្ទីរតិលមេត៌ប្រាថ្នាធ្វើអំណោយ ។ វត្តុទាំងនេះជាព័ស្តុតាងធ្វើឲ្យឃើញទូវសហភាតភាព នៃស្ថាប័នឯកទេសទាំងបច្ចុប្បន្នប្រទេស ទៅនឹងស្ថាប័នឯកទេសទាំងបូរាណប្រទេស តែមានន័យផ្សេងពីទាំងលើនេះទៅទៀត គឺព័ស្តុតាងចំពោះការរលាយមូលច្បូលគ្នាជាឯកច្ឆន្ទនៅទីវាលទន្លេឡឹកធំទាំង

លើ រវាងចិន្តាខាងពុទ្ធសាសនា នឹងសិល្បៈខាងសមុទ្រមេឌីតែរ៉ាណេ, តាំងពី ២.០០០ ឆ្នាំមុនមក ។

ក្រមពុទ្ធសាសនបណ្ឌិត្យ ដែលខ្ញុំបានពណ៌នាអំពីវឌ្ឍនធម៌ជាសុភដុំឥឡូវនេះ បានចំរើនវ័យឡើងរហូតដល់នីតិកាពតាមច្បាប់ ។ នីតិកាពពិតប្រាកដ ដូចជាយើងធ្លាប់បានឃើញមកជាញឹកញយ នោះបានចំរើនជំឡើងតាំងពីខែមុនៗ ជាច្រើនខែមកហើយ ។ នីតិកាពនេះដែលបានទទួលស្គាល់មកហើយ នឹងត្រូវទទួលអនុម័តិ ក្នុងរយៈវេលាមិនយូរប៉ុន្មានតទៅទៀត តាមលំនាំជាស្ថាពរ ។

ចំពោះនីតិកាពនេះ យើងបានឃើញព័ស្តុតាងដ៏ទូលាំទូលាយ ក្នុងការទទួលនូវប្រតិសំពូធ្វើយចេញពីសភាកុងក្រែស នៃពុទ្ធសាសនាទៅសឹឡង់ ។ ព្រឹត្តិការណ៍មានសភាពជាសម្រើមអស្ចារ្យនេះ បានលើកតំកើងនូវកិត្យានុភាពនៃប្រទេសកម្ពុជា ចូលទៅក្នុងវិធីនការណ៍ខាងផ្លូវប្រាជ្ញា មានសារៈប្រយោជន៍ដ៏សំខាន់រវាងប្រជាជាតិ ។ ក្នុងមួយរំពេចនោះ ព្រះសង្ឃដែលរាប់បញ្ចូលជាសមាសភាពក្នុងគណៈប្រតិភូខ្មែរ បានទទួលបសំសនីយភាពពីក្រមពុទ្ធសាសនា នឹងក្រមពួកបណ្ឌិតទាំងប៉ុន្មាន ដោយក្រមទាំងនេះបានយល់ជាក់ច្បាស់នូវចំណេះវិជ្ជារបស់លោក ដូចជាចំណេះដ៏ស៊ុខុមគម្ភីរភាពខាងភាសាតិសិដ្ឋជាដើម ។

ព្រះសង្ឃនឹងលោកអ្នកដែលមានតំណាងបានឧម្មត្តនឹងអញ្ជើញទៅកាន់មហាសន្និបាតនៃសភាកុងក្រែសទៅសឹឡង់ គង់បានជ្រាប់ច្បាស់

ថា: ពុទ្ធសាសនបណ្ឌិត្យដាវិប្រជុំនៃចិន្តាខាងសាសនាសកលលោក ហើយយើងមានអំណរដោយបានចាត់ផ្ញើដាទម្លាកឲ្យទូរគ្រួមនេះ ទៅកដផ្តាកិច្ចាលខ្លួន ដោយយល់ថា អំណើរតទៅពុទ្ធសាសនបណ្ឌិត្យនឹងដំណើការទៅតាមលំអានដោយពាយាមតំកើងប្រទេសកម្ពុជានៅក្នុងហាន:ជាទត្តមដ្ឋនៃពុទ្ធសាសនាក្នុងសកលលោក មិនមែនចំពោះតែមួតដំនឿជាយ៉ាងជ្រាលជ្រៅប៉ុណ្ណោះទេ ថែមទាំងបដិការណានឹងតក្តវិទ្យានៃព្រះសង្ឃដែលជាឯតទគ្គបុគ្គល លោកបានអប់រំសង្ឃចរិយាទៅតាមវិន័យនៃវិជ្ជាស្ថាននេះទៀត ។

ក្នុងអវសានបទនេះ, ខ្ញុំសូមអភ័យទោស ដោយខ្ញុំជាសមាជិកនៃសាលាចាំងនៅចុងបូតាប្រទេស, ខ្ញុំសូមជូនធន្ទ:ជាភាតរភាពរបស់សាលានេះ ហើយសូមឲ្យកិច្ចការទាំងប៉ុន្មាននៃពុទ្ធសាសនបណ្ឌិត្យ ឲ្យបានសម្រេចទូរជោគជ័យតទៅអនាគត ។ ដើម្បីនឹងបត្តមន្ទូរអង្គការដែលខើបនឹងកើតឡើងជាថ្មី. សាលានេះបានចាត់ពួកតិកនិកឲ្យមកកាន់តំណែងជាអគ្គលេខាធិការដូចលោកស្រីសុយសានការប៉ីលេះ លោកពីអែរងុយប៉ុង, លោកហ្គូង់ស្វាស់ម៉ារីនី, ហើយលោក-អ្នកស្រីទាំងនេះក៏បានយកចិត្តទុកដាក់ប្រើដើការដែលខ្លួនបានអប់រំ មកប្រើក្នុងវិជ្ជាស្ថាននេះ ។ ខ្ញុំអាចបញ្ជាក់ថា: សាលាចាំងក្នុងបូតាប្រទេសបានបម្រុងនឹងជួយទ្រទ្រង់ទូរវិជ្ជាស្ថាននេះ ទៅតាមបំណងចំពោះផែនការណ៍ដែលជា

សាធារណៈប្រយោជន៍ ក្នុងបញ្ហាគ្រប់យ៉ាងដែលនៅក្នុងកំផ្លុងកេតនគ័ណ្ឌ នៃសាលានេះដែលមានសភាពជាវិទ្យាសាស្ត្រ ជាព័ស្តុតាងធ្វើឲ្យយើញនូវមេត្រីភាព ដែលអ្នកប្រាជ្ញខាងស្រាវជ្រាវនូវវប្បធម៌ផ្សេងៗ នឹងពួកបណ្ឌិត ប្រាថ្នាធ្វើសេចក្តីសាមគ្គីរួបរួមគ្នាជាឯកភាពទៅកាន់ទុត្តមគតិតែមួយ ជាសាធារណៈព្រមទាំងសេចក្តីខុកចិត្តគ្នាទៅវិញទៅមក ។

សុន្ទរកថា ព្រះតេជព្រះគុណ ហែល-មាស

រដ្ឋមន្ត្រីក្រសួងធម្មការនិងសិល្បការ

ព្រះគុណាជាម្ចាស់ដីវត្តលើត្បូង,

លោកស្នងសាធារណរដ្ឋ,

សម្តេច (ខាងព្រះសង្ឃ),

ខ្ញុំ,

ព្រះថេរានុត្ថេរៈ,

ព្រះតេជព្រះគុណ,

លោកស្រី,

លោកអ្នកទាំងឡាយ !

បើតាមពិនិត្យនូវលក្ខណៈដែលមានសភាពសាមញ្ញទៅ គួរតែឲ្យរំជួលចិត្តតិចតួចតែក, ព្រោះពិធីដែលនើបនឹងធ្វើមកអម្បាញ់មិញនេះ កន

អាស់សង្ឃឹមានឫទ្ធានុភាពក្រៃពេក, តាំងមានន័យប្រកបដោយសារៈសំខាន់ដែលជាប្រស្នាខាងសីលធម៌ដ៏សុខុមគម្ភីរភាព ។

ពិធីផ្លូវក្រសួងនេះ ត្រូវមានមកក្នុងពេលខាងក្រោយនៃការចាត់ចែងទៅតាមធម្មជាតិ ក្នុងកិច្ចដែលរដ្ឋាភិបាលប្រទេសថៃបានធ្វើទៅតាមអនុវត្តន៍នៃកិច្ចព្រមព្រៀង ដែលចុះហត្ថលេខាពីថ្ងៃ ១៥ មិថុនា ១៩៥០ ។

ការផ្លូវជាទូទៅក៏អំណាចតាំងនេះ អាចសំគាល់បានថា ព្រះរាជអាណាចក្របស់យើងធ្វើដំណើរការទៅកាន់វឌ្ឍនធម៌ រហូតដល់និយ្យានិកភាពជាស្ថាពរ ព្រមទាំងទទួលនូវអធិបតេយ្យខាងក្នុងប្រទេសនៃក្របខ័ណ្ឌក្នុងសហការភាពជាតិ ។

ការផ្លូវក្នុងពេលឥឡូវនេះ មិនមែនផ្លូវត្រឹមតែក្រមដែលមានប្រយោជន៍ជាសម្ភារៈនោះទេ គឺផ្លូវតាំងការព្យាយាមខាងផ្លូវចិត្តជាដែលប្រទេសជាតិបានដំណើរការមកតាំងពី គ. ស. ១៩៣០ មានធន្លុះបង់ឲ្យសហធម្មិក, ព្រះសង្ឃថ្នាក់ជាន់ខ្ពស់ ព្រមទាំងចិត្តាខាងសាសនា នៃគម្មុជរដ្ឋ រក្សាទុកនូវហានៈដែលត្រូវបានក្នុងចំណោមប្រជាជាតិទាំងអស់ដែលរួបរួមគ្នានៅក្រោមអធិបតីភាពនៃអចលនសង្ឃក្នុងពុទ្ធសាសនា ។ វិរិយភាពដែលបំពេញចំពោះវប្បធម៌នៃលទ្ធិពុទ្ធបូជានិយម បានផ្សាយចេញតាំងពី ២០ ឆ្នាំមុនមក ប្រៀបដូចបុប្ផបទុមអណ្តែតត្រសែតចេញពាក់ដើមឡើងពីក្នុងភក់ស្រែដូច្នោះ លុះចម្រើនវ័យវឌ្ឍនាការហើយ

បុជ្ជានោះបម្រុងនឹងរីកស្វាងរុងរឿងឡើង ។ ប្រទេសជាតិបានជួយ
អភិបាលរក្សា ថែទាំឲ្យបានល្អគួរសមតទៅទៀត ការពារព្រមទាំង
ចិញ្ចឹមបីបាច់ឲ្យចំរើនធាត់ធំ ដោយមានបំណងចង់ឲ្យព្រះពុទ្ធសាសនា
របស់យើងបានស្ថិតនៅក្នុងហានៈដែលធ្លាប់មានមក ចំពោះប្រពៃណី
ពិសិដ្ឋខាងសាសនា, ការសិក្សាខាងលទ្ធិសាសនា, ការសួរសុខទុក្ខខាង
ធំទៀមទម្លាប់ពីបូរាណព្រមទាំងកិច្ចវត្តន៍ដោយពិស្តារ ។

សេចក្តីព្យាយាមនោះ ដំបូងឡើយមានឧបសគ្គជាច្រើនប្រការមក
រាំងរា ព្រោះក្រមខ័ណ្ឌខាងសាសនារបស់យើង បានបោះបង់ចោលខ្លួ
វប្បធម៌ដើមរបស់ខ្លួន ត្រឡប់និយមចូលទៅក្នុងអនិស្សរភាពក្រមខ័ណ្ឌ
សាសនានៃសមន្តប្រទេសនឹងនានាប្រទេស ។

សេចក្តីព្យាយាមនៃបាំង បានប្រគល់នូវបទមួយចំពោះព្រះសង្ឃ
របស់យើង ជាវត្ថុដែលយើងមិនត្រូវបោះបង់ចោល ត្រូវអភិបាលរក្សាត ។
មក ព្រមទាំងរចនាស្នើនោះឲ្យកាន់តែភ្លឺរុងរឿងឡើង ។

ចំពោះកិច្ចការដ៏ប្រសើរនេះ យើងសូមថ្វាយអំណរគុណជាយ៉ាង
ក្រៃលែងចំពោះប្រទេសបាំង ។

ដោយហេតុដូចនេះ ប្រទេសកម្ពុជាមិនមែនគ្រាន់តែបានស្ថិតនៅ
ក្នុងហានៈដែលត្រូវបានចំពោះការព្យាយាមនូវវប្បធម៌ព្រមទាំងសាសនាទេ
តែត្រូវមានសន្ទុះស្មើ ឬ លើសជាងពួកសមន្តប្រទេសទៅទៀត ។

ដោតកាសនាវៃគ្រែមភុទ្ធសាសនបណ្ឌិត្យដែលគេបានប្រគល់មកឲ្យយើងកន្លងទៅនេះ, យើងត្រូវព្យាយាមរក្សាទុកនូវកេរ្តិ៍ដំណែលនេះឲ្យគង់ខ្ជង់ទៅតទៅអនាគត ត្រមាំងកតហានដែលបានខ្ជួលនោះឲ្យកាន់តែរីកធំខ្ជួលាយឡើង ។

សេចក្តីព្យាយាមនេះមិនអាចនឹងបន្ទរបន្តួយបានឡើយ ហើយត្រូមព្រះសង្ឃរបស់យើង មុខជានឹងរីករាលវិធីការឲ្យវិរិយភាពនេះដើរទៅកាន់សេចក្តីចំរើនបាន ។ សេចក្តីព្យាយាមត្រូវតែបំពេញឲ្យកាន់តែមាំមួនតទៅទៀត តែវិជ្ជាស្ថានដែលរចនាដ៏វិចិត្រនេះស្ថិតនៅក្នុងយុវភាពនៅឡើយ ។ មានគេពោលថា វិជ្ជាស្ថាននេះបានចំរើនវ័យវឌ្ឍនភាពដល់ទីតិភាពហើយ ។ តែមានទីតិភាពខ្លះដូចជាផ្នែកខាងផ្លូវចិត្តានឹងការស្រាវជ្រាវរឿងព័ត៌មានផ្សេង ។ ត្រូវតែមានការឧបត្ថម្ភពីអ្នកជំនៃ ។ ការឧបត្ថម្ភនេះ យើងបានខ្ជួលដោយសេចក្តីស្មោះស្ម័គ្រហើយ ។ យើងសូមថ្លែងកតញ្ញូតវេទិចំពោះអ្នកជួយឧបត្ថម្ភយើង ត្រមាំងបានណែនាំយើងអំពីទីតិភាពដែលនៅខន់ខ្លីនៅឡើយទៅកាន់ព្រឹទ្ធភាព (maturité) ដែលមានលក្ខណៈរឹងប៉ឹងចំពោះខ្ជួនលែងរួញរាក្នុងការធ្វើដំណើរតទៅអនាគត ។

ចំពោះវត្តុជាតុទាំងអស់ យើងត្រូវប្រុងប្រយ័ត្នការពារកុំឲ្យកិច្ចការទាំងនោះខុតួលភាព អន់ខន់ខ្ជោយទៅវិញ ។ បក្សាដែលតំណោធន៍ខ្ជូវស្ទាបខ្ជោយតែងភ្ជាក់ចាកចេញពីសំបុកមិនខាន ។ យើងត្រូវការពារ

កុំឲ្យដួលបន្ទប់ទុបស័ក្តិបែបនេះ ។ ព្រោះហេតុដូចនេះ ខ្ញុំសូមថ្លែងនូវ
អំណរជាយ៉ាងក្រៃលែង ចំពោះសាលាចាក់ឆ្លងចុងបូព៌ាប្រទេសដែល
បញ្ចេញរស្មីភ្លឺស្វាងរុងរឿងតាសពេញសកលលោក ដោយសាលានេះ
បានជួយទុបត្តម្ភជាយ៉ាងមាំមួនទូរវិជ្ជាស្ថានរបស់យើងនេះ ។

អ្នកទទួលការៈដ៏រឹងប៉ឹងបែបនេះ ដែលបានពិសោធន៍ឃើញច្បាស់
លាស់ពីមុនមកហើយ អាចជានាអះអាងដោយពិតប្រាកដ មិនគ្រាន់តែ
រៀបចំកិច្ចការនេះឲ្យបានស្រួលល្អទេ ថែមទាំងធ្វើដំណើរការទៅកាន់
សេចក្តីចំរើនជានិន្នការ រហូតដល់សុខុមវិជ្ជានៃកាសាស្ត្រនឹងប្រ-
ពៃណីនិយមអំពីអតីតកាល ។

ខ្ញុំមិនចង់បញ្ចប់សុន្ទរកថាខ្ញុំ ដោយគ្មានថ្លែងកតញ្ញូតាចំពោះ
ពួកបណ្ឌិតដែលមានឧត្តមលក្ខណ៍ល្អៗ ហើយជាអ្នកបានព្យាយាមទុបត្តម្ភ
វិជ្ជាស្ថាននេះ តាំងពីដើមរៀងរៀបដកបមក ព្រមទាំងបានជួយទំនុក
បម្រុងដោយបច្ចុយព្រមទាំងវិរិយភាព ដើម្បីនឹងរចនាទូរវិជ្ជាស្ថានរបស់
យើងឲ្យបានឡើងទៅកាន់ឋានៈដែលត្រូវបានក្នុងសម័យបច្ចុប្បន្ន ស្មើមុខ
នឹងវិជ្ជាស្ថាននៃវប្បធម៌ដែលមានទាំងប៉ុន្មាននៅចុងបូព៌ាប្រទេស ។

បណ្ឌិតទាំងនោះ បានជួយទំនុកបម្រុងប្រទេសកម្ពុជាឲ្យរួចពាក់ព័
អនិស្សរភាពនៃបរទេស ហើយធ្វើឲ្យប្រទេសយើងអាចបានឡើងទៅកាន់

ECOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE

ហានដែលគួរបាន ។ យើងសូមថ្វាយនូវអំណរជាភាទ្វីតត្រមាំងតតញ្ជូ
ទីងតតវេទីជាមុន ។

តាំងពីថ្ងៃនេះតទៅ ពុទ្ធសាសនបណ្ឌិត្យ ទៅជាវិជ្ជាស្ថានរបស់
ប្រជាជាតខ្មែរមួយ ដែលយើងត្រូវតែរក្សាទុកនូវកេរ្តិ៍ដំណែលទៅតាមប្រ-
ពៃណីនៃប្រទេសបារាំងបានចំណាយមកជាដើម ឲ្យកើតឲ្យមានឡើងនៅ
ប្រទេសយើង ហើយយើងមានសេចក្តីសង្ឃឹមថា ប្រទេសបារាំងនឹង
ជួយទុបត្ថម្ភនូវវិជ្ជាស្ថាននេះតទៅអនាគត ឲ្យបានស្ថិតនៅក្នុងគ្រប់ខ័ណ្ឌ
សហការមួយ ដើម្បីណែនាំឲ្យព្រះពុទ្ធសាសនាចក្ររបស់យើងបញ្ចេញ
នូវរស្មីឲ្យកាន់តែភ្លឺស្វាងរុងរឿងតទៅ ។

— ចប់ —

ខ្ញុំតែមួយណាដោគបំផុត?

ខ្មែរតែម្នាក់ជាក់ខ្ញុំគេ, ជាតិសោភ័ន;
បើខ្មែរអន់ខ្ញុំទាំងជាតិដោគបំផុត
ខ្មែរជាន់ថ្លៃគង់បង្រៃនោះតាមជុត
ឲ្យស្រែកស្រែតកិត្តនាមជាមួយផង ។

យួរ - អ៊ុន

កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ដ្រ ប្រពៃផ្សេងៗ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ដ្រ៖ លោក ភ័យ - ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកសាសនា៖ ព្រះទេពសត្ថា សួរ - ហាយ
ក្រុមជំនុំត្រួតត្រៃចំនួន នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ដ្រ	ប្រធានបទ	ទំព័រ
លោក ភ័យ - ប៊ុក ក្រមការ	ទេវាទមហាឆ្នះតន្ត្រី (ត-ចប់)	៨៧១
— —	ប្រៃវត្តិសាស្ដ្រនៃស៊ីវិល្យៃខ្មែរបុរាណ (តមក)	៨៨២
លោក ម៉ូញ - ឥន្ទ្រី	ស័ព្ទបារាំងប្រែជាខ្មែរ (តមក)	៩០១
លោកសាង - សុភ័ត ស្មៀនតុការ	រឿងព្រៃនគរភូមា (តមក)	៩០៥
អ្នកឧកញ៉ាវិមុលរាជសេនា ង្គួ - កន	រឿងសាមកុក (តមក)	៩១២
— ទេពតិវ្ងរ ឈឹម - ក្រសែម	ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	៩២២
វិនយធរគណៈ ប៉ៅអធិការ	សាវតារវត្តបាចិនភាប (តមក)	៩២៨
លោកផែង - ដ្រែរ	ប្រវត្តិរបស់អសុប (តមក)	៩៣៣
ផ្នែកសាសនា		
លោក ភ័យ - ប៊ុក ក្រមការ	ពន្ធអាស៊ីទ័ប (តមក)	៩៤០
ឃនបណ្ឌិតមុនីវង្ស ប៊ុំ - ប៊ុំ	កំឡាំងនៃពាក្យពេចន៍ (ត-ចប់)	៩៤៣
កំណត់ទីន្លែប្រវត្តិការណ៍		
ព្រះមហា កែ - អឿន	ពិធីសម្ពោធឡបើកស្ថាលាធម្មវិន័យ នៅវត្តព្រះ ត្រហ្មរតន៍ សៀមរាប	៩៥១
ក្រសួងធម្មការ	បញ្ជីកិច្ចការមួយចំនួនអធិការដែលតាំងថ្មី (ត-មក)	៩៥៨

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kromakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Ray-Buc Kromokar	Paroles de Gandhi (suite et fin)	881
	Histoire de l'ancienne civilisation Khmère (suite)	892
M. Menh-Nakry ancien député	Recueil des mots traduits par la Commission Culturelle (suite)	901
M. Sang-Savath Secrétaire au Ministère des Finances	Contes birmans (suite).....	905
Neak Okuha Vibularaja-séna Neu-Kân	Histoire de SAUKOK (suite).....	912
Neak Okuha Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite).....	922
Vinayadhâra Kon Chau athicar de cette pagode	Notice historique de la pagode de Pacinaràmà (suite et fin).....	928
M. Pheng Chhieu, professeur au Collège des Jeunes Filles	Biographie d'Esope (suite).....	933

Partie religieuse:

M. Ray-Buc Kromokar	La lumière de l'Asie (suite).....	940
Khun Pannanuraksa Bou-Po	Les effets de la calomnie (suite et fin)	943

Notes et Chroniques

Préah Moha Ker-Oeun	Fête de l'Inauguration de l'Ecole Dharmavinaya à la pagode de Préah Brahmaratana.....	951
Ministère des Cultes	Nomination des nouveaux Chau-Addhikar (suite).....	958

22e Année: N° 12 — Mois de Décembre 1950 — Prix d'abonnement: 145$00 par an

ECOLE FRANCAISE
BIBLIOTHEQUE
D'EXTREME-ORIENT

ជុំភ ធម្មមហាស្នុះកង្ខ៊ី

លោក រ៉ាយ - ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ព័ត៌មានពីកាសែត ហ្សឺន អាំង (Jeune Inde)

(ត-ចប់)

---

៥៣ – ប្រជាជាតិណាដែលបណ្តាយឲ្យចិត្តគំនុតខ្លាចសេចក្តីស្លាប់ ប្រជាជាតិនោះមិនអាចទទួលនូវស្វ័យភាពបានទេ, បើប្រសិនណាជាបានស្វ័យភាព ក៏មិនអាចរក្សាស្វ័យភាពនោះឲ្យគង់ខ្ជាប់បានឡើយ ។

ជាតិអង់គ្លេសគេដាក់ជីវិតរបស់គេក្នុងហោប៉ៅអាវ ។ ពួកជាតិអាភ៉ាន់នីចាំង (Pathans) យល់ថា សេចក្តីស្លាប់ជាសភាវៈបង់ថ្លាម្តងបន្តិចបន្តួច ហើយបើកាលណាមានញាតិមិត្តអនិច្ចកម្ម គេមិនដែលសំដែងសេចក្តីសោកស្តាយអ្វីឡើយ ។ ស្ត្រីជាតិបូអែរ (Boers) មិនដែលបានដួបប្រទះនឹងសេចក្តីខ្លាចគក់ស្នូតបែបនេះសោះ ។ ក្នុងសង្គ្រាមជាតិបូអែរ, មានស្ត្រីជាតិនេះជាច្រើនម៉ឺននាក់នៅជាមេម៉ាយ ។ នាងទាំងនេះកាន់ចិត្តជាឧបេក្ខា ។ ខ្ញុំយល់ថាមិនជាអ្វីឡើយ គ្រាន់តែសេចក្តីស្លាប់នៃស្វាមីឬបុត្រា, ឲ្យតែមាតុភូមិរួចផុតពីសេចក្តីវិក្ខុលំបាក; កិច្ចនេះល្អបំផុតថែមទាំងប្រសើរណាស់ផង ។ ស្វាមីនៅរស់តើស្វាមីនោះមានប្រយោជន៍អ្វីខ្លះ បើមាតុប្រទេសជាក់ប្តូរនៅតាន់ភាសតាត ? ការដែលកប់ជាតុភូនដែលជាអនត្តាធម៌ (វត្ថុសាបសូន្យ) ហើយរក្សាទុកនូវសេចក្តីស្នេហានៃ

អាត្មន ដែលជាអមតធម៌ (ធម្មជាតិមិនចេះស្លាប់) ប្រសើរជាងខ្មុក
កូននោះឲ្យរស់នៅក្នុងអនិស្សរភាព ។ ព្រោះហេតុដូចនេះបានជាស្ត្រី
ជាតិបូរអែរមានសន្ដានចិត្តវែងប៉ុន៎ដូចដែក ហើយបូជាខ្លួនបុគ្គលដែលជា
ទីស្រឡាញ់ តេញចិត្តរបស់ខ្លួន ឲ្យទៅស្ដេចមច្ចុរាជដោយហាសនចិត្ត ។

... អាត្មនៃអ្នកស្លាប់ខឹងអាត្មនៃអ្នករស់ បើតាមពិនិត្យទៅ ប្លែកម្ល
មកមានតែមួយដូចគ្នា ។

... សេចក្ដីទុក្ខដែលគេទទួលដោយសេចក្ដីកែកយ មិនមែនជាទុក្ខ
ទេ គ្រាន់តែប្រែទៅជាសេចក្ដីសប្បាយស្រួលអស្ចារ្យ ។ មនុស្សដែលជួប
ប្រទះនឹងសេចក្ដីទុក្ខហើយមានចិត្តរញ្ជែរតែចោលទុក្ខនោះ តែងជួបប្រទះ
នូវសេចក្ដីត្រួយចារម្លាំងច្រើន ; បើទុកជាសេចក្ដីលំបាកនេះមិនទាន់មក
ដល់ បុគ្គលនោះទៅជាភ័យតក់ស្លុត, ហើយបើសេចក្ដីលំបាកនោះមកដល់
ខ្លួនវេលាណា បុគ្គលនោះទៅជាញ័រញាន់ដូចជាស្លាប់មួយកំណាត់ខ្លួន ។
អ្នកណាដែលបម្រុងខ្លួនចាំទទួលនូវសេចក្ដីលំបាកគ្រប់យ៉ាងដោយចិត្តខ្ជឺ
សោះច្រៃ: អ្នកនោះមុខជានឹងរួចផុតពីសេចក្ដីទុក្ខនោះបាន ព្រោះការ
កាន់ខ្ជឺនឹងសោះច្រៃ: អាចធ្វើឲ្យអ្នកទទួលទុក្ខទៅជាសុខស្រួលដូចជាគេ
ហិតនូវអេតទុសប៉ (Anesthésique) ។

... សិទ្ធិធ្វើឲ្យមនុស្សខ្វាក់ឬថ្លង់; មនុស្សនោះមិនអាចនឹងមើល
ឃើញនូវវត្ថុអ្វីដែលនៅចំពោះមុខខ្លួន ឬស្ដាប់សព្ទសំឡេងដែលមានមក
ដល់ត្រចៀកខ្លួនបានទេ ។

...ខ្ញុំយល់ឃើញថា: ពួកស្មេហាជាតិគួរហាត់ចិត្តខ្លួនជាមុនបន្តិចជាស្រេចនូវការខ្លួលស្ងាប់, ខ្លួលឆន់លំបាកដោយការជាប់ពន្ធនាគារ (គុក) ឬខ្លួលឆន់នូវយថាកម្មដែលមានសភាពដូចខាងលើ ។

បុគ្គលអ្នកក្លាហានតែងត្រេចដើរទៅចំពីមុខសេចក្តីស្ងាប់, មានបបូរមាត់ញញឹម មុខរីករស់ តែពោលដូចនេះមិនមែនហាមឃាត់មិនឲ្យបុគ្គលការពារខ្លួនទេ បើសិនណាជាត្រូវការពារបាន ។

សេចក្តីភ័យស្ងាប់
(១៣ ខែតុលា ១៩២១)

៥៤– ស្ងួយរាជ្យ បានខាងសេរីភាពចំពោះបុគ្គលម្នាក់ៗ គឺចំពោះបុគ្គលជាសាម័ញ (ដូចយើង) ក្នុងការដែលធ្វើបានតាមអំពើចិត្ត ដោយមិនមានឧបស័គ្គមកពាំងកាមិនឲ្យសេរីភាពប្រព្រឹត្តទៅបាន ។ ការដែលមិនត្រូវធ្វើតាមបង្គាប់ពាជការ ដោយប្រើអវិហឹសាចរិយា គឺជាវិធីដែលយើងត្រូវធ្វើនូវមគ្គមិនឲ្យចំរើនដោយសេរី ហើយនឹងយកមគ្គនោះទៅអនុវត្តនាការឲ្យបានផលប្រយោជន៍ឡើងតាមលំដាប់ ។ បើកាលណាមានសេរីភាពក្នុងការបញ្ចេញនូវមគ្គផ្សេងៗ ត្រូវយកមគ្គភាគច្រើនសម្រេចជាគោលច្បាប់; បើយើងនៅក្នុងចំណោមមគ្គភាគតិច បើខុសជាមានគេបង្ខំយ៉ាងណាក៏ដោយ យើងត្រូវតែខ្លួលដោយចរិយាខ្ជិច្ចរតាមសាសនារបស់យើង ។

ចំពោះយោបល់នៃសីលធម៌
(២៤ ខែធេសា ១៩២១)

៥៥ - ស្ងួយភាវ គឺសម្បូរវត្តន៍នៃវដ្ឋតិចុះ ដោយការធ្វើឲ្យតិច្ច
ការពិនិត្យត្រួតត្រាធ្លាក់ទៅលើតណ្ហាជាប់ដែលជាភស្តុ ។ តែសភាពបែប
នេះគ្រាន់តែជាទម្រង់ត្រោះ, ចំណែកខាងអត្ថរសនៃស្ងួយភាវដែលពុំមាន
បំណងយ៉ាងមាំមួន គឺការខ្វះខូចខូរមធ្យោបាយដាក់ចូរ្យាស់ត្រង់យ៉ាង ជា
ហេតុនាំឲ្យបែបបួលខ្លួនចិត្តប្រជាភស្តុតិចបាតជ ។

·· ការអនុវត្តន៍ខ្លួកម្មដ៏នេះតាមសេរីបែកបដោយច្បាជ្ញានៃប្រជា
ជាតិនាំឲ្យយើញថា ឡាក់ត្រលស់ខាន់ ។ នៃសម្បរិវត្តន៍ទឹងបានសម្រេច
តិចបាតជ ។ បដិមារូបនៃសម្បរិវត្តន៍នេះ គឺការផ្លេរខ្លួសិទ្ធិពាំងប៉ុន្មាន
ដែលអាចធ្វើបានតាមបំណង ដូចជាគ្រាប់ឈើដែលត្រោះសាបដោយ
ល្អ ត្រូវតែតខ្លួកដុះលូតលាស់ផ្សាយទៅទឹងជាដើមឈើមួយ ។

ការពិនិត្យឃើញ

(ចាប់ថ្ងៃទី៣ ខែ៤ ឆ្នាំ១៩៦៦)

៥៦ - ស្ងួយភាវមិនមែនប្រជាជាតិមួយឲ្យដល់ប្រជាជាតិមួយបាន
ទេ គឺជាវត្ថុវិសេសមួយ ដែលយើងត្រូវទិញដោយលោហិតដ៏បរិសុទ្ធ
របស់ប្រជាជាតិ ។ ហេតុនេះ ស្ងួយភាវមិនមែនជាអំណោយអំពី
អ្នកណាទេ ត្រោះយើងត្រូវទិញថ្ងៃសម្បើមអស្ចារ្យ ។

ឯកភាវ

(៥ ខែមេសា ១៩៦៦)

៥៧ – ករណីយកិច្ចដែលប្រទេសត្រូវបំពេញភ្លាម ។ គឺត្រូវធ្វើបត្តម្ភជាតិឲ្យមានសេរីភាពក្នុងការនិយាយ, សេរីភាពក្នុងការប្រមូលផ្តុំសង្គមសមាគម និងសេរីភាពក្នុងការឃោសនាផ្សាយតាមសារពត៌មាន កុំឲ្យធ្លាក់ចុះទៅក្នុងសភាពជាមនុស្សពិការគ្មានសិទ្ធិធ្វើអ្វីបាន ។

លិទ្ធលោកមហាឧត្តមដ្ឋានទៅលោកនរបាជនស្មៀ

៩ ខែកុម្ភៈ ១៩២៤

៥៨ – ធ្វើចិត្តមិនស្មោះស្ម័គ្រ ១.០០០ ដង ចំពោះអ្នកដទៃមិនជាការអ្វីទេ, តែកុំគប្បីធ្វើចិត្តមិនស្មោះស្ម័គ្រចំពោះខ្លួនឯងឲ្យសោះ ។

. . . មានតែវិធីមួយទេដែលត្រូវប្រើក្នុងកិច្ចផ្តន្ទាទោសចំពោះបុគ្គលដែលយើងស្រឡាញ់ពេញចិត្ត គឺត្រូវខ្លួនយើងធ្វើចិត្តខន្តីសូមទទួលទុក្ខទោសលំបាកគ្រប់យ៉ាង ដែលកើតពីសេចក្តីស្នេហានោះ ។

បទនក្រិត្តផ្ទៃលធ្វើទៅទីក្រុង សៅរី-សោភ

១៦ ខែកុម្ភៈ ១៩២៤

៥៩ – ពន្ធនាគារ (គុក) សម្រាប់ដាក់ពួកមនុស្សដែលប្រព្រឹត្តបទឧក្រិដ្ឋមកយូរហើយ មិនមែនជាគ្រូដែលនាំមនុស្សនោះទៅកាន់សេរីភាពបានឡើយ ។

យូរឆ្នាំមកហើយ ពិតមែនតែមានពួកជាតិវុស្សជាច្រើនសែននាក់រងទុក្ខលំបាកនៅពន្ធនាគារមែនសហការវុស្សី, ប្រទេសនេះក៏មិនទាន់បានសេរីភាពនៅឡើយ ។

. . . សេរីភាពជានិរន្តរភាពមួយលំបាកនឹងប្រែអាកប្បកិរិយាឲ្យសុខចិត្តប្តូរធ្វើឫកពាឲ្យត្រូវចិត្ត ។

. . . ជាតិអធ៌ត្រូវសង់ជាតិក្រអើតក្រទម ជាតិនេះមិនអាចយល់ខ្លួនខ្លួននៃជាតិយើងបានទេ ហើយពួកនេះលើកតំកើងខ្លួនជាអរិយបុគ្គល ។ ជាតិនេះយល់ថា ខ្លួនគេកើតមកកន់លោកសន្និវាសសម្រាប់តែឲ្យជនជាតិយើងស្គាប់បង្គាប់ប៉ុណ្ណោះ ហើយគេអាងមានកាំភ្លើងធំនឹងពលភាពនៃកងទ័ពសម្រាប់ការពារខ្លួនគេផង ។

. . . កណ្តាមិនអាចចៀសពីឆ្នាំបាន កណ្តាមិនអាចសន្ធនាការជាមួយនឹងឆ្នាំបាន បើឆ្នាំមិនកាត់ត្រចក់នឹងឆ្មេញចេញ ។

. . . គោលកំហុសនៃរដ្ឋាភិបាល នាំឲ្យដើរជាក់ខ្លួនទៅតួមគតិរបស់យើង ។ គោលកំហុសនៃក្រុមយើង ជាការខំនាស់នឹងរដ្ឋាភិបាល ។

គណៈកម្មាធិការនៃសភាកុងត្រែស៍ប្រទេសឥណ្ឌា

២-៣-១៩២២

B). ឯកស្រង់ពីសៀវភៅ ខ្សែត្រអាឌ្រាស្រម

(Lettres à l'Ashram).

៦០ – ត្រង់ណាដែលមានសច្ចធម៌ ត្រង់នោះក៏មានវិជ្ជាពិត ។

៦១ – សច្ចធម៌ត្រូវខុសជាមូលហេតុនៃកម្មកាតរបស់យើង ។

៦២ – ចិត្តមិនអាចរកសុខឃើញទេ បើគ្មានវិជ្ជាពិត ។

៦៣- វត្ថុពិតបើពិនិត្យដោយស្មាន ខឹងឃើញថាមានសភាព ផ្សេងៗគ្នា ប្រៀបដូចជាស្លឹកឈើមានច្រើនឥតគណនា តែមានលក្ខណៈ ខុសពីគ្នា សូម្បីដុះរួមនៅនឹងដើមតែមួយ ។

៦៤- បើសេចក្តីស្នេហាប្រកបដោយអត្តទដ្ឋភាពហើយមានគ្រប ខ័ណ្ឌ មុខជានឹងមានទុក្ខាសបង្កប្រឈ្មោះគ្នាកាន់តែច្រើនៗឡើង ។

៦៥- បើចិត្តវង្វេងហើយ រូបមិនយូរក៏ខាប់ គង់តែប្រព្រឹត្តទៅ តាមចិត្តមិនខាន ។

៦៦- អ្នកណាមានធន: ចង់ធ្វើអង្គការណាមួយក៏ដោយឲ្យនៅ ក្រោមបង្គាប់អាត្មា ត្រូវកំណត់ទុកក្នុងចិត្តជាជាច់ខាតថានឹងធ្វើអង្គការ ឯទៀតៗឲ្យនៅក្រោមទាន់ខ្លួនផង ។

៦៧- ទុសថដែលគេផឹកមានប្រមាណតិចពេក រមែងមិនមានផល ឬមិនអាចឲ្យផលពេញលេញ; បើគេផឹកទុសថនោះច្រើនហួសប្រមាណ ត្រឡប់ជាឲ្យទុក្ខលំបាកដល់ខ្លួនវិញ ។

៦៨- អ្នកណាដែលមានចិត្តសន្តោសក្នុងកត្តាហារ ដល់យូរទៅ មុខជានឹងហាត់ចិត្តឲ្យជាឯកគ្គតាបាន ។

៦៩- យើងមិនត្រូវគិតលុកខ្លួនដោយខ្លួនឯង ដោយប្រែគិត ល្បិចប្រមាណាទេ ។

៧០ - បើធ្វើទុក្ខមគតិណាមួយឱ្យវុឌ្ឍលាភ ឬឱ្យវិនាសអន្តរាយ ដោយសារការចង់ស្រួលខ្លួនឯង គឺការមិនប្រតិបត្តិតាមសច្ចធម៌, អំពើយ៉ាងនេះឈ្មោះថាធ្វើខ្លួនឯងឱ្យទាបថោក ។

៧១ - បើយល់ឃ្លាស់ខ្លះទុក្ខមគតិណាមួយហើយព្យាយាមប្រែងប្រែជាអនេកប្បការដើម្បីនឹងត្រូវសំរេចទៅតាមទុក្ខមគតិនោះ, បើទុកជាទុក្ខមគតិនោះមានសភាពលំបាកយ៉ាងណាក៏ដោយ គេទុកថាការពិសោធន៍នោះជាបរិយាដ៏ខ្ពង់ ។

៧២ - ពួកសេដ្ឋីប្រមូលវត្ថុដែលមិនជាប្រយោជន៍សំខាន់ច្រើនឥតគណនា ហើយយកមកចាយវាយតាមអំពើចិត្ត, ចំណែកមនុស្សទាំងកោដិនាក់ស្លាប់ដោយសេចក្តីស្រេកឃ្លានគ្មានអ្នកហាបរិភោគ ។

៧៣ - ពាក្យ "ស៊ីវិល្យ" បើតាមពិត មិនមែនធ្វើវត្ថុដែលត្រូវការនោះឱ្យចំរើនទេ គឺត្រូវបន្ថយចំនួននៃវត្ថុទាំងនោះដោយចិត្តស្មោះស្ម័គ្រ ។

៧៤ - សាសនាឯកនោះគឺស្ថិតនៅកងដែនដោយខ្លួនឯង មើលមិនឃើញថាមិនត្រូវ ។

៧៥ - អ្នកណាដែលយកដំរីតធ្វើពលិកម្មចំពោះអ្នកដទៃ អ្នកនោះមិនមានទុក្ខាសនឹងការពារខ្លួនឯង ដែលខ្លួនត្រូវបាននៅក្រោមព្រះអាទិត្យទេ ។

៧៦ - ទឹកមួយតំណក់ដែលឃ្លាតចេញពីមហាសាគរអាចឈប់សំរ៉ាកបានមួយពេលមួយខណៈ តែទឹកមួយតំណក់ដែលស្ថិតនៅក្នុងសាគរគ្មានឧបាសនឹងឈប់សំរ៉ាកបានសោះឡើយ ។

៧៧ - គ្រាន់តែពិនិត្យបន្តិចបន្តួច យើងអាចយល់ច្បាស់ឥតសង្ស័យថា "សត្វដែលមានជីវិតរស់នៅក្នុងលោកសន្និវាសនេះ គឺជាបរមាណូមួយតិចតួចស្ពួចស្តើងណាស់ក្នុងចក្រវាឡ" ។

៧៨ - សច្ចធម៌ស្ងួតរឹងដូចពេជ្រ ហើយផុយដូចបុប្ផានៃវុក្ខជាតិ "ប៉ែសេ្ស" (pêcher) ។

៧៩ - សកលលោកត្រូវសំរេចដោយច្បាប់ព្រហ្មវិហារ ។ ពិតមែនតែមានសេចក្តីស្លាប់ តែជីវិតស្ថិតនៅជាដរាប ។ ចក្រវាឡចេះតែធ្វើដំណើរលឿនទៅមុខ ពិតមែនតែមានវិនាសកម្មជានិច្ច ។ ធម៌ពិតឈ្នះធម៌មិនពិត ។ សភាពស្រឡាញ់ ឈ្នះសេចក្តីស្អប់ ។ ព្រះឈ្នះជានិច្ចលើស្តេចបិសាច ។

៨០ - ការពារទ្រព្យសម្បត្តិ, កិត្តិយស នឹងសាសនារបស់ខ្លួនដោយចុងដាវជាកិច្ចដ៏ខ្ពង់ខ្ពស់ ។ ការពារវត្ថុទាំងនេះ ដោយកុំឆ្លៀតគុណកម្មដល់ពួកបច្ចាមិត្តរបស់ខ្លួន នេះជាកិច្ចប្រសើរបំផុត ។

៨១ - សាសនារបស់ខ្ញុំខ្លួនប្រដៅខ្ញុំថា "បើខ្ញុំឧស្សាហ៍តុះតំនិតចំពោះវត្ថុណាមួយ ដែលខ្ញុំមិនអាចរកមធ្យោបាយប្តូរសច្ចៈកែបានទេ ខ្ញុំត្រូវអត់អាហារហើយស្លាប់ចោលធម៌" ។

៨២– កុងមួយវិញ។ ធម្មជាតវែងឲ្យផលានុផលល្មមចិញ្ចឹមជីវិតបានត្រប់គ្រាន់បរិបូណ៌ ។ បើកុងម្នាក់ៗ បរិភោគអាហារល្មមសមគួរ, នៅកុងលោកក៏គ្មានអ្នកកំសត់ទុគ៌តទេ តាំងគ្មានអ្នកស្លាប់ដោយសារអត់ឃ្មាយ ។

៨៣– ជីវិតគ្មានសាសនា គឺជីវិតគ្មានគោលការណ៍ ហើយជីវិតគ្មានគោលការណ៍ទុកដូចជានាវ៉ាគ្មានចង្កូត ។

៨៤– ខ្ញុំមិនត្រមអនុម័តតាមលទ្ធិសាសនាណាដែលមិនយកវិចារ-ញ្ញាណជាមូលហេតុ ដែលប្រើវិធីដំបាស់នឹងសីលធម៌ ។ ខ្ញុំយល់ត្រមអនុម័តតាមមនោសញ្ចេតនាខាងសាសនា ដែលមិនប្រកបផៅតាមវិចារណញ្ញាណ តែមានសភាពមិនផ្ទុយគ្នានឹងសីលធម៌ ។

៨៥– បុគ្គលមានចំនួនប៉ុន្មាន, សាសនាក៏មានចំនួនប៉ុណ្ណោះ ។

៨៦– សាសនាប្រៀបដូចជាផ្លូវមានសភាពផ្សេងៗគ្នា តែរួមចូលកុងស្ថានទីបំណងតែមួយ ។ មិនជាអ្វីទេ ទោះបីយើងត្រាច់តាមផ្លូវផ្សេងៗគ្នាក៏ដោយ ឲ្យតែយើងទៅដល់ស្ថានទីបំណងដូចគ្នា ។

៨៧– វិធានវិសេសនៃការប្រព្រឹត្តរបស់យើង គឺយើងត្រូវធ្វើចិត្តសន្តោសទៅវិញទៅមក, ដោយហេតុថាយើងមិនមានមនោគតិដូចគ្នា ហើយយើងអាចយើញខ្លួនសុចរិតតាមបែបដែលយើងគួរយើញ ហើយតាមយោបល់ផ្សេងៗគ្នាតាំងអស់ ។ មនសិការនៃបុគ្គលតាំងអស់មិន

ដូចគ្នាទេ ។ មនសិការនេះអាចធ្វើជាមគ្គុទ្ទេសក៍ ដ៏ប្រសើរចំពោះការប្រព្រឹត្តិរបស់យើង ។ តែបើយើងបង្ខំឲ្យអ្នកឯទៀតប្រតិបត្តិតាមគោលការរបស់យើង គេទុកយើងជាអ្នករំលោភនូវសិទ្ធិនៃបុគ្គលនីមួយៗ ចំពោះសេរីភាពនៃមនសិការ ។

៨៨- ប្រទេសនីមួយៗ ត្រូវមានសេរីភាពដើម្បីនឹងយកដរិតទៅធ្វើពលិកម្មជាប្រយោជន៍សកលលោក បើកាលណាគេត្រូវការ ។ ព្រោះហេតុដូចនេះ មតិរបស់ខ្ញុំ ចំពោះលទ្ធិប្រជាជាតិនិយម, សេចក្តីស្នេហារបស់ខ្ញុំចំពោះលទ្ធិនេះ គឺខ្ញុំមានបំណងសូម្បីឲ្យប្រទេសខ្ញុំស្លាប់ចុះ ឲ្យតែជាតិមនុស្សក្នុងសកលលោកមានជីវិតរស់នៅ ។

៨៩- សាសនារបស់ខ្ញុំមិនមានព្រំដែនតាមភូមិសាស្ត្រទេ បើខ្ញុំមានសទ្ធាជ្រាំងក្នុង, សទ្ធានោះមានពលភាពហួសសេចក្តីស្នេហារបស់ខ្ញុំចំពោះប្រទេសឥណ្ឌៀទៅទៀត ។

៩០- កុំឲ្យដឿថា ខ្ញុំប្រមាថមើលងាយនូវធម្មជាតដ៏អស់ដែលចេញមកពីខាងបច្ចិមប្រទេស ។ មានធម្មជាតជាច្រើនដែលខ្ញុំបានផ្ទេរយកនូវពីប្រទេសនេះ ។

ប្រវត្តិសាស្ត្រនៃសម័យឱឡុកខ្មែរបុរាណ

លោក សាស៊ែ - ស៊ីដែស តែង

លោកវ៉ាយ - ប៉ែក ក្រែមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

ពួកចាំឯនេះត្រូវធ្វើការពេលថ្ងៃ ចាំឯត្រូវបង់ប្រាក់ដែលអ្នកកសាងវត្តបានបង្គាប់ឲ្យធ្វើបេង មានអនុក្សម្នាក់ត្រួតត្រាពួកចាំឯប៉ុន្មានបេងជាពីក្រុមក្នុងមួយក្រុមៗ ត្រូវធ្វើការមានវេនផ្ទាស់គ្នាក្នុង ១ ខែ ១៥ ថ្ងៃជាលំដាប់ ។

គោគទ្យនៃប្រាសាទ វត្តចាំឯនោះមានច្រើនឥតគណនា ។ បដិមារូបមួយធ្វើពីសិលាដំកល់ទុកនៅក្នុងវត្តចំពោះមុខត្រើមួយៗ មានគ្រឿងអលង្ការពេញបរិបូណ៌ គឺមានគ្រឿងមាសនឹងប្រាក់មកុដពជ្ឈ, កងក, ខ្សែខ្ចូន,ការពាក់ត្រចៀក, ចិញ្ចៀន, ខ្សែដៃ, កងជើង ។ ឃ្លាំងនៃវត្តឬប្រាសាទនេះ មានគណ្ឌីសម្រាប់ធ្វើពិធីនឹងគ្រឿងប្រដាប់ឯទៀតជាច្រើនរចនាដោយមាស, ប្រាក់, ស្ពាន់ឬលង្ហិន ។ ដល់មកចុងសតវត្សទី ១២ ប្រាសាទដែលជាស្ថូបសម្រាប់ដំកល់អដ្ឋិធាតុ មានគោគទ្យសំបើមអស្ចារ្យ ដែលគេបានឆ្លើបញ្ជីចុះនាមរបស់ដោយពិស្តារ ។ នៅប្រាសាទតាព្រំដែលជាប្រាសាទកសាងចំពោះព្រះជនន៍នាថ សិទ្ធិត្រួតត្រាលើភូមិ ៣.១៤០ ពជបរិវារ ៧៩.៣៦៥ នាក់ ។ ក្នុងចំនួនពជបរិវារនេះមាន

១២.៦៤០ នាក់ ដែលនៅប្រចាំក្នុងកំពែងជ្រុងសាទ ។ ក្រៅពីនេះមាន លោកសង្ឃដែលជាចៅអាវាស ១៨អង្គ, លោកសង្ឃសម្រាប់សូត្រពិធី ២ ៧៤០អង្គ, អ្នកប្រជាស្រុក ២.២០២ នាក់, នាងនាដកា ៦១៥ នាក់ ។ ជ្រុងសាទនេះមានឃ្លាំងមួយមានសុវណ្ណភាជន: មួយទម្ងន់ ៥ ០០០ គីឡូ, មានភាជន: ជ្រុងជាច្រើន, មានតួងពេជ្រ ៣៥ គ្រាប់, កែវមុក្តា ៤០.៦២០ គ្រាប់ ទឹងតួងឯទៀតជាច្រើនចំនួន ៤.៥៤០ គ្រាប់, មានសុវណ្ណកិង្ការមួយធំព្រមទាំងមុងវិស្សប្រទេសចិន ៤៦៧, គ្រែសំពត់ព្រៃ ៥១២ ធ្នែរួត ៥២៣ ... ។

ក្រមព្រះនគរជ្រលនៃព្រះវិហារទាំងនោះជ្រានបញ្ញត្តតឹងរឹង គឺហាមមិនឲ្យចូលទៅក្នុងជ្រុងសាទឬព្រះវិហារទាំងនោះ ដោយជិះសេះឬជ្រុងធ្នែត, ត្រូវតែទទួលដោយពាក់ទាន់ខ្លួនអ្នកដំណើរ, ចិញ្ចឹមអ្នកគ្រលំជ្រក, មនុស្សចាស់ ហើយត្រូវគោរពអ្នកទាំងនោះតាមឋានន្តរស័ក្តិខ្ពស់ទាប: ពួកព្រាហ្មណ៍, ព្រះអង្គម្ចាស់, មន្ត្រី, មេទ័ព ។ មួយវិញទៀត ជ្រុងសាទដែលកសាងសម្រាប់សាសនាមានសិទ្ធិដោយខ្លួនឯក គឺមិនមានកំណែន, មិនបង់ពន្ធធម្មជាតិ, មិនបង់ពន្ធឲ្យភាជកណ្ណាគារ (Magasins royaux) មិនត្រូវនៅក្រោមបង្គាប់នៃភាជការខែត្រ, ត្រូវនៅក្រោមបញ្ជាការនៃអំណាចវង្សត្រកូលពួកជនក: ឬលោកសង្ឃ ដែលពួកជនក: ជ្រានផ្ទេរអំណាចឲ្យត្រួតត្រា ។ អក្សរនៅក្នុងសិលាចារឹក គឺពណ៌នាអំពីសិទ្ធិទាំងនោះនឹងរៀបចំទូវកេតនភ័ណ្ឌ (Attributs) សព្វៗខ្លួន ។

ពីកាលមុននោះ ខ្ញុំបានអធិប្បាយអំពីភាពដូចគ្នានៃព្រះមហាក្សត្រ ប្រៀបធៀបទៅនឹងព្រះ គឺជាបដិមារូបនៃព្រះមហាក្សត្រសម្មតិជាព្រះមួយអង្គ ត្រមាំងនាមបដិមា (Symbolisme) នៃព្រះពាជនគរដែលស្ថាបនាឡើងមានលំនាំជាតំណាងចម្រាក់ឡជាខ្នុតភាព (En miniature) យើងអាចយល់បានថាកិច្ចការក្នុងនគរ ដែលយើងទុកជាកិច្ចរបស់គ្រហស្ថត្រឡប់ទៅជាកិច្ចការខាងសាសនា បុរាណទំនៀមទម្លាប់ប្រពៃណីទៅវិញ ។ ព្រះវិហារដែលនៅចំកណ្តាលព្រះពាជនគរ ដែលមានស្ថានភាពខ្ពង់ត្រាយជាចេតិយ គឺសម្មតិនាមដាក្តីព្រះសុមេរុដែលនៅចំកណ្តាលលោក, កំពែងព្រះវិហារនោះជាបរិវារក្តីព្រះសុមេរុដែលព័ទ្ធជុំវិញចម្រាក់ឡ, ព្រែកជីតដែលរចនាប្រៀបទៅនឹងមហាសាគរ ដែលនៅជាតក្តីព្រះសុំមេរុនឹងជួរក្តងៗ, ស្ពានដែលមានរចាំងជារូបនាគនោះគឺជាឥន្ទធនូដែលជាផ្លូវគមនាគមចំពោះពិភពលោកៈទៅកាន់សុវណ្ណភូមិ, ច្បាសាទតូចៗ ដែលមានរចនាខាងក្រៅមានរូបបក្សានោះ គេទុកជាច្បាសាទប្តីមានអណ្តែតដែលមានទេវតាឥន្ទ្រព្រហ្មស្ថិតនៅក្នុងទីនោះ ។

មិនតែប៉ុណ្ណោះ ការចាប់ដំទំនើបប្លែគប៉ោះបង់ចោល ត្រមាំងចាត់មនុស្សឲ្យទៅតាំងទីលំនៅ។ ទីនោះ សុទ្ធតែមានរៀបពិធីខាងសាសនាដែលជាឫកគោលនៃកម្មកាពជាតិខ្មែរសម័យបុរាណ ។ ខ្ញុំមិនមែនពោលថាកិច្ចការតាំងអស់ចំពោះការដែលយកផលពីព្រៃធរណីនោះ មាន

សាសនាជាបុព្វហេតុ តែបើតាមពិត កិច្ចការកសាងវត្ត ឬសាងព្រះសាទ សម្រាប់ជាក់អដ្ឋិធាតុនីមួយ។ ត្រូវបង្កើតឲ្យមានភូមិមួយឬច្រើន ហើយចាត់បង់ពន្ធឲ្យទៅតាំងទីលំនៅ។ ភូមិនោះ ត្រូវមានជីកស្រះជាប្រយោជន៍ដល់ព្រះវិហារឬព្រះសាទនោះ នឹងប្រជាកសិករជាច្រើនដែលត្រូវទៅថែទាំបោសសំអាតព្រះវិហារ ។

សិលាចារឹកនាំឲ្យបានឃើញអំពីការជីកស្រះឬទឹកបឹងទេស (pièces d'eau) ជាច្រើនកន្លែង; កិច្ចការនេះសំខាន់បំផុតចំពោះប្រទេសនេះ, បើគ្មានទឹក គ្មានការដាំស្រែចំណាំ ដីដែលប្រកបដោយខ្យាច់ច្រើនទៅជាគ្មានផល ។ ក្បួនធារាសាស្ត្រនៅភូមិភាគអគ្នេយ៍ជាស្នាព្រះហស្តសម្តែងអស្ចារ្យ នៃព្រះមហាក្សត្រិយ៍ជាច្រើនសន្ធតិវង្ស ដែលពួកអ្នកឯកទេស (spécialistes) បានកោតសរសើរជាអនេកប្រការក្នុងរឿងនេះ ។ ក្នុងពេលមុននេះ, គេបានចាត់តាំងក្បួនធារាសាស្ត្រកសិកម្ម (hydraulique agricole) ដោយប្រើព្រែកជីកតាំងប៉ុន្មាន ត្រមតាំងលៃលកន្លះស្រះបាយ័ខាងត្បូងដែលជាស្រះធំ ដីតពីគាលសតវត្សទី ១១ ស្ថិតនៅខាងលិចអង្គរឲ្យមានទឹកបរិបូណ៌ឡើង, កិច្ចការនេះ អាចធ្វើឲ្យវាលស្រែនោះមានផលសម្បូណ៌ឡើងបាន ។ ស្នាព្រះហស្តនៃព្រះមហាក្សត្រិយ៍សម័យបុរាណ ដែលគេមិនយកមកអនុវត្តនាការជាច្រើនសតវត្សមកហើយ នាំឲ្យភូមិភាគដែលសម្បូណ៌ហើយមានពលរដ្ឋ

ជាច្រើន ទៅជាជនបរទ្រឹត្រឹតលំបាក់ទៅវិញ ។ ស្ថាព្រះហស្តមោះមាន
បំណងចង់ឲ្យមានប្រយោជន៍ដល់ប្រជាជនទាំងអស់ តែបើតាមពិតិត្យគង់
មានបញ្ហាសាស្នាទៅលាយឡំជាមួយផង ។ ហើយចំពោះសិលាចារឹក
ដែលស្ថិតនៅទាំងបួនជ្រុងនៃស្រះបាក់យទាងកើត ដឹកពីចុងសតវត្ស ៩
ទាងកើតព្រះពជ្ជាន័ តទ្បាវ័ងឹកអស់, ព្រះមហាក្សត្រិយ៍ យសោវ្ម័ន
ព្រះអង្គទ្រង់មានព្រះបន្ទូលសួរសុីហនាទចំពោះស្ថាព្រះហស្តនេះ ហើយ
ទ្រង់បានធ្វើព្រះពជបណ្តាំដល់ព្រះពជាយាទនឹងស្តេចដែលសោយរាជ្យ
ក្រោយតមកទៀតថា: "សូមឲ្យការពារនូវព្រះពជកុសលដ្ឋានទាំងនេះ";
ទៅទីនេះ ព្រះអង្គបានប្រើពាក្យដែលគេសម្រាប់ប្រើទាងព្រះវិហារដែល
សាងសម្រាប់សាសនា ដែលមានហេតុទាក់ទងចំពោះគុណសម្បត្តិទៅ
បរលោក ។

ផលប្រយោជន៍ ដែលបានពីដីដោយយកទឹកស្រះនេះស្រោចនឹង
ចំនួនពួកក្សត្រតរដែលយកមកប្រើក្នុងកិច្ចនេះ, គេអាចយកមកធ្វើជា
របៀបពិនិត្យគ្រោងការគួរជាទីពេញចិត្តអ្នកនិពន្ធ ដោយកត់ស្រង់វត្ថុធាតុ
ទាំងប៉ុន្មានដែលមានក្នុងសិលាចារឹកនោះ ។ ដីដែលជាកម្មសិទ្ធិនៃព្រះ
វិហារប្តូរសាទទាំងនេះ, មានឯកសារបញ្ជាក់ដោយច្បាស់លាស់អំពី
ទីកន្លែង, ចំនួន, របៀបដែលដីទាំងនោះបានមកពីពួកទាយក ។ គេ
បានឃើញនូវការប្រស្រ័យគ្នាទៅវិញទៅមកចំពោះពួកពាណិជ ដោយ

ពួកខ្មែរបុរាណមានប្រើក្បួនបកតិសំខ្យា (système numéral) ដ៏ល្អ
ហើយខ្មែរទាំងនោះមិនចេះប្រើរូបិយវត្ថុ ។

ជាតិខ្មែរ, បើតាមសេចក្តីពិត ឋានវត្ថុនាការជាធំពួកជាតិឯទៀតដែល
នៅកងពួកដែលប្រជាជាតិភាសាមន-ខ្មែរ (groupe ethnolinguistique mon-
Khmer) តែចំពោះក្បួនបកតិសំខ្យា បុរាណសំខ្យា នៅល្ងង់ជាងគេ ។
ចំណែកខាងជាតិភ្នង, សម្រែ, ម៉យ មានពាក្យសម្រាប់ហៅគ្រប់គ្នាចំពោះ
លេខតាំងដប់; ជាតិខ្មែរចេះកាប់លេខត្រឹមតែ ៥; ឯលេខ ៦ ជាតិនេះ
ពោលថា ៥+១; លេខ ៧, ៨, ៩ ពោលថា ៥+២, ៥+៣,
៥+៤ ។ តែឥឡូវ ជាតិខ្មែរមានពាក្យហៅ ៣០, ៤០, ៥០ ។ល។
ដោយខ្ចីពីសៀមយកមកប្រើ; ពីដើមមានតែពាក្យហៅថា: ១០, ២០,
៤០០; ឯពាក្យ ១០០ ហៅតាមភាសាសំស្ក្រឹតថា សត (çata) ។ លេខ
១៤៨ ពីដើមពោលថា: "មួយរយមួកពីរដង[ចុំាបី" (១០០, ២០
ពីរដង, ៥+៣); លេខ ៦៣៧ ពោលថា: "ប្លុនរយ, ពីរយ
មួកមួយដង, ដប់, [ចុំាពីរ" (៤០០, ២០០, ៦០ មួយដង ១០, ៥+២)។

បើតាមសិលាចារឹកមិនឃើញមានពោលអំពីរូបិយវត្ថុ ([ចុាក់)
ហើយការដែលស្វែងគាស់កកាយរកតាម[ចុាសាខ មិនដែលឮថាមាន
រូបិយបុរាណសោះឡើយ (រៀវលែងតែមានសាកាឮ ដែលគ្មានឃើញ
គឺ[ចុាក់ដែលគេរកឃើញពីបុរាណសម័យនៅប្រទេសសៀម,

ភូមា ឬសម័យនគរភ្នំ) ។ ព្រោះហេតុដូចនេះ, ការប្រែស្ម័យគ្នាទៅ
វិញទៅមក ដូចជាការរំលឹកដែលគេបានកត់ត្រាទុកនូវសិលាចារឹកគឺធ្វើ
ដោយការដូរគ្នាទៅវិញទៅមកយ៉ាយរបស់ផ្សេងៗមានថូធ្វើនឹងលោហជាតុ
មានតម្លៃ ឬ ធ្វើនឹងស្ពាន់, ត្រឿងប្រដាប់ចំរើនអាហារជាច្រើន, ខោអាវ,
សំពត់, អង្គប្រស្បែ, សត្វតោមាន, ទាសករ ។ ការប្រែប្រួលជាច្រើន
លើកកងកំឡាំងសតវត្សទាំងនោះ ចំពោះការយកវត្ថុគ្រប់យ៉ាងទៅដូរយក
ដីមានចំនួនប៉ុន្មានៗនេះ ជាការមានប្រយោជន៍សំខាន់ចំពោះប្រវត្តិការ
នៃកម្មសិទ្ធិអសង្ហារិមកម្មវត្ថុ ។

ការលំបាកដោយប្រើក្បួនតួន្ត លេខសំគាល់នឹងការប្រែស្ម័យគ្នាទៅ
វិញទៅមក គឺមកពីគ្មានរូបិយវត្ថុ ។ ព្រោះហេតុដូចនេះ ខ្ញុំសូម
ពណ៌នាអំពីរឿងកំរៅទាំងពីរបែបនេះ ឲ្យមានសេចក្តីពិស្តារបន្តិចដើម្បី
នឹងបង្ហាញឲ្យឃើញថា ហេតុម្តេចក៏ប្រទេសដែលស៊ីវិល្យដែលគេទុក
ថាវិសេសវិសាលចំពោះបញ្ហាខ្លះ ទៅជាមានគំនិតប្លែកគួរឲ្យសង្ស័យ ។

បញ្ហាទាងសម្ភារៈ ចំពោះដំរីតាមនៃឡូរបូកណា, គេហាជ្ជនទាំង
នោះ, ត្រឿងតុបតែង, ត្រឿងទបកាត, ត្រឿងការពារយុទ្ធភ័ណ្ឌ,
កុលាលភាជន៍, របៀបធ្វើឆ្នាំង, ចាន, ថូ (céramique). ការត្បាញសំពត់,
ត្រឿងអលង្ការសម្រាប់តែងកាយ គួរតែពណ៌នាឲ្យបានក្បោះក្បាយថែម
មានរូបគំនូរជាច្រើនទៀត ។ កិច្ចពិនិត្យត្រួតពិនិត្យការនេះ លោកសិរីស៍

ត្រូស្ស៊ីយេរ (Georges Groslier) បានរៀបចំតែក្នុងសៀវភៅលោកហៅថា "រីសែរស៍ ស៊ើរឡេកាំបូដស៊ីយាង (Recherche Sur les Cambodgiens) ដែលបានធ្វើជាពិពណ៌នា (partie descriptive) ដោយមានរូបគំនូរក្បាច់រចនាអង្គរវត្ត នឹងប្រាសាទប្រាយ័នគួរជាទីទស្សនាពន់ពេក ។ ចំពោះរឿងនេះមានសិលាចារឹកជាច្រើន ដែលបានអធិប្បាយពីបន្លាយវត្តផ្សេង ។ ដែលជាគ្រឿងអលង្ការនៃរូបចំឡាក់នឹងកោតខ្ពស់នៃប្រាសាទទាំងនោះ ។ មានវាក្យដែលគេហៅនាមនៃវត្តទាំងនោះ ឥឡូវគេលែងប្រើហើយមិនអាចបកប្រែបាន តែគេអាចយល់បានថាជានាមវត្តដែលចារឹកទុកនឹងផែនសិលា គឺជានាមវត្តដែលមានក្នុងប្រាសាទនោះ ។ ការនៅសល់ដែលយើងត្រូវព្យាយាមធ្វើតទៅទៀត ជាការមិនមែនងាយ គឺត្រូវស្វែងរកន្លឹះនាមពិតនៃវត្តទាំងនោះយកទៅប្រៀបធៀបនឹងនាមនៃវត្តដែលបានកត់ត្រាទុកនៅសិលាចារឹក ។

ចំពោះអក្សរសាស្ត្រ ជាតិខ្មែរបានទុកកេរ្តិ៍តំណែលឲ្យយើងចំពោះតែសិលាចារឹកជាភាសាសំស្ក្រឹត ។ អត្ថបទខ្មែរគ្មានតែពណ៌នាពីរឿងរ៉ាវក្នុងកាំង មិនអាចយកជាឯកសារនៃអក្សរសាស្ត្របានឡើយ ។ ឯអត្ថបទសំស្ក្រឹតសុទ្ធតែជាពាក្យកាព្យទាំងអស់ ប្រមូលរៀងជាគាថានិទាន មានតែជាបឋមបទជាពាក្យប្រកាសទាន៍សាសនា ដើម្បីរាប់នាមរបាក្យត្រៃយ៍នឹងសន្ធក្តីវង្សនៃមហាពលដែលសោយរាជ្យក្នុងពេលនោះ

ដែលខ្ញុំបានយកអត្ថបទខ្លះមកចុះបង្ហាញពីមុនជាគំរូស្រាប់ហើយ មានបរិយោសានបទជាពាក្យសរសើរ ខ្ញុំតែងតាយកត្រមាំងបែបផែននៃការសាងថ្មាសាទទាំងនោះ ។ សិលាចារឹកទាំងនោះបញ្ជាក់ឲ្យយើងយល់ច្បាស់ខ្ញុំការផ្សាយតំណែលវប្បធម៌សំស្ក្រឹតចូលមកប្រទេសកម្ពុជាសម័យបូរាណ ។ បើគេដឿជាក់ខ្ញុំអាម្ភកថានៃពួកសស្ត្រាចារ្យ នឹងពួកនិស្សិតកន្លងពេលនោះ, គេអាចដឹងបានថា វប្បធម៌សំស្ក្រឹតផ្សាយមកកន្លងប្រទេសនេះបានខ្លះ ហើយកែប្រែចំរើនតាមលំដាប់កន្លងពេលដែលពួកព្រាហ្មណ៍ឥណ្ឌូចូលមកម្ត្តង។ ។ បើតាមពិនិត្យយល់ឃើញចំពោះរឿងដែលបានពណ៌នាជាច្រើនទំព័រនេះផ្សេង។ ពិនិត្យគ្រោងការនេះត្រូវធ្វើទៅតាមមាតិកាដូចគ្នា ទំព័រមាតិកាក្នុងរឿងប្រទេសឥណ្ឌៀ គឺ: អត្ថបទនៃមនុម្ភាប់, ក្បួនទស្សនវិទ្យា, វេយ្យាករណ៍, ការជកស្រង់បញ្ចេញញ័ត្តិច្បាប់សាស្ត្រទំព័រតាកសាស្ត្រ, វេជ្ជសាស្ត្រ ។ រីឯនិទានកវីនិពន្ធ (poèmes épiques) នេះជាប្រភពដ៏សំខាន់ប្លែកគតិនិម្មិតនៃពួកកវីចាំងប៉ុន្មាន ត្រមាំងពួកជាងគំនូរទំព័រជាងធ្វាក់ក្បាច់ដញ្ជាំងថ្មាសាទ ។

(មានត)

លោកម៉ុញ - ដាំគ្រី អតីតតំណាងរាស្ត្រ រួបរួម

(ត្រមក)

Lexique = សព្ទានុក្រម

Vocabulaire = វាក្យសព្ទ

Mot = ពាក្យ

Phrase = ប្រយោគ

Etymologie = និរុត្តិសាស្ត្រ

Etymologiste = អ្នកនិរុត្តិសាស្ត្រ

Syntaxe = វាក្យសម្ព័ន្ធ

Grammaire = វេយ្យាករណ៍

Grammairien = អ្នកវេយ្យាករណ៍

អង្គរ ៤១ ពុទ្ធៈ ១៩៨១

Parti de l'Union démocratique = គណៈបក្ស "សហប្រជាធិបតេយ្យ"

Disciple = សាវ័ក

Condisciple = សមានាចារ្យ

Un maître sévère = គ្រូបឹងប្រៀន

Un maître inflexible = គ្រូតឹងរ៉ឹង

ថ្ងៃ ៣០ ខែឧសភា ១៩៤០

Le talent = ភាវប៉ិន

Talentueux = ប៉ិន

Une notion = សញ្ញាណ

Notion préliminaire = បុព្វសញ្ញាណ

Le zèle = យតិភាព

La culture générale = សារពើវប្បធម៌

La culture intellectuelle = បញ្ញាវប្បធម៌

Un élève étourdi = សិស្សរាយឆាយ

Un élève distrait = សិស្សរេឃមាយ

L'étourderie = សេចក្តីរាយឆាយ

La mémoire = សតិ, ស្មារតី, វិញ្ញាណក្ខន្ធ

Le mémoire = សារណា

L'imagination = មនោគតិ

ថ្ងៃ ២ ខែមិថុនា ឆ្នាំ ១៩៤០

លោក សាង - សារ៉ាត លេខាធិការក្រសួងហ៊ារញ្ញវត្ថុ

ប្រែពីភាសាហ្ការ៉ាំងមកជាខ្មែរ

(តមក)

៩ - ប្រុសមួយប្រពន្ធបី

"ស្រីណាស្មោះសរ សោមនស្សសាទរ មួលមិត្រស្នេហា ប្តូរជន្មជីវិត ផ្តាប់ចិត្តកស្តា ផ្សងតាមវាស្នា ត្រេងពីនាយមក។ បំរើស្វាមី ផ្តឹតផ្តង់ស្មារតី ចិត្តគ្មានរលក ពេលមានទុក្ខផង ត្រូវធ្វើរកគ្រប់ កិច្ចតស៊ូជ្រែតជ្រក ឲ្យផុតទុក្ខគ្រោះ។ ប្រុសណាបើបាន ស្រីតបកល្យាណ ដូចបានពោលនោះ ត្រូវតែថ្នាក់ថ្នម ដោយកិច្ចសង្រ្គោះ កុំឲ្យមានមោះ ហ្មងមួយដំរ៉ាំ។ ស្រីណាតាំងខុស គោរពជាតំប្រុស ដោយខ្លាចគេថា បំរើស្វាមី គ្មានក្តីជ្រះថ្លា ស្រីនេះហៅមហាកាឡកណ្ណី។ ប្រសិនប្រុសណា យកជាកវិយា ទំនើតអប្រិយ ជាមដល់អាត្មា ទុក្ខាកក្រី ត្រូវលះចោលខ្មីរកស្រីខៀតវិញ"។

រឿងភាវៈគ្រោយថ្នង់នេះ ដូចមានសេចក្តីដំណាលថា កាលណោះ ក្នុងស្រុកតម្ពូត្បូមានលោកអតិជនម្នាក់ជាមហាសេដ្ឋី។ មហាសេដ្ឋីនេះ

ជាប់តូដតង្វែវែង្រ្តែកូលរន្ទាយន្ទាយអំពីព្រះមហាកស្ត្រែបន្តិចផង ប៉ុន្តែ
វត្តុដទៃក្រៅអំពីទ្រព្យសម្បត្តិរបស់លោកគ្មានអ្វីជាសំខាន់ឡើយ ។ ឯរឿង
ដែលយើងនិទានេះ មិនមែនរឿងរបស់លោកទុំះទេ គឺជារឿងរបស់កូន
លោកដែលបានដើរផ្សងព្រែងសំណាង; លោកអ្នកចាំងឡាយកាលបាន
មើលឬស្តាប់គង់ចាប់ចិត្តចាប់គំនិតពុំខាន ។

មានបុរសម្នាក់ជាកូនមហាសេដ្ឋីនៅស្រុកកម្ពុត្ស មាតាបិតាបានរៀប
មង្គលការឲ្យមានកិយាតាំងអំពីកាលនៅក្មេង តាមទំនៀមទម្លាប់ស្រុក ។
កន្លងវេលាកន្ត្រីស្វាត់មួយ បុរសនេះមានសុបិននិមិត្តឃើញគេមកប្រាប់ថា
ខ្លួននឹងស្លាប់ដោយពស់ចឹក ។ ចាប់ដើមអំពីថ្ងៃដែលឃើញសុបិនមក
បុរសនេះចេះតែមានបារម្ភទុក្ខព្រួយជានិច្ចកាល ដោយក្រែងខ្លួនស្លាប់ដូច
យល់សប្តិនោះមែន ទើបនិយាយប្រាប់មាតាបិតានឹងកិយាថា "បើសិន
ណាខ្ញុំស្លាប់នឹងពស់វែកចឹកដូចខ្ញុំបានយល់សប្តិមែន ខ្ញុំសូមផ្តាំផ្តាច់ កុំធ្វើ
ឈាបនកិច្ចរូបខ្ញុំ ឲ្យយកសពខ្ញុំទៅចងនៅលើក្បូនមួយ រួចបណ្តែត
ក្បូនតាមទៀងទឹកទៅ" ។

ចំណែកអស្ចារ្យណាស់ ការណ៍ដែលបុរសនោះបានយល់សប្តិចាំង
ប៉ុន្មានក៏មានមែនត្រូវប្រាកដ ។ ថ្ងៃមួយនោះ អ្នកដើរកាត់ព្រៃ
ស្រាប់តែពស់មួយចឹកដៃអ្នក, រួចក្នុងថ្ងៃនោះអ្នកក៏ខ្លួលមរណភាពទៅ ។

ឯនាងជាកវិយាតតបានយកវ្ថូបសពប្តីទៅបូជាទេ នាងធ្វើតាមបណ្តាំ
ស្វាមី ។ នាងឲ្យគេយកខ្សែសូត្រយ៉ាងល្អចងរូបនោះនៅលើក្បូនឫស្សី
មួយហើយនាងឃុបផ្តា បណ្តែតក្បូននោះទៅ ទាំងមិនឲ្យអ្នកណាមួយ
អុំទូកតាមមើលឬនឹកនាអ្វីឡើយ ។ នាងបានធ្វើតាមពាក្យប្តី នាងពេញ
ចិត្តឥតរង្គើស ។

ឯក្បូននោះអណ្តែតទៅៗដោយស្រួលតាមទន្លេ ។ ដល់កន្លងទៅ
បានចំនួនច្រើនសប្តាហ៍ ក្បូននោះទៅដល់ប្រទេសមួយ ដែលមានគ្រូ
អាលម្ភាយម្នាក់យ៉ាងពូកែ ។ លោកគ្រូនេះមានកូនស្រីប៉ែនាក់ ។ ក្នុង
ពេលដែលក្បូនអណ្តែតទៅដល់មុខផ្ទះគ្រូនេះ នារីទាំងបីដើរទៅដល់មាត់
ច្រែកបុរាំងនឹងចុះទៅសំអាតសក់ដូចសព្វដង ។ នាងច្បងក្រឡេកពីលើ
មាត់ច្រាំងទៅឃើញក្បូន ហើយនិយាយទៅកនាងប្អូនទាំងពីរថា "មើល
នោះហ្ន៎! ក្បូនមួយអណ្តែតចុះមក មានទាំងរូបបុគ្គលមួយផង" ។

នាងបន្ទាប់ឆ្លើយថា "មែនអ្នកបង! មើលហ្ន៎ដៃគាត់ហើមឡើង
ភ្លៅ, មនុស្សនេះមុខតែស្លាប់ដោយសារពស់ចឹកមិនខាន" ថាហើយនាង
ក៏យកឫស្សីមួយរែង គាវទាញក្បូននោះបន្តិចម្តង ។ មកជិតច្រាំង ។
ក្នុងពេលនោះ នាងទៅបំផុតទំនៀតពាក់ប្រឆាប់តែទៅហៅឪពុករបស់
ខ្លួន ដែលជាគ្រូចេះមន្តអាលម្ភាយយ៉ាងឯកក្នុងដំបន់នោះ ។

ឯនាគរាជក៏មកដល់ភ្លាម ហើយយកថ្នាំឥតឈឺបន្តិចសោះ ។ ស្រួលដាក់ថ្នាំរួចហើយ ប្រុសគ្មានកំរើករំពើកបន្តិចសោះ ។ គ្រូនោះក៏បណ្តេញកូនរបស់គាត់ទាំងអស់ឲ្យចេញសិនចេញឆ្ងាយអំពីទីនោះបន្តិច រួចគាត់តាំងសូត្រអាគមគាថាយ៉ាងអស្ចារ្យណាស់ ។ មិនយូរប៉ុន្មានបុរសនោះបើកភ្នែកបន្តិចម្តងៗ ឯាកមើលជុំវិញខ្លួនគាំងស្មារតី រួចដល់ដឹងខ្លួនមែនទែនក៏ត្រេកអរខ្លាំង ហើយសាកសួរលោកគ្រូដែលបានជួយសង្គ្រោះជីវិតខ្លួន អំពីរឿងហេតុដែលមានមកទាំងប៉ុន្មាននេះ ។

ប៉ុន្តែដើម្បីនឹងពន្យល់ឲ្យបានច្បាស់ អំពីរឿងដែលមានតទៅមុខទៀតនោះ យើងគោងដំណាលជាមុនថា បុរសនេះមានរូបរាងល្អល្មមពណ៌ស្អាតស្អាងណាស់ ភង្កស្តើង ភ្នែកភ្លៅរលោង ឫកពាសមសួនសុភាពរាបសា ។ ឯគ្រឿងសំលៀកបំពាក់នឹងមាសពេជ្រដែលអ្នកពាក់ជាប់នឹងខ្លួនបង្ហាញឲ្យឃើញច្បាស់ថា អ្នកជាកូនចៅអ្នកមានតូចអំបូរខ្ពង់ខ្ពស់ក្នុងលោកិយនេះ ។ លុះនាងទាំងបីដែលតួនតីគ្រាយដើមអម្ពិលទឹកមួយធំនោះឃើញរូបបុរសល្អដេតឆាយយ៉ាងនេះ ក៏ចាប់ចិត្តស្នេហាជាពន់ពេក ។ នាងទាំងបីនាក់ទឹកក្នុងចិត្តថា នាងទើបតែបានជួយស្រោចស្រង់ជីវិតព្រះមហាក្សត្រមួយអង្គដែលគ្រងរាជ្យក្នុងអាណាចក្រមួយដ៏ត ។ នោះ ។

ក្នុងពេលនោះ បងប្អូនទាំងបីនាក់ប្រកែកគ្នាដោយការគតិដូចមានតទៅនេះ :

នាងឃ្វាងនិយាយថា "អញ្ជើញបុរសនេះមុនគេនៅលើក្បួន ត្រូវតែអញ្ជើញកគាត់ធ្វើជាប្តី" ។ នាងបន្ថាប់តបថា "ទេមិនត្រូវទេ; ខ្ញុំទេដែលត្រូវបានគាត់ ព្រោះថាខ្ញុំបានទំនាញក្បួន យ៉ាងត្រដេបត្រដាបមកជិតចប់ឆ បើអត់ពីខ្ញុំទេនាងគាត់មុខតែអណ្តែតបាត់ទៅហើយ" ។ នាងពៅនិយាយថា "ទេនៅតែមិនត្រូវទេតើ ខ្ញុំបានទៅហៅលោកឥតុកមក, ខ្ញុំបានជួយយោងជីវិតគាត់ ហេតុដូច្នេះ មានតែខ្ញុំមួយទេដែលត្រូវបានគាត់" ។

ឯការប្រកែកប្រណាំងរឿងនោះ កំពុងតែវែងទៅ។ ។ កន្លងពេលនោះ ឥតុករបស់នាងកំពុងនិយាយរៀបរាប់អំពីស្រុកទេសចាប់បុរស ។ ឯរូបនឹងឫកពារបស់បុរសនេះពិតជាល្អមែនហើយ បានជានារីពាំងបីចាប់ចិត្តដល់ម្ល៉ះ ។ តើអ្នកណាមួយអាចមើលឆ្លុះ? ចិត្តមនុស្សស្រីមិនងាយនឹងសំគាល់បានឡើយ ទោះតាំងពីណាមកក្តី ទោះឥឡូវនេះក្តី ។ ចិត្តមនុស្សស្រី គេទុកជាអណ្តូងនៃសេចក្តីពិតនឹងសេចក្តីមិនពិត ជាអណ្តូងកុសលនឹងអកុសល ជាអណ្តូងនៃសេចក្តីលោភនឹងសេចក្តីផ្តួយដោះសារគ្នា ជាអណ្តូងនៃសេចក្តីស្នេហានឹងសេចក្តីនិន្ទា ជាចិត្តប្រឡូកភ្ញាំងគ្នាកន្ទឹងឆឹត; ទៅពីលើអណ្តូងនេះ មានខ្សែស្ពឺមួយដែលចាំងភ្លឺព្រោងព្រាយល្អអនេក នាំឲ្យតែវង្វែកអកមើលចាំងភ្លាយភ្លឺរាល់ស្រុកស្រាងរង្វែងអស់ ។

គ្រាយបន្តិចមក នាងប្អូនដែលមានចិត្តអៀនខ្មាសនឹងការប្រឈ្មោះឯណ្តើមប្តីគាត់នេះណាស់ ។ មួយទៀតប្រពៃលនាងខ្លាចក្រែងដល់គ្រាយទៅមិនឈ្នះនាងប្អូន ។ ដែលទៅក្នុងជាងខ្លួននាងក៏និយាយដោយបង្អន់សំឡេងថា "នែប្អូន ! យើងមានបងប្អូនតែបីនាក់ប៉ុណ្ណោះ, ពីដើមយើងស្រឡាញ់គ្នាណាស់ ។ ឥឡូវយើងមិនគួរមកប្រឈ្មោះគ្នាដណ្តើមប្រុសម្នាក់យ៉ាងដូច្នោះទេ ។ ទោះបីប្រុសនោះជាស្តេចសោយរាជ្យក៏ដោយ គោងយើងនឹកដល់ពាក្យដំបូន្មានចាស់ ហើយនាំគ្នាកុំរវល់ស្រឡាញ់បុរសនេះទាំងអស់គ្នាទៅ ។ ឥឡូវនេះគេមានជីវិតទៀងវិញហើយដោយសារសំលៀកសាស្តារបស់ឥតុកយើង គួរណាស់តែយើងជួយគេឲ្យគេបានទៅដល់ផ្ទះសំបែងរបស់គេដោយស្រួល ហើយយ៉ាងរហ័សផង ។

នាងប្អូនទាំងពីរគិតមួយស្របក់ ក៏សុខចិត្តធ្វើតាមពាក្យនាងច្បង ហើយថែមទាំងបានសន្យាទាំងជួយបុរសនោះឲ្យបានទៅដល់ផ្ទះវិញ ។ នាងច្បងក៏ធ្វើឧបាយទៅនិយាយនឹងឥតុករបស់នាងថា សុំយកកម្រងផ្កាមួយយ៉ាងល្អទៅចងកឲ្យបុរសនោះ ។ កងរណៈនោះនាងបន្ធូរយកខ្សែសូត្រមួយយ៉ាងចំខ្សែក ដែលឥតុកនាងលាក់ទុកកន្លងហិបទៅចងកឲ្យបុរសនោះ ។ លុះគាលណានាងចងស្រេចហើយ បុរសរូបស្អាតក៏ក្លាយខ្លួនក្លាមទៅជាសត្វសេកមួយយ៉ាងល្អពណិខៀវលាយលឿង មានតាំងកងក

មួយ ពណ៌ផ្កាកូឡាបយ៉ាងស្រស់ផង ។ សត្វនេះខ្ចះស្ងាបមួយស្របក់ បង្វិលខ្លួនហាក់ដូចជាសូមលាគេពាល់គ្នា ហើយហើរកាត់តម្រង់ទៅស្រុកកំណើតរបស់ខ្លួនវិញ ។

សេកលុះហើរយូរទៅ ក៏ចាន់ទៅដល់សួនច្បារស្តេចមួយ ហើយចាន់ទំនៅលើមែកឈើដែលមានសន្ទឹកជាច្រើននៅជិតស្រះមួយគូច ។ សត្វសេកចង់សម្លាកខ្លួននៅទីនោះចំទួនត្រឹមតែប៉ុប៊ីមាន់ទេ ប៉ុន្តែដោយសារមួយចំណែកត្រជាក់ល្អផង ដោយសារឃើញសត្វស្វាបងទៀតច្រើនស៊ីផ្លែឈើយ៉ាងសប្បាយក្នុងទីសួននោះផង បក្សាក៏ភ្លេចនឹកនាដល់គោលបំណងនៃដំណើរបស់ខ្លួន ។ បក្សាក៏តាំងទីលំនៅ ។ ទីនោះយ៉ាងក្សេមក្សាន្តជាទីបំផុត ហើយលែងនឹកនាដល់បងប្អូនឪពុកម្តាយប្រពន្ធកូនទាំងអស់ ដែលនឹកស្មានថាអ្នកស្លាប់ចុះតបង់ជីវិតទៅហើយ ។

មានថ្ងៃមួយ នាយសួនច្បារបានយកកន្ត្រែងដែលជាក់ផ្កាន៏ងផ្លែឈើទៅថ្វាយស្តេច ។ ព្រះករុណាក៏ទ្រង់មានព្រះពាក្យថា "នែនាយសួន ! កាលពីមុន ផ្កាន៏ងផ្លែឈើដែលឯងយកមកឲ្យអញសុទ្ធតែល្អទាំងអស់ ចុះហេតុអ្វីបានជាឥឡូវនេះខុសពីដើមម្ល៉ះ អញឃើញប្លែកចំទួនពីរបីថ្ងៃមកហើយ ។

កណ្ដាទី ៣

អ្នកឧកញ៉ាវិបុលរាជសេដ្ឋា និង កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធឹងបេះខុបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

លុះចៅស៊ុនប្រញាប់ទៅនាំបន្ទាន់តៀវសៀនដាប់ហើយយំថា សេចក្ដីខ្ញើតត្រង់សុចរិតនឹងសេចក្ដីស្ម័គ្រស្រឡាញ់របស់ប្អូនខ្ញុំនោះបងបានឃើញច្បាស់ណាស់ហើយ តែថាមានអកុសលមកជំទាស់ ទើបយើងមិនបានដឹងសុខទុក្ខគ្នា ។ នាងតៀវសៀនតបថា ចុំដែលនឹងទំនាក់ទំនងគ្នាខ្លួនក្នុងជាតិនេះមានតែសេចក្ដីលំបាកត្រួយខ្លួឡើងទៀត ព្រោះមានកម្មតាមមកទាន់ជាតិនេះបុណ្យាក់សនាតិចណាស់ ទើបត្រាត់ប្ដាសមិនឲ្យជួបគ្នាជាស្វាមីភរិយា នឹងរស់នៅថ្ងៃក្រោយសូមបាប់កំណើតឲ្យកើតមកជួបជាភរិយាអ្នក នឹងបានប្រណិបត្តិន៍ឲ្យអស់ចិត្តដែលស្រឡាញ់ ។ លុះចៅឆ្លើយតបថា ប្អូននឹងមកធ្វើខ្លួនឲ្យ

ស្លាប់មុនឈឺនោះមិនគួរសោះ នាងចាំស្តាប់តាក្សបងសិនចុះ កុងជាតំនេះ
បើបងមិនបានខ្លួនប្អូនជាកវិយារេ បងក៏មិនស្ងៀមវាស់ជាកូនប្រុសតទៅ
ទៀត ។ នាងតៀវសៀនតបថា តាំងពីខ្ញុំទ្រាំលំបាកវៀងមកជាង ១
ខែហើយ អ្នកអើយខ្ញុំក្តុកក្តង់ខ្លួនខ្ញុំតែតឹម ១ ថ្ងៃវិស័យដូចខ្ញុំក្តុកក្តន់ឆ្មាំ បើ
អាណិតខ្លួនខ្ញុំឲ្យបានខែវាស់ឆ្លើជាកវិយាអ្នក ត្រូវគិតដូចម្តេចឲ្យស្រេច
ដោយរួសពន់ទៅចុះ ។ លីចោ៉ាឆ្លើយថា បងតាមតាំងតុ:ចូលទៅកុង
កាំង ដល់ម្ន្ទេសាសស្រួលបានជាត្រឡប់ចូលមកវាកប្អូន មិនបានចុះបាប់
តាំងតុ:ថាទៅណាទេ ឥឡូវនេះនៅបារម្ភត្រែងតាំងតុ រកមិនឃើញនឹង
សង្ស័យ បើដូច្នេះបងសូមលាប្អូនទៅសិនចុះ ។ នាងតៀវសៀនតបថា
បើអ្នកខ្វាចអាសត្រូវកេញ្ចាស់ហើយ អ្នកប្រហែលមិនបានឃើញមុខខ្ញុំ
ទៀតឡើយ ។ លីចោ៉ាឆ្លើយថា សូមឲ្យប្អូនបង្អង់បន្តិចចុះ ចាំឲ្យបង:ទៅ
ត្រែរិះគិតសិន ។ នាងតៀវសៀនថ្លែងតបថា "ខ្ញុំបានឮគេរ៉ូឈ្មោះ
អ្នកល្បីល្បាញខ្លាំងណាស់ សូម្បីតែឈ្មោះក៏ដូចឆ្កួរខ្លះ ខ្ញុំឮឈ្មោះច្បាស់
មានតែយកដៃខ្ទប់ត្រចៀកជាប ដោយការខ្វាចអំណាចលោក ព្រោះបា
អ្នកខ្លាំងពូកែកងការសង្គ្រាមនឹងគេអ្នកឯណាត្រឹមស្មើគ្នាន ឥឡូវខ្ញុំបាន
ឃើញបានស្តាប់ពាក្យរបស់អ្នកមិនសមដូចពាក្យឮសោះ បើនឹងពីត្រែ:
ម៉ែលទៅឃើញថាអ្នកជាមនុស្សខ្លាច សូម្បីតែត្រឹមអំណាចតាំងតុ:
ប៉ុណ្ណេះខ្លាចណាស់ទៅហើយ បើដូច្នេះហើយនឹងគិតការអ្វីបាន"

ថាហើយក៏ធ្វើជាខ្ចីយំខ្លះគេរៃដៃពីលីចោ៉ាចេញ ហើយសុំទៅទឹង
លោតទឹកសម្ងាប់ ។ លីចោ៉ាទឹកភ្លូចចិត្តណាស់ចោះចោលខ្លួនចេញពីដៃ
ហើយសុំទៅតុបត្រកងនាងតៀវសៀនជាក់លើគ្រែ ហើយនិយាយលួង
លោមថ្នាក់ថ្នមនាងជាយូរណាស់ ។

ចំណែកខាងតាំងតុះកាលដែលកំពុងអង្គុយគាល់ព្រះចៅហៀនតេ
នោះដល់ក្រែឡេកមើលទៅរកលីចោ៉ាពុំឃើញក៏ពិគាល់ក្នុងចិត្ត ។ ខ្លួល
ស្តេចចូលទៅខាងក្នុង តាំងតុះឡើងថើស្រួតមកផ្ទះជាប្រញាប់ស្រាប់តែ
ឃើញសេះលីចោ៉ាចងខ្នុកទៅមុខផ្ទះ ក៏លេះរលាំងឡើងទៅដល់ទីដំណែក
ក្រែឡេកកេន្ទាងតៀវសៀនពុំឃើញ ស្បួតួកស្រីតាំងពួងៗ ជំពប់ថា
នាងចុះទៅមើលសួនផ្កា ។ តាំងតុះក័យន្ធាទឹកថា "ប្រហែលអាលីចោ៉ា
ទៅជួបគ្នាខេដឹង" ហើយប្រឹងចុះដើរទៅតាមមើលដល់សួនឧទ្យាន ។
ឯនាងតៀវសៀនឃាងក្រែឡេកទៅឃើញតាំងតុះចុះទៅដល់មាត់ទ្វារ
ធ្វើជាមាយាសុំទៅទឹងលោតទឹកសម្ងាប់ ។ លីចោ៉ាក៏សុំទៅចាប់តុបចាប់
ពនាងឡើងមកវិញ, តាំងតុះដើរលឿនរលេញទៅដល់ត្រែតអង្គុយកង
សួនឃើញលីចោ៉ាតុបពនាងតៀវសៀន។ បេះប្រែឡេះដៃចេញ. តាំងតុះ
នោះមិញក៏មានសេចក្តីក្តៅក្តៅខ្លាំង ព្រោះមិនដឹងតលមាយាស្រីក៏ស្រែក
ខ្ទ្រាំដីថា ម៉ែអាលីចោ៉ាអាចោរក្បាលអត្រកំហានមកធតំលួចថ្វើមអញ ។
លីចោ៉ាងាកមុខចេញមកមើលឃើញឪឡាស់ជាតាំងតុះ ក៏ភ្ញាក់ខ្លួនដូចជាគេ

កន្លែងក់ សុះខោលខ្លួនដែលជាស់លើគ្រែម្ដងៗទៅ ។ តាំងតុះសុះខោលបានខ្លួនទៅលើគ្រែ បែរដេញតាមប្រកិតទៅផុតអាត់ភ្នែក ។ លុយឃើញហើយក៏សុះទៅកាន់ពាប់ពារលើតាំងតុ.។ ដួលសន្លប់ទៅពីនោះ ។ លុយក៏សុះទៅគ្រាប់លើកឡើងនាំទៅជាស់លើឆ្នេរ, លុះដល់តាំងតុះដឹងស្មារតីសួរលុយថា អ្នកវត់មកមានការអ្វី? ។ លុយឆ្លើយថាខ្ញុំបាទចេញតាមលោកមកពីគាល់ដល់ភ្នែងផ្ទះ គិតនឹងលាលោកត្រឡប់ទៅវិញ ស្រាប់តែឃើញលីចោ"វត់ចេញទៅស្រែកថា "មហាឧបាជដេញកាប់សម្លាប់ហ៊ុយ" ខ្ញុំបាទវត់ចេញមកប៉ងនឹងឃាត់លោក ទទួលលោកវត់ចេញមកទន្ទឹងនឹងខ្ញុំបាទដួលទៅ ខ្ញុំបាទសូមអភ័យទោសលោកចុះ ។ តាំងតុះនិយាយច្រាប់លុយថា អាលីចោ"នោះជាមនុស្សអកតញ្ញូណាស់, បង់កំឡាំងសោះដែលយើងចិញ្ចឹមវាជាបុត្រ គួរឬវាមកលួចហុតឈាមយើង តឹកមកលួចឧបត្រែសោបនាងតៀវសៀនក្នុងទីសួនផ្កា យើងនឹងតាមសម្លាប់វាចេញទើបអស់សេចក្ដីទោមន្ទិលក្នុងចិត្ត ។

លីយូឆ្លើយថា លោកនឹងសម្លាប់លំចោ"ចេញនោះមិនគួរទេ ខ្ញុំបាទសូមនាំសេចក្ដីមកប្រៀបផ្ទួនលោកស្ដាប់: អាល ព្រះពុទ្ធសង្ឃរតនៈដ៏ឯកដំណាំថា ស្ពេចនគរ ១ មានកូនត្រកុំល្អណាស់ប៉ានបាត់ឲ្យគេចូលដណ្ដឹង, ស្ពេចនគរនោះមិនព្រមប្ដាយ, ព្រះពុទ្ធសង្ឃអង្វែងខ្លាល់ ទើបប្រើឲ្យយ៉ងឆាហានឯកលើកពលទៅវាយយកស្រុកនោះបាន, ចៀវយ៉ងក៏នាំ

យកកូនត្រីមុំនោះទៅថ្វាយ ត្រេះបានសង៏អង្គ ។ មានត្រេះបន្ទូលទឹង៏ចៀវ-
យ៉ង៏ថា អ្នកទៅក៏យយកស្រុកបានខ្លឹង៏យកមាង៏នេះមកថ្វាយយើង៏ ។ មិន
ត្រូវទឹង៏ត្រែកអរខ្លួលយកទេ គួរតែអ្នកយកទុកធ្វើជាកវិយាចុះ ស្តេច
លើកនាង៏នោះឲ្យជាកវិយាចៀវយ៉ង៏តាមមានគុណបំណាច់ ចៀវយ៉ង៏មាន
សេចក្តីត្រែកអរគិតកតញ្ញាដល់ត្រេះទៅឧសង៏អង្គ; លុះយូរមកមានសឹក
លើកមកឡោមព័ទ្ធទីត្រេះនគរជុំវិញ ស្តេចទ្រង់ព្រួយត្រេះហឫទ័យខ្លាំង
ណាស់ ព្រោះគ្មានខន្តិណាទឹង៏យកការសោចេញចាំង៏ទឹង៏បច្ចាមិត្របាន
ចៀវយ៉ង៏មានសេចក្តីកំក្តិដល់ត្រេះទ័យដ៏ណាស់ ក៏ខ្លួលអាសោចេញ
ចាំង៏បង្ក្រាបសត្រូវបាន ; ឯលីចោ៉ដាតាហានឯកបេស់លោក ហើយ
លោកខ្លួលចិញ្ចឹមដាវុត្រធម៌ភេញមុខ ឥរតែលោកខំនុកបំរុង៏បំពេញ
ចិត្តលីចោ៉តាមប្រាថ្នា ដែលលោកនឹង៏មកទាំង៏ការស្រីម្នាក់ឲ្យខ្លួចការជា
ប្រយោជន៍ដ៏ល្អតទៅមុខនោះមិនគួរសោះ ហេតុនេះខ្ញុំបាទសុំឲ្យលោក
លើកនាង៏តៀវសៀនឲ្យទៅធ្វើជាកវិយាលីចោ៉ចុះទើបគួរ លីចោ៉នឹង៏មាន
ចិត្តក័ក្តិដល់លោក ។

តាំង៏តុ:តបថា ដែលអ្នកថាតាំង៏នេះត្រូវណាស់ តែសុំបង្ហង៏ឲ្យយើង
ត្រែះរែះបន្តិចទៅសិន, លើយក៏វិលត្រឡប់ទៅផ្ទះវិញ ។ កាលតាំង៏តុ:
ទឹង៏លើយកំពុង៏និយាយគ្នានោះ នាង៏តៀវសៀនមកលបស្តាប់ផ្ទាប់ទៅ
ដញ្ជាំង៏ លុះលើយត្រឡប់ទៅហើយ តាំង៏តុ:ចូលទៅសួរនាង៏តៀវសៀន

ថា ឯងនឹងលីចោ"សហាយនឹងគ្នាបុះ? ។ ភេងតៀវសឿនឮដូច្នោះយំ
ឡឹកឡួលហើយវៃសែតឡើងដំរាបតាំងតុះថា តាលព័ត្រតមិញនេះខ្ញុំម្ចាស
ចុះទៅបេះផ្កាកងសួន មិនដឹងខ្លួនដាលីចោ"លបចូលទៅរកខ្ញុំ ក្រេរួក
ឃើញលីចោ"កាន់ខ្លួននៅវៃង ខ្ញុំម្ចាស់ភ័យណាស់ស្ទុះចៀសទៅ លីចោ"តាម
ទៅដឹងខ្ញុំម្ចាស់ហើយនិយាយថា ខ្ញុំជាកូនមហាឧបរាជ ខ្លួនអ្នកជាភរិយា
មហាឧបរាជ នឹងខ្លាចខ្ញុំថ្លើឈប់និយាយគ្នាសិន លីចោ"ក៏ស្ទុះទៅសង្កិន
ចាប់ខ្ញុំម្ចាស់តាំងអំណាច ខ្ញុំម្ចាស់ដេរថាក៏ក៏មិនស្តាប់ រឹតតែឆបក្រសោប
ខ្លួនខ្ញុំម្ចាស់ៗ ខឹងពេកណាស់ ស្ទុះទៅច្បាំងនឹងលោតទឹកសម្លាប់ ក៏ស្ទុះ
ទៅតែកងចាប់ពខ្ញុំម្ចាស់មកវិញ ខ្លួលលោកអញ្ជើញទៅគាន់ កុំអីលីចោ"
ក៏ធ្វើទុក្ខទោសខ្ញុំយ"ងណាមិនដឹង ខ្ញុំម្ចាស់ទឹកចិត្តណាស់ដែលលីចោ"
ធ្វើឲ្យអាប់យសដូច្នេះ ។

តាំងតុះបានស្តាប់ហើយឆ្លើយតបថា លីចោ"នោះក៏មានសេចក្តីស្នេហ
ស្រឡាញ់នាងខ្លាំងណាស់ យើងនឹងលើកនាងឲ្យជាភរិយាក៏ចុះ ។
នាងតៀវសឿនបានស្តាប់ដូច្នោះ កំត្រឡប់ធ្វើជាក្រាក់ខ្លួន ហើយក៏ក្រួន
វិរោគសោកាថា "ខ្ញុំម្ចាស់ជាស្រីមានសេចក្តីទុស្សាហ៍រក្សាកេរ្តិ៍ឈ្មោះតាំង
ពីតូចមក ដល់លោកយកមកធ្វើជាភរិយា ទោះបីមិនពេញជាបឋមភរិយា
ក្តីណា ក៏ហាក់ដូចជាមានាលីចោ"ច្រាកដ ដែលលោកនឹងលើកខ្ញុំម្ចាស់
ឲ្យទៅជាភរិយាលីចោ"ជាបុត្រលោកវិញនោះ លោកនឹងឲ្យខ្ញុំទៅយកឋាវ

ត្រាវលោកត្រៀមដួរល្អជាជាង ខ្ញុំម្ចាស់មិនត្រមយកលីប៉ោះសោះឡើយ
ឧបមាដូចលោកគួរបបួលក្មេកហើយយកទឹកភ្នែកទៅលាបឲ្យខូចពាណិសម្បុរ
ទៅដូច្នោះ ខ្ញុំម្ចាស់មានសេចក្តីពាក់ព័ន្ធសណាស់ ដែលនឹងបំរុងជីវិតឲ្យស៊ៅ
ទៅមើលមុខគេតទៅមិនបាន" ថាហើយឆ្លើងរត្រៀកឡើងតាញយក
គ្រឹបដែលទៅប្រហប្ងូននោះមកនឹងការតែសម្លាប់ ។ តាឯតុះស្តុះទៅចាប់
ជណ្តើមយកគ្រឹបពីដៃបាន ហើយលួនលោមថា ដែលបងថាតាឯនេះជា
ពាក្យចំអកឡកបញ្ឆោតលេងទេ ។ នាងត្រៀវសឿនទុនដ្រាប់ក្រាបទុប
ចាទដើនតាឯតុះហើយសោតាថា ការដែលកើតហេតុតាឯនេះក៏ព្រោះតែ
លីយូស្រឡាញ់លីប៉ោ" ទើបនាំបង្កហេតុឲ្យលោកលើកខ្ញុំម្ចាស់ទៅធ្វើ
ជាតរាយលីប៉ោដូច្នេះ ខ្ញុំឃើញថាលីយូមិនមែនស្រឡាញ់លោកដោយ
ស្មោះត្រង់ ហើយមិនមែនអាណិតខ្ញុំម្ចាស់សោះ ។ តាឯតុះតបថា
ដែលលីយូនិយាយដូចម្តេចៗ ខោះ បងមិនបានដឿឮពាក្យវាទេ ។
នាងត្រៀវសឿនជំកបថា ខ្ញុំម្ចាស់ដែលនឹងទៅកងទីនេះតទៅ គង់តែលី-
ប៉ោនឹងមកធ្វើអន្តរាយដល់ខ្ញុំម្ចាស់ជ្រាកជ ខ្ញុំម្ចាស់ក៏គង់តែបាន់សេចក្តី
ភក្តីស្រវាសាស្ត្រាសគេជាងនេះទៅវិត្ត ហេតុនេះសូមលោកអញ្ជើញ
ទៅទៅឯទីក្រុងថ្មី ទើបបាន់ខ្ញុំម្ចាស់អស់ភ័យបារម្ភតទៅ ។ តាឯតុះ
ភ័យលំយើញត្រូវទើបនិយាយថា ចាំដល់ព្រឹកស្អែកសុំយើងលើកទៅ ។
លុះដល់វេលាព្រឹកឡើង លីយូចូលទៅជំកបតាឯតុះថា ថ្ងៃនេះល្អ
ហើយ សុំឲ្យលោកលើកនាងត្រៀវសឿនឲ្យជាតរាយលីប៉ោចុះ ។ តាឯ

តុ:តបថា លីចោ"ជាកូនចិញ្ចឹមរបស់យើង នាងតែវិសឿនជាកវិយានៃយើងដែរ បើនឹងលើកឲ្យធ្វើជាកវិយាលីចោ"ដូច្នោះ យើញខុសនឹងទំនៀមទម្លាប់បុពណ ដែលលីចោ"ចានជាធ្លើស្ទើសដល់នាងតែវិសឿនឲ្យមានសេចក្តីអៀនខ្មាស នោះយើងក៏លើកទោសចោលទៅហើយ ការណ៍នេះសុំឲ្យអ្នកទៅប្រាប់លីចោ"ចុះ ។ លីយូតបថា ដែលលោកមិនព្រមស្តាប់ពាក្យខ្ញុំបាទនោះ ការណ៍ដែលគិតទុកចាំងប្អូនគង់នឹងអន្តរាយជានព្រោះស្រីម្នាក់នេះ ។ តាំងតុ:ចានស្តាប់ក៏នឹកខឹងណាស់តបថា អ្នកនៅទូចឲ្យយើងលើកកវិយាឲ្យលីចោ"នោះ យើងមិនស្តាប់ពាក្យអ្នកទេ បើអ្នកមានចិត្តស្រឡាញ់លីចោ" ចូរអ្នកលើកកវិយារបស់អ្នកឲ្យលីចោ"ចុះ ពីថ្ងៃនេះតទៅកុំឲ្យនរណាយកវឿងនេះមកនិយាយដដែលទៀត បើនរណាមិនស្តាប់យើងនឹងបង្គាប់ឲ្យគាត់ក្បាលចេញ ។ លីយូបានឮដូច្នោះក៏លាគ្រាតដើរចេញទៅ ហើយនិយាយប្រាប់សេនាដែលចូលទៅរកតាំងតុ:នោះថា "យើងគាំងឡាយនឹងបានសេចក្តីវិនាសអន្តរាយព្រោះមេតែវិសឿនម្នាក់នេះជាប្រាកដហើយ" និយាយហើយលីយូក៏ត្រឡប់ទៅផ្ទះ ។

ក្រោយនោះតាំងតុ:ឲ្យរៀបចាត់ចែងសេនាគាហាន ហើយនាំនាងតែវិសឿនឡើងរថទៅនៅក្រុងថ្មី. បណ្តានាហ៊ុនសព្វមុខមន្ត្រីតូចធំក៏តាមជូនដំណើរតាំងតុ:ទៅដល់ព្រំស្រុក. ឯនាងតែវិសឿនដែលអង្គុយលើរថ លុះគ្រឡប់ទៅឃើញលីចោ"ឈរនៅជាមួយនឹងពួកនាហ៊ុនក្បែរផ្លូវ

នាងក៏សំឡឹងមើលទៅប្រពន្ធលីចាំងធ្វើជាខ្លួញយំសោក, លីចាំងឃើញ
ដូច្នោះកើតខឹងមានសូរគ្រោតក្អកជាខ្លាំង ប្រឹងឈរមើលចាស់តែដុតកន្ទុយ
ក្អែកហើយជតកដង្កើមធំ ។ អង់អ៊ុនឃើញលីចាំងដើរចូលទៅចាប់ដៃហើយ
សួរថា មហាឧបាដទេញ្ញៈវ៉ៅហើយ ខ្លួនអ្នកមានកង្វល់អ្វីបានជាមិនទៅ
តាម? ។ អង់អ៊ុនឧិយាយថា ខ្លួនខ្ញុំមិនសូវសប្បាយជាយូរថ្ងៃហើយ
ទើបបានជាទានមកជួបអ្នកទន់ធម៌មហាឧបាដ ថ្ងៃនេះតួគេនិយាយថា មហា-
ឧបាដវើទៅនៅក្រុងថ្មី ខ្ញុំឧប្រឹងមកដើម្បីជួនដំណើរលោក តែឃ្លាឃើញ
ទឹកមុខអ្នកមិនសប្បាយ តើអ្នកមានសេចក្តីទុក្ខព្រួយពីការអ្វី? ។ លីចាំង
តបថា ដែលខ្ញុំមានសេចក្តីទុក្ខក្តៅក្រហាយខាំងម្ល៉ះនេះ ពីព្រោះតែនាង
តៀវសៀនជាកូនលោក ។ អង់អ៊ុនក្លែងសួរធ្វើបែបមិនដឹងថា មហា-
ឧបាដមិនខាន់រៀបការនាងតៀវសៀនឲ្យអ្នកទេឬ? ។ លីចាំងតបថា
រៀបការឯណា បើងយកទៅខុតជាការយាក់ទៅហើយ ។ អង់អ៊ុនធ្វើ
ជាភ្ញាក់ស្រឡាំងកាំងហើយថា ដែលអ្នកនិយាយនេះខ្ញុំមិនខាន់ដឿងសោះ មហា
ឧបាដនោះទន់ឆ្ងាយធ្វើដូច្នោះឬ? ។ លីចាំងក៏នាំដំណើរតាំង
ពីដើមហេតុដរបៀបចុងឲ្យអង់អ៊ុនស្តាប់គ្រប់ប្រការ ។ អង់អ៊ុនស្តាប់ហើយ
ក៏លោតខ្ទាំងើងហើយថា ដែលមហាឧបាដធ្វើដូច្នេះឧបមាដូចសត្វ
តិរច្ឆានក្រតំណាស់ ដំយាងហើយក៏នាំលីចាំងទៅផ្ទះ ឲ្យរៀបកោដ-
នាហារអញ្ជើញលីចាំងបរិភោគផឹកស្រា, អង់អ៊ុនឧិយាយថា តាំងតុះធ្វើ

ការអាត្រកុំដល់កូនខ្ញុំដែលជាកវិយាអ្នកៗ ទើនខ្ញុំក៏បានសេចក្តីអាស្រូវគាស
ខ្មាសគេណាស់ តែថាខ្លួនខ្ញុំនេះចាស់ជរាហើយ ជីវិតគង់នៅប៉ុន្មានថ្ងៃ
ខ្ញុំគិតអាណិតតែខ្លួនអ្នកដែលនៅក្មេង ព្រោះសត្វថ្ងៃមានមនុស្សក្នុងព្រៃ
នគរសរសើរពប់អានអ្នកថា មានថ្វីដៃខ្លាំងពូកែ ដែលតាំងតុ:ធ្វើអ្នកបាន
ដូច្នេះ មនុស្សទាំងអស់គង់តុះតិះដៀលថា អ្នកជាមនុស្សល្ងីល្ងើខ្លាចណាស់
វិញ ។ លីចាំបានឮដូច្នោះខឹងណាស់ យកដៃទះតុហើយថា ដែលអាតាំងតុ:ក៏ធ្វើខ្ញុំដល់ទីនេះ ខ្ញុំត្រូវសងសឹកវាឲ្យបាន ។ អង់អ៊ុនបានឮធ្វើជាយកដៃទប់មាត់លីចាំ៉ហើយឃាត់ហាមថា អ្នកកុំពោលពាក្យដូច្នោះ
ក្រែងនាំខ្ញុំឲ្យខុសមានទោសទៅផង ។ លីចាំ៉ធ្វើយថា ខ្លួនខ្ញុំកើតមកជា
ប្រុសតែម្តងសំគាល់ថា ខ្លួនមានថ្វីដៃខ្លាំងពូកែ មិនត្រូវនៅក្រោមបង្គាប់
អ្នកណា ។ អង់អ៊ុនតបថា គំនិតចេះដឹងនឹងថ្វីដៃនៃអ្នកនោះ មិនគួរ
នៅក្រោមអំណាចឲ្យតាំងតុ:ប្រើប្រាស់សោះ ឧបមាដូចជាតែវមានដម្លៃ
បានទៅដៃពានរកាន់ ។

លីចាំ៉ធ្វើយថា ខ្ញុំមានសេចក្តីតូចចិត្តពេក គិតនឹងសម្លាប់អាស្រូវ
កញ្ជាស់ឲ្យបានដាច់ខ្យែងមកហើយ តែគិតរកវែកសង្កត់ចិត្តព្រោះបាន
ជារហាវជាបិតា ប៉ះនឹងសម្លាប់ចេញរលាណាខ្លាចគ្រូតរហាមខ្លាំងបាន ។

ភាគទី ២

សម័យឧកញ៉ាចំ

អ្នកឧកញ៉ាទេពតីទូរ ឈ្មោះ - ក្រសែម រៀបរៀង

(តទៅ)

និយាយអំពីព្រះបាទបរមរាជាវ័ន្ទទី ៣ កាលទ្រង់ជ្រាបថាព្រះមហានគរធ្លាក់ទៅក្នុងកណ្តាប់ដៃបច្ចាមិត្រហើយ ទ្រង់ក៏បង្ខំចិត្តដើរទៅតាមព្រះនគរ ស្តេចគង់នៅក្រុងស្រីអយុធ្យាជាមួយព្រះអាទិត្យវង្ស រហូតមកដល់ឆ្នាំ ព.ស. ១៦៣២ គ.ស. ១០៨៩ ក៏សោយទិវង្គតនៅទីនោះ ។ ពាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទសាសរៀបទ" ។ ទ្រង់គ្មានព្រះពាជទេសទ្វេលពាជសម្បត្តិស្នងព្រះអង្គទេ ។

កាលព្រះបាទជយវ័ន្ទទី ៦ ទ្រង់ជ្រាបដំណឹងថា ស្តេចសោយទិវង្គតហើយ ក៏គ្រាស់ប្រើពាជបុរសជាច្រើននាក់ ព្រមដោយគជេន្ទ្រយានឲ្យទៅអញ្ជើញព្រះបរមអដ្ឋិ ទឹងព្រះពាជទីជយពាជចូឌាមណីត្រឡប់ព្រះនគរវិញ ។

ចំណែកព្រះអាទិត្យវង្ស មហាឧបពាជ, កាលព្រះនាងជយពាជចូឌាមណី ទឹងស្តេចត្រឡប់ព្រះនគរ, បានគ្រាបទូលសុំព្រះកែវមរកតទុក ធ្វើសក្ការបូជា ។ ព្រះនាងទ្រង់ទើសពាល់ព្រះហឫទ័យ ក៏ទ្រង់ព្រះពាជទាន

តាមសុំ ។ ព្រះអាទិត្យវង្សខ្មែរអណោះ ខ្មែរកំធ្វើពិធីសម្ពោធជា
ទ្បាវិតអស់ពារៈ ៧ ថ្ងៃ ៧ យប់ ។ ព្រះតែវមកតបានស្តេចមកស្ថិតនៅ
ក្នុងក្រុងស្រីយសោធរបុរៈ ពីក្នុងឆ្នាំ ព. ស. ១៩៨៦ ដល់ឆ្នាំ ១៦២៣
រួមជា ២៧ ឆ្នាំ ទើបស្តេចទៅស្ថិតនៅក្រុងស្រីអយុធ្យាខឹងក្រុងកំពែងពេជ
ដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា អស់កាលជាយូរឆ្នាំតមកទៀត ហើយ
ទើបស្តេចចេញផុតពីដែនខ្មែរ ទៅស្ថិតនៅទីដទៃ ដូចជានឹងមានអធិប្បាយ
តទៅខាងមុខ ។

ព្រះចាន ៨ យវ័ន្តទី ៦

ព. ស. ៦២៤-១៦៨០ គ. ស. ១៨០១-១១០៧

កាលព្រះបាទហសិរ៉ាជទី ៣ ស្តេចចេញចាកព្រះរាជធានីទៅគង់
ឯក្រុងស្រីអយុធ្យាហើយ ព្រះរាជធានីក៏ចំហ គ្មានរាជក្សត្រគាន់គាប់ដូច
ពោលហើយ ជាទុកាសឲ្យអ្នកលោភយសចង់ចេញចង់ឡើងគ្រងរាជ-
បល្ល័ង្កដែលទំនេរនោះ ។

ពិតដូច្នេះ ប្រាកដតាមប្រវត្តិសាស្ត្រថា ក្នុងគ្រានោះ មានបុរស
១ នាក់ដែលគេមិនស្គាល់ឈ្មោះនឹងត្រកូល ទឹងព្រាហ្មណ៍ ១ នាក់ទៀត
ជាអ្នកលោភលាភយសហួសវាសនា ប្រាថ្នារួមសេនាវេហ៍ពលបានជា
ច្រើនហើយ ទៅតាំងទីសំណាក់នៅខាងជើងកំដងវែក ដោយសន្មតនា
បម្រុងនឹងលើកមកលុកយកក្រុងស្រីយសោធរបុរៈ តែគ្រានោះជាដោយ

វេលានោះ មានព្រះរាជវង្ស ១ អង្គព្រះនាមជយវ៉ារ្ម័ន កាលទ្រង់ជ្រាបការណ៍នេះហើយ ក៏ទ្រង់ស្រែកប្រមូលសេនាពាហានបានល្មមហើយក៏ស្តេចលើកចូលទៅឈរគាន់គាប់ត្រង់ស្រីយសោធរបុរៈបានមុនបង្អាមត្រៃ, លំដាប់នោះ ទ្រង់ក៏លើកទ័ពទៅកំចាត់អ្នកបរិបោរនោះបង់ ហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ ហើយទ្រង់ក៏ចាប់ត្រួតត្រាការផែនដី តែតំនង់នៅក្នុងឋានៈជាបណ្តាអាសន្ន ។

ស្តាននការណ៍នៃការគ្រប់គ្រងផែនដីក្នុងពេលនោះ នៅក្នុងផ្លូវចង្អៀតនឹងដោះស្រាយ ដោយមានបញ្ជាថា គួរនឹងទៅគាបទូលអញ្ជើញព្រះបាទហសិរ៉ាន់ទី ៣ ឲ្យស្តេចមកគ្រងរាជសម្បត្តិវិញ ឬមួយនឹងអញ្ជើញព្រះជយវ៉ារ្ម័នឲ្យឡើងគ្រងរាជសម្បត្តិតែម្តង ។ តាមយោបល់កាតជ្រែនថា ព្រះបាទហសិរ៉ាន់ ពិតមែនតែទ្រង់នៅក្នុងឋានៈជាព្រះពាជាម្ចាស់ផែនដី តែវេលានេះស្តេចចេញទៅគង់នៅឯបច្ចន្តរដ្ឋទៅហើយតាំងទ្រង់ព្រះជាខុទ្ទលភាពណាស់ទៅហើយផង តាំងទ្រង់ខ្សោយព្រះសមត្ថភាពណាស់ទៅហើយផង តុំគួរនឹងស្តេចត្រឡប់មកគ្រប់គ្រងផែនដី ក្នុងពេលដែលមានអាសន្នជាមិនខាន នេះទេ គួរតែថ្វាយរាជសម្បត្តិទៅព្រះជយវ៉ារ្ម័នតែម្តងទៅ ទើបអាចគ្រប់គ្រងផែនដីបាន ។

ដោយយោបល់នេះ រាជសម្បត្តិទើបបានទៅព្រះជយវ៉ារ្ម័ន ។ ទ្រង់ឲ្យប្រកាសធ្វើព្រះរាជពិធីបរមរាជាភិសេក ក្នុង ព. ស. ១៦២៤ នោះ ។

កន្លែងនោះ ប្រទេសកម្ពុជាមានព្រះពាជាជាម្ចាស់ផែនដីពីរអង្គស្មើគ្នា តែព្រះបាទជយវរ្ម័នទី៧អស់អំណាចទៅហើយ ។ ព្រះជយវរ្ម័នអង្គនេះជាឧរសទី ២ របស់ព្រះហិរណ្យវរ្ម័ន ទ្រង់ព្រះនាម ហិរណ្យលក្ស្ម៊ី ទ្រង់បានឡើងគ្រងព្រះពាជាយអំណាចកន្លាងអារុធ មានព្រះបរមនាមថា ព្រះបាទជយវរ្ម័នទី ៦ ។ ស្តេចគង់នៅក្រុងស្រីយសោធរបុរៈ, ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនច្បាស់, ព្រះពាជឧរស ព្រះពាជធីតានោះទ្រង់គ្មានសោះទេ ។

ព្រះបាទជយវរ្ម័នទី ៦ នេះ ត្រូវរាប់ជាវង្សថ្មី, ព្រះពាជវង្សវែលជាអំបូររបស់ព្រះអង្គ បានទទួលតំណាពាជសន្តតិវង្សមកជាច្រើនព្រះអង្គដរាបដល់រជ្ជកាលព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ដែលសោយរាជ្យប្រមាណក្នុង ព. ស. ១៨៣៨ – ១៨៩០ ជាទីបំផុត ។

ការផែនដី ការគ្រប់គ្រងផែនដីក្នុងរជ្ជកាលនេះមិនច្បាស់ថាបានចំរើនយ៉ាងណា ។ ការព្រះសាសនាទ្រង់រាប់អានលទ្ធិសៃវ មានរាជបុរោហិតធំនាម "កម្រតេង៑អញគុរុ ស្រីទិកគរបណ្ឌិត" ជាទីប្រឹក្សាការផែនដី ទឹង ធ្វើតិធីផ្សេង ។ ថ្វាយ ។ ការព្រះសាសនាក៏មិនច្បាស់ថាទ្រង់បានសាងអ្វីជាសំខាន់ខ្លះទេ ។

និយាយពីជាតិសៃក្នុងប្រទេសខ្មែរ

ជាតិសៃ ឬហៅថា "សៀម" ជាជាតិមួយដែលដើមឡើយនៅកណ្តាលផែន

ហ៊ុនណាំ តែឥឡូវនេះ ទៅជាខែត្រ ១ របស់ចិន ។ ក្នុងរវាងពុទ្ធសតវត្សទី ១៥ ទី ១៦ ត្រូវចិនលើកទំពមកវុកពនជាញឹកញាយក៏បានប្រទេសទៅចិន ។ លោនោះដនជាតិថៃកាតច្រើនគ្រានៅមិនបាន កំចុះបង់ស្រុកទេសរបស់ខ្លួនទាំគ្នារត់សឹក ចុះមកអាស្រ័យនៅតាមជាយដែនប្រទេសកម្ពុជាកាតខាងលើ; ដោយចំពោះមានកាតច្រើនបានមកតាំងភូមិលំនៅ នៅត្រង់ខាងដើមទន្លេវិស្ណុដែលសៀមហៅថា "ម៉ែណាំចៅព្រះយា" នៅក្នុងអំណាចគ្រប់គ្រងរបស់ផ្លាកិបាលខ្មែរ, តែផ្លាកិបាលខ្មែរ បានតាំងជាតិសៀមឲ្យជាមេគ្រប់គ្រងគ្នាផ្ទាល់ ដោយអន្ទើៗ នៅ ចំនងដូចជាតាំងមេចិនគ្រប់គ្រងពួកចិនក្នុងបច្ចុប្បន្ន ។ ថៃនៅក្នុងអំណាចអាក្នុងរបស់ខ្មែរ ដោយអាការយ៉ាងនេះមិនតិចជាង ៣០០ ឆ្នាំ ។

មកក្នុងសម័យ ១ ពប់តាំងពីចុងរជ្ជកាលព្រះបាទហសិវ៉ែនទី ៣ នៅខាងទីងរជ្ជកាលព្រះបាទសូរ្យវ៉ែនទី ២ ប្រទេសកម្ពុជាមានការណ៍បះបោរចលាចលជាញឹកញាយ ដោយក្សត្រិយ៍អ្នកគ្រងពិតពក្នុងសម័យនោះខ្សោយព្រះតេជានុភាព មិនអាចទីងកម្រាបការបះបោរឲ្យរាប់ថាបៅបានដោយងាយ ។ មកក្នុងសម័យ ៣ ស. ១៦៤០ ក្នុងចុងរជ្ជកាលព្រះបាទជយវ៉ែនទី ៦ ជាពេលដែលមានការបះបោរដូចពោលហើយ លោនោះ មានបុរស ១ នាក់ជាតិសៀមឈ្មោះ ព្រហ្មពជ ជាបុត្រឈ្មោះ ពង្គពជ មានផ្ដើមតាំងខ្លួនជាក្សត្រិយ៍គ្រប់គ្រងពួកថៃ នៅមណ្ឌល

យោនកដៀនសែនក្នុងវែត្រៃនៃព្រះពជរាណាចក្រកម្ពុជា ។ ព្រះបាទ
ជយវរ្ម័នទី ៦ ទ្រង់រំលែកតែកម្រាបអសន្តិសុខខាងក្នុងព្រះនគរនឹងការពារ
ពជបល្ល័ង្កឲ្យគង់នៅសិនទេនោះ ទើបដាក់ការឲ្យព្រះត្រៃហ្វាពជតាំងខ្លួន
ឡើងបាន រហូតមកអស់រៀលាជាច្រើនឆ្នាំ, ដល់ទៅកន្លងរជ្ជកាលព្រះបាទ
សូរ្យវរ្ម័នទី ២ ទើបកម្រាបការបះបោរគ្រប់ទិសទាំងខាងក្នុង - ខាងក្រៅប្រទេសឲ្យពាបាបទៅបាន ដូចជានឹងមានពោលជាថ្មីទៀតទៅខាងក្រោយ ។

ព្រះបាទជយវរ្ម័នទី ៦ ស្តេចស្ថិតនៅក្នុងពជរាជសម្បត្តិដល់ក្នុងឆ្នាំ ព.ស. ១៦៥០ ក៏សោយទិវង្គត ពជបណ្ឌិតថ្វាយព្រះនាម ព្រះបរមសពថា "ព្រះបាទបរមវៃរ៉ល្យបទ" ។

ព្រះចាន ជរាណាត្រូវរ្ម័នទី ១

ព. ស. ១៦៥៤-១៦៥៦, គ. ស. ១១០៨-១១១៣

កាលព្រះបាទជយវរ្ម័នទី ៦ សោយទិវង្គតហើយ ព្រះអង្គគ្មានព្រះពជនុរសនឹងទទួលពជសម្បត្តិស្នងព្រះអង្គ, ពជបុរោហិតព្រមដោយគណៈសេនាបតី បានគ្រាបទូលអញ្ជើញព្រះអង្គជរាណាត្រូវរ្ម័ន ដែលជាព្រះដេដ្ឋាធិពជរបស់ព្រះបាទជយវរ្ម័នទី ៦ ដែលទ្រង់ព្រះជរាតាណាស់ទៅហើយ នោះឲ្យឡើងគ្រងពិតតែមក, ក្នុងដានដំបូងទ្រង់ប្រកែក ពុំព្រមទទួល, តែមកក្នុងទីបំផុត ដែលត្រូវទូលអង្វរណាស់ទៅ ក៏ទ្រង់ព្រមទទួលគ្រងពជសម្បត្តិ ធ្វើពិធីបរមពជាភិសេកនៅក្រុងស្រីយសោធរបុរៈ ។ (មាន)

ស្ថានភាពវត្តកំពង់ចាចជាភម

នៅឃុំពោធិ៍ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ព្រះវិន័យធរគណៈ បៅអធិការវត្តនេះ រៀបរៀង

(ភ្ជាប់លេខ ៣)

ការណ៍ដែលនាំឲ្យកើតជាវត្តនេះឡើង អាស្រ័យហេតុ ២ ប្រការ

១ – ដោយពួកឧបាសក ឧបាសិកា នៅភូមិកំពង់ចាចនេះមានចិត្តជ្រះថ្លាទំនឹងព្រះពុទ្ធសាសនា ។

២ – ព្រោះភូមិនេះចាប់តាំងពីមានមនុស្សមកនៅ មិនទាន់មានវត្តសោះ សូម្បីទីដំណែលវត្តចាស់ព័ុកណាក៏គ្មាន ។ ពួកអ្នកស្រុកត្រូវការធ្វើបុណ្យទានមួយៗ តោងស្វែងទៅកន្លែងវត្តជាច្រើនឆ្ងាយៗ ជាហេតុនាំឲ្យលំបាកក្នុងកិច្ចធ្វើបុណ្យទាន ។

អាស្រ័យហេតុនេះ ទើបចាស់ទុំក្នុងស្រុកបានប្រជុំគ្នាគិតកសាងវត្ត ។ បុព្វបុរសកាលសម័យនោះ ដែលជាអ្នកផ្តើមភាឯឡើងជាដំបូង ចំនួន ១១ អាក់ គឺ តា - លិខ, តា - មាស, តា - ឡាយ, តា - គង់, តា - ព្រាប, តា - ម៉ាន់, តា - ជាន់, តេន៍ករ ស្វា, ស្រីស្វាង្វ ព្រំ, យសក្តេ សុខ, ដំនប់ ថ្មាក់, ។ ឈ្មោះបុព្វបុរសទាំង ១១ នាក់នេះ បានទៅនិមន្តលោកគ្រូព្រះនាម "ពុត" ព្រមទាំងតិក្ខបរិស័ទចំនួន ៣ អង្គ រួមជា ៤ អង្គ ពីភូមិត្រពាំងពុល ឃុំកំពង់ឆ្នាំង ស្រុកសាលាប្អូរ

ខែត្រកំពង់ធ្នាំង មកធ្លើជាចៅវត្ត ។ លោកត្រូវអន្តរនេះ កាលដើមជា
ចៅអធិការវត្ត "ខិន" ក្នុងខែត្រចំប៉ាកុំ និមន្តមកកាលបះស្នងសូរ ពម
កំហែង, មកនៅក្នុងភូមិត្រពើពុល, គង់ផ្ទៃបណ្តែតទឹកជាទីសេនាសខ: ។

កាលកសាងទីវត្តនេះ ជាដំបូងពីថ្ងៃ ៥កើត ឆ្នាំជូតសំរឹទ្ធិស័ក.
ព. ស. ២៤០៥ ត្រៃវស្សា គ. ស. ១៨៦២ ឆ្នាំ ក្នុងកាលព្រះករុណា
នរោត្តម ។

ភូមិភាគផែនដីដែលកសាងវត្តនេះ

វត្តកំពង់ចាចិននេះ កសាងលើថ្នល់អំពីបុរាណ ១, ថ្នល់នោះវែង
បណ្តោយពីទិសទក្សិណទៅទិសឧត្តរ ហើយវែងតទៅទៀត ដួនជាប់
ដួនជាប់ដោយអន្លើ ។ ។

(ថ្នល់នេះតាមអាត្មាភាពយល់ថា មិនមែនជាមនុស្សលើតទេ គឺកើត
ឡើងដោយសន្ធារលោកតាក់តែង ។ ព្រោះថាជាច្រើនពាន់ឆ្នាំមកហើយ
កាលទីដីទំនាបនេះ នៅជាទឹកខ្នេរនៅឡើយ ទឹកជំនន់ខ្នេរមេគង្គហូរ
នាំដីល្បប់មកចាក់បំពេញជានគរកម្ពុជានេះ ខ្សែទឹកហូរមកប៉ះនឹងភ្នំនាំ
ឲ្យដីល្បប់សង្កត់ដោយអន្លើ ។ តាមសំនាំខ្សែទឹក ព្រោះហេតុនេះបានជា
ថ្នល់នោះច្រើនតែឃើញតភ្ជាប់ពីភ្នំមួយទៅភ្នំមួយ ។)

វត្តកំពង់ចាចិននេះកសាងបែរមុខទៅទិសបូព៌; ទិសទក្សិណមាន
ភ្នំកំពង់ចាចិន ១ ចម្ងាយពីខែត្រវត្តចំនួន ១០០ ម៉ែត្រ ។ ភ្នំនេះតាម

បុរាណហៅថាភ្នំត្រែតើ ត្រែះមានសណ្ឋានដូចរូបត្រែតើ ចែវក្បាលទៅខាងដើង, ទិសអគ្នេយ៍មានភ្នំនាងត្រែ – សម្តេចនន – អកត្រពុំ(ឬអកពុំ), ទិសខាងកើតមានភ្នំសម្រែង, ទិសឦសានមានភ្នំត្រែងាល – ភ្នំខ្លួកមាស, ទិសឧត្តរមានភ្នំបឹង - ភ្នំត្រែង, ទិសបស្ចិមមានទន្លេអន្ទង់លត - បង្គោលកំដរកំពុត ។

វត្តនេះដល់ជូវរស្យា ខឹកទន្លេឡើងលិចព័ទ្ធជុំវិញនៅតែទីលូលវត្ត ។ ប៉ន្តែណាខឹកធំម្តង។ លិចទីវត្តពាំងមូល នៅសល់តែតួរឿនព្រះវិហារ ។

មុនដែលកសាងព្រះវិហារថ្មីនេះ ភ្លក្ខុបាសកនឹងឧបាសិកា បានធ្វើសាលា ១ ប្រគល់ស្បូវ សម្រាប់ប្រគេនលោកគ្រូចៅអធិការគង់ នឹងកុដិតូច។ បីសម្រាប់ប្រគេនលោកបរិស័ទគង់ ។ ដល់មកឆ្នាំម្សាញ់ទើបលើកព្រះវិហារថ្មី ជាដំបូងនេះ កសាងដកបហើយស្រេច ។

ក្នុងបុណ្យលៅកគ្រូចៅគធិការទី ១ នេះមានហេតុ ១ ដែលគួរតាញាមកអធិប្បាយដូចតទៅនេះ ។

សេចក្តីថា: ខាងត្បូងកុដិលោក ចំក្បាលសំណឹង ចម្ងាយប្រមាណជា ៣ - ៤ ម៉ែត្រ មានដើមស្តកស្ពោរ ១ ដើម ទំហំ ១ ឧប រិចរិលដោយអ្នកស្រុកស្មោះយកសម្រកធ្វើប្ញាំ ។ លោកឲ្យច្រូកពន ៣ ថ្នាក់តម្កល់ខុកគ្រាមដើមឈើនោះ. ដល់ចប្ងស់ល ឲ្យកន្លែងយកគោជនាហារផ្សែង។ មានទំ - ចេកជាដើមភៅដាក់ចូជាលើកមនោះ ។ ដួនកាលមានលេងភ្លេងផង តាមហេតុការណ៍ ១ ដង ១ កាល ។

កន្លងមកមួយនោះ លោកគ្រូចៅអធិការមិនសូវសប្បាយក្នុងត្រកូលគ្នុនស្រែវស្រាញ់ ដូនក្តៅដូនត្រជាក់ជាយូរថ្ងៃ ។ ពេលយប់មួយនោះ លោកនិមន្តទៅសិង្ហ ស្រាប់តែយល់សប្តិឃើញហេតុផ្សេង ។, ដល់ព្រឹកព្រហាមឡើង លោកប្រែបន្ទុស្សឲ្យយកចបទៅដីតប្រែបគល់ស្កុកស្តោះនោះដំរៀបមាណជា ៥-៦ តឹក ក៏ប៉ះលើថ្ម ១ ដុំធំ ជាហេតុនាំឲ្យផ្អើលអ៊ូអរដល់តិក្ខ-សាមណេរកន្លងទីវត្ត មកមើលជួយគាស់តកាយលើតយកមកលើ ហើយឃើញរូបភាពចាក់បែកនៅលើថ្មនោះផង ។ កន្លងពេលនោះគ្មានអ្នកណាស្គាល់ថាជាឋ្មូទេ នាំគ្នាហៅថា "ថ្មបល្ល័ង្ក" ។ រួចលោកគ្រូចៅអធិការបង្គាប់ឲ្យសែងទៅដាក់ខាងត្រែវបងវត្ត ខាងទិសឧត្តរ ។ តអំពីនោះមក ទៅជាមានបីសាចកាន់តាប់ថាជានាមបញ្ញត្តិថា "អ្នកតាយាយមាស" ដរាបសព្វថ្ងៃនេះ ។

ថ្មបល្ល័ង្កនោះយើងបានទៅពិនិត្យមើល គឺជាលង្គព្រះឥសូរ ហើយរូបចាក់បែកនោះ គឺរូបព្រះនាគយណ៍ដុះត្រួច ។ លង្គនេះខ្ពស់ ០ ម. ៨៥ បណ្តាយ ០ ម, ៩០ កំតស់ ០ ម. ៧៤ ហើយសព្វថ្ងៃនេះ ប្រែធាចាក់បែកជាច្រើនអន្លើ ។

វត្តនេះតើតឡើង កន្លងមកយូរយើងពាក់អាន្តព្រហ្មញ្ញាសាសនា ។ រឿងនេះមុខគួរឲ្យសង្ស័យ ព្រោះយើងបានសួរមនុស្សចាស់ៗ អាយុកន្លង

៨០ ឆ្នាំមកហើយថា តូមតំពន់ចាចិននេះ ដែលមានមនុស្សមកនៅប្រហែលប៉ុន្មានឆ្នាំហើយ ? ។ គាត់ឆ្លើយថា មិនយូរប៉ុន្មានទេ គឺមានមនុស្សមកនៅមុនតាសាងវត្ត ប្រមាណជា ២០ ឆ្នាំ ឬ ៣០ ឆ្នាំ យ៉ាងយូរ ព្រោះតំពន់នេះភាគដើមជាកន្លែងអ្នកស្រុក តូមិនាងកើតគេចតខ្លួក គេឲ្យឈ្មោះតំពន់នេះថា តំពន់បស្ចិម (គ្រាយមកជាតំពន់ចាចិន) ។ គួរឆ្ងល់ បើទើបនឹងមានមនុស្សមកនៅប្រមាណជាង ១០០ ឆ្នាំទេ ហេតុម្តេចក៏មានសិលាឆ្លាក់នេះតប់ក្នុងដីជំរៅដល់ម្ល៉ះ ។ (តាមយើងយល់ថា កន្លែងនេះជាភូមិចាស់ កាលសម័យព្រះនាយមានមនុស្សមកនៅម្តង ហើយលះបង់ចោលទីនេះទៅវិញជាច្រើនៈយឆ្នាំ ចាត់ស្នាមអ្នកដឹងអ្នកយល់អស់ទៅ ហើយវៃព្រៃដុះដេរដោសពាសពេញឡើង គ្រាក្រោយទើបមានមនុស្សមកនៅជាថ្មីទៀតដរាបមកដល់សព្វថ្ងៃនេះ ។)

លោកគ្រូចៅអធិការទី ១ នោះ កាលនិមន្តមកគង់ជាដំបូង ព្រះជន្ម ៦០ ឆ្នាំ លុះដល់ព្រះជន្ម ៨០ ឆ្នាំទើបលោកសុគត ។

ដល់ឆ្នាំជូតបញ្ចស័ក ព. ស. ២៤៣០ លោកគ្រូព្រះនាម "កែវ" ធ្វើជាចៅអធិការទី ២ តមកទៀត : លោកគង់បានឲ្យសាច់ចាកសិក្ខាបទ ។

ដល់ឆ្នាំមមែឆស័ក ព. ស. ២៤៣៨ លោកគ្រូព្រះនាម "ខៀប" ធ្វើជាចៅអធិការទី ៣ តមកទៀត លោកគង់បាន ៦៦ វស្សាព្រះជន្ម-គត់ ៥១ ឆ្នាំ, លុះដល់ថ្ងៃ ៦ រោចខែអស្សុជ ឆ្នាំវកសោស័ក ព. ស. ២៤៦៣ គ. ស. ១៩២០ លោកសុគត ។

(មានត)

ប្រវត្តិរបស់អេសុប

លោក ផេង-ជ្រៃ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យតាំរីភ្នំពេញ

ប្រែពីចាក់ដងមកជាខ្មែរ

(តទៅ)

អេសុបឆ្លើយថា "ខ្ញុំរមើលចុះប្រផ្នូលចំជាមេកុហកយ៉ាងធំ ខ្លួនអញដែលបានឃើញអន្ទេបពីរបែរជាត្រូវរំពាត់; ចំណែកព្រះតេជព្រះគុណ លោកបានឃើញតែមួយ លោកត្រូវបង់ជាមានលាភ គឺមានគេមកអញ្ជើញទៅពីសាលៀង" ។ សង្ឃុះឮសំដីត្រូវ ក៏ពេញចិត្តស្តាប់បាន ហើយប្រាប់ឲ្យមនុស្សឈប់រាយលោក តែមិនទាន់ឲ្យចេញពេលនេះទេ ·គឺចាំពេលត្រលាយទៅខែត ។

ថ្ងៃមួយ សង្ឃុះនឹងអេសុបទាំគ្នាដើរលេងមើលសិលាចារឹក នៅឯប្រាសាទបុរាណដោយសេចក្តីសប្បាយ ។ មានសិលាចារឹកមួយកន្លែងចៅហ្វាយរបស់លោកពិនិត្យមើលយូរណាស់ តែមិនយល់សេចក្តីសោះ ។ អក្សរក្នុងសិលាចារឹកនោះគេដាក់សុទ្ធតែអាទិសង្កេត ។ ចៅហ្វាយនិយាយចំពោះមុខថាវ៉ា ខ្លួនមើលចារឹកហ្នឹងមិនយល់ទេ ។ អេសុបសួរទៅចៅហ្វាយរបស់លោកថា: "បើខ្ញុំបានប្រាប់កំណប់ឲ្យដល់លោក តើលោកឲ្យអ្វីដល់ខ្ញុំបាទ?" ។ សង្ឃុះឆ្លើយថា: "អញបើកឯងឲ្យចេញជាអ្នកជាហើយចែកកំណប់ឲ្យតាកកណ្តាលថែមទៀត" ។ អេសុបប្រាប់ថា: "សិលាចារឹកនេះបានសេចក្តីដូច្នេះ គឺដើរចេញពីគោលចារឹក

៤ ដំហាន ទឹងប្រទះកំណប់ទ្រព្យមួយ" ។ លុះគេជីកទៅក៏ឃើញកំណប់
មែន ។ សង្ឃឹះនៅចាំតាក្យដែលខ្លួនសន្យាដែរ តែលោកពុំបានព្រមឲ្យ
អេសុបចេញ ហើយមានភាសាថា "ព្រះជាម្ចាស់ឃាត់អញថាកុំអាលឲ្យ
ឯងចេញ តាលែតែឯងបង្ហាញភាពវិតដល់អញទៀត ព្រោះក្នុងអក្សរ
នៃសិលាចារឹកដូចជាច្បាប់ថា នោះមានកុំណប់មួយមានដាំឡៃជាងមុនទៅ
ទៀត" ។ អេសុបឆ្លើយថា "តាមចារឹកវាងនេះ គឺបានសេចក្តីថា ថយ ៩
ដំហានទៅទៀតគេនឹងប្រទះកំណប់មួយទៀត" ។ លុះគេថយតាមសេចក្តី
ដែលបង្គាប់ហើយជីកទៅ គេឃើញកំណប់មួយទៀតមែន ។ ចៅហ្វាយ
របស់លោកឃើញតម្រៃនៃលោកភ្លូតែដូច្នេះក៏មានភាថាថា: "ឯងមាន
ប្រយោជន៍ដល់អញណាស់ កុំសង្ឃឹមថាអញបើកឲ្យឯងឡើយ" ។
អេសុបឆ្លើយថា: "បើលោកមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទៅគ្រាបបង្គំទូល
ដល់ព្រះករុណាព្រះនាមដឺនីះ (Denis) ព្រោះក្នុងសិលាចារឹកនោះមាន
សេចក្តីតែស្រឡាំងថា "កំណប់នេះជាកំណប់របស់ព្រះអង្គ" ។ សង្ឃឹះភ័យ
ក៏អង្វរថា: "ចាំអញឲ្យចំណែកដល់ឯង ចូរឯងគណិតតែកុំមាត់ចុះ" ។
អេសុបឆ្លើយទៀតថា "មិនចាំបាច់លោកមានប្រសាសន៍ថាចែកឲ្យ
ដល់ខ្ញុំទេ ក្នុងចារឹកនោះមានសេចក្តីទៀតថា: ត្រូវតែលោកចែកឲ្យខ្ញុំ" ។
លុះរំលែកឲ្យបាទៅដល់ផ្ទះ សង្ឃឹះឲ្យគេយកអេសុបទៅដាក់ប្រព័ន្ធដើង
ខុកក្នុងផ្ទះមួយជាចំណែកឯង ខ្លាចក្រែងលោកដើរទៅបរិហារប្រាប់អ្នកដទៃ ។

លោកវិស្សកថា: "ហ្នឹងហើយឬ ដែលលោកអ្នកថ្នាក់ត្រូវចាំពាក្យ
សន្យា? តែណ្តើយចុះ ទោះបីលោកធ្វើយ៉ាងដូចម្តេចក៏ដោយ អាណិត
តែលោកបើកឲ្យទៅជាអ្នកជា" ។

ខំនាយរបស់អេសុបត្រូវហ្វាតដ ។ ហេតុដ៏អស្ចារ្យមួយដែលកើត
ឡើងធ្វើឲ្យប្រជាពលក្នុងប្រទេសសាមូសមានសេចក្តីត្រេកអែចែន ។ មាន
សត្វក្តែងមួយធាបយកក្រវិលដែកមួយ ក្រវិលនេះមានសណ្ឋានដូចជាត្រា
ដែលសម្រាប់ចុះលើសេចក្តីដំនុំរបស់ក្រុមរដ្ឋមន្ត្រី ហើយខំលាក់ចុះលើ
ទ្រូងនៃមនុស្សជាខ្លាំងម្នាក់ ។ មហាជនទៅប្រកាសាវណ៌នេះជាមួយ
ទឹងលោកសង្ឃរ ដែលជាអ្នកថ្នាក់មួយក្នុងនគរផង ជាទីប្រឹក្សាក្នុងព្រះ
រាជអាណាចក្រផង ។ លោកនេះ សូមឧកាសអំពីគេពាល់គ្នាថាចាំយក
រឿងនេះមកពិចារណាមើល ហើយក៏ទៅរកតែតម្រាមួយដែលឲ្យជួយ
គឺអេសុប ។ លោកថ្នាក់សង្ឃរថា "សូមឲ្យនាំលោកទៅឯកណ្តាល
មហាជន ព្រោះថាបើកាលណាខ្ញុំធ្វើយទៅ ហើយត្រូវក្តើរឈ្មោះគឺងឺ
ថ្នាក់ទៅលើលោក, បើកាលណាខ្ញុំធ្វើយទៅ ហើយមិនត្រូវសមប្រកប
ខោះមានខ្លួនខ្ញុំស្រាប់ដែលត្រូវគេគ្នុះគិនដៀល ។ សង្ឃរយល់ព្រមហើយ
នាំលោកឡើងកាន់ទីវេទិកា ដែលសង់សម្រាប់ដំនុំប្រឹក្សាខ្ពស់រឿងក្រៃលែ
ងាន់លើ ។ គ្រានតែឃើញអេសុបឡើងទៅ គេនាំគ្នាសើចហើយនិយាយ
ស្នានថា "មនុស្សដែលមានរូបភាពដែលហ្នឹងមិនសមនឹងមានថ្នាក្បាលប

ដោះស្រាយនេះបានដែរឬទេ" ។ លោកឆ្លើយតបថា "សូមអស់លោកកុំសំគាល់តែពាក្យខ្លីៗរបស់ខ្ញុំសោះ សូមគិតដល់សេចក្តីពិតដែលមាននៅខាងក្នុង" ។ អ្នកនគរទាំងឡាយស្រែកឡើងថា "បើដូច្នេះ ចូរឯងនិយាយចុះ កុំគោតញ្ញូតញ្ញូតអ្វីខ្លាំងអស្ចារ្យនេះ" ។ អេសុបឆ្លើយថា "សូមទោស! ខ្ញុំបាទមិនមានហ៊ានអធិប្បាយទេ ព្រោះនឹងមានការទាស់គ្នាអំពីជ័យជំនះនឹងក្លែងឈ្នះពាក់ព័ន្ធនាយចៅហ្វាយហើយនឹងបាត់ខ្លួនខ្ញុំបាទនេះឯង បើគាល់ណាខ្ញុំបាទនិយាយខុស គេនឹងវាយខ្លួនខ្ញុំបាទ បើគាល់ណានិយាយទៅហើយត្រូវជាប់ពាក់ព័ន្ធនាយចៅហ្វាយ ខ្ញុំបាទក៏គង់ត្រូវរំពាត់ទៀត" ។ អ្នកនគរឮសំដីដូច្នេះ ក៏បង្ខំសង្កុះឲ្យបើកអេសុបលែងទៅជាអ្នកជា ។ សង្កុះមិនព្រម ។ ទ័ពបំផុតមានសេនាបតីយ៉ាងធំម្នាក់មានវាចាថា "ត្រូវតែអ្នកឯងបើកគេលែង បើធ្វើទទឹងមិនបាន" ។ សង្កុះគាល់ប្រាជ្ញក៏សុខចិត្តព្រមតាមសំដីរបស់លោកសេនាបតី ។ អេសុបតាំងនិយាយឡើងថា "តាមហេតុគេទនេះ គឺនឹងមានគេរបៀនសំបុងចង់យកយើងធ្វើជាអ្នកបំរើបស់គេ សត្វខ្វៃឆ្លៀតមានអំណាច" ។

លុះកាលកន្លងមកមិនយូរប៉ុន្មាន ព្រះរាជាព្រះនាមក្រែសុីះ (Krésus) ជាស្តេចសោយរាជ្យក្នុងដែនលីឌី (Lydée) មានបង្គាប់មកថា "ត្រូវឲ្យអ្នកនគរសោមូសនាំពាក្យសួយរៃទៅថ្វាយចំពោះព្រះអង្គ បើមិនយល់ព្រមតាមទេ ខ្លួនឯងនឹងបញ្ជូនកងទ័ពមកកំហែងបង្ខំជាមិនខាន" ។ មានមនុស្ស

តាំងឡាយភាគច្រើនយល់ព្រមថាត្រូវចំណុះគេ ។ តែអេសុបនិយាយ
ច្រាប់ថា "ភាពរបស់ពិភពលោកមានតែផ្លូវពីរ: ទី ១ ឯកភាពមុនដំបូង
ពិបាកណាស់ឈឺខ្លួន តែសុខសប្បាយច្បើនមុខស្រួលចិត្តក្នុងពេលក្រោយ,
ទី ២ ភាវៈជាអ្នកខ្ញុំគេងាយស្រួលដំបូង តែត្រូវពិបាករងទុក្ខវេទនាចុង
ក្រោយ" ។ អេសុបគឺជាអ្នកប្រដៅឲ្យដំបូន្មានពេញដោយបញ្ញា គួរ
សមល្មមឲ្យប្រទេសសាមូសអាចការពារខ្លួនឯកភាពរបស់ខ្លួនបាន ។
បណ្តាជនបានស្តាប់សំដីត្រូវដូច្នេះ ក៏នាំគ្នាបណ្តេញភាពខូតរបស់ព្រះចុង
ក្រៃស៊ុះ ឲ្យចេញពីព្រះនគរសាមូស ។

ព្រះចុងក្រៃស៊ុះរៀបពលត្រៀម ចុះធ្វើសឹកទៅវាយប្រទេស
សាមូស ។ ភាពខូតបានក្រាបបង្គំទូលថា: "រឿងវាយដែនសាមូសសូម
ទ្រង់ឈប់បង្អង់សិន ព្រោះក្នុងដែននោះមានមនុស្សម្នាក់ឈ្មោះអេសុប
បើអ្នកនេះនៅក្នុងសាមូសដរាបណា យើងមិនងាយនឹងវាយបែកដរាប
នោះ - ដ្បិតប្រជាពលរដ្ឋតាំងឡាយក្នុងស្រុក តែងជឿស្តាប់ពាក្យ
នៃអេសុបនោះពេក" ។ ព្រះចុងក្រៃស៊ុះបញ្ជូនភាសាមួយមកកាន់
សាមូសដោយមានពាក្យសន្យាថា "បើព្រមប្រគល់ថ្វាយអេសុបដល់ព្រះ
អង្គ នោះទើបទ្រង់ទុកឯកភាពឲ្យជាសេរី" ។ ពួករដ្ឋមន្ត្រីឃើញការណ៍
នេះស្រួល ហើយមិនគិតឃើញថាការណ៍ដែលខ្លួនរួចរបូតបានសុខសាន្ត
ដោយសារមានលោកនៅជាមួយឡើយ ។ អេសុបដឹងដំណឹងដូច្នោះក៏

តាន្យស់ខ្លះតួកនាម៉ឺនតាំងនោះដោយសេចក្តីឧបមាមួយថា: "ផ្កែចចកនឹងតួកវែកតាំងឡាយ ចាន់ត្រូវចុះតំបូរសំឡាងើសន្តិភាពជាមួយគ្នា តែច្រាប់ឲ្យតួកពវែកតាំងឡាយដេញផ្កែស្រែកតាំងឡាយចេញ; លុះពវែកតាំងឡាយគ្មានអ្នកណាការពារ ផ្កែចចកមកចាំស៊ីដោយស្រណុក គ្មានពិបាកដូចលើកមុន" ។

ពួកមនុស្សក្នុងសាមូសយល់ព្រមតាមយោបល់របស់អេសុប ។ ប៉ុន្តែគេអ្នកស្រុកយល់ព្រមតាមដូច្នោះគំរាំងាយ លោកនៅតែមានបំណងចង់ទៅជួបព្រះចៅក្រែសុីះ តែលោកច្រាប់អ្នកស្រុកសាមូសថា: "ពិតមែនតែខ្ញុំទៅនៅទាន់ព្រះចៅក្រែសុីះ គង់តែខ្ញុំគិតជួយអ្នកកាល់គ្នាឲ្យបានសម្រេចនូវផលល្អ ដូចជាខ្លួនរបស់ខ្ញុំនៅឯនគរសាមូសដែរ" ។

ព្រះចៅក្រែសុីះ លុះទតយល់មេសុបកាលណា ទឹកឆ្អែលក្នុងព្រះរាជហ្ឫទ័យថា "មនុស្សបែបហ្នឹងបំនគួរឡើយរាចមកជំទាស់ដល់កិច្ចការរបស់អញសោះ ហើយទ្រង់ត្រាស់ស្រែកថា: យើ! អាហ្នឹងហើយឬដែលឆ្កើងើសទៃឆ្គងដល់ការរបស់អញ" ។ អេសុបចូលទៅជិតក្បែរព្រះបាទតាំងពីរៃព្រះរាជា ហើយនិយាយគ្រាបទូលថា: "សូមទ្រង់ព្រះមេត្តាច្រោស! មនុស្សម្នាក់ដែលបង់ចាប់សត្វកណ្តុប ក៏ទៅប្រទះឯសត្វវែញ ហើយគិតនឹងសម្លាប់សត្វវែដូចជាសត្វកណ្តុបដែរ ឯសត្វវែអង្វរមនុស្សនោះថា: ខ្ញុំគ្មានបានធ្វើអ្វីដល់អ្នកទេ: គ្មានកាត់ស្រវគ្មានបំផ្លាញដំណាំអ្វីរបស់អ្នកឡើយ ខ្ញុំមានតែសំឡេងដែលអ្នកឮខ្ញុំច្រៀង

គ្មានប្រកបដោយគោរព; បពិត្រមហាកវ! ខ្ញុំសូមព្រះបង្គំជាខ្ញុំ
ក៏ដូចជាសត្វនៃនោះដែរ គឺមានតែសំដី, ហើយសំដីហ្នឹងទៀត ក៏មិន
មែនន័យាយសម្រាប់ប្រមាថមើលងាយដល់ព្រះកិត្តិយសរបស់ព្រះអង្គ
ឡើយ ។ ព្រះចៅក្រសុះដែលចាន់ទ្រង់ព្រះសណ្តាប់នូវរាជ្ជប្បោះ
ហើយ ក៏សរសើរនូវបញ្ញាដ៏វៀងវៃ ទំនងមានព្រះពុទ្ធិយអាណិតគាន់
តែក មិនត្រឹមតែប្រទានរោសដល់អេសុបទេ ព្រះអង្គថែមទាំងឈប់រក
រឿងហេតុនឹងប្រជាពស្ត្រីនៃនគរសាមូសផងទៀត ។

ក្នុងវេលានោះ អេសុបចាប់ផ្តើមនូវសុភាសិតទាំងឡាយជាពាក្យកាព្យ
ហើយទុកថ្វាយចំពោះព្រះចៅក្រសុះ, ចំណែកលោកតំរិលទៅគាន់សា-
មូសវិញ ។ ពួកនាម៉ឺនធំតូចត្រមទាំងប្រជាពស្ត្រវៀបទួលលោកជាម-
ច្ចាវិក ។ រួចលោកមានបំណងនឹងធ្វើដំណើរទៅគាន់ប្រទេសក្រៅផ្សេង
ដើម្បីរកវៀននូវវិជ្ជាថែមទៀត ជាមួយនឹងមនុស្សទាំងឡាយដែលមាននាម
ហៅថា "បណ្ឌិត" ។ ខាងក្រោយបំផុត លោកទៅអាស្រ័យនឹងព្រះ
រាជាព្រះនាមលីសេរុះ (Lycérus) ដែលស្តាយរាជ្យក្នុងនគរចាប៉ីឡូន ។
ក្នុងសម័យនោះ ព្រះរាជាទាំងឡាយចូលចិត្តលេងចំណោទណាស់ បើ
នគរណារកមិនឃើញ នគរនោះត្រូវនាំសួយសារអាករទៅថ្វាយចំពោះ
ព្រះរាជាដែលជាដៃគូ ឬមួយគេយករាជ្យចាក់ ។ ចំណែកព្រះករុណា
លីសេរុះដែលមានអេសុបនៅជាមួយច្រើនមានជ័យ ល្បីស្តើរល្បាញអស់
ការដោះស្រាយប្រស្នាឬចោទឲ្យគេរក ។ (អានត)

លោក រ៉ាយ - ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ប្រៀបរឿង

(តមក)

តែព្រះសិទ្ធត្ថបានតបទៅព្រះបាទពិម្ពិសារថា: "ព្រះករុណាថ្លៃវិសេស! របស់ទាំងអស់នោះខ្ញុំព្រះបង្គំមានហើយ, ខ្ញុំព្រះបង្គំបានលះបង់ដើម្បីនឹងស្វែងរកធម៌ពិត, ខ្ញុំព្រះបង្គំបានរំកេះហើយនឹងរកតទៅអនាគតទៀត, បើពុកណាជាប្រាសាទសក្ក: (សក្កទេវរាជ: ព្រះឥន្ទ្រាធិរាជ) បើកទ្វារចំហ ហើយក៏តាមកអង្វរឲ្យខ្ញុំព្រះបង្គំចូលទៅកន្លែងមហាប្រាសាទនោះ ខ្ញុំលបង្គំក៏មិនព្រមចូលទៅដែរ, ខ្ញុំលបង្គំមានបំណងនឹងស្ថាបនាព្រះពុទ្ធអាណាចក្រនៃធម្មាប់; ខ្ញុំលបង្គំនឹងទៅឯប្រទេសគយាដែលមានរុក្ខជាតមានសន្ធឹកត្រសុំសាខា មានម្លប់ត្រជាក់ស្រួលទៅទីនោះ, ប្រសិនខ្ញុំលបង្គំអាចរកតន្ទីដែលជាធម៌ពិតឃើញបាន, តន្ទីពាំងនោះដែលមកស្ថិតនៅក្នុងពួកប្តីបាន មិនមែនមកពីអានសាស្ត្រ[1] ឬដោយអត់អាហារតាលតែរូបនោះទេព្រោះអនិច្ចកម្មនោះទេ; តែតន្ទីនោះមាន; ខ្ញុំលបង្គំបំណងនឹងទៅរកតន្ទីនោះឲ្យឃើញ, ស្វែងរកធម៌ពិតឲ្យឃើញ,

---

១ សាស្ត្រ: គម្ពីរពិសិដ្ឋជាតិឥណ្ឌាមានសៀវភៅវាងសាសន៍, ទស្សនវិជ្ជាគណិតសាស្ត្រ, វេយ្យាករណ៍, ធម្មសាស្ត្រ និងគម្ពីរវេទណ្ឌ។

ដល់ខ្ញុំលបង្គំឃើញធម៌នោះវេលាណា ខ្ញុំលបង្គំនឹងវិលត្រឡប់មកបំពេញ
ការណ៍យកិច្ចចំពោះព្រះមហាក្សត្រិយ៍ក្នុងវេលានោះមិនខាន" ។

ព្រះបាទពិម្ពិសារ ទ្រង់បានធ្វើប្រទក្សិណព្រះអង្គម្ចាស់បីដុំ, ទន
ព្រះសិរសាគោរពជិតព្រះបាទព្រះពោធិសត្វ ហើយថ្វាយពរសត្ថុសាធុ-
ការថា "សូមឲ្យបានសេមើចដូចព្រះពុដបំណង" ។ រួចព្រះពោធិសត្វ
ព្រះអង្គនិមន្តទៅកាន់ទុរុវេលៈ (ទុរុវេលសេនានិគម) តែព្រះទ័យរបស់
ព្រះអង្គមិនទាន់រកធម៌នោះឃើញនៅឡើយ; ព្រះភ័ក្ត្រព្រះអង្គស្វាយ
ស្វេតស្វាំង ហើយព្រះកាយពលអន់ខ្សោយដោយការស្វះស្វែងរកធម៌នេះ
(បំពេញទុក្ករកិរិយា) អស់ពេល ៦ ឆ្នាំ រួចពីនោះព្រះអង្គបាននិមន្តទៅ
សំណាក់ក្នុងពួកបណ្ឌិត (ព្រាហ្មណ៍) នៅជិតក្នុងឆ័ន្ទអជនបទទេស គឺ
អាឡារគាបសនឹង១ ទុកគាបស ព្រមទាំងឥសី ៥ នាក់ដែលបានសំដែង
ពិតទូលព្រះអង្គអំពីធម៌ពិត ដែលបានពណ៌នាទូវគម្ពីរសាស្ត្រ គឺគ្មាន
អ្នកណាបំណងឲ្យបានដល់ភោនន្តរខ្ពស់ជាងពួកស្រោតិ (Srouti) នឹងស្មតិ
ប្ញី (Smriti) [៤] បើទុកជាលោភកណា ដែលជាសន្តិបុគ្គលវិសេសក៏ដោយ ។
ព្រោះថា ធម្មតាមនុស្សប្រុសក្នុងលោកនេះមិនដែលមានអ្នកណាចេះជាងគម្ពីរញាណ-

---

១ ស្រោតិ (សំស្រុត)= ធម៌ពិតដែលរាកឃើញ, ដែលមានតៅគម្ពីរវេទ ។ ស្មតិ= ប្ញី
សេរ្ចីភោធម៌ទាំងអស់ ដែលពួកឥសីពីបុរាណរៀបរៀង ។

ក័ណ្ឌ (Jnana-Kand) [1] ដែលថ្លែងថា ព្រះត្រៃបិដកនាមធម៌, មិនប្រតិបត្តិការអ្វីទេទៅស្រឡាំងកាំង, ព្រះចំឃើយសូម្បីដែលគេមិនអាចប្រៀបធៀបទៅនឹងអ្វីបានឡើយ, ចំឯបេះដែលប្រែប្រួល, មានដីវភាពបរិសុទ្ធផុតមន្ទិលសៅហ្មង, មនោគតំស្អាត, គួរជាទីគោរពតាន់ពេក, ប្តមនុស្សសាមញ្ញមិនមានអ្នកណាអាចបេះជាន់គម្ពីរ កម៌ក័ណ្ឌ (Karma-Kand) [2] ដែលបង្ហាញនូវវិធីលះបង់នូវបាបអកុសលនឹងកម្មកាត បំបាត់នូវច្រកក់នៃអាត្មន ហើយចេញក្រៅពីទំនួ ប្រែទៅជាព្រះ (Dieu) រួចយទៅជាមួយនឹងសុខុមធម៌, ហោះហើរពីសភាពទុសទៅកសភាពត្រូវ, ការតស៊ូនឹងកាមារម្មណ៍ ដើម្បីនឹងបានទៅដល់ស្ថានបរមសុខ ដែលមានតែសភាពស្ងាត់ស្ងៀមទេ ។

តែព្រះពោធិសត្វទ្រង់ចាន់សារនាពួកឥសីទាំងនោះ ហើយព្រះអង្គទៅតែមិនចាន់ពេញព្រះទ័យ ។

(មានត)

---

* ញ្ញាណៈក័ណ្ឌ (សំស្ក្រឹត : សៀវភៅទាំងឡាយស្តីអំពីធម៌ដែលល្អិតម៌ពីភាពនៃតម្លៃរបស់ ។

* កម៌ក័ណ្ឌ (សំស្ក្រឹត សៀវភៅទាំងឡាយស្តីអំពីធម៌, ផ្នែកទាំងឡាយនៃព្រះធម៌របស់ ។

ឃុនបណ្ណាគុរក្ស ប៊ូ-ប៊ូ ទៅពុទ្ធសាសនបណ្ឌិត្យ

ប្រៀបធៀបរឿង

(ត-ចប់)

ព្រះមហាក្សត្រគ្រាស់យ៉ាងនេះហើយ ទ្រង់គ្រាស់គាថាតទៅទៀតថា

រតនាករោ កម្ប៊ីរេ　　មាលុតេន ច ខុកំសោ
តារឆរោ ភូមិចាលោ　　អមច្ចេនេវ ខុកំសោ
ន ហោតំ បញ្ញតោ ភាវោ　　ន ភាវោ សព្វសាភរោ
មិត្តន្ទុព្ភិ នរោ ភាវោ　　វិសាសនត្តោ ជនោ
បឋវី សាភរោ មេរុ　　ឧយំ យន្តំ យុក្តក្ខយេ
ភេប្បានំ សតសហស្សានំ　　ទុព្ភិចាបំ ន បស្សតិ
ភណ្ណាជប្បមិ ភាភាន　　ភាលេ ភបិ វិនាសភា
ចាសាណាប្បលុភ្ភជាវ　　ឧនភេនេវ ភេនភា ។

"អណ្តូងវែកវែងខ្លាំងជ្រៅ។ នៅតែខ្សល់បក់ឲ្យរង្គើកំរើកបាន ព្រះរាជាម្ចាស់ផែនដីគ្រប់គ្រងនគរ ពួកអាមាត្យអាចធ្វើឲ្យកម្រើកញាប់ញ័របាន ; កំទេចសមុទ្រទាំងពួងមិនខុកជាជ្រៅរបស់ធ្ងន់ទេ នរជនអ្នកទ្រុស្តមិត្តអ្នកធ្វើឲ្យបែកបាក់សេចក្តីស្និទ្ធស្នាលរបស់គេខើបធ្ងន់ ; ផែនដីនឹងសមុទ្រប្រុកុំ ដល់វេលាអស់យុគ្គនៃសែនកប្បហើយ កំរើមេរុវិនាសសាបសូន្យ

ទៅទាំងអស់, មនុស្សដែលគិតតែញុះញង់បំបែកបំបាក់មិត្តសំឡាញ់គេ
មិនយើញទូវបាបកម្ម ដេះតែធ្វើការឡើបក្បែត្រចៀកគឺការញុះញង់គេ
មានទៅកន្ត្រកូលណា ក៏អាចធ្វើត្រកូលនោះឲ្យវិនាសភ្លាត់ភ្លាយទៅ
ប្រៀបដូចជាដុំថ្មដ៏ធំប៉ុនជាលជាក់ស្រួវត្រូវទឹកហូរយ៉ាងខ្លាំងបោកបំបែក
ល្អិត ខ្ទេចខ្ទីរទៅបាន" ។

តាំងពីពេលនោះមក ព្រះមហាសត្វត្រាស់បង្គាប់ឲ្យកេចាប់មនុស្ស
ដែលញុះញង់គេ បានប៉ាយឲ្យបណ្តេញចេញអំពីដែន ព្រមទាំងឲ្យ
លើកទោសចោលខ្លះតាមគួរ, គាលព្រះអង្គទូន្មានប្រជាពស្តែងត្រាស់
គាថាថា:

ជីវិតម្បី ចជិត្វាន កេនន្តរំ ការយេ
ការយភេទញ្ច រក្ខិត្វា វិចារេត្វា ការយេ
ជំសម្ម បណ្ឌិតា ការយិរ ជាជំសម្មាបំ ការយិរ
វិមំសិត្វា វិចារេត្វា បច្ចា ន អនុតប្បតិ
យថា សុវណ្ណការំសាបំ កេនចំ បរិកេនិតា
តំន្តន្តស្ស តហោត្វាន អញ្ញមញ្ញាវ កេនិតា
ឯកោ អជ្ជោ ជំវេសេតិ ឯកោ ឥមំ ជំវីសតិ
អញ្ញមញ្ញំ អសំសដ្ឋា មុខេជាបំ អនុសំតា ។

"បើខ្លួនជាជីវិតនឹងក្សណក្សយ បុគ្គលកុំគប្បីធ្វើទោស គឺការ
ចាក់រុកគ្នាឲ្យបែកបាក់ឡើយ គប្បីសម្លឹងការយ៉ាងច្បាស់ឲ្យ

ល្អិតល្អហើយទើបធ្វើតែអំពើដែលត្រូវ, អ្នកថ្មដ្ឋាន់ឆ្ងាយលុះតែត្រិះរិះពិចារណារួចហើយទើបបានធ្វើ, បើលោកមិនទាន់បានពិចារណាដាបុនលោកមិនធ្វើទេ; បុគ្គលមិនត្រិះរិះពិចារណាជាមុនហើយចេះតែធ្វើៗ ទៅវាមែនបានសេចក្តីក្តៅក្រហាយខាងក្រោយ ដូចដាហង្សមាសក្សាលពីរខ្លួនមួយជាប់គ្នា ត្រូវអាមាត្យអ្នកញុះញង់ឲ្យបែកគ្នា ប្រកាន់សំដីរបស់អាមាត្យអ្នកញុះញង់ក៏បែកខ្លួនចេញពីគ្នាដាពីរ, ហង្សមួយទុកចំញ៉ីមក្នុងព្រះពដាំង, ហង្សមួយទុកឲ្យនៅក្រៅពាំង បែកខែកត្រាត់ច្រាសគ្នាយើញដាក់ស្តែងនឹងភ្នែក ។ ។

លំដាប់ពីនោះមក ព្រះមហាក្សត្របានសោយរាជសម្បត្តិដោយធម៌ដ៏ស្មើ ប្រជារាស្ត្រមានចិត្តស្មោះស្ម័គ្រស្មូតត្រង់នឹងគ្នា ប្រព្រឹត្តកាយវាចាចិត្តដាសុចរិតរៀបរយល្អ ។ ព្រះបាទពារាណសីទ្រង់បំពេញបារមីទាំង ៣០ ប្រការ លុះដល់វេលាទិវង្គតហើយបានទៅកើតក្នុងទេវលោក, ក្នុងដាតិដាទីបំផុតបានសោយព្រះដាតិដាព្រះបាទវេស្សន្តរ ទ្រង់បំពេញសត្តសតកមហាទាន ដល់ទិវង្គតទៅកើតក្នុងតុសិតបុរី, លុះព្រះបាទវេតញ្ញបរិបូណ៌ហើយ ទេវតាក្នុងមុខចក្រវាឡូលអាភធនាឲ្យច្យុត, ព្រះអង្គបានពិចារណាមើលមហាវិលោកនៈទាំង ៥ ស្រេចហើយ - កំប្យុតចាកតុសិតសួគ៌មកចាប់បដិសន្ធិក្នុងព្រះឧទរនៃព្រះនាងមហាមាយា, ចាប់ចាប់ដើមពីច្រសូតមកហូតដល់ព្រះជន្មបាន ២៩ ឆ្នាំ មានព្រះរាជនុសេ ១ អង្គ

ព្រះនាមថាភទ្ទវតីកុមារ, កន្លះរសៀលត្រីកណ្តាលអធ្រាត្រថ្ងៃមួយ ព្រះអង្គ
ច្រាច្ចាទឹងទ្រង់ព្រះផ្ទៃ មានរោគាតង្កមុំនចក្រកាឡទឹងនាយធន្តអាមាត្យ
តាមហៅផៅដង ស្តេចចេញកាន់មហាកិនិស្រួមន៍ ទ្រង់បំពេញមហា-
បធានវិរិយៈនៅកន្លះព្រៃដល់ ៦ ខែ ព្រះអង្គច្រានសោយមធុច្ចាយាសដែល
នាងសុជាតានាំមកថ្វាយ ហើយស្តេចឡើងគង់លើពោធិបល្ល័ង្ក បែរព្រះ
កត្តែទៅទិសបូព៌តាំងព្រះខ័យងាយសមាធិវត្ត ទ្រង់ផ្តាញ់ស្តេចមារព្រម
ទាំងពល ហើយក៏ច្រានត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ, តាំងពីនោះមក
ព្រះអង្គទ្រង់ប្រថានព្រះធម៌ទេសនាដល់ទេវតា ទឹងមនុស្សជាលំដាប់មក
ព្រះអង្គទឹកព្យុកដល់ពាកណាសីរាជដាតក ទើបលើករឿងនោះមកអាង
ជាមូលហេតុហើយសំដែងព្រះធម៌ទេសនា ដោយន័យគាថាប៉ុណ្ណេះ
ជាដើមថា ។

អត្តំវំយេសុ កដ្ឋេ អមិត្តញ្ច សេវំយេ
សុក្កេ ច មំ បវត្តេ កណ្ហេ ច មំ ច សេវិត្ថ ។

"អ្នកចាំងច្បាយចូរសេពគប់តែមិត្តដែលជាទីស្រឡាញ់ ចូរកុំសេព
គប់នឹងមនុស្សជាអមិត្ត ចូរប្រព្រឹត្តធម៌ស កុំសេពធម៌ខ្មៅ, មួយទៀត
មនុស្សល្អកាលចូលទៅសេពគប់នឹងមនុស្សអាក្រក់ហើយ ក៏ទៅជា
អាក្រក់ដូចគ្នា, បុគ្គលសាបព្រោះបណ្តុះពូជយ៉ាងណា រមែងបានផល
យ៉ាងនោះ, អ្នកធ្វើអំពើល្អរមែងបានផលល្អ អ្នកធ្វើអំពើអាក្រក់

រមែងបានផលអាក្រក់, អ្នកគាំងឡាយកុំសេពគប់នឹងបុរសបោកគាប
គប្បីសេពគប់នឹងបុរសដែលល្អ។ តែម្យ៉ាង, បុគ្គលយកមនុស្សបែបណា
មកធ្វើជាមិត្ត ស្និទ្ធស្នាលនឹងមនុស្សបែបណា អ្នកសេពគប់ស្និទ្ធស្នាល
នោះរមែងក្លាយទៅតាមគ្នាបាន, ដំណែកលោកអ្នកមានបញ្ញាមិនហ៊ាន
សេពគប់នឹងមនុស្សអាក្រក់ទេ ព្រោះខ្លាចសេចក្តីអាក្រក់នោះប្រឡាក់
ដល់ខ្លួនលោក, អ្នកណាខ្ចប់ត្រីស្អុយដោយស្បូវភ្ញីង។ នោះក៏ស្អុយទៅ
តាមផងដូចម្តេច ការសេពគប់នឹងមនុស្សគ្រោលក៏មានអាការដូច្នោះដែរ ។
អ្នកណាខ្ចប់ត្រីស្ពានដោយស្លឹកឈើ។ នោះ ក៏មានក្លិនត្រអូបទៅតាមផង
ដូចម្តេច ការសេពគប់នឹងបណ្ឌិតរមែងត្រអូបដូច្នោះដែរ, មនុស្ស
អសប្បុរសរមែងទៅនរក មនុស្សសប្បុរសមានស្ថានសួគ៌ជាទីទៅខាង
មុខ, អ្នកស្វែងរកទោសជាក់គេរមែងទំលាយបំផ្លាញមនុស្សពួកច្រើនឲ្យ
វិនាស នាយព្រានវៃព្រលឹងបញ្ឆោតសត្វទ្រឹគដោយទុំបាយកល ឲ្យមក
កាន់សំណាក់ខ្លួន ហើយសម្លាប់យកតាមចិត្តបានយ៉ាងណា មនុស្ស
ទាំងឡាយល្ងង់បញ្ឆោតមហាជនដោយថ្នាយទឹកនឹងវាចាផ្អែមល្ហែម ស្មែង
រកទោសគេបានតែបន្តិចបន្តួចហើយ ក៏ដួលទុក្ខទោសឲ្យកើតឡើងបំផ្លាញ
សេចក្តីល្អរបស់គេឲ្យសាបសូន្យអស់ទៅដូច្នោះដែរ ។

. មួយទៀត ផ្លែចចកនឹងសត្វស្វាបទាំងឡាយដឹងចិត្តគ្នាល្អហើយ
នៅជាមួយគ្នាបាន, ឯមនុស្សនៅជាមួយនឹងមនុស្សដូចគ្នាលំបាកណាស់

កម្រែនឹងដឹងចិត្តគ្នាបាន, ដ្បិតចិត្តរបស់មនុស្សតែងតែប្រែប្រួលទៅក្នុងខណៈ។ ព្រោះហេតុនោះ បុគ្គលគប្បីវៀរចាកទោសគឺការញុះញង់គេឲ្យឃ្លាតចេញឆ្ងាយកាល់តែបាន, ទោសនៃការបែកបាក់ចាកគ្នាតើតមានឡើងព្រោះតែពាក្យញុះញង់. អ្នកពេញចិត្តតែនឹងការញុះញង់គេត្រមាំងធ្វើឲ្យបែកខ្ញែកគ្នា រមែងទៅនេះក្នុងនរកអស់សែនកប្ប កាលផុតពីនរកមកហើយ ទើបតើតជាមនុស្ស ក៏ជាមនុស្សភាល់ក្រពិកលពិការ កាយាតាំងជាមនុស្សកំព្រាអនាថា មានកាយាដូចប្រែតឆ្អែតឆ្អឹម អត់ឃ្លានក្រហាយទឹក តាំងនេះក៏ព្រោះតែទោសនៃការធ្វើឲ្យគេបែកបាក់គ្នាឲ្យផុសមក, អ្នកញុះញង់គេខ្លះទៀតតើតជាប្រែតស៊ីតែដង្កូវជាអាហារ, អ្នកប្រាជ្ញដែលមានប្រាជ្ញាណាលោកយើញទោសយ៉ាងនេះហើយ ឃ្លានជាលោកវៀរចាកការញុះញង់ឲ្យឃ្លាតឆ្ងាយពីសន្តានចិត្ត; ការធ្វើអត្រកន់ទឹងធ្វើល្អទុកមក រមែងបានផលអត្រកន់ទឹងឆាប់ល្អដូច្នោះឯង មិនត្រូវសង្ស័យឡើយ។

សម្តេចព្រះបរមសាស្តា ឥលនឹងទ្រង់ប្រកាសអានិសង្សនៃសេចក្តីសាមគ្គី ទ្រង់ត្រាស់គាថានេះជាដើមថា :

យេសមត្តា បុញ្ញវតា ឯតកិច្ចេសវេ ឥតា
បមជ្ជន្តិ សត្តសម្បត្តិ វិសេសំ ចាបុណន្តិ សុ ឯតេ ។

អ្នកណាត្រេកអរនឹងបុណ្យ មានមេត្រីចិត្ត ជាទីតិចិត្តមួលមួយគ្នា

អ្នកនោះរមែងដល់នូវសម្បត្តិសួគ៌នឹងគុណវិសេសយ៉ាងធំក្រៃលែង ៗ ដ
ក្រោយនឹងដល់ព្រះនិព្វានជាទីក្សេមក្សាន្តប្រាសចាកភ័យ ។

មួយទៀត អ្នកនោះកាលនឹងទៅកាន់ទៅកន្លែងសង្ឃាវាសវត្ត ជាអ្នកមាន
ញាតិសន្តានច្រើនព្រមព្រៀងមូលចិត្តគ្នា ដូចវត្ថុជាតិដែលតើតច្រើនដោ
កន្លែងព្រៃដូច្នោះដែរ, សេចក្តីព្រមព្រៀងគ្នាជាគុណអាចនឹងការពារនូវ
អន្តរាយដែលនឹងមានមកដល់ខ្លួនឲ្យផុតទៅបាន ប្រៀបដូចសត្វដែលមាន
ហ្វូងធំច្រើនស្រុះចិត្តគ្នា ក៏អាចនឹងចាប់ខ្លាធំមួយដ៏កាចសាហាវទាំងមូលបាន
បាន ។ ព្រោះដូច្នោះ លោកទាំងឡាយ ចូរតែតអរក្នុងអប្បមាទធម៌
ចូររក្សាចិត្តខ្លួនឲ្យល្អ គប្បីរក្សាកាយវចីមនោទ្វារខ្លួនឲ្យល្អពាល់ថ្ងៃ គប្បី
លះបង់សំដីញុះញង់ចេញ ទំនងដៀសវាងការឈ្លោះប្រកែកគ្នាចេញឲ្យ
ឆ្ងាយពីសន្តានគ្រប់ថ្ងៃ, អ្នកប្រកបដោយសាមគ្គី នឹងមានតែសេចក្តីសុខ
គ្រប់ឥរិយាបថ ហើយនឹងបានអានិសង្ស ១១ ប្រការ (តែព្រះសាស្តា
មិនបានសំដែងក្នុងទីនេះទេ) ។

សត្ថា ឥមំ ធម្ម ទេសនំ អាហរិត្វា សម្តែចព្រះបរមសាស្តា
ទ្រង់នាំព្រះធម្មទេសនានេះចប់ហើយ ទើបប្រដុំជាតកថា "នាយព្រានព្រៃ
ក្នុងគ្រានោះ គ្រឡប់ជាតំមកគឺព្រះឆន្នត្ថេរ, ហង្សមាសមួយកន្លះគ្រានោះ
គ្រឡប់ជាតំមកគឺព្រះគិរីមានន្ទត្ថេរ, ហង្សមាសមួយទៀតកន្លះគ្រានោះ

ត្រឡប់ជាតិមកគឺព្រះកាលុទាយីត្ថេរ. អាមាត្យអ្នកឈ្វាសវៃក្នុងគ្រានោះ ត្រឡប់ជាតិមកគឺព្រះសារីបុត្តត្ថេរ, បរិស័ទទាំងឡាយក្នុងគ្រានោះត្រឡប់ជាតិមកគឺពុទ្ធបរិស័ទ, ព្រះបុទុមាពាណសីក្នុងគ្រានោះត្រឡប់ជាតិមកគឺតថាគត" ។ មានពុទ្ធវចនៈឲ្យចប់ចុះដោយប្រការដូច្នេះ ។

ពាណសីរាជជាតក ៤ចប់ ។

សុភាសិត

ប្ដូរជាសំពើនឹងខ្លួនដោយខ្លួនឯង ។
សេចក្ដីបរិសុទ្ធិនឹងមិនបរិសុទ្ធិ ជារបស់បំពោះខ្លួនអ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបាន ។

ប្រទេសឯកវាជ្យ មានសេចក្ដីលំបាកវេទនាដំបូង
តែខាងក្រោយមក មានសេចក្ដីក្សេមក្សាន្តប្ដេជ្ញាគ ។
ប្រទេសទុំគេ មានសេចក្ដីធូរស្រួលដំបូង
តែខាងក្រោយមក មានសេចក្ដីវេទនាជាអនេក ។

ពិធីសម្ពោធឲ្យបើកសាលាធម្មវិន័យ

នៅវត្តព្រះព្រហ្មវត្ត ស្រុកមកប

ព្រះមហាកែ-អ៊ឿន រៀបរៀង

ការពិធីបុណ្យនេះ ស្ថិតនៅថ្ងៃពុធ ១២ កើតខែទុតិយាសាធ ឆ្នាំខាលចត្វាស័ក ព.ស. ២៤៨៣ ត្រូវនឹងថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៤០, នៅវត្តព្រះព្រហ្មវត្ត ខែត្រស្រុកមកប មានធ្វើពិធីដ៏ឧឡារិក ហៅថា: "បុណ្យសម្ពោធឲ្យបើកសាលារៀនធម្មវិន័យ" ។ ក្នុងពិធីបុណ្យនេះ ល្អចំឡែកអស្ចារ្យពន់ពេក គឺសាលាធម្មសភាចាំងមូលនឹងសាលាធម្មវិន័យ មានរៀបគ្រឿងសក្ការបូជាថ្វាយដល់ព្រះរតន ត័យ, គ្រឿងសក្ការនោះប្រដាប់ដោយស្លឹកឆ្ការ-ឈើស្រស់ចំរុះពណ៌ទៀវៗនឹងនឹងជាតិតូចធំជារួចន ។ ក្នុងកណ្ដាលសាលាធម្មសភា មានភ្ជាររៀនបញ្ឈរធំមួយតែងជាវិត្តសណ្ឋាន គឺជាតិ-សាសនា-មហាក្សត្រ ។ នៅកណ្ដាលភ្ជាររៀននោះមានសរសេរអក្សរធំៗ ខ្លះជាតិពីរបីឯទៀតគ្រប់ជាតិមិនឲ្យឃើញអក្សរ ខ្លះបំរុងឲ្យលោកជាឥស្សរជនខាងក្រៅបើក ។ ខាងលើភ្ជាររៀននោះគេតម្កល់ព្រះពុទ្ធរូបកញ្ចក់មួយព្រះអង្គ, ចុងភ្ជាររៀនខាងស្ដាំសងខាង គេតម្កល់ព្រះបរមរូបព្រះករុណាជាម្ចាស់ដ៏ថ្កៅ ខ្ញុំរូបអ្នកអង្គម្ចាស់យុត្តិវង្ស, ខាងមុខភ្ជាររៀន មានតុ ១ តម្កល់ព្រះវិត្តបដក ។ បន្ទាប់ពីនោះគេរៀបកៅអីជាពីរ

ជូនទឹកតុះតម្ពល់ផ្កាសម្រាប់ទ្រលុតស្បែជន, ចុងក្លោងទៀនសងខាងមុខ
ព្រះបាំងពីរ គេដាក់ដើមរណារពីរតម្ពល់តម្លឹះសាស្ត្រា ។ តាំងពីមុខ
សាលាទៅគេរៀបធ្វើជាកជរតែប្រដាប់ដោយស្លឹកឈើស្រស់ខ្ចាត់ខ្ចែង ទឹង
ចង់ជាតដកបដល់ក្លោងទ្វារធំកំពែងត្រៃ ។ វេលាម៉ោងពីរ ២០ នាទី
រសៀលព្រះសង្ឃជាង ១០០ អង្គ មានព្រះតេជព្រះគុណព្រះសុមង្គល-
សីលាចារ្យមេគណ ទឹងព្រះតេជព្រះគុណព្រះគ្រូបញ្ញាវិជ្ជាអនុគណជា
ប្រធាន ទឹងពុទ្ធបរិសទ្យជាច្រើន កុះករជាងពាន់នាក់ចូលនិមន្តទឹង
អញ្ជើញទៅដួបជុំនៅសាលាធម្មសភា ត្រៀមចាំបដិសណ្ឋារៈទទួលលោក
ឧកញ៉ាព្រះពលប្រតិភូ (ទេព - ជន) ទឹងលោកវរសេនីយត្រី (ឈួន
ម្លូលពេជ្រ) ព្រមទាំងឥស្បែជនខ្លះក្នុងវិត្រ ។ នៅពេលនេះមានគេ
ចំតរូបម្ពង ។ វេលាម៉ោងប៉ែ ២០ នាទី អស់លោកជាឥស្បែជនអញ្ជើញ
ទៅដល់, ត្រូមភ្លេងលេងភ្លេងនគរពេជទទួល ។ លុះឥស្បែជនអញ្ជើញ
ទៅដល់ថ្វាយបង្គំចំពោះព្រះសង្ឃរួចហើយក៏អង្គុយលើកៅអី ដោយ
ឯកឧត្តមា ។ ក្រោយពីខោះបន្តិចមកមានឧបាសកម្នាក់យកវិត្រដែល
ចងទឹងជាតិទាំងសន្ទានជូនទៅលោកឧកញ៉ាព្រះពលប្រតិភូ ឲ្យទាញ
បើកក្តារបញ្ជីរខោះ លោកក៏ទាញបើកភ្លាម ទឹងជាតិទាំងគូរក៏បើកចេញ
ពីគ្នាសុះទៅទៅបុង្គារទាំងពីរទាង ។ ពេលខោះគេមើលឃើញអក្សរ
សរសេរនៅក្តារថា:

សាលារៀនជាន់ខ្ពស់

វត្តព្រះស្ទឹងមានជ័យ

ធម្មវិនយោ សាសនស្ស មូលំ

ធម្មវិន័យជាឫសគល់នៃសាសនា, សាសនាជាពន្លឺនៃប្រទេសជាតិ

កម្ពុជោ ភូមិស្មេ ភវេ

សូមឲ្យប្រទេសកម្ពុជា រួចខាតទាសភាព

ពេលនោះ ភ្លើងពិណពាទ្យក៏ពេទ្ធគឹកកងរំពងឡើងខ្ទរខ្ទាំងអណ្តែរ, លុះចប់ភ្លេងហើយ ព្រះមហាវែក - អឿន សូត្រសុន្ទរកថា ដោយទគ្ឃាសនសញ្ញ ដូចមានសេចក្តីតទៅនេះ :

សុន្ទរកថា

ខ្ញុំព្រះករុណា អាត្មាភាព ជាតំណាងព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណទីពាគណៈ ទទឹងព្រះតេជព្រះគុណព្រះគ្រូបញ្ញា ទីជាអនុគណ ទទឹងភិក្ខុសង្ឃទាំងអស់ ព្រមទាំងពុទ្ធបរិស័ទ្ធជាចំណុះដើងវត្តនេះ ។

សូមពិតថេរវាចា ព្រះករុណាគ្រប់ព្រះអង្គ !

សូមចំរើនពរព្រះតេជព្រះគុណលោកអ្នកទកញ្ញា ព្រះពេជ្រចិតភូ !

ព្រះតេជព្រះគុណលោកវិរៈសេនីយត្រី ខាយកកងឯកទេសខ្មែរ!
ខ្ញុំ លោកជាតិសូវជនតំណឡាយក្នុងខែត្រតាំងអស់!

សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព មានសេចក្តីត្រេកអរដ៏ពន្លឹក ខ្ញុំមានអំណរអរគុណដ៏ក្រៃលែង ចំពោះព្រះករុណាគ្រប់ព្រះអង្គខ្ញុំអស់លោក-អ្នកភំនឡាយ ដែលឯកនឹមន្ត អញ្ជើញមកដាមជ្ឈល ខ្ញុំជាកិត្តិយស ក្នុងការបុណ្យសម្ពោធប្រើការសាលារៀនធម្មវិន័យថ្មីនេះ:

ព្រះករុណាគ្រប់អង្គ!
ព្រះតេជព្រះគុណលោកឧកញ៉ាព្រះពជប្រតិភូ!
ព្រះតេជព្រះគុណលោកវរសេនីយត្រី!
អស់លោកជាតិសូវជនតំាងឡាយ!

ពេលនេះខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងការណ៍នៃកិច្ចរៀនសូត្រធម្មវិន័យក្នុងព្រះពុទ្ធសាសនាដោយសេចក្តីសង្ខេប ដូចតទៅនេះ:

ធម្មវិន័យជាឫសតែវនៃព្រះពុទ្ធសាសនា ជាសភាវៈសំដែងប់ក្លឹងនូវផ្លូវលោកនឹងផ្លូវធម៌ ។ ក្នុងលោកភំនឡូល លុះតែមានតំាងផ្លូវលោកផ្លូវធម៌ស្មើគ្រប់កាល ទើបបានសេចក្តីសុខ សេចក្តីចំរើនថ្កើងរុងរឿងជានិច្ច, បើមានតែផ្លូវលោកមួយចំណែកមិនមានផ្លូវធម៌សោះ លោកនឹងក្តៅឆេះជាក្តើង, បើមានតែផ្លូវធម៌មួយចំណែកមិនមានផ្លូវលោកសោះ លោកនឹង

ក្នុងទៅជាដៃ, ហេតុនោះផ្លូវលោកនឹងផ្លូវធម៌តែងអាស្រ័យគ្នាដើរឆ្ងៃ
ទៅមកគ្រប់កាលទើបប្រព្រឹត្តទៅបាន, ប្រៀបដូចជាគោ ១ ទ័មដែលអូសនង្គរភារៈដ៏ធ្ងន់ លុះតែគោទាំងគូប្រឹងអូសទៅស្មើគ្នាទើបប្រព្រឹត្តទៅរួច សេចក្តីនេះយ៉ាងណា ឯផ្លូវលោកនឹងផ្លូវធម៌ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ព្រះតេជព្រះគុណព្រះពជប្រតិកូ នឹងព្រះតេជព្រះគុណវរសេនីយត្រីនាយកកងឯកទេសខ្មែរ កាលបានជាបកាណ៍នេះដោយជាក់ច្បាស់ ទើបលោកបួបរួមជាមួយនឹងអាត្មាភាពជាមេគណនឹងអនុគណជួយទប្ចុក្តម្ភផ្នែងផ្តើមបង្កបង្កើត ឲ្យមានសាលាសិក្សាធម្មវិន័យនេះរឿងសម្រាប់បណ្តុះធម្មវិជ្ជា នៃសិក្ខាកាមកុលបុត្រដែលបព្វជ្ជាកងព្រះពុទ្ធសាសនា ជាគុណញ្ជាំងព្រះពុទ្ធសាសនាឲ្យថ្កុំថ្កើងរុងរឿង នឹងជាប្រទីបពន្លឺនៃប្រទេសជាតិ ។

អាត្មាភាពមានសេចក្តីនឹកសង្ឃឹមកក់ក្តៅកងចិត្តថា: កងវិទ្យាល័យសៀមពហនេះ មិនយូរប៉ុន្មាននឹងទៅជាវិទ្យាល័យ ១ សម្បូណ៌ដោយធម្មវិន័យ នឹងវឌ្ឍនធម៌ខាងព្រះពុទ្ធសាសនា ជាទិដ្ឋានុគតិនៃវិទ្យាគារកងកម្ពុជរដ្ឋឲ្យសមរំពៅតាមហាន:ជាប្រទេសឯករាជ្យ ដោយសារសេចក្តីឧបត្ថម្ភរបស់ព្រះតេជព្រះគុណព្រះពជប្រតិកូ នឹងព្រះតេជព្រះគុណវរសេនីយត្រីនាយកកងឯកទេសខ្មែរ ព្រមទាំងលោកជាឥស្សរជនកងវិទ្យាល័យមិនខាន ។

កងកាលជាអវសានៃសុន្ទរកថានេះ អាត្មាភាព សូមបួងសួងដល់

គុណត្រៃរតនៈតំណ ខ្ញុំដែលកើតជាតិ ១ ហ្នឹងលោកជាតុ សូមជួយបីបាច់
រក្សាត្រៃរតនគុណជាតិសម្បុរនេះតំណឡាយ ឲ្យបានប្រកបដោយ
សេចក្តីសុខ សេចក្តីចំរើន ខ្ញុំដែលបានបហេសិក្តីជាលំដាប់ខ្ញុំមានជន្មាយុ
យឺនយូរអង្វែង ដើម្បីខ្ញុំដួយបីបួយមាតុភូមិឲ្យអណ្តែតត្រសែតទៅតាន់
វឌ្ឍនៈ ខ្ញុំឯងកាលក្សោយសម្បុរណា ខ្ញុំដែលបំពេញកិត្តិយសចំពោះខ្ញុំជាតិ
មានច្បាសាខនតរត្តដាំដីខ្ញុំមិត្តភ្លុប ។ ម្យ៉ាងទៀតសូមជូនសព្ទសាធុការពរ
ដល់ពុទ្ធបរិសទ្យគាំងឡាយត្រចេះវាងញាតិគ្រួសារ ឲ្យបានសេចក្តីសុខ
សេចក្តីចំរើនក្នុងត្រៃពុទ្ធសាសនា ដរាបដល់ព្រះនិព្វានជាអវសាន-
ជាតិកុំបីឃ្លាត ។

បន្ទាប់ពីសុន្ទរកថានេះ លោកទេសកញ៉ាត្រៃរាជប្រតិភូថ្វៃងច្បាប់កថា
តិតថេរោចាដល់ព្រះសង្ឃឲ្យចំតំរៀនសូត្រធម៌វិន័យ ដោយលោកមាន
សេចក្តីរេរាញចិត្តជាទីបំផុត ។

តមកទៀត លោកវរសេនីយត្រីនាយកឯកទេសខ្មែរថ្វៃងការណ៍
ខួលតំណាងដែលបានបង្កើតសាលាធម្មវិន័យនេះ ហើយពន្យល់ព្រះ
សង្ឃឲ្យមករៀនធម្មវិន័យ ព្រមទាំងប្រដៅប្រដាជនឲ្យមានសាមគ្គីធម៌
ដើម្បីសួយមាតុភូមិឲ្យបានឯករាជ្យដោយតេញលេញជាដើម ។

— ត្រើយតីនោះ លោកគលបាលឯក ចក់-តេជ ប្រកាស
ឃោសនាដល់ពុទ្ធបរិសទ្យ ឲ្យដួយឧបត្ថម្ភដោយចតុប្បច្ច័យដល់ព្រះសង្ឃ

ដែលរៀនសូត្រ ។ ពេលនោះលោកវរសេនីយ៍ត្រី មានសទ្ធា ជួយ
បូលជួយទុបត្ថម្ភការសិក្សា ១.០០០ រៀល, ចំណែកពុទ្ធបរិស័ទ្ធ
ច្រើនក៏បានជារៀងរៀល ស្មើបប៉ាំពាន់ - ទៀងដែរដើម មានចំនួនច្រើន
ទុបត្ថម្ភការសិក្សា ។

- រួចកិច្ចយោសនាហើយ លោកគុណញ៉ាំព្រះពុទ្ធបតិមាប្រគេន
ប្រគាសសនីយ៍បត្រ ២ សន្លឹក ដល់ព្រះមហាកែ - អឿន ឧទ្ទេស
សុខ - សាន តាំងជាសាស្ត្រាចារ្យ ឲ្យបង្រៀនធម្មវិន័យ ។

- ខាងចុងបំផុត លោកគ្រូព្រះវិនយធរឯក - ញឹម ថ្លែងប្រាប់ពាក្យ
អំពីអានិសង្សនៃការរៀនសូត្រនឹងចំណេះវិជ្ជា យ៉ាងពីពេះក្បាះក្បាយ ។

លុះចប់ការណីយកិច្ចតាំងនេះហើយ ព្រះសង្ឃសូត្រជយន្តោគឹកកង
រំពងឡើង គួរឲ្យមានសេចក្តីជ្រះថ្លាក្រៃពេក ។ កិច្ចប៉ុណ្ណេះឈានចប់
ពិធីបុណ្យសម្ភោធ្យបើកសាលាធម្មវិន័យ ។ លុះចប់កិច្ចនេះហើយ លោក
ជាឥស្សរជនក៏ថ្វាយបង្គំលាព្រះសង្ឃ ទើបសំពះលាពុទ្ធបរិស័ទ្ធ្យះចញ្ជាមៅ
ដោយគារវកាព ។ ពេលនោះព្រះសង្ឃមានព្រះមេគណទើបអនុគណ
ជាដើមបានផ្ញើនដំណើរ ទៅបានត្រឹមក៏ប្រគំគ្រឿងអ៊ឺងអ៊ាងឡើងសា
កិត្តិយស ផ្ញើនដំណើរលោកជាឥស្សរជនអញ្ជើញទៅវិញ, ពេលនេះ
មានប្រជុំជនជាច្រើនលើក ឈរនៅតំបូលតះហើយ លោកជាឥស្សរជន
អញ្ជើញឡើងរថយន្ត ទៅកាន់នេះស្ថានដោយសុវត្ថិភាពរៀងៗខ្លួន ។

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៩២ ចុះថ្ងៃចន្ទ ១ កើតខែអាសាធ ឆ្នាំថោះឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ខៀវ-ជា នាមឆាយា ធម្មជោត កើតឆ្នាំច អាយុ ៤០ វស្សា ៧ ជាសៅអធិការវត្តពោធិវ័ន ឃុំស្មោ-ស្រុកគ្នំពេញ ខែត្រកណ្តាល ។

សញ្ញាប័ត្រលេខ ៦៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-សាយ នាមឆាយា ព្រហ្មសុវណ្ណ កើតឆ្នាំខាល អាយុ ៣៦ វស្សា-១៤ ជាសៅអធិការវត្តឈូកវ់ ឃុំ គោកគោ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែត-ហ័ម នាមឆាយា ព្រាហ្មបញ្ញា កើតឆ្នាំច អាយុ ៤០ វស្សា ៩ ជាសៅអធិការវត្តអង្គមេត្រី ឃុំព្រៃវែង ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទឹម-ទាំ នាមឆាយា ធម្មជោត កើតឆ្នាំវក អាយុ ៣០ វស្សា ១ ជាសៅអធិការវត្តបុប្ផសាញ់ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាន់-យ៉ាក នាមឆាយា ធម្មបាល កើតឆ្នាំកេង អាយុ ៥៨ វស្សា ៣០ ជាសៅអធិការវត្តលម្ពស់វ័ន ឃុំកាកាប ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រ ៧០២ ចុះថ្ងៃសុក្រ ៣ រោចខែស្រាពណ៍ ឆ្នាំខ្លូឯកស័ក ព.ស. ២៤៨២ គាំង៖លោកគ្រូ ណុប - ខុយ នាមនាយ ឧម្ចាន់ឃ កើតឆ្នាំខ្លូ អាយុ ៣៧ វស្សា ១៦ ជាចៅអធិការវត្តមុនីសាគរ ឃុំជាងដែក ស្រុកកំពង់ត្រែបែក ខែត្រកែវ ។

សញ្ញាប័ត្រលេខ ៧០៦ ចុះគាលបរិច្ឆេទដដែល គាំង៖លោកគ្រូ ទី - ពង់ នាមនាយាសុវណ្ណគ្នេរ កើតឆ្នាំខាល អាយុ ៣៦ វស្សា ១៥ ជាចៅអធិការវត្តពោធិមាស ឃុំអម្ពិលតាពក់ ស្រុកកោះសុទិន ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៧០៧ ចុះគាលបរិច្ឆេទដដែល គាំង៖លោកគ្រូ ឌុម - ស៊ូ នាមនាយា ឧទ្ធន្តេរ កើតឆ្នាំកុរ អាយុ ៣៩ វស្សា ៩ ជាគ្រូសូត្រស្តាំវត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧០៨ ចុះគាលបរិច្ឆេទដដែល គាំង៖លោកគ្រូ គុង - ប្ងង់ នាមនាយា ចន្ទកេសរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៦ ជាគ្រូសូត្រឆ្វេងវត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧១០ ចុះថ្ងៃសុក្រ ៣ កើតខែកត្តិកឆ្នាំខ្លូ ឯកស័ក ព.ស. ២៤៨២ គាំង៖លោកគ្រូ ខោល - ឃួន នាមនាយា ពុទ្ធន្តេរ កើតឆ្នាំច រកា អាយុ ៦៥ វស្សា ៤១ ជាចៅអធិការវត្តបំរោងប្ងូ ឃុំមង់ការ ស្រុកត្បូងឃ្មុំ ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ធាន - ប៉ាត់ នាមនាយា ធម្មប្ញាល កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣១ ជាគ្រូសូត្រស្តាំវត្ត - ឃុំ - ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេត - សុទ្ធ នាមនាយា សុវណ្ណត្ថេរ កើតឆ្នាំរកា អាយុ ២១ វស្សា ១ ជាចៅអធិការវត្តពោធិ៍ទន្ទឹម ឃុំត្រងិលស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៧១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លាវ - ខ្លែង នាមនាយា ពុទ្ធលិកិត្ត កើតឆ្នាំកេង អាយុ ៥៨ វស្សា ២០ ជាចៅអធិការវត្តព្រែកជ្រា ឃុំចារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៧១៤ ចុះថ្ងៃចន្ទ ៥ កេចខែកត្តិក ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៨២ តាំងលោកគ្រូ ប៊ុ - ដៀប នាមនាយា ចន្ទត្ថេរ កើតឆ្នាំកេង អាយុ ៤៦ វស្សា ២៤ ជាចៅអធិការវត្តសុវណ្ណភម ឃុំចែកមូស ស្រុកស្វាយរៀប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៧១៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អុង - ជាង នាមនាយា ខៃយត្ថេរ កើតឆ្នាំ... អាយុ ៣៣ វស្សា ៣១ ជាចៅអធិការវត្តព្រៃអង្គ ឃុំប្រសូត ស្រុក - ខេត្តដដែល ។

(មានត)

ECOLE FRANÇAISE

សៀវភៅលេខ ១០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ហានសង្ឃម	មានសង្ឃឹម	៧២១	១២
អគ្គាចិនភាព	អគ្គាធីនភាព	៧៣១	៧
មធុហេមភេគ	មធុមេហភេគ	៧៣២	២
	(ហានគ)	៧៦៧	១២

សៀវភៅលេខ ១១

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
នៅមជ្ឈិមប្រទេស	នៅបច្ចិមប្រទេស	៨១៦	២
នីតិវិនី	នីតិវិធី	៨២៩	១៩
សង្គមិក–	សង្គមិក–	៨២៦	១០
រើសថ្នើង	រើសអើង	៨២៨	២
ឋក្សាត្រួចច្រូតបាន	ឋក្សាត្រួចដ្រែកបាន	៨៩៣	២
Xeptre	Sceptre	៨៩៩	១២
កិត្តនាម	កិត្តិនាម	៨៩០	១៩